# សមន្តប្បាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ បាចិត្តិយាទិ

## ភិក្ខុនីវិភង្គ

## ភាគ ៣-៤-៥

# សមន្តប្បាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ បាចិត្តិយាទិ

## ភិក្ខុនីវិភង្គ

## ភាគ ៣-៤-៥

ឈ្មោះសៀវភៅ **សមន្តប្បាសាទិកា អដ្ឋកថាវិនយបិដក**

**ភាគ ៣_៤_៥**

ប្រែដោយ **ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**

ប្រែផ្ទៀងផ្ទាត់ដោយ **ភិក្ខុ_សាមណេរ វត្តនិគ្រោធវ័ន“គល់ទទឹង”**

ភិក្ខុ ភួង សុវណ្ណ
ភិក្ខុ គុច បូណា
ភិក្ខុ ឈឹម ហ៊ាន
ភិក្ខុ ឆៃ សុផល្លី
ភិក្ខុ តុន ប៊ុនសាយ
ភិក្ខុ សិន ផល្លា
សាមណេរ នៅ ហៃឡុន
សាមណេរ ចក់ សាវើន

កាលបរិច្ឆេទ ព.ស. ២៥៥៣

ស្ថានទីធ្វើ ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន “គល់ទទឹង” ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល

ISBN 9789996306037



ភិក្ខុ អគ្គធីរោ គង់_សុមិត្ត

# ជីវប្រវត្តិសង្ខេប

ភិក្ខុ គង់-សុមិត្ត អាយុ៣៥ឆ្នាំ គង់នៅវត្តនិគ្រោធវ័នគល់ទទឹង ។

ញោមប្រុសឈ្មោះ គង់-តិក( ស្លាប់ ) ញោមស្រីឈ្មោះ ហុក-តាង

កើតថ្ងៃព្រហស្បតិ៍៩កើត ខែមិគសិរ ឆ្នាំជោះ ព.ស.២៥១៩ ។ មានបងប្អូន ៧ នាក់ គឺប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ ។ ក្នុងកុមារបានចូលរៀនសាលារដ្ឋ ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡយលឿង វត្តស្លាកែត មកគង់នៅវត្តក្ដាំងផា ខេត្តបាត់ដំបង ។ ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទា ជាភិក្ខុភាវៈ ។

ព.ស. ២៥៤០ មកគង់នៅវត្តនិគ្រោធវ័ន រៀនធម៌វិន័យ ។ ព.ស. ២៥៤១ បេញទៅគង់នៅវត្តខេមវ័ន( ខេត្តកំពង់ចាម ) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌វិន័យ ។

ព.ស. ២៥៤៦ បួសជាសាមណេរវិញ ឧបជ្ឈាយ៍ព្រះនាម យឹ ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុក គៀនស្វាយ ខេត្តកណ្ដាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។

ព.ស. ២៥៤៧ បំពេញជាភិក្ខុភាវៈ បានជួយបង្រៀននិងខិតខំរៀបចំអដ្ឋកថា និងសៀវភៅធម៌វិន័យជាច្រើនទៀត រហូតមក ។

# ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ

ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតក្រុងវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍បានចូលទៅលើកពាក្យចោទប្រកាន់ ចំពោះព្រះដ៏មានព្រះភាគ មានពាក្យជាដើមថា "ព្រះគោតមមិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមក ក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ ឱ្យអង្គុយលើអាសនៈ(ក៏ព្រះអង្គមិនធ្វើ )" ព្រះដ៏មានព្រះភាគទ្រង់ញ៉ាំងព្រាហ្មណ៍នោះ ឱ្យជ្រះថ្លាហើយ និងប្រកាសខ្លួនជាឧបាសក ដល់ព្រះត្រ័យសរណគមន៍ស្មើដោយជីវិត រួចក៏អារាធនាឱ្យទ្រង់ចាំវស្សាជិតស្រុកវេរញ្ជានោះមួយអន្លើដោយភិក្ខុសង្ឃ ។

ក្នុងវស្សានោះ ស្រុកវេរញ្ជាកើតអំណត់អត់បាយ ព្រះដ៏មានព្រះភាគ និងព្រះភិក្ខុសង្ឃឆាន់បាយក្រៀមរបស់ពួកឈ្មួញសេះ ។ ព្រះមហាមោគ្គល្លានទូលសូមសម្តែងឫទ្ធិប្រែត្រឡប់ផែនដី ដើម្បី បានឱជារសដែលកើតឡើងអំពីស្រទាប់នៃផែនដី និងទូលសូមនាំភិក្ខុទៅបិណ្ឌបាត

ឯឧត្តរកុរុទ្វីប, តែព្រះដ៏មានព្រះភាគទ្រង់មិនអនុញ្ញាត ។ ចំណែកព្រះសារីបុត្រ ក៏ក្រាបទូលសួរអំពីសាសនារបស់ព្រះពុទ្ធទាំងឡាយ ដែលឋិតនៅមិនបានយូរ និងដែលឋិតនៅបានយូរ, ព្រះដ៏មានព្រះភាគក៏ទ្រង់សម្ដែងសាសនារបស់ព្រះពុទ្ធទាំង ៦ ព្រះអង្គមានព្រះពុទ្ធព្រះនាមវិបស្សីជាដើម ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ក្រោកចាកអាសនៈហើយ ធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា "សូមទ្រង់ព្រះមេត្តាប្រោស កាលនេះជាកាលគួរហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ៗ គួរបញ្ញត្តិសិក្ខាបទ គួរសម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ព្រោះកិច្ចដូច្នេះហើយ ជាហេតុនឹងឱ្យព្រហ្មចរិយធម៌ឋិតនៅអស់កាលអង្វែងទៅ" ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា "ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន តថាគតឯងសឹងដឹងកាលគួរក្នុងកិច្ចដែលនឹងបញ្ញត្តសិក្ខាបទជាដើមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ មិនទាន់ប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះសាស្ដាក៏មិនទាន់បញ្ញត្តសិក្ខាបទ មិនទាន់សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយត្រឹមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទី

តាំងនៃអាសវៈ មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលណា ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយក្នុងកាលនោះ ដើម្បីនឹងការពារពាក់ពាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងនោះប៉ុណ្ណោះ ម្នាលសារីបុត្ត សង្ឃនៅមិនទាន់មានភិក្ខុបួសចាស់វស្សាច្រើនគ្នាត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្តម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្តីចម្រើនមានភិក្ខុបួសចាស់វស្សាច្រើនគ្នា ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នឹងមានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារពាក់ពាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់បាននូវសេចក្តីចម្រើនមានគ្នាច្រើនត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះ ត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្តីចម្រើនមានគ្នាច្រើន ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារពាក់ពាំងនូវធម៌ទាំងឡាយ

ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់ដល់នូវសេចក្តីចម្រើនដោយលាភសក្ការៈដ៏ប្រសើរត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នៅមិនទាន់មានប្រាកដចំពោះសង្ឃត្រឹមនោះ ម្នាលសារីបុត្ត លុះសង្ឃបានដល់នូវសេចក្តីចម្រើនដោយលាភសក្ការៈដ៏ប្រសើរក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងកាលនោះដែរ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារពាំងនូវធម៌ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត ពីព្រោះ( ឥឡូវ )ភិក្ខុសង្ឃនៅមិនទាន់មានពុត( ហ៊ានលបលួចធ្វើអាក្រក់ )នៅឡើយ មិនទាន់មានទោសមោះមៃនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ ឥតទាន់មានពណ៌ខ្មៅសៅហ្មង សុទ្ធសឹងតែផូរផង់ផ្លង់ចិត្តឋិតនៅក្នុងធម៌មានខ្លឹមនៅឡើយ ម្នាលសារីបុត្ត ក៏បណ្តាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុដែលមានមគ្គផលយ៉ាងទាបចុងគេបំផុតនោះ ក៏គង់បានសម្រេចត្រឹមថ្នាក់សោតៈ ជាបុគ្គលទៀងទាត់ លែងធ្លាក់ទៅក្នុងអបាយភូមិហើយ នឹងបានត្រាស់ដឹងមគ្គផលត ៗទៅទៀតជាប្រាកដ” ។

ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ ចប់

# ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ

## ឃោសកុមារកើតឡើង និងការសិក្សាត្រៃវេទ

រាប់អំពីកាលនៃការបរិនិព្វានរបស់ព្រះមានព្រះភាគ កន្លងទៅហើយបាន ៩៥៦ ព្រះវស្សា ។ ព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមថា មហានាម បានគ្រងរាជ្យសម្បត្តិ ប្រកបដោយទសពិធរាជធម៌ក្នុងលង្កាទ្វីប ។ បានឮថា ក្នុងសម័យនោះឯង មានព្រាហ្មណ៍ មាណពម្នាក់ កើតនៅក្នុងត្រកូលព្រាហ្មណ៍មួយ បិតាឈ្មោះ **កេសី** ជារាជបុរោហិត មាតាឈ្មោះ **កេសិនី** មានលំនៅស្ថិតនៅក្នុងទីជិតនៃពោធិមណ្ឌល (កន្លែងត្រាស់ដឹងរបស់ព្រះសម្ពុទ្ធ) ក្នុងមជ្ឈិមប្រទេសជម្ពូទ្វីប ។

ក៏ព្រោះក្នុងវេលាដែលមាណពនោះប្រសូតមក ពួកបរិវាររបស់ព្រាហ្មណ៍មានទាសនិងកម្មករជាដើម បញ្ចេញសំឡេង សម្ដែងភាពត្រេកអររីករាយយ៉ាងគឹកកង ដូច្នោះ ទើបគេដាក់ឈ្មោះឱ្យកុមារនោះថា **ឃោសៈ** ។ ទីខ្លះក៏ពោលថា មាណពនោះ កើតនៅក្នុងឃោសគ្រាម ទើបដាក់ឈ្មោះឱ្យថា ឃោសៈ ។ ឃោសៈមាណពនោះ ជាអ្នកដឹងវិជ្ជានិងក្បួនសិល្បៈទាំងពួងយ៉ាងជំនាញ ចេះចប់ត្រៃវេទយ៉ាងប្រាកដក្នុងលទ្ធិ បានត្រាច់ទៅដើម្បីសាកសួរ និងដោះស្រាយបញ្ហាវិជ្ជាសិល្បៈ ក្នុងស្រុកនិគមជនបទ រាជធានីទាំងឡាយ ក្នុងជម្ពូទ្វីប ។

ដឹងថា មានសមណព្រាហ្មណ៍ ដែលជាបណ្ឌិតនៅក្នុងទីណា ៗ ក៏ចូលទៅធ្វើការសាកប្ញាក្នុងទីនោះ ៗ បណ្ឌិតដទៃ (នោះ) ៗ មិនអាចឆ្លើយនូវបញ្ហាដែលមាណពនោះ សួរបានឡើយ តែមាណពនោះ អាចឆ្លើយនូវបញ្ហារបស់បណ្ឌិតទាំងនោះ ៗ ដែលសួរហើយបាន ។

## ឃោសមាណពជួបនឹងព្រះរេវតត្ថេរ

មាណពនោះ ត្រាច់ទៅសព្វពេញ ទូទាំងជម្ពូទ្វីបដោយអាការយ៉ាងនេះ រហូតមកដល់វត្តមួយ (ក៏បានស្នាក់នៅក្នុងបរិវេណវត្តនោះ) ។ ក៏ក្នុងវត្តនោះ មានភិក្ខុនៅច្រើនរូប ព្រះរេវតៈ(ឬធម្មឃោសៈ) ជាសង្ឃត្ថេររបស់ភិក្ខុទាំងនោះ ជាព្រះមហាខីណាស្រពបានសម្រេចបដិសម្ភិទា អាចញ៉ាំញីបរប្បវាទបាន ។ គ្រានោះ កាលវេលាអាធ្រាត្រ ព្រាហ្មណ៍មាណព បានបរិវត្តបាតញ្ជលី (ស្វាធ្យាយ) នូវមន្តឱ្យមានបទបរិបូណ៌ និងឱ្យជាបរិមណ្ឌល ព្រះថេរៈស្តាប់នូវសំឡេងព្រាហ្មណ៍ស្វាធ្យាយមន្ត ក៏ជ្រាបថា "ព្រាហ្មណ៍នេះជាអ្នកមានបញ្ញាច្រើន" (រួចទើប) គិតថា "បើយើងទូន្មានឱ្យមករាប់អានព្រះពុទ្ធសាសនាបាន នឹងជាការល្អ" ទើបហៅព្រាហ្មណ៍នោះមក រួចសួរថា "ម្នាលព្រាហ្មណ៍ អ្នកណាហ្នឹងស្រែកជាសំឡេងដូចលា" ។ ឃោសៈព្រាហ្មណ៍នោះសួរថា "នែបព្វជិតដ៏ចម្រើន លោកដឹងនូវសំឡេងរបស់ពួកលាឬ ?" ព្រះថេរៈតបថា "យើង

ដឹង" ។ ព្រាហ្មណ៍នោះ ទើបសួរព្រះថេរៈក្នុងគណ្ឋិដ្ឋាន (គឺមន្តដែលយល់បាន លំបាក) ទាំងឡាយក្នុងគម្ពីរត្រៃវេទ ទាំងគម្ពីរឥតិហាសជាគម្ពីរ ទី៥ ដែលខ្លួន ឯងសម្លឹងមិនឃើញន័យឡើយ ទាំងអាចារ្យរបស់ខ្លួន ក៏មិនឃើញមកហើយផង ដែលព្រះថេរៈនោះ ដោយប្រក្រតីក៏ជាអ្នកចេះចប់ត្រៃវេទហើយ មកដល់ឥឡូវ នេះ ជាអ្នកបានសម្រេចនូវបដិសម្ភិទាទៀត ព្រោះហេតុនោះ សេចក្តីលំបាកក្នុង ការឆ្លើយនូវបញ្ហាទាំងនោះ ទើបមិនមានដល់លោក ព្រោះដូច្នោះ ទើបព្រះថេរៈ ឆ្លើយនូវបញ្ហាទាំងនោះបានភ្លាម ។ ហើយពោលនឹងព្រាហ្មណ៍នោះថា "នែ ព្រាហ្មណ៍ដ៏ចំរើន អ្នកសាកសួរយើងមកច្រើនហើយ ឥឡូវនេះ យើងនឹង សាកសួរនូវបញ្ហាកម្ទេចអ្នកមួយ អ្នកនឹងឆ្លើយបញ្ហារបស់យើងបានឬទេ ?" ព្រាហ្មណ៍តបថា "ខ្ញុំនឹងឆ្លើយមន្តនោះប្រគេនបាន លោកម្ចាស់ចូរសួរមកចុះ" ទើបព្រះថេរៈសួរនូវបញ្ហាក្នុងគម្ពីរអភិធម្ម ចិត្តយមកៈ[១]នេះថា "**យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ យស្ស វា បន ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ តស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ,** : ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើត

១. អភិ. យម. យមកវគ្គ. ៩១. ១/១ ។

ឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់"[១] ។

ព្រាហ្មណមាណពនោះ មិនអាចនឹងឆ្លើយបាន មិនថា លើ ឬក្រោម ទើបសួរថា "បពិត្រលោកម្ចាស់ដ៏ចំរើន មន្តនេះឈ្មោះមន្តអ្វី ?" ព្រះថេរៈតប ថា "ម្នាលព្រាហ្មណ៍ មន្តនេះ ឈ្មោះថា ពុទ្ធមន្ត" ។ ព្រាហ្មណ៍សួរថា "លោកម្ចាស់ដ៏ចម្រើន ឱ្យមន្តនេះដល់ខ្ញុំព្រះករុណាបានដែរឬទេ ?" ព្រះថេរៈ តបថា "ម្នាលព្រាហ្មណ៍ យើងឱ្យ (មន្តនេះ) ដល់អ្នកបាន លុះត្រាតែ អ្នកបួសជាបព្វជិតដូចយើង" ។

## មាណពបួស ប្រាកដឈ្មោះ ព្រះពុទ្ធឃោសៈ

ឃោសៈព្រាហ្មណ៍ដែលបុព្វហេតុ (គឺកុសលក្នុងកាលមុន) ទាំងឡាយ ដាស់តឿនហើយ ទើបសូមបព្វជ្ជា ដើម្បីត្រូវការមន្ត ព្រះថេរៈទើឱ្យព្រាហ្មណ៍ បព្វជ្ជាឧបសម្បទាហើយ ឱ្យរៀនព្រះត្រៃបិដកពុទ្ធវចនៈ ភិក្ខុនោះ ក៏យល់ដឹង អត្ថធម៌របស់ព្រះត្រៃបិដកថា "នេះជាឯកាយមគ្គ (ដំណើរផ្លូវដ៏ឯក ប្រសើរ ជាផលទិចាស់របស់ខ្លួន)" (តមក) ក៏បានជាអ្នកប្រាកដច្បាស់ក្នុងលោក ដូច

---

១. ពាក្យថា **រមែងកើតឡើង** គឺនៅក្នុងឧប្បាទខណៈ, ពាក្យថា **រមែងមិនរលត់** គឺមិនទាន់ដល់ និរោធឬភង្គខណៈ ។ ចិត្តក្នុងទីនេះ សំដៅដល់បច្ឆិមចិត្ត គឺចុតិចិត្ត របស់ព្រះអរហន្ត ខណៈចិត្ត របស់ព្រះអរហន្តកំពុងប្រព្រឹត្តទៅ ឈ្មោះថា រមែងកើតឡើង រមែងមិនរលត់ កាលដល់ភង្គ ខណៈហើយ ចុតិចិត្តនោះ ក៏នឹងរលត់ និងមិនមានចិត្តដទៃកើតឡើងតទៅទៀត ។

ពន្លឺភ្លើង ដូចពន្លឺព្រះចន្ទ ដូចពន្លឺព្រះអាទិត្យ ដោយការដែលលោកបានព្យាករណ៍ ពោលឆ្លើយបញ្ហាព្រះធម៌ដ៏ជ្រាលជ្រៅដល់ជនទាំងឡាយ ដូចជាពុទ្ធព្យាករណ៍, ភិក្ខុឃោសៈ ទើបបានប្រាកដនាមថា "ព្រះពុទ្ធឃោសៈ" ព្រោះល្បីផ្សាយទៅក្នុងផ្ទៃផែនដីដូចព្រះពុទ្ធអង្គ ។

## ព្រះថេរៈបញ្ជូនឱ្យទៅប្រែគម្ពីរអដ្ឋកថា

ព្រះពុទ្ធឃោសៈនោះ ជាអ្នកនៅក្នុងវិហារនោះ បានតែងបករណ៍ឈ្មោះញាណោទ័យទុកក្នុងវិហារហើយ ផ្ដើមតែងអដ្ឋកថា ព្រះអភិធម្មសង្គណី និងអដ្ឋកថាច្បាប់ឈ្មោះអដ្ឋសាលិនី ព្រះថេរៈឃើញដូច្នោះទើបប្រាប់ថា "ម្នាលអាវុសោពុទ្ធឃោសៈ ក្នុងជម្ពូទ្វីបនេះ មានតែគម្ពីរព្រះត្រៃបិដកបាលីប៉ុណ្ណោះ អដ្ឋកថារបស់ព្រះត្រៃបិដកនោះ និងថេរវាទ (គឺពាក្យដែលព្រះថេរៈក្នុងសម័យសង្គីតិ ពោលទុកជាច្បាប់) មិនមាន តែអដ្ឋកថាព្រះត្រៃបិដកដែលឡើងកាន់សង្គីតិទាំង៣លើក ជាពាក្យដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងទុក និងព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើមចងក្រងទុកហើយ ឯព្រះមហិន្ទត្ថេរត្រួតមើលកថាមគ្គ (សម្ដែងផ្លូវនៃពាក្យដែលពោលទុក)ហើយ (រួបរួមមក) តែងទុកដោយភាសាសីហឡៈ កំពុងប្រព្រឹត្តទៅនៅក្នុងសីហឡទ្វីប ចូរលោកទៅកាន់សីហឡទ្វីបនោះ ត្រួតមើលឱ្យសព្វអន្លើហើយ បកប្រែមកជាភាសាមគធ

បាន អដ្ឋកថានោះ នឹងនាំមកនូវប្រយោជន៍សុខដល់មនុស្សលោកទាំងពួង” ។

កាលព្រះថេរណែនាំយ៉ាងនោះ ព្រះពុទ្ធឃោសៈ ជាអ្នកមានបញ្ញាច្រើន ក៏កើតបីតិសោមនស្ស ក្រាបទូលលាព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃ បានធ្វើដំណើរទៅកាន់កំពង់ទឹកដោយលំដាប់ឡើង ទូកទៅជួបព្រះពុទ្ធទត្តត្ថេរតាមផ្លូវដែលមកដល់កណ្តាលសមុទ្រ ក៏បាននិយាយប្រាស្រ័យគ្នា ហើយធ្វើដំណើរបន្តទៅដរាបដល់កំពុង ក្រុងលង្កា ក្នុងកាលនោះ ព្រះបាទមហានាម គ្រប់គ្រងរាជ្យក្នុងលង្កាទ្វីប ។

# តែងបករណ៍ ឈ្មោះវិសុទ្ធិមគ្គ

ព្រះពុទ្ធឃោសៈ និមន្តទៅជួបព្រះសង្ឃក្នុងវិហារ ក្រុងអនុរាធបុរី ហើយទើបទៅកាន់សំណាក់ព្រះសង្ឃបាលត្ថេរ ដែលគង់នៅក្នុងមហាបធានឃរៈ បានស្តាប់( ជ្រាបសេចក្តី ) អដ្ឋកថាភាសាសីហឡៈ និងថេរវាទទាំងពួងហើយ ជឿទុកចិត្តថា “នេះឯងជាព្រះពុទ្ធាធិប្បាយរបស់ព្រះធម្មសាមិត្រពិត” ទើបទៅកាន់ទីប្រជុំសង្ឃ ក្នុងវិហារនោះ ដើម្បីសូមគម្ពីរធ្វើអដ្ឋកថាព្រះត្រៃបិដក ក៏បានពោលសូមថា “សូមលោកម្ចាស់ទាំងឡាយ មេត្តាឱ្យសៀវភៅគម្ពីរទាំងឡាយដល់ខ្ញុំព្រះករុណាដើម្បីធ្វើអដ្ឋកថា” ។ ដើម្បីសាកល្បង សមត្ថភាពរបស់

លោក ទើបភិក្ខុសង្ឃឱ្យគាថា ២ បទ ហើយពោលថា "លោកចូរសម្ដែងសមត្ថភាពក្នុងគាថា ២ បទនេះ យើងទាំងឡាយ បានឃើញសមត្ថភាពរបស់លោកហើយ នឹងប្រគល់ ច្បាប់គម្ពីរឱ្យទាំងអស់" ព្រះពុទ្ធឃោសមើលបាលីព្រះត្រៃបិដក និងអដ្ឋកថារបស់ព្រះត្រៃបិដកនោះហើយ ទើបព្រះថេរៈរួបរួមព្រះត្រៃបិដកព្រមទាំងអដ្ឋកថាដោយសង្ខេប តែងបករណ៍ ឈ្មោះ វិសុទ្ធិមគ្គឡើង ក្នុងមហាវិហារនេះឯង ។

គ្រានោះ ទេវតា[១]មានបំណង ដើម្បីនឹងប្រកាសថ្វីដៃរបស់លោកឱ្យប្រាកដ ក្នុងមហាជន ទើបបណ្ដាលឱ្យសៀវភៅគម្ពីរច្បាប់ (ដែលលោកសរសេររួចហើយ) ឱ្យអន្តរធានបាត់ទៅ ទើបលោកសរសេរឡើងថ្មីមួយច្បាប់ទៀត ទេវតាក៏បណ្ដាលឱ្យអន្តរធានបាត់ទៅទៀត ទើបលោកសរសេរឡើងថ្មីលើកទី ៣ ទៀត ក៏បាន ចប់សព្វគ្រប់ទៀត ក្នុងគ្រានោះ ព្រះពុទ្ធឃោសៈនិមន្តព្រះសង្ឃ ដែលជាអ្នកឆ្លាសក្នុងធម៌របស់ព្រះសម្ពុទ្ធឱ្យមកប្រជុំគ្នា ក្នុងទីជិតមហាពោធិព្រឹក្ស (ប្រទេសលង្កា) ប្រារព្ធនឹងអានបករណ៍វិសុទ្ធិមគ្គនោះ (ឱ្យសង្ឃស្ដាប់) ស្រាប់តែទេវតាដែលបំបាំងសៀវភៅនោះ នាំសៀវភៅទាំងពីរចប់នោះ មកប្រគេនសងវិញព្រមក្នុងខណៈនោះ ទើបបានជាសៀវភៅវិសុទ្ធិមគ្គ

---

១. ខ្លះថា ព្រះសង្ឃ ។

បីចប់ឡើង ក៏បានប្រគល់សៀវភៅទាំងបីចប់ ទៅព្រះភិក្ខុសង្ឃ, ភិក្ខុសង្ឃឱ្យអានសៀវភៅទាំងបីចប់ ព្រមគ្នា ការខុសគ្នាំងភ្លាត់បីចប់នោះ ដោយគណ្ឋៈក្តី ដោយអក្ខរៈក្តី ដោយបទក្តី ដោយព្យញ្ជនៈក្តី ដោយអត្ថក្តី ដោយការសរសេរមុន ក្រោយក្តី ដោយវាទៈទាំងឡាយមានថេរវាទជាដើមក្តី ដោយព្រះបាលីទាំងឡាយក្តី មិនមានឡើយ បានឮថា កាលគម្ពីរវិសុទ្ធិមគ្គ ទាំង ៣ ដែលព្រះពុទ្ធឃោសៈធ្វើរួចស្រេចហើយយ៉ាងនោះ ទេវតាទាំងឡាយ បាននាំគ្នាធ្វើសាធុការ សម័យនោះភិក្ខុច្រើនពាន់ប្រជុំ គ្នានៅក្នុងវិហារ ឃើញការអស្ចារ្យនោះហើយ ក៏នាំគ្នាសរសើរឱ្យសាធុការ ប្រកាសប្រាប់គ្នាសុសសាយទៅថា "នេះព្រះពោធិសត្វ មេត្រីមកកើត ដោយឥតសង្ស័យ"[១] ។

## បកប្រែអដ្ឋកថាព្រះត្រៃបិដក មកជាភាសាមគធៈ

ចំណែកស្តេចផែនដី ទ្រង់បានស្តាប់ដំណឹងនោះ ក៏ស្តេចចេញពីព្រះនគរព្រមទាំងរាជបរិវារទៅកាន់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយ ទ្រង់នមស្ការព្រះពុទ្ធឃោសៈ និមន្តឱ្យទទួលនូវចង្ហាន់នៅក្នុងរាជវាំងជាប្រចាំ រហូតដល់ការតែងគម្ពីរចប់ ព្រះថេរៈ ទទួលនិមន្តដោយតុណ្ហីភាព ។

ព្រះភិក្ខុសង្ឃឃើញសមត្ថភាពរបស់ព្រះថេរៈហើយ ទើបប្រគល់សៀវភៅ

---

១. នេះជាការឃើញអស្ចារ្យរបស់ភិក្ខុទាំងឡាយទេ មិនប្រាកដជាព្រះមេត្រីឡើយ ។

ព្រះត្រៃបិដកបាលី ព្រមទាំងសៀវភៅអដ្ឋកថាសីហឡៈឱ្យដល់ព្រះថេរៈ, ព្រះថេរៈទទួលសៀវភៅគម្ពីរទាំងអស់ទៅទុកក្នុងប្រាសាទ ឈ្មោះថា បធានឃរៈ ដែលតាំងនៅខាងត្បូងនៃមហាវិហារ ប្រែអដ្ឋកថាទាំងអស់ធ្វើជាអដ្ឋកថាព្រះត្រៃបិដកក្នុងភាសាមគធ ដែលជាមូលភាសា ( គឺភាសាដើម ) ។

ក៏អដ្ឋកថាសីហឡៈនោះ មាន ៣ ភាគ គឺ មហាអដ្ឋកថា ១ បច្ចរិយអដ្ឋកថា ១ កុរុន្ទីអដ្ឋកថា ១ ។

អដ្ឋកថាដែលឡើងកាន់មហាសង្គីតិ ព្រះមហិន្ទត្ថេរនាំមកតែងទុកក្នុងភាសាសីហឡៈ ឈ្មោះថា **មហាអដ្ឋកថា** ។

មានផ្ទះផែមួយខ្នង មានឈ្មោះហៅក្នុងភាសាសីហឡៈថា បច្ចរិយៈ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងផ្ទះផែនោះ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

មានវិហារមួយកន្លែង ឈ្មោះកុរុន្ទីវិហារ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងវិហារនោះ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទដែលព្រះថេរៈជំនាន់មុនមានព្រះថេរិកាចារ្យ ( អាចារ្យធំ ) ជាដើមកាន់យកន័យព្រះបាលីតែងទុក ឈ្មោះថា **ថេរវាទ** ។

ព្រះពុទ្ធឃោសៈ ប្រែកុរុន្ទីអដ្ឋកថាភាសាសីហឡៈ ធ្វើអដ្ឋកថាព្រះវិន័យបិដក ឈ្មោះសមន្តបាសាទិកា ក្នុងភាសាមគធៈហើយ តពីនោះក្នុងសុត្តន្តបិដក បកប្រែមហាអដ្ឋកថាអំពីភាសាសីហឡៈ តាំងជាអដ្ឋកថាទីឃនិកាយ

ឈ្មោះសុមង្គលវិលាសិនី, ជាអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី, ជាអដ្ឋកថាសំយុត្តនិកាយ ឈ្មោះ សារត្ថបកាសិនី, និងជាអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី, តពីនោះ ក្នុងអភិធម្មបិដក បកប្រែបច្ចុរិយអដ្ឋកថាអំពីភាសាសីហឡ: តាំងជាអដ្ឋកថាបករណ៍ធម្មសង្គណី ឈ្មោះអដ្ឋសាលិនីក្នុងភាសាមគធ: ជាអដ្ឋកថាបករណ៍វិភង្គ ឈ្មោះសម្មោហវិនោទនី និងជាអដ្ឋកថា ៥ បករណ៍ ឈ្មោះបរមត្ថទីបនី ។

ព្រះពុទ្ធឃោស: ធ្វើអដ្ឋកថាសីហឡ:ទាំងអស់ឱ្យជាអដ្ឋកថា ព្រះត្រៃបិដក ក្នុងភាសាមគធ: ដែលជាមូលភាសាដូចពោលមកហើយដូច្នោះ អដ្ឋកថានោះឯង បាននាំមកនូវប្រយោជន៍សុខដល់ពពួកជន ក្នុងប្រទេសដទៃ ៗទាំងពួងយ៉ាងច្រើនសន្ធឹកសន្ធាប់ហើយ រស់នៅរហូតដល់អស់អាយុ ទើបទៅកាន់ទេវលោកនោះឯង ។

កាលដែលបានបកប្រែអដ្ឋកថាព្រះត្រៃបិដក ចប់សព្វគ្រប់ហើយ ផែនដីក៏កក្រើកញ័រ (ជាអស្ចារ្យ) អដ្ឋកថាព្រះត្រៃបិដក ដែលព្រះថេរ: ធ្វើដូចពោលមកនេះ គឺបកប្រែចប់សព្វ គ្រប់ តែក្នុងរយ:កាល ១ ឆ្នាំប៉ុណ្ណោះ ។

លុះបកប្រែរួចហើយ ព្រះពុទ្ធឃោស: ប្រាថ្នាដើម្បីនឹងបាន មកថ្វាយបង្គំព្រះមហាពោធិព្រឹក្ស ទើបក្រាបថ្វាយបង្គំព្រះភិក្ខុសង្ឃ ត្រឡប់មកជម្ពូទ្វីបវិញ ។

ព្រះរាជាមហានាម ទ្រង់គ្រងផែនដីអស់ ១២ ឆ្នាំ ទ្រង់ធ្វើបុណ្យច្រើនយ៉ាង ដោយប្រការផ្សេង ៗហើយ ស្ដេចក៏ទៅកាន់បរលោកតាមយថាកម្ម ។ ចំណែកព្រះពុទ្ធឃោសត្ថេរនោះ បានរចនាអដ្ឋកថានៃព្រះត្រៃបិដកទុក បានសាងប្រយោជន៍ដ៏សមគួរដល់សត្វលោកជាច្រើន តាំងនៅរហូតគ្រប់អាយុខ័យ ក៏បានទៅកាន់ឋានតាវត្តិង្សហើយ ដូច្នេះឯង ។

## សេចក្ដីប្រាថ្នារបស់ព្រះពុទ្ធឃោសត្ថេរ

យំ សិទ្ធំ ឥមិនា បុញ្ញ    យំ ចញ្ញំ បសុតំ មយា
ឯតេន បុញ្ញកម្មេន    ទុតិយេ អត្តសម្ភវេ
តាវតឹសេ បមោទេន្តោ    សីលាចារគុណេ រតោ
អលគ្គោ បញ្ចកាមេសុ    បត្វា បឋមំ ផលំ
អន្តិមេ អត្តភាវម្ហិ    មេត្តេយ្យំ មុនិបុង្គវំ
លោកគ្គបុគ្គលំ នាថំ    សព្វសត្តហិតេ រតំ
ទិស្វាន តស្ស ធីរស្ស    សុត្វា សទ្ធម្មទេសនំ
អធិគន្ត្វា ផលំ អគ្គំ    សោភេយ្យំ ជិនសាសនន្តិ ។

បុណ្យណា ដែលសម្រេចហើយដោយការធ្វើនេះ និងបុណ្យដទៃណា ដែលខ្ញុំបានខ្វល់ខ្វាយទុក ដោយអំណាចនៃបុណ្យនោះ ក្នុងអត្តភាពទី២ សូមឱ្យខ្ញុំរីករាយក្នុងឋានតាវត្តិង្ស ត្រេកអរក្នុងគុណគឺសីលនិងអាចារៈ មិនជាប់ជំពាក់ក្នុងកាមគុណទាំង ៥ បានសម្រេចអរិយផលទី ១ (សោតាបត្តិផល) ក្នុងអត្តភាពចុងបំផុត សូមឱ្យខ្ញុំបានជួបព្រះអារ្យមេត្រី ព្រះមុនីដ៏ប្រសើរ ជាបុគ្គលចម្បងក្នុងលោក ជាព្រះលោកនាថ ទ្រង់ពេញព្រះទ័យក្នុងការជួយសត្វលោកទាំងពួង សូមឱ្យខ្ញុំបានស្តាប់ព្រះសទ្ធម្មរបស់ព្រះមុនីអង្គនោះ ដែលទ្រង់ជាអ្នកប្រាជ្ញា ហើយបានសម្រេចអរិយផលជាន់ខ្ពស់ (អរហត្តផល) ញុំាំងព្រះសាសនារបស់ព្រះជិនស្រីឱ្យល្អស្អាត ដោយប្រការដូច្នេះហោង ។

ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ ចប់

# ឧប្បត្តិកថា

សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យ ជាស្នាដៃរបស់ព្រះពុទ្ធឃោសាចារ្យ

ប្រទេសខ្មែរយើងនេះ មានគម្ពីរព្រះត្រៃបិដកចប់សព្វគ្រប់ ដែលក្រុមជំនុំ បានរៀបចំឡើងជាភាសាបាលីផង ភាសាខ្មែរផង ខ្ញុំមានចិត្តសោមនស្សរីករាយ ហើយក៏រៀបចំប្រែអដ្ឋកថាព្រះវិន័យនេះ ឱ្យមកជាភាសាខ្មែរផង ដើម្បីបានការយល់ដឹងក្នុងផ្នែកព្រះវិន័យរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទខ្មែរយើង ដែលកំពុង តែប្រឹងប្រែងសិក្សាព្រះវិន័យ ។

ខ្ញុំបានសសេរពាក្យបញ្ចូលថែម, គឺ ពាក្យខ្លះយកអំពីបិដក តាមដែល អដ្ឋកថាចង្អុលប្រាប់ផង មិនប្រាប់ផង ដោយមានលេខយោងបញ្ជាក់, ពាក្យខ្លះ មិនមានក្នុងបាលីអដ្ឋកថាទេ ថែមដោយបំណងដើម្បីបញ្ជាក់សេចក្ដីប៉ុណ្ណោះ, ម្យ៉ាងទៀត បានដាក់លេខឃ្នាបតាមបិដក ដើម្បីងាយដឹងថា នេះជាសេចក្ដីពន្យល់ ក្នុងបិដកត្រង់លេខឃ្នាបនេះ ។ តែដោយសមត្ថភាពរបស់ខ្ញុំព្រមទាំងក្រុមប្រឹក្សា តិចតួច សៀវភៅនេះក៏នៅមានសេចក្ដី និងអក្ខរៈ ខុសភ្លាំងភ្លាត់នៅឡើយ ដោយអចេតនា សូមមេត្តាជួយសម្រួលដោយអនុគ្រោះផងចុះ ។

បុណ្យដែលកើតអំពីការព្យាយាមសាងសៀវភៅនេះ សូមចែកដល់អ្នកសិក្សាទាំងឡាយផង ។ សូមអ្នកសិក្សាទាំងឡាយ ទទួលអនុមោទនាត្រេកអរនូវបុណ្យនេះ ដោយមហាកុសលសោមនស្សរីករាយ ដែលប្រកបដោយបញ្ញា ឱ្យបានគ្រប់ ៗគ្នា សូមអនុមោទនា !!! ។

សូមឱ្យកុលបុត្រខ្មែរ ខិតខំសិក្សាព្រះធម៌វិន័យ ឱ្យកើតបញ្ញាយល់ដឹង ហើយទ្រទ្រង់សិក្ខាឱ្យបានមាំមួន ឱ្យបានតាំងនៅក្នុងភាពជាអ្នកខ្មាសបាប សង្រួម ប្រយ័ត្នដើម្បីកម្ចាត់បង់នូវបាបចេញ លាងជម្រះមន្ទិលសៅហ្មងក្នុងចិត្ត បំពាក់ អលង្ការ គឺព្រះសទ្ធម្ម ធ្វើខ្លួនឱ្យមានគុណតម្លៃ ឱ្យប្រសើរ ឱ្យផុតពីទុក្ខកង្វល់ នាំខ្លួនឱ្យដល់ឋានសុខសាន្ត ។

ខ្ញុំសូមប្រាថ្នាឱ្យមានបញ្ញាទ្រទ្រង់ព្រះធម៌ព្រះវិន័យ សូមឱ្យបានផុតពីក្តី អន្តរាយទាំងពួង និងបានសម្រេចតាមគោលបំណងដ៏ល្អ ជាពិសេស ឱ្យបានដល់ ទីបំផុតទុក្ខ គឺ ព្រះនិព្វាន ដោយឆាប់រហ័សហោង ។

# អក្សរសង្ខេប និងអក្សរពេញ

## បិដក

| អក្សរសង្ខេប | អក្សរពេញនៃបិដក | | | ភាគ |
|---|---|---|---|---|
| វិន. បារា. | វិន័យបិដក | ខុទ្ទកនិកាយ | បារាជិក | ភាគ ១ |
| វិន. សង្ឃា. | វិន័យបិដក | ខុទ្ទកនិកាយ | សង្ឃាទិសេស | ភាគ ២ |
| វិន. និស្ស. | វិន័យបិដក | ខុទ្ទកនិកាយ | និស្សគ្គិយ | ភាគ ៣ |
| វិន. បាចិ. | វិន័យបិដក | ខុទ្ទកនិកាយ | បាចិត្តិយ | ភាគ ៤ |
| វិន. ភិក្ខុនី. | វិន័យបិដក | ខុទ្ទកនិកាយ | ភិក្ខុនីវិភង្គ | ភាគ ៥ |
| វិន. មហា. | វិន័យបិដក | ខុទ្ទកនិកាយ | មហាវគ្គ | ភាគ ៦-៨ |
| វិន. ចុល្ល. | វិន័យបិដក | ខុទ្ទកនិកាយ | ចុល្លវគ្គ | ភាគ ៩-១១ |
| វិន. បរិ. | វិន័យបិដក | ខុទ្ទកនិកាយ | បរិវារៈ | ភាគ ១២-១៣ |
| ទីឃ. សីល. | សុត្តន្តបិដក | ទីឃនិកាយ | សីលក្ខន្ធវគ្គ | ភាគ ១៤-១៥ |
| ទីឃ. មហា. | សុត្តន្តបិដក | ទីឃនិកាយ | មហាវគ្គ | ភាគ ១៦-១៧ |
| ទីឃ. បាដិ. | សុត្តន្តបិដក | ទីឃនិកាយ | បាដិកវគ្គ | ភាគ ១៨-១៩ |
| មជ្ឈិ. មូល. | សុត្តន្តបិដក | មជ្ឈិមនិកាយ | មូលបណ្ណាសក | ភាគ ២០-២២ |
| មជ្ឈិ. មជ្ឈិ. | សុត្តន្តបិដក | មជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក | ភាគ ២៣-២៥ |
| មជ្ឈិ. ឧប. | សុត្តន្តបិដក | មជ្ឈិមនិកាយ | ឧបរិបណ្ណាសក | ភាគ ២៦-២៨ |
| សំយុ. សគា. | សុត្តន្តបិដក | សំយុត្តនិកាយ | សគាថវគ្គ | ភាគ ២៩-៣០ |
| សំយុ. និទា. | សុត្តន្តបិដក | សំយុត្តនិកាយ | និទានវគ្គ | ភាគ ៣១-៣២ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| សំយុ. ខន្ធ. | សុត្តន្តបិដក | សំយុត្តនិកាយ | ខន្ធវារវគ្គ | ភាគ ៣៣-៣៤ |
| សំយុ. សឡា. | សុត្តន្តបិដក | សំយុត្តនិកាយ | សឡាយតនវគ្គ | ភាគ ៣៥-៣៦ |
| សំយុ. មហា. | សុត្តន្តបិដក | សំយុត្តនិកាយ | មហាវារវគ្គ | ភាគ ៣៧-៣៩ |
| អង្គុ. ឯក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកនិបាត | ភាគ ៤០ |
| អង្គុ. ទុក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទុកនិបាត | ភាគ ៤០ |
| អង្គុ. តិក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | តិកនិបាត | ភាគ ៤១ |
| អង្គុ. ចតុ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ចតុក្កនិបាត | ភាគ ៤២-៤៣ |
| អង្គុ. បញ្ច. | សុត្តន្តបិដក | អង្គុត្តរនិកាយ | បញ្ចកនិបាត | ភាគ ៤៤-៤៥ |
| អង្គុ. ឆក្ក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឆក្កនិបាត | ភាគ ៤៦ |
| អង្គុ. សត្ត. | សុត្តន្តបិដក | អង្គុត្តរនិកាយ | សត្តកនិបាត | ភាគ ៤៧ |
| អង្គុ. អដ្ឋ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | អដ្ឋកនិបាត | ភាគ ៤៨ |
| អង្គុ. នវ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | នវកនិបាត | ភាគ ៤៩ |
| អង្គុ. ទស. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទសកនិបាត | ភាគ ៥០-៥១ |
| អង្គុ. ឯកា. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកាទសកនិបាត | ភាគ ៥១ |
| ខុទ្ទ. បាឋ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ខុទ្ទកបាឋ | ភាគ ៥២ |
| ខុទ្ទ. ធម្ម. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ធម្មបទ | ភាគ ៥២ |
| ខុទ្ទ. ឧទា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឧទាន | ភាគ ៥២ |
| ខុទ្ទ. ឥតិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឥតិវុត្តក | ភាគ ៥៣ |
| ខុទ្ទ. សុត្ត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | សុត្តនិបាត | ភាគ ៥៤ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| ខុទ្ទ. វិមា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | វិមានវត្ថុ | ភាគ ៥៥ |
| ខុទ្ទ. បេត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បេតវត្ថុ | ភាគ ៥៦ |
| ខុទ្ទ. ថេរ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរគាថា | ភាគ ៥៦. ៥៧. |
| ខុទ្ទ. ថេរី. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរីគាថា | ភាគ ៥៧ |
| ខុទ្ទ. ជាត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ជាតក | ភាគ ៥៨-៦៣ |
| ខុទ្ទ. មហា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | មហានិទ្ទេស | ភាគ ៦៤-៦៦. |
| ខុទ្ទ. ចូឡ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចូឡនិទ្ទេស | ភាគ ៦៧. ៦៨. |
| ខុទ្ទ. បដិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ | ភាគ ៦៩-៧១. |
| ខុទ្ទ. អបទ្ឋ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | អបទ្ឋទាន | ភាគ ៧២-៧៦ |
| ខុទ្ទ. ពុទ្ធ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ពុទ្ធវំស | ភាគ ៧៦ |
| ខុទ្ទ. ចរិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចរិយាបិដក | ភាគ ៧៦ |
| អភិ. សង្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធម្មសង្គណី | ភាគ ៧៨. ៧៩. |
| អភិ. វិភ. | អភិធម្មបិដក | ខុទ្ទកនិកាយ | វិភង្គ | ភាគ ៨០-៨២. |
| អភិ. ធាតុ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធាតុកថា | ភាគ ៨៣. |
| អភិ. បុគ្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | បុគ្គលបញ្ញត្តិ | ភាគ ៨៣. |
| អភិ. កថា. | អភិធម្មបិដក | ខុទ្ទកនិកាយ | កថាវត្ថុ | ភាគ ៨៤-៩០ |
| អភិ. យម. | អភិធម្មបិដក | ខុទ្ទកនិកាយ | យមក | ភាគ ៩១-៩៣. |
| អភិ. បដ្ឋា. | អភិធម្មបិដក | ខុទ្ទកនិកាយ | មហាបដ្ឋាន | ភាគ ៩៤-១១០ |

# អដ្ឋកថា

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | |
|---|---|---|---|
| សមន្ត. ពាហិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | ពាហិរនិទាន |
| សមន្ត. វេរ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | វេរញ្ជកណ្ឌ |
| សមន្ត. បារា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បារាជិកកណ្ឌ |
| សមន្ត. សង្ឃា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | សង្ឃាទិសេស |
| សមន្ត. និស្ស. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | និស្សគ្គិយ |
| សមន្ត. បាចិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បាចិត្តិយ |
| សមន្ត. មហា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | មហាវគ្គ |
| សមន្ត. ចុល្ល. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | ចុល្លវគ្គ |
| សមន្ត. បរិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បរិវារៈ |
| សុមង្គ. សីល. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | សីលក្ខន្ធវគ្គ |
| សុមង្គ. មហា. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | មហាវគ្គ |
| សុមង្គ. បាដិ. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | បាដិកវគ្គ |
| បបញ្ច. មូល. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មូលបណ្ណាសក |
| បបញ្ច. មជ្ឈិ. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក |
| បបញ្ច. ឧប. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | ឧបរិបណ្ណាសក |
| សារត្ថ. សគា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សគាថវគ្គ |
| សារត្ថ. និទា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | និទានវគ្គ |
| សារត្ថ. ខន្ធ. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | ខន្ធវារវគ្គ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | |
|---|---|---|---|
| សារត្ថ. សឡា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សឡាយតនវគ្គ |
| សារត្ថ. មហា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | មហាវារវគ្គ |
| មនោរ. ឯក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកនិបាត |
| មនោរ. ទុក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទុកនិបាត |
| មនោរ. តិក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | តិកនិបាត |
| មនោរ. ចតុ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ចតុកនិបាត |
| មនោរ. បញ្ច. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | បញ្ចកនិបាត |
| មនោរ. ឆក្ក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឆក្កនិបាត |
| មនោរ. សត្ត. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | សត្តកនិបាត |
| មនោរ. អដ្ឋ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | អដ្ឋកនិបាត |
| មនោរ. នវ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | នវកនិបាត |
| មនោរ. ទស. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទសកនិបាត |
| មនោរ. ឯកា. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកាទសកនិបាត |
| បរត្ថ. បាឋ. | បរមត្ថជោតិកាយ | អដ្ឋកថានៃខុទ្ទកនិកាយ | ខុទ្ទកបាឋ |
| អដ្ឋ. ធម្ម. | ធម្មបទដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ធម្មបទគាថា |
| បរត្ថ. ឧទា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឧទាន |
| បរត្ថ. ឥតិ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឥតិវុត្តក |
| បរត្ថ. សុត្ត. | បរមត្ថជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | សុត្តនិបាត |
| បរត្ថ. វិមា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | វិមានវត្ថុ |
| បរត្ថ. បេត. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | បេតវត្ថុ |

## អក្សរសង្ខេប អក្សរពេញនៃអដ្ឋកថា

| | | | |
|---|---|---|---|
| បរត្ថ. ថេរ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរគាថា |
| បរត្ថ. ថេរី. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរីគាថា |
| អដ្ឋ. ជាត. | ជាតកដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ជាតក |
| សទ្ធម្ម. មហា. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | មហានិទ្ទេស |
| សទ្ធម្ម. ចូឡ. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | ចូឡនិទ្ទេស |
| សទ្ធម្ម. បដិ. | សទ្ធម្មប្បកាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ |
| វិសុទ្ធ. អប្ប. | វិសុទ្ធជនវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | អប្បទាន |
| មធុរ. ពុទ្ធ. | មធុរត្ថវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ពុទ្ធវង្ស |
| បរម. ចរិ. | វិមលវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ចរិយា |
| អដ្ឋសា. សង្គ. | អដ្ឋសាលិនី | អដ្ឋកថានៃព្រះអភិធម្ម | ធម្មសង្គណី |
| សម្មោហ. វិភ. | សម្មោហវិនោទនី | អដ្ឋកថានៃព្រះអភិធម្ម | វិភង្គ |
| បរម. បញ្ចប. | បរមត្ថទីបនី | អដ្ឋកថានៃព្រះអភិធម្ម | បញ្ចបករណ៍ |
| វិសុ. សីល. | វិសុទ្ធិមគ្គ | សីលនិទ្ទេស | ភាគ ១ |
| វិសុ. សមាធិ. | វិសុទ្ធិមគ្គ | សមាធិនិទ្ទេស | ភាគ ២ |
| វិសុ. បញ្ញា. | វិសុទ្ធិមគ្គ | បញ្ញានិទ្ទេស | ភាគ ៣ |
| ថៃ. | អដ្ឋកថាថៃ | | |
| ភូមា. | ឆដ្ឋសង្គាយនាភូមា | | |

គប្បីជ្រាបលេខ ដែលនៅបន្ទាប់ពីអក្សរសង្ខេប ដូច្នេះ គឺ លេខខាងដើមជាលេខភាគនៃគម្ពីរ លេខកណ្ដាលជាលេខឃ្លាប លេខខាងចុងជាលេខទំព័រ ។

ឧទាហរណ៍ ៤. ៤៧៦/៤៧៨ គឺ ភាគទី ៤ ឃ្លាបទី ៤៧៦ ទំព័រទី ៤៧៨ ។

# បញ្ជីមាតិកា


មាតិកាសិក្ខាបទបាចិត្តិយាទិវណ្ណនា ទំព័រ

ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ … … … … … … ក
ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ … … … … … … … ង
ឧប្បត្តិកថា … … … … … … … … … … … … ឋ
អក្សរសង្ខេប និងអក្សរពេញ … … … … … … … ធ
បញ្ជីមាតិកា … … … … … … … … … … … … ម


## មាតិកាសិក្ខាបទបាចិត្តិយាទិវណ្ណនា


បាចិត្តិយកណ្ឌ មាន ៩ វគ្គ

១. មុសាវាទវគ្គ

១. មុសាវាទសិក្ខាបទវណ្ណនា … … … … … … ១
២. ឱមសវាទសិក្ខាបទវណ្ណនា … … … … … ១០
៣. បេសុញ្ញវាទសិក្ខាបទវណ្ណនា … … … … … ១៨
៤. បទសោធម្មសិក្ខាបទវណ្ណនា … … … … … ២១
៥. សហសេយ្យសិក្ខាបទវណ្ណនា … … … … … ៣០
៦. ទុតយសហសេយ្យសិក្ខាបទវណ្ណនា … … … ៤៥

## មាតិកាសិក្ខាបទបាចិត្តិយាទិវណ្ណនា ទំព័រ


៧. ធម្មទេសនាសិក្ខាបទវណ្ណនា ... ... ... ... ... ៤៧
៨. ភូតារោចនសិក្ខាបទវណ្ណនា ... ... ... ... ... ៥១
៩. ទុដ្ឋុល្លារោចនសិក្ខាបទវណ្ណនា ... ... ... ... ... ៥៥
១០. បឋវីខណនសិក្ខាបទវណ្ណនា ... ... ... ... ... ៦០

## ២. ភូតគាមវគ្គ

១. ភូតគាមសិក្ខាបទវណ្ណនា ... ... ... ... ... ... ៧៣
២. អញ្ញវាទសិក្ខាបទវណ្ណនា ... ... ... ... ... ... ១០០
៣. ឧជ្ឈាបនសិក្ខាបទវណ្ណនា ... ... ... ... ... ... ១០៥
៤. បឋមសេនាសនសិក្ខាបទវណ្ណនា ... ... ... ... ១១០
៥. ទុតិយសេនាសនសិក្ខាបទវណ្ណនា ... ... ... ... ១២៤
៦. អនុបខជ្ជសិក្ខាបទវណ្ណនា ... ... ... ... ... ១៣៣
៧. និក្កឌ្ឍនសិក្ខាបទវណ្ណនា ... ... ... ... ... ... ១៣៧
៨. វេហាសកុដិសិក្ខាបទវណ្ណនា ... ... ... ... ... ១៤០
៩. មហល្លកវិហារសិក្ខាបទវណ្ណនា ... ... ... ... ១៤៣
១០. សប្បាណកសិក្ខាបទវណ្ណនា ... ... ... ... ... ១៥០

មាតិកា ទំព័រ


### ៣. ភិក្ខុនីវគ្គ

១. ឱវាទសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ១៥៣

២. អត្ថង្គតសិក្ខាបទវណ្ណនា ... ... ... ... ... ... ១៩៤

៣. ភិក្ខុនីឧបស្សយសិក្ខាបទវណ្ណនា ... ... ... ... ២០០

៤. អាមិសសិក្ខាបទវណ្ណនា ... ... ... ... ... ... ២០៣

៥. ចីវរទានសិក្ខាបទវណ្ណនា ... ... ... ... ... ... ២០៥

៦. ចីវរសិព្វនសិក្ខាបទវណ្ណនា ... ... ... ... ... ២០៦

៧. សំវិធានសិក្ខាបទវណ្ណនា ... ... ... ... ... ... ២១០

៨. នាវាភិរូហនសិក្ខាបទវណ្ណនា ... ... ... ... ... ២១៧

៩. បរិបាចនសិក្ខាបទវណ្ណនា ... ... ... ... ... ... ២២០

១០. រហោនិសជ្ជសិក្ខាបទវណ្ណនា ... ... ... ... ... ២២៣

### ៤. ភោជនវគ្គ

១. អាវសថបិណ្ឌសិក្ខាបទវណ្ណនា ... ... ... ... ... ២២៥

២. គណភោជនសិក្ខាបទវណ្ណនា ... ... ... ... ... ២៣០

៣. បរម្បរភោជនសិក្ខាបទវណ្ណនា ... ... ... ... ... ២៤៦

៤. កាណមាតាសិក្ខាបទវណ្ណនា ... ... ... ... ... ២៥២

## មាតិកាសិក្ខាបទបាចិត្តិយាទិវណ្ណនា ទំព័រ


៥. បឋមបវារណាសិក្ខាបទវណ្ណនា ... ... ... ... ២៥៨

៦. ទុតិយបវារណាសិក្ខាបទវណ្ណនា ... ... ... ... ២៨៦

៧. វិកាលភោជនសិក្ខាបទវណ្ណនា ... ... ... ... ... ២៨៨

៨. សន្និធិការកសិក្ខាបទវណ្ណនា ... ... ... ... ... ៣០៣

៩. បណីតភោជនសិក្ខាបទវណ្ណនា ... ... ... ... ៣០៩

១០. ទន្តបោណសិក្ខាបទវណ្ណនា ... ... ... ... ... ៣១៥

### ៥. អចេលកវគ្គ

១. អចេលកសិក្ខាបទវណ្ណនា ... ... ... ... ... ... ៣៤៧

២. ឧយ្យោជនសិក្ខាបទវណ្ណនា ... ... ... ... ... ៣៤៩

៣. សភោជនាសិក្ខាបទវណ្ណនា ... ... ... ... ... ៣៥២

៤.៥. រហោបដិច្ឆន្នរហោនិសជ្ជសិក្ខាបទវណ្ណនា ... ... ៣៥៤

៦. ចារិតសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៣៥៤

៧. មហានាមសិក្ខាបទវណ្ណនា ... ... ... ... ... ៣៥៧

៨. ឧយ្យុត្តសិក្ខាបទវណ្ណនា ... ... ... ... ... ... ៣៥៩

៩. សេនាវាសសិក្ខាបទវណ្ណនា ... ... ... ... ... ៣៦២

១០. ឧយ្យោធិកសិក្ខាបទវណ្ណនា ... ... ... ... ... ៣៦៣

មាតិកា ទំព័រ


## ៦. សុរាបានវគ្គ

១. សុរាបានសិក្ខាបទវណ្ណនា ... ... ... ... ... ... ៣៦៥

២. អង្គុលិបតោទកសិក្ខាបទវណ្ណនា ... ... ... ... ៣៦៩

៣. ហសធម្មសិក្ខាបទវណ្ណនា ... ... ... ... ... ៣៧០

៤. អនាទរិយសិក្ខាបទវណ្ណនា ... ... ... ... ... ៣៧៣

៥. ភឹសាបនសិក្ខាបទវណ្ណនា ... ... ... ... ... ... ៣៧៤

៦. ជោតិសមាទហនសិក្ខាបទវណ្ណនា ... ... ... ... ៣៧៥

៧. នហានសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៣៧៧

៨. ទុព្វណ្ណករណសិក្ខាបទវណ្ណនា ... ... ... ... ... ៣៧៨

៩. វិកប្បនសិក្ខាបទវណ្ណនា. ... ... ... ... ... ៣៨១

១០. ចីវរាបនិធានសិក្ខាបទវណ្ណនា ... ... ... ... ៣៨២

## ៧. សប្បាណវគ្គ

១. សញ្ចិច្ចបាណសិក្ខាបទវណ្ណនា ... ... ... ... ... ៣៨៤

២. សប្បាណកសិក្ខាបទវណ្ណនា ... ... ... ... ... ៣៨៦

៣. ឧក្កោដនសិក្ខាបទវណ្ណនា ... ... ... ... ... ... ៣៨៨

៤. ទុដ្ឋុល្លសិក្ខាបទវណ្ណនា ... ... ... ... ... ... ៣៩០

## មាតិកាសិក្ខាបទបាចិត្តិយាទិវណ្ណនា ទំព័រ


៥. ឱនវីសតិវស្សសិក្ខាបទវណ្ណនា ... ... ... ... ... ៣៩២

៦. ថេយ្យសត្ថសិក្ខាបទវណ្ណនា ... ... ... ... ... ៣៩៧

៧. សំវិធានសិក្ខាបទវណ្ណនា ... ... ... ... ... ... ៣៩៨

៨. អរិដ្ឋសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៣៩៩

៩. ឧក្ខិត្តសម្ភោគសិក្ខាបទវណ្ណនា ... ... ... ... ... ៤០៣

១០. កណ្ដកសិក្ខាបទវណ្ណនា ... ... ... ... ... ៤០៥

### ៨. សហធម្មិកវគ្គ

១. សហធម្មិកសិក្ខាបទវណ្ណនា ... ... ... ... ... ៤០៨

២. វិវណ្ណនសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤០៩

៣. មោហនសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤២៥

៤. បហារសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤២៧

៥. តលសត្តិកសិក្ខាបទវណ្ណនា ... ... ... ... ... ៤២៩

៦. អមូលកសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤៣១

៧. សញ្ចិច្ចសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤៣២

៨. ឧបស្សុតិកសិក្ខាបទវណ្ណនា ... ... ... ... ... ៤៣៣

៩. កម្មបដិពាហនសិក្ខាបទវណ្ណនា ... ... ... ... ៤៣៥

## មាតិកាសិក្ខាបទបាចិត្តិយាទិវណ្ណនា ទំព័រ


១០. ឆន្ទំអទត្វាសិក្ខាបទវណ្ណនា ... ... ... ... ... ៤៣៦

១១. ទព្វសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៤៣៧

១២. បរិណាមនសិក្ខាបទវណ្ណនា ... ... ... ... ... ៤៣៨

៩. រតនវគ្គ

១. អន្តេបុរសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤៤០

២. រតនសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤៤៣

៣. វិកាលគាមប្បវេសនសិក្ខាបទវណ្ណនា ... ... ... ៤៤៨

៤. សូចិឃរសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤៥១

៥. មញ្ចបីឋសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤៥២

៦. តូលោនទ្ធសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤៥២

៧. និសីទនសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤៥៣

៨. កណ្ឌុបដិច្ឆាទិសិក្ខាបទវណ្ណនា ... ... ... ... ... ៤៥៤

៩. វស្សិកសាដិកសិក្ខាបទវណ្ណនា ... ... ... ... ... ៤៥៦

១០. សុគតចីវរសិក្ខាបទវណ្ណនា ... ... ... ... ... ៤៥៦

## មាតិកាសិក្ខាបទបាចិត្តិយាទិវណ្ណនា ទំព័រ

### បាជិទេសនីយ ៤


១. អញ្ញាតិកាយសិក្ខាបទវណ្ណនា ... ... ... ... ... ៤៥៨
២. ទប្បជិកាសេយ្យសិក្ខាបទវណ្ណនា ... ... ... ... ៤៦២
៣. សេក្ខសម្មតិសិក្ខាបទវណ្ណនា ... ... ... ... ... ៤៦៣
៤. អរញ្ញកសេនាសនសិក្ខាបទវណ្ណនា ... ... ... ... ៤៦៥


### សេក្ខិយវត្ត ៧៥


១. បរិមណ្ឌលវគ្គ ... ... ... ... ... ... ... ... ៤៧០
២. ឧជ្ជគ្ឃិកវគ្គ ... ... ... ... ... ... ... ... ... ៤៧៦
៣. ខម្ភកតវគ្គ ... ... ... ... ... ... ... ... ... ៤៧៨
៤. សក្កច្ចវគ្គ ... ... ... ... ... ... ... ... ... ៤៨៣
៥. កពឡវគ្គ ... ... ... ... ... ... ... ... ... ៤៨៤
៦. សុរុសុរុវគ្គ ... ... ... ... ... ... ... ... ... ៤៨៦
៧. បាទុកាវគ្គ ... ... ... ... ... ... ... ... ... ៤៩០
បកិណ្ណកៈក្នុងសេក្ខិយវត្តវណ្ណនា ... ... ... ... ... ៥០៦
អធិករណសមថវណ្ណនា ... ... ... ... ... ... ... ៥០៨

# មាតិកាសិក្ខាបទភិក្ខុនីវិភង្គវណ្ណនា

មាតិកាសិក្ខាបទភិក្ខុនីវិភង្គវណ្ណនា ទំព័រ

## បារាជិកកណ្ឌវណ្ណនា


១. ឧព្ភជាណុមណ្ឌលិកាសិក្ខាបទវណ្ណនា ... ... ... ៥០៩

២. វជ្ជប្បដិច្ឆាទិកាសិក្ខាបទវណ្ណនា ... ... ... ... ៥១៩

៣. ឧក្ខិត្តានុវត្តិកាសិក្ខាបទវណ្ណនា ... ... ... ... ៥២១

៤. អដ្ឋវត្ថុកាសិក្ខាបទវណ្ណនា ... ... ... ... ... ៥២៤


## សត្តរសកសង្ឃាទិសេសកណ្ឌវណ្ណនា


១. ឧស្សយវាទិកាសិក្ខាបទវណ្ណនា ... ... ... ... ៦៣០

២. ចោរិវុដ្ឋាបិកាសិក្ខាបទវណ្ណនា ... ... ... ... ... ៥៤០

៣. ឯកគាមន្តរគមនសិក្ខាបទវណ្ណនា ... ... ... ... ៥៤២

៤. ឧក្ខិត្តកឱសារណសិក្ខាបទវណ្ណនា ... ... ... ... ៥៤៩

៥. ភោជនប្បដិគ្គហណបឋមសិក្ខាបទវណ្ណនា ... ... ៥៥០

៦. ភោជនប្បដិគ្គហណទុតិយសិក្ខាបទវណ្ណនា ... ... ៥៥១

៧. សិក្ខំបច្ចាចិក្ខណសិក្ខាបទវណ្ណនា ... ... ... ... ៥៥២

៨. អធិករណកុបិតសិក្ខាបទវណ្ណនា ... ... ... ... ៥៥៣

## មាតិកាសិក្ខាបទភិក្ខុនីវិភង្គវណ្ណនា ទំព័រ


៩. បាបសមាចារបឋមសិក្ខាបទវណ្ណនា ... ... ... ៥៥៣

១០. បាបសមាចារទុតិយសិក្ខាបទវណ្ណនា ... ... ... ៥៥៥

តឹសកកណ្ឌនិស្សគ្គិយវណ្ណនា ២ វគ្គ

១. បត្តវគ្គ

១. បត្តសន្និចយសិក្ខាបទវណ្ណនា ... ... ... ... ... ៥៥៨

២. អកាលចីវរសិក្ខាបទវណ្ណនា ... ... ... ... ... ៥៥៩

៣. ចីវរបរិវត្តនសិក្ខាបទវណ្ណនា ... ... ... ... ... ៥៦០

៤. អញ្ញវិញ្ញាបនសិក្ខាបទវណ្ណនា ... ... ... ... ... ៥៦១

៥. អញ្ញចេតាបនសិក្ខាបទវណ្ណនា ... ... ... ... ... ៥៦២

៦. បឋមសង្ឃិកចេតាបនសិក្ខាបទវណ្ណនា ... ... ... ៥៦៣

៧. ទុតិយសង្ឃិកចេតាបនសិក្ខាបទវណ្ណនា ... ... ៥៦៥

៨. បឋមគណិកចេតាបនសិក្ខាបទវណ្ណនា ... ... ... ៥៦៥

៩. ទុតិយគណិកចេតាបនសិក្ខាបទវណ្ណនា ... ... ៥៦៦

១០. បុគ្គលិកចេតាបនសិក្ខាបទវណ្ណនា ... ... ... ៥៦៦

មាតិកា ទំព័រ

## ២. ផាតុរូបវគ្គ

១១. គរុបាវុរណសិក្ខាបទវណ្ណនា … … … … … ៥៦៧

១២. លហុបាវុរណសិក្ខាបទវណ្ណនា … … … … ៥៦៧

# បាចិត្តិយកណ្ឌ ១៦ វគ្គ

## ១. លសុណវគ្គ

១. លសុណសិក្ខាបទវណ្ណនា … … … … … … ៥៧០

២. សម្ពាធលោមសិក្ខាបទវណ្ណនា … … … … ៥៧៤

៣. តលឃាតកសិក្ខាបទវណ្ណនា … … … … … ៥៧៥

៤. ជតុមដ្ឋកសិក្ខាបទវណ្ណនា … … … … … … ៥៧៦

. ឧទកសុទ្ធិកសិក្ខាបទវណ្ណនា … … … … … ៥៧៧

៦. ឧបតិដ្ឋនសិក្ខាបទវណ្ណនា … … … … … … ៥៧៨

៧. អាមកធញ្ញសិក្ខាបទវណ្ណនា … … … … … ៥៨០

៨. បឋមឧច្ចារឆឌ្ឌនសិក្ខាបទវណ្ណនា … … … … ៥៨២

៩. ទុតិយឧច្ចារឆឌ្ឌនសិក្ខាបទវណ្ណនា … … … … ៥៨៤

១០. នច្ចគីតសិក្ខាបទវណ្ណនា … … … … … … ៥៨៥

មាតិកា ទំព័រ


២. រត្តន្ធការវគ្គ

១. រត្តន្ធការសិក្ខាបទវណ្ណនា … … … … … … ៥៨៩

២. បដិច្ឆន្នោកាស លូបទសិក្ខាបទវណ្ណនា … … ៥៩០

៣. អជ្ឈោកាសសល្លាបនសិក្ខាបទវណ្ណនា … … ៥៩០

៤. ទុតិយិកឧយ្យោជនសិក្ខាបទវណ្ណនា … … … ៥៩១

៥. អនាបុច្ឆាបក្កមនសិក្ខាបទវណ្ណនា … … … … ៥៩២

៦. អនាបុច្ឆាអភិនិសីទនសិក្ខាបទវណ្ណនា … … … … ៥៩៣

៧. អនាបុច្ឆាសន្ថរណសិក្ខាបទវណ្ណនា … … … ៥៩៤

៨. បរឧជ្ឈាបនកសិក្ខាបទវណ្ណនា … … … … … ៥៩៤

៩. បរអភិសបនសិក្ខាបទវណ្ណនា … … … … … ៥៩៥

១០. រោទនសិក្ខាបទវណ្ណនា … … … … … … ៥៩៦

៣. នគ្គវគ្គ

១. នគ្គសិក្ខាបទវណ្ណនា … … … … … … … ៥៩៨

២. ឧទកសាដិកសិក្ខាបទវណ្ណនា … … … … … ៥៩៩

៣. ចីវរសិព្វនសិក្ខាបទវណ្ណនា … … … … … ៥៩៩

៤. សង្ឃាដិចារសិក្ខាបទវណ្ណនា … … … … … ៦០០

**មាតិកា** **ទំព័រ**

៥. ចីវរសង្កមនីយសិក្ខាបទវណ្ណនា ... ... ... ... ៦០១
៦. គណចីវរសិក្ខាបទវណ្ណនា ... ... ... ... ... ៦០២
៧. បដិពាហនសិក្ខាបទវណ្ណនា ... ... ... ... ... ៦០៣
៨. ចីវរទានសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦០៤
៩. កាលអតិក្កមនសិក្ខាបទវណ្ណនា ... ... ... ... ៦០៥
១០. កឋិនុទ្ធារសិក្ខាបទវណ្ណនា ... ... ... ... ... ៦០៦

៤. តុវដ្តវគ្គ

១. ឯកមញ្ចតុវដ្តនសិក្ខាបទវណ្ណនា ... ... ... ... ៦០៨
២. ឯកត្ថរណតុវដ្តនសិក្ខាបទវណ្ណនា ... ... ... ... ៦០៩
៣. អផាសុករណសិក្ខាបទវណ្ណនា ... ... ... ... ៦១០
៤. នឧបដ្ឋាបនសិក្ខាបទវណ្ណនា ... ... ... ... ... ៦១១
៥. និក្កឌ្ឍនសិក្ខាបទវណ្ណនា ... ... ... ... ... ៦១២
៦. សំសដ្ឋសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦១២
៧.៨.៩. អន្តោរដ្ឋតិរោរដ្ឋន្តោវស្សសិក្ខាបទវណ្ណនា ... ៦១៣
១០. ចារិកនបក្កមនសិក្ខាបទវណ្ណនា ... ... ... ... ៦១៤

**មាតិកា** **ទំព័រ**


## ៥. ចិត្តាគារវគ្គ

១. រាជាគារសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦១៦
២. អាសន្ទិបរិភុញ្ជនសិក្ខាបទវណ្ណនា ... ... ... ... ៦១៨
៣. សុត្តកន្តនសិក្ខាបទវណ្ណនា ... ... ... ... ... ៦១៩
៤. គិហិវេយ្យាវច្ចសិក្ខាបទវណ្ណនា ... ... ... ... ៦២០
៥. អធិករណសិក្ខាបទវណ្ណនា ... ... ... ... ... ៦២១
៦. ភោជនទានសិក្ខាបទវណ្ណនា ... ... ... ... ... ៦២២
៧. អាវសថចីវរសិក្ខាបទវណ្ណនា ... ... ... ... ... ៦២៣
៨. អាវសថវិហារសិក្ខាបទវណ្ណនា ... ... ... ... ៦២៤
៩. តិរច្ឆានវិជ្ជាបរិយាបុណនសិក្ខាបទវណ្ណនា ... ... ៦២៥
១០. តិរច្ឆានវិជ្ជាវាចនសិក្ខាបទវណ្ណនា ... ... ... ៦២៦

## ៦. អារាមវគ្គ

១. អារាមបវិសនសិក្ខាបទវណ្ណនា ... ... ... ... ៦២៧
២. ភិក្ខុអក្កោសនសិក្ខាបទវណ្ណនា ... ... ... ... ៦២៨
៣. គណបរិភាសនសិក្ខាបទវណ្ណនា ... ... ... ... ៦២៩
៤. បវារិតសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦២៩

មាតិកា ទំព័រ

៥. កុលមច្ចរិនីសិក្ខាបទវណ្ណនា ... ... ... ... ... ៦៣០
៦. អភិក្ខុកាវាសសិក្ខាបទវណ្ណនា ... ... ... ... ... ៦៣១
៧. អបវារណាសិក្ខាបទវណ្ណនា ... ... ... ... ... ៦៣២
៨. ឱវាទសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦៣២
៩. ឱវាទូបសង្កមនសិក្ខាបទវណ្ណនា ... ... ... ... ៦៣៣
១០. បសាខេជាតសិក្ខាបទវណ្ណនា ... ... ... ... ៦៣៤

## ៧. គព្ភិនីវគ្គ

១. គព្ភិនីសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦៣៦
២. បាយន្តីសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦៣៦
៣. បឋមសិក្ខមានសិក្ខាបទវណ្ណនា ... ... ... ... ៦៣៧
៤. ទុតិយសិក្ខមានសិក្ខាបទវណ្ណនា ... ... ... ... ៦៣៨
៥. បឋមគិហិគតសិក្ខាបទវណ្ណនា ... ... ... ... ៦៣៩
៦. ទុតិយគិហិគតសិក្ខាបទវណ្ណនា ... ... ... ... ៦៣៩
៧. តតិយគិហិគតសិក្ខាបទវណ្ណនា ... ... ... ... ៦៤០
៨. បឋមសហជីវិនិសិក្ខាបទវណ្ណនា ... ... ... ... ៦៤០
៩. នានុពន្ធនសិក្ខាបទវណ្ណនា ... ... ... ... ... ៦៤១
១០. ទុតិយសហជីវិនិសិក្ខាបទវណ្ណនា. ... ... ... ៦៤២

មាតិកា ទំព័រ


## ៨. កុមារិភូតវគ្គ

១. ២. ៣. បឋមកុមារិភូតាទិសិក្ខាបទវណ្ណនា ... ៦៤៤

៤.៥.៦. ឩនទ្វាទសវស្សបរិបុណ្ណទ្វាទសវស្ស ទីយនធម្ម សិក្ខាបទវណ្ណនា ... ... ... ... ... ... ... ... ... ... ៦៤៥

៧. បឋមសិក្ខមាននវុដ្ឋាបនសិក្ខាបទវណ្ណនា ... ... ៦៤៦

៨. ទុតិយសិក្ខមាននវុដ្ឋាបនសិក្ខាបទវណ្ណនា ... ... ៦៤៦

៩. សោកាវាសសិក្ខាបទវណ្ណនា ... ... ... ... ... ៦៤៧

១០. អននុញ្ញាតសិក្ខាបទវណ្ណនា ... ... ... ... ... ៦៤៨

១១. បារិវាសិកសិក្ខាបទវណ្ណនា ... ... ... ... ... ៦៤៩

១២. អនុវស្សសិក្ខាបទវណ្ណនា ... ... ... ... ... ៦៥២

១៣. ឯកវស្សសិក្ខាបទវណ្ណនា ... ... ... ... ... ៦៥២

## ៩. ឆត្តុបាហនវគ្គ

១. ឆត្តុបាហនសិក្ខាបទវណ្ណនា ... ... ... ... ... ៦៥៤

២. យានសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦៥៥

៣. សង្ឃាណិសិក្ខាបទវណ្ណនា ... ... ... ... ... ៦៥៥

៤. ឥត្ថាលង្ការសិក្ខាបទវណ្ណនា ... ... ... ... ... ៦៥៦

មាតិកា ទំព័រ

៥. គន្ធវណ្ណកសិក្ខាបទវណ្ណនា ... ... ... ... ... ៦៥៦
៦. វាសិតកសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦៥៧
៧. ភិក្ខុនិឧម្មុទ្ទាបនសិក្ខាបទវណ្ណនា ... ... ... ... ៦៥៧
៨. ៩. ១០. សិក្ខមានឧម្មុទ្ទាបនាទិសិក្ខាបទវណ្ណនា ៦៥៨
១១. អនាបុច្ឆាសិក្ខាបទវណ្ណនា ... ... ... ... ... ៦៥៨
១២. បញ្ញាបុច្ឆនសិក្ខាបទវណ្ណនា ... ... ... ... ... ៦៥៩
១៣. អសំកច្ចិកសិក្ខាបទវណ្ណនា ... ... ... ... ... ៦៦០

១០-១៦ មុសាវាទវិគ្គ

មុសាវាទាទិសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦៦២

បាដិទេសនីយកណ្ឌ

សប្បិវិញ្ញាបនាទិសិក្ខាបទវណ្ណនា ... ... ... ... ... ៦៦៥

សេក្ខិយវត្ត

១. បរិមណ្ឌលាទិសិក្ខាបទវណ្ណនា ... ... ... ... ... ៦៦៦
ឧយ្យោជនគាថារបស់អ្នករចនា ... ... ... ... ៦៦៦

ចប់ បញ្ជីមាតិកា

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## បាចិត្តិយ

## តតិយភាគ

## ៣

# បាចិត្តិយកណ្ឌវណ្ណនា

អដ្ឋកថាព្រះវិន័យបិដក ភាគ ៣-៤-៥ ពួកបាចិត្តិយ
សិក្ខាបទណា សង្គ្រោះតាមវគ្គ មាន ៩ វគ្គ ប្រតិស្ឋាន
ទុកដោយល្អហើយ ឥឡូវនេះ នឹងពណ៌នាសិក្ខាបទ
ទាំងនោះ ដូចតទៅនេះ ។

## ១. មុសាវាទវគ្គ

### ១. មុសាវាទសិក្ខាបទវណ្ណនា

បណ្ដាវគ្គទាំង ៩ នោះ គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃ មុសាវាទវគ្គ ជាមុន ។

#### ពន្យល់រឿងព្រះហត្ថកៈ

[១៧៣] ពាក្យថា ហត្ថកោ : ហត្ថកៈ ជាឈ្មោះរបស់ព្រះថេរៈនោះ ។ បុត្ររបស់ស្ដេចសក្យៈឈ្មោះថា សក្យបុត្រ ។ បានឮថា ក្នុងសម័យពុទ្ធកាលបុរស ៨ម៉ឺននាក់ បានចេញអំពីសក្យត្រកូលហើយបួស ។ ព្រះហត្ថកៈនោះ ជាបុរសម្នាក់ បណ្ដាបុរស ៨ ម៉ឺននាក់នោះ ។

បទថា វាទក្ខិត្តោ : ជាអ្នកហុចពាក្យសំដី មានសេចក្ដីថា ត្រូវ

ពាក្យនិយាយដែលខ្លួន កំណត់ទុកយ៉ាងនេះថា "យើងនឹងធ្វើវាទៈ (ការតទល់វាទៈគ្នា)", បន្ទ្រាត់ទៅ គឺ ច្រានទៅ អធិប្បាយថា រុញច្រានទៅ គឺ បញ្ជូនទៅកាន់សំណាក់របស់ពួកបរវាទី ។ ម្យ៉ាងទៀត ព្រះហត្ថកៈនោះ ត្រូវចិត្តរបស់ខ្លួនបន្ទ្រាត់ទៅក្នុងវាទៈ រមែងប្រាកដក្នុងស្ថានដែលមានការតទល់វាទៈគ្នា គ្រប់គ្រាទៅ; ព្រោះហេតុនោះ លោកទើបឈ្មោះថា ត្រូវបន្ទ្រាត់ទៅក្នុងវាទៈ (ជាអ្នកនិយាយត្រឡប់ត្រឡិន) ។

ពាក្យថា អវជានិត្វា បដិជានាតិ : **គេចកែសំដីហើយទទួលដឹង** មានសេចក្ដីថា ព្រះហត្ថកៈនោះ កំណត់ទោសយ៉ាងណាមួយ ក្នុងពាក្យនិយាយរបស់ខ្លួនបាន គេចកែទៅថា "នេះមិនមែនពាក្យនិយាយរបស់យើង" កាលនិយាយទៅ ៗ សង្កេតបានថា មិនមានទោស ហើយព្រមទទួលថា "នេះ ជាពាក្យនិយាយរបស់យើង" ។

ពាក្យថា បដិជានិត្វា អវជានាតិ : **ទទួលដឹងហើយគេចកែសំដីវិញ** មានសេចក្ដីថា លោកកាលកំណត់អានិសង្សក្នុងពាក្យនិយាយយ៉ាងណាមួយបាន ក៏ព្រមទទួលថា "នេះ ជាពាក្យនិយាយរបស់យើង" កាលនិយាយតទៅទៀតកំណត់ទោសក្នុងពាក្យនោះបាន ក៏គេចកែទៅថា "នេះមិនមែនជាពាក្យនិយាយរបស់យើង" ដូច្នេះ ។

ពាក្យថា អញ្ញេនញ្ញំ បដិចរតិ : **បិទបាំងហេតុដទៃដោយហេតុដទៃ** មានសេចក្ដីថា រមែងបន្លប់ គឺ រមែងបិទបាំង បានដល់ គ្រប

សន្តត់ហេតុមួយ ដោយហេតុមួយ គឺ ពោលហេតុថា "រូបមិនទៀង ព្រោះជារបស់ដែលគប្បីដឹងបាន" ហើយត្រឡប់ពោលហេតុជាដើមថា "ព្រោះមានការកើតជាធម្មតា" ។

តែក្នុងកុរុន្ទីលោកពោលថា រមែងនិយាយរឿងដទៃជាច្រើន ព្រោះហេតុដែលនឹងបិទបាំងប្តេជ្ញា និងសេចក្តីគេចកែនោះ ។

ក្នុងពាក្យថា ឯតស្ស : ជាដើមនោះ មានអធិប្បាយដូចតទៅនេះថា លោក តែងពោលពាក្យជាច្រើនមានយ៉ាងនេះថា "អ្នកណាពោល ? ពោលថា យ៉ាងណា ? ពោលទីណា ?"ជាដើម ដូច្នេះ ដើម្បីបិទបាំងពាក្យប្តេជ្ញានិងពាក្យគេចកែនោះ ។

ក្នុងមហាអដ្ឋកថា លោកពោលទុកទៀតថា គេចកែហើយទទួលដឹង និងទទួលដឹងហើយគេចកែនុ៎ះឯង ឈ្មោះថា បិទបាំងហេតុដទៃដោយហេតុដទៃ ។

ពីរបទថា សម្បជានមុសា ភាសតិ : **ពោលពាក្យកុហកដោយដឹងខ្លួន** បានដល់ ពោលពាក្យកុហកទាំងដែលដឹងខ្លួន ។

ច្រើនបទថា សង្កេតំ កត្វា វិសំវាទេតិ : **ធ្វើនូវសេចក្តីកំណត់ហើយពោលឱ្យហួសពីកំណត់នោះវិញ** មានសេចក្តីថា ធ្វើការកំណត់ទុកថា "ការតទល់វាទៈ ចូរមានក្នុងប្រទេសឯណោះ ក្នុងបណ្តាកាលមានបុរេភត្តជាដើម ឯណោះ" ដូច្នេះ ហើយទៅមុន ឬ ក្រោយពីវេលាដែល

ខ្លួនកំណត់ទុក ហើយពោលថា "ចូរមើលចុះ លោកដ៏ចម្រើន ពួកតិរ្ថិយមិនមកទេ បរាជ័យហើយ" ដូច្នេះ ជៀសចេញទៅ ។

បទថា សម្បជានមុសាវាទេ : ពោលពាក្យកុហកដោយដឹងខ្លួនបានដល់ ព្រោះការនិយាយកុហកទាំងដែលដឹងខ្លួនហើយ និងកំពុងដឹង ។

[១៧៤] បទថា វិសំវាទនបុរេក្ខារស្ស : របស់បុគ្គលដែលធ្វើគំនិតនឹងពោលឱ្យខុសជាប្រធាន បានដល់ របស់អ្នកនិយាយដែលធ្វើគំនិត គិតនឹងពោលឱ្យខុសជាប្រធាន ។

ចេតនាញុំាងពាក្យនិយាយ ដែលរាប់បញ្ចូលក្នុងមិច្ឆាវាចាឱ្យតាំងឡើង ឈ្មោះថា វាចា ។

លោកសម្តែងសំឡេងដែលតាំងឡើងដោយចេតនានោះ ដោយពាក្យថា គិរា : សំដី ។

គន្លងនៃពាក្យ ឈ្មោះថា ព្យបថ : គន្លងពាក្យ ។ ក៏វាចានុ៎ះឯង លោកហៅថា ព្យបថ ព្រោះជាគន្លងមកសូម្បីរបស់ជនពួកដទៃ អ្នកដល់ទិដ្ឋានុគតិ ។

ការថ្លែងវាចាដែលមានសេចក្តីដឹងបានថា ពាក្យនិយាយ, ឈ្មោះថា វចីភេទ ។ វាចាមានប្រភេទផ្សេង ៗគ្នានុ៎ះឯង លោកហៅយ៉ាងនេះ (ថា វចីភេទ) ។

វិញ្ញត្តិដែលប្រព្រឹត្តទៅមកវាចា ឈ្មោះថា វចីវិញ្ញត្តិ ។ ដោយអាការយ៉ាងនេះអ្នកសិក្សាគប្បីជ្រាបថា ដោយបទដំបូង ព្រះឧបាលីពោលត្រឹមតែចេតនាសុទ្ធ, ដោយ ៣ បទកណ្តាល ពោលចេតនាដែលប្រកបដោយសំឡេងដែលតាំងឡើងដោយចេតនានោះ, ដោយបទមួយខាងចុងពោលចេតនាដែលប្រកបដោយវិញ្ញត្តិ ។

វោហារ (ពាក្យនិយាយ) របស់ពួកជនអ្នកមិនមែនព្រះអរិយៈ គឺ ពួកពាលបុថុជ្ជនឈ្មោះថា អនរិយវោហារ ។

[១៧៥] ព្រះឧបាលី គ្រាសម្តែងសម្បជានមុសាវាទយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងលក្ខណៈនៃអនរិយវោហារ ដែលរាប់ថាជា សម្បជានមុសាវាទ ដែលពោលទុកក្នុងទីបំផុត ទើបពោលពាក្យមានជាដើមថា អទិដ្ឋំ ឆាម ដូច្នេះ ។

## អត្ថាធិប្បាយអនរិយវោហារ ៨ យ៉ាង

ក្នុងពាក្យថា អទិដ្ឋំ : មិនឃើញ ជាដើមនោះ បណ្ឌិតគប្បីជ្រាបអត្ថដោយន័យនេះថា ពាក្យ ឬ ចេតនាជាហេតុញ៉ាំងពាក្យនោះឱ្យតាំងឡើង របស់ភិក្ខុដែលពោលរឿងដែលខ្លួនមិនឃើញយ៉ាងនេះថា "ខ្ញុំឃើញ" ឈ្មោះថា អនរិយវោហារមួយ ។

ន័យមួយទៀត បណ្ឌិតគប្បីជ្រាបសន្និដ្ឋាន ក្នុងពាក្យថា អទិដ្ឋំ

ទិដ្ឋំ មេ : ដែលខ្លួនមិនឃើញថា អាត្មាឃើញ ជាដើមនេះថា អារម្មណ៍ដែលខ្លួនមិនបានទទួលដោយអំណាចនៃចក្ខុឈ្មោះថា មិនឃើញ, ដែលមិនបានទទួលដោយអំណាចនៃសោតៈ ឈ្មោះថា មិនបានឮ, ដែលមិនបានទទួលធ្វើឱ្យដូចជាជាប់គ្នានឹងឥន្ទ្រិយ ៣ ដោយអំណាចនៃឃានិន្ទ្រិយជាដើម ឈ្មោះថា មិនជ្រាប[១], ដែលវិញ្ញាណស្អុទ ៗតែម្យ៉ាង ក្រៅអំពីឥន្ទ្រិយ ៥ មិនបានទទួល ឈ្មោះថា មិនដឹង ។

តែក្នុងព្រះបាលី ព្រះមានព្រះភាគត្រាស់ទេសនា ដោយន័យដែលប្រាកដច្បាស់យ៉ាងនេះថា ដែលឈ្មោះថា មិនឃើញ គឺ មិនឃើញដោយភ្នែក ដូច្នេះឯង ។

ក៏បណ្ដាអារម្មណ៍ដែលបានឃើញជាដើម អារម្មណ៍ណាដែលខ្លួនឯងក្ដី អ្នកដទៃក្ដី ឃើញហើយ ឈ្មោះថា ទិដ្ឋៈទាំងអស់ ។ អារម្មណ៍ដែលឈ្មោះថា សុតៈ មុតៈ និងវិញ្ញាតៈ ក៏យ៉ាងនេះ, នេះជាបរិយាយមួយ ។ ចំណែកបរិយាយមួយទៀត អារម្មណ៍ណាដែលខ្លួនឃើញដោយខ្លួនឯង អារម្មណ៍នោះ ចាត់ជាទិដ្ឋៈពិត ។ ក្នុងសុតៈជាដើម ក៏មានន័យដូចគ្នា ។ ក៏អារម្មណ៍ណាដែលអ្នកដទៃឃើញ អារម្មណ៍នោះ រមែងតាំងនៅក្នុងឋានៈនៃអារម្មណ៍ដែលខ្លួនបានឮ ។ សូម្បីអារម្មណ៍មានសុតៈជា

១. បិដកប្រែថា មិនពាល់ត្រូវ ។

ដើម ក៏មានន័យយ៉ាងនេះ ។

[១៧៦] ឥឡូវនេះ ព្រះឧបាលី កាលលើកអាបត្តិឡើងសម្តែង ដោយអំណាចនៃអនរិយវោហារទាំងនោះ ទើបពោលថា "តីហាការេហិ : ដោយអាការ ៣ យ៉ាង" ជាដើម ។ បណ្ឌិតគប្បីជ្រាបសេចក្តីនៃពាក្យថា តីហាការេហិ ជាដើមនោះ ដោយន័យដូចដែលខ្ញុំពោលហើយ ក្នុងវណ្ណនាបាលីចតុត្ថបារាជិក មានយ៉ាងនេះជាដើមថា "ភិក្ខុពោលសម្បជានមុសាវាទថា ខ្ញុំសម្រេចបឋមឈាន ត្រូវអាបត្តិបារាជិកដោយអាការ ៣" ដូច្នេះឯង ។ ពិតមែន ក្នុងបាលីចតុត្ថបារាជិកនោះ លោកពោលទុកត្រឹមតែពាក្យថា "**បឋមំ ឈានំ សមាបជ្ជឹ : អាត្មាបានចូលបឋមឈានហើយ**"[១] តែម្យ៉ាង, ក្នុងសិក្ខាបទនេះ ពោលទុកថា "អទិដ្ឋំ ទិដ្ឋំ មេ : **មិនឃើញនិយាយថា ខ្ញុំឃើញ**" ដូច្នេះ ។ ក៏ក្នុងបាលីចតុត្ថបារាជិកនោះ ពោលទុកថា "**អាបត្តិ បារាជិកស្ស : ត្រូវអាបត្តិបារាជិក**"[២] ក្នុងសិក្ខាបទនេះពោលថា "អាបត្តិ បាចិត្តិយស្ស : ត្រូវអាបត្តិបាចិត្តិយ" ដូច្នេះ ។ មានសេចក្តីប្លែកគ្នាត្រឹមតែក្នុងវត្ថុ និងអាបត្តិយ៉ាងនេះ ។ ពាក្យដែលនៅសល់មានលក្ខណៈតែមួយដូចគ្នា ។ សម្បី

១. វិន. បារា. ឧត្តរិមនុស្សធម្ម. ១. ២៣៧/៣០៤ ។

២. វិន. បារា. ឧត្តរិមនុស្សធម្ម. ១. ២៣៧/៣០៤ ។

ពាក្យជាដើមថា តីហាការេហិ ចិនេ្ន វេមតិកោ : ភិក្ខុមានសេចក្តីសង្ស័យក្នុងវត្ថុដែលខ្លួនឃើញ ក៏គប្បីជ្រាបសេចក្តីដោយន័យដូចពោលហើយ ក្នុងវណ្ណនាបាលីទុដ្ឋទោសសិក្ខាបទជាដើម យ៉ាងនេះថា "ទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ ទិដ្ឋេ វេមតិកោ : ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះក៏ឃើញមែន (តែភិក្ខុអ្នកចោទ) មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនឃើញហើយ"[១] ដូច្នេះឯង ។ ក៏ក្នុងសិក្ខាបទនេះ ត្រឹមតែពាក្យបាលីប៉ុណ្ណោះ ដែលប្លែកគ្នា (អំពីបាលីចតុត្ថបារាជិក) ។ ចំណែកក្នុងសេចក្តីព្រមទាំងវិនិច្ឆ័យ មិនមានការបែកផ្សេងគ្នាឡើយ ។

[១៨១] ពីរបទថា សហសា ភណតិ : ភិក្ខុពោលដោយរហ័ស សេចក្តីថា ភិក្ខុមិនបានរិះគិត ឬមិនបានពិចារណា និយាយដោយរហ័សដល់វត្ថុដែលមិនឃើញថា ខ្ញុំឃើញ ។

ពាក្យថា អញ្ញំ ភណិស្សាមីតិ អញ្ញំ ភណតិ : ភិក្ខុគិតថា អញនឹងពោលពាក្យដទៃ ហើយត្រឡប់ពោលពាក្យដទៃក្រៅអំពីគំនិតនោះវិញ សេចក្តីថា កាលខ្លួនគួរនឹងពោលពាក្យថា "ចីវរំ : ចីវរ" ភ្លាត់ជាពោលថា "ចីរំ : សំពត់" ដូច្នេះជាដើម ព្រោះភាពជាអ្នកខ្សោយក្នុងការ

១. វិន. សង្ឃា. ទុដ្ឋទោសសិក្ខាបទ. ២. ២៥៧/២៦៥ ។

គិត ព្រោះជាអ្នកវង្វេង ព្រោះការភ្លាំងភ្លាត់ ។ តែភិក្ខុណាដែលសាមណេរទូលសួរថា "លោកម្ចាស់ឃើញឧបជ្ឈាយ៍របស់ខ្ញុំដែរទេ" ដូច្នេះ ធ្វើការលេងលេងពោលថា "ឧបជ្ឈាយ៍របស់លោកបររទេះដឹកឧសទៅហើយទេដឹង" ឬថា កាលសាមណេរបាន ឮសំឡេងចចកហើយ សួរថា "នេះសំឡេងសត្វអ្វី លោកម្ចាស់" ពោលថា "នេះសំឡេងរបស់ពួកមនុស្សជួយគ្នាលើកកង់រទេះដែលជាប់ភក់របស់មាតាអ្នក ដែលកំពុងទៅដោយយាន" ដូច្នេះ យ៉ាងនេះពោលពាក្យដទៃ មិនមែនពោលញាប់មាត់ មិនមែនពោលដោយភ្លាត់មាត់, ភិក្ខុនោះ រមែងត្រូវអាបត្តិពិត ។ នៅមានពាក្យមួយទៀត ឈ្មោះថា បូរណកថា គឺ ភិក្ខុមួយរូប បានប្រេងបន្តិចបន្តួចក្នុងស្រុក ហើយត្រឡប់មកកាន់វិហារនិយាយនឹងសាមណេរថា "អ្នកទៅណា ថ្ងៃនេះ ស្រុកមានតែប្រេងទេ" ដូច្នេះក្តី បានដុំនំដែលគេដាក់ទុកក្នុងល្អី ពោលចំពោះសាមណេរថា "ថ្ងៃនេះ មនុស្សទាំងឡាយក្នុងស្រុក យកល្អីជាច្រើនដាក់នំទៅ" ដូច្នេះក្តី នេះក៏ជាមុសាវាទដែរ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះមានសមុដ្ឋាន៣ កើតឡើងតាមមកកាយចិត្ត១ វាចាចិត្ត១ កាយវាចាចិត្ត១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា៣ ដូច្នេះឯង ។

មុសាវាទសិក្ខាបទវណ្ណនា ចប់

## ២. ឱមសវានសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

### ពន្យល់រឿងឆព្វគ្គិយភិក្ខុ និងគោនន្ទិវិសាល

[១៨២] បណ្តាបទទាំងនោះ បទថា ឱមសន្តិ : ពោលចាក់ដោត គឺ រមែងពោលចាក់ដោត ។

បទថា ខុំសេន្តិ : ជេរ គឺ រមែងជេរ ។

បទថា វម្ភេន្តិ : ប្រទេច គឺ រមែងគម្រាមកំហែង ។

[១៨៣] ដោយបទថា ភូតបុព្វំ : កាលពីដើម ព្រះមានព្រះភាគទ្រង់នាំរឿងនេះមកសម្តែង ដើម្បីទ្រង់តិះដៀលការពោលចាក់ដោត ។

ពាក្យថា នន្ទិ ក្នុងពាក្យថា នន្ទិវិសាលោ នាម : ឈ្មោះនន្ទិវិសាល (នេះ) ជាឈ្មោះរបស់គោស្ទាវនោះ ។ ក៏គោស្ទាវនោះ មានស្នែងវែងធំ ព្រោះហេតុនោះ ទើបម្ចាស់នោះតាំងឈ្មោះថា នន្ទិវិសាល, ក្នុងសម័យនោះ គោនោះ ក៏គឺព្រះពោធិសត្វ ។ ព្រាហ្មណ៍ចិញ្ចឹមថែទាំគោស្ទាវនោះយ៉ាងល្អក្រៃលែង ដោយអាហារមានយាគូនិងបាយជាដើម ។ គ្រានោះ គោនន្ទិវិសាលនោះ កាលនឹងអនុគ្រោះព្រាហ្មណ៍ ទើបពោលថា "អញ្ជើញលោកទៅចុះ" ដូច្នេះជាដើម ។

ពីរបទថា តេន្ហិ អដ្ឋាសិ : ក៏ឈរទ្រឹងក្នុងទីនោះឯង មាន

សេចក្ដីថា សូម្បីក្នុងកាលនៃអហេតុកបដិសន្ធិ គោនន្ទិវិសាលមែនស្គាល់ពាក្យពោលចាក់ដោតរបស់អ្នកដទៃបាន ដោយជាពាក្យមិនជាទីពេញចិត្ត; ព្រោះដូច្នោះ វាប្រាថ្នាដើម្បីសម្ដែងទោសដល់ព្រាហ្មណ៍ ទើបបានឈរស្ងៀម ។

ច្រើនបទថា សកជសតំ អតិពទ្ធំ បវដ្ដេសិ : ក៏ទាញរទេះចំនួនមួយរយដែលគេចងភ្ជាប់គ្នាឱ្យវិលទៅបាន មានសេចក្ដីថា ព្រះពោធិសត្វកាលនឹងទាញរទេះ ១០០ ដែលចតទុកតាមលំដាប់ ស៊កឈើទុកខាងក្រោម ធ្វើឱ្យតជាប់គ្នា ដែលផ្ទុកពេញដោយសណ្ដែកបាយ សណ្ដែករាជមាស និងខ្សាច់ជាដើម ។ រទេះ ១០០ ជារបស់ដែលខ្លួនត្រូវទាញទៅទៀត សូម្បីក្នុងកាលកាំវិល១ជុំហើយ(ឈ្នះ) ក៏ពិត តែ(ព្រះពោធិសត្វ) ក៏បានទាញទៅរហូតដល់ទីប្រមាណ ១០០ រទេះ ដើម្បីឱ្យរទេះក្រោយចតក្នុងទីរទេះមុខចតហើយ ។ ពិតមែន ព្រះពោធិសត្វទាំងឡាយរមែងមិនមានការធ្វើដំធូរថយ ។

[១៨៤] បាទគាថាថា តេន ចត្តមនោ អហុ : ព្រោះការងាររបស់ខ្លួនផង មានសេចក្ដីថា គោនន្ទិវិសាលនោះ មានចិត្តសប្បាយរីករាយព្រោះការបានទ្រព្យនោះរបស់ព្រាហ្មណ៍ និងព្រោះការងាររបស់ខ្លួន ។

[១៨៦] ក៏ក្នុងពាក្យថា អក្កោសេនបិ : ពាក្យជេរ១ នេះ ព្រះ

មានព្រះភាគទ្រង់ប្រាប្ថានឹងចែកទុកខាងមុខថា "ដែលហៅថា ជេរ គឺ ជេរមានពីរយ៉ាង បានដល់ ជេរយ៉ាងថោកទាប១ ជេរយ៉ាងខ្ពង់ខ្ពស់១"; ព្រោះដូច្នោះ ទើបមិនត្រាស់ដូចមុនថា "រមែងជេរ ដោយពាក្យជេរដ៏ថោកទាបខ្លះ" ត្រាស់ទុកយ៉ាងនេះថា "អក្កោសេន : **ដោយពាក្យជេរ**" ដូច្នេះ ។

## ពន្យល់អំពីឱមសវាទជាដើម

[១៨៧] ជាតិនៃអ្នកដែលជាជាងចាំងឈើ ឈ្មោះថា **វេណជាតិ** : ជាតិជាង ត្បាញផែង ។

អាចារ្យពួកខ្លះពោលថា **វេឡុការជាតិ** : ជាតិជាងត្បាញឬស្សី ដូច្នេះក៏មាន ។

ជាតិនៃព្រានម្រឹគជាដើម ឈ្មោះថា **នេសាទជាតិ** : ជាតិអ្នកនេសាទ ។

ជាតិនៃអ្នកជាជាងធ្វើស្បែក ឈ្មោះថា **រថការជាតិ** : ជាតិអ្នកធ្វើរទេះ ។

ជាតិនៃអ្នកចាក់ផ្កាឈើ ឈ្មោះថា **បុក្កុសជាតិ** : ជាតិអ្នកបោលសម្រាម ។

[១៨៨] ពាក្យថា អវកណ្ណកា (អ្នកមានត្រចៀកដាក់ចុះ) ជាឈ្មោះរបស់ពួកមនុស្សដែលជាខ្ញុំបម្រើគេ; ព្រោះដូច្នោះ ទើបជាពាក្យ

អាក្រក់ ។

បទថា ឱញ្ញាតំ : ដែលគេមើលងាយ គឺ ដែលគេចំអកឡកឡឺយ ។ ភិក្ខុពួកខ្លះសូត្រថា "ឧញ្ញាតំ" ដូច្នេះក៏មាន ។

បទថា អវញ្ញាតំ : ដែលគេបន្ទាបបន្ថោក គឺ ដែលគេប្រទេចហើយ ។

បទថា ហីឡិតំ : គេបៀតបៀន គឺ ដែលគេស្អប់ខ្ពើម ។

បទថា បរិភូតំ : គេពេបជ្រាយ គឺ ដែលគេពេបជ្រាយថា នឹងមានប្រយោជន៍អ្វីដោយមនុស្សនេះ ។

បទថា អចិត្តីកតំ : គេមិនគោរព គឺ ដែលគេមិនធ្វើសេចក្តីគោរព លើកតម្កើង ។

[១៩០] ការងារជាងឈើ ឈ្មោះថា កោដ្ឋកកម្ម : ការងាររបស់អ្នកចាំងឈើ ។

[១៩១] ការរាប់ម្រាមមេដៃ ឈ្មោះថា មុទ្ទា : រាប់ដោយដៃទទេ ។ ការរាប់ដែលនៅសល់មានការរាប់មិនទាក់ទើជាដើម ឈ្មោះថា គណនា : រាប់ដោយវិធីទព្វន្ត ។ សរសេរទូវអក្សរ ឈ្មោះថា លេខា : ការសរសេរអក្សរ ។

[១៩២] រោគទឹកនោមផ្អែម លោកហៅថា រោគឧក្រិដ្ឋ :

អាពាធយ៉ាងស្រាល ព្រោះមិនមានវេទនា ។

[១៩៦] បទថា **ធាដិកត្វា : មានតែ ឬប្រាកដ បានដល់** គប្បីប្រាថ្នា ។

ពីរបទថា យកាេរន វា ភកាេរន វា **: ដេរដោយ យ អក្សរក្តី ដេរដោយ ភ អក្សរក្តី** មានសេចក្តីថា ពាក្យដេរដែលប្រកប យ អក្សរ និង ភ អក្សរ (ឈ្មោះថា ជាពាក្យដេរដែលអាក្រក់) ។

ក្នុងពាក្យថា កាដកោដចិកាយ វា **: ដោយនិមិត្តបុរស និង និមិត្តស្រីក្តី** (នេះ) និមិត្តនៃបុរសឈ្មោះថា កាដ, និមិត្តនៃស្ត្រីឈ្មោះ ថា កោដចិកា ។ ពាក្យដេរដែលប្រកបដោយបទទាំងពីរនោះយ៉ាងណា ពាក្យដេរនោះ ឈ្មោះថា អាក្រក់ ។

[១៩៧] ឥឡូវនេះ ព្រះមានព្រះភាគកាលនឹងទ្រង់លើកអាបត្តិឡើង ពិន័យដោយអំណាចនៃប្រភេទរបស់អក្កោសវត្ថុ មានជាតិជាដើមទាំងនោះ ទើបត្រាស់ពាក្យមានជាដើមថា "ឧបសម្បន្នោ ឧបសម្បន្នំ" ដូច្នេះ ។

បណ្តាបទទាំងនោះ បីបទថា ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ **: ប្រាថ្នាដើម្បីដេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីឱ្យ មានមុខចុះក្រោម** មានសេចក្តីថា អ្នកប្រាថ្នានឹងដេរ ប្រាថ្នានឹងតិះដៀល ប្រាថ្នានឹងធ្វើឱ្យអាប់យស ។

ពីរបទថា ហីនេន ហីនំ : **ចំពោះបុគ្គលដែលមានជាតិថោកទាប ដោយពាក្យថោកទាប** បានដល់ ដោយពាក្យពោលដល់ជាតិដែលអាក្រក់ គឺដោយជាតិដែលថោកទាប ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងបទទាំងពួង ដោយឧបាយយ៉ាងនេះ ។

ម្យ៉ាងទៀត បណ្ដាបទទាំងនេះ ភិក្ខុកាលពោលឱ្យអាក្រក់ដោយពាក្យដែលអាក្រក់ ទោះបីជាពោលពាក្យពិតក៏ដោយ លោកក៏នៅតែត្រូវបាចិត្តិយ គ្រប់ ៗពាក្យនិយាយ ព្រោះជាអ្នកប្រាថ្នានឹងពោលចាក់ដោត ។ ក៏កាលពោលឱ្យបុគ្គលអាក្រក់ ដោយពាក្យដែលល្អ សូម្បីពោលពាក្យមិនពិតក៏ដោយ, ក៏នៅតែត្រូវអាបត្តិបាចិត្តិយ ដោយសិក្ខាបទនេះ ព្រោះជាអ្នកប្រាថ្នានឹងពោលសិកសៀត មិនមែនដោយសិក្ខាបទមុន ។ ចំណែកភិក្ខុណាពោលពាក្យជាដើមថា "អ្នកឯងជាចណ្ឌាលល្អ អ្នកឯងជាព្រាហ្មណ៍ល្អ អ្នកឯងជាចណ្ឌាលអាក្រក់ អ្នកឯងជាព្រាហ្មណ៍អាក្រក់" ដូច្នេះ ។ សូម្បីភិក្ខុនោះ ព្រះវិន័យធរគប្បីពិន័យដោយអាបត្តិដូចគ្នា ។

[២៣៧-២៤៤] ក៏ក្នុងពាក្យថា សន្តិ ឥធេកច្ចេ : **ក្នុងលោកនេះ មានមនុស្សពួកខ្លះ** ជាដើមនេះ ជាអាបត្តិទុក្កដ ព្រោះជាពាក្យពោលប៉ះទង្គិច ។

[២៤៥] សូម្បីក្នុងពាក្យថា យេ-នូន, ន-មយំ : **មនុស្សទាំង**

ឡាយណា, **យើងទាំងឡាយមិនមែន** ដូច្នេះជាដើម ក៏ន័យនេះដែរ ។ តែក្នុងអនុបសម្បន្ន ជាទុក្កដតែម្យ៉ាងក្នុងវារៈ ទាំង ៤ ។ តែដោយពាក្យថា ចោរោសិ គណ្ឋិភេទកោសិ (អ្នកឯងជាចោរ អ្នកឯងជាអ្នកទម្លាយគុក)ជាដើម ជាទុក្កដគ្រប់ ៗវារៈ ដូចគ្នា ទាំងឧបសម្បន្ន ទាំងអនុបសម្បន្ន ។

[២៤៦-២៥៣] មួយទៀត ព្រោះសេចក្តីប្រាថ្នា នឹងលេង ជាទុព្ភាសិត គ្រប់ ៗវារៈ ទាំងឧបសម្បន្នទាំងអនុបសម្បន្ន ។ ភាពជាអ្នកមានសេចក្តី ប្រាថ្នាក្នុងការលេងសើច ឈ្មោះថា ភាពជាអ្នកប្រាថ្នានឹងលេង ។ ក៏ក្នុងសិក្ខាបទនេះ វៀរភិក្ខុចេញ សត្វទាំងអស់មានភិក្ខុនីជាដើម បណ្ឌិតគប្បីជ្រាបថា ជាអនុបសម្បន្ន ។

[២៥៤] ក្នុងពាក្យថា អត្ថបុរេក្ខារស្ស : **ភិក្ខុធ្វើសេចក្តីអធិប្បាយជាប្រធាន** ជាដើម គប្បីជ្រាបថា ភិក្ខុដែលពោលអត្ថនៃព្រះបាលី ឈ្មោះថា **អត្ថបុរេក្ខារៈ** ។ អ្នកបង្រៀនព្រះបាលីគប្បីជ្រាបថា **ធម្មបុរេក្ខារៈ** : ភិក្ខុធ្វើធម៌ជាប្រធាន ។ អ្នកតាំងនៅក្នុងការទូន្មានពោលដោយន័យជាដើមថា "សូម្បីឥឡូវនេះ អ្នកឯងជាចណ្ឌាល, អ្នកឯងកុំធ្វើបាប, កុំជាអ្នកមកងងឹតទៅងងឹត" ដូច្នេះ, គប្បីជ្រាបថា ឈ្មោះថា **អនុសាសនីបុរេក្ខារៈ** : ភិក្ខុធ្វើពាក្យប្រៀនប្រដៅជាប្រធាន ។ បទដែលនៅសល់ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងមកកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ដូច្នេះឯង ។

តែក្នុងអាបត្តិទាំងនេះ អាបត្តិទុក្កដសិត កើតមកវាចាចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ អកុសលចិត្ត មានវេទនា ២ គឺ សុខវេទនា ១ ឧបេក្ខាវេទនា ១ ។

ឱមសវាទសិក្ខាបទវណ្ណនា ចប់

# ៣. បេសុញ្ញវានសិក្ខាបទវណ្ណនា

*គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖*

## ពន្យល់រឿងឆព្វគ្គិយភិក្ខុ

*[២៥៥] បទថា* ភណ្ឌនជាតានំ **:** *បង្កហេតុប្រកួតប្រកាន់ បានដល់ អ្នកកើតជម្លោះទាស់ទែងគ្នាហើយ ។ ចំណែកខាងដើមនៃការឈ្លោះគ្នា ឈ្មោះថា* **ភណ្ឌន :** *ប្រកួតប្រកាន់ ។ គឺ ការប្រឹក្សាគ្នាក្នុងបក្ខពួករបស់ខ្លួន មានជាដើមថា "កាលគេពោលពាក្យយ៉ាងនេះថា កម្មយ៉ាងនេះដែលអ្នកនេះនិងអ្នកនេះធ្វើហើយ ពួកយើងនឹងពោលយ៉ាងនេះ" ឈ្មោះថា* **ភណ្ឌន: ។** *ការប្រព្រឹត្តិកន្លងដោយកាយ វាចា ឱ្យដល់អាបត្តិ ឈ្មោះថា* **កលហ :** *ការឈ្លោះ ។ ការពោលចាក់រុកគ្នា ឈ្មោះថា* **វិវាទ :** *ទាស់ពាក្យសំដី ។ ពួកភិក្ខុដែលដល់សេចក្តីវិវាទគ្នានោះ ឈ្មោះថា* **វិវាទបន្ន : *វិវាទគ្នា ។***

*បទថា* បេសុញ្ញំ **: ពាក្យញុះញង់** *បានដល់ វាចាស៊ិកសៀត ។ មានពាក្យអធិប្បាយថា វាចាដែលធ្វើឱ្យសាបសូន្យនូវសេចក្តីស្រឡាញ់រាប់អានគ្នា ។*

*បទថា* ភិក្ខុបេសុញ្ញេ **: *ព្រោះពោលពាក្យញុះញង់ភិក្ខុផងគ្នា*** *បានដល់ ព្រោះពាក្យស៊ិកសៀតដល់ភិក្ខុទាំងឡាយ, អធិប្បាយថា ព្រោះ*

ពាក្យសឹកសៀតដែលភិក្ខុស្តាប់ពីភិក្ខុហើយនាំចូលទៅប្រាប់ដល់ភិក្ខុ ។

[២៥៦] ពីរបទថា ទ្វីហាការេហិ : ដោយអាការពីរយ៉ាង បានដល់ ដោយហេតុ ២ យ៉ាង ។

បទថា បិយកម្យស្ស វា : ចង់ឱ្យគេស្រឡាញ់ខ្លួន ១ គឺ អ្នកប្រាថ្នាឱ្យគេស្រឡាញ់ខ្លួនថា "យើងនឹងជាទីស្រឡាញ់របស់អ្នកនេះ" យ៉ាងនេះ ១ ។

បទថា ភេទាធិប្បាយស្ស វា : ចង់បំបែកគេ ១ គឺ អ្នកប្រាថ្នាការប្រេះឆានៃមនុស្សម្នាក់និងមនុស្សម្នាក់ថា "អ្នកនេះនឹងបែកចេញពីអ្នកនេះ" ដោយអាការយ៉ាងនេះ ១ ។

បទទាំងពួង មានបទថា ជាតិតោបិ : ដោយជាតិក្តី ជាដើម មានន័យដូចពោលហើយក្នុងសិក្ខាបទមុននុ៎ះឯង ។ សូម្បីក្នុងសិក្ខាបទនេះ ជនទាំងអស់មានភិក្ខុនីជាដើម ក៏ឈ្មោះថា អនុបសម្បន្ន ។

[២៨៣] ពីរបទថា ន បិយកម្យស្ស ន ភេទាធិប្បាយស្ស : ដល់ភិក្ខុមិនចង់ឱ្យគេស្រឡាញ់ខ្លួន ដល់ភិក្ខុមិនប្រាថ្នាឱ្យគេបែកគ្នា មានសេចក្តីថា មិនមានអាបត្តិដល់ភិក្ខុដែលឃើញភិក្ខុមួយរូបកំពុងជេរ និងមួយរូបអត់ធន់បាន ហើយពោល ព្រោះខ្លួនជាអ្នកច្រើនតិះដៀលបុគ្គលអាក្រក់តែម្យ៉ាង ដោយទំនងនេះថា "ឱ បុគ្គលមិនអៀនខ្មាស នឹង

សម្គាល់អ្នកផ្សើល្អ ដូច្នេះថា ខ្ញុំនឹងគួរពោលបានជានិច្ច" ។ បទដែលនៅសល់មានអត្ថងាយយល់ទាំងអស់ ។

សិក្ខាបទនេះមានសមុដ្ឋាន ៣ កើតឡើងមកកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

បេសុញ្ញវាទសិក្ខាបទវណ្ណនា ចប់

# ៤. បទសោធម្មសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

## ពន្យល់អំពីការបង្រៀនធម៌ដោយបទ

[២៨៤] បទថា អបច្ចិតិស្សា បានដល់ អបច្ចិតិស្សវា : មិនកោតក្រែង អធិប្បាយថា កាលពួកឆព្វគ្គិយភិក្ខុពោលថា "ម្នាលឧបាសកទាំងឡាយ" សូម្បីពាក្យក៏មិនចង់ស្ដាប់ គឺ មិនអើពើ ។ ម្យ៉ាងទៀត សេចក្ដីថា មិនមានសេចក្ដីកោតក្រែង មិនប្រព្រឹត្តឱនលំទោន ។

បទថា អសភាគវុត្តិកា : ប្រព្រឹត្តមិនសមគួរ បានដល់ អ្នករស់នៅមិនត្រូវគ្នា; អធិប្បាយថា អ្នកមិនប្រព្រឹត្តឱ្យដូចជាពួកឧបាសកគួរប្រព្រឹត្តក្នុងពួកភិក្ខុ ។

ពាក្យថា បទសោ ធម្មំ វាចេយ្យ : បង្រៀនធម៌ជាបទ សេចក្ដីថា ឱ្យពោលធម៌ជាបទ ៗ រួមគ្នា (នឹងអនុបសម្បន្ន), អធិប្បាយថា ឱ្យពោល (ធម៌) ជាកោដ្ឋាស ៗ (ចំណែក ៗ) ។ ក៏ព្រោះបទដែលមានឈ្មោះថា កោដ្ឋាសនោះមាន ៤ យ៉ាង ; ដូច្នោះ ដើម្បីសម្ដែងបទទាំង ៤ យ៉ាងនោះ ទើបព្រះឧបាលីពោលទុកក្នុងបទភាជនៈ ថា បទំ អនុបទំ អន្វក្ខរំ អនុព្យញ្ជនំ ។

[២៨៦] បណ្ដាបទជាដើមនោះ បទ សំដៅយកគាថា មួយបាទ ។

អនុបទ សំដៅយកបាទទីពីរ ។ អនុអក្ខរៈ សំដៅយកអក្ខរៈមួយ ៗ ។

អនុព្យញ្ជនៈ សំដៅយកព្យញ្ជនៈខាងចុងដូចនិងព្យញ្ជនៈដើម ។ អ្នកសិក្សាគប្បីជ្រាបសេចក្តីផ្សេងគ្នា ក្នុងបទជាដើមនោះយ៉ាងនេះ គឺ អក្ខរៈណាមួយ ឈ្មោះថា អនុអក្ខរៈ, ប្រជុំអក្ខរៈ ឈ្មោះថា អនុព្យញ្ជនៈ, ប្រជុំអក្ខរៈនិងអនុព្យញ្ជនៈ ឈ្មោះ
ថា បទ, បទដំបូងក៏ឈ្មោះថា បទ ដែរ, បទទីពីរ ឈ្មោះថា អនុបទ ។

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា បទំ ណាម ឯកតោ បដ្ឋបេត្វា ឯកតោ ឱសារេន្តិ : ដែលហៅថា ជាបទនោះ គឺ ឧបសម្បន្ននិងអនុបសម្បន្នផ្តើមតាំងព្រមគ្នា បញ្ចប់ព្រមគ្នា តទៅ ៖

កាលភិក្ខុបង្រៀនធម៌ដែលជាប់ដោយគាថា ហើយផ្តើមមួយបទ ៗ នេះថា មនោបុព្វង្គមា ធម្មា ព្រមគ្នានឹងអនុបសម្បន្នហើយឱ្យចប់ក៏ព្រមគ្នា ។ សូម្បីភិក្ខុឱ្យពោលយ៉ាងនេះ ក៏គប្បីពិន័យបាចិត្តិយច្រើនតាមចំនួនបទ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អនុបទំ ណាម ធាដេក្កំ បដ្ឋបេត្វា ឯកតោ ឱសារេន្តិ : ដែលហៅថា ជាអនុបទនោះ គឺ ឧបសម្បន្ននិងអនុបសម្បន្នផ្តើមតាំងផ្សេងគ្នា បញ្ចប់ព្រមគ្នា តទៅ ៖

កាលព្រះថេរៈពោលថា មនោបុព្វង្គមា ធម្មា ដូច្នេះ សាមណេរ

ពោលបទនោះមិនទាន់ ទើបពោលបទទីពីរព្រមគ្នាថា មនោសេដ្ឋា មនោមយា ។ ភិក្ខុនិងសាមណេរទាំងពីររូបនេះ ឈ្មោះថា ផ្ដើមផ្ដេផ្ដងគ្នាឱ្យចប់ព្រមគ្នា ។ សូម្បីសម្រាប់ភិក្ខុដែលឱ្យពោលយ៉ាងនេះ ក៏គប្បីពិន័យបាចិត្តិយច្រើនតាមចំនួនអនុបទ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អន្វក្ខរំ ឆាម រូបំ អនិច្ចន្តិ វុច្ចមានោ រូតិ ឱបាតេតិ : ដែលហៅថា ជាអន្វក្ខរនោះ គឺ ឧបសម្បន្នប្រាប់អនុបសម្បន្នថា រូបំ អនិច្ចំ អនុបសម្បន្នទទួលថា រូ ព្រមគ្នាតទៅ ៖

ភិក្ខុទូន្មានសាមណេរថា នៃសាមណេរ លោកចូរថា "រូបំ អនិច្ចំ" ពោលព្រមគ្នាត្រឹមតែ រូ ប៉ុណ្ណោះ ហើយឈប់ ។ សូម្បីសម្រាប់ភិក្ខុដែលឱ្យពោលយ៉ាងនេះ ក៏គប្បីពិន័យបាចិត្តិយច្រើនតាមចំនួនអនុអក្ខរៈ ។ និងសូម្បីក្នុងគាថាព័ន្ធ បណ្ឌិតក៏រមែងបានន័យដូច្នេះដែរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អនុព្យញ្ជនំ ឆាម រូបំ អនិច្ចន្តិ វុច្ចមានោ វេទនា អនិច្ចាតិ សទ្ទំ និច្ឆារេតិ : ដែលហៅថា ជាអនុព្យញ្ជនៈនោះ គឺ ឧបសម្បន្នប្រាប់អនុបសម្បន្នថា រូបំ អនិច្ចំ អនុបសម្បន្នបញ្ចេញសំឡេង(ដោយរហ័ស)ថា វេទនា អនិច្ចា តទៅ ៖

សាមណេរឱ្យភិក្ខុបង្រៀនព្រះសូត្រនេះថា "រូបំ ភិក្ខវេ អនិច្ចំ

វេទនា អនិច្ចា” ជាដើម កាលព្រះថេរៈប្រាប់ថា រូបំ អនិច្ចំ ដូច្នេះ ក៏ថ្លែងវាចាពោល អនិច្ច បទនេះថា វេទនា អនិច្ចា ព្រមទឹងអនិច្ចបទរបស់ព្រះថេរៈថា រូបំ អនិច្ចំ នេះ ព្រោះជាអ្នកមានបញ្ញារហ័សរហួន ។ សូម្បីសម្រាប់ភិក្ខុដែលឱ្យបង្រៀនយ៉ាងនេះ ព្រះវិន័យធរក៏គប្បីពិន័យបាចិត្តិយច្រើន តាមចំនួនអនុព្យញ្ជនៈ ។ ចំណែកសេចក្តីសង្ខេបក្នុងបទទាំងនេះ មានដូច្នេះថា បណ្តាបទជាដើមនេះ ភិក្ខុពោលបទណា ៗ ព្រមគ្នា រមែងត្រូវអាបត្តិដោយបទនោះ ៗ ។

## ភាសិត ៤ មានពុទ្ធភាសិតជាដើម

វិន័យបិដកទាំងអស់ អភិធម្មបិដក ធម្មបទ ចរិយាបិដក ឧទានឥតិវុត្តកៈ ជាតកៈ សុត្តនិបាត វិមានវត្ថុ បេតវត្ថុ និងព្រះសូត្រទាំងឡាយមានព្រហ្មជាលសូត្រជាដើម ឈ្មោះថា ពុទ្ធភាសិត ។

ធម៌ដែលពួកសាវកដែលរាប់បញ្ចូលក្នុងបរិស័ទ ៤ សម្តែងទុកមានអនង្គណសូត្រ សម្មាទិដ្ឋិសូត្រ អនុមានសូត្រ ចូឡវេទល្លសូត្រ មហាវេទល្លសូត្រជាដើម ឈ្មោះថា សាវកភាសិត ។

ធម៌ដែលពួកបរិព្វាជកខាងក្រៅពោលទុក មានជាដើមយ៉ាងនេះ គឺបរិព្វាជកវគ្គទាំងអស់ ពាក្យបុច្ឆារបស់ព្រាហ្មណ៍ ១៦ នាក់ ដែលជាអន្តេវាសិករបស់ព្រាហ្មណ៍ឈ្មោះពាវរី ឈ្មោះថា ឥសិភាសិត ។

ធម៌ដែលពួកទេវតាពោលទុក ឈ្មោះថា ទេវតាភាសិត ។ ទេវតាភាសិតនោះ បណ្ឌិតគប្បីជ្រាបដោយអំណាចរឿង មានទេវតាសំយុត្ត ទេវបុត្តសំយុត្ត មារសំយុត្ត ព្រហ្មសំយុត្ត និងសក្កសំយុត្តជាដើម ។

បទថា អត្ថុបសញ្ហិតោ : ប្រកបដោយអត្ថ បានដល់ ធម៌ដែលអាស្រ័យអដ្ឋកថា ។

បទថា ធម្មុបសញ្ហិតោ : ប្រកបដោយធម៌ បានដល់ ធម៌ដែលអាស្រ័យព្រះបាលី ។

សូម្បីដោយបទទាំងពីរនេះ ព្រះឧបាលីពោលធម៌ដែលអាស្រ័យនិព្វាន ដែលប្រាសចាកវដ្តៈទុំះឯង ។ សូម្បីពោលដល់ធម៌ដែលអាស្រ័យនិព្វាន ដែលប្រាសចាកវដ្តៈ ក៏ដោយ, ក៏នៅតែជាអាបត្តិដល់ភិក្ខុអ្នកបង្រៀនធម៌ ដែលឡើងកាន់សង្គីតិទាំង ៣ ដង ដោយបទដូចគ្នា ។ មិនជាអាបត្តិសូម្បីក្នុងពាក្យដែលអាស្រ័យព្រះនិព្វាន ដែលលោករចនាទុកដោយចងជាពាក្យស្លោកជាដើម ដោយអំណាចភាសាផ្សេង ៗ ។ សូម្បីក្នុងសូត្រដែលមិនបានលើកឡើងកាន់សង្គីតិ ៣ ដង ដូច្នេះ គឺ កុលុម្ពសូត្រ រាជោវាទសូត្រ តិក្ខិន្ទ្រិយសូត្រ ចតុបរិវត្តសូត្រ និងនន្ទោបនន្ទសូត្រ ក៏ជាអាបត្តិដែរ សូម្បីការទូន្មានស្តេចនាគ ឈ្មោះថាអបលាលៈ អាចារ្យក៏ពោលទុក (ដោយអំណាចបង្កឱ្យកើតអាបត្តិ), តែក្នុងមហាបច្ចរីលោកបដិសេធ (ថា មិនជាអាបត្តិ) ។

ក្នុងបដិភាណរបស់ព្រះថេរៈ ក្នុងមេណ្ឌកមិលិន្ទបញ្ហា មិនជាអាបត្តិ ។ តែជាអាបត្តិក្នុងពាក្យដែលព្រះថេរៈនាំមកពោល ដើម្បីឱ្យព្រះរាជាទ្រង់យល់ព្រម ។

អាចារ្យទាំងឡាយពោលថា ក៏បករណ៍ទាំងឡាយមានជាដើម គឺវណ្ណបិដក អង្គុលិមាលបិដក រដ្ឋបាលគជ្ជិត អាឡវកគជ្ជិត គុឡ្ហឧម្មគ្គៈ គុឡ្ហវេស្សន្តរ គុឡ្ហវិន័យ វេទល្លបិដក[១] ជាដើម មិនជាពុទ្ធវចនពិត ។

អាចារ្យពួកខ្លះពោលថា ធម៌ឈ្មោះថា សីលូបទេស ព្រះធម្មសេនាបតីពោលទុក, ក្នុងធម៌នោះ ក៏ជាអាបត្តិដែរ នៅមានបករណ៍ដទៃទៀត ដូចមគ្គកថា អារម្មណកថា វុឌ្ឍិករណ្ឌកញ្ញាណវត្ថុ និងអសុភកថាជាដើម, ក្នុងបករណ៍ទាំងនោះ លោកចែកពោធិបក្ខិយធម៌ ៣៧ ទុក ។ ក្នុងធុតង្គបញ្ហា លោកចែកបដិបទាទុក, ព្រោះហេតុនោះ ទើបលោកពោលថា ជាអាបត្តិក្នុងបករណ៍ទាំងនោះ ។

តែក្នុងអដ្ឋកថា មហាបច្ចរីជាដើមលោកពោលអនាបត្តិទុក ក្នុងពួករាជោវាទសូត្រ តិក្ខិន្ទ្រិយសូត្រ ចតុបរិវត្តសូត្រ នន្ទោបនន្ទសូត្រ កុលុម្ពសូត្រ[២]នុ៎ះឯង ដែលមិនឡើងកាន់សង្គីតិ ហើយកំណត់អត្ថទុក ដូច្នេះថា បណ្តាពាក្យដែលនៅសល់ ពាក្យណាដែលលោកនាំមកអំពីពុទ្ធ

---

១-២ ជាព្រះសូត្រផ្នែកមហាយាន ។

វចនៈពោលទុកប៉ុណ្ណោះ ជាវត្ថុនៃអាបត្តិ ក្រៅអំពីនេះមិនជាអាបត្តិទេ ។

[២៨៨] ពាក្យថា ឯកតោ ឧទ្ទិសាបេន្តោ : ដល់ភិក្ខុរៀនបាលីជាមួយ មានសេចក្ដីថា ភិក្ខុសូម្បីរៀនបាលីរួមនឹងអនុបសម្បន្នពោលព្រមគ្នា មិនជាអាបត្តិ ។

ក្នុងពាក្យនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ឧបសម្បន្ន និងអនុបសម្បន្នអង្គុយហើយ សូមឱ្យអាចារ្យសូធ្យ, អាចារ្យគិតថា យើងនឹងសូធ្យដល់ឧបសម្បន្ន និងអនុបសម្បន្នទាំងពីរដែលអង្គុយហើយ ទើបសូធ្យព្រមគ្នានឹងលោកទាំងនោះ ។ ជាអាបត្តិដល់អាចារ្យ ជាអនាបត្តិដល់ភិក្ខុដែលរៀនយកព្រមនឹងអនុបសម្បន្ន ។ សូម្បីឧបសម្បន្ននិងអនុបសម្បន្នទាំងពីរដែលឈររៀន ក៏មានន័យយ៉ាងនេះដែរ, ភិក្ខុកម្លោះអង្គុយ សាមណេរឈរ, មិនជាអាបត្តិដល់អាចារ្យដែលប្រាប់ដោយគិតថា យើងនឹងពោលដល់ភិក្ខុដែលអង្គុយ ។ បើភិក្ខុកម្លោះឈរ ចំណែកសាមណេរអង្គុយ មិនជាអាបត្តិដល់អាចារ្យដែលពោលដោយគិតថា យើងនឹងពោលដល់ភិក្ខុដែលឈរ ។

បើមានសាមណេរមួយរូប អង្គុយនៅក្នុងចំណោមភិក្ខុជាច្រើនរូប ជាអចិត្តកាបត្តិដល់អាចារ្យអ្នកបង្រៀនធម៌ដោយបទ ព្រោះតែមានសាមណេរអង្គុយនៅផង ។

បើសាមណេរឈរ ឬអង្គុយលះឧបចារៈចេញ ព្រោះសាមណេរ

មិនរាប់បញ្ចូលនៅក្នុងពួកភិក្ខុ ដែលអាចារ្យបង្រៀន (ធម៌ដោយបទ) លោកទើបដល់ការរាប់ថា រៀនយកគម្ពីរគេចចេញទៅកាន់ទិសមួយ ; ព្រោះដូច្នោះ ទើបមិនជាអាបត្តិ (ដល់អាចារ្យ)

ពាក្យថា ឯកតោ សជ្ឈាយំ ករោន្តោ : ដល់ភិក្ខុស្វាធ្យាយជាមួយ មានសេចក្តីថា ឧបសម្បន្នកាលធ្វើការស្វាធ្យាយរួមគ្នានឹងអនុបសម្បន្ន សូធ្យព្រមគ្នានឹងអនុបសម្បន្ននោះឯង មិនជាអាបត្តិ ។ សូម្បីភិក្ខុរៀនឧទ្ទេសក្នុងសំណាក់នៃ អនុបសម្បន្ន សូធ្យរួមគ្នានឹងអនុបសម្បន្ននោះ ក៏មិនជាអាបត្តិ ។ ព្រោះថា សូម្បីឧបសម្បន្ននេះ ក៏ដល់ការរាប់ថា "ធ្វើការស្វាធ្យាយព្រមគ្នាពិត" ។

ពាក្យថា យេភុយ្យេន បគុណំ គន្ថំ ភណន្តំ ឱបាតេតិ : ដល់ភិក្ខុកំពុងសូធ្យគម្ពីរដែលស្ទាត់ជំនាញដោយច្រើន មានសេចក្តីថា បើក្នុងគាថា១ នៅមួយបាទដែលចាំមិនបាន បាទដែលនៅសល់ចាំបាន នេះឈ្មោះថា គម្ពីរដែលស្ទាត់ជំនាញដោយច្រើន ។ សូម្បីក្នុងព្រះសូត្រ អ្នកសិក្សាក៏គប្បីជ្រាបដោយន័យនេះ ។ មិនជាអាបត្តិដល់ភិក្ខុដែលរអាក់រអួលពាក់កណ្តាល ទើបសូធ្យសូម្បីព្រមគ្នាដោយពោលថា លោកចូរសូធ្យយ៉ាងនេះ ។

ពីរបទថា ឱសារេន្តំ ឱបាតេតិ : ពោលជាមួយនឹង(អនុបសម្ប

ន្ទ )កំពុងសូធ្យធម៌ មានសេចក្ដីថា មិនជាអាបត្តិដល់ភិក្ខុដែលពោលនឹងអនុបសម្បន្ន ដែលសូធ្យរអាក់រអួលកណ្ដាលបរិស័ទថា "លោកចូរសូធ្យយ៉ាងនេះ" ហើយសូធ្យសូម្បីព្រមគ្នានឹងអនុបសម្បន្ននោះ ។ ក៏ពាក្យណាដែលលោកពោលទុកក្នុងអដ្ឋកថាមហាបច្ចរីជាដើមថា ភិក្ខុណាដែលអនុបសម្បន្នពោលថា "លោកម្ចាស់ កុំសូធ្យជាមួយខ្ញុំអី" បើសូធ្យជាអាបត្តិ ដូច្នេះ ។ ពាក្យនោះ មិនមានក្នុងមហាអដ្ឋកថា ។ ក៏ភាវៈនៃពាក្យដែលលោកពោលទុកក្នុងអដ្ឋកថាមហាបច្ចរីជាដើមនោះ មិនមានឡើយ ត្រឹមត្រូវហើយ (ក៏សេចក្ដីដែលអាបត្តិមិនមានដល់ភិក្ខុនោះឡើយ ត្រឹមត្រូវហើយ) ។ ព្រោះហេតុអ្វី ? ព្រោះអាបត្តិកើតអំពីការធ្វើ ។ តែកាលមានការកាន់យកអត្ថក្រៅនេះ សិក្ខាបទនេះ គប្បីជាកិរិយានិងជាអកិរិយា បទដែលនៅសល់ក្នុងសិក្ខាបទនេះ មានអត្ថងាយយល់ទាំងអស់ ។

សិក្ខាបទនេះ ជាបទសោធម្មសមុដ្ឋាន កើតឡើងមកវាចា ១ វាចាចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បទសោធម្មសិក្ខាបទទី ៤ ចប់

# ៥. សហសេយ្យសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

## ពន្យល់រឿងព្រះនវកៈនិងសាមណេររាហុល

[២៨៩] ពីរបទថា មុដ្ឋស្សតី អសម្បជានា : ក៏ភ្លេចស្មារតី មិនដឹងខ្លួន នេះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចការមិនធ្វើសតិសម្បជញ្ញៈ ក្នុងបុព្វភាគ ។ ក៏ក្នុងកាលដែលចិត្តធ្លាក់ចុះកាន់ភវង្គ សតិសម្បជញ្ញៈនឹងមានមកពីណា ?

បទថា វិក្កុជ្ជមានា : ថ្ងូរ គឺ មមើមមាយ ។

បទថា កាកច្ឆមានា : ស្រមុក បានដល់ បញ្ចេញសំឡេងមិនមានអត្ថន័យ ដូចសំឡេងក្អែក តាមប្រមុះ ។

បទថា ឧបាសកា : ឧបាសកទាំងឡាយ បានដល់ ពួកឧបាសកដែលក្រោកឡើងមុន ។

[២៩០] ពីរបទថា ឯតទវោចុំ : បានពោលពាក្យនេះ មានសេចក្តីថា ភិក្ខុទាំងឡាយបានពោលពាក្យនេះថា “ម្នាលរាហុលដ៏មានអាយុ សិក្ខាបទព្រះមានព្រះភាគទ្រង់ត្រាស់បញ្ញត្តថា ភិក្ខុមិនត្រូវដេកជាមួយនឹងអនុបសម្បន្នទេ” ដូច្នេះ ដោយគោរពក្នុងសិក្ខាបទនោះតែម្តង ។ តែដោយប្រក្រតី ព្រោះសេចក្តីគោរពក្នុងព្រះមានព្រះភាគ និងព្រោះ

រាហុលជាអ្នកប្រាថ្នាក្នុងការសិក្សា ភិក្ខុទាំងនោះ កាលរាហុលនោះមកកាន់ទីលំនៅ ទើបក្រាលគ្រែតូច ៗ ឬបន្ទែកយ៉ាងណាមួយដែលមាន ហើយបត់ចីវរ ( សង្ឃាដិ ) ឬឧត្តរាសង្គៈ ដើម្បីឱ្យធ្វើជាគ្រឿងកើយសីសៈ ។ ក្នុងការដែលព្រះរាហុលជាអ្នកប្រាថ្នាក្នុងការសិក្សានោះ ( មានជាគ្រឿងសាធក ) ដូចតទៅនេះ ៖

បានឮថា ភិក្ខុទាំងឡាយ ឃើញរាហុលនោះ កំពុងដើរមកអំពីចម្ងាយ រមែងដាក់អំបោសនិងបង្គីចាក់សម្រាមទុកខាងក្រៅ ។ តមកកាលភិក្ខុពួកដទៃពោលថា "លោកដ៏មានអាយុ អ្នកណាយករបស់នេះមកដាក់ចោលអ៊ីចឹង" ដូច្នេះ ភិក្ខុមួយពួកទៀតពោលយ៉ាងនេះថា "លោកដ៏ចម្រើន រាហុលដើរតម្រង់មកក្នុងប្រទេសនេះ ប្រហែលជាលោកដាក់ចោលទេដឹង" ។ ចំណែកព្រះរាហុលនោះ មិនធ្លាប់និយាយសូម្បីក្នុងថ្ងៃមួយថា "នេះមិនមែនការធ្វើរបស់ខ្ញុំករុណាទេ" ប្រមូលទុកដាក់អំបោសជាដើមនោះហើយ សូមខមាទោសនឹងភិក្ខុទាំងឡាយជាមុន ទើបទៅ ។

ប្រេីនបទថា វច្ចកុដិយា សេយ្យំ កប្បេសិ : **ក៏ទៅសឹងក្នុងវច្ចកុដិ** មានសេចក្តីថា រាហុលនោះ បង្កើនទូវបំណងប្រាថ្នាក្នុងសិក្ខា ( អំពីភិក្ខុទាំងឡាយ ) នោះឯង ទើបមិនទៅកាន់លំនៅនៃព្រះធម្មសេនាបតី ព្រះមហាមោគ្គល្លាន និងព្រះអានន្ទជាដើម សម្រេចការដេកក្នុងវច្ចកុដិជាបន្ទន់របស់ព្រះមានព្រះភាគ ។ បានឮថា កុដិនោះ គេភ្ជាប់ទ្វារ

ទុក ធ្វើការប្រោះព្រំដោយរបស់ក្រអូប មានកម្រងផ្កាឈើព្យួរទុកពេញតាំងនៅដូចចេតិយស្ថាន មិនគួរដល់ការបរិភោគប្រើប្រាស់របស់ពួកមនុស្សដទៃ ។

ពីរបទថា ឧត្តរិទ្វិរត្តតិរត្តំ : លើជាងពីរយប់ឬបីយប់ឡើង មានសេចក្តីថា ព្រះមានព្រះភាគទ្រង់បានប្រទានបរិហារអស់ ៣ រាត្រី ដើម្បីត្រូវការធ្វើសេចក្តីសង្គ្រោះដល់ពួកសាមណេរ ។ ពិតមែន ការដែលភិក្ខុឱ្យពួកក្មេងក្នុងត្រកូលបួសហើយ មិនអនុគ្រោះ មិនសមគួរ ។

បទថា សហសេយ្យំ : នូវទីដេកជាមួយ គឺ ការដេករួមគ្នា ។ សូម្បីការដេក ពោលគឺ ការសណ្ដូកកាយ លោកហៅថា សេយ្យៈ ។ ភិក្ខុទាំងឡាយដេកក្នុងសេនាសនៈណា សូម្បីសេនាសនៈនោះ លោកហៅថា សេយ្យៈ ទីដេក ។ បណ្តាទីដេកពីរយ៉ាងនោះ ដើម្បីទ្រង់សម្តែងសេនាសនៈមុន ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា "សេយ្យា ណាម សព្វច្ឆន្នា : ដែលហៅថា ទីដេក គឺទីដែលគេប្រក់ទាំងអស់" ដូច្នេះ ។

[២៩១] ដើម្បីសម្តែងការសណ្ដូកកាយ ទើបត្រាស់ពាក្យថា "អនុបស ម្បន្នេ ណិបន្នេ ភិក្ខុ ណិបជ្ជតិ : កាលបើអនុបសម្បន្នដេក ភិក្ខុក៏នៅដេក" ជាដើម ។ ព្រោះដូច្នោះ ក្នុងពាក្យថា សេយ្យំ

កប្បេយ្យ : សម្រេចនូវទីដេក នេះ មានសេចក្ដីដូច្នេះថា ភិក្ខុចូលទៅកាន់ទីដេក ពោលគឺ សេនាសនៈ គប្បីសម្រេច គឺ គប្បីចាត់ចែង បាន ដល់ ញុំាងការដេក គឺ ការលាតកាយឱ្យសម្រេច ។

## អធិប្បាយលក្ខណៈនៃទីដេក គឺសេនាសនៈផ្សេងៗគ្នា

ក៏ដោយបទថា សព្វច្ឆន្នា : ប្រក់ទាំងអស់ ជាដើម ព្រះមានព្រះភាគត្រាស់លក្ខណៈនៃទីដេក ពោលគឺ សេនាសនៈនោះ ។ ព្រោះហេតុនោះ សេនាសនៈណាប្រក់ទាំងអស់តែម្ដង ក្នុងខាងលើដោយគ្រឿងប្រក់ ៥ ប្រភេទ ឬដោយវត្ថុណាមួយ ដទៃ ក៏ដោយ, ទីដេកនេះ ឈ្មោះថា ប្រក់ទាំងអស់ ។ តែក្នុងអដ្ឋកថាទាំងឡាយ លោកកាន់យកវោហារដែលប្រាកដ ពោលដោយអំណាចពាក្យស្ទាត់មាត់ថា ទីដេកដែលប្រក់ដោយគ្រឿងប្រក់ ៥ ប្រភេទ ឈ្មោះថា ប្រក់ទាំងអស់ ដូច្នេះ សូម្បីលោកពោលពាក្យនោះទុកហើយក៏ដោយ, ក៏នៅតែមិនអាចធ្វើឱ្យមិនជាអាបត្តិសូម្បីដល់ភិក្ខុដែលនៅក្នុងកុដិសំពត់បាន, ព្រោះដូច្នោះ អ្នកសិក្សា គប្បីជ្រាបគ្រឿងប្រក់ និងគ្រឿងបាំងក្នុងសិក្ខាបទនេះ ប្រភេទណាមួយ ដែលអាចបិទបាំងបាន ។

ពិតមែន កាលកាន់យកគ្រឿងប្រក់ ៥ ប្រភេទប៉ុណ្ណោះ ការដេករួមក្នុងកុដិ សូម្បីដែលប្រក់ដោយបន្ទះក្ដារ ក៏មិនគប្បីមាន ។ ក៏

សេនាសនៈណា ដែលគេបិទបាំងតាំងពីផែនដីដរាបទល់ដំបូល ដោយកំពែង ឬដោយវត្ថុណាមួយដទៃក៏ដោយ ដោយហោចទៅ សូម្បីដោយសំពត់, ទីដេកនេះ គប្បីជ្រាបថា ឈ្មោះថា បាំងទាំងអស់ ។

លោកពោលទុកក្នុងអដ្ឋកថា កុរុន្ទីថា ទីដេកសូម្បីដែលគេបិទបាំងដោយជញ្ជាំងមានកំពែងជាដើម កម្ពស់ ១ ហត្ថ ១ ចំអាម ដោយបរិយាយយ៉ាងទាបបំផុតមិនប៉ះដំបូល ចាត់ថា បាំងទាំងអស់ដូចគ្នា ។ ក៏ព្រោះទីដែលប្រក់ខាងលើច្រើនជាង ដែលមិនបានប្រក់តិច ឬថា ទីដែលគេបិទបាំងដោយជុំវិញច្រើនជាង ដែលមិនបានបិទបាំងតិច ; ដូច្នោះ ទីដេកនេះ ទើបឈ្មោះថា ប្រក់ដោយច្រើន បិទបាំងដោយច្រើន ។

ក៏ប្រាសាទដែលប្រកបដោយលក្ខណៈយ៉ាងនេះ ប្រសិនបើថា មានដល់ ៧ ជាន់ មានឧបចារជាមួយគ្នា ឬថា សាលាមុខ ៤ មានបន្ទប់រាប់រយ ក៏រាប់ថា ទីដេកជាមួយគ្នាពិត ។ ព្រះមានព្រះភាគទ្រង់ សំដៅដល់ទីដេកនោះ ទើបត្រាស់ពាក្យមានជាដើមថា “កាលបើព្រះអាទិត្យក្នុងថ្ងៃជាគម្រប់ ៤ អស្តង្គតទៅហើយ កាលបើអនុបសម្បន្នដេក ភិក្ខុក៏នៅដេក ត្រូវអាបត្តិបាចិត្តិយ” ដូច្នេះ ។ និងជាបាចិត្តិយ ដោយត្រឹមតែដេកលើទីដេកនោះ ប៉ុណ្ណោះ ។

ក៏បើថា មានសាមណេរច្រើនរូប ភិក្ខុតែមួយរូប ជាបាចិត្តិយច្រើនតាមចំនួនសាមណេរ, ប្រសិនបើថា សាមណេរទាំងនោះក្រោក

ដេក ៗ ភិក្ខុត្រូវអាបត្តិគ្រប់ ៗ ប្រយោគ( នៃការដេក )របស់សាមណេរទាំងនោះ ។ ក៏ដោយករក្រោកដេក ៗ របស់ភិក្ខុ ជាអាបត្តិដល់ភិក្ខុព្រោះប្រយោគ( នៃការដេក )របស់ភិក្ខុនុ៎ះឯង ។

បើភិក្ខុច្រើនរូប សាមណេរតែមួយរូប, សាមណេរមួយរូបនោះក៏ធ្វើឱ្យជាអាបត្តិដល់ភិក្ខុទាំងអស់ ។ សូម្បីដោយករក្រោកដេក ៗ របស់សាមណេរនោះ ក៏ជាអាបត្តិដល់ភិក្ខុទាំងឡាយដែរ ។ ចំណែកក្នុងការក្រោកដេក ៗ របស់ភិក្ខុនិងសាមណេរច្រើនទាំងពីរផ្នែក ក៏មានន័យដូចគ្នា ។

## អធិប្បាយចតុក្កៈ ៤ មានអាវាសចតុក្កៈជាដើម

ន័យមួយទៀត ក្នុងសិក្ខាបទនេះ គប្បីជ្រាបចតុក្កៈ សូម្បីមានអាវាសមួយជាដើម ។ សេចក្តីពិស្តារថា ភិក្ខុណា សម្រេចការដេករួមគ្នានឹងអនុបសម្បន្នត្រឹមតែម្នាក់ក្នុងអាវាសមួយ អស់ ៣ រាត្រី, ចាប់ផ្តើមតាំងពីថ្ងៃទី ៤ ជាអាបត្តិរាល់ថ្ងៃ ដល់ភិក្ខុនោះ, ចំណែកភិក្ខុណាសម្រេចការដេករួមអស់ ៣ រាត្រី ជាមួយនឹងអនុបសម្បន្នផ្សេងគ្នាច្រើននាក់ ក្នុងអាវាសមួយនុ៎ះឯង ជាអាបត្តិរាល់ថ្ងៃដល់ភិក្ខុនោះ (ចាប់តាំងពីថ្ងៃទី ៤ ), សូម្បីភិក្ខុណាសម្រេចការដេករួម អស់ ៣ រាត្រី នឹងអនុបសម្បន្នត្រឹមតែម្នាក់ប៉ុណ្ណោះ ក្នុងអាវាសផ្សេង ៗគ្នា ជាអាបត្តិរាល់

ថ្ងៃ ដល់ភិក្ខុនោះ (ចាប់ផ្ដើមតាំងពីថ្ងៃទី ៤) ។ សូម្បីភិក្ខុណា ធ្វើដំណើរអស់ចម្ងាយ ១០០ យោជន៍ សម្រេចការដេករួម (អស់ ៣ រាត្រី) នឹងអនុបសម្បន្នផ្សេងគ្នាច្រើននាក់ ក្នុងអាវាសផ្សេង ៗ ជាអាបត្តិដល់ភិក្ខុនោះរាល់ថ្ងៃ រាប់ពីថ្ងៃទី ៤ ទៅ ។

ក៏ឈ្មោះថា សហសេយ្យាបត្តិនេះ រមែងមានសូម្បីជាមួយសត្វតិរច្ឆាន ព្រោះព្រះបាលីថា វៀរលែងតែភិក្ខុចេញ ក្រៅអំពីនោះ ជាអនុបសម្បន្នទាំងអស់ ។ ក្នុងសហសេយ្យាបត្តិនោះ ការកំណត់សត្វតិរច្ឆាន គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងមេថុនធម្មាបត្តិនុ៎ះឯង ។ ព្រោះហេតុនោះ ប្រសិនបើថា បណ្ដាសត្វតិរច្ឆានជើង ៤ មានទន្សង ឆ្មា និងត្រកួតជាដើម តិរច្ឆានខ្វះចូលទៅដេកនៅក្នុងទីមានឧបចារជាមួយគ្នាក្នុងសេនាសនៈជាទីនៅរបស់ភិក្ខុ ចាត់ជាការដេករួមដូចគ្នា ។ បើថា វាចូលទៅមកប្រហោងរនូត ធ្នឹម មានប្រហោងដែលតាំងនៅខាងលើជញ្ជាំងនៃប្រាសាទ ដែលគេសាងទុកខាងលើសសរទាំងឡាយដែលមានជញ្ជាំងមិនជាប់តគ្នានឹងផ្ទៃជាន់លើ ហើយដេកនៅខាងក្នុងឈើធ្នឹម ចេញទៅតាមប្រហោងធ្នឹមនោះឯង ; មិនជាអាបត្តិដល់ភិក្ខុដែលដេករួមខាងក្រោមប្រាសាទ ។

បើមានប្រហោងលើដំបូល វាចូលទៅតាមប្រហោងនោះ នៅខាងក្នុងដំបូលហើយចេញទៅតាមប្រហោងពីដើមនោះឯង, ជាអាបត្តិដល់ភិក្ខុ

ដែលដេករួមខាងក្នុងជំបូល ជាផ្ទៃជាន់លើដែលមានឧបចារផ្សេងគ្នា, មិនជាអាបត្តិដល់ភិក្ខុដែលដេកក្នុងផ្ទៃជាន់ក្រោម ។ បើពួកភិក្ខុឡើងតាមផ្នែកខាងក្នុងប្រាសាទទាំងនោះ ប្រើប្រាស់ផ្ទៃទាំងអស់, ផ្ទៃទាំងអស់មានឧបចារតែមួយ, ជាអាបត្តិដល់ភិក្ខុដែលដេកលើផ្ទៃណាមួយ បណ្ដាផ្ទៃទាំងអស់នោះ ។

ភិក្ខុដេកក្នុងសេនាសនៈដែលមានជញ្ជាំងជាបង្ហា ដែលសាងដោយអាការដូចទីងសភា សត្តព្រាបជាដើម ចូលទៅដេកនៅក្នុងទីទាំងឡាយ មានរូបដែលធ្វើជារូបសត្វសាហាវជាដើម ជាអាបត្តិដូចគ្នា ។ សត្វព្រាបជាដើម ដេកខាងក្នុងជាយស្បូវដែលលយចេញទៅខាងក្រៅគ្រឿងឡោមព័ទ្ធ (ជញ្ជាំងឥដ្ឋយាំង) មិនជាអាបត្តិ ។ ប្រសិនបើជាសេនាសនៈរាងមូល ឬ បួនជ្រុង មានបន្ទប់មួយរយ ដោយជុំវិញបន្ទប់ដែលមានជំបូលជាមួយគ្នា ។ បើពួកភិក្ខុចូលទៅក្នុងសេនាសនៈនោះតាមទ្វារសាធារណៈ មួយហើយ ឆ្លងកាត់ចូលទៅក្នុងបន្ទប់ទាំងអស់ដែលមានឧបចារបន្ទប់ មិនបានបិទបាំងដោយកំពែងផ្សេងដទៃ, កាលអនុបសម្បន្ន ដេកហើយ សូម្បីក្នុងបន្ទប់មួយ ក៏ជាអាបត្តិដល់ភិក្ខុទាំងឡាយ ដែលដេកក្នុងគ្រប់ ៗ បន្ទប់ ។

បើបន្ទប់ទាំងឡាយមានយ៉មុខ, និងយ៉មុខមិនបានប្រក់ខាងលើ, ប្រសិនបើជា ជាកន្លែងមានផ្ទៃដីខ្ពស់, អនុបសម្បន្នដេកនៅយ៉មុខ មិន

ធ្វើឱ្យជាអាបត្តិដល់ភិក្ខុទាំងឡាយអ្នកដេកក្នុងបន្ទប់ ។ តែបើថា យ៉មុខមានជំបូលតជាប់គ្នានឹងជំបូលនៃបន្ទប់តែម្តង, អនុបសម្បន្នដេកនៅយ៉មុខនោះ ធ្វើឱ្យជាអាបត្តិដល់ភិក្ខុគ្រប់រូប, ព្រោះហេតុអ្វី ? ព្រោះជាបន្ទប់ប្រក់ទាំងអស់ និងបិទបាំងទាំងអស់ ។ ពិតមែន ជញ្ជាំងបិទបាំងបន្ទប់នុ៎ះឯង ជាជញ្ជាំងបិទបាំងយ៉មុខនោះផង ។ សមពិតដោយន័យនេះឯង ក្នុងអដ្ឋកថាទាំងឡាយលោកអាចារ្យ ទើបពិន័យអាបត្តិទុក ក្នុងស៊ុមទ្វារទាំង ៤ នៃជញ្ជាំងឃាំង (ជញ្ជាំងឥដ្ឋ)លោហប្រាសាទ ។ តែពាក្យណាដែលលោកពោលទុក ក្នុងអដ្ឋកថាអន្ធកៈថា "ពាក្យថា ក្នុងយ៉មុខដែលមិនបានបិទបាំង ជាអនាបត្តិ" លោកពោលសំដៅយកយ៉មុខលើផ្ទៃក្រៅអំពីផែនដី ដូច្នេះ, ពាក្យនោះ លោកពោលសំដៅយកបន្ទប់ជួរដែលមានជំបូលជាមួយគ្នា ដែលសាងទុកជាសង្កាត់ផ្សេងដទៃ ក្នុងដែនអន្ធកៈ ក៏ពាក្យដែលលោកពោលទុកថា "លើទីផ្ទៃក្រៅអំពីផែនដី" ក្នុងអដ្ឋកថាអន្ធកៈនោះ មិនមានក្នុងអដ្ឋកថាទាំងឡាយឡើយ ទាំងមិនសមដោយព្រះបាលី ។ សេចក្តីពិត ផែនដីសូម្បីខ្ពស់ដល់ ១០ ហត្ថ ក៏មិនដល់ការរាប់ថា ជាជញ្ជាំងបិទបាំងបាន ។ ព្រោះដូច្នោះ សូម្បីពាក្យណា ដែលលោកពោលប្រមាណនៃផែនដីទុកក្នុងសិក្ខាបទទី ២ ក្នុងអដ្ឋកថាអន្ធកៈនោះ ហើយពោលថា "ឋាន ពោលគឺ ផែនដីនោះ ឈ្មោះថា បិទបាំងដោយឧបចារជាមួយគ្នា" ដូច្នេះ, ពាក្យនោះ បណ្ឌិតមិនគួរកាន់

យក ។

មហាប្រាសាទណា ដែលមានទ្រង់ទ្រាយជាសាលាមួយខ្នង ២ខ្នង ៣ខ្នង និង ៤ខ្នង, ភិក្ខុលាងជើងក្នុងឱកាសមួយហើយ ចូលទៅ អាចដើរវិលជុំវិញទៅបានគ្រប់កន្លែង, សូម្បីក្នុងមហាប្រាសាទទាំងនោះ ភិក្ខុរមែងមិនផុតពីសហសេយ្យាបត្តិ ។ បើថា មហាប្រាសាទជាទីដែលគេសាងកំណត់ឧបចារទុកក្នុងទីនោះ ៗ, ជាអាបត្តិចំពោះក្នុងទីមានឧបចារជាមួយគ្នាប៉ុណ្ណោះ ។

ពួកជាងធ្វើកំពែងបាំងពាក់កណ្ដាលនៃមណ្ឌប ដែលមានដំបូលបូកដោយបាយអប្រកបដោយទ្វារពីរ អនុបសម្បន្នចូលទៅតាម ទ្វារមួយដេកនៅក្នុងកន្លែងមួយ និងភិក្ខុដេកនៅក្នុងកន្លែងមួយ មិនជាអាបត្តិ ។ ក្នុងកំពែងមានប្រហោងល្មមសត្វតិរច្ឆានមានទន្សងជាដើមចូលទៅបានពួកទន្សងដេកនៅក្នុងកន្លែងមួយ, មិនជាអាបត្តិដូចគ្នា ព្រោះផ្ទះមិនឈ្មោះថា មានឧបចារតែមួយដោយប្រហោងទេ, បើថា ពួកជាងបោះត្រង់កណ្ដាលកំពែង ហើយប្រកបទ្វារទុក ជាអាបត្តិ ព្រោះជាទីមានឧបចារជាមួយគ្នា ។ ភិក្ខុទាំងឡាយ បិទសន្លឹកទ្វារនោះហើយដេក ជាអាបត្តិដូចគ្នា ។ ព្រោះការបិទទ្វារ ផ្ទះនឹងឈ្មោះថា មានឧបចារផ្សេងគ្នា ឬទ្វារនឹងឈ្មោះថា មិនមែនទ្វារមិនមានឡើយ ។ ព្រោះទ្វារគេធ្វើទុកដើម្បីប្រយោជន៍សម្រាប់ប្រើប្រាស់ ដោយករបិទបើកបានតាមសប្បាយ មិន

មែនធ្វើដើម្បីត្រូវការនឹងកាត់ការប្រើប្រាស់ ។ ក៏បើថា ភិក្ខុទាំងឡាយយកឥដ្ឋទាំងឡាយបិទទ្វារនោះដដែលទៀត មិនចាត់ថា ជាទ្វារមែងតាំងនៅក្នុងភាវៈដែលមានឧបចារផ្សេង ៗគ្នា ដូចដើមនុ៎ះឯង ។

ព្រះចេតិយមានឃ៉ុមខ្វែង ទ្វារមួយនៅខាងក្នុង, មួយនៅខាងក្រៅ, អនុបសម្បន្នដេកក្នុងចន្លោះទ្វារទាំងពីរ រមែងធ្វើឱ្យជាអាបត្តិដល់ភិក្ខុដែលដេកខាង ក្នុងផ្ទះចេតិយ ព្រោះមានឧបចារជាមួយគ្នា ។

មានពាក្យចោទថា ក្នុងពាក្យថា **ឌីឃបមុខំ : មានឃ៉ុមខ្វែង** ជាដើមនោះ អាចារ្យអ្នកចោទណាគប្បីមានសេចក្តីប្រាថ្នាដូច្នេះថា ឈ្មោះថាទីដែលមានឧបចារជាមួយគ្នា និងមានឧបចារផ្សេងគ្នានេះ ព្រះមានព្រះភាគត្រាស់ទុកហើយក្នុងឧទ្ទេសិតសិក្ខាបទ, តែក្នុងសិក្ខាបទនេះ ព្រះមានព្រះភាគត្រាស់ពាក្យត្រឹមតែប៉ុណ្ណេះថា "ដែលហៅថា ទីដេក គឺទីដេក ដែលគេប្រក់ទាំងអស់ ដែលគេបិទបាំងទាំងអស់ ដែលគេប្រក់ដោយច្រើន ដែលគេបិទបាំងដោយច្រើន" ដូច្នេះប៉ុណ្ណោះ, មួយទៀត បន្ទប់ដែលបិទទ្វារហើយ ចាត់ថា បិទបាំងទាំងអស់ដូចគ្នា; ព្រោះហេតុនោះ ក្នុងចេតិយនោះ ទើបជាអាបត្តិដល់ភិក្ខុដែលដេករួមនឹងអនុបសម្បន្នដែលដេកខាងក្នុងប៉ុណ្ណោះ, មិនជាអាបត្តិដល់ភិក្ខុដែលដេករួមនឹងអនុបសម្បន្នដែលដេកខាងក្រៅ ។

អាចារ្យអ្នកចោទនោះ ដែលសកវាទីគប្បីពោលជំទាស់យ៉ាងនេះថា "ក៏ក្នុងព្រះចេតិយដែលមិនបិទទ្វារ ហេតុអ្វី ទើបជាអាបត្តិដល់ភិក្ខុដែលដេករួមទីងអនុបសម្បន្នដែលដេកក្នុងខាងក្រៅហ្នំ ?" ។

អាចារ្យអ្នកចោទ នឹងគប្បីឆ្លើយថា "ព្រោះយ៉មុខនឹងបន្ទប់ជាទីប្រក់ទាំងអស់" ។

សកវាទីសួរថា ក៏កាលបិទបន្ទប់ហើយ ដំបូលរុះរើចេញបានឬ ?

អាចារ្យអ្នកចោទឆ្លើយថា រុះរើចេញមិនបាន, ព្រោះយ៉មុខនឹងបន្ទប់បិទបាំងទាំងអស់ ទើបរើមិនបាន ។

សកវាទីសួរថា ជញ្ជាំងឥដ្ឋបិទបាំង (យ៉មុខ) រុះរើចេញបានឬ ? អាចារ្យដែលចោទនឹងពោលពិតប្រាកដថា រុះរើចេញមិនបាន (ព្រោះ) ឧបចារបិទបាំងទុកដោយសន្លឹកទ្វារ ។ អាចារ្យអ្នកចោទនឹងដំណើរទៅឆ្ងាយសែនឆ្ងាយ ដោយន័យយ៉ាងនេះហើយ នឹងបែរត្រឡប់មករកសេចក្តីមានឧបចារជាមួយគ្នា និងឧបចារផ្សេងគ្នានុ៎ះឯងទៀត ។

ន័យមួយទៀត ប្រសិនបើថា យល់សេចក្តីបានឆាយ ដោយហេតុត្រឹមតែព្យញ្ជនៈតែម្យ៉ាងសោត, ទីដេកប្រក់ដោយគ្រឿងប្រក់ ៥ ប្រភេទ ណាមួយប៉ុណ្ណោះ ទើបចាត់ជាទីដេកបាន ព្រោះព្រះបាលីថា "ប្រក់ទាំងអស់", ទីដេកប្រក់ដោយគ្រឿងប្រក់យ៉ាងដទៃ មិនគប្បីមាន

ទេ ។ បើដូច្នោះ ក៏មិនគប្បីជាអាបត្តិក្នុងទីដេកដែលប្រក់ដោយបន្ទះក្តារជាដើម ។ ព្រោះមិនមានភាពជាអាបត្តិនោះ សិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តទុកដើម្បីប្រយោជន៍យ៉ាងណា, ប្រយោជន៍យ៉ាងនោះឯងគប្បីវិនាសទៅ ។ នឹងខូចប្រយោជន៍យ៉ាងនោះទៅឬមិនខូចក៏ដោយ; ហេតុដូចម្តេច នឹងទៅកាន់យកពាក្យដែលព្រះមានព្រះភាគ មិនបានត្រាស់ទុកហ្ន៎ ? ឬថា អ្នកណាហ្ន៎ពោលថា គួរជឿកាន់ពាក្យដែលព្រះមានព្រះភាគ មិនបានត្រាស់ទុក ។ ពិតមែន ព្រះមានព្រះភាគត្រាស់ពាក្យនេះទុកក្នុងអនិយតសិក្ខាបទទាំងពីរថា "ដែលហៅថា អាសនៈកំបាំង គឺអាសនៈ ដែលបិទបាំងដោយជញ្ជាំងក្តី ដោយសន្ទះទ្វារក្តី ដោយកន្ទេលផែងក្តី ដោយករពន្លព័ទ្ធរាំងននបាំងក្តី ដោយឈើក្តី ដោយសសរក្តី ដោយស៊ុមក្តី ឬដោយវត្ថុឯណានីមួយក្តី"[១] ដូច្នេះ ។

ព្រោះដូច្នោះ ក្នុងអនិយតសិក្ខាបទនោះ លោកកាន់យកអាសនៈដែលគេបិទបាំងដោយវត្ថុឯណានីមួយ យ៉ាងណា, សូម្បីក្នុងសិក្ខាបទនេះ បណ្ឌិតក៏គប្បីកាន់យកសេនាសនៈនោះ យ៉ាងនោះ ។ ព្រោះហេតុនោះ សេនាសនៈណា ៗ ទោះជាតូចឬធំក៏ដោយ ជាប់ ឬមិនជាប់ដោយវត្ថុដទៃក៏ដោយ វែង ឬមូល ឬ ៤ជ្រុងក៏ដោយ មានផ្ទៃតែមួយជាន់ ឬ

---

១. វិន. អនិ. បឋិច្ឆន្នាសនសិក្ខាបទ. ២. ៣៣៣/៣៥៤ ។

មានផ្ទៃច្រើនជាន់ក៏ដោយ ដែលមានឧបចារជាមួយគ្នា, ជាសហសេយ្យាបត្តិក្នុងសេនាសនៈនោះ ៗ ទាំងអស់ ដែលប្រក់ទាំងអស់ បាំងទាំងអស់ ឬប្រក់ដោយច្រើន បិទបាំងដោយច្រើន ដោយគ្រឿងបិទបាំងណាមួយ ។

ក្នុងពាក្យថា "ប្រក់ពាក់កណ្ដាល បិទបាំងពាក់កណ្ដាល ត្រូវអាបត្តិទុក្កដ" នេះ ក្នុងមហាបច្ចរីក៏ពោលថា ជាទុក្កដដូចគ្នា សូម្បីក្នុងពាក្យ មានជាដើមយ៉ាងនេះថា "ប្រក់ទាំងអស់ បិទបាំងពាក់កណ្ដាល" ។ តែក្នុងមហាអដ្ឋកថាពោលថា "ក្នុងសេនាសនៈដែលប្រក់ទាំងអស់ បិទបាំងដោយច្រើន ជាបាចិត្តិយ ក្នុងសេនាសនៈប្រក់ទាំងអស់ បិទបាំងពាក់កណ្ដាល ជាបាចិត្តិយ, ប្រក់ដោយច្រើន បិទបាំងពាក់កណ្ដាលជាបាចិត្តិយ, បាំងទាំងអស់ ប្រក់ដោយច្រើន ជាបាចិត្តិយ, បិទបាំងទាំងអស់ ប្រក់ពាក់កណ្ដាលជាបាចិត្តិយ, បិទបាំងដោយច្រើន ប្រក់ពាក់កណ្ដាល ជាបាចិត្តិយ, ទើបជាបាចិត្តិយ ៧ រួមជាមួយបាចិត្តិយដែលត្រាស់ទុកក្នុងបាលី" ។ (ក្នុងមហាអដ្ឋកថា) ពោលថា "ក្នុងសេនាសនៈប្រក់ទាំងអស់ បិទបាំងបន្តិចបន្តួច ជាទុក្កដ, ប្រក់ដោយច្រើន បិទបាំងបន្តិចបន្តួច ជាទុក្កដ, បាំងទាំងអស់ ប្រក់បន្តិចបន្តួច ជាទុក្កដ, បាំងដោយច្រើន ប្រក់បន្តិចបន្តួច ជាទុក្កដ, ទើបជាអាបត្តិទុក្កដ ៥ រួមនឹងទុក្កដក្នុងបាលី" ក្នុងសេនាសនៈដែលប្រក់ពាក់កណ្ដាល បាំងបន្តិច

បន្ទួចជាអនាបត្តិ, ប៉ាំងពាក់កណ្តាល ប្រក់បន្តិចបន្តួច ជាអនាបត្តិ, ប្រក់បន្តិចបន្តួច ប៉ាំងបន្តិចបន្តួច ជាអនាបត្តិ ។

ក៏ក្នុងពាក្យថា "ក្នុងស្ថានទីប្រក់ទាំងអស់ មិនបិទប៉ាំងទាំងអស់" នេះ លោកពោលថា "មានសេចក្តីប្រាថ្នាយកមណ្ឌបសម្រាប់ប្រជុំគ្នា" ។ ផែនដី រមែងមិនដល់ការរាប់ថា ជាគ្រឿងឡោមព័ទ្ធបាន យ៉ាងណា, សូម្បីដោយពាក្យថា "ក្នុងទីប្រក់ទាំងអស់ មិនបិទប៉ាំងទាំងអស់" នេះ បណ្ឌិតក៏គប្បីជ្រាបពាក្យថា "ផែនដី មិនដល់ការរាប់ថា ជាគ្រឿងឡោមព័ទ្ធបាន"នេះ ដូច្នោះ ។ បទដែលនៅសល់មានអត្ថងាយយល់ទាំងអស់ទុះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ កើតឡើងមកកាយ ១ កាយចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សហសេយ្យសិក្ខាបទវណ្ណនា ចប់

# ៦. ទុតិយសហសេយ្យសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងទុតិយសហសេយ្យសិក្ខាបទ ដូចតទៅនេះ ៖

## ពន្យល់រឿងព្រះអនុរុទ្ធ

[២៩៤] បទថា អាវសថាគារំ : អាគារសម្រាប់សំណាក់ បានដល់ ផ្ទះសម្រាប់ស្នាក់នៅរបស់ពួកអាគន្តុកៈ ។

ពីរបទថា បញ្ញត្តំ ហោតិ : បានសង់ទុកហើយ បានដល់ ជាស្ថានទីដែលនាងចាត់សាងទុក ព្រោះជាអ្នកប្រាថ្នាបុណ្យ ។

ពាក្យថា យេន សា ឥត្ថី តេនុបសង្កមិ : ចូលទៅរកស្រីនោះ មានសេចក្ដីថា ព្រះអនុរុទ្ធៈស្ដាប់ពាក្យរបស់ពួកអ្នកស្រុកថា "មានផ្ទះសំណាក់ គេចាត់ចែងទុកក្នុងទីឈ្មោះឯណោះ" ដូច្នេះ ទើបចូលទៅរក ។

បទថា គន្ធគន្ធិនី : ជាស្រីមានក្លិនក្រអូប មានវិគ្រោះថា ក្លិនរបស់ក្រអូប មានក្រឹស្នា និងកំញានជាដើម ឈ្មោះថា ក្លិនរបស់ក្រអូប, ក្លិនរបស់ក្រអូបនោះ មានដល់ស្រីនោះ ; ហេតុនោះ ស្រីនោះទើបឈ្មោះថា គន្ធគន្ធិនី : អ្នកមានក្លិនក្រអូប ។

ពីរបទថា  សាដកំ  និក្ខិបិត្វា  :  ដាក់សំពត់សាដកទាំងអស់ផុតចេញ  មានសេចក្តីថា  ស្រីនោះគិតថា  ធ្វើដូចម្តេចហ្ន៎  កាលលោកម្ចាស់នោះ  ឃើញសភាពដែលប្លែកសូម្បីនេះឯង  គប្បីកើតសេចក្តីតម្រេកដូច្នេះ  ទើបបានធ្វើយ៉ាងនោះ ។

បទថា  ឱក្ខិបិត្វា  :  ក៏សង្រួម  បានដល់  ដាក់ចុះ  (នូវឥន្ទ្រិយ) ។

សេចក្តីខុសឆ្គាំឆ្គង  ឈ្មោះថា  ទោសកំហុស ។

ពីរបទថា  មំ  អច្ចគ្គមា  :  ខ្ញុំព្រះករុណា  ជាស្រីមានកំហុស  បានដល់  ប្រព្រឹត្តកន្លង  គឺ  គ្របសង្កត់នូវខ្ញុំព្រះករុណា ។  បទដែលនៅសល់បណ្ឌិតគប្បីជ្រាបដោយន័យដូចពោលហើយ  ក្នុងសិក្ខាបទមុននុ៎ះឯង ។ ក៏សេចក្តីប្លែកគ្នា  មានត្រឹមតែយ៉ាងនេះ  គឺ  ក្នុងសិក្ខាបទមុនជាអាបត្តិ  ក្នុងថ្ងៃទី  ៤,  ក្នុងសិក្ខាបទនេះ  ជាអាបត្តិសូម្បីក្នុងថ្ងៃដំបូង ។  ជាទុក្កដ (ដល់ភិក្ខុដែលដេករួមគ្នា)  ទីងនាងយក្ខទីងនាងប្រេតដែលមានរូបប្រាកដ  និងសត្វតិរច្ឆានញី  ដែលជាវត្ថុនៃមេថុនធម្មប៉ុណ្ណោះ ។  ឯសត្វតិរច្ឆានញីដ៏សេស  ជាអនាបត្តិ ។  សូម្បីសមុដ្ឋានជាដើម  ក៏ដូចគ្នានឹងសិក្ខាបទមុននុ៎ះឯង ។

ទុតិយសហសេយ្យសិក្ខាបទវណ្ណនា  ចប់

# ៧. ធម្មទេសនាសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

## ពន្យល់រឿងព្រះឧទាយី

[២៩៨] ស្រីម្ចាស់ផ្ទះ ឈ្មោះថា ឃរណី : ស្រីជាមេផ្ទះ ។

បទថា និវេសនទ្វារេ : ជិតទ្វារផ្ទះ បានដល់ ក្បែរទ្វារជំនៃនិវេសន៍ (ផ្ទះ) ។

ស្រីកូនប្រសារក្នុងផ្ទះនោះ ឈ្មោះថា ឃរសុណ្ហា : ស្រីជាកូនប្រសារនៃស្រីជាមេផ្ទះ ។

បទថា អាវសថទ្វារេ : ជិតទ្វារផ្ទះសំណាក់ បានដល់ ក្បែរទ្វារបន្ទប់ដេក ។

បទថា វិស្សដ្ឋេន : ដោយសំឡេងក្បួសក្បាយ បានដល់ ដោយសំឡេងប្រាកដច្បាស់ល្អ ។

បទថា វិវដេន : ដោយច្បាស់លាស់ បានដល់ បើកប្រកាស គឺមិននិយាយខ្សាវ ៗ ។

ពីរបទថា ធម្មោ ទេសេតព្វោ : គួរតែសម្ដែងធម៌ មានសេចក្ដីថា ព្រះធម្មកថិកគួរសម្ដែងធម៌ ដែលផ្សេងដោយសរណៈនិងសីល ជាដើមនេះ ។

[២៩៩] បទថា អញ្ញាតុំ : ចាំ គឺ (អាច) នឹងដឹងទូទៅបាន ។

[៣០០] ពីរបទថា វិញ្ញុណា បុរិសវិគ្គហេន : មានបុរសដែលដឹងក្ដី មានសេចក្ដីថា (វៀរចាក) បុរសអ្នកដឹងក្ដី (អ្នកដឹងអត្ថន័យ) មិនមែនយក្ខ មិនមែនប្រេត មិនមែនតិរច្ឆាន សូម្បីអ្នកប្លែងភេទជាបុរសឋិតនៅ(ជិត) ។

[៣០១] ច្រើនបទថា អនាបត្តិ វិញ្ញុណា បុរិសវិគ្គហេន : អាបត្តិមិនមានដល់ភិក្ខុដែលសម្ដែងធម៌ មានបុរសដឹងក្ដី(នៅជិត) មានសេចក្ដីថា មិនជាអាបត្តិដល់ភិក្ខុដែលសម្ដែងធម៌ សូម្បីច្រើនដល់ស្រីដែលឈរជាមួយនឹងបុរសដែលដឹងក្ដី ។

បទថា ឆប្បញ្ចវាចាហិ : ត្រឹមប្រាំម៉ាត់ឬប្រាំមួយម៉ាត់ មានសេចក្ដីថា មិនជាអាបត្តិសូម្បីដល់ភិក្ខុដែលសម្ដែង(ធម៌) ដោយវាចា

៥ ឬ ៦ ម៉ាត់ ។ ក្នុងពាក្យថា ឆប្បញ្ចវាចាហិ នោះ បណ្ឌិតគប្បីជ្រាប ប្រមាណនៃវាចាក្នុងធម៌ទាំងពួងយ៉ាងនេះ គឺ បាទនៃគាថាមួយ ឈ្មោះថា វាចាមួយម៉ាត់ ។ បើថា ភិក្ខុជាអ្នកប្រាថ្នានឹងពោលអដ្ឋកថា ឬថា រឿង មានរឿងធម្មបទនិងជាតកជាដើម, នឹងពោលត្រឹមតែ ៥-៦ បទប៉ុណ្ណោះ គួរ ។ កាលនឹងពោលព្រមដោយបាលី គប្បីពោលធម៌កុំឱ្យលើស ៦ បទ យ៉ាងនេះ គឺអំពីព្រះបាលីមួយបទ អំពីអដ្ឋកថា ៥ បទ ។ ពិតមែន ធម៌មានប្រភេទដូចពោលក្នុងបទសោធម្ម ចាត់ជាធម៌ដូចគ្នាអស់ សូម្បី ក្នុងសិក្ខាបទនេះ ។

ពីរបទថា តស្មឹ ទេសេតិ : សម្តែងក្នុងនោះ គឺ សម្តែងក្នុង ខណៈនោះ ។ ម្យ៉ាងទៀតពាក្យថា តស្មឹ នេះ ជាសត្តមីវិភត្តិចុះក្នុងអត្ថ ឆដ្ឋីវិភត្តិ, សេចក្តីថា ភិក្ខុសម្តែងធម៌ដល់ស្រីនោះ ។

ពីរបទថា អញ្ញស្ស មាតុគាមស្ស : ដល់មាតុគ្រាមឯទៀត មាន សេចក្តីថា ភិក្ខុអង្គុយលើអាសនៈតែមួយ សម្តែង (ធម៌) សូម្បីដល់ មាតុគ្រាម ១០០ នាក់ យ៉ាងនេះ គឺ សម្តែងដល់ស្រីម្នាក់ហើយ សម្តែងសូម្បីដល់ស្រីដទៃ អ្នកមកហើយ ៗទៀត ។ ក្នុងអដ្ឋកថាមហា

បច្ចុរីលោកពោលទុកថា "ភិក្ខុពោលថា អាត្មានឹងសម្តែងគាថា ដល់ពួកនាងម្នាក់១គាថា ៗ ពួកនាងចូរស្តាប់គាថានោះ" ដូច្នេះ ហើយសម្តែង (ធម៌) ដល់ពួកមាតុគ្រាមដែលអង្គុយប្រជុំគ្នានោះ មិនជាអាបត្តិ ។ ភិក្ខុធ្វើទុកក្នុងចិត្តតាំងពីដំបូងថា "យើងនឹងពោលគាថាដល់ស្រីម្នាក់មួយគាថា ៗ" ដូច្នេះ ហើយប្រាប់ឱ្យដឹងមុន សឹមសម្តែងសមគួរ ។

ប្រែបទថា បញ្ហំ បុដ្ឋោ បញ្ហំ បុដ្ឋោ កថេតិ : សួរប្រស្នា ហើយឆ្លើយដោះប្រស្នា(នោះ) មានសេចក្តីថា មាតុគ្រាមសួរថា លោកម្ចាស់ ឈ្មោះថា ទីឃនិកាយសម្តែងអត្ថដូចម្តេច ? ភិក្ខុត្រូវសួរបញ្ហាយ៉ាងនេះ សូម្បីនឹងពោលទីឃនិកាយទាំងអស់ ក៏មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ ជាបទសោធម្មសមុដ្ឋាន តាំងឡើងមកវាចា ១ វាចាចិត្ត ១ ជាកិរិយា និងអកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ធម្មទេសនាសិក្ខាបទវណ្ណនា ចប់

# ៨. ភូតារោចនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

## ពន្យល់រឿងភិក្ខុពួកនៅមាត់ស្ទឹងវគ្គុមុទា

[៣០៤] ពាក្យណាដែលខ្ញុំគួរនឹងពោលមុនក្នុងវត្ថុកថា, ពាក្យនោះ ទាំងអស់ មានន័យដូចដែលពោលហើយក្នុងចតុត្ថបារាជិកវណ្ណនានុ៎ះឯង ។ ចំណែកសេចក្តីប្លែកគ្នា ដូចតទៅនេះ ៖

ក្នុងចតុត្ថបារាជិកនោះ ពួកភិក្ខុប្រាប់ឧត្តរិមនុស្សធម្មដែលមិនមាន, ក្នុងសិក្ខាបទនេះប្រាប់ឧត្តរិមនុស្សធម្មដែលមានពិត ។ បុថុជ្ជនទាំងឡាយប្រាប់ឧត្តរិមនុស្សធម្មសូម្បីដែលមានពិត ។ ព្រះអរិយទាំងឡាយ រមែងមិនប្រាប់ ។ ពិតមែន ឈ្មោះថា បយុត្តវាចា (វាចាដែលថ្លែងព្រោះហេតុនៃផ្ទៃ) មិនមានដល់ព្រះអរិយៈទាំងឡាយ ។ តែកាលអ្នកដទៃប្រាប់គុណវិសេសរបស់ខ្លួនឯង លោកក៏មិនហាមអ្នកពួកដទៃ និងត្រេកអរបច្ច័យទាំងឡាយ ដែលកើតឡើងដោយអាការដែលមិនជ្រាបថាកើតឡើង (ព្រោះការប្រាប់គុណរបស់ខ្លួន) ។

[៣០៥] ក៏ក្នុងពាក្យថា អជ្ជេវ តេ ភិក្ខុ ភគវតោ ឯតមត្ថំ អារោចេសុំ : គ្រានោះ ភិក្ខុអម្បាលនោះ ក៏ក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ (ដោយសព្វគ្រប់) ជាដើមបណ្ឌិតគប្បីជ្រាបថា

ភិក្ខុទាំងឡាយណា ពោលគុណនៃឧត្តរិមនុស្សធម្ម, ភិក្ខុទាំងនោះ បានក្រាបទូលហើយ ។ ព្រះមានព្រះភាគត្រាស់សួរថា "នែភិក្ខុទាំងឡាយ ពាក្យរបស់អ្នកទាំងឡាយ ពិតមែនឬ ?" ក៏ភិក្ខុទាំងអស់នោះ ទូលទទួលប្តេជ្ញាថា "សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន" ព្រោះថា ឧត្តរិមនុស្សធម្មមានពិតនៅខាងក្នុងសូម្បីនៃព្រះអរិយៈទាំងឡាយ ; ព្រោះដូច្នោះ គ្រានោះ ទើបព្រះមានព្រះភាគមិនត្រាស់ថា មោឃបុរិសា ទេ ព្រោះភិក្ខុទាំងនោះ ប្របូកប្របល់លាយឡំដោយព្រះអរិយៈ ត្រាស់ថា "កច្ចិ ហិ ឆាម តុម្ហេ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាមិនសមបើនឹងហ៊ាន" ហើយ ទើបត្រាស់ ពាក្យមានជាដើមថា "ឧទរស្ស ការណា : ព្រោះហេតុតែចង់ឆ្អែត" ដូច្នេះ ។

ក្នុងពាក្យមានពាក្យថា កច្ចិ ហិ ឆាម តុម្ហេ ភិក្ខវេ ជាដើមនោះ ព្រោះព្រះអរិយៈទាំងឡាយ ស្តាប់ពាក្យរបស់អ្នកដទៃ ត្រូវពួកអ្នកស្រុកដែលមានសេចក្តីជ្រះថ្លាសួរហើយ ដោយន័យជាដើមថា "បពិត្រលោកដ៏ចម្រើន បានឮថា លោកម្ចាស់ ជាសោតាបន្នឬ ?" ដូច្នេះ មានប្រក្រតីឃើញថា មិនមានទោស ក្នុងកាលសិក្ខាបទដែលព្រះមានព្រះភាគទ្រង់មិនទាន់បានបញ្ញត្ត ទើបប្តេជ្ញាការសម្រេចគុណវិសេសរបស់ខ្លួននិងរបស់អ្នកដទៃ ព្រោះជាអ្នកមានចិត្តបរិសុទ្ធ, ម្យ៉ាងទៀត លោកទាំងនោះ

កាលបើថ្លាយ៉ាងនេះ សូម្បីត្រេកអរនូវបិណ្ឌបាតដែលបុថុជ្ជនពួកដទៃពោលគុណនៃឧត្តរិមនុស្សធម៌ ព្រោះហេតុនៃផ្ទៃឱ្យកើតឡើងហើយដោយភាពជាអ្នកមានចិត្តបរិសុទ្ធិ ទើបដូចជាអ្នកពោលគុណនៃឧត្តរិមនុស្សធម៌ ព្រោះហេតុនៃផ្ទៃ ; ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ដោយសព្វសង្គាហិកន័យនុ៎ះឯងថា “ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាមិនសមបើនឹងហ៊ានពោលសរសើរគុណឧត្តរិមនុស្សធម៌របស់គ្នានិងគ្នាចំពោះពួកគ្រហស្ថ ព្រោះហេតុតែចង់ឆ្អែតផ្ទៃទេ” ដូច្នេះ ។ ពាក្យដ៏សេសដូចគ្នានឹងរឿងចតុត្ថបារាជិកទាំងនោះឯង ។

សូម្បីក្នុងវិភង្គនៃសិក្ខាបទ ក្នុងចតុត្ថបារាជិកនោះ ជាបារាជិកនឹងថុល្លច្ច័យតែម្យ៉ាង, ក្នុងសិក្ខាបទនេះ ជាបាចិត្តិយនិងទុក្កដ ព្រោះជាគុណមានពិត, នេះជាសេចក្តីប្លែកគ្នា ។ បទដ៏សេស មានន័យដូចពោលហើយនុ៎ះឯង ។

[៣៤១] ពាក្យថា ឧបសម្បន្នស្ស ភូតំ អារោចេតិ: ប្រាប់ឧត្តរិមនុស្សធម៌ ដែលខ្លួនបានពិតប្រាកដដល់ឧបសម្បន្ន (នេះ) លោកពោលសំដៅយកឧត្តរិមនុស្សធម៌នុ៎ះឯង ។ ពិតមែន ភិក្ខុដែលត្រូវគេទទូចសួរក្នុងវេលាបរិញោន និងក្នុងកាលដទៃ នឹងប្រាប់គុណដែលមានពិតដល់ឧបសម្បន្ន ក៏គួរ ។ មួយទៀត នឹងប្រាប់គុណ គឺ សុតៈ បរិយត្តិ

និងសីលសូម្បីដល់អនុបសម្បន្នក៏គួរ, មិនជាអាបត្តិដល់ភិក្ខុដែលជាដើមបញ្ញត្តិ, តែពាក្យថា ឧម្មត្តកស្ស : ដល់ភិក្ខុឆ្កួត នេះ ព្រះមានព្រះភាគមិនបានត្រាស់ទុកក្នុងសិក្ខាបទនេះ ។ ព្រោះហេតុអ្វី ? លោកពិចារណាទុកក្នុងអដ្ឋកថា មហាបច្ចរីថា ព្រោះលោកអ្នកដល់ព្រមដោយទិដ្ឋិ មិនមានសេចក្ដីឆ្កួត ឬចិត្តរវើរវាយ ដូច្នេះ ។ តែលោកដែលបានឈានគប្បីជាបុគ្គលឆ្កួតបានក្នុងកាលឈានសាបសូន្យ ។ សូម្បីសម្រាប់ភិក្ខុនោះក៏មិនគួរពោលអនាបត្តិ ដែលមានការប្រាប់ឈានដែលមានពិតជាបច្ច័យ ព្រោះឈានដែលមានពិតនុ៎ះឯង មិនមាន ដូច្នេះ បទដែលនៅសល់មានអត្ថងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ ឈ្មោះថា ភូតារោចនសិក្ខាបទ កើតឡើងដោយសមុដ្ឋាន ៣ (ដែលមិនបានត្រាស់ទុកក្នុងខាងដើម) គឺ កាយ ១ វាចា ១ កាយវាចា ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្មមានចិត្ត ២ ជាកុសលចិត្ត និងអព្យាកតចិត្ត មានវេទនា ២ ជាសុខវេទនា និងឧបេក្ខាវេទនា ដូច្នេះឯង ។

ភូតារោចនសិក្ខាបទវណ្ណនា ចប់

# ៩. ទុដ្ឋុល្លារោចនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

## ពន្យល់អំពីអាបត្តិអាក្រក់

[៣៤២] លោកពោលទុកក្នុងអដ្ឋកថាទាំងឡាយថា ព្រះមានព្រះភាគត្រាស់បារាជិកទុកក្នុងព្រះបាលីថា "អាបត្តិបារាជិក ៤ និងអាបត្តិសង្ឃាទិសេស ១៣ ឈ្មោះថា ទុដ្ឋុល្លាបត្តិ" ដូច្នេះ ដើម្បីសម្ដែងអត្ថនៃទុដ្ឋុល្លសព្ទ, តែសង្ឃាទិសេស ទ្រង់ប្រាថ្នាយកក្នុងសិក្ខាបទនេះ ។ ក្នុងបាលីនោះ មានការវិចារណ៍ដូចតទៅនេះ ៖

បើថា កាលភិក្ខុប្រាប់បារាជិក មិនគប្បីជាបាចិត្តិយសោត ។ សូម្បីកាលមានសព្ទថា ឧបសម្បន្ន សម្រាប់ភិក្ខុនិងភិក្ខុនី ក្នុងសិក្ខាបទណា លោកមិនប្រាថ្នាយកភិក្ខុនី, ក្នុងសិក្ខាបទនោះវៀរភិក្ខុចេញ ដែលនៅសល់ក្រៅពីនេះ លោកហៅថា អនុបសម្បន្នយ៉ាងណា, ក្នុងសិក្ខាបទនេះក៏ដូច្នោះ សូម្បីកាលមានសព្ទថា ទុដ្ឋុល្លៈ សម្រាប់បារាជិក និងសង្ឃាទិសេស បើមិនទ្រង់ប្រាថ្នាយកបារាជិក ព្រះមានព្រះភាគ ក៏នឹងគប្បីត្រាស់ពាក្យនេះប៉ុណ្ណោះថា "ដែលហៅថា ទុដ្ឋុល្លាបត្តិ បានដល់អាបត្តិសង្ឃាទិសេស ១៣" ។

[៣៤៣] ក្នុងពាក្យថា **ទុដ្ឋុល្លា នាម អាបត្តិ : ឈ្មោះថា**

ទុដ្ឋុល្លាបត្តិ ជាដើមនោះ គប្បីមានមតិរបស់អាចារ្យខ្លះថា “ភិក្ខុណា ត្រូវបារាជិកហើយ, ភិក្ខុនោះ ឃ្លាតហើយចាកភិក្ខុភាវៈ ; ព្រោះហេតុនោះ ភិក្ខុកាលប្រាប់អាបត្តិរបស់ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ” ។ កាលមានអធិប្បាយយ៉ាងនេះ សូម្បីភិក្ខុដែលជេរក៏គប្បីត្រូវអាបត្តិទុក្កដ និងត្រូវបាចិត្តិយប៉ុណ្ណោះ ។ សមពិតដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា “បុគ្គលគឺភិក្ខុដែលត្រូវអាបត្តិបារាជិកឯណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ, បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អទេ ឱ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងជេរភិក្ខុនោះទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ (ឱមសវាទ)[1] ។ កាលបាលីត្រូវវិចារណ៍យ៉ាងនេះ បាចិត្តិយនុ៎ះឯង រមែងប្រាកដសូម្បីដល់អ្នកប្រាប់អាបត្តិបារាជិក ។ នឹងប្រាកដ ក៏ពិតមែនហើយ តែថា ព្រះអដ្ឋកថាចារ្យប៉ុណ្ណោះជាគោលបាន ក្នុងពាក្យថា ទុដ្ឋុល្ល ឆាម អាបត្តិ ជាដើមនេះ ព្រោះ (ពាក្យថា ព្រះមានព្រះភាគត្រាស់បារាជិកទុក ដើម្បីទ្រង់សម្ដែងអត្ថនៃទុដ្ឋុល្លសព្ទ តែសង្ឃាទិសេស ទ្រង់ប្រាថ្នាយកក្នុងសិក្ខាបទនេះ) ព្រះអដ្ឋកថាចារ្យពោលទុកហើយក្នុងអដ្ឋកថាទាំងពួង ។ ការវិចារណ៍សូម្បីយ៉ាងដទៃ មិនមានទេ ។

---

១. វិន. សង្ឃា. ទុដ្ឋទោសសិក្ខាបទ. ២. ២៥៨/២៦៧ ។

សូម្បីក្នុងខាងដើម ខ្ញុំបានពោលទុកហើយថា
"ធម៌និងវិន័យណា ដែលព្រះពុទ្ធត្រាស់ហើយ ធម៌និងវិន័យនោះ ដែលឱរសទាំងឡាយរបស់ព្រះពុទ្ធនោះ ដឹងហើយយ៉ាងនោះ ពិតមែន" ដូច្នេះជាដើម ។

ពិតមែន ព្រះអដ្ឋកថាចារ្យទាំងឡាយ រមែងជ្រាបព្រះបំណងរបស់ព្រះពុទ្ធ ។ ក៏ពាក្យរបស់ព្រះអដ្ឋកថាចារ្យនោះ បណ្ឌិតគប្បីជ្រាបដោយបរិយាយសូម្បីនេះ ៖

សមពិតដូចដែលត្រាស់ទុកថា "វៀរលែងតែភិក្ខុដែលបានទទួលសន្មត" ។ ក៏ការប្រាប់ដល់ភិក្ខុដែលបានទទួលសន្មត ព្រះមានព្រះភាគទ្រង់អនុញ្ញាត ដើម្បី ប្រយោជន៍ក្នុងការសង្រួមតទៅ គឺ ដើម្បីប្រយោជន៍នឹងមិនត្រូវអាបត្តិដូច្នោះទៀត, និងមិនមែនដើម្បីត្រូវការនឹងប្រកាសត្រឹមតែទោសរបស់ភិក្ខុនោះ, ទាំងមិនមែនដើម្បីត្រូវការរពាំងទីពឹងរបស់ភិក្ខុនោះ ក្នុងព្រះសាសនា, និងភាពជាភិក្ខុរបស់អ្នកត្រូវបារាជិកដោយមិនត្រូវអាបត្តិបែបនោះទៀតទេ ; ព្រោះហេតុនោះ ពាក្យដែលព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថាទាំងឡាយថា "ព្រះមានព្រះភាគត្រាស់បារាជិកទុក ដើម្បីសម្តែងអត្ថនៃទុដ្ឋុល្លស័ព្ទ តែសង្ឃាទិសេស ទ្រង់ប្រាថ្នាយកក្នុងសិក្ខាបទនេះ" ដូច្នេះ ជាការលោកពោលប្រពៃហើយ ។

[៣៨៤] ក៏ក្នុងពាក្យថា អត្ថិ ភិក្ខុសម្មតិ អាបត្តិបរិយន្តា :

ឯសេចក្តីសម្មតិរបស់ភិក្ខុដែលសង្ឃកំណត់ឱ្យ មាន ៤ យ៉ាង គឺសម្មតិកំណត់អាត្តិ ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុសម្មតិ ដែលព្រះមានព្រះភាគត្រាស់ទុកនេះ មិនបានមកក្នុងសិក្ខាបទខ្លះ, តែព្រោះភិក្ខុសម្មតិត្រាស់ទុកក្នុងសិក្ខាបទនេះឯង ទើបគួរជ្រាបថា សង្ឃឃើញភិក្ខុដែលត្រូវអាបត្តិរឿយ ៗ ហើយអបលោកន៍ ៣ ដង ធ្វើដោយភាពជាអ្នកស្វែងរកប្រយោជន៍ដល់ភិក្ខុនោះថា ភិក្ខុនេះនឹងដល់សេចក្តីសង្រួមតទៅ សូម្បីដោយសេចក្តីខ្មាសនិងសេចក្តីកោតក្រែងខ្លាចក្នុងអ្នកដទៃយ៉ាងនេះ ។

[៣៤៧] ពាក្យថា អទុដ្ឋុល្លំ អាបត្តិ អារោចេតិ អាបត្តិ ទុក្កដស្ស : ភិក្ខុប្រាប់អទុដ្ឋុល្លាបត្តិ (ដល់អនុបសម្បន្ន) ត្រូវអាបត្តិទុក្កដ មានសេចក្តីថា ជាទុក្កដ ដល់ភិក្ខុដែលប្រាប់អាបត្តិសូម្បីទាំង ៥ ។ ក្នុងមហាបច្ចរីលោកពិន័យអាបត្តិទុក្កដតែម្យ៉ាង សូម្បីដល់ភិក្ខុដែលប្រាប់អាបត្តិបារាជិក ។

ក្នុងពាក្យថា អនុបសម្បន្នស្ស ទុដ្ឋុល្លំ វា អទុដ្ឋុល្លំ វា អជ្ឈាចារំ : ភិក្ខុប្រាប់អជ្ឈាចារអាក្រក់ក្តី មិនសូវអាក្រក់ក្តី របស់អនុបសម្បន្ន គឺ សាមណេរ (ដល់អនុបសម្បន្នដទៃ) ត្រូវអាបត្តិទុក្កដនេះ លោកពោលរូបសេចក្តីទុកថា សិក្ខាបទ ៥ ខាងដើម ឈ្មោះថា

អជ្ឈាចារអាក្រក់ ដែលនៅសល់ឈ្មោះថា អជ្ឈាចារឲ្យមិនអាក្រក់, ក៏សុក្កវិស្សដ្ឋិ កាយសំសគ្គៈ ទុដ្ឋុល្លវាចា និងអត្តកាមៈ ឈ្មោះថា ជាអជ្ឈាចាររបស់ភិក្ខុនោះ ។

[៣៤៨] ពីរបទថា វត្ថុំ អារោចេតិ : ដល់ភិក្ខុប្រាប់តែវត្ថុ មានសេចក្តីថា មិនជាអាបត្តិ ដល់ភិក្ខុដែលប្រាប់យ៉ាងនេះថា "ភិក្ខុនេះត្រូវសុក្កវិស្សដ្ឋិ ត្រូវកាយសំសគ្គៈ ត្រូវទុដ្ឋុល្លៈ ត្រូវអត្តកាមៈ" ។

ពីរបទថា អាបត្តឹ អារោចេតិ : ដល់ភិក្ខុប្រាប់តែអាបត្តិ មានសេចក្តីថា ភិក្ខុពោលថា "ភិក្ខុនេះត្រូវបារាជិក ត្រូវសង្ឃាទិសេស ត្រូវថុល្លច្ច័យ ត្រូវបាចិត្តិយ បាដិទេសនីយៈ ទុក្កដ ទុព្ភាសិត" ដូច្នេះ មិនជាអាបត្តិ ។ កាលភិក្ខុប្រាប់ ភ្ជាប់អាបត្តិនិងវត្ថុ ដោយន័យជាដើមថា "ភិក្ខុនេះ បញ្ចេញអសុចិ ត្រូវសង្ឃាទិសេស" ដូច្នេះប៉ុណ្ណោះ ទើបជាអាបត្តិ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងមកកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្មវចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ទុដ្ឋុល្លារោចនសិក្ខាបទវណ្ណនា ចប់

# ១០. បឋវីខណនសិក្ខាបទវណ្ណនា

*គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖*

## ពន្យល់អំពីជាតបឋវី និងអជាតបឋវី

*[៣៥០] ព្រះមានព្រះភាគទ្រង់សម្តែងជាតបឋវី និងបឋវីមិនពិត ដោយបទទាំងនេះថា ជាតា ច បថវី អជាតា ច បថវី* **: *ជាតបឋវី ១ អជាតបឋវី ១*** *ដូច្នេះ ។*

*ក្នុងបទទាំងឡាយមានបទថា* ***អប្បបាសាណា*** **:** *មានថ្មតិច ជាដើម អ្នកសិក្សាគប្បីឃើញសេចក្តីយ៉ាងនេះថា ដែលជាជាតបឋវីនេះ មានថ្មតិច; ដូច្នោះ ទើបឈ្មោះថា* ***អប្បបាសាណា*** **:** *ដីមានថ្មតិច ។ ក្នុងបទថា មានថ្មតិចជាដើមនោះ គប្បីជ្រាបថា មានថ្មលើសពីខ្នាតមួយក្តាប់ដៃ ។ គ្រួសក៏គប្បីជ្រាបថា មានប្រមាណមួយក្តាប់ដៃ ។ កំទេចក្បឿងឈ្មោះថា* ***កឋលា*** **:** *បំណែកអម្បែង ។ ដុំគ្រួសដែលប្រាកដ (ថ្មគ្រួសស្រដៀងវល័យ) ឈ្មោះ* ***មរុម្ពា*** **:** *គ្រួសវាន ។ ខ្សាច់ទុំះឯង ឈ្មោះថា* ***វាលុកា*** *។*

*ពីរបទថា យេភុយ្យេន បំសុ* **: *មានអាចម៍ដីច្រើន*** *មានសេចក្តីថា ក្នុង៣ ចំណែក, ពីរចំណែក ជាអាចម៍ដី, មួយចំណែក ជាថ្មជាដើម ណាមួយ ។*

បទថា អទឌ្ឍាបិ : ឬជាផែនដីគេមិនដែលដុត មានសេចក្តីថា មិនទាន់បានដុត ដោយប្រការណាមួយ ដោយអំណាចនៃចង្ក្រានភ្លើងដែលដុតបាត្រ និងឡជាន់ឆ្នាំងជាដើម ។ ក៏បឋវីដែលនៅមិនបានដុតភ្លើងនោះ មិនមានផ្សេងដទៃ, គប្បីជ្រាបថា ជាបឋវីប្រភេទណាមួយមានដីល្បាប់សុទ្ធជាដើម ។

ពីរបទថា យេភុយ្យេន សក្ខរា : មានក្រួសច្រើន បានដល់ មានដុំគ្រួសច្រើនជាង ។ បានឮថា ក្នុងហត្ថិកុច្ឆិប្រទេស ពួកភិក្ខុឱ្យមនុស្សជញ្ជូនដីមកពេញមួយបន្ទី ហើយលាងក្នុងប្រឡាយដឹងថា ជាបឋវីមានគ្រួសច្រើន ទើបជីកស្រះបោក្ខរណីដោយខ្លួនឯង ។

ក៏ពីរបទថា អប្បបំសុ អប្បមត្តិកា : មានអាចម៍ដីតិច មានដីស្អិតតិច ដែលមាននៅត្រង់កណ្តាលរួមចូលក្នុងពួក ៥ មានថ្មដោយច្រើនជាដើមនុ៎ះឯង ។ ពិតមែន ពាក្យនេះ ជាពាក្យសម្តែងប្រភេទនៃបឋវីទាំង ២ នោះឯង ។

[៣៥១] ក្នុងពាក្យថា សយំ ខណតិ អាបត្តិ បាចិត្តិយស្ស : ភិក្ខុជីកដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ នេះ អ្នកសិក្សាគប្បីជ្រាបថា ជាបាចិត្តិយគ្រប់ ៗ វារៈដែលជីក ។

ពាក្យថា សកឹ អាណត្តោ ពហុកំបិ ខណតិ : ភិក្ខុបង្គាប់

មនុស្សឱ្យជីកតែម្តង មនុស្សនោះទៅជីកច្រើនដង មានសេចក្តីថា ប្រសិនបើថា អ្នកទទួលបង្គាប់ជីករហូតដល់អស់មួយថ្ងៃ ក៏ជាបាចិត្តិយតែមួយប៉ុណ្ណោះដល់អ្នកបង្គាប់ ។ តែបើអ្នកទទួលបង្គាប់ជាអ្នកខ្ជិលច្រអូស អ្នកបង្គាប់ត្រូវបង្គាប់រឿយ ៗ ជាបាចិត្តិយដល់ភិក្ខុដែលបង្គាប់ឱ្យគេជីកគ្រប់ ៗម៉ាត់ ។ ពណ៌នាបាលីប៉ុណ្ណោះសិន ។

## បាលីមុត្តកវិនិច្ឆ័យការជីកដីជាដើម

ចំណែកសេចក្តីវិនិច្ឆ័យក្រៅព្រះបាលី មានដូចតទៅនេះ ៖

ភិក្ខុពោលថា លោកចូរជីកស្រះបោក្ខរណី ដូច្នេះ គួរ ។ ព្រោះថា ស្រះដែលជីកហើយប៉ុណ្ណោះ ទើបឈ្មោះថា ជាស្រះបោក្ខរណី ; ដូច្នោះ វោហារនេះ ជាកប្បិយវោហារ ។ សូម្បីក្នុងពាក្យជាដើមថា "ចូរជីក បឹង អណ្តូង រណ្តៅ" ដូច្នេះ ក៏មានន័យយ៉ាងនេះដូចគ្នា ។ តែនឹងពោលថា "ចូរជីកឱកាសនេះ ចូរជីកស្រះបោក្ខរណី ក្នុងឱកាសនេះ" ដូច្នេះ មិនគួរ ។ នឹងពោលមិនកំណត់ឱ្យប្រាកដទេថា "ចូរជីកក្រអៅ ចូរជីកឫស" ដូច្នេះ គួរ, នឹងពោលថា "ចូរជីកវល្លិនេះ ចូរជីកក្រអៅ ឬឫសក្នុងឱកាសនេះ" ដូច្នេះ មិនសមគួរ, កាលជម្រះស្រះបោក្ខរណី អាចនឹងយកឆ្នាំងបាចភក់រាវ ៗណាចេញបាន, នឹងនាំភក់នោះចេញ គួរ ។ នឹងនាំភក់ដែលខាប់ចេញ មិនគួរ ។ ភក់ស្ងួតព្រោះកម្តៅថ្ងៃបែក

ក្រហែង ក្នុងភក់ស្ងួតនោះ ចំណែកណាមិនជាប់នឹងផែនដីក្នុងខាងក្រោម, នឹងនាំភក់នោះឯងចេញ គួរ, ឈ្មោះថា ក្រហែង (ដីបន្ទុះសំណាកទឹក,[១] ដីស្រួយព្រោះទឹករីងទៅ) មាននៅក្នុងទីទឹកហូរទៅ, រមែងរបើកព្រោះត្រូវខ្យល់បក់ នឹងនាំយកក្រហែង នោះចេញ គួរ ។ មាត់ច្រាំងនៃស្រះបោក្ខរណីជាដើម បាក់ធ្លាក់ចុះទៅមាត់ទឹក ។ បើត្រូវភ្លៀងធ្លាក់ស្រោចតិចជាង ៤ ខែ នឹងកាប់ចេញ ឬជំចេញ ក៏គួរ ។ បើលើស ៤ ខែ មិនគួរ ។ តែបើធ្លាក់ចុះក្នុងទឹកអស់ សូម្បីកាលភ្លៀងធ្លាក់ស្រោចលើស ៤ ខែហើយ ក៏គួរ ព្រោះទឹក (ភ្លៀង) ធ្លាក់ចុះទៅក្នុងទឹកប៉ុណ្ណោះ ។

ភិក្ខុទាំងឡាយជីក (បោះ) អណ្តូងទឹក (អណ្តូងថ្ម) លើថ្មផា ។ ប្រសិនបើថា ផង់ធូលីធ្លាក់ចុះទៅក្នុងអណ្តូងថ្មនោះ តាំងពីដំបូងតែម្តង ។ ផង់ធូលីនោះត្រូវភ្លៀងធ្លាក់ស្រោច, ដោយករកន្លងទៅបាន ៤ ខែ ទើបដល់ការរាប់ថា ជាអកប្បិយបឋវី ។ កាលទឹករីងហើយ (ស្ងួតហើយ) ពួកភិក្ខុដែលសម្អាតអណ្តូងថ្ម នឹងបំបែកផង់ធូលីនោះចេញ

---

១. វិមតិ. ឧទកបប្បដកោតិ ឧទកេ អន្តោភូមិយំ បវិដ្ឋេ តស្ស ឧបរិភាគំ ឆាទេត្វា តនុកបំសុ វា មត្តិកា វា បដលំ ហុត្វា បតមានា តិដ្ឋតិ, តស្មឹ ឧទកេ សុក្ខេបិ តំ បដលំ វាតេន ចលមានា តិដ្ឋតិ, តំ ឧទកបប្បដកោ នាម អ្នកជម្រះ ។

មិនគួរ ។ បើទឹកនៅពេញមុន, ទើបផង់ធូលីធ្លាក់ចុះទៅខាងក្រោយ, នឹងបំបែកផង់ធូលីនោះចេញ គួរ ។ ពិតមែន សូម្បីកាលភ្លៀងធ្លាក់ក្នុងអណ្តូងថ្មនោះ ទឹក រមែងធ្លាក់ចុះក្នុងទឹកប៉ុណ្ណោះ ។ ផង់ធូលីមាននៅលើពួកថ្មជា ផង់ធូលីនោះ កាលត្រូវភ្លៀងធ្លាក់ជោគហើយ ក៏ជាប់គ្នាទៀត ។ នឹងបំបែកផង់ធូលី សូម្បីនោះចេញដោយកន្លង ៤ ខែទៅមិនគួរ ។

ដំបូកកើតឡើងឯងត្រង់ញកមិនមានអ្នកសាង, នឹងបំបែកចេញតាមសប្បាយ គួរ ។ បើដំបូកកើតឡើងក្នុងទីវាល ត្រូវភ្លៀងធ្លាក់ស្រោចតិចជាង ៤ ខែប៉ុណ្ណោះ ទើបគួរ ។ សូម្បីក្នុងដីស្អិតរបស់សត្វកណ្តៀរដែលឡើងទៅលើដើមឈើជាដើម មានន័យយ៉ាងនេះដូចគ្នា ។ សូម្បីក្នុងដីអាចម៍ជន្លេន កំទេចដីកណ្តុរកកាយ និងក្រហែងក្រចកគោជាដើម ក៏មានន័យយ៉ាងនេះដូចគ្នា ។ ភក់ដែលត្រូវកាត់ដោយក្រចកហ្វូងគោ (ភក់ស្នាមក្រចកហ្វូងគោ) ហៅថា ក្រហែងក្រចកគោ ។ ក៏បើថា ក្រហែងក្រចកគោនោះ ជាប់នឹងផែនដីខាងក្រោម សូម្បីក្នុងមួយថ្ងៃ នឹងបំបែកចេញ ក៏មិនគួរ ។ ភិក្ខុកាន់យកដុំដីស្អិតដែលត្រូវភ្ជួរកាត់ សូម្បីក្នុងទីដែលអ្នកស្រែភ្ជួរទុក ក៏មានន័យយ៉ាងនេះដូចគ្នា ។

សេនាសនៈចាស់ មិនមានដំបូល ឬមានដំបូលបាក់បែកក៏ដោយ ត្រូវភ្លៀងធ្លាក់ស្រោចលើស ៤ ខែ រមែងដល់ការរាប់ថា ជាតបឋវីដូច

គ្នា ៗ ភិក្ខុនឹងកាន់យកក្បឿងប្រក់ដំបូល ឬគ្រឿងឧបករណ៍មានគន្លឹះជាដើម ដែលនៅសល់អំពីសេនាសនៈចាស់នោះដោយសម្គាល់ថា "យើងនឹងយកឥដ្ឋ នឹងយកគន្លឹះ នឹងយកជើងទ្រជញ្ជាំង នឹងយកក្តារក្រាលផ្ទៃ នឹងយកសសរថ្ម" ដូច្នេះ គួរ ៗ ដីស្អិតធ្លាក់ចុះជាប់នឹងក្បឿងដំបូលជាដើមនោះ មិនជាអាបត្តិ ៗ តែជាអាបត្តិដល់ភិក្ខុដែលយកដីស្អិតលាបត្រង់ជញ្ជាំង ៗ បើដុំដីណា ៗ មិនទទឹក, ភិក្ខុកាន់យកដុំដីនោះ ៗ មិនជាអាបត្តិ ៗ

ខាងក្នុងផ្ទះមានគំនរដី កាលគំនរដីនោះត្រូវភ្លៀងធ្លាក់ស្រោចពេញមួយថ្ងៃ ជនទាំងឡាយទើបប្រក់ផ្ទះ ៗ បើគំនរដីសើមទាំងអស់, កន្លងទៅបាន ៤ ខែ ក្លាយជាជាតបឋវីដូចគ្នា ៗ បើចំណែកខាងលើនៃគំនរដីនោះប៉ុណ្ណោះសើម ខាងក្នុងមិនសើម, នឹងប្រើឱ្យពួកកប្បិយការកៈកកាយយកដីប៉ុនចំនួនដែលសើមចេញ ដោយកប្បិយវោហារហើយ ប្រើប្រាស់ដីចំណែកដែលនៅសល់តាមសប្បាយក៏គួរ ៗ ពិតមែន ដីដែលសើមដោយទឹកហើយស្អិតជាប់ជាផ្ទាំងតែមួយនុ៎ះឯង ចាត់ជាជាតបឋវី, ក្រៅនេះមិនមែន ៗ

កំពែងដីស្អិតនៅក្នុងទីវាល បើត្រូវភ្លៀងធ្លាក់ស្រោចលើស ៤ ខែ រមែងដល់ការរាប់ថា ជាតបឋវី ៗ តែភិក្ខុនឹងយកដៃសើមចាប់ពាល់ដី

ស្រួយ ដែលជាប់នៅត្រង់ជាតបវរីនោះ គួរ ។ ប្រសិនបើថា ជាកំពែងឥដ្ឋ, តាំងនៅក្នុងឋានជាក្បៀងឥដ្ឋដោយច្រើន នឹងកកាយចេញបានតាមសប្បាយ ។

ភិក្ខុនឹងរំកៀកយកសសរមណ្ឌបដែលតាំងនៅក្នុងទីវាល ទៅខាងឯណោះខាងឯណេះ ធ្វើឱ្យដីបែក មិនគួរ ។ លើកឡើងត្រង់ ៗ ប៉ុណ្ណោះ ទើបគួរ ។ សម្រាប់ភិក្ខុដែលនឹងកាន់យកដើមឈើស្ងួត ឬ ដង្កត់ឈើស្ងួត សូម្បីយ៉ាងដទៃ ក៏ន័យនេះឯង ។ ភិក្ខុទាំងឡាយយកកំណាត់ឈើគាស់ថ្ម ឬដើមឈើប្រមៀលទៅ ដើម្បីការកសាង ។ ផែនដីក្នុងទីប្រមៀលទៅនោះ បែកជាស្នាម, បើភិក្ខុទាំងឡាយមានចិត្តបរិសុទ្ធិប្រមៀលទៅ មិនជាអាបត្តិ ។ តែបើថា ភិក្ខុទាំងឡាយ ជាអ្នកប្រាថ្នានឹងទម្លាយផែនដីដោយលេសនោះឯង ជាអាបត្តិ ។ ពួកភិក្ខុដែលទាញមែកឈើជាដើមទៅក្តី ពុះឧសលើផែនដីក្តី ក៏មានន័យយ៉ាងនេះដូចគ្នា ។ នឹងដំឬនឹងចាក់ចូលនូវវត្ថុយ៉ាងណាមួយ មានឆ្នឹង មួលនិងបន្លាជាដើមចុះទៅក្នុងផែនដី ក៏មិនគួរ ។ សូម្បីនឹងបន្ទោបង់បស្សាវៈ ដោយគិតយ៉ាងនេះថា "យើងនឹងទម្លាយផែនដីដោយកម្លាំងនៃខ្សែទឹកបស្សាវៈ" ក៏មិនគួរ ។ កាលភិក្ខុបន្ទោបង់ដីបែកដាច់ ជាអាបត្តិ ។ សូម្បីនឹងយកអំបោសបោសវាស ដោយគិតថា "យើងនឹងធ្វើផែនដីដែលមិនស្មើឱ្យស្មើ" ដូច្នេះ ក៏

មិនគួរ ។ សេចក្តីពិត គួរនឹងបោសដោយវត្ថុជាធំប៉ុណ្ណោះ ។

ភិក្ខុពួកខ្លះ បុកផែនដី ដោយចុងឈើច្រត់ យកចុងម្រាមមេជើងគួសវាស (ផែនដី) ។ ដើរចង្ក្រមទម្លាយផែនដី ម្តងហើយម្តងទៀត ដោយគិតថា យើងនឹងសម្តែងស្ថានទីដែលយើងចង្ក្រម ដូច្នេះ, កម្ម ដូច្នោះ មិនគួរគ្រប់យ៉ាង ។ តែភិក្ខុអ្នកធ្វើសមណធម៌ដើម្បីលើកតម្កើងសេចក្តីព្យាយាម មានចិត្តបរិសុទ្ធិចង្ក្រម សមគួរ ។ កាលធ្វើ (ការដើរចង្ក្រមលើផែនដី) ទោះបីជាដីបែកក៏ដោយ ក៏មិនជាអាបត្តិ ។ ភិក្ខុទាំងឡាយត្រដុស(ដៃ)លើផែនដី ដោយគិតថា នឹងជម្រះដៃ មិនគួរ ។ ចំណែកភិក្ខុ អ្នកមិនគិតឬត្រដុសទេ តែដាក់ដៃសើមចុះលើផែនដី ហើយផ្តិតយកល្អងទៅ គួរ ។ ភិក្ខុពួកខ្លះ អាពាធដោយរោគស្រែងនិងរមាស់ជាដើម ទើបត្រដុសអវយវៈ ធំតូច លើទីមានមាត់ច្រាំងចោតជាដើម, ការធ្វើនោះ ក៏មិនសមគួរ ។

## ការជីកខ្លួនឯង និងការប្រើអ្នកដទៃឱ្យជីកផែនដីជាដើម

[៣៥២] ពីរបទថា ខណតិ វា ខណាបេតិ វា : ជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យជីកក្តី មានសេចក្តីថា ភិក្ខុជីកខ្លួនឯងក្តី ប្រើឱ្យអ្នកដទៃជីកក្តី (នូវផែនដី) ដោយហោចទៅសូម្បីដោយចុងម្រាមជើងខ្លះ ដោយឆ្អឹងអំបោសខ្លះ ។

ពីរបទថា ភិន្ទតិ វា ភេទាបេតិ វា : **ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យទម្លាយក្តី** មានសេចក្តីថា ភិក្ខុទម្លាយខ្លួនឯងក្តី ប្រើឱ្យអ្នកដទៃទម្លាយក្តី ( នូវផែនដី ) ដោយហោចទៅសូម្បីតែបាក់ទឹក ។

ពីរបទថា ឌហតិ វា ឌហាបេតិ វា : **ដុតដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យដុតក្តី** មានសេចក្តីថា ភិក្ខុដុតដោយខ្លួនឯងក្តី ប្រើឱ្យអ្នកដទៃដុតក្តី ដោយហោចទៅ សូម្បីតែដុតបាត្រ ។ ភិក្ខុដុតភ្លើងដោយខ្លួនឯង ឬប្រើឱ្យអ្នកដទៃដុតក្នុងទីមានចំនួនប៉ុន្មាន, ជាបាចិត្តិយមានចំនួនប៉ុណ្ណោះ ។ ភិក្ខុសូម្បីកាលនឹងដុតបាត្រ គប្បីដុតក្នុងទីធ្លាប់ដុតមុនហើយនុ៎ះឯង ។ នឹងដាក់ភ្លើងចុះលើផែនដី ដែលភ្លើងមិនទាន់ឆេះ មិនគួរ ។ តែបើដាក់ភ្លើងចុះលើគ្រៀងសម្រាប់ដុតបាត្រ គួរ ។ ដាក់ភ្លើងចុះលើគំនរឱស, ភ្លើងនោះឆេះឱសទាំងនោះហើយ នឹងរាលដាលហួសទៅឆេះដីមិនគួរ ។ សូម្បីក្នុងទីមានឥដ្ឋនិងថ្មជាដើម ក៏មាន ន័យយ៉ាងនេះដូចគ្នា ។ ពិតមែន ក្នុងទីសូម្បីនោះ នឹងដាក់ភ្លើង ចុះលើគំនរឥដ្ឋជាដើមនុ៎ះឯង គួរ ។ ព្រោះហេតុអ្វី ? ព្រោះឥដ្ឋជាដើមនោះ មិនមែនគ្រឿងឆេះនៃភ្លើង ។ ពិតមែន ឥដ្ឋជាដើមនោះ មិនរាប់ថា ជាគ្រឿងឆេះនៃភ្លើង ។ ទោះជាដុតភ្លើងលើជន្លត់ឈើស្ងួត និងដើមឈើស្ងួតជាដើម ក៏មិនគួរ ។

តែបើភិក្ខុនឹងដុតភ្លើងដោយគិតថា “យើងនឹងពន្លត់ភ្លើងដែលឆេះមិនទាន់ដល់ផែនដីឱ្យបានមុនហើយទើបចេញទៅ” ដូច្នេះ គួរ ។ ខាងក្រោយមិនអាចពន្លត់បាន មិនជាអាបត្តិ ព្រោះមិនមែនវិស័យ ។ ភិក្ខុកាន់គប់ភ្លើងដើរទៅ កាលដៃត្រូវភ្លើងឆេះ ទើប ចោលលើផែនដី, មិនជាអាបត្តិ ។ លោកពោលទុកក្នុងមហាបច្ចរីថា “ទឹងថែមគ្រឿងឆេះបន្ទាត់ភ្លើង ក្នុងទីគប់ភ្លើងធ្លាក់នុ៎ះឯង គួរ” ។ លោកពោលទុកក្នុងមហាបច្ចរីនោះឯងថា “ក៏ទីមានប្រមាណប៉ុនណា ក្នុងផែនដីដែលត្រូវភ្លើងឆេះចំហាយក្តៅជះទៅដល់ នឹងកើបយកដីទាំង អស់នោះចេញ គួរ” ។

ក៏ភិក្ខុណា មិនទាន់ចេះពួតឱ្យភ្លើងកើតដោយឈើពួតភ្លើង យកដៃចាប់លើកឡើងហើយពោលថា “ខ្ញុំនឹងធ្វើយ៉ាងណា ?” ភិក្ខុដទៃប្រាប់ថា “ចូរធ្វើឱ្យឆេះឡើង” ។ លោកពោលថា “វានឹងឆេះដៃខ្ញុំ” ទើបប្រាប់ថា “ចូរកុំធ្វើឱ្យវាឆេះ” ។ តែមិនគប្បីប្រាប់ថា “ចូរចោលលើផែនដីទៅ” ។ បើថា កាលភ្លើងឆេះដៃ លោកចោលចុះ, មិនជាអាបត្តិ ព្រោះលោកមិនបានចោលចុះដោយតាំងចិត្តថា “យើងនឹងដុតផែនដី” ។ លោកពោលទុកក្នុងកុរុន្ទីថា “ទោះបីនឹងបន្ទាត់ភ្លើងក្នុងទីភ្លើងធ្លាក់ចុះ ក៏គួរ” ។

[៣៥៣] ក៏ក្នុងពាក្យថា អនាបត្តិ ឥមំ ជាន : **អាបត្តិមិនមានដល់ភិក្ខុដែលពោលថា អ្នកឯងចូរដឹងនូវវត្ថុនេះ** ជាដើម អ្នកសិក្សា

គប្បីជ្រាបសេចក្តីយ៉ាងនេះ គឺ (មិនជាអាបត្តិដល់ភិក្ខុដែលពោលថា) "លោកចូរដឹងនូវរណ្តៅសម្រាប់សសរនេះ, ចូរដឹងនូវដីស្អិតដុំធំ, ចូរដឹងនូវដីលាយអង្កាម, ចូរឱ្យដីស្អិតដុំធំ, ចូរឱ្យដីលាយអង្កាម, ចូរនាំដីស្អិតមក, ចូរនាំដីស្រួយមក, ត្រូវការដីស្អិត, ត្រូវការដីស្រួយ, ចូរធ្វើរណ្តៅឱ្យជាកប្បិយសម្រាប់សសរនេះ, ចូរធ្វើដីស្អិតនេះឱ្យជាកប្បិយ, ចូរធ្វើដីស្រួយនេះ ឱ្យជាកប្បិយ" ។

បទថា អសញ្ចិច្ច : **ដល់ភិក្ខុមិនបានក្លែង** មានសេចក្តីថា កាលភិក្ខុប្រមៀលថ្ម និងដើមឈើជាដើមទៅឬដើរយកឈើច្រត់ឆូត ៗទៅ ផែនដីបែក ។ ផែនដីនោះ ឈ្មោះថា ដែលភិក្ខុមិនបានក្លែងធ្វើបែក ព្រោះលោកមិនបានតាំងចិត្តទម្លាយយ៉ាងនេះថា "យើងនឹងទម្លាយ (ផែនដី) ដោយឈើច្រត់នេះ", មិនជាអាបត្តិដល់ភិក្ខុដែលមិនក្លែងទម្លាយដោយប្រការដូច្នេះ ។

បទថា អសតិយា : **ដល់ភិក្ខុភ្លាត់ស្មារតី** មានសេចក្តីថា ភិក្ខុបញ្ជូនចិត្តទៅទីដទៃ ឈរនិយាយអ្វី ៗនឹងអ្នកណាម្នាក់ អ្នកយកម្រាមមេជើង ឬឈើច្រត់គូសវាសផែនដីទៅបណ្តើរ, មិនជាអាបត្តិដល់ភិក្ខុដែលគូសវាស ឬទម្លាយ (ដី) ដោយមិនមានសតិយ៉ាងនេះ ។

បទថា អជានន្តស្ស : **ដល់ភិក្ខុកាលមិនដឹង** មានសេចក្តីថា ភិក្ខុ

មិនដឹងផែនដីដែលភ្លៀងធ្លាក់ស្រោចខាងក្នុងផ្ទះ ដែលប្រក់ដំបូលបិទហើយថា "ជាអកប្បិយបឋវី" ទើបកើបឬបាចេញ ដោយសម្គាល់ថា "ជាកប្បិយបឋវី"ក្តី មិនដឹងថា "យើងជីក យើងទម្លាយ យើងដុតភ្លើង" ក្តី កើបឬបារជាដើម ដើម្បីត្រូវការរក្សាទុកតែម្យ៉ាងក្តី ដៃត្រូវភ្លើងឆេះចោលភ្លើងចុះក្តី, មិនជាអាបត្តិដល់ភិក្ខុដែលមិនដឹងយ៉ាងនេះ ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមមកកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បឋវីខណនសិក្ខាបទវណ្ណនា ចប់

ចំនួនសិក្ខាបទក្នុងមុសាវាទវគ្គនោះ គឺ

| | |
|---|---|
| ១. មុសាវាទសិក្ខាបទ | ការពោលពាក្យកុហក |
| ២. ឱមសវាទសិក្ខាបទ | ការពោលពាក្យអាក្រក់ ( ជេរ ) |
| ៣. បេសុញ្ញវាទសិក្ខាបទ | ការពោលពាក្យញុះញង់ |
| ៤. បទសោធម្មសិក្ខាបទ | ការបង្រៀនធម៌បទ |
| ៥. សហសេយ្យសិក្ខាបទ | ការដេករួម |
| ៦. ទុតិយសហសេយ្យសិក្ខាបទ | ការដេករួមទី ២ |
| ៧. ធម្មទេសនាសិក្ខាបទ | ការសម្តែងធម៌ដល់មាតុគ្រាម |
| ៨. ភូតារោចនសិក្ខាបទ | ការប្រាប់គុណវិសេសដែលមានពិត |
| ៩. ទុដ្ឋុល្លារោចនសិក្ខាបទ | ការប្រាប់អាបត្តិអាក្រក់ |
| ១០. បឋវីខណនសិក្ខាបទ | ការទម្លាយផែនដី |

អដ្ឋកថា មុសាវាទវគ្គទី ១ ចប់ ។

# ២. ភូតគាមវគ្គ

## ១. ភូតគាមសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃភូតគាមវគ្គ ដូចតទៅនេះ ៖

### ពន្យល់រឿងភិក្ខុក្រុងអាឡវីកាត់ដើមឈើ

[៣៥៤] បទថា អនាធិយន្តោ : មិនអើពើ គឺ មិនជឿតាមពាក្យរបស់ទេវតា នោះ ។

ប្រើនបទថា ទារកស្ស ពាហុំ អាកោដេសិ : ក៏ត្រូវដៃទារក មានសេចក្ដីថា ភិក្ខុនោះ មិនអាចទប់ពូថៅ ដែលផាឡើង ទើបកាត់ដាច់ដៃត្រង់ទីជិតដោះរបស់ទារកដេកនៅលើវិមានទិព្វ ដែលតាំងនៅលើដើមឈើ ដែលទេវតានោះ បានមកពីសំណាក់របស់ស្ដេចចាតុម្មហារាជ ដែលកន្លងហួសវិស័យនៃចក្ខុរបស់ពួកមនុស្ស ។

ក្នុងពាក្យថា ន ខោ បនេតំ បដិរូបំ : អំពើនេះមិនសមគួរដល់អញសោះឡើយ ជាដើម មានការពណ៌នា ដោយសង្ខេបដូចតទៅនេះ ៖

បានឮថា ក្នុងព្រៃហិមពាន្ត មានការប្រជុំទេវសភា រាល់ថ្ងៃបក្ខ,

ក្នុងព្រៃហិមពាន្តនោះ ពួកទេវតា រមែងសួរអំពីរុក្ខធម៌ថា លោកតាំងនៅឬ មិនបានតាំងនៅក្នុងរុក្ខធម៌ ។ ឈ្មោះថា រុក្ខធម៌ បានដល់ការដែលរុក្ខទេវតា មិនធ្វើសេចក្ដីប្រទូសរ៉ាយមកចិត្ត ក្នុងកាលដើមឈើត្រូវកាត់ ។ បណ្ដាទេវតាទាំងនោះ ទេវតាអង្គណាមិនតាំងនៅក្នុងរុក្ខធម៌, ទេវតាអង្គនោះ រមែងមិនបានចូលកាន់ទីប្រជុំ ។ ទេវតាអង្គនោះ បានមើលឃើញទោស មានការមិនតាំងនៅក្នុងរុក្ខធម៌ជាបច្ច័យនេះ ដោយប្រការដូច្នេះ និងរលឹកដល់បុព្វចរិយា ក្នុងកាលដែលព្រះតថាគតសោយព្រះជាតិជាស្ដេចដំរីឆទ្ទន្តជាដើម ដោយត្រៃសនៃព្រះធម្មទេសនាដែលខ្លួនធ្លាប់ស្ដាប់មកចំពោះព្រះភ័ក្ត្រនៃព្រះមានព្រះភាគ ។ ព្រោះហេតុនោះ ទេវតានោះ ទើបបានមានសេចក្ដីរំពឹងថា "ន ខោ បនេតំ បដិរូបំ យាហំ ឥមំ ភិក្ខុ ឥធេវ ជីវិតា វោរោបេយ្យំ : ខ្ញុំអញសម្លាប់ភិក្ខុនេះក្នុងទីនេះដោយអំពើណា អំពើនេះមិនសមគួរដល់អញសោះឡើយ" ក៏ការដែលយើងនឹងផ្ដាច់ជីវិតភិក្ខុរូបនេះ ចេញក្នុងទីនេះ មិនសមគួរឡើយ" ដូច្នេះ ។ ក៏សេចក្ដីរំពឹងនេះថា បើយ៉ាងអីចឹង យើងគួរក្រាបទូលរឿងនេះចំពោះព្រះមានព្រះភាគ ដូច្នេះ បានមានដល់ទេវតានោះ អ្នកគិតយ៉ាងនេះថា ភិក្ខុនេះជាបុត្រមានបិតា, ព្រះមានព្រះភាគបានទ្រង់ស្ដាប់អជ្ឈាចាររបស់ភិក្ខុនេះហើយ នឹងទ្រង់ការពារមារយាទ នឹងទ្រង់បញ្ញត្តិ

សិក្ខាបទពិតប្រាកដ ។

ពាក្យថា សចជ្ជ តុំ ទេវតេ : ម្នាលទេវតា បើអ្នក មានសេចក្តីថា ម្នាលទេវតា បើអ្នក( ផ្តាច់ជីវិតភិក្ខុនោះ ) ក្នុងថ្ងៃនេះសោត ។

បទថា បសវេយ្យាសិ : ត្រូវបាន បានដល់ គប្បីឱ្យកើត គឺគប្បីឱ្យកើតឡើង ។ ក៏ឯព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយកាលទឹងឱ្យទេវតានោះយល់ព្រម ទើបបានត្រាស់ព្រះគាថានេះថា ៖

យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំវ វារយេ
តមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ ។

បុគ្គលណា ឃាត់សេចក្តីក្រោធដែលកើតឡើងហើយ
ដូចសារថីទប់រថដែលកំពុងលឿនបាន តថាគតហៅ
បុគ្គលនោះថា ជាសារថី ជនក្រៅពីនេះគ្រាន់តែជាអ្នក
កាន់ខ្សែបរ ( មិនមែនសារថីឡើយ )[១] ។

ក្នុងវេលាចប់ព្រះគាថា ទេវតានោះ បានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះមានព្រះភាគ កាលទឹងទ្រង់សម្តែងធម៌ដល់បរិស័ទ ដែលមកប្រជុំគ្នាហើយ ទើបបានទ្រង់ត្រាស់ព្រះគាថានេះទៀតថា ៖

យោ ឧប្បតិតំ វិនេតិ កោធំ វិសដំ សប្បវិសំវ ឱសធេហិ

---

១. ខុទ្ទ. ធម្ម. កោធវគ្គ. ៥២. ២៧/៦៨ ។

សោ ភិក្ខុ ជហាតិ ឱរបារំ ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

ភិក្ខុណា បន្ទោបង់សេចក្ដីក្រោធ ដែលឆួលឡើង ដូចបុគ្គលបន្សាបពិសពស់ ដែលជ្រាបទៅ ដោយឱសថទាំងឡាយ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ[១] ។

បណ្ដាគាថា ទាំងពីរនោះ គាថាទី ១ ព្រះធម្មសង្គាហកាចារ្យលើកឡើងកាន់សង្គហៈ ក្នុងធម្មបទ, គាថាទី ២ លើកឡើងកាន់សង្គហៈ ក្នុងសុត្តនិបាត, ចំណែករឿងលើកឡើងកាន់សង្គហៈ ក្នុងវិន័យបិដក ។

លំដាប់នោះ ព្រះមានព្រះភាគកំពុងទ្រង់សម្ដែងធម៌នោះ ពិតមែនទ្រង់ត្រួតពិនិត្យមើលស្ថានទីនៅរបស់ទេវតានោះ ទតឃើញស្ថានទីដែលសមគួរហើយ ទើបត្រាស់ថា "នែទេវតា អ្នកឯងចូរត្រឡប់ទៅវិញចុះ ក្នុងទីឯណោះមានដើមឈើមួយដើមស្ងាត់ អ្នកឯងចូរទៅនៅអាស្រ័យលើដើមឈើនោះចុះ" ។ បានឮថា ដើមឈើនោះ មិនមានក្នុងដែនអាឡវី ។ មាននៅខាងក្នុងកំពែងរបងនៃវត្តជេតវន ដែលមានទេវបុត្រជាម្ចាស់វិមានបានចុតិទៅហើយ; ព្រោះហេតុនោះ ដើមឈើនោះ ទើបត្រាស់ថា "យ៉ាងស្ងាត់" ។ ចាប់តាំងពីកាលនោះមក ទេវតានោះ បាន

---

១. ខុទ្ទ. សុត្ត. ឧរគសូត្រ. ៥៤. ១/១ ។

សេចក្តីគ្រប់គ្រងអំពីព្រះសម្មាសម្ពុទ្ធ បានជាពុទ្ធឧបដ្ឋាយិកា ។ ក្នុងគ្រាមានទេវសមាគម កាលទេវតាអ្នកមានសក្តិធំទាំងឡាយមកហើយ ទេវតាពួកដទៃអ្នកមានសក្តិតូច រមែងថយដរាបទៅទល់មហាសមុទ្រ និងភ្នំចក្រវាឡ ។ ចំណែកទេវតានេះ អង្គុយស្តាប់ធម៌នៅក្នុងទីកន្លែងរបស់ខ្លួនទុំះឯង ។ ទេវតានោះ អង្គុយស្តាប់បញ្ហាទាំងអស់ សូម្បីដែលពួកភិក្ខុសួរក្នុងបឋមយាម (និង)ដែលពួកទេវតាសួរក្នុងមជ្ឈិមយាមលើវិមាននោះឯង ។ សូម្បីស្តេចមហារាជទាំង៤ មកកាន់ទីឧបដ្ឋាករបស់ព្រះមានព្រះភាគ កាលទឹងទៅ ក៏សួរសុខទុក្ខទេវតានោះ ជាមុនហើយទើបទៅ ។

## ពន្យល់ភូតគាមបាតព្យតាយ

ក្នុងបទថា ភូតគាមបាតព្យតាយ : ភិក្ខុធ្វើភូតគាម មានឈើនិងស្មៅជាដើមឱ្យវិនាស នេះ គប្បីជ្រាបវិនិច្ឆ័យ ដូច្នេះ ៖

ដែលឈ្មោះថា ភូតៈ ព្រោះអត្ថថា កើតផង ធំធាត់ឡើងផង ។ អធិប្បាយថា រមែងកើត រមែងចម្រើន ឬថា កើតហើយ ចម្រើនហើយ ។

បទថា គាមោ : ស្រុក គឺ គំនរ ។ គំនរនៃភូតទាំងឡាយ ហេតុនោះ ទើបឈ្មោះថា ភូតគាម ។ ម្យ៉ាងទៀត គំនរ គឺ ភូត ឈ្មោះ

ថា ភូតគាម ។ ពាក្យថា **ភូតគាម** នោះ ជាឈ្មោះនៃស្មៅ និងដើមឈើខៀវស្រស់ដែលតាំងនៅហើយជាដើម ។

ភាវៈនៃការផ្តាច់ ឈ្មោះ **បាតព្យតា** **:** ភាពនៃការធ្វើឱ្យវិនាស ។ អធិប្បាយថា ភាវៈដែលបុគ្គលគប្បីបរិភោគប្រើប្រាស់តាមសេចក្តីពេញចិត្ត ដោយករកាត់និងការដំបំបែកជាដើម ។ ព្រោះភាវៈនៃភិក្ខុនោះជាអ្នកធ្វើភូតគាមឱ្យវិនាស ។ ពាក្យនេះជាសត្តមីវិភត្តិចុះក្នុងអត្ថនៃនិមិត្ត ។ អធិប្បាយថា ត្រូវអាបត្តិបាចិត្តិយ ព្រោះភាពជាអ្នកផ្តាច់ភូតគាមជាហេតុ គឺ ព្រោះការកាត់ភូតគាមជាដើមជាបច្ច័យ ។

## អធិប្បាយភូតគាម ៥ ប្រភេទ មានមូលពូជជាដើម

[៣៥៥] ឥឡូវនេះ ព្រះមានព្រះភាគ កាលទឹងទ្រង់ចែកសម្តែងភូតគាមនោះ ទើបត្រាស់ពាក្យជាដើមថា "ភូតគាមោ នាម បញ្ចវិជជាតានិ **:** **ពូជមាន ៥ យ៉ាង ហៅថា ភូតគាម**" ដូច្នេះ ។

លោកពោលទុកក្នុងអដ្ឋកថាទាំងឡាយថា ក្នុងពាក្យថា ភូតគាមជាដើមនោះ ព្រះមានព្រះភាគទ្រង់លើកភូតគាមឡើង ដោយពាក្យថា ភូតគាមោ នាម ដូច្នេះ ហើយត្រាស់ពាក្យ បញ្ច វិជជាតានិ ជាដើម ដើម្បីទ្រង់សម្តែងពូជកាលមាន ភូតគាមទើបមាន ។ សូម្បីកាលមាន

យ៉ាងនេះ ពាក្យថា យានិ វា បនញ្ញានិបិ អត្ថិ មូលេ ជាយន្តិ : សូម្បីវត្ថុទាំងឡាយដទៃណា កើតអំពីមើមឬឫស ជាដើម ក៏មិនសមគ្នា ។ ពិតមែន ពូជ ៥ ប្រភេទ មានពូជកើតអំពីមើម ឬ ឫសជាដើម មិនមែនកើតនៅត្រង់មើមឬឫសជាដើមទេ, តែពូជទាំងនោះ កាលនឹងកើតត្រង់មើមឬ ឫសជាដើម ក៏ឈ្មោះថា មូលពូជជាដើម ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបវណ្ណនាក្នុងពាក្យថា ភូតគាមោ ឆាម ជាដើមនេះ (ដោយន័យដែលកំពុងពោល) យ៉ាងនេះ ៖

បទថា ភូតគាមោ ឆាម ជាបទគួរបែក

បទថា បញ្ច : ៥ ជាការកំណត់ប្រភេទនៃភូតគាមនោះ ៗ

បទថា ពីជជាតានិ : ពូជកើត ជាបទសម្តែងចេញនូវធម៌ដែលបានកំណត់ទុក ។ សេចក្តីនៃបទថា ពីជជាតានិ នោះថា ដែលឈ្មោះថា ពីជជាត ព្រោះអត្ថថា កើតអំពីពួកគ្រាប់ ពាក្យនេះជាឈ្មោះនៃពូជមានដើមឈើជាដើម ។ ន័យមួយទៀត ពូជទាំងនោះផង កើតហើយផង គឺ ដុះហើយ បានដល់ មានស្លឹកនិងឫសដុះចេញហើយ; ព្រោះហេតុនោះទើបឈ្មោះថា ពីជជាត ៗ ដោយពាក្យថា ពីជជាតនេះ ជាការដែលលោកធ្វើការសង្គ្រោះយកពូជមានខ្ញីជាដើម ដែលគេផ្សាំទុកក្នុងខ្សាច់សើមជាដើម ដែលមានស្លឹក និងឫសដុះឡើងហើយ ។

ឥឡូវនេះ ពូជមានដើមឈើជាដើម ដែលត្រាស់ហៅថា "**ពីជជាតានិ** ព្រោះកើតអំពីពូជពួកណា" កាលទឹងទ្រង់សម្ដែងពូជពួកនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា មូលពីជំ : **ពូជកើតពីមើម ឬឫស** ជាដើម ។ ឧទ្ទេសនៃពូជ មានពូជកើតអំពីមើមឬឫសជាដើមនោះ ប្រាកដច្បាស់ហើយ ។ ក្នុងពាក្យថា "មិនតែប៉ុណ្ណោះ សូម្បីវត្ថុទាំងឡាយដទៃណា កើតអំពីមើមឬឫស ដុះពីមើមឬឫស" នេះ ក្នុងឧទ្ទេស ព្រះមានព្រះភាគទ្រង់សម្ដែងពូជដែលកើតអំពីគ្រាប់ ។ ព្រោះដូច្នោះ គប្បីឃើញសេចក្ដីក្នុងពាក្យថា យានិ វា បនញ្ញានិ : **វត្ថុសូម្បីទាំងឡាយដទៃណា** ជាដើមនេះ យ៉ាងនេះថា សូម្បីវត្ថុទាំងឡាយដទៃណា មានជាដើមថា គុម្ពឈើ វល្លិ និងដើមឈើ ដែលកើតនិងដុះឡើងពីមើមឬឫស មានប្រភេទដូចជាជំឡូងបាកំង[១] ក្រចាប់ ឈូកក្រហម ឈូកខៀវ ឈូកសព្រលឹត ត្រាវ ជំឡូង និងជ្រនៀងជាដើម, គុម្ពឈើ វល្លិ និងដើមឈើជាដើមនោះ រមែងកើត និងរមែងដុះត្រង់មើមឬឫសណា, ក៏មើមឬឫសនោះ ព្រះមានព្រះភាគត្រាស់ទុកហើយក្នុងបាលី, ពូជកើតអំពីមើម មានល្មៀតជាដើមនេះ សូម្បីទាំងអស់ ឈ្មោះថា មូលពីជ ។ ក្នុងខន្ធពីជជាដើម (ពូជកើតអំពីដើម) ក៏ន័យនេះ ។

---

១. សម័យនេះហៅថា ជំឡូងបាកំង តែឥណ្ឌាហៅថា "អាលុ" ។

ក៏ម្យ៉ាងទៀត បណ្ដាពូជទាំងឡាយ មានពូជដែលកើតអំពីដើមជាដើមនេះ ពូជពួកណា មានដើមម្កាក់ ដើមពោន ដើមរលួស ដើមគកណ្ណិការជាដើម បណ្ឌិតគប្បីឃើញថា ពូជកើតអំពីដើម, ពូជទាំងឡាយមានវល្លិមាស វល្លិបួនជ្រុង និង វល្លិដីប៉ូជាដើម បណ្ឌិតគប្បីឃើញថា ពូជកើតពីថ្នាំង, ពូជមានថ្ពៃ ម្លិះ ដើមច្បារជាដើម បណ្ឌិតគប្បីឃើញថា ពូជកើតអំពីត្រួយឬចុង, ពូជមានគ្រាប់ស្វាយ ព្រីង និងខ្នុរជាដើម គប្បីជ្រាបថា ពូជកើតអំពីគ្រាប់ ។

[៣៥៦] ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងប្រភេទនៃអាបត្តិ អនាបត្តិ និងប្រភេទនៃសេចក្ដីត្រូវផ្ដាច់ ដោយអំណាចសញ្ញា ( ឈ្មោះ ) ក្នុងពាក្យដែលព្រះអង្គត្រាស់ថា “ភូតគាមបាតព្យតាយ បាចិត្តិយំ : ភិក្ខុធ្វើភូតគាមមានឈើ និងស្មៅជាដើមឱ្យវិនាស ត្រូវអាបត្តិបាចិត្តិយ” ទើបត្រាស់ថា “ពីជេ ពីជសញ្ញី : វត្ថុជាពូជមែន ភិក្ខុសំគាល់ថា ពូជ” ជាដើម ។

ភូតគាមដែលកើតអំពីគ្រាប់ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហៅថា ពូជ ក្នុងពាក្យថា ពីជេ ពីជសញ្ញី : វត្ថុជាពូជមែន ភិក្ខុសំគាល់ថា ពូជ នោះ ដូចបាយនៃស្រូវសាលីគេហៅថា បាយស្រូវសាលី ក្នុងប្រយោគថា “សាលីនមោទនំ ភុញ្ជតិ : រមែងបរិភោគ

នូវបាយនៃស្រូវសាលី"[១] ជាដើម ដូច្នោះ ។ ចំណែកពូជដែលលោកធ្វើឱ្យរួចផុតទៅចាកភូតគាម ហើយតម្កល់ទុក ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងពាក្យថា "ពីជគាមភូតគាមសមារម្ភា បដិវិរតោ : វៀរស្រឡះចាកការធ្វើពីជគាម និងភូតគាមឱ្យវិនាសហើយ"[២] ជាដើមជាវត្ថុនៃទុក្កដ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីប្រកបនឹងបទដើម នៃសិក្ខាបទវិភង្គដែលថា ភូតគាមោ ឆាម ហើយគប្បីជ្រាបសេចក្ដីក្នុងពាក្យថា ពីជេ ពីជសញ្ញី នេះ យ៉ាងនេះថា ភិក្ខុមានសេចក្ដីសម្គាល់ក្នុងពូជដែលមានឈ្មោះថា ភូតគាម ថា ជាពូជ យកសស្ត្រាជាដើម កាត់ដោយខ្លួនឯងក្ដី ប្រើឱ្យអ្នកដទៃកាត់ក្ដី យកដុំថ្មជាដើមដំខ្លួនឯងក្ដី ប្រើឱ្យអ្នកដទៃដំក្ដី នាំយកភ្លើងចូលទៅដុតដោយខ្លួនឯងក្ដី ប្រើអ្នកដទៃឱ្យដុតក្ដី ត្រូវបាចិត្តិយ ។ តែបណ្ឌិតមិនគប្បីកាន់យកតាមព្រះបាលី ពិន័យបាចិត្តិយព្រោះការផ្ដាច់ នូវពូជមានប្រភេទដែលផុតពីភូតគាមជាដើម ។

---

១. មជ្ឈិ. មូល. វត្ថូបមសូត្រ. ២០. ៩៦/១២៤ ។
២. ទីឃ. សីល. ព្រហ្មជាលសូត្រ. ១៤. ៥/១០ ។

# អធិប្បាយពីជគាម និងភូតគាមជាដើម

ពិតមែន ក្នុងភូតគាមសិក្ខាបទនេះ មានវិនិច្ឆ័យកថា ដូចតទៅនេះ ៖

ភិក្ខុផ្តាច់ភូតគាម ជាបាចិត្តិយ ។ ផ្តាច់ពីជគាមសូម្បីទាំង ៥ យ៉ាង ដែលផុតពីភូតគាម ជាទុក្កដ ។ ឈ្មោះថា ពីជគាម និងភូតគាមនេះ នៅក្នុងទឹកក៏មាន នៅលើគោកក៏មាន ។ បណ្តាពីជគាមនិងភូតគាមដែលនៅក្នុងទឹកនិងលើគោកទាំងពីរនោះ ពីជគាមនិងភូតគាមដែលនៅក្នុងទឹក គឺ សេវាលជាតិ ( សារាយ ) ទាំងដែលមានស្លឹកនិងមិនមានស្លឹកទាំងអស់ មានប្រភេទដូចចកបាយទានិងចកធំជាដើម ដោយហោចទៅសូម្បីតែស្លែទឹក បណ្ឌិតគប្បីជ្រាបថា ភូតគាម ។ ឈ្មោះថា ស្លែទឹក ខាងលើរឹង មានពណ៌គគ្រើមខាងក្រោមទន់ មានពណ៌ខៀវ ។

បណ្តាសេវាលជាតិនោះ ឫសរបស់សារាយណា ចាក់ចុះទៅក្នុងផែនដី, ផែនដីជាឋានរបស់សារាយនោះ ។ ទឹកជាឋានរបស់សារាយដែលអណ្តែតទៅមកលើទឹក ជាបាចិត្តិយដល់ភិក្ខុដែលផ្តាច់ភូតគាមដែលនៅក្នុងផែនដីក្នុងទីណាមួយក្តី លើកឡើងគ្រវាត់ទៅកាន់ទីដទៃក្តី ។ ជាបាចិត្តិយដល់ភិក្ខុដែលផ្តាច់ភូតគាម ដែលអណ្តែតទៅមកលើទឹកដូចគ្នា ។ តែនឹងយកដៃទាំងពីរវាចទៅឯណេះឯណោះ ហើយងូតទឹក គួរ ។

ពិតមែន ទឹកទាំងអស់ជាឋានរបស់សារាយដែលនៅក្នុងទឹកនោះ ព្រោះហេតុនោះ សារាយនោះ មិនទាន់ចាត់ថា ភិក្ខុប្តូរទៅកាន់ទីដទៃ ដោយហេតុត្រឹមប៉ុណ្ណោះទេ, តែនឹងក្លែងលើកឡើងអំពីទឹកដោយរៀវទឹកចេញ មិនគួរ ។ លើកឡើងព្រមទាំងទឹក ហើយដាក់ចុះក្នុងទឹកទៀត គួរ ។ សារាយដោយមកតាមប្រហោងសំពត់តម្រងទឹក, គួរឱ្យធ្វើកប្បិយៈសិន សឹមបរិភោគទឹក ។ ភិក្ខុដកវល្លិនិងស្មៅដែលកើតក្នុងទឹក មានគុម្ពឧប្បល និងគុម្ពបទុមជាដើម ឡើងអំពីទឹកក្តី ផ្តាច់ចេញក្នុងទឹកនោះដោយខ្លួនឯងក្តី ជាបាចិត្តិយ ។ ផ្តាច់គុម្ពឧប្បលនិងគុម្ពបទុមជាដើមដែលអ្នកដទៃដក ឡើងទុកហើយ ជាទុក្កដ ។ ពិតមែន គុម្ពឧប្បលនិងបទុមជាដើមដែល អ្នកដទៃដកឡើងទុកនោះ រមែងដល់ការសង្គ្រោះចូលក្នុងពីជគាម ។ សូម្បីសារាយគឺ ចកធំនិងចកបាយទា[1] ដែលគេលើកឡើងអំពីទឹកហើយ មិនទាន់ស្វិត រមែងដល់នូវការសង្គ្រោះចូលក្នុង

---

១. យោជនាបាលី តត្ថ តិលពីជកសេវាលោ ឆាម ឧបរិ ខុទ្ទកបត្តោ ហេដ្ឋា ខុទ្ទកមូលោ សេវាលោ ។ សាសបសេវាលោ ឆាម សាសបមត្តោ ខុទ្ទកសេវាលោ : បណ្តាសារាយ ទាំងនោះ ដែលឈ្មោះថា តិលពីជកសារាយ បានដល់ សារាយដែលខាង លើមានស្លឹកតូច ៗ ខាងក្រោមមាន ឫសតូច ៗ ដែលមាន ឈ្មោះថា សាសបសារាយ បានដល់ សារាយតូច ៗ មានខ្នាតប៉ុនគ្រាប់ស្ពៃ ។

ពូជ ដែលកើតអំពីចុង ។ ក្នុងអដ្ឋកថា មហាបច្ចរីជាដើម លោកពោលទុកថា ចកបាយទាមិនមានឫស និងពន្លក[១] និងស្លែជាដើម ជាវត្ថុនៃទុក្កដ ។ ហេតុក្នុងពាក្យនោះ មិនប្រាកដ ។ ក្នុងអដ្ឋកថាអន្ធកៈ លោកពោលទុកថា មិនទាន់ជាភូតគាមពេញបរិបូរទេ ហេតុនោះ ទើបជាទុក្កដ ។ សូម្បីពាក្យក្នុងអដ្ឋកថាអន្ធកៈនោះ ក៏មិនសមគ្នា (នឹងព្រះបាលី) ។ ពិតមែន ព្រះមានព្រះភាគ ពិន័យបាចិត្តិយ ព្រោះផ្ដាច់ភូតគាម, ពិន័យទុក្កដ ព្រោះផ្ដាច់ពីជគាម ។

ឈ្មោះថា ភូតគាមពេញបរិបូរ ជាកោដ្ឋាសទី ៣ មិនបានមកក្នុងបាលី មិនបានមកក្នុងអដ្ឋកថាទាំងឡាយឡើយ ។ បើមានមតិថា ចកបាយទានោះ មានឫសនិងពន្លកនោះ នឹងដល់ការសង្គ្រោះចូលក្នុងពីជគាមសោត, សូម្បីពាក្យនោះ ក៏មិនគួរ ព្រោះពូជដូច្នោះ មិនជាមូលហេតុនៃភូតគាមឡើយ ។ ន័យមួយទៀត ពាក្យថា បណ្ដាឋានៈដែលធ្ងន់និងស្រាល ភិក្ខុគួរតាំងនៅក្នុងឋានៈដែលធ្ងន់ នេះជាលក្ខណៈនៃវិន័យ ។

---

១. យោជនា. អនង្កុរកតិលកពូជកោតិ អមូលង្កុរតិលពូជកោ ពូជខ្មាតប៉ុនអង្កាមមិនមាន ឫសនិងពន្លក ឈ្មោះថា ចកតូច ។

## ភូតគាមដែលកើតលើគោក និងការផ្តាច់ភូតគាមនោះ

វិនិច្ឆ័យក្នុងភូតគាមដែលកើតលើគោកតទៅ ៖

ចំណែកដ៏សេសរបស់ពួកឈើ ដែលកាត់ដាច់ហើយ នៅលើគោក ឈ្មោះថា ជាដង្គត់ឈើខៀវស្រស់ ។ ក្នុងដង្គត់ឈើខៀវស្រស់នោះ គល់ថ្ងាន់ ដើមទន្លា ដើមស្ដៅ និងដើមខ្នុរជាដើម ដុះឡើងវិញបាន ។ ដើមឈើនោះលោកសង្គ្រោះចូលភូតគាម ។ គល់ត្នោត និងដូងជាដើម រមែងមិនដុះឡើងបាន ។ គល់ត្នោតជាដើមនោះ លោកសង្គ្រោះចូលពីជគាម ។

ចំណែកគល់ចេកដែលមិនទាន់ធ្លាក់ត្រយូង លោកសង្គ្រោះភូតគាម ។ គល់ចេកដែលធ្លាក់ត្រយូងហើយ លោកសង្គ្រោះចូលពីជគាម ។ តែដើមចេកដែលធ្លាក់ត្រយូងហើយ លោកសង្គ្រោះចូលភូតគាមដូចគ្នា រហូតដល់អស់វេលាដែលនៅមានស្លឹកខៀវ ។ ឫស្សីដែលចេញផ្លែហើយក៏យ៉ាងនោះដែរ ។ តែឫស្សី ក្នុងវេលាស្ងួតចុះមកតាំងពីចុង ទើបដល់ការសង្គ្រោះជាពីជគាម[1] ។ សង្គ្រោះដោយពីជគាមប្រភេទណា គឺដោយពីជគាមប្រភេទកើតពីថ្នាំង ។ តើមានអ្វីកើតអំពីដើមឫស្សីនោះ ? ពិត

---

១. ឫស្សីស្ងួតនោះ បើសង្គ្រោះចូលក្នុងមែកឈើងាប់ដែលនៅជាប់នឹងដើម ត្រូវជាង ព្រោះបើជាពីជគាម ក៏ត្រូវដុះទៀត ។

មែន ប្រសិនបើថា អ្វី ៗ (មែកស្លឹក )មិនគប្បីកើត (នៅនឹងដើមឫស្សីចេញផ្លែ ) គប្បីដល់ការសង្គ្រោះចូលក្នុងភូតគាម ។

ជនទាំងឡាយកត់ដើមពោនជាដើម ប្រមូលគរទុក ។ មែកទាំងឡាយ សូម្បីប្រមាណមួយហត្ថ ដុះចេញពីកំណាត់ឈើដែលគរទុក រមែងដល់ការសង្គ្រោះចូលដោយពីជគាមដូចគ្នា ។ ជនទាំងឡាយបោះចុះក្នុងផែនដី ដើម្បីប្រយោជន៍ជាមណ្ឌបក្តី ដើម្បីប្រយោជន៍ជារបងក្តី ដើម្បីប្រាថ្នានឹងដាំវល្លិក្តី ។ កាលពួកឫសនិងស្លឹកដុះចេញច្រើនហើយ រមែងដល់ការរាប់បញ្ចូលជាភូតគាមទៀតសូម្បីដោយពិត, តែថា កាលដុះត្រឹមតែពកឫស ឬត្រឹមតែពកស្លឹក ក៏សង្គ្រោះចូលជាពីគាមប៉ុណ្ណោះ ។

គ្រាប់ពូជណាមួយ ដែលជនទាំងឡាយយកទឹកស្រោចផ្សាំទុកក្នុងផែនដី ឬថា ជនទាំងឡាយដាក់ដីសើមចុះក្នុងផើងជាដើមផ្សាំទុក, គ្រាប់ទាំងអស់នោះ សូម្បីកាលដុះត្រឹមតែពកឫស ឬត្រឹមតែពកស្លឹក ក៏នៅតែជាពូជដដែរ ។ បើថា ឫសទាំងឡាយ និងពន្លកខាងលើដុះចេញ ក៏នៅចាត់ជាពូជនោះឯង រហូតដល់វេលាដែលពន្លកមិនទាន់ខៀវ ។ ក៏កាលស្លឹកនៃសណ្តែកបាយជាដើមដុះឡើង ឬកាលពន្លកនៃស្រូវជាដើមខៀវស្រស់ កើតស្លឹកមានពណ៌ខៀវហើយ រមែងដល់ការសង្គ្រោះចូលជាភូតគាម ។

ឫសនៃគ្រាប់ត្នោតទាំងឡាយដុះចេញដំបូង ដូចចង្កូមជ្រូក ។ សូម្បីកាលដុះចេញហើយ ក៏ចាត់ជាពីជគាមដូចគ្នា រហូតដល់វេលាដែលស្រទបត្របកស្លឹកខាងលើ មិនទាន់លាចេញ ។ ពន្លកដុះធ្លុះសំបកដូងចេញដូចឈើកន្លាស់ ក៏ចាត់ជាពីជគាមនុ៎ះឯង រហូតដល់វេលាដែលស្រទបត្របកស្លឹកខៀវដូចនិងស្នែងម្រឹគមិនទាន់មាន ។ សូម្បីកាលឫសមិនទាន់ចេញ ត្របកស្លឹកដូច្នោះ កើតឡើងហើយ ក៏ដល់ការសង្គ្រោះចូលក្នុងភូតគាមដែលមិនមានឫស ។

ជំពូកគ្រាប់មានគ្រាប់ស្វាយជាដើម ព្រះវិន័យធរគប្បីកាត់សេចក្តីដោយជំពូកស្រូវជាដើម ។ បញ្ញើក្អែក ឬរុក្ខជាតិយ៉ាងណាមួយដទៃក្តី កើតលើដើមឈើហើយរុំព័ទ្ធដើមឈើ ។ ដើមឈើនុ៎ះឯង ជាឋានរបស់បញ្ញើក្អែកជាដើមនោះ ។ ភិក្ខុផ្តាច់បញ្ញើក្អែកជាដើមនោះក្តី ដកឡើងពីដើមឈើនោះក្តី ជាបាចិត្តិយ ។

វល្លិមួយប្រភេទមិនមានឫស រមែងព័ទ្ធព័ន្ធគុម្ពឈើព្រៃ និងកំណាត់ឈើដូចវង់ចិញ្ចៀន ( វល្លិមាស ), សូម្បីវល្លិនោះក៏មានវិនិច្ឆ័យយ៉ាងនេះដូចគ្នា ។ ត្រង់យ៉មុខផុះ កំពែង និងចេតិយជាដើម មានស្លែពណ៌ខៀវ ។ រហូតដល់មិនទាន់កើតស្លឹក ២-៣ សន្លឹក ក៏នៅសង្គ្រោះចូលជាពូជកើតអំពីចុង ។ កាលស្លឹកទាំងឡាយកើតហើយ ជា

វត្ថុនៃបាចិត្តិយ ។ ព្រោះហេតុនោះ ទឹងឱ្យការលាបទឹកកំបោរសក្នុងឋាន: ដូច្នោះមិនគួរ ។ ទឹងឱ្យការលាបទឹកកំបោរសដែលស្ដើង ៗ លើទីដែលអនុបសម្បន្នលាបហើយ គួរ ។ បើក្នុងរដូវក្ដៅស្លែស្ងួតនៅជាប់ ។ ទឹងយកអំបោសជាដើម កោសស្លែនោះចេញ គួរ ។ ស្លែខាងក្រៅក្អមដាក់ទឹកផឹកជាដើម ជាវត្ថុនៃទុក្កដ, នៅខាងក្នុងជាអព្វោហារិក ។ សូម្បីផ្សិតត្រង់ឈើជម្រះធ្មេញ និងនំជាដើមជាអព្វោហារិកដូចគ្នា ។ សមពិតដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកក្នុងមហាខន្ធក:ថា "បើជញ្ជាំងដែលគេលាបដោយវង់ មានសៅហ្មងពណ៌សម្បុរស ត្រូវជ្រលក់សំពត់ហើយពូតរួចសឹមជូត"[១] ។

បាសាណជាតិ បាសាណទទ្ទុ សេវាល:[២] សេលេយ្យក: (ផ្សិតថ្មស្លែថ្ម សារាយ និងផ្កាថ្ម) ជាដើម មិនទាន់មានពណ៌ខៀវ និងមិនមានស្លឹក ជាវត្ថុនៃទុក្កដ ។ ផ្សិត ជាវត្ថុនៃទុក្កដរហូតដល់វេលាដែលនៅ

---

១. វិន. មហា. មហាខន្ធក. ៦. ៨១/១៤៤ ។ ២. វិមតិ. សាលេយ្យកំ ឆាមសិលាយ សម្ភូតា ឯកា គន្ធជាតិ ប្រែថា របស់ក្រអូបមួយប្រភេទកើតអំពីថ្ម ឈ្មោះថា សាលេយ្យក: ។ ប្រហែលជាបានដល់ ដែលគេហៅថា រំអិលថ្ម ។ សារត្ថទីបនី ៣/២៦៥ សាលេយ្យកំ ឆាម សិលាយ សម្ភូតា ឯកា សគន្ធជាតិ ។

ក្រពុំ ។ ចាប់តាំងពីរីកហើយ ជាអព្វោហារិក ។ ក៏ភិក្ខុបេះផ្សិតអំពីដើមឈើស្រស់ កេះយកសំបកដើមឈើចេញ; ព្រោះហេតុនោះ ទើបជាបាចិត្តិយ ព្រោះការកេះសំបកឈើនោះ ។ សូម្បីក្នុងក្រមរឈើ ក៏មានន័យយ៉ាងនេះដូចគ្នា ។ ក្រមរនៃដើមពោន និងដើមថ្វាន់ជាដើមរបូតអំពីដើមហើយ នៅតោងជាប់ ។ កាលភិក្ខុកាន់យកក្រមរនោះ មិនជាអាបត្តិ ។ សូម្បីជ័រឈើហូរចេញពីដើមឈើហើយ នៅជាប់ក្តី ជាប់នៅត្រង់ដើមឈើស្ងួតក្តី ទឹងកាន់យកគួរ ។ ទឹងកាន់យកអំពីដើមដែលនៅស្រស់ មិនគួរ ។ សូម្បីក្នុងអាចម៍ល័ក្ខ ក៏មានន័យដូចគ្នា ។ កាលភិក្ខុអង្រួនដើមឈើ ឱ្យស្លឹកលឿងជ្រុះក្តី ធ្វើឱ្យផ្កាមានផ្កាកណ្ណិការរោយជាដើមជ្រុះក្តី ជាបាចិត្តិយពិត ។ សូម្បីភិក្ខុចារឹកតួអក្សរជាប់នឹងដើមឈើ មានដើមពោន និងដើមស្រឡៅជាដើម ត្រង់ទីដែលនៅខ្ពីក្តី ត្រង់ស្លឹកត្នោត ដែលកើតនៅលើដើមត្នោតជាដើមនោះក្តី ដោយសេចក្តីរពឹសដៃ ក៏មានន័យដូចគ្នា ។

កាលពួកសាមណេរកំពុងជ្រើសរើសផ្កាឈើដើម្បីបេះ ភិក្ខុនឹងទាញមែកចុះឱ្យ ក៏គួរ ។ តែភិក្ខុកុំគប្បីអប់ទឹកផឹកដោយផ្កាឈើទាំងនោះ ។ ភិក្ខុត្រូវការអប់ទឹកផ្កា គប្បីលើកសាមណេរឡើងហើយឱ្យបេះផ្កាឈើឱ្យ ។ សូម្បីមែកឈើដែលមានផ្លែ ខ្លួនឯងត្រូវការនឹងទំពាឆាន់កុំគប្បីទាញចុះ

មក ។ គប្បីលើកសាមណេរឡើងហើយឱ្យបេះផ្លែឈើ ។ នឹងចាប់ទាញមករួមនឹងសាមណេរទាំងឡាយអ្នកកំពុងដកគុម្ពឈើ ឬវល្លិយ៉ាងណាមួយ មិនគួរ ។ តែដើម្បីឱ្យកើតសេចក្ដីឧស្សាហ៍ដល់សាមណេរទាំងនោះ នឹងចាប់ត្រង់ចុងសម្ដែងអាការទាញដូចកំពុងទាញមក គួរ ។

ភិក្ខុឆូតមែកឈើ ដែលមានមែកដុះឡើង ដែលខ្លួនមិនបានឱ្យអនុបសម្បន្នធ្វើឱ្យជាកប្បិយកន់យក ដើម្បីប្រយោជន៍ដល់ផ្លិតបក់រុយជាដើម ត្រង់សំបក ឬត្រង់ស្លឹក ដោយហោចទៅ សូម្បីដោយក្រចកដៃជាទុក្កដ ។ សូម្បីក្នុងខ្ទីស្រស់ជាដើមក៏ន័យនេះឯង ។ ក៏ប្រសិនបើថាឫសនៃខ្ទីស្រស់ ដែលភិក្ខុឱ្យធ្វើឱ្យជាកប្បិយហើយ រក្សាទុកក្នុងកន្លែងត្រជាក់ ដុះឡើងនឹងកាត់ចំណែកខាងលើ គួរ ។ បើកើតពន្លកនឹងកាត់ចំណែកខាងក្រោម ក៏គួរ ។ កាលឫសនិងពន្លកខៀវកើតហើយ នឹងកាត់មិនគួរ ។

## ការកាត់ទម្លាយដុតដោយខ្លួនឯងនិងប្រើឱ្យធ្វើជាដើម

ពីរបទថា ឆិន្ទតិ វា ឆេទាបេតិ វា : កាប់ដោយខ្លួនឯងក្ដី ប្រើអ្នកដទៃឱ្យកាប់ក្ដី មានសេចក្ដីថា ភិក្ខុកាលនឹងបោសដី ដោយគិតថា យើងនឹងកាត់ស្មៅ កាត់ដោយខ្លួនឯងក្ដី ប្រើអ្នកដទៃឱ្យកាត់ក្ដី ដោយហោចទៅ សូម្បីដោយឆ្អឹងអំបោស ។

ពីរបទថា ភិន្ទតិ វា ភេទាបេតិ វា : **ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យទម្លាយក្តី** មានសេចក្តីថា ដោយហោចទៅ សូម្បីកាលដើរចង្ក្រមក្លែងយកជើងទាំងពីរជាន់ទៅ ដោយគិតថា "វត្ថុដែលនឹងដាច់ ចូរដាច់ទៅ, វត្ថុដែលនឹងបែក ចូរបែកទៅ, យើងនឹងសម្តែងទី ដែលយើងចង្ក្រម" ដូច្នេះ រមែងទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យទម្លាយក្តី នូវស្មៅនិងវល្លិជាដើម ។ បើថា កាលភិក្ខុធ្វើស្មៅ និងវល្លិឱ្យជាគំនរ ស្មៅនិងវល្លិនឹងដាច់ សូម្បីធ្វើឱ្យជាគំនរនោះ ក៏មិនគួរ ។

ក៏ជនទាំងឡាយ រមែងជាប់ឈើពីងពាង (តុក្កតាយន្តពីងពាង) ចងបន្ទាត្រង់ដើមត្នោតជាដើម ដើម្បីត្រូវការមិនឱ្យពួកចោរឡើងលួច ។ ការធ្វើយ៉ាងនោះមិនគួរដល់ភិក្ខុ ។ ក៏បើថា តុក្កតាយន្តពីងពាងត្រឹមតែជាប់នៅត្រង់ដើមឈើប៉ុណ្ណោះ, មិនរួតរឹតដើមឈើ គួរ សូម្បីនឹងពោលថា "លោកចូរកាត់ដើមឈើ, ចូរកាត់វល្លិ, ចូរដកមើម ឬឫស" ដូច្នេះ ក៏គួរពិត ព្រោះជាពាក្យនិយាយ មិនកំណត់ឱ្យប្រាកដ ។ តែនឹងធ្វើការកំណត់ និយាយពាក្យជាដើមថា ចូរកាត់ដើមឈើនេះ មិនគួរ ។ សូម្បីការបញ្ជាក់ឈ្មោះពោលពាក្យជាដើមថា ចូរកាត់ ចូរជំ ចូរដក ដើមស្វាយ វល្លិបួនជ្រុង មើមត្រាវ ជំឡូង ស្មៅដំណេកទន្សាយ ក្រម៉ារដើមឈើឯណោះ ដូច្នេះ ក៏ជាពាក្យដែលមិនកំណត់ពិតប្រាកដដូចគ្នា ។ ពិតមែន ពាក្យជាដើមថា ដើមស្វាយនេះ ប៉ុណ្ណោះ ឈ្មោះថា ជាពាក្យ

កំណត់ឱ្យប្រាកដ, ពាក្យនោះ មិនគួរ ។

ពីរបទថា បចតិ វា បចាបេតិ វា : **ចម្អិនដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យចម្អិនក្តី** មានសេចក្តីថា បណ្ឌិតគប្បីជ្រាបពាក្យទាំងពួងដោយន័យដូចបានពោលហើយក្នុងបឋវីខណនសិក្ខាបទនោះឯងថា ដោយហោចទៅសូម្បីប្រាថ្នានឹងដុតបាត្រ ក្លែងបង្កាត់ភ្លើងខាងលើគំនរស្មៅជាដើមដុតដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យដុតក្តី ដូច្នេះ ។ តែនឹងពោលមិនកំណត់ពិតប្រាកដថា ចូរស្ងោរសណ្តែកបាយ ចូរស្ងោរសណ្តែកលឿងជាដើម គួរ ។ នឹងពោលយ៉ាងនេះថា ចូរស្ងោរសណ្តែកបាយទាំងនេះ, ចូរស្ងោរសណ្តែករាជមាសទាំងនេះ មិនគួរ ។

[៣៥៧] ក្នុងពាក្យថា អនាបត្តិ ឥមំ ជាន : **អាបត្តិមិនមានដល់ភិក្ខុដែលនិយាយថា អ្នកចូរដឹងនូវវត្ថុនេះ** ជាដើម បណ្ឌិតគប្បីឃើញសេចក្តីយ៉ាងនេះថា លោកចូរដឹងមូលភេសជ្ជៈនេះ ចូរឱ្យឫសឈើ ឬ ស្លឹកឈើនេះក្តី ចូរនាំដើមឈើឬវល្លិនេះមកក្តី ត្រូវការផ្កាឈើ ឬផ្លែឈើ ឬស្លឹកឈើនេះក្តី ចូរធ្វើដើមឈើ ឬវល្លិ ឬថា ផ្លែឈើនេះ ឱ្យជាកប្បិយៈក្តី ។ ដោយពាក្យត្រឹមតែប៉ុណ្ណេះ ភិក្ខុឈ្មោះថា ធ្វើការជៀសវៀងពីភូតគាម ។ តែភិក្ខុដែលនឹងបរិភោគគប្បីឱ្យអនុបសម្បន្នធ្វើឱ្យជាកប្បិយដដែលទៀត ដើម្បីដកពីជគាមចេញ ។

## អធិប្បាយការធ្វើកប្បិយនិងវត្ថុដែលប្រើឱ្យធ្វើកប្បិយៈ

ក៏ការធ្វើកប្បិយក្នុងសិក្ខាបទនេះ បណ្ឌិតគប្បីជ្រាបដោយក្រសែនៃសូត្រនេះថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីបរិភោគផ្លែឈើដោយសមណកប្បៈ (សមណវោហារ)៥ គឺ ផ្លែដែលដុតដោយភ្លើង ដែលចាក់ដោយកំបិត ដែលឆូតដោយក្រចក ផ្លែដែលមិនមានគ្រាប់ ដែលប្រឡេះគ្រាប់ចេញហើយ ជាគម្រប់ ៥”[១] ។

បណ្ដាបទទាំងនោះ បទថា អគ្គិបរិចិតំ : ផ្លែដែលដុតដោយភ្លើង មានអត្ថថា អុជ គឺ ស្រុស ដុត អាំងហើយដោយភ្លើង ។

បទថា សត្ថបរិចិតំ : ដែលចាក់ដោយកំបិត មានអត្ថថា ចោះ គឺ ពុះ ចិត កាត់ ឬចាក់ហើយដោយកំបិតតូច ៗ ។ ក្នុងពាក្យថា ដែលឆូតដោយក្រចក ក៏មានន័យដូចគ្នា ។ ផ្លែដែលមិនមានគ្រាប់ និងដែលប្រឡេះគ្រាប់ចេញហើយ ជាកប្បិយដោយខ្លួនវាហើយ ។

ភិក្ខុកាលនឹងធ្វើកប្បិយដោយភ្លើង គប្បីធ្វើកប្បិយដោយបណ្ដាភ្លើងឧស និងភ្លើងអាចម៍គោជាដើម យ៉ាងណាមួយ ដោយហោចទៅសូម្បីដោយដុំលោហៈដែលក្ដៅ ។ ក៏ឯវត្ថុនោះចាប់ដោយដៃម្ខាង គប្បី

---

១. វិន. ចុល្ល. ខុទ្ទកវត្ថុក្ខន្ធក. ១០. ១៣៥/១៣៨ ។

ពោលពាក្យថា កប្បិយំ [១] ហើយធ្វើចុះ ។

កាលទឹងធ្វើដោយកាំបិត សម្តែងស្នាមកាត់ ស្នាមពុះ ដោយចុង ឬដោយមុខនៃកាំបិតដែលធ្វើដោយលោហៈយ៉ាងណាមួយ ដោយហោច ទៅសូម្បីដោយម្ខុលនិងកាំបិតកាត់ក្រចកជាដើម ។ គប្បីពោលថា កប្បិយំ ហើយធ្វើចុះ ។

កាលទឹងធ្វើកប្បិយដោយក្រចក កុំគប្បីធ្វើដោយក្រចកស្អុយ ។ ក៏ក្រចករបស់ពួកមនុស្ស សត្វជើង៤ មានសីហៈ ខ្លាធំ ខ្លាដំបង និង ស្វាជាដើម និងក្រចកនៃបក្សីទាំងឡាយ ជារបស់ស្រួចមុត, គប្បីធ្វើ កប្បិយដោយក្រចកទាំងនោះ ។ ក្រចកនៃសត្វមានសេះ ក្របី ជ្រូក ម្រឹគ និងគោជាដើម មិនមុត, កុំគប្បីធ្វើដោយក្រចកទាំងនោះ ។ សូម្បីធ្វើហើយ ក៏មិនជាការធ្វើ ។ ចំណែកក្រចកដំរី មិនជា ក្រចក ។ ទឹងធ្វើកប្បិយ ដោយក្រចកដំរីទាំងនោះ គួរ ។ តែការធ្វើ កប្បិយដោយក្រចកពួកណា សមគួរ, គប្បីសម្តែងការកាត់ ការបោះ

---

១. ឧបសម្បន្នអ្នកឱ្យធ្វើកប្បិយពោលថា "កប្បិយំ ករោហិ : អនុបសម្បន្នអ្នក ធ្វើកប្បិយៈ យកដៃមួយចាប់វត្ថុដែលទឹងធ្វើកប្បិយៈ ដៃមួយចាប់វត្ថុដែលនិងប្រើធ្វើ កប្បិយៈ មានកាំបិតជាដើមហើយ ចាក់ ឬឆូត ឬអុជត្រង់វត្ថុនោះ ព្រមគ្នាទឹងការ ពោលថា "កប្បិយំ ភន្តេ : គួរលោកម្ចាស់" ជាសម្រេចពិធី ។

ដោយក្រចកទាំងនោះដែលកើត នៅក្នុងទីនោះក្តី ដែលលើកឡើងកាន់ទុកក្តី ពោលថា កប្បិយំ ហើយធ្វើចុះ ។

បណ្តាពូជជាដើមទាំងនោះ ប្រសិនបើថា ពូជគុកប៉ុនភ្នំក្តី ដើមឈើចំនួន ១ ពាន់ ដែលគេកាត់ហើយ ធ្វើឱ្យជាប់ជាគំនរតែមួយក្តី អំពៅបាច់ធំដែលគេចងទុកក្តី, កាលធ្វើពូជមួយគ្រាប់ ឈើមួយមែក ឬអំពៅមួយដើមឱ្យជាកប្បិយហើយ រមែងជាការធ្វើជាកប្បិយហើយទាំងអស់ ។ ដើមអំពៅនិងឈើឧសជារបស់ដែលគេចងរួមគ្នាទុក ។ អនុបសម្បន្ននឹងចាក់ឈើឧសដោយតាំងចិត្តថា យើងនឹងធ្វើអំពៅឱ្យជាកប្បិយ ដូច្នេះ ក៏គួរដូចគ្នា ។ តែបើជារបស់ដែលគេចងក្តួចដោយខ្សែ ឬដោយវល្លិណា នឹងចាក់ខ្សែឬវល្លិនោះ មិនគួរ ។ ជនទាំងឡាយដាក់បំពេញល្អី ដោយកំណាត់អំពៅហើយនាំមក ។ កាលធ្វើអំពៅមួយកំណាត់ឱ្យជាកប្បិយហើយ កំណាត់អំពៅទាំងអស់ រមែងជាការធ្វើឱ្យកប្បិយហើយដូចគ្នា ។

ក៏បើថា ពួកទាយកនាំភត្តលាយជាមួយនឹងម្ទេសទុំជាដើមមក, កាលភិក្ខុពោលថា ចូរធ្វើកប្បិយ បើថា អនុបសម្បន្នចាក់នូវគ្រាប់បាយក៏សមគួរដូចគ្នា ។ សូម្បីក្នុងគ្រាប់ល្ងនិងស្រូវជាដើម ក៏ន័យនេះឯង ។ តែម្ទេសទុំជាដើមនោះ ដែលគេដាក់ចុះក្នុងបបរមិនឋិតនៅជាប់គ្នា

បណ្ដាមេរុសទុំជាដើមនោះគប្បីធ្វើកប្បិយចាក់ម្ដងមួយគ្រាប់ ៗនោះឯង ។ សាច់ផ្លែខ្វិតជាដើម ខាងក្នុងរបេះដាច់សំបកហើយរលុង (នៅខាងក្នុង) ភិក្ខុគប្បីឱ្យជំហើយឱ្យធ្វើកប្បិយ ។ (បើ) នៅជាប់គ្នានឹងសំបក នឹងធ្វើ (កប្បិយ) សូម្បីទាំងសំបក (លលា) ក៏សមគួរ ។

# អធិប្បាយអនាបត្តិវារ

បទថា អសញ្ចិច្ច : ដល់ភិក្ខុមិនបានក្លែង មានសេចក្ដីថា កាលភិក្ខុប្រមៀលថ្ម និងដើមឈើជាដើមក្ដី ទាញមែកឈើក្ដី យកឈើច្រត់កូតផែនដីដើរទៅក្ដី ស្មៅជាដើមដាច់ទៅ ។ ស្មៅទាំងនោះ រមែងឈ្មោះថា ភិក្ខុមិនបានតាំងចិត្តធ្វើឱ្យដាច់ ព្រោះមិនបានតាំងចិត្តកាត់យ៉ាងនេះថា “យើងនឹងកាត់ស្មៅ ដោយការប្រមៀលជាដើមនោះ” ។ មិនជាអាបត្តិដល់ភិក្ខុដែលមិនក្លែងកាត់យ៉ាងនេះ ។

បទថា អសតិយា : ដល់ភិក្ខុភ្លាត់ស្មារតី មានសេចក្ដីថា បញ្ជូនចិត្តទៅមកដទៃ ឈរនិយាយអ្វី ៗនឹងអ្នកណា ៗ យកមេជើង ឬដៃក្តិចស្មៅ ឬវល្លិ, មិនជាអាបត្តិដល់ភិក្ខុដែលកាត់ព្រោះមិនមានសតិយ៉ាងនេះ ។

បទថា អជានន្តស្ស : ដល់ភិក្ខុមិនដឹង មានសេចក្ដីថា ភិក្ខុមិន

ដឹងថា ពីជគាម ឬថា ភូតគាម មាននៅខាងក្នុងនេះ ទាំងមិនដឹងថា យើងកំពុងកាត់ ដាក់ពន្លាក ចបជីក និងចបកាប់ត្រង់របង ឬទីគំនរ ចំបើង ដើម្បីត្រូវការថែរក្សាតែម្យ៉ាង ឬថា ដៃត្រូវភ្លើងឆេះទម្លាក់ភ្លើង ចោលក្តី, បើថា ក្នុងទីនោះ ស្មៅជាដើម ដាច់ក្តី ត្រូវភ្លើងឆេះក្តី មិនជា អាបត្តិ ។

តែគ្រប់ ៗអដ្ឋកថា ក្នុងមនុស្សវិគ្គហបារាជិកវណ្ណនា លោកពោល ទុកថា បើភិក្ខុត្រូវដើមឈើរលំសង្កត់ ឬថា ធ្លាក់ចុះក្នុងរណ្តៅ និងអាច ដើម្បីកាត់ដើមឈើហើយ ប្រមៀលដើមឈើនោះចេញទៅ ឬជីកផែនដី ហើយចេញមកបាន, ភិក្ខុមិនគួរនឹងធ្វើដោយខ្លួនឯង សូម្បីព្រោះហេតុនៃ ជីវិត, តែភិក្ខុដទៃនឹងជីកផែនដី ឬកាត់ដើមឈើ ឬថា កាត់កំណាត់ឈើ ពីដើមឈើស្រស់ គាស់ដើមឈើនោះទៅហើយ ឱ្យ(ភិក្ខុនោះ) ចេញ មក គួរ មិនជាអាបត្តិ ។ ហេតុក្នុងពាក្យនោះ មិនប្រាកដ ។ តែប្រាកដ ត្រឹមតែសូត្រមួយនេះប៉ុណ្ណោះថា "ម្នាលភិក្ខុទាំងឡាយ កាលបើភ្លើង ព្រៃឆេះមក តថាគតអនុញ្ញាតឱ្យដុតភ្លើងតទល់ ដើម្បីនឹងធ្វើសេចក្តីការ ពារបាន"[១] ដូច្នេះ ។ បើថា (ការជីកដីជាដើម) នឹងអនុលោម ចូល សូត្រនេះបាន ក៏មិនអាចបានហេតុផ្សេងគ្នានេះថា ដើម្បីខ្លួនមិនគួរ ដើម្បី

---

១. វិន. ចុល្ល. ខុទ្ទកវត្ថុក្ខន្ធក. ១០. ២៨៧/២២៨ ។

អ្នកដទៃគួរ ។

បើក្នុងសូត្រនេះ អាចារ្យអ្នកចោទគប្បីពោលថា "ភិក្ខុដែលធ្វើប្រយោជន៍ខ្លួនឯង រមែងធ្វើដោយអកុសលចិត្ត ព្រោះស្រឡាញ់ខ្លួនប៉ុណ្ណោះ, តែភិក្ខុដទៃធ្វើឱ្យដោយសេចក្ដីករុណា ; ព្រោះហេតុនោះ ទើបមិនជាអាបត្តិ" ។ សូម្បីពាក្យដែលថា ដើម្បីប្រយោជន៍ដល់ខ្លួននោះ ក៏មិនមែនហេតុ ។ ពិតមែន ភិក្ខុរមែងត្រូវអាបត្តិនេះ សូម្បីដោយកុសលចិត្ត តែព្រោះពាក្យនេះលោកពោលទុកក្នុងអដ្ឋកថាគ្រប់កន្លែង ទើបមិនអាចដើម្បីជំទាស់បាន, បណ្ឌិតទើបគួរស្វែងរកយុត្តិ( សេចក្ដីត្រឹមត្រូវ ) ក្នុងពាក្យនេះ, ម្យ៉ាងទៀត គប្បីទទួលទុកដោយជឿចំពោះអដ្ឋកថាចារ្យទាំងឡាយចុះ ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងមកកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ភូតគាមសិក្ខាបទវណ្ណនា ចប់

# ២. អញ្ញវាទសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

## ពន្យល់រឿងព្រះឆន្នៈ

[៣៥៨] ពីរបទថា អញ្ញេនញ្ញំ អាចរិត្វា : ប្រព្រឹត្តអនាចារ គឺធ្វើវត្ថុដែលមិនគួរធ្វើ ។ មានពាក្យអធិប្បាយថា ត្រូវអាបត្តិក្នុងមកកាយទ្វារឬវចីទ្វារ ។

ពីរបទថា អញ្ញេនញ្ញំ បដិចរតិ : កំពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃ បានដល់ រមែងបន្ទែបន្ទប់ គឺបិទបាំង សង្កត់ពន្លិចពាក្យដទៃដោយពាក្យដទៃ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងវិធីបន្ទែបន្ទប់នោះ ទើបត្រាស់ពាក្យថា "កោ អាបន្នោ : អ្នកណា ត្រូវអាបត្តិ" ជាដើម ។ ក្នុងពាក្យនោះ មានវចនសម្ពន្ធដូចតទៅនេះ ៖

បានឮថា ឆន្នភិក្ខុនោះត្រូវភិក្ខុទាំងឡាយ ឃើញការកន្លងល្មើសយ៉ាងណាមួយ ហើយសាកសួរដោយអាបត្តិនៅក្នុងកណ្តាលសង្ឃថា "ម្នាលអ្នកមានអាយុ លោកជាអ្នកត្រូវអាបត្តិមែនទេ ?" កំពោលថា "អ្នកណាត្រូវ" ដូច្នេះ ។ លំដាប់នោះ កាលភិក្ខុទាំងឡាយពោលថា "លោកហ្នឹងឯង" ទើបពោលថា "ខ្ញុំត្រូវអាបត្តិអ្វី ?" ភ្លាមនោះ កាលភិក្ខុទាំងឡាយពោលថា "បាចិត្តិយ ឬទុក្កដ" កាលនឹងសួរវត្ថុ ទើបពោលថា

"ខ្ញុំត្រូវក្នុងវត្ថុអ្វី ?" ។ លំដាប់នោះ កាលពួកភិក្ខុពោលថា "ក្នុងវត្ថុឈ្មោះឯណោះ" ទើបសួរថា "ខ្ញុំត្រូវយ៉ាងណា ? ខ្ញុំធ្វើអ្វី ទើបត្រូវ ?" ដូច្នេះ ។ គ្រានោះ កាលពួកភិក្ខុពោលថា "ធ្វើការល្មើសឈ្មោះនេះ ទើបត្រូវ" ក៏ពោលបង្វែរទៀតថា "ពួកលោកនិយាយចំពោះអ្នកណា ?" ដូច្នេះ ។ ពេលនោះ កាលពួកភិក្ខុពោលថា "ពួកយើងនិយាយនឹងលោក" ទើបពោលថា "ពួកលោកនិយាយរឿងអ្វី ?"

ម្យ៉ាងទៀត ក្នុងពាក្យថា កោ អាបន្នោ នេះ មានវិធីបន្ទៃបន្ទប់ពាក្យដទៃដោយពាក្យដទៃ សូម្បីក្រៅព្រះបាលី ដូចតទៅនេះ ៖

ភិក្ខុត្រូវពួកភិក្ខុពោលថា ពួកយើងឃើញកហាបណៈ ក្នុងថង់របស់លោក, លោកធ្វើកម្មមិនសមគួរយ៉ាងនេះ ដើម្បីអ្វី ? ហើយពោលថា "ដែលពួកលោកឃើញត្រូវហើយ លោកម្ចាស់ តែនោះមិនមែនកហាបណៈទេ វាជាដុំសំណ" ដូច្នេះក្តី, ត្រូវពួកភិក្ខុពោលថា "ពួកយើងឃើញលោកផឹកសុរា, លោកធ្វើកម្មមិនសមគួរយ៉ាងនេះ ដើម្បីអ្វី ?" ហើយពោលថា "ដែលពួកលោកឃើញត្រូវហើយ តែនោះ មិនមែនសុរា, ជាថ្នាំត្រាំឈ្មោះអរិដ្ឋៈ គេផ្សំឡើងដើម្បីត្រូវការជាថ្នាំ" ដូច្នេះក្តី, ត្រូវពួកភិក្ខុពោលថា "ពួកយើងឃើញលោកអង្គុយក្នុងអាសនៈកំបាំង ជាមួយនឹងមាតុគ្រាម, លោកធ្វើកម្មមិនសមគួរយ៉ាងនេះ ដើម្បីអ្វី ?" ហើយពោលថា "លោកដែលឃើញរាប់ថា ឃើញត្រូវហើយ, តែក្នុងទីនោះមាន

បុរសអ្នកដឹងក្តីនៅជាសម្លាញ់, ព្រោះហេតុអ្វី បានជាលោកមិនឃើញគេ ?" ដូច្នេះក្តី, ត្រូវពួកភិក្ខុសួរថា "លោកឃើញការល្មើសដូច្នេះ យ៉ាងណាមួយទេ ?" ផ្ទៀងត្រចៀកចូលទៅនិយាយថា "មិនបានឮ" ឬភ្នែកសម្លក់ទៅរកពួកភិក្ខុ អ្នកឧប្បសួរក្នុងទីជិតត្រចៀកក្តី, បណ្ឌិតគប្បីជ្រាបថា រមែងបន្ទៃបន្ទប់ពាក្យដទៃដោយពាក្យដទៃ ។

[៣៦១] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អញ្ញវាទកេ វិហេសកេ បាចិត្តិយំ : **ព្រោះពោលនូវពាក្យដទៃ (ឬ) ព្រោះធ្វើឱ្យសង្ឃបានសេចក្តីលំបាក** នេះតទៅ ៖

ពាក្យណា[១] រមែងពោលសេចក្តីដទៃអំពីពាក្យសួរ; ព្រោះដូច្នោះ ពាក្យនោះ ឈ្មោះថា អញ្ញវាទកៈ ។ ពាក្យថា អញ្ញវាទកៈ នេះ ជាឈ្មោះនៃសេចក្តីបិទបាំងពាក្យ (ការបិទបាំងហេតុដទៃដោយហេតុដទៃ) ។

ភាពជាអ្នកស្ងៀមណា រមែងធ្វើសង្ឃឱ្យលំបាក; ព្រោះដូច្នោះ ភាពជាអ្នកស្ងៀមនោះ ឈ្មោះថា វិហេសកៈ ។ ពាក្យថា វិហេសកៈ នេះ ជាឈ្មោះនៃភាពជាអ្នកស្ងៀម ។ ក្នុងភាពជាអ្នកពោលពាក្យដទៃ ក្នុងភាពជាអ្នកឱ្យលំបាកនោះ ។

ដោយបទថា បាចិត្តិយំ : ត្រូវអាបត្តិបាចិត្តិយ នេះ ព្រះមានព្រះភាគពិន័យបាចិត្តិយ ២ ក្នុងវត្ថុ ២ ។

---

១. ប្រែតាមយោជនា ។

[៣៥៨] ពីរបទថា អញ្ញវាទកំ រោបេតុ : ចូរលើកអញ្ញវាទកកម្ម សេចក្តីថា សង្ឃចូរលើកអញ្ញវាទកកម្មឡើង គឺ ចូរឱ្យតាំងឡើង ។ សូម្បីក្នុងពាក្យថា វិហេសកំ រោបេតុ : ត្រូវលើកនូវវិហេសកកម្ម នេះ ក៏ន័យនេះដូចគ្នា ។

[៣៦៤] ពីរបទថា អរោបិតេ អញ្ញវាទកេ : កាលបើអញ្ញវាទកកម្ម មិនបានលើកឡើងទេ បានដល់ ក្នុងភាពជាអ្នកពោលពាក្យដទៃដែលសង្ឃមិនបានលើកឡើងដោយកម្មវាចា ។ សូម្បីក្នុងពាក្យថា អរោបិតេ វិហេសកេ នេះ ក៏ន័យនេះដូចគ្នា ។

[៣៦៦] ក្នុងពាក្យថា ធម្មកម្មេ ធម្មកម្មសញ្ញី : កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ ជាដើម គប្បីជ្រាបសេចក្តីដោយន័យនេះថា អញ្ញវាទកវិហេសករោបនកម្មនោះណាដែលសង្ឃធ្វើហើយ, បើកម្មនោះជាកម្មប្រកប ដោយធម៌, និងភិក្ខុនោះមានសេចក្តីសម្គាល់ក្នុងកម្មនោះថា ជាកម្មប្រកបដោយធម៌ នៅធ្វើភាពជាអ្នកពោលពាក្យដទៃ និងភាពជាអ្នកឱ្យលំបាក, កាលនោះ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះពោលពាក្យដទៃ និងព្រោះធ្វើឱ្យលំបាកនោះ ។

[៣៦៧] ពីរបទថា អជានន្តោ បុច្ឆតិ : ភិក្ខុដែលមិនដឹងសេចក្តី ហើយសួរ មានសេចក្តីថា ភិក្ខុកាលមិនដឹងថា ខ្ញុំត្រូវអាបត្តិ

ឡើយ ទើបសួរថា "លោកទាំងឡាយ និយាយអ្វី ខ្ញុំមិនដឹងឡើយ" ។

ពីរបទថា គិលានោ ន ការេតិ : **ភិក្ខុដែលមានជម្ងឺហើយមិននិយាយ** មានសេចក្ដីថា ភិក្ខុមានព្យាធិត្រង់មាត់ ដូចព្យាធិដែលជាហេតុធ្វើឱ្យនិយាយមិនបាន (គប្បីចង្អុលបង្ហាញឱ្យសង្ឃដឹងផង ជាការល្អ) ។

ក្នុងពាក្យថា សង្ឃស្ស ភណ្ឌនំ វា : **ការបង្កហេតុ(នឹងនាំឱ្យរវល់)ដល់សង្ឃ ក្ដី** ជាដើម បណ្ឌិតគប្បីជ្រាបសេចក្ដីដោយន័យនេះថា ភិក្ខុមានសេចក្ដីសម្គាល់ថា កាលយើងពោលនៅកណ្ដាលសង្ឃ ការបង្កហេតុ ការបង្កជម្លោះ សេចក្ដីទាស់ទែង ឬសេចក្ដីវិវាទនឹងមានដល់សង្ឃ ព្រោះការនិយាយនោះជាបច្ច័យ, សេចក្ដីវិវាទនោះ កុំមានឡើយ ទើបមិននិយាយ ។ បទដែលនៅសល់ងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះមានសមុដ្ឋាន ៣ កើតឡើង មកកាយចិត្ត ១ មកវាចាចិត្ត ១ មកកាយវាចាចិត្ត ១ ជាកិរិយាក៏មាន ជាអកិរិយាក៏មាន ពិតមែន កាលភិក្ខុបិទបាំងហេតុដទៃដោយហេតុដទៃ ជាកិរិយា កាលធ្វើឱ្យលំបាក ព្រោះការនៅស្ងៀម ជាអកិរិយា ជាសញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្តជាទុក្ខវេទនា ដូច្នេះឯង ។

អញ្ញវាទសិក្ខាបទវណ្ណនា ចប់

# ៣. ឧជ្ឈាបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

## ពន្យល់រឿងព្រះទព្វមល្លបុត្រ

[៣៦៨] ប្រើនបទថា ធត្វំ មល្លបុត្តំ ភិក្ខូ ឧជ្ឈាបេន្តិ : បន្ទាប់ភិក្ខុទាំងឡាយ ឱ្យពោលទោសព្រះទព្វមល្លបុត្តដ៏មានអាយុ មានសេចក្ដីថា ពួកភិក្ខុមេត្តិយៈ និងភុម្មជកៈ កាលពោលពាក្យជាដើមថា ឆន្ទាយ ធញ្ញោមល្លបុត្តោ : ព្រះទព្វមល្លបុត្រ ក្រាលសេនាសនៈតាមសេចក្ដីគាប់ចិត្តរបស់ខ្លួន ដូច្នេះ ឈ្មោះថា ញ៉ាំងភិក្ខុទាំងឡាយនោះឱ្យមើលងាយ គឺ ឱ្យសម្លឹងមើលព្រះទព្វមល្លបុត្រនោះដោយសេចក្ដីមើលងាយ, ម្យ៉ាងទៀត សេចក្ដីថា រមែងគិតទៅក្នុងមកលាមក ក៏ក្នុងពាក្យថា ឧជ្ឈាយន្តិ នេះគប្បីជ្រាបលក្ខណៈ (នៃសព្ទ) តាមផ្លូវនៃគម្ពីរសព្ទសាស្ត្រ ។ បាលីថា ឱជ្ឈាបេន្តិ ដូច្នេះ ក៏មាន ។ សេចក្ដីក៏យ៉ាងនេះដូចគ្នា ។

បទថា ឆន្ទាយ : តាមសេចក្ដីគាប់ចិត្តរបស់ខ្លួន បានដល់ ដោយសេចក្ដីពេញចិត្តគ្នា គឺ ដោយធ្លាក់ចូលជាបក្សពួកគ្នា ។ អធិប្បាយថា រមែងចាត់ចែងសេនាសនៈដែលប្រណីត ដើម្បីពួកភិក្ខុដែលជាសម្លាញ់បានឃើញ សម្លាញ់បានសេពគប់ជាគ្នារបស់ខ្លួន ដោយសេចក្ដី

ពេញចិត្តគ្នានោះ ។

បទថា ខិយន្តិ : តិះដៀល គឺ ពួកភិក្ខុមេត្តិយៈនិងភុម្មជកៈ កាលពោលពាក្យថា ឆន្ទាយ ទោសា មល្លបុត្តោ ជាដើម ឈ្មោះថា រមែងប្រកាស ។

[៣៦៩] ក្នុងពាក្យថា ឧជ្ឈាបនកេ ខីយនកេ[១] បាចិត្តិយំ : ពោលទោសតិះដៀល ត្រូវអាបត្តិបាចិត្តិយ នេះ មានវិនិច្ឆ័យថា ពួកភិក្ខុមេត្តិយៈនិងភុម្មជកៈ រមែងឱ្យពោលទោសដោយពាក្យណា, ពាក្យនោះ ឈ្មោះថា ឧជ្ឈាបនកៈ ។ និងពោលតិះដៀលដោយពាក្យណា, ពាក្យនោះ ឈ្មោះថា ខីយនកៈ ព្រោះភាពជាអ្នកឱ្យពោលទោស ព្រោះភាពជាអ្នកពោលតិះដៀលនោះ ។

ដោយបទ បាចិត្តិយំ ព្រះមានព្រះភាគ ពិន័យបាចិត្តិយ ២ ក្នុងវត្ថុ ២ ។

[៣៧០] បទទាំងនេះថា ឧជ្ឈាបនកំ នាម ឧបសម្បន្នំ សង្ឃេន សម្មតំ សេនាសនបញ្ញាបកំ វា ។បេ។ អប្បមត្តកវិស្សជ្ជកំ វា : ដែលហៅថា ភិក្ខុបង្គាប់ភិក្ខុដទៃឱ្យពោលទោស គឺ បុគ្គលដែលសង្ឃសន្មតឱ្យជាអ្នកក្រាលនូវសេនាសនៈក្តី ។ល។ ឱ្យជាអ្នកចែកចាយនូវ

---
[១] ថៃ. ភូមា. ខិយ្យនកេ ។

វត្ថុមានប្រមាណតិចតួចក្តី ដូច្នេះ ភ្ជាប់សេចក្តីនឹងបទថា មង្កុកត្តុកាមោ : មានសេចក្តីប្រាថ្នានឹងធ្វើនូវសេចក្តីបង្អាប់បង្អោន នេះ ។

ដោយអំណាចនៃបទទាំងនេះថា អវណ្ណំ កត្តុកាមោ អយសំ កត្តុកាមោ : ភិក្ខុមានសេចក្តីប្រាថ្នានឹងធ្វើនូវសេចក្តីតិះដៀល មានសេចក្តីប្រាថ្នានឹងធ្វើនូវសេចក្តីបង្អាប់យស បណ្ឌិតគប្បីធ្វើការផ្លាស់វិភត្តិក្នុងបទថា ឧបសម្បន្នំ : នូវឧបសម្បន្ន ជាដើមយ៉ាងនេះថា ឧបសម្បន្នស្ស : ចំពោះឧបសម្បន្ន ដូច្នេះ ។

ក៏ព្រោះក្នុងពាក្យថា ឧជ្ឈាបេតិ វា ខិយតិ វា អាបត្តិ បាចិត្តិយស្ស : ហើយបង្អាប់ភិក្ខុដទៃឱ្យពោលទោស ឬតិះដៀលឧបសម្បន្នបុគ្គល ( នោះ ) ត្រូវអាបត្តិបាចិត្តិយ នេះ ព្រះមានព្រះភាគសូម្បីទ្រង់លើកបទមាតិកាឡើងយ៉ាងនេះថា ខីយនកំ ឆាម : ដែលហៅថា តិះដៀល ដូច្នេះហើយ នឹងគប្បីត្រាស់វិភង្គដែលត្រាស់ហើយនោះឯង នៃបទថា ឧជ្ឈាបនកំ ឆាម នេះ ( តែ ) សេចក្តីប្រែផ្សេងគ្នាយ៉ាងដទៃ ( ក្នុងសិក្ខាបទនេះ ) មិនមានដូចក្នុងអញ្ញវាទសិក្ខាបទ; ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់មិនលើកឡើង ទាំងទ្រង់មិនចែកបទមាតិកា( ខីយនក )នោះទេ ចែកទុកផ្សេងដទៃ ទ្រង់ធ្វើពាក្យនិគមប៉ុណ្ណោះទុករួមគ្នា ។

[៣៧១] ក្នុងពាក្យជាដើមថា ធម្មកម្មេ ធម្មកម្មសញ្ញី : កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ នេះ បណ្ឌិតគប្បីជ្រាបសេចក្ដីដោយន័យនេះថា សម្មតិកម្មណា សង្ឃធ្វើហើយដើម្បីឧបសម្បន្ននោះ, បើកម្មនោះជាកម្មប្រកបដោយធម៌ និងភិក្ខុនោះមានសេចក្ដីសម្គាល់ក្នុងកម្មនោះថា កម្មប្រកបដោយធម៌ រមែងធ្វើការពោលទោស និងពោលតិះដៀល, លំដាប់នោះ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយព្រោះភាពជាអ្នកពោលទោសនិងពោលតិះដៀលនោះ ។

[៣៧២] ក្នុងពាក្យថា អនុបសម្បន្នំ ឧជ្ឈាបេតិ វា ខិយ្យេតិ វា : ភិក្ខុបង្គាប់ភិក្ខុដទៃឱ្យពោលទោសក្ដី តិះដៀលដោយខ្លួនឯងក្ដី នូវអនុបសម្បន្នបុគ្គល មានសេចក្ដីថា ភិក្ខុរមែងញ៉ាំងអនុបសម្បន្នដទៃឱ្យពោលទោសឧបសម្បន្នអ្នកដែលសង្ឃសន្មតហើយ ឬឱ្យមើលងាយក្ដី ពោលតិះដៀលលោកក្នុងសំណាក់នៃ អនុបសម្បន្ននោះក្ដី ។

ពាក្យថា ឧបសម្បន្នំ សម្មតំ អសម្មតំ : ចំពោះឧបសម្បន្នបុគ្គល ដែលសង្ឃមិនបានសន្មត មានសេចក្ដីថា អ្នកដែលសង្ឃមិនបានសន្មតដោយកម្មវាចា គឺ អ្នកដែលសង្ឃលើកភារៈឱ្យថា "នេះ ជាភារៈរបស់លោកតែម្យ៉ាង" ឬថា "អ្នកនាំភារៈនោះទៅដោយខ្លួនឯងដើម្បីត្រូវការការនៅសប្បាយរបស់ភិក្ខុទាំងឡាយ" ។ ម្យ៉ាងទៀត

អធិប្បាយថា (រមែងឱ្យពោលទោសឧបសម្បន្ន) អ្នកធ្វើកម្មដូច្នោះ ក្នុងអាវាសដែលមានភិក្ខុនៅ ២-៣ រូប ។

ក៏ការឱ្យសន្មត ១៣ យ៉ាង ដល់អនុបសម្បន្ន រមែងមិនគួរសូម្បីដោយពិត, តែថា អនុបសម្បន្នដែលបានទទួលសន្មត ក្នុងកាលជាឧបសម្បន្ន ខាងក្រោយតាំងនៅក្នុងភាពជាអនុបសម្បន្ន ព្រះមានព្រះភាគត្រាស់សំដៅយកអនុបសម្បន្ននោះថា "អនុបសម្បន្នបុគ្គលដែលសង្ឃបានសន្មត" ក្នុងពាក្យថា អនុបសម្បន្នំ សម្មតំ វា អសម្មតំ វា : ចំពោះអនុបសម្បន្នបុគ្គល ដែលសង្ឃបានសន្មត ឬសង្ឃមិនបានសន្មត នេះ ។ តែសង្ឃឬភិក្ខុដែលសង្ឃសន្មត ប្រគល់ភារៈដល់សាមណេររូបណា អ្នកឆ្លាតតែម្យ៉ាងថា លោកនឹងធ្វើកម្មនេះ ដូច្នេះ, ព្រះមានព្រះភាគត្រាស់ សំដៅដល់សាមណេរដូច្នោះថា ឬអ្នកដែលសង្ឃមិនបានសន្មត ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងមកកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ឧជ្ឈាបនសិក្ខាបទវណ្ណនា ចប់

# ៤. បឋមសេនាសនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

## ពន្យល់រឿងភិក្ខុច្រើនរូប

[៣៧៤] ពីរបទថា ហេមន្តិកេ កាលេ : កាលហេមន្តរដូវបានដល់ ក្នុងហេមន្តរដូវ គឺ ក្នុងកាលសន្សើមធ្លាក់ (ចុះអ័ព្ទឬទឹកកក) ។

ពីរបទថា កាយំ ឱតាបេន្តា : ហើយកំដៅកាយ បានដល់ អង្គុយលើគ្រែនិងតាំង ជាដើមហើយ ហាលកាយដោយកម្តៅថ្ងៃស្រទន់ ។

ពីរបទថា កាលេ អារោចេតិ : កាលបើគេប្រាប់នូវភត្តកាល គឺ និមន្តឆាន់ បានដល់ កាលគេប្រាប់វេលានៃអាហារយ៉ាងណាមួយ មានយាគូនិងភត្តជាដើម ។

ពីរបទថា ឱវុដ្ឋំ ហោតិ : ទទឹកដោយទឹកសន្សើមជោកអស់ បានដល់ ត្រូវភ្លៀងសន្សើមជះសាចឱ្យសើម ។

[៣៧៥] បទថា អវស្សិកសង្កេតេ : កំណត់យកខែដែលគ្មានភ្លៀង មានសេចក្តីថា រហូតដល់អស់៨ខែ គឺ ៤ខែក្នុងហេមន្តរដូវ ៤ខែក្នុងគិម្ហន្តរដូវដែលមិនបានបញ្ញត្តយ៉ាងនេះថា ខែទាំងឡាយនៃរដូវភ្លៀង ។

បទថា មណ្ឌបេ : រោងមូល បានដល់ ក្នុងបារាំធ្វើដោយមែកឈើ ឬក្នុងបារាំធ្វើដោយឈើលៀប ។

បទថា រុក្ខមូលេ វា : ឬក្រោមម្លប់ឈើ បានដល់ ខាងក្រោមនៃដើមឈើណាមួយ ។

## ស្ថានទីគួររក្សាគ្រែតាំង

ច្រើនបទថា យត្ថ កាកា វា កុលលា វា ន ឩហទន្តិ : ពួកសត្វក្អែកក្តី ពួកសត្វខ្លែងក្តី មិនបានបន្ទោបង់ឧច្ចារៈដាក់ក្នុងទីណា មានសេចក្តីថា សត្វក្អែកនិងសត្វខ្លែងទាំងនេះ ឬពួកសត្វដទៃធ្វើសំបុកនៅជាប្រចាំក្នុងដើមឈើណា ទីងមិនជុះអាចម៍ដាក់សេនាសនៈនោះ, តថាគតអនុញ្ញាតឱ្យរក្សាទុកគ្រែតាំងគល់ឈើដូច្នោះ; ព្រោះហេតុនោះ សត្វទាំងឡាយស្វែងរកចំណី ដែលសម្រាកដើមឈើណាហើយហើរទៅ ទីងរក្សាទុកគ្រែតាំងគល់នៃដើមនោះក៏គួរ ។ ប៉ុន្តែថា សត្វទាំងឡាយ ធ្វើសំបុកនៅជាប្រចាំលើដើមឈើណា កុំគប្បីរក្សាទុកគ្រែតាំងគល់ដើមឈើនោះ ។

ព្រោះព្រះបាលីថា អដ្ឋ មាសេ : អស់កាល ៨ ខែ ដូច្នេះ ក្នុងជនបទទាំងឡាយណា ភ្លៀងមិនធ្លាក់ក្នុងរដូវភ្លៀង, សូម្បីក្នុងជនបទទាំងនោះ ទីងរក្សាទុករហូតដល់អស់ ៤ ខែ ក៏មិនគួរដូចគ្នា ។

ព្រោះព្រះបាលីថា អវស្សិកសង្កេតេ ដូច្នេះ ក្នុងជនបទពួកណា

ភ្លៀងធ្លាក់ក្នុងហេមន្តរដូវ ក្នុងជនបទទាំងនោះ ទឹងរក្សាទុកក្នុងទីវាល សូម្បីក្នុងហេមន្តរដូវ ក៏មិនគួរ ។ ចំណែកក្នុងគិម្ហរដូវ ផ្ទៃមេឃបរិសុទ្ធិប្រាសចាកពពកក្នុងទីទាំងពួង, ក្នុងវេលាដូច្នេះទឹងរក្សាគ្រែទឹងតាំងទុកក្នុងទីវាល ដោយករណីចាំបាច់យ៉ាងណាមួយ រមែងគួរ ។

សូម្បីភិក្ខុដែលកាន់អព្ភោកាសិកធុតង្គ ក៏គួរដឹងវត្ត ។ ពិតមែនបើលោកមានគ្រែចំណែកបុគ្គល ក៏គប្បីដេកលើគ្រែចំណែកបុគ្គលនុ៎ះឯងកាលទឹងកាន់យកគ្រែរបស់សង្ឃ គប្បីកាន់យកគ្រែដែលត្បាញដោយផ្ដៅ ឬដោយខ្សែ ។ កាលគ្រែត្បាញដោយផ្ដៅ ឬដោយខ្សែនោះមិនមាន គប្បីកាន់យកគ្រែចាស់ ។ កាលគ្រែចាស់នោះមិនមាន គប្បីកាន់យកគ្រែដែលត្បាញថ្មី ៗ ឬគ្រែដែលទ្រាប់ដោយស្បែក, ក៏គ្រាកាន់យកហើយ គិតថា "យើងទឹងកាន់រុក្ខមូលយ៉ាងឧក្រិដ្ឋ កាន់អព្ភោកាសយ៉ាងឧក្រិដ្ឋ" ដូច្នេះ ហើយមិនធ្វើសូម្បីនូវកុដិចីវរ (ពិតានធ្វើដោយចីវរ) រៀបចំគ្រែ និងតាំងនោះក្នុងទីវាល ឬក្បែរគល់ឈើ ហើយដេកក្នុងគ្រាដែលមិនមែនសម័យ រមែងមិនគួរ ។ ក៏បើថា ភិក្ខុមិនអាចរក្សាកុដិដែលធ្វើដោយចីវរ សូម្បីទាំង ៤ ជាន់ មិនឱ្យសើមបាន, មានភ្លៀងធ្លាក់បន្តរហូតដល់អស់ ៧ ថ្ងៃ, (ទឹងរៀបចំគ្រែតូចដេក) ក៏គួរ ព្រោះគ្រែដេកប្រព្រឹត្តទៅតាម រាងកាយរបស់ភិក្ខុ ។

ពួកមនុស្សមានចិត្តជ្រះថ្លាក្នុងសីលសម្បទារបស់ភិក្ខុទាំងឡាយអ្នក

នៅក្នុងខ្ទមស្លឹកក្នុងព្រៃ ទើបប្រគេនគ្រែនិងតាំងថ្មីពោលថា "សូមលោកទាំងឡាយប្រើប្រាស់ ដោយការប្រើប្រាស់ជារបស់សង្ឃ" ។ ភិក្ខុទាំងឡាយ អ្នកនៅហើយនឹងទៅ គប្បីបញ្ជូនដំណឹង (ទៅប្រាប់)ដល់ភិក្ខុដែលជាទីពេញចិត្តនឹងគ្នា ក្នុងវិហារដែលជិត ៗ ហើយ សឹមទៅ ។ កាលមិនមានពួកភិក្ខុដែលជាទីពេញចិត្តទេ គប្បីរក្សាទុកក្នុងទីដែលភ្លៀងនឹងមិនស្រោចលើហើយ សឹមទៅ ។ កាលមិនមានទីដែលភ្លៀងមិនស្រោចលើ គប្បីព្យួរទុកត្រង់ដើមឈើហើយ សឹមទៅ ។

## ស្ថានទីគួររក្សាអំបោសនិងវិធីបោស

ភិក្ខុកាន់យកអំបោសឯលានព្រះចេតិយ ទៅបោសលានបន្ទប់ឆាន់ក្តី រោង ឧបោសថក្តី ទីកន្លែងណាមួយ មានបរិវេណដែលសម្រាកពេលថ្ងៃ និងរោងភ្លើងជាដើមលាង គោះ (អំបោសនោះ) ហើយ គប្បីរក្សាអំបោសទុកក្នុងរោងនុ៎ះឯងទៀត ។ សូម្បីភិក្ខុដែលកាន់យកអំបោសក្នុងទីកន្លែងណាមួយ មានរោងឧបោសថជាដើម ទៅបោសបរិវេណដ៏សេសក៏ន័យនេះឯង ។ ចំណែកភិក្ខុណាបោសមកត្រាច់ភិក្ខាចារប្រាថ្នានឹងទៅ (បិណ្ឌបាត)បន្តិស, ភិក្ខុនោះបោសហើយគប្បីរក្សាទុកត្រង់សាលាដែលមាននៅក្នុងចន្លោះមកនោះ ។ បើសាលាមិនមាន, កំណត់ថា ពពកភ្លៀងមិនទាន់តាំងឡើងទេ ដឹងថា ភ្លៀងមិនធ្លាក់ក្នុងរយៈពេលដែលយើងមិន

ទាន់ចេញមកពីស្រុក រក្សាទុកក្នុងទីកន្លែងណាមួយ ហើយត្រឡប់មក គប្បី( នាំមក )រក្សាទុកក្នុងទីដើមទៀត ។

ក្នុងមហាបច្ចរីលោកពោលថា "បើភិក្ខុដឹងថា ភ្លៀងនឹងធ្លាក់ ដាក់ទុកក្នុងទីវាល ជាទុក្កដ" ដូច្នេះ ។ តែបើថា អំបោសជារបស់ដែលគេរក្សាទុកដើម្បីប្រយោជន៍សម្រាប់បោសក្នុងទីនោះ ៗឯង, ភិក្ខុនឹងបោសទីនោះ ៗហើយ រក្សាទុកក្នុងទីនោះ ៗឯង សមគួរ ។ ភិក្ខុដែលនឹងបោសរោងឆាន់ គួរស្គាល់វត្ត ។ វត្តក្នុងការបោសរោងនោះ មានន័យដូចតទៅនេះ ៖

គប្បីបោសខ្សាច់តាំងពីកណ្ដាល កៀរមកទុកត្រង់មុខជើងឈរ ។ គប្បីយកដៃទាំងពីរកើបសម្រាមចេញទៅចោលខាងក្រៅ ។

## លក្ខណៈគ្រែតាំងជាដើម

[៣៧៦] គ្រែដែលគេធ្វើបោះជើងគ្រែ ស៊កមេគ្រែទាំងឡាយចូលទៅក្នុងជើងគ្រែនោះ ឈ្មោះថា មសារកៈ **: គ្រែដែលគេបញ្ចូលមេទៅក្នុងជំណាប់ជើង ។**

គ្រែដែលគេធ្វើឱ្យមេគ្រែបន្ទាំជើងគ្រែ ដោយលក្ខណៈស្រដៀងបល្ល័ង្ក ឈ្មោះថា ពុន្ទិកាពទ្ធ **: គ្រែដែលមានមេជាប់នឹងជើង ។**

គ្រែដែលគេធ្វើដោយជើងដូចទីងជើងនៃសត្វ មានសេះនិងពពែជា

ជើម ឈ្មោះថា កុលិរបាទក : គ្រែដែលមានជើងដូចជើងក្តាម ឬថា គ្រែដែលមានជើង យ៉ាងណាមួយ នេះលោកហៅថា កុលិរបាទក ។ ក៏គ្រែឈ្មោះថា អាហច្ចបាទក : គ្រែដែលមានជើងចុច ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងជំណាប់មេ នេះ លោកពោលទុកក្នុងបាលីខាងមុខទុំះ ឯងយ៉ាងនេះថា "អាហច្ចបាទកោ នាម មញ្ចោ អង្គេ វិជ្ឈិត្វា ឋិតោ ហោតិ : គ្រែដែលមានជើងគ្រាន់តែសិកចូលក្នុងមេហើយតាំងទុក ហៅថា គ្រែដែលមានជើងគ្រាន់តែសិកទុក"[១] ។ ព្រោះហេតុនោះ គ្រែដែលធ្វើបោះមេគ្រែទាំងឡាយ ហើយសិកចុងជើងចូលទៅក្នុងមេគ្រែនោះ កន្លាស់ខាងលើ បណ្ឌិតគប្បីជ្រាបថា គ្រែមានជើងបញ្ចូលមេគ្រែ ។ សូម្បីក្នុងតាំង ក៏មានន័យយ៉ាងនេះដូចគ្នា ។

ប្រើនបទថា អង្គេ សំវេជេត្វា ពន្ធំ ហោតិ : ដែលគេរុំទុកហើយចងភ្ជាប់គ្នាខាងក្នុងមានសេចក្តីថា កៅអីដែលគេត្បាញឱ្យជុំទាំងខាងក្រោមទិងខាងលើ ឯកណ្តាលតូច (ចង្អៀត) មានសណ្ឋានស្រដៀងស្គរ ។ បានឮថា ជនទាំងឡាយធ្វើកៅអីនោះ ឱ្យពាសដោយស្បែកសីហ: និងខាធំនៅត្រង់កណ្តាលក៏មាន ។ ក្នុងសេនាសន:នេះ ឈ្មោះថា ស្បែកដែលជាអកប្បិយមិនមាន ។ ពិតមែន សូម្បីសេនាសន:ដែលជា

---

១. វិន. បាចិ. ភូតគាមវគ្គ. ៤. ១២/១២ ។

វិការនៃមាស ក៏គួរ ។ ព្រោះហេតុនោះ សេនាសនៈនោះ ទើបជារបស់មានតម្លៃច្រើន ។

ពាក្យថា អនុបសម្បន្នំ សន្ថរាបេតិ តស្ស បលិពោធោ : ភិក្ខុប្រើអនុបសម្បន្នបុគ្គលឱ្យតម្កល់ទុក សេចក្តីខ្វល់ខ្វាយនឹងមានដល់ភិក្ខុនោះ មានសេចក្តីថា ជាធុរៈរបស់អនុបសម្បន្នអ្នកដែលត្រូវប្រើឱ្យតម្កល់ទុក ។

ពាក្យថា លេឌ្ឌុបាតំ អតិក្កមន្តស្ស អាបត្តិ បាចិត្តិយស្ស : ដើរកន្លងមួយលេណ្ឌុបាតរបស់មជ្ឈិមបុរសទៅ ត្រូវអាបត្តិបាចិត្តិយ មានសេចក្តីថា ភិក្ខុដែលដើរហួសលេណ្ឌុបាតរបស់មជ្ឈិមបុរសទៅ ត្រូវបាចិត្តិយ ។

## អ្នកទទួលខុសត្រូវសេនាសនបរិក្ខារមានគ្រែជាដើម

ក៏ក្នុងពាក្យថា លេឌ្ឌុបាតំ អតិក្កមន្តស្ស : ដើរកន្លងមួយលេណ្ឌុបាតរបស់មជ្ឈិមបុរសទៅ ជាដើមនេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ព្រះថេរៈធ្វើភត្តកិច្ចក្នុងរោងឆាន់ ហើយបង្គាប់ភិក្ខុកម្មោះថា លោកចូរទៅរៀបចំគ្រែ តាំង ក្នុងទីសម្រាកពេលថ្ងៃ ។ ភិក្ខុកម្មោះនោះ ធ្វើតាមបង្គាប់ហើយអង្គុយ ។ ព្រះថេរៈត្រាច់ទៅតាមសេចក្តីពេញចិត្តហើយ

ទើបទៅក្នុងទីសម្រាកពេលថ្ងៃនោះ ដាក់ចង្ហាន់យាមនិងឧត្ដរាសង្គទុក ។ ចាប់ផ្ដើមតាំងពីនោះទៅជាធុរៈរបស់ព្រះថេរៈ ។ ព្រះថេរៈអង្គុយហើយកាលទឹងទៅ មិនរើសទុកដាក់ មិនបង្គាប់រើសទុកដាក់ ជាបាចិត្តិយ ក្នុងកាលដើរហួសលេណ្ឌុបាតទៅ ។

ក៏បើព្រះថេរៈមិនដាក់ចង្ហាន់យាម និងឧត្ដរាសង្គទុកលើគ្រែនិងតាំងនោះ ចង្ក្រមបណ្ដើរបង្គាប់ភិក្ខុកម្លោះថា លោកអាចទៅបាន, គប្បីប្រាប់ថា "លោកម្ចាស់ នេះគ្រែ នេះតាំង" បើព្រះថេរៈស្ដាល់ទំនៀម, គប្បីពោលថា "លោកទៅចុះ, យើងនឹងធ្វើឱ្យដូចដើមវិញ" ។ បើភិក្ខុដែលថេរៈជាបុគ្គលល្ងង់មិនបានសិក្សាទំនៀម ត្រឡប់គម្រាមគំហោកភិក្ខុកម្លោះថា "ទៅចុះ កុំមកឈរក្នុងទីនេះ, យើងមិនឱ្យអង្គុយ មិនឱ្យដេក", ភិក្ខុកម្លោះឆ្លើយប្រាប់ថា "លោកម្ចាស់ នៅសឹងតាមសប្បាយចុះ" បានខអាងថ្វាយបង្គំលោកហើយទិមន្ដទៅចុះ ។ កាលភិក្ខុកម្លោះនោះទៅហើយជាធុរៈរបស់ព្រះថេរៈប៉ុណ្ណោះ ។ មួយទៀត បណ្ឌិតគប្បីជ្រាបថា ជាអាបត្តិដល់ព្រះថេរៈនោះ ដោយន័យមុននោះតែម្ដង ។

ក៏បើថា ក្នុងខណៈដែលបង្គាប់នុ៎ះឯង ភិក្ខុកម្លោះឆ្លើយប្រាប់ថា "លោកម្ចាស់ ខ្ញុំមានកិច្ចចាំបាច់ត្រូវធ្វើយ៉ាងណាមួយ មានការបោកលាងវត្ថុជាដើម" ព្រះថេរៈពោលទឹងលោកថា "លោករៀបចំហើយចូរទៅចុះ" ដូច្នេះ ហើយចេញចាករោងឆាន់ទៅក្នុងទីដទៃ, ព្រះវិន័យធរគប្បីពិន័យ

(ព្រះថេរៈ)ដោយជំហានជើង ។ បើព្រះថេរៈទៅអង្គុយក្នុងទីនោះឯង, និងជាអាបត្តិដល់ព្រះថេរៈនោះ ក្នុងកាលដើរហួសលេណ្ឌុបាតទៅ ដោយន័យមុននុ៎ះឯង ។

ក៏បើថា ព្រះថេរៈបង្គាប់សាមណេរ, កាលសាមណេរសូម្បីរៀបចំគ្រែ និងតាំងក្នុងរោងដូច្នោះហើយអង្គុយ ព្រះថេរៈចេញទៅទីដទៃអំពីរោងឆាន់ ព្រះវិន័យធរគប្បីពិន័យដោយជំហានដើរ ។ ព្រះថេរៈទៅអង្គុយហើយ ក្នុងវេលានិមន្តទៅវិញ គប្បីពិន័យដោយអាបត្តិក្នុងកាលដើរហួសលេណ្ឌុបាតទៅ ។

ក៏បើថា ព្រះថេរៈកាលនឹងបង្គាប់ថា លោករៀបចំគ្រែនិងតាំងហើយចូរអង្គុយចាំជិតគ្រែនិងតាំងនោះឯង ដូច្នេះ, រមែងបានដើម្បីទៅក្នុងទីដែលខ្លួនប្រាថ្នា ។ ចំណែកអ្នកទទួលបង្គាប់ កាលមិនធ្វើឱ្យជាប្រក្រតីដោយខ្លួនឯង ដើរទៅជាបាចិត្តិយ ក្នុងកាលដើរហួសលេណ្ឌុបាតទៅ ។

ក្នុងចន្លោះការប្រជុំភិក្ខុទាំងឡាយ រៀបចំគ្រែនិងតាំងហើយអង្គុយក្នុងវេលានឹងទៅគប្បីប្រាប់ដល់អារាមិកបុរស(អ្នកធ្វើការវត្ត)ថា "លោកទាំងឡាយ ចូររក្សាគ្រែនិងតាំងនេះទុក" ដូច្នេះ ជាអាបត្តិដល់ភិក្ខុដែលមិនបង្គាប់ចេញទៅ ក្នុងកាលដើរហួសលេណ្ឌុបាតទៅ ។

ធម្មតា កាលមានការស្តាប់ធម៌ដ៏ធំ ភិក្ខុទាំងឡាយនាំយកគ្រែនិងតាំងអំពីរោងឧបោសថខ្លះ អំពីរោងឆាន់ខ្លះ មកទុកក្នុងទីស្តាប់ធម៌នោះ ។

ជាធុរៈរបស់ពួកភិក្ខុម្ចាស់ទីកន្លែងប៉ុណ្ណោះ ។ បើពួកភិក្ខុអាគន្តុកៈកាន់យកទៅដោយអាងថា នេះសម្រាប់ឧបជ្ឈាយ៍របស់យើង នេះសម្រាប់អាចារ្យរបស់យើង ដូច្នេះ, ចាប់តាំងពី នោះទៅជាធុរៈរបស់ពួកភិក្ខុអាគន្តុកៈនោះប៉ុណ្ណោះ ។ ក្នុងវេលាទៅ កាលមិនធ្វើទុកដូចដើម ដើរហួសលេឌ្ឌុបាតទៅ ជាអាបត្តិ ។

តែក្នុងមហាបច្ចរី លោកពោលទុកថា "រយៈវេលាដែលពួកភិក្ខុដទៃមិនទាន់មកអង្គុយជាភារៈរបស់ពួកភិក្ខុដែលចាត់តាំង, កាលពួកភិក្ខុដទៃមកអង្គុយជាភារៈ របស់ពួកភិក្ខុដែលអង្គុយ, បើពួកភិក្ខុដែលអង្គុយទាំងនោះមិនរើសទុកដាក់ខ្លួនឯងក្តី មិនប្រើគេឱ្យរើសទុកដាក់ក្តី ចេញទៅជាទុក្កដ ។ ព្រោះហេតុអ្វី ? ព្រោះរៀបចំដោយមិនបានបង្គាប់ ។

កាលរៀបចំធម្មាសនៈហើយ ភិក្ខុអ្នកសូធ្យឬអ្នកសម្តែងធម៌ មិនទាន់មកត្រឹមណា, ជាភារៈរបស់ពួកភិក្ខុដែលរៀបចំត្រឹមនោះ ។ កាលភិក្ខុអ្នកសូធ្យ ឬអ្នកសម្តែងធម៌មកអង្គុយហើយ ជាភារៈរបស់ភិក្ខុនោះ ។ មានការស្តាប់ធម៌រហូតដល់អស់ថ្ងៃនិងយប់ទាំងអស់ ។ ភិក្ខុដែលសូធ្យឬអ្នកសម្តែងធម៌ដទៃក្រោកទៅ, ភិក្ខុដទៃមកអង្គុយ, ភិក្ខុណា ៗមកអង្គុយ, ជាភារៈរបស់ភិក្ខុនោះ ៗ ។ តែកាលក្រោកឡើងគប្បីពោលថា អាសនៈនេះ ជាភារៈរបស់លោក ហើយទើបទៅ ។ ប្រសិនបើកាលភិក្ខុអ្នកសូធ្យ អ្នកសម្តែងធម៌ក្រៅនេះ មិនទាន់មកទុំះឯង

ភិក្ខុដែលអង្គុយនៅមុនក្រោកទៅ, និងភិក្ខុដែលអង្គុយមុនក្រៅនេះ មក អង្គុយនៅខាងក្នុងឧបចារ ស្ថានទីនោះឯង, ព្រះវិន័យធរមិនគប្បីពិន័យ លោកអ្នកក្រោកទៅដោយអាបត្តិ ។ ក៏បើថា កាលភិក្ខុដែលសូត្រ និង អ្នកសម្តែងធម៌ក្រៅនេះ មិនទាន់មកទុំះឯង ភិក្ខុដែលអង្គុយមុនក្រោកពី អាសនៈ ដើរហួសលេឌ្ឌុបាតទៅ, ព្រះវិន័យធរគប្បីពិន័យ លោកដោយ អាបត្តិ ។ តែក្នុងមហាបច្ចរីលោកពោលន័យនេះទុកថា គ្រប់ ៗកន្លែង ក្នុងកាលដើរហួសលេឌ្ឌុបាតទៅជាទុក្កដក្នុងជំហានទី ១, ជា បាចិត្តិយក្នុងជំហានទី ២ ។

## កម្រាលនិងនាទីក្នុងការរក្សា

[៣៧៧] គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា ចិមិលិកំ វា : គ្រឿងទ្រនាប់ក្តី ជាដើមដូច្នេះ ៖

កម្រាលដែលគេធ្វើទុក ដើម្បីរក្សាសម្បុររបស់ផែនដីដែលធ្វើបរិកម្ម ដោយបាយអជាដើម ឈ្មោះថា ចិមិលិកា ។ ជនទាំងឡាយ ក្រាល កម្រាលនោះទុកខាងក្រោម ហើយក្រាលកន្ទេលផែងតម្រួតទុកខាងលើ ។

កម្រាលដែលគួរក្រាលទុកលើគ្រែនិងតាំង ឈ្មោះថា កម្រាល គ្រែ ។ ប្រភេទនៃកម្រាល មានកន្ទេលផែងជាដើមដែលគួរក្រាលទុកលើ ផែនដី ឈ្មោះថា កម្រាលផែនដី ។ កន្ទេលទន់ដែលគេធ្វើដោយស្លឹក

ត្នោតក្តី ដោយសំបកផ្នែក្តី ឈ្មោះថា កន្ទេលទន់ ។ សូម្បីបណ្តាស្បែកសត្វ មានសីហៈ ខ្លាធំ ខ្លាដំបង ខ្លារខិន និងខ្លាឃ្មុំជាដើមស្បែកប្រភេទណាមួយ ឈ្មោះថា ផែនស្បែក ។ ពិតមែន ឈ្មោះថា ស្បែកដែលលោកហាម ក្នុងការបរិភោគសេនាសនៈ មិនប្រាកដក្នុងអដ្ឋកថាទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា ហាមចំពោះក្នុងការបរិហារស្បែកសីហៈជាដើម ។

គ្រឿងជូតដែលគេធ្វើដោយខ្សែតូច ៗក្តី ដោយសំពត់ចាស់ក្តី ដើម្បីជូតជើង ឈ្មោះថា គ្រឿងជូតជើង ។

តាំងដែលគេធ្វើដោយបន្ទះក្តារ ឈ្មោះថា តាំងបន្ទះក្តារ ។ ម្យ៉ាងទៀត បានដល់ បន្ទះក្តារនិងតាំងដែលធ្វើដោយឈើ ។ សូម្បីគ្រឿងឈើជាដើមទាំងអស់ លោកសង្គ្រោះដោយតាំងផែនក្តារនោះ តែក្នុងមហាបច្ចរីលោកពោលទុកដោយពិស្តារតែម្តងថា ភិក្ខុដាក់ជើងទ្របាត្រគម្របបាត្រ គ្រឿងជូតជើង ផ្តិតស្លឹកត្នោត ផ្តិតស្លឹកឈើ គ្រឿងឈើណាមួយដោយហោចទៅ សូម្បីទុកឲ្យជងទឹក សំឡឹងជងទឹកផឹក ក្នុងទីវាលហើយចេញទៅ ក៏ត្រូវអាបត្តិទុក្កដ ។ តែក្នុងមហាអដ្ឋកថា ន័យនេះលោកសម្តែងទុកក្នុងសិក្ខាបទទី ២ ។ ភិក្ខុស្ងោរទឹកជ្រលក់ក្នុងទីវាលហើយ គប្បីរក្សាគ្រឿងប្រើទាំងពួង គឺភាជនៈទឹកជ្រលក់ ឲ្យជងទឹកជ្រលក់ ស្នូកទឹកជ្រលក់ជាដើម ទុកក្នុងរោងភ្លើង ។ បើរោងភ្លើងមិន

មាន គប្បីរក្សាទុកក្នុងញកភ្នំដែលទឹកភ្លៀងមិនស្រោចលើ ។ សូម្បីកាលញកភ្នំនោះមិនមាន ទោះជាដាក់ទុកក្នុងទីដែលមានពួកភិក្ខុធ្លាប់ថែរក្សា ហើយទើបទៅ ក៏គួរ ។

ពីរបទថា អញ្ញស្ស បុគ្គលិកេ : វត្ថុជារបស់បុគ្គលនៃភិក្ខុឯទៀត មានសេចក្ដីថា ក្នុងមហាបច្ចរីជាដើមពោលថា ការកាន់យកដោយវិស្សាសៈក្នុងបុគ្គលណា មិនឡើង, ជាទុក្កដ ព្រោះវត្ថុរបស់បុគ្គលនោះ, តែវិស្សាសៈក្នុងបុគ្គលណាឡើង, វត្ថុរបស់បុគ្គលនោះ រមែងដូចជារបស់ចំណែកនៃខ្លួន ។

[៣៧៨] ពីរបទថា អាបុច្ឆំ គច្ឆតិ : ភិក្ខុដែលបានប្រាប់ (អ្នកដទៃ) ហើយដើរចេញទៅ មានសេចក្ដីថា បុគ្គលណា នឹងជាភិក្ខុក្ដី សាមណេរក្ដី អារាមិកបុរសក្ដី ជាលជ្ជី រមែងសម្គាល់ដូចជាភារៈរបស់ខ្លួន ។ ភិក្ខុណាពោលលាបុគ្គលដូច្នោះហើយទៅ, មិនជាអាបត្តិដល់ភិក្ខុនោះ ។

ពីរបទថា ឱតាបេន្តោ គច្ឆតិ : ភិក្ខុដែលហាលគ្រឿងសេនាសនៈហើយដើរចេញទៅ មានសេចក្ដីថា ភិក្ខុយកចេញ គប្បីទុកត្រង់កម្ដៅថ្ងៃ ទៅដោយគិតថា យើងនឹងមករើទុកដាក់ មិនជាអាបត្តិដល់ភិក្ខុដែលទៅយ៉ាងនេះ ។

ពាក្យថា កេនចិ បលិពុទ្ធំ ហោតិ : ភិក្ខុដែលមានគ្រឿង

សេនាសនៈ ដែលមានបុគ្គលណាមួយមកបៀតបៀន មានសេចក្តីថា សេនាសនៈ ត្រូវរុកកួនដោយអន្តរាយយ៉ាងណាមួយ ។ ក៏បើភិក្ខុដែលចាស់ជាងឱ្យផ្លាស់ប្តូរចេញហើយ កាន់យក(សេនាសនៈ)ក្តី, បើថា យក្ខឬប្រេត មកអង្គុយក្តី ឬថា ឥស្សរជនខ្លះមកកាន់យកក្តី, សេនាសនៈ ចាត់ថា ត្រូវហួងហែង (ការពារ) ។ ម្យ៉ាងទៀត កាលសត្វកាចមានសីហៈ និងខ្លាធំជាដើម មកកាន់ប្រទេសនោះហើយសម្រាក សេនាសនៈ ចាត់ថា ត្រូវរុកកួនដូចគ្នា ។ មិនជាអាបត្តិដល់ភិក្ខុសូម្បីមិនទុកដាក់ចេញទៅ ព្រោះសេនាសនៈត្រូវអន្តរាយយ៉ាងណាមួយរុកកួនយ៉ាងនេះ ។

បទថា អាបទាសុ : ភិក្ខុដែលមានសេចក្តីអន្តរាយ គឺ ព្រោះការអន្តរាយនៃជីវិត និងអន្តរាយនៃព្រហ្មចរិយៈ ។ បទដ៏ងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងមកកាយវាចា១ កាយវាចាចិត្ត១ ជាកិរិយានិងជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

បឋមសេនាសនសិក្ខាបទវណ្ណនា ចប់

# ៥. ទុតិយសេនាសនសិក្ខាបទវណ្ណនា

គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសេនាសនសិក្ខាបទ ដូចតទៅនេះ ៖

## ទីដេកមានពូកជាដើម

[៣៧៩] ពូកគ្រែក្តី ពូកតាំងក្តី ឈ្មោះថា ពូក ។ កម្រាលមានកម្រាលផែនដីជាដើម មានន័យដូចពោលហើយក្នុងសិក្ខាបទមុនទុំះឯង ។ សំពត់ក្រាលអង្គុយមានជាយ គប្បីជ្រាបថា និសីទនៈ ។ លោកពោលត្រឹមតែប៉ុណ្ណេះថា សំពត់បាវារ សំពត់ព្រំ ឈ្មោះថា សំពត់ក្រាលដេក ។

កម្រាលស្មៅប្រភេទណាមួយ ឈ្មោះថា កម្រាលធ្វើដោយស្មៅ ។ ក្នុងកម្រាលធ្វើដោយស្លឹកឈើ ក៏ន័យនេះ ។

[៣៨០] ក្នុងពាក្យថា បរិក្ខេបំ អតិក្កាមេន្តស្ស : ដើរទៅកន្លងរបង នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ជាទុក្កដដល់ភិក្ខុដែលឈានជើងជំបូងទៅ, ជាបាចិត្តិយក្នុងជំហានទី២ ។ ២ លេណ្ឌុបាតអំពីសេនាសនៈ ឈ្មោះថា ឧបចារៈនៃអារាមដែលមិនមានរបងព័ទ្ធ ។

## ការពោលលានិងរក្សាគ្រឿងសេនាសនៈ

[៣៨១] ក្នុងពាក្យថា អនាបុច្ឆំ វា គច្ឆេយ្យ : ឬឥតបានប្រាប់ ស្រាប់តែដើរចេញទៅ នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

កាលមានភិក្ខុ គប្បីពោលលាភិក្ខុ ។ កាលភិក្ខុនោះមិនមាន គប្បីពោលលាសាមណេរ ។ កាលសាមណេរនោះមិនមាន គប្បីពោលលាអ្នកធ្វើការវត្ត, សូម្បីកាលអ្នកធ្វើការវត្តនោះក៏មិនមាន គប្បីពោលលាម្ចាស់របស់វិហារ អ្នកសាងវត្ត ឬអ្នកណាមួយ ក្នុងវង្សត្រកូលរបស់គេ ។ សូម្បីកាលម្ចាស់របស់វិហារ ឬអ្នកកើតក្នុងវង្សត្រកូលរបស់គេនោះក៏មិនមាន ។ ភិក្ខុគប្បីដាក់គ្រែចុះលើថ្ម ៤ ដុំ ហើយលើកគ្រែតាំងដែលនៅសល់ឡើងដាក់លើគ្រែនោះរួមទីដេកទាំង ១០ យ៉ាង មានពូកជាដើម គរទុកខាងលើ ហើយរក្សាទុកដាក់កណ្ដាលឈើ កណ្ដាលដីបិទទ្វារនិងបង្អួច បំពេញគមិកវត្តហើយទើបទៅ ។

ក៏បើសេនាសនៈភ្លៀងលិចបាន, និងស្មៅ ឬឥដ្ឋដែលគេនាំមកដើម្បីប្រក់ដំបូលក៏មាន, បើអាច ក៏គប្បីប្រក់ ។ បើមិនអាចគប្បីរក្សាគ្រែនិងតាំងទុកក្នុងឱកាសដែលភ្លៀងនឹងមិនស្រោចលើហើយទើបទៅ ។ បើសេនសសនៈភ្លៀងលិចទាំងអស់, កាលអាចគប្បីរក្សាទុកក្នុងផ្ទះរបស់

ពួកឧបាសកខាងក្នុងស្រុក ៗ ប្រសិនបើថា ពួកឧបាសកទាំងនោះ មិនព្រមទទួលពោលថា លោកដ៏មានអាយុ ធម្មតារបស់សង្ឃជារបស់ធ្ងន់, ពួកខ្ញុំខ្លាចភ័យមានភ្លើងឆេះជាដើម ដូច្នេះ ភិក្ខុនឹងដាក់គ្រែចុះខាងលើថ្មសូម្បីក្នុងឱកាសវាលស្រឡះ ហើយរក្សាគ្រែតាំងជាដើមដែលនៅសល់ដោយន័យដូចពោលហើយក្នុងកាលមុននុ៎ះឯង យកស្មៅ និងស្លឹកឈើបិទបាំងហើយទើបទៅ ក៏គួរ ៗ ពិតមែន របស់ដែលនៅសល់ នៅក្នុងទីនោះ សូម្បីនឹងត្រឹមតែជាចំណិតចំណែក (តួគ្រែតាំង) ក៏នឹងជាឧបការៈដល់ពួកភិក្ខុដទៃដែលមកក្នុងទីនោះ ដូច្នេះឯង ៗ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា វិហារស្ស ឧបចារេ : ក្នុង **ឧបចារវិហារ** ជាដើម ដូច្នេះ ៖

បរិវេណ ឈ្មោះថា ឧបចារៈនៃវិហារ ៗ រោងឆាន់ដែលគេសាងទុកក្នុងបរិវេណឈ្មោះថា ឧបដ្ឋានសាលា ៗ បារាំដែលគេសាងទុកក្នុងបរិវេណ ឈ្មោះថា មណ្ឌប ៗ គល់ឈើក្នុងបរិវេណ ឈ្មោះថា រុក្ខមូល ៗ នេះជាន័យដែលលោកពោលទុកក្នុងអដ្ឋកថាគុរុន្ទីមុន ៗ លោកពោលន័យទុកហើយ ក៏ពិតមែនហើយ តែបន្ទប់ខាងក្នុងក្តី សេនាសនៈដែលការពារបាន បាំងទាំងអស់យ៉ាងដទៃក្តី គប្បីជ្រាបថា វិហារ ៗ

ពីរបទថា វិហារស្ស ឧបចារេ : ក្នុងឧបចារវិហារ បានដល់ក្នុងឱកាសខាងក្រៅជិតវិហារនោះ ។

បទថា ឧបដ្ឋានសាលាយំ វា : ក្នុងរោងសម្រាប់ឆាន់ក្តី បានដល់ ក្នុងរោងឆាន់ក្តី ។

បទថា មណ្ឌបេ វា : ក្នុងមណ្ឌបក្តី បានដល់ ក្នុងមណ្ឌបជាទីប្រជុំនៃមនុស្សច្រើនដែលមិនបានបិទបាំង ឬស្លឹកឬស្សីតែបិទបាំងក្តី ។ ក្នុងគល់ឈើមិនមានពាក្យដែលនឹងគប្បីពោល ។

ពីរបទថា អាបត្តិ ទុក្កដស្ស : ត្រូវអាបត្តិទុក្កដ មានសេចក្តីថា ក៏ព្រោះកាលភិក្ខុក្រាលកម្រាលដេក ១០ យ៉ាង មានប្រការដូចដែលពោលហើយខាងក្នុងបន្ទប់ជាដើម និងក្នុងទីគ្រប់គ្រងបាន ហើយចេញទៅ, ទីដេកក្តី សេនាសនៈក្តី រមែងវិនាសអស់ព្រោះកណ្តៀរជាដើមនឹងក្លាយជាដំបូកទៅតែម្តង; ដូច្នោះ ទើបលោកពិន័យជាបាចិត្តិយ ។ តែសម្រាប់ភិក្ខុដែលក្រាលទុកក្នុងទីមានឧបដ្ឋានសាលាជាដើម ក្នុងខាងក្រៅហើយទៅត្រឹមតែទីដេកប៉ុណ្ណោះវិនាសអស់ទៅ ព្រោះជាស្ថានទីគ្រប់គ្រងមិនបាន, សេនាសនៈមិនវិនាសអស់ ។ ព្រោះដូច្នោះ លោកទើបពិន័យជាទុក្កដ ក្នុងឧបដ្ឋានសាលាជាដើមនេះ ។

វិនិច្ឆ័យក្នុងពាក្យថា មញ្ចំ វា បីឋំ វា : នូវគ្រែឬតាំង ជាដើម នេះ គប្បីជ្រាបដូច្នេះ ៖

ក៏ព្រោះពួកកណ្ដៀរទាំងឡាយ មិនអាចដើម្បីស៊ីគ្រែនិងតាំងភ្លាម; ដូច្នោះ ភិក្ខុដាក់គ្រែតាំងនោះទុកសូម្បីក្នុងវិហារហើយទៅ លោកក៏ពិន័យជាទុក្កដ ។ ចំណែកក្នុងឧបចារៈនៃវិហារ ពួកភិក្ខុសូម្បីកាលត្រាច់ទៅត្រូតមើលវិហារ ឃើញគ្រែនិងតាំងនោះហើយទើងទុកដាក់ ។

[៣៨២] វិនិច្ឆ័យក្នុងពាក្យថា ឧទ្ធរិត្វា គច្ឆតិ : ភិក្ខុបានរើកម្រាលយកមកទុកដាក់ដោយខ្លួនឯង រួចហើយដើរចេញទៅ នេះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុកាលទឹងរើទុកដោយខ្លួនឯងហើយទៅ គប្បីរើយកគ្រឿងត្បាញរបស់គ្រែ និងតាំងចេញអស់ហើយ រុំព្យួរទុកលើស្នូរចីវរហើយទើបទៅ ។ សូម្បីភិក្ខុដែលមកនៅខាងក្រោយ ត្បាញគ្រែនិងតាំងថ្មីហើយដេក កាលទឹងទៅ ក៏គប្បីធ្វើយ៉ាងនោះដូចគ្នា ។ ភិក្ខុដែលក្រាលទីដេកអំពីខាងក្នុងជញ្ជាំងទៅ ដល់ខាងក្រៅជញ្ជាំងហើយនៅ ក្នុងវេលាទឹងទៅ គប្បីរក្សាទុកក្នុងទីដែលខ្លួនកាន់យកមកហើយនោះតែម្ដង ។ សូម្បីភិក្ខុដែលលើកចុះពីជាន់លើនៃប្រាសាទហើយនៅខាងក្រោមប្រាសាទ ក៏

ន័យនេះឯង ។ សូម្បីភិក្ខុទុកដាក់គ្រែនិងតាំងទុកក្នុងទីសម្រាកពេលថ្ងៃ និងទីសម្រាកពេលយប់ហើយ ក្នុងវេលានឹងទៅ គប្បីរក្សាទុកដូចដើម ក្នុងទីដែលខ្លួនកាន់យកមកនុ៎ះឯង ។

## ស្ថានទីត្រូវពោលលានិងមិនត្រូវពោលលា

ក្នុងពាក្យថា អាបុច្ឆំ គច្ឆតិ : ភិក្ខុដែលបានប្រាប់ រួចហើយដើរចេញទៅ នេះ មានវិនិច្ឆ័យស្ថានទីគួរពោលលា និងមិនគួរពោលលា ដូចតទៅនេះ ៖

សាលាណា ជាសាលាវែងក្តី ជាសាលាស្លឹកក្តី នៅលើផែនដី, ឬថា ផ្ទះដែលគេសាងលើសសរឈើទាំងឡាយណា ជាកន្លែងកណ្តៀរឡើងបាន, ភិក្ខុកាលនឹងជៀសទៅអំពីសាលាវែងជាដើមនោះ គប្បីពោលលាជាមុន ហើយទើបជៀសទៅ ។ ព្រោះថា កាលស្ថានទីនោះមិនមានអ្នកណាបដិបត្តិត្រឹមតែ ២-៣ថ្ងៃ កណ្តៀរទាំងឡាយ រមែងតាំងឡើង ។

ចំណែកសេនាសនៈណា ជាសេនាសនៈដែលគេសាងទុកលើថ្មដា ឬលើសសរថ្មក្តី ល្អាងភ្នំថ្មក្តី សេនាសនៈដែលលាបបូកកំបោរសក្តី ក្នុងសេនាសនៈណាមិនមានសេចក្តីសង្ស័យក្នុងរឿងកណ្តៀរ (នឹងឡើង), កាលភិក្ខុនឹងជៀសទៅអំពីទីនោះ នឹងពោលលាក៏ដោយ មិនពោលលាក៏

ដោយ ចេញទៅ ក៏គួរ ។ តែការពោលលា រមែងជាទំនៀម (របស់អ្នកត្រៀមនឹងទៅ) ។ បើកណ្ដៀរទាំងឡាយនឹងឡើងមកមួយ ក្នុងសេនាសនៈ សូម្បីដូច្នោះបាន គួរពោលលាមុនហើយទើបទៅ ។

ចំណែកភិក្ខុអាគន្តុកៈណា ប្រព្រឹត្តតាមភិក្ខុដែលកាន់សេនាសនៈរបស់សង្ឃ មិនកាន់សេនាសនៈសម្រាប់ខ្លួន ។ សេនាសនៈនោះជាធុរៈរបស់ភិក្ខុរូបមុនទុំះឯង ដរាបប៉ុនដែលភិក្ខុនោះមិនទាន់កាន់ (សេនាសនៈសម្រាប់ខ្លួន) ។ ក៏ចាប់ផ្ដើមតាំងពីភិក្ខុនោះកាន់យកសេនាសនៈ ហើយនៅដោយឥស្សរៈរបស់ខ្លួន ជាធុរៈរបស់ភិក្ខុអាគន្តុកៈទុំះឯង ។ ប្រសិនបើទាំង២រូបចែកគ្នាហើយកន់យក, ជាធុរៈសូម្បីរបស់លោកទាំង២រូប ។

តែក្នុងមហាបច្ចរីពោលទុកថា បើភិក្ខុ ២-៣ រូប រួមគ្នារៀបចំទុក, ក្នុងវេលាទៅគួរពោលលាគ្រប់រូប ។ បើបណ្ដាភិក្ខុទាំងនោះ ភិក្ខុមួយរូបទៅមុន ធ្វើសេចក្ដីកំណត់ក្នុងចិត្តថា ភិក្ខុរូបក្រោយនឹងបដិបត្តិហើយទៅ រមែងសមគួរ ។ ការរួចផុត (អំពីអាបត្តិ) រមែងមិនមានដល់ភិក្ខុរូបក្រោយ ព្រោះសេចក្ដីចងចិត្ត ។ ភិក្ខុច្រើនរូប បញ្ជូនភិក្ខុមួយរូបឱ្យទៅក្រោល ។ ក្នុងវេលានឹងទៅ ភិក្ខុទាំងអស់ទើបពោលលា, ឬគប្បីបញ្ជូនភិក្ខុមួយរូបទៅពោលលា ។ ភិក្ខុនាំយកគ្រែនិងតាំងជាដើម

មកពីទីដទៃ សូម្បីនៅក្នុងទីដទៃ ក្នុងវេលានឹងទៅ គប្បីនាំទៅទុកក្នុងទីដើមនោះឯង ។ បើកាលភិក្ខុនាំមកពីទីដទៃហើយអង្គុយ, ភិក្ខុដទៃដែលចាស់ជាងមក កុំគប្បីហាមលោក គប្បីឆ្លើយប្រាប់ថា លោកដ៏មានអាយុ គ្រែតាំងខ្ញុំនាំមកពីអាវាសដទៃ លោកគប្បីធ្វើឱ្យជាប្រក្រតីដូចដើម ។ កាលភិក្ខុដែលចាស់ជាងទទួលថា យើងនឹងធ្វើយ៉ាងនោះ ដូច្នេះ ភិក្ខុក្រៅអំពីនេះនឹងទៅ ក៏គួរ ។ ពិតមែន កាលភិក្ខុសូម្បីនាំទៅក្នុងទីដទៃយ៉ាងនេះ ប្រើប្រាស់ជារបស់សង្ឃ គ្រែនិងតាំងនោះនឹងវិនាសអស់ក្តី ចាស់ទ្រុឌទ្រោមទៅក្តី ត្រូវពួកចោរលួចទៅក្តី មិនជាសំណង ។ តែកាលភិក្ខុប្រើប្រាស់ដោយករប្រើប្រាស់ជារបស់បុគ្គល ជាសំណង ។ មួយទៀត ភិក្ខុប្រើប្រាស់គ្រែតាំងរបស់អ្នកដទៃ ដោយករប្រើប្រាស់ជារបស់សង្ឃក្តី ជាចំណែកបុគ្គលក្តី គ្រែតាំងវិនាសទៅ ជាសំណងវិញដូចគ្នា ។

ពាក្យថា កេនចិ បលិពុទ្ធំ ហោតិ : ភិក្ខុមានកម្រាលដែលមានបុគ្គលណាមួយចូលទៅបៀតបៀន មានសេចក្តីថា សេនាសនៈ មានហេតុយ៉ាងណាមួយបណ្តាហេតុមានភិក្ខុដែលចាស់ជាង ឥស្សរជន យក្ខ សីហៈ ម្រឹគកាច និងពស់វែកជាដើមបៀតបៀន ។

ក្នុងពាក្យថា សាបេក្ខោ គន្ត្វា តត្ថ ឋិតោ អាបុច្ឆតិ កេនចិ-

បលិពុទ្ធោ ហោតិ : ភិក្ខុដែលមានសេចក្តីអាឡោះអាល័យ បានដើរចេញទៅឈរក្នុងទីនោះប្រាប់ ( បុគ្គលណាមួយ ) ថា ភិក្ខុនោះមានសេចក្តីអន្តរាយទីមួយមកបៀតបៀនហើយ គប្បីជ្រាបសេចក្តីវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុនៅមានការហួងហែងយ៉ាងនេះថា យើងនឹងមកបដិបត្តិក្នុងថ្ងៃនេះឯង ទៅកាន់ត្រើយទន្លេ ឬចន្លោះស្រុកហើយ ឈរក្នុងទីដែលលោកកើតសេចក្តីគិតដែលនិងទៅនោះឯង បញ្ជូនអ្នកណា ៗ ទៅពោលលា, ឬមានហេតុយ៉ាងណាមួយ បណ្តាហេតុមានទឹកទន្លេជន់ឡើងពេញប្រាំង ព្រះរាជានិងចោរជាដើមបៀតបៀន ។ ភិក្ខុត្រូវអន្តរាយបៀតបៀន មិនអាចនឹងត្រឡប់មកបាន, ដោយហេតុដូចពោលនេះ មិនជាអាបត្តិ សូម្បីដល់ភិក្ខុនោះ ។ បទដែលនៅសល់ព្រមទាំងសមុដ្ឋានជាដើម មានន័យដូចពោលហើយក្នុងបឋមសិក្ខាបទនុ៎ះឯង ។

ទុតិយសេនាសនសិក្ខាបទវណ្ណនា ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## បាចិត្តិយ

## តតិយភាគ

## ៣

## ចប់

# សមន្តបាសាទិកា

## អដ្ឋកថា  វិនយបិដក

## មហាវិភង្គ

## បាចិត្តិយានិ

## ចតុត្ថភាគ

## ៤

# ៦. អនុប្បខជ្ជសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

## ពន្យល់រឿងចូលទៅដេកជ្រៀតបៀត

[១] បទថា បលិពុន្ធន្តិ : បៀតបៀន មានសេចក្តីថា ពួកឆព្វគ្គិយភិក្ខុទៅដល់មុនដណ្តើមបាត្រនិងចីវរទៅឈរជ្រៀតបៀត ។

ពាក្យថា ថេរេ ភិក្ខូ វុដ្ឋាបេន្តិ : ញ៉ាំងភិក្ខុចាស់ទាំងឡាយឱ្យចៀសចេញទៅ មានសេចក្តីថា កាន់យកតាមលំដាប់វស្សាពោលថា "លោកអ្នកមានអាយុ (ទីនេះ) ត្រូវបានដល់ពួកយើង" ដូច្នេះ ហើយឱ្យផ្លាស់ប្តូរចេញទៅ ។

ពាក្យថា អនុប្បខជ្ជ សេយ្យំ កប្បេន្តិ : ចូលទៅដេកប្រៀតបៀត មានសេចក្តីថា ពួកភិក្ខុឆព្វគ្គិយចូលទៅប្រៀតបៀតពោលថា "លោកដ៏មានអាយុ ត្រឹមប៉ុណ្ណោះ ត្រូវបានដល់ពួកលោកម្ចាស់ មិនមែនវិហារទាំងអស់ទេ ។ ឥឡូវនេះ ទីនេះ ត្រូវបានដល់ពួកខ្ញុំព្រះករុណា" ដូច្នេះ ដាក់គ្រែនិងតាំង និងអន្ថយខ្លះ ដេកខ្លះ ធ្វើការស្វាធ្យាយខ្លះ ។

បទថា ជានំ : ដឹង បានដល់ ដឹងថា ភិក្ខុនេះមិនគួរត្រូវផ្លាស់ប្តូរ ។ ព្រោះហេតុនោះឯង ក្នុងវិភង្គនៃបទថា ជានំ នោះ ព្រះមានព្រះភាគ ទើបត្រាស់ពាក្យជាដើមថា "វុឌ្ឍោតិ ជានាតិ : ភិក្ខុដឹងថា ភិក្ខុ

នេះចាស់” ។ ពិតមែន ភិក្ខុចាស់ជាអ្នកមិនគួរបណ្តេញ ព្រោះខ្លួនជាភិក្ខុចាស់, ភិក្ខុដែលអាពាធជាអ្នកមិនគួរបណ្តេញ ព្រោះលោកជាអ្នកជម្ងឺ ។ ក៏សង្ឃកំណត់ភាពជាអ្នកមានឧបការៈច្រើន និងភាពជាអ្នកមានគុណពិសេស នៃភិក្ខុភណ្ឌាគារិកក្តី នៃភិក្ខុដែលជាព្រះធម្មកថិកក្តី និងព្រះវិន័យធរជាដើមក្តី នៃភិក្ខុដែលជាអាចារ្យទូន្មានគណៈក្តី ទើបសន្មតវិហារឱ្យដើម្បីត្រូវការឱ្យនៅប្រចាំ ។ ព្រោះហេតុនោះ សង្ឃឱ្យវិហារដល់ភិក្ខុណា, ភិក្ខុសូម្បីនោះឈ្មោះថា ជាអ្នកមិនគួរបណ្តេញ ។ ក៏ក្នុងពាក្យថា វុឌ្ឍាតិ ជាឆាតិ ជាដើមនេះ សង្ឃប៉ុណ្ណោះនឹងឱ្យសេនាសនៈ ដែលសមគួរសូម្បីដល់ភិក្ខុដែលអាពាធក៏ពិត, ទោះជាយ៉ាងនោះ ភិក្ខុអាពាធក៏ត្រាស់ចែកទុកមួយផ្នែក ដើម្បីសម្តែងថា សូម្បីជាអ្នកមានសេនាសនៈដែលសង្ឃមិនទាន់អបលោកន៍ឱ្យ ក៏មិនគួរបៀតបៀត គួរអនុគ្រោះដូច្នេះ ។

(៣) ក្នុងពាក្យថា ឧបចារេ : ក្នុងឧបចារៈ នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

មួយហត្ថមួយចំអាមដោយជុំវិញក្នុងវិហារធំ ឈ្មោះឧបចារៈនៃគ្រែនិងតាំងមុន ។ ក្នុងវិហារតូចមួយហត្ថ មួយចំអាមចាកទី ល្មមនឹងតម្កល់គ្រែនិងតាំងបាន (ឈ្មោះថា ឧបចារនៃគ្រែតាំង) ។ មកទទឹងមួយ

ហត្ថមួយចំអាម ចាប់ពីទីដាក់ជុំថ្ងសម្រាប់លាងជើងដែលដាក់ទុកត្រង់ទ្វារ និងទីបន្ទោបង់បស្សាវៈ រហូតដល់គ្រែនិងតាំង ឈ្មោះឧបចារ ។ ភិក្ខុណាប្រាថ្នានឹងសម្រេចការដេកជៀតបៀត ក្រាលខ្លួនឯងក្តី ឱ្យគេក្រាលក្តី នូវទីដេកក្នុងឧបចារនៃភិក្ខុដែលឈរត្រង់ឧបចារនៃគ្រែ ឬតាំងនោះក្តី អ្នកចូល ឬចេញទៅក្តី ភិក្ខុនោះត្រូវទុក្កដ ។

ក្នុងពាក្យថា អភិនិសីទតិ វា អភិនិបជ្ជតិ វា : អង្គុយសង្កត់ក្តី ដេកសង្កត់ក្តី នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ជាបាចិត្តិយ ព្រោះហេតុត្រឹមតែថា អង្គុយសង្កត់ខ្លះ ព្រោះហេតុត្រឹមតែថា ដេកលើខ្លះ, តែបើភិក្ខុធ្វើការអង្គុយនិងធ្វើការដេកទាំង ២ យ៉ាង ជាបាចិត្តិយ ២ ។ កាលក្រោកអង្គុយ ៗ ឬក្រោកដេក ៗ ជាបាចិត្តិយគ្រប់ប្រយោគ( នៃការអង្គុយ ដេក ) ។

បណ្ឌិតគប្បីជ្រាបប្រភេទនៃទុក្កដ សូម្បីក្នុងទុក្កដវារៈ មានជាដើមថា វិហារស្ស ឧបចារេ ដូច្នេះ ក្នុងពាក្យថា ឧបចារំ ឋបេត្វា សេយ្យំ សន្ថរតិ វាសន្ថរាបេតិ វា : ភិក្ខុក្រាលដោយខ្លួនឯងក្តី ប្រើគេឱ្យក្រាលក្តី នូវទីដេក វៀរលែងតែឧបចារ( នៃគ្រែតាំង ) នេះ និងជាទៃអំពីពាក្យនេះ ដូចប្រភេទនៃបាចិត្តិយដែលត្រាស់ទុកក្នុងការធ្វើកិច្ចទាំង ២ គឺ ត្រឹមតែអង្គុយនិងដេកលើ ក្នុងពាក្យថា អភិនិសីទតិ វា អភិនិបជ្ជតិ

វា នេះ និងក្នុងប្រភេទនៃប្រយោគដូច្នោះ ។ ព្រោះមិនត្រូវការដោយវិសភាគបុគ្គលដូច្នេះនៅក្នុងវិហារជាមួយគ្នា ឬក្នុងបរិវេណជាមួយគ្នា ដូច្នោះ លោកទើបហាមការនៅនៃវិសភាគបុគ្គលនោះ ក្នុងទីគ្រប់កន្លែងតែម្តង ។

សូម្បីក្នុងពាក្យថា អញ្ញស្ស បុគ្គលិកេ : ជារបស់បុគ្គល គឺវិហារនៃភិក្ខុដទៃ នេះ ក៏គប្បីជ្រាបវិនិច្ឆ័យ ដូច្នេះ ៖

សេនាសនៈជាចំណែករបស់បុគ្គលដែលស្និទ្ធស្នាលគ្នា ដូចជាចំណែកបុគ្គលខ្លួនដែរ មិនជាអាបត្តិក្នុងសេនាសនៈជាចំណែកបុគ្គលរបស់អ្នកស្និទ្ធស្នាលគ្នានោះ ។

[៤] បទថា អាបទាសុ : មានសេចក្តីអន្តរាយ មានសេចក្តីថា បើមានអន្តរាយនៃជីវិត និងព្រហ្មចរិយដល់ភិក្ខុដែលនៅខាងក្រៅ ព្រោះតែអន្តរាយបែបនោះ សូម្បីភិក្ខុអ្នកចូលទៅ (ខាងក្នុង) ក៏មិនជាអាបត្តិ ។ បទដែលនៅសល់ ងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

អនុប្បខជ្ជសិក្ខាបទវណ្ណនា ចប់

# ៧. និកឌ្ឍនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

## ស្ថានទីនិងកិរិយាអូសទាញ

[៧] ពាក្យថា ឯកេន បយោគេន ពហុកេបិ ទ្វារេ អតិក្កាមេតិ : ភិក្ខុជាភិក្ខុទង់ទាញឱ្យកន្លងទ្វារទាំងឡាយជាច្រើន មានសេចក្តីថា ក្នុងសេនាសនៈទាំងឡាយ ដូចប្រាសាទ ៤-៥ ជាន់ ក្តី សាលា ៤ ជ្រុង មានស៊ុមទ្វារ ៦-៧-៨ ស៊ុមក្តី ភិក្ខុចាប់ត្រង់ដៃទាំងពីរ ឬត្រង់កឱ្យឈានចេញទៅដោយប្រយោគតែមួយ មិនបានឈប់, ជាបាចិត្តិយតែមួយប៉ុណ្ណោះ ។ កាលឱ្យឈានចេញទៅឈប់ជាសំណាក់ ៗ ដោយប្រយោគផ្សេង ៗ ជាបាចិត្តិយច្រើនតាមចំនួនទ្វារ ។ សូម្បីកាលមិនយកដៃចាប់ពាល់ ទាញចេញទៅដោយវាចា ពោលថា ចូរចេញទៅក៏ន័យនេះឯង ។

វិនិច្ឆ័យក្នុងពាក្យថា អញ្ញំ អាណាបេតិ : ភិក្ខុបង្គាប់អ្នកដទៃនេះ គប្បីជ្រាបដូច្នេះ ៖

ត្រឹមតែបង្គាប់ថា "ចូរទាញភិក្ខុនេះចេញទៅ" ជាទុក្កដ ។ បើភិក្ខុដែលបានទទួលបង្គាប់ម្តងនោះឱ្យឈានផុតទ្វារសូម្បីច្រើនកន្លែង ក៏ត្រូវបាចិត្តិយតែមួយ ។ តែបើថា លោកបានទទួលបង្គាប់កំណត់យ៉ាង

នេះថា “ចូរទាញចេញឱ្យកន្លងទ្វារប៉ុណ្ណេះទៅ”ក្តី ថា “ចូរទាញទៅដរាបដល់ទ្វារធំ”ដូច្នេះក្តី ជាបាចិត្តិយតាមចំនួនទ្វារ ។

(៨) ពីរបទថា តស្ស បរិក្ខារំ : នូវបរិក្ខារភិក្ខុនោះ មានសេចក្តីថា ភិក្ខុណា ជញ្ជូនចេញខ្លួនឯងក្តី ប្រើឱ្យជញ្ជូនចេញក្តី នូវរបស់យ៉ាងណាមួយ ដែលជារបស់ចំណែកនៃភិក្ខុនោះ មានបាត្រ ចីវរ ធម្មក្រក តម្រងទឹក គ្រែ តាំង ពូក និងខ្នើយជាដើម ដោយហោចទៅសូម្បីបំណែកទឹកជ្រលក់ ជាទុក្កដដល់ភិក្ខុនោះច្រើនតាមចំនួននៃវត្ថុ ។ លោកពោលទុកក្នុងមហាបច្ចរីថា ក៏ក្នុងវត្ថុទាំងនោះ ដែលម្ចាស់របស់ចងទុកយ៉ាងមាំ ជាអាបត្តិតែមួយប៉ុណ្ណោះ ។

វិនិច្ឆ័យសូម្បីក្នុងពាក្យថា អញ្ញស្ស បុគ្គលិកេ : ព្រោះវិហារជារបស់បុគ្គលនៃភិក្ខុដទៃ គឺវិហាររបស់គេ នេះ គប្បីជ្រាបដូច្នេះ ៖

របស់ជាចំណែកបុគ្គលអ្នកស្និទ្ធស្នាល ដូចគ្នានឹងរបស់ជាចំណែកនៃខ្លួនទុ៎ះឯង ។ ក៏ក្នុងទីគ្រប់ ៗកន្លែង អ្នកសិក្សាគប្បីជ្រាបន័យដូចក្នុងពាក្យនេះ ។ តែក្នុងទីណានឹងមានសេចក្តីប្លែកគ្នា ពួកយើងនឹងពោលទុកក្នុងទីនោះ ។

(៩) វិនិច្ឆ័យក្នុងពាក្យថា អលជ្ជី និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា : ភិក្ខុដែលទង់ទាញឯង ឬប្រើគេឱ្យទង់ទាញនូវភិក្ខុអលជ្ជី ជាដើម

គប្បីជ្រាបដូច្នេះ ៖

ភិក្ខុ រមែងបានដើម្បីបណ្តេញភិក្ខុដែលធ្វើសេចក្តីទាស់ទែង និង អ្នកធ្វើការឈ្លោះគ្នាប៉ុណ្ណោះ ចេញចាកសង្ឃារាមទាំងមូល ។ ព្រោះថា លោកបានបក្ខពួកហើយ គប្បីទម្លាយសង្ឃក៏បាន ។ ចំណែកពួកភិក្ខុ អលជ្ជីជាដើម ភិក្ខុគប្បីទាញចេញចាកទីនៅរបស់ខ្លួនប៉ុណ្ណោះ នឹងដេញ លោកទាំងនោះ ចេញចាកសង្ឃារាមទាំងមូល មិនគួរ ។

បទថា ឧម្មត្តកស្ស : ដល់ភិក្ខុឆ្កួត បានដល់ មិនជាអាបត្តិដល់ ភិក្ខុឆ្កួតនោះឯង ។ បទដែលនៅសល់ងាយយល់ទាំងនោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងមកកាយចិត្ត ១ វាចា ចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្មវចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

និកឌ្ឍនសិក្ខាបទវណ្ណនា ចប់

# ៨. វេហាសកុដិសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

## ពន្យល់វេហាសកុដិនិងកិរិយាអង្គុយសង្កត់

[១០] បទថា ឧបរិវេហាសកុដិយា : លើថ្នាក់ បានដល់ លើកុដិ២ជាន់ក្តី លើកុដិ៣ជាន់ក្តី ដែលខាងលើមិនបានក្រាលផ្ទៃទុក ។

ពាក្យថា មញ្ចំ សហសា អភិនិសីទតិ : អង្គុយចុះដោយរហ័សសង្កត់គ្រែ បានដល់ អង្គុយសង្កត់ គឺ អង្គុយសង្កត់គ្រែដោយរហ័ស ។ ម្យ៉ាងទៀត ពាក្យថា មញ្ចំ នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ សេចក្តីថា អង្គុយចុះលើគ្រែ ។ ក៏ពាក្យថា អភិ នេះ ត្រឹមតែជាឧបសគ្គដើម្បីធ្វើឱ្យបទស្អាតល្អប៉ុណ្ណោះ ។

បទថា បតិត្វា : ក៏របូតធ្លាក់ចុះ គឺ ធ្លាក់ចុះ ឬរបូតចេញហើយ ។ ព្រោះថា ក្នុងខាងលើរបស់ជើងគ្រែនោះ សូម្បីស្នៀតក៏មិនដាក់; ព្រោះដូច្នោះ, ជើងគ្រែទើបរបូតចេញ ។

បទថា វិស្សរមកាសិ : ស្រែកសំឡេងឮប្លែក ៗ គឺ បានធ្វើសំឡេងស្រែកយំខុសពីប្រក្រតី ។

[១២] ពាក្យថា វេហាសកុដិ ឆាម មជ្ឈិមស្ស បុរិសស្ស អសីសឃដ្ដា : ធ្វើមិនទង្គិចក្បាលមជ្ឈិមបុរស ហៅថា ថ្នាក់ មានសេចក្តីថា កុដិណាមិនប៉ះក្បាលនៃមជ្ឈិមបុរសដោយរនូតខាងក្រោមគេ,

(កុដិនោះ ឈ្មោះថា វេហាសកុដិ) ។ ដោយពាក្យនេះ គឺព្រះមានព្រះភាគ ទ្រង់សម្តែងវេហាសកុដិ ដែលទ្រង់ប្រាថ្នាហើយក្នុងសិក្ខាបទនេះ ។ (តែ) មិនបានទ្រង់សម្តែងលក្ខណៈរបស់វេហាសកុដិទុកទេ ។ ពិតមែន កុដិមាន ២ ជាន់ក្តី កុដិមាន ៣ ជាន់ជាដើមក្តី ប្រភេទណាមួយ ដែលខាងលើមិនបានក្រាលផ្ទៃ ព្រះមានព្រះភាគត្រាស់ហៅថា **វេហាសកុដិ** ។ តែក្នុងសិក្ខាបទនេះ ប្រាថ្នាយកវេហាសកុដិដែលមិនប៉ះសិរ្សៈ ។ បណ្ឌិតគប្បីជ្រាបសេចក្តីផ្សេងគ្នានៃអាបត្តិ ក្នុងការអង្គុយសង្កត់ជាដើមដោយអំណាចនៃប្រយោគ ដោយន័យដូចពោលហើយក្នុងកាលមុននោះឯង ។

[១៤] បទថា អវេហាសកុដិយា **: មិនមែនថ្នាក់** មានសេចក្តីថា មិនជាអាបត្តិក្នុងសាលាស្លឹកដែលគេសាងទុកលើផែនដីជាដើម ។ ព្រោះថា មិនអាចដើម្បីធ្វើសេចក្តីបៀតបៀនដល់អ្នកដទៃ ក្នុងកុដិមានបណ្ណសាលាជាដើមនោះ ។

បទថា សីសឃដ្ដាយ **: ដែលដើរទង្គិចក្បាល** មានសេចក្តីថា កុដិណាប៉ះក្បាលបាន, មិនជាអាបត្តិក្នុងកុដិសូម្បីនោះ ។ ព្រោះថា អ្នកណាមិនឱនចុះ មិនអាចត្រាច់ទៅក្នុងប្រាសាទជាន់ក្រោម ក្នុងកុដិនោះបាន; ដូច្នោះ ទើងមិនមានការបៀតបៀនដល់អ្នកដទៃ ព្រោះមិនមែនស្ថានទីសញ្ចារ ។

បីបទថា ហេដ្ឋា អបរិភោគំ ហោតិ **: ដែលមិនបានប្រើប្រាស់ខាងក្រោមឱ្យជាទីនៅ** មានសេចក្តីថា ខាងក្រោមជាទីប្រើប្រាស់មិនបាន

ព្រោះរក្សាសម្ភារៈជាដើម ។ សូម្បីក្នុងកុដិនោះ ក៏មិនជាអាបត្តិ ។

ពីរបទថា បទរសញ្ឆិត្តំ ហោតិ : ទីដែលគេក្រាលជិតដោយរនាប មានសេចក្តីថា ផែនដីខាងលើកុដិណាគេក្រាលពេញដោយផែនក្តារឈើក្តី ធ្វើការបរិកម្មដោយកំបោរសជាដើមក្តី ។ សូម្បីក្នុងកុដិនោះក៏មិនជាអាបត្តិ ។

ពាក្យថា បដាណិ ទិន្នា ហោតិ : ដែលគេដាក់គន្លឹះហើយ មានសេចក្តីថា បានបោះស្នៀត ទុកត្រង់ចុងជើងគ្រែនិងតាំងជាដើម ។ សូម្បីកាលភិក្ខុអង្គុយលើគ្រែនិងតាំងណា (ជើងគ្រែ) មិនធ្លាក់ចុះមក, សូម្បីភិក្ខុដែលអង្គុយលើគ្រែ និងតាំង ដូច្នោះ ក៏មិនជាអាបត្តិ ។

ពាក្យថា តស្មិំ ឋិតោ : ភិក្ខុដែលឈរនៅលើគ្រែ ឬតាំងនោះ មានសេចក្តីថា ភិក្ខុឈរលើគ្រែ និងតាំងដែលមានជើងស៊ក (ចូលទុកក្នុងគ្រែតាំង) ចាប់យកចីវរឬវត្ថុអ្វី ៗ ដែលព្យួរទុកលើឈើធ្មេញម្ករជាដើមខាងលើ, ឬថា ទឹងព្យួរវត្ថុដទៃ, មិនជាអាបត្តិ សូម្បីដល់ភិក្ខុនោះ ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ កើតឡើងមកកាយ ១ កាយចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្មមានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

វេហាសកុដិសិក្ខាបទវណ្ណនា ចប់

# ៩. មហល្លកវិហារសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

## ពន្យល់ក្របទ្វារបង្អួច

[១៥] ឱកាសប្រមាណប៉ុនទីធំទទឹងរបស់សន្ទឹកទ្វារ ដោយជុំវិញនៃក្របទ្វារ ឈ្មោះថា ទ្វារកោស : សន្ទឹកទ្វារ ក្នុងពាក្យថា យាវ ទ្វារកោសា នេះ ។ តែក្នុងមហាបច្ចរីលោកពោលទុកថា មួយហត្ថ មួយចំអាម វាស់អំពីសន្ទឹកទ្វារ ។ ក្នុងកុរុន្ទីពោលថា ខ្នាតប៉ុនសន្ទឹកទ្វារក្នុងខាងទាំងពីរផ្នែកនៃទ្វារ ។ ក្នុងមហាអដ្ឋកថា លោកពោលថា ឈ្មោះថាសន្ទឹកទ្វារ មានខ្នាតមួយហត្ថ មួយចំអាម ក៏មាន, ២ ហត្ថក៏មាន, ពីរហត្ថ មួយចំអាម ក៏មាន ។ ពាក្យក្នុងមហាអដ្ឋកថានោះលោកពោលល្អហើយ ។ ពិតមែន ព្រះមានព្រះភាគទ្រង់សំដៅយកអត្ថនោះឯង ទើបទ្រង់ធ្វើការកំណត់យ៉ាងខ្ពស់ទុក ដូច្នេះថា កំណត់ត្រឹមហត្ថបាស ដោយជុំវិញនៃក្របទ្វារ ។

បទថា អគ្គឡដ្ឋបនាយ : ដើម្បីទុកប្រើប្រាស់នូវទ្វារ មានសេចក្ដីថា ដើម្បីដាក់ទ្វារព័ន្ធ (ក្របទ្វារ) ព្រមទាំងសន្ទឹកទ្វារ, អធិប្បាយថា ដើម្បីត្រូវការសេចក្ដីមិនឃ្លាតទីនៃក្របទ្វារព្រមទាំងសន្ទឹកទ្វារ ។ ពិតមែន សូម្បីបទភាជនៈថា ទ្វារដ្ឋបនាយ នេះព្រះមានព្រះភាគ

ក៏ត្រាស់សំដៅយកអត្ថនេះឯង ។

ក៏ក្នុងពាក្យនេះ មានអធិប្បាយដូចតទៅនេះ ៖

ក៏សន្ទឹកទ្វារវិលរហ័ស រមែងប៉ះខ្ទប់ជញ្ជាំងក្នុងវេលាបើក, រមែងប៉ះខ្ទប់ក្រុបទ្វារក្នុងវេលាបិទ, ជញ្ជាំង រមែងកក្រើកដោយការប៉ះខ្ទប់នោះ, ព្រោះជញ្ជាំងកក្រើកនោះ ដី រមែងរលុង កាលរលុងហើយ រមែងជ្រុះឬរបូតចុះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "យាវទ្វារកោសា អគ្គឡដ្ឋបនាយ : មានឱកាសកំណត់ត្រឹមតែសន្ទឹកទ្វារដើម្បីទុកប្រើប្រាស់នូវទ្វារ" ដូច្នេះ ។

បណ្ឌិតគប្បីឃើញសេចក្ដីក្នុងពាក្យនោះយ៉ាងនេះថា ព្រះមានព្រះភាគមិនបានត្រាស់ទុកក្នុងមាតិកា មិនបានត្រាស់ទុកក្នុងបទភាជនៈឡើយថា "កិច្ចនេះ គួរធ្វើ" ក៏ពិតមែនហើយ តែដើម្បីបូកលាបត្រឹមតែទ្វារ ក៏គប្បីលាបខ្លួនឯង ឬគប្បីឱ្យលាបរឿយ ៗ ដោយអធិការតាមក្នុងអត្ថុប្បត្តិហេតុថា ភិក្ខុឱ្យប្រក់រឿយ ៗ ឱ្យបូកលាបរឿយ ៗ ដូច្នេះ ។

[១៦] ចំណែកក្នុងពាក្យដែលត្រាស់ទុកក្នុងបទភាជនៈថា "បិដ្ឋិសង្ឃាដស្ស សមន្តា ហត្ថបាសា : កំណត់ត្រឹមហត្ថបាសដោយជុំវិញនៃក្របទ្វារ" គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

វិហារណាមានទ្វារនៅត្រង់កណ្ដាល និងមានជញ្ជាំងខ្ពស់នៅផ្នែក

លើ, ហត្ថបាសដោយជុំវិញក្នុងទិសទាំង ៣ ជាឧបចារនៃវិហារនោះ ។ សម្រាប់វិហារតូច មានឧបចារក្នុងទិសទាំង ២ ។ សូម្បីក្នុងវិហារតូចនោះ សន្ទឹកទ្វារដែលបើកចេញ រមែងប៉ះខ្ទប់ជញ្ជាំងណា, សូម្បីជញ្ជាំងនោះ ក៏នៅចាត់ជាឧបចារមិនបានគ្រប់គ្រាន់ ។ តែដោយកំណត់យ៉ាងខ្ពស់ ទ្រង់អនុញ្ញាតហត្ថបាសដោយជុំវិញក្នុងទិសទាំង ៣ (និង) ទ្រង់អនុញ្ញាតការបូកលាប ដើម្បីត្រូវការធ្វើទ្វារឱ្យមាំ ។ តែបើថា មានឱកាសដែលគួរលាបសូម្បីក្នុងចំណែកខាងលើនៃទ្វារ ។ ទឹងលាបឱកាសសូម្បីនោះ ក៏គួរ ។

ក្នុងពាក្យថា អាលោកសន្ធិបរិកម្មាយ នេះ ព្រះមានព្រះភាគត្រាស់ហៅសន្ទះបង្អួចថា អាលោកសន្ធិ ។ ក្នុងពាក្យនេះ មានអធិប្បាយដូច្នេះថា សន្ទះបង្អួចទាំងនោះក្នុងវេលាបើក ទឹងប៉ះខ្ទប់ជញ្ជាំងប្រមាណមួយចំអាមខ្វះ លើសមួយចំអាមខ្វះ ។ ក៏ក្នុងពាក្យថា អលោកសន្ធិ នេះ រមែងបានឧបចារក្នុងទិសទាំងពួង ព្រោះហេតុនោះ ឱកាសប្រមាណប៉ុនទំហំទទឹងនៃសន្ទះបង្អួចក្នុងទិសទាំងពួង ។ ភិក្ខុគប្បីលាបខ្លួនឯង ឬគប្បីឱ្យលាបដើម្បីប្រយោជន៍ដល់ការបរិកម្មសន្ទះបង្អួច ។

ពាក្យថា សេតវណ្ណំ : ពណ៌សជាដើម មិនមែនជាការចែកបទមាតិកា ។ ពិតមែនឈ្មោះថា វិហារទឹងជារបស់ធូន់ដោយពណ៌សជាដើម

នេះ ក៏ទេ; ហេតុនោះ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាត (ពណ៌សជាដើម) ទុកក្នុងបទភាជនៈនោះឯង ។ ព្រោះហេតុនោះ ភិក្ខុគប្បីធ្វើកិច្ចគ្រប់យ៉ាងមានការលាបកំបោរសជាដើមនេះ តាម សប្បាយ ។

## ការបរិកម្ម ការប្រក់លើដំបូល

ដើម្បីទ្រង់សម្តែងកម្ម គឺ ការលាបដែលភិក្ខុគប្បីធ្វើយ៉ាងនេះ ហើយ សម្តែងកម្មដែលភិក្ខុគប្បីធ្វើលើដំបូលទៀត ទើបព្រះមានព្រះភាគត្រាស់ពាក្យថា "ទ្វិត្តិច្ឆទនស្ស : ត្រឹមពីរបីជាន់" ជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះ ដូច្នេះ ៖

ពាក្យថា ទ្វិត្តិច្ឆទនស្ស បរិយាយំ : ឯដំបូល (ប្រក់)បាន ត្រឹមពីរបីជាន់ គឺ (តាំងចិត្ត) ការប្រក់ដំបូលបាន ២-៣ ជាន់ ។ ការប្រក់ លោកហៅថា បរិយាយ អធិប្បាយថា គប្បីតាំងចិត្តប្រក់បាន ២-៣ ជង ។

ពីរបទថា អបហរិតេ ឋិតេន : ភិក្ខុត្រូវឈរក្នុងទីដែលគ្មានដំណាំ គឺ ឈរក្នុងទីប្រាសចាករបស់ខៀវស្រស់ ។ ក៏ក្នុងពាក្យថា ហរិតំ នេះ ទ្រង់ប្រាថ្នាយកបុព្វណ្ណជាតិ បានដល់ ស្រូវ ៧ ប្រភេទ និងអបរណ្ណជាតិ មានសណ្តែកបាយ សណ្តែករាជមាស ល្ង សណ្តែកជ្រូក ឃ្លោក និងត្រឡាចជាដើម ។ ព្រោះហេតុនោះឯង ទើបព្រះអដ្ឋ

ត្រាស់ថា "ឯដំណាំនោះ បានដល់ វត្ថុដែលត្រូវស៊ីមុន (បុព្វណ្ណជាតិ) វត្ថុដែលត្រូវស៊ីក្រោយ (អបរណ្ណជាតិ)" ។

ក៏ក្នុងពាក្យថា សចេ ហរិតេ ឋិតោ អធិដ្ឋាតិ អាបត្តិ ទុក្កដស្ស : បើភិក្ខុឈរធ្វើការប្រក់ក្នុងទីដែលមានដំណាំ នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ពូជដែលគេសាបព្រោះក្នុងស្រែសូម្បីណា ជាដំបូងនៅមិនទាន់សម្រេច (មិនទាន់ដុះ) ក៏ឬថា កាលភ្លៀងធ្លាក់ហើយ ទីងសម្រេច (ទីងដុះ), ពូជសូម្បីនេះ ក៏ដល់ការរាប់ថា របស់ខៀវស្រស់ដូចគ្នា ។ ព្រោះដូច្នោះ ភិក្ខុឈរ សូម្បីក្នុងស្រែបែបនោះ ក៏មិនគួរបរិកម្ម ។ គប្បីឈរបរិកម្មក្នុងទីប្រាសចាករបស់ខៀវស្រស់ប៉ុណ្ណោះ ។

ក្នុងរឿងបរិកម្មប្រាសចាករបស់ខៀវស្រស់ ក្នុងស្រែដែលសាបព្រោះពូជហើយ សូម្បីនោះមានកំណត់ដូចតទៅនេះ ៖

គឺ ភិក្ខុអង្គុយនៅក្នុងទីខាងដំបូលក្តី ជហ្វាជញ្ជាំងផុះកំពូលក្តី កំពូលខាងលើក្តី សម្លឹងមើលជើងជាយនៃដំបូលឃើញអ្នកឈរលើភូមិភាគណា, និងអ្នកឈរត្រង់ភូមិភាគណា រមែងឃើញភិក្ខុនោះ អង្គុយនៅខាងលើ, គប្បីឈរត្រង់ភូមិភាគនោះ, រមែងមិនបានដើម្បីឈរបរិកម្មក្នុងទីសូម្បីជាទីប្រាសចាករបស់ខៀវស្រស់ ខាងក្នុងនៃភូមិភាគនោះចូលមក

ព្រោះហេតុអ្វី ? ព្រោះថា ភូមិភាគនេះ ជាឱកាសដែលទិងបាក់ចុះមកនៃវិហារកាលដែលត្រូវបាក់ ។

ការប្រក់ត្រង់ ៗទៅមិនអម ឈ្មោះថា ការប្រក់តាមជួរមក ក្នុងពាក្យថា មគ្គេន ឆាទេន្តស្ស : កាលភិក្ខុប្រើឱ្យគេប្រក់ម្តងរួចទៅហើយនេះ ។ ការប្រក់តាមជួរមកនោះ រមែងកើតបាន ដោយឥដ្ឋ សិលានិងបាយអ ។

ពាក្យថា ទ្វេ មគ្គេ អធិដ្ឋហិត្វា : ត្រូវប្រក់ខ្លួនឯងបានត្រឹមពីរជង មានសេចក្តីថា ជួរមក ២ ជួរ បើប្រក់មិនល្អ, រមែងបានសូម្បីដើម្បីរើចេញហើយឱ្យប្រក់រឿយ ៗ ។ ព្រោះដូច្នោះ គប្បីប្រក់ដោយខ្លួនឯង ២ ជួរ ដែលខ្លួនត្រូវការ ហើយជួរទី ៣ គប្បីបង្គាប់ថា តទៅនេះចូរប្រក់យ៉ាងនេះ ហើយជៀសចេញទៅ ។

បទថា បរិយាយេន : ប្រក់មួយជាន់ គឺ ដោយការប្រក់ជាជាន់ ៗ ។ ក៏ការប្រក់យ៉ាងនេះ រមែងបានដោយស្មៅនិងស្លឹកឈើ ។ ព្រោះហេតុនោះ ក្នុងការប្រក់សូម្បីនេះភិក្ខុគប្បីប្រក់ខ្លួនឯង ២ ជាន់ ដូចដែលខ្លួនត្រូវការហើយ ជាន់ទី ៣ គប្បីបង្គាប់ថា "ទីនេះ ចូរប្រក់យ៉ាងនេះ" ហើយជៀសចេញទៅ ក៏បើថា មិនជៀសចេញទៅ គប្បីឈរស្ងៀម ។ ក៏ការប្រក់ទាំងអស់នេះគប្បីជ្រាបថា ក្នុងខាងលើដំបូល ។

ភិក្ខុទាំងឡាយ យល់ថា ក៏វិហារដែលប្រក់ជាជាន់ ៗ ភ្លៀងទឹងមិនអាចស្រោចបាន ទើបប្រក់យ៉ាងនេះ ។

[១៧] ពាក្យថា តតោ ចេ ឧត្តរឹ : លើសពីកំណត់នោះទៅ មានសេចក្តីថា ហួស ៣ ជួរ ឬ ៣ ជាន់ឡើងទៅ គឺ ក្នុងជួរទី ៤ ឬក្នុងជាន់ទី ៤ ។

ពាក្យថា គរេឡ្វ គរេឡ្វ : គ្រប់ ៗ កណ្តប គឺ ក្នុងស្បូវគ្រប់ ៗកណ្តប ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

មហល្លកវិហារសិក្ខាបទវណ្ណនា ចប់

# ១០. សប្បាណកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

## ចាក់ទឹកមានសត្វស្រោចស្មៅឬដី

[២០] ពីរបទថា ជានំ សប្បាណកំ : ដឹងថា មានសត្វ បាន ដល់ ដឹងដោយប្រការណាមួយថា ទឹកនេះ មានសត្វតូច ៗ ។

ពីរបទថា សិញ្ចេយ្យ វា សិញ្ចាបេយ្យ វា : ស្រោចឯងក្ដី ប្រើគេឱ្យស្រោចក្ដី មានសេចក្ដីថា ភិក្ខុគប្បីយកទឹកនោះស្រោចខ្លួនឯងក្ដី បង្គាប់អ្នកដទៃឱ្យស្រោចក្ដី ។

[២២] ក៏ពាក្យដូច្នេះថា សិញ្ចេយ្យាតិ សយំ សិញ្ចតិ : ពាក្យថា ស្រោចឯង គឺភិក្ខុស្រោចដោយខ្លួនឯង ដូច្នេះ ក្នុងព្រះបាលី អ្នកសិក្សាគប្បីជ្រាបសេចក្ដីដោយន័យដូចពោលហើយក្នុងសិក្ខាបទមុនទុំះឯង ។ កាលភិក្ខុស្រោចមិនធ្វើឱ្យខ្សែ (ទឹក) ក្នុងទឹកនោះដាច់ ជាអាបត្តិត្រឹមតែមួយក្នុងផ្ទាំងទឹកជាមួយគ្នា, ក្នុងភាជនៈគ្រប់យ៉ាងក៏ន័យនេះ ។ តែជាអាបត្តិគ្រប់ ៗ ប្រយោគដល់ភិក្ខុដែលស្រោចធ្វើឱ្យខ្សែទឹកដាច់ ។ ភិក្ខុធ្វើប្រឡាយឱ្យជាមកត្រង់, (ទឹក) ទឹងហូរអស់មួយថ្ងៃក៏ដោយ ក៏ជាអាបត្តិតែមួយ ។ បើភិក្ខុទប់ទំនប់ក្នុងទីនោះ ៗ ហើយបង្វែរ

ទឹកទៅមកដទៃ ៗ ជាអាបត្តិគ្រប់ ៗប្រយោគ ។ បើស្មៅនៅពេញរទេះ ភិក្ខុដាក់ចុះក្នុងទឹកដោយប្រយោគតែមួយ ក៏ជាអាបត្តិតែមួយ ។ ភិក្ខុបោលស្មៅ ឬស្លឹកឈើចុះមួងមួយសរសៃមួងមួយស្លឹក ជាអាបត្តិគ្រប់ប្រយោគ ។ ក្នុងដីស្អិតក្តី ក្នុងវត្ថុដទៃមានឈើ ភក់ និងអាចម៍គោជាដើមក្តី ក៏ន័យនេះឯង ។ ក៏វិធីបោលស្មៅនិងដីចុះក្នុងទឹកនេះ មិនបានត្រាស់សំដៅដល់ទឹកច្រើនទេ ។ ទឹកណា កាលបោលស្មៅនិងដីចុះទៅនឹងដល់សេចក្តីស្ងួតទៅ ឬនឹងជាទឹកល្អក់កករ, ក្នុងទឹកណា ពួកសត្វតូច ៗនឹងស្លាប់, បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សំដៅយកទឹកដូច្នោះ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងមកកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សប្បាណកសិក្ខាបទវណ្ណនា ចប់

ចំនួនសិក្ខាបទក្នុងភូតគាមវគ្គនោះ គឺ

១. ភូតគាមសិក្ខាបទ ការញ៉ាំងភូតគាមឱ្យវិនាស
២. អញ្ញវាទសិក្ខាបទ ការពោលពាក្យដទៃឱ្យសង្ឃលំបាក
៣. ឧជ្ឈាបនសិក្ខាបទ ការពោលទោសអ្នកដទៃ
៤. បឋមសេនាសនសិក្ខាបទ ការទុកដាក់សេនាសនៈទី១
៥. ទុតិយសេនាសនសិក្ខាបទ ការទុកដាក់សេនាសនៈទី២
៦. អនុបខជ្ជសិក្ខាបទ ការចូលទៅច្រៀតបៀត
៧. និកឌ្ឍនសិក្ខាបទ ការទង់ទាញឱ្យចេញ
៨. វេហាសកុដិសិក្ខាបទ ការអង្គុយឬដេកលើគ្រែឬតាំងលើកុដិថ្នាក់ខាងលើ
៩. មហល្លកវិហារសិក្ខាបទ ការប្រក់បូកវិហារធំ
១០. សប្បាណកសិក្ខាបទ ការចាក់ទឹកដែលមានសត្វ

អដ្ឋកថា ភូតគាមវគ្គទី ២ ចប់ ។

# ៣. ឱវាទវគ្គ

## ១. ឱវាទសិក្ខាបទវណ្ណនា

*គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃឱវាទវគ្គ ដូចតទៅនេះ ៖*

### ពន្យល់រឿងភិក្ខុមិនបានទទួលសន្មត ប្រៀនប្រដៅនាងភិក្ខុនី

*[២៤] ក្នុងពាក្យថា លាភិនោ ហោន្តិ : ជាអ្នកបាន នេះ គប្បីជ្រាបវិនិច្ឆ័យ ដូច្នេះ ៖*

*ភិក្ខុនីទាំងឡាយ រមែងមិនប្រគេនដោយខ្លួនឯង មិនប្រើអ្នកដទៃឱ្យប្រគេនដល់ព្រះថេរៈទាំងនោះ ។ តែពួកកុលធីតាអ្នកចេញបួសអំពីត្រកូលធំ រមែងចំពោះព្រះអសីតិមហាសាវកថា ព្រះថេរៈឯណោះ ៗ រមែងពោលទូន្មាន ហើយពោលសរសើរគុណដែលមាន ដូចជាសីល សុតៈ អាចារៈ ជាតិ និងគោត្រជាដើម របស់ព្រះអសីតិមហាសាវកទាំងនោះ តាមក្រសែនៃពាក្យរបស់ពួកញាតិ ជនដែលមកកាន់សំណាក់របស់ខ្លួន សួរថា បពិត្រនាងជាម្ចាស់ ពួកនាងជាម្ចាស់បានទទួលឱវាទ ឧទ្ទេស បរិបុច្ឆា អំពីទីណា ? ដូច្នេះ ។ ពិតមែន គុណដែលមានបែបនេះ គួរដើម្បីពោល ។ ព្រោះហេតុនោះ ពួកមនុស្សដែលមានចិត្តជ្រះថ្លា ទើប*

បាននាំយកលាភនិងសក្ការៈជាច្រើន ដូចចីវរជាដើមទៅប្រគេនដល់ព្រះថេរៈទាំងឡាយ ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកៈទាំងឡាយពោលថា លាភិនោ ហោន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយ-ភេសជ្ជបរិក្ខារានំ : បាននូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ដូច្នេះ ។

ពីរបទថា ភិក្ខុនិយោ ឧបសង្កមិត្វា : ចូលទៅរកភិក្ខុនីទាំងឡាយ មានសេចក្តីថា បានឮថា បណ្តានាងភិក្ខុនីទាំងនោះ សូម្បីភិក្ខុនីមួយរូបក៏មិនមកក្នុងសំណាក់របស់ឆព្វគ្គិយភិក្ខុទាំងនោះ, តែពួកឆព្វគ្គិយភិក្ខុដែលមានចិត្តត្រូវតណ្ហាក្នុងលាភទាក់ទាញទៅរឿយ ៗ បានទៅកាន់សំណាក់នៃភិក្ខុនីទាំងនោះ ។ ព្រះធម្មសង្គាហកៈទាំងឡាយសំដៅដល់ការទៅកាន់លំនៅភិក្ខុនី នៃឆព្វគ្គិយភិក្ខុនោះ ទើបបានពោលពាក្យថា ភិក្ខុនិយោ ឧបសង្កមិត្វា ដូច្នេះ ។ សូម្បីភិក្ខុនីទាំងនោះ បានធ្វើតាមពាក្យនៃពួកឆព្វគ្គិយភិក្ខុនោះ ព្រោះជាអ្នកមានចិត្តជ្រួលជ្រើម ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកៈទាំងឡាយពោលពាក្យថា "អថខោ តា ភិក្ខុនិយោ ។បេ ។ និសីទឹសុ : គ្រានោះ ភិក្ខុនីទាំងឡាយនោះ ក៏ចូលទៅរកឆព្វគ្គិយភិក្ខុទាំងឡាយ លុះចូលទៅដល់ហើយ បានថ្វាយបង្គំឆព្វគ្គិយភិក្ខុទាំងឡាយ ហើយអង្គុយក្នុងទីគួរមួយ"

ដូច្នេះ ។

បទថា តិរច្ឆានកថំ : ហើយក៏ពោលពាក្យតិរច្ឆានកថា បានដល់ពាក្យដែលគ្មានប្រយោជន៍ មានច្រើនយ៉ាង មានរាជកថាជាដើម ដែលហាមឃាត់ សូម្បីក្នុងការទៅកាន់ឋានសួគ៌ ។

បទថា ឥទ្ធោ : សម្រេចហើយ គឺ ដែលសម្រេចហើយ ។ អធិប្បាយថា មានប្រយោជន៍ជ្រាលជ្រៅមានរសច្រើន ប្រកបដោយលក្ខណបដិវេធ ។

ក្នុងពាក្យថា អនុជានាមិ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាត នេះ បណ្ឌិតគប្បីជ្រាបថា ព្រោះឆព្វគ្គិយភិក្ខុ កាលត្រូវព្រះមានព្រះភាគត្រាស់ហាមថា "ម្នាលភិក្ខុទាំងឡាយ ពួកលោកកុំពោលទូន្មានភិក្ខុនីទាំងឡាយ" ដូច្នេះ ទើងគប្បីចងអាឃាតក្នុងព្រះតថាគតហើយជាអ្នកចូលដល់អបាយ ព្រោះជាអ្នកមិនទាន់ឃើញសច្ចៈ ដូច្នោះ ព្រះមានព្រះភាគកាលទឹងទ្រង់ជៀស បញ្ចៀសមិនឱ្យចូលដល់អបាយនៃឆព្វគ្គិយភិក្ខុទាំងនោះ ទ្រង់ប្រាថ្នាទឹងឃាត់ឃាំងឆព្វគ្គិយភិក្ខុទាំងនោះ ទុកខាងក្រៅអំពីការពោលទូន្មានភិក្ខុនី ដោយឧបាយយ៉ាងដទៃទុំះឯង ទើបទ្រង់អនុញ្ញាតភិក្ខុនោវាទកសម្មតិនេះ ។

[២៥] ព្រះមានព្រះភាគទ្រង់អនុញ្ញាត (ភិក្ខុនោវាទកសម្មតិ)

ព្រោះមានព្រះប្រាថ្នានឹងហាមឃាត់ភិក្ខុទាំងនោះ ទុកខាងក្រៅក្នុងសិក្ខាបទនេះ យ៉ាងនេះ កាលនឹងទ្រង់ធ្វើតទៅខាងមុខ ទើបត្រាស់ពាក្យថា "អនុជានាមិ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យសង្ឃសន្មតភិក្ខុដែលប្រកបដោយអង្គ ៨" ជាដើម ។ ពិតមែន អង្គ ៨ ទាំងនេះ មិនទាន់ធ្លាប់មានដល់ពួកឆព្វគ្គិយភិក្ខុ សូម្បីតែការយល់សប្តិឡើយ ។

## អធិប្បាយអង្គ ៨ របស់ភិក្ខុដែលពោលទូន្មានភិក្ខុនី

បណ្ឌិតគប្បីជ្រាបវិគ្រោះក្នុងបទថា សីលវា : ជាអ្នកមានសីល នោះថា សីលរបស់ភិក្ខុនោះមាន; ហេតុនោះ ភិក្ខុនោះ ឈ្មោះថា អ្នកមានសីល ។ ឥឡូវនេះ ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងសីលដែលមាន និងសម្តែងសីលនោះ មាន ដល់ភិក្ខុនោះ យ៉ាងណា ទើបឈ្មោះថា មាន, ក៏បានត្រាស់ពាក្យថា បាដិមោក្ខសំវរសំវុតោ : ការសង្រួមក្នុងបាតិមោក្ខសំវរ ជាដើម ។

ក្នុងពាក្យនោះ មានវិនិច្ឆ័យដូច្នេះ ៖

សំវរៈ គឺ បាដិមោក្ខ ឈ្មោះថា បាតិមោក្ខសំវរៈ ។ ភិក្ខុដែលសង្រួម គឺ ប្រកបដោយបាតិមោក្ខសំវរនោះ ; ហេតុនោះ ភិក្ខុនោះទើបឈ្មោះថា អ្នកសង្រួមដោយបាតិមោក្ខសំវរ ។

បទថា វិហរតិ : សម្រេចឥរិយាបថ[១] បានដល់ ប្រព្រឹត្តទៅ ។ សមពិត ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកក្នុងវិភង្គថា "ពាក្យថា បាដិមោក្ខ បានដល់ សីល ការតាំងមាំ កិច្ចខាងដើម ការប្រព្រឹត្តិ ការសង្រួម ការរវាំង ប្រធាន ប្រមុខ នៃការដល់នូវកុសលធម៌ទាំងឡាយ ។ ពាក្យថា សំវរៈ គឺ ការមិនកន្លងដែលប្រព្រឹត្តក្នុងកាយ ការមិនកន្លងដែលប្រព្រឹត្តក្នុងវាចា ការមិនកន្លងដែលប្រព្រឹត្តក្នុងកាយ និងក្នុងវាចា ។ ពាក្យថា ជាអ្នកសង្រួម គឺ ជាអ្នកព្រមព្រៀង មូលមិត ចូលទៅជិត អែបណែប កៀកកើយ ប្រជិតប្រជី( ផ្ចិតផ្ចង់ ) ប្រកបព្រមដោយការសង្រួមក្នុងបាតិមោក្ខនេះ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ ។ ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ប្រព្រឹត្ត រក្សា រស់នៅ ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ ត្រាច់ទៅ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ"[២] ។

បទថា អាចារគោចរសម្បន្នោ : បរិបូណ៌ដោយអាចារនិងទីគោចរ មានសេចក្ដីថា លះអគោចរមានស្រីពេស្យាជាដើម ដោយអាចារៈដែលទប់ស្កាត់មិច្ឆាជីវៈ មានការមិនឱ្យឫស្សីជាដើម ហើយដល់ព្រម

---

១. បិដកក្នុងទីនេះ មិនប្រែពាក្យនេះ ។ ២. អភិ. វិភ. ឈានវិភង្គ. ៨១. ៣៤៨/២៤៩ ។

ដោយគោចរ មានត្រកូលដែលបរិបូរដោយសទ្ធាជាដើម ឈ្មោះថា អ្នកដល់ព្រមដោយអាចារៈនិងគោចរ ។

ពាក្យថា **អនុមត្តេសុ វជ្ជេសុ ភយទស្សាវី** : **ជាអ្នកឃើញក្នុងទោសទាំងឡាយមានប្រមាណតិចតួច** បានដល់ អ្នកមានប្រក្រតីឃើញភ័យក្នុងទោសទាំងឡាយ មានប្រមាណបន្តិចបន្តួច ។ មានពាក្យអធិប្បាយថា មានប្រក្រតីឃើញទោសទាំងនោះដោយភាពជាភ័យ ។

ពាក្យថា **សមាទាយ សិក្ខតិ សិក្ខាបទេសុ** : **សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ** មានសេចក្ដីថា បណ្ដាសិក្ខាបទដែលចាត់ជា ៣ យ៉ាង ដោយភាពជាអធិសីលសិក្ខាជាដើម សមាទានកាន់យកដោយប្រពៃ បានដល់ ទទួលយកដោយល្អ សិក្សាមិនលះបោលសិក្ខាបទនោះ ៗ ។ នេះសេចក្ដីសង្ខេបក្នុងពាក្យថា **អាចារគោចរសម្បន្នោ**នេះ ចំណែកអ្នកត្រូវការសេចក្ដីពិស្ដារគប្បីកាន់យកក្នុងអដ្ឋកថា មជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី ក្នុងអដ្ឋកថាវិភង្គបករណ៍ ឈ្មោះសម្មោហវិនោទនី ឬថា អំពីវិសុទ្ធិមគ្គបករណ៍ ។

សុតៈរបស់ភិក្ខុនោះច្រើន; ភិក្ខុនោះ ទើបឈ្មោះថា ពហុស្សុត ។ ភិក្ខុណាទ្រទ្រង់ចាំសុតៈទុក; ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា សុតធរៈ ។ អធិប្បាយថា ពាក្យដែលភិក្ខុនោះបានស្ដាប់ ឈ្មោះថា

ពហុស្សុត, សុតៈនោះមិនមែនត្រឹមតែស្តាប់ម៉្យាងទេ បើតាមពិត រមែងទ្រទ្រង់សុតៈនោះផង ។ សុតៈសន្សំក្នុងភិក្ខុនោះ ដូចរតនៈ ដែលរក្សាទុកក្នុងហិប; ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា មានការសន្សំសុតៈ ។ ដោយបទនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីមិនសាបសូន្យទៅ សូម្បីដោយកលយូរនៃសុតៈដែលភិក្ខុនោះទ្រទ្រង់ទុក ដូចរតនៈដែលរក្សាទុកក្នុងហិប ដូច្នោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទឹងទ្រង់សម្តែងសុតៈនោះដោយសរុប ទើបត្រាស់ពាក្យថា "យេ តេ ធម្មា : ធម៌ទាំងឡាយណា" ជាដើម ។ ពាក្យនោះ មានន័យដូចពោលក្នុងវេរញ្ជកណ្ឌ[១]នុ៎ះឯង តែនេះជាពាក្យត្រាស់ដដែលក្នុងសិក្ខាបទនេះទៀត ។ ធម៌បែបនោះ ភិក្ខុនោះស្តាប់ច្រើនហើយ; ព្រោះហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា ពហុស្សុត, ធម៌ទាំងនោះ ដែលភិក្ខុនោះ ទ្រទ្រង់ចាំទុកបាន; ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា សុតធរៈ, ធម៌ទាំងនោះ ដែលភិក្ខុនោះ សន្សំទុកដោយវាចា តាមសម្ទឹងដោយចិត្ត ចាក់ធ្លុះល្អហើយដោយទិដ្ឋិ; ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា សុតសន្និចយៈ ។

បណ្តាបទទាំងនោះ ពីរបទថា វចសា បរិចិតា : សន្សំហើយ

១. សមន្ត. វេរ. ១. ១/២៣៥ ។

ដោយវាចាដ៏ស្អាតរត់មាត់ បានដល់ ដែលភិក្ខុនោះ ធ្វើឱ្យស្អាតរត់មាត់ ។

បទថា មនសានុបេក្ខិតា : ចូលចិត្តច្បាស់លាស់ មានសេចក្ដីថា ដែលភិក្ខុសម្លឹងដោយចិត្តហើយ ប្រាកដដូចភ្លឺដោយពន្លឺប្រទីបរាប់ពាន់ដួង ដល់អ្នកពិចារណា ។

ពីរបទថា ទិដ្ឋិយា សុប្បដិវិទ្ធា : យល់ត្រូវល្អដោយទិដ្ឋិ មានសេចក្ដីថា ធម៌ទាំងឡាយ រមែងជាការដែលភិក្ខុនោះចាក់ធ្លុះហើយដោយល្អ គឺ ធ្វើឱ្យប្រចក្សហើយ ដោយបញ្ញាដោយអត្ថ និងដោយហេតុ ។

## ភិក្ខុពហុស្សូត ៣ ពួក

ក៏ភិក្ខុដែលឈ្មោះថា ពហុស្សូតនេះ មាន ៣ ពួក គឺ និស្ស័យមុច្ចនក: អ្នកផុតនិស្ស័យ ១ បរិសុបដ្ឋាបក: អ្នកឱ្យបរិស័ទឧបដ្ឋាក ១ ភិក្ខុនោវាទក: អ្នកប្រៀនប្រដៅភិក្ខុនី ១ ។ បណ្ដាពហុស្សូតទាំង ៣ នោះ ភិក្ខុដែលជានិស្ស័យមុច្ចក:មានវស្សា ៥ ដោយឧបសម្បទា គប្បីទ្រទ្រង់ចាំមាតិកា[១] ២ ឱ្យស្ទាត់ជំនាញ រត់មាត់ ដោយកំណត់យ៉ាងទាបបង្អស់, គប្បីរៀនភាណវារ: ៤ អំពីសុត្តន្តបិដក ដើម្បីប្រយោជន៍ដល់ធម្មស្សវនៈក្នុងថ្ងៃបក្ខទាំងឡាយ, គប្បីរៀនកថាមគ្គមួយចប់ ប្រាកដ

១ សារត្ថទីបនីថា មាតិកា ២ បានដល់ ភិក្ខុមាតិកា និងភិក្ខុនីមាតិកា ។

ដូចជាអន្ធកវិន្ទសូត្រ មហារាហុលោវាទសូត្រ អម្ពដ្ឋសូត្រ ដើម្បីប្រយោជន៍ដល់ការពោលធម៌បន្តិចបន្តួចដល់ពួកជនដែលមករក, គប្បីរៀនគាថាអនុមោទនា ៣ យ៉ាង ដើម្បីប្រយោជន៍អនុមោទនាក្នុងសង្ឃភត្តការងារមង្គលនិងអវមង្គល, គប្បីរៀនវិនិច្ឆ័យកម្ម និងមិនមែនកម្ម ដើម្បីដឹងឧបោសថនិងបវារណាជាដើម, គប្បីរៀនកម្មដ្ឋានមួយយ៉ាង មានព្រះអរហត្តជាទីបំផុត ដោយអំណាចនៃសមាធិក្តី ដោយអំណាចនៃវិបស្សនាក្តី ដើម្បីធ្វើសមណធម៌, គប្បីរៀន (ពុទ្ធវចនៈមានព្រះសូត្រ ៤ ភាណវារៈជាដើម) ត្រឹមតែប៉ុណ្ណោះ ។ ពិតមែន ដោយការរៀនត្រឹមតែប៉ុណ្ណោះ ភិក្ខុនេះ រមែងឈ្មោះថា ជាពហុស្សូត ជាអ្នកប្រាកដក្នុងទិសទាំង ៤ រមែងបានដើម្បីនៅដោយភាពជាឥស្សរៈរបស់ខ្លួនក្នុងទីកន្លែងណាមួយ ។

ភិក្ខុដែលជាបរិសុបដ្ឋាបកៈ មានវស្សា ១០ ដោយឧបសម្បទា គប្បីធ្វើវិភង្គទាំង ២ ឱ្យជំនាញរត់មាត់ ដើម្បីណែនាំបរិស័ទក្នុងអភិវិន័យ ដោយកំណត់យ៉ាងទាបទីបំផុត ។ កាលមិនអាច គប្បីធ្វើ (វិភង្គទាំង ២ គម្ពីរ) ឱ្យគួរដល់ការផ្លាស់ប្តូរគ្នានឹងភិក្ខុ ៣ រូប ។ គប្បីរៀនកម្ម និងមិនមែនកម្ម និងខន្ធកវត្ត ។ តែដើម្បីណែនាំបរិស័ទក្នុងអភិធម្ម បើជាអ្នកពោលមជ្ឈិមនិកាយ គប្បីរៀនមូលបណ្ណាសកៈ ។ អ្នកពោលទីឃនិកាយ គប្បីរៀនសូម្បីមហាវគ្គ ។ អ្នកពោលសំយុត្តនិកាយ គប្បីរៀន

៣ វគ្គ ខាងដើម ឬមហាវគ្គ ។ អ្នកពោលអង្គុត្តរនិកាយ គប្បីរៀនពាក់កណ្ដាលនិកាយខាងដើម ឬខាងចុង ។ អ្នកមិនអាច សូម្បីនឹងរៀនខាងដើមតាំងពីតិកនិបាតទៅក៏បាន, តែក្នុងមហាបច្ចរីពោលថា អ្នកនឹងរៀនយកនិបាតតែមួយសូម្បីនឹងរៀនយកចតុក្កនិបាត ឬបញ្ចកនិបាត ក៏បាន ។ អ្នកពោលជាតក គប្បីរៀនយកជាតកព្រមទាំងអដ្ឋកថា ។ នឹងរៀនតិចជាងជាតកព្រមទាំងអដ្ឋកថា មិនគួរ ។ លោកពោលទុកក្នុងមហាបច្ចរីថា នឹងរៀនយកសូម្បីធម្មបទ ព្រមទាំងវត្ថុនិទាន ក៏គួរ ។

សួរថា នឹងជ្រើសរើសរៀនយកអំពីនិកាយនោះ ៗ មានទីឃនិកាយជាដើម សូម្បីត្រឹមតែមូលបណ្ណាសកៈ គួរ ឬមិនគួរ ។

ឆ្លើយថា លោកបដិសេធទុកក្នុងអដ្ឋកថាកុរុន្ទី មិនគួរ ។ ក្នុងអដ្ឋកថា ក្រៅនេះ មិនមានការវិចារណ៍ទុកឡើយ ក្នុងអភិធម្មលោកមិនបានពោលថា គួររៀនយកអ្វី ។ ក៏ភិក្ខុណាជំនាញវិន័យបិដក និងអភិធម្មបិដកព្រមទាំងអដ្ឋកថា, តែមិនមានគណ្ឋៈមានប្រការដូចដែលពោលក្នុងសុត្តន្តបិដក, ភិក្ខុនោះ រមែងមិនបានដើម្បីឱ្យបរិស័ទឧបដ្ឋាក ។ តែភិក្ខុណារៀនគណ្ឋៈ មានប្រមាណដូចពោលហើយ អំពីសុត្តន្តបិដកខ្លះ អំពីវិន័យបិដកខ្លះ, ភិក្ខុនេះជាបរិសូបដ្ឋាបកៈ ជាពហុស្សូត ជាទិសាបាមោក្ខទៅបានតាមសេចក្ដីប្រាថ្នា រមែងបានដើម្បីឱ្យបរិស័ទឧបដ្ឋាក ។

ចំណែកភិក្ខុដែលប្រៀនប្រដៅភិក្ខុនី គប្បីរៀនបិដក ៣ ព្រមទាំងអដ្ឋកថា ។ កាលមិនអាច គប្បីធ្វើអដ្ឋកថានៃនិកាយណាមួយ បណ្ដានិកាយទាំង ៤ ឱ្យជំនាញ ។ ព្រោះថា ដោយនិកាយតែមួយ ក៏នឹងអាចដើម្បីពោលពន្យល់បញ្ហា សូម្បីក្នុងនិកាយដែលនៅសល់បាន ។ បណ្ដាបករណ៍ ៧ គប្បីធ្វើអដ្ឋកថានៃបករណ៍ ៤ ឱ្យជំនាញ ព្រោះថា ដោយន័យដែលបានក្នុងអដ្ឋកថានៃបករណ៍ទាំង ៤នោះ ក៏នឹងអាចដើម្បីពោលបកស្រាយបញ្ហាក្នុងបករណ៍ដែលនៅសល់បាន ។ ចំណែកវិន័យបិដកមានអត្ថផ្សេង ៗគ្នា មានហេតុផ្សេង ៗគ្នា ព្រោះហេតុនោះ ភិក្ខុដែលប្រៀនប្រដៅនាងភិក្ខុនី គប្បីធ្វើវិន័យបិដកនោះព្រមទាំងអដ្ឋកថាឱ្យជំនាញតែម្ដង ។ ក៏ដោយការរៀនសុតៈមានប្រមាណប៉ុណ្ណេះ ភិក្ខុដែលប្រៀនប្រដៅភិក្ខុនី ឈ្មោះថា ជាអ្នកមានសុតៈច្រើននោះឯង ។

## បាដិមោក្ខទាំងពីររបស់លោកមកល្អហើយដោយពិស្ដារ

ចំណែកពាក្យថា ឧភយានិ ខោ បនស្ស : ចំណែកទាំងពីរ ជាដើម ព្រះមានព្រះភាគត្រាស់ទុកផ្សេងដទៃ ក៏ព្រោះកាលពហុសច្ចៈ សូម្បីមានអង្គ ៩ យ៉ាងដទៃមាននៅគ្រប់ទាំងអស់ និងរៀនវិន័យបិដកព្រមទាំងអដ្ឋកថាចេញ រមែងមិនគួរតែម្ដង ។

បណ្ដាបទទាំងនោះ បទថា វិត្ថារេន : ដោយពិស្ដារ បានដល់

ព្រមដោយឧភតោវិភង្គ ។

បទថា ស្វាគតានិ : ក៏ចេះចាំ គឺ មកហើយដោយល្អ ។ ក៏បាតិមោក្ខទាំង ២ មកហើយដោយប្រការណា ទើបចាត់ថា មកហើយដោយល្អ ដើម្បីសម្តែងសេចក្តីនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា "សុវិភត្តានិ" ជាដើម ។

បណ្តាបទទាំងនោះ បទថា សុវិភត្តានិ : ចែកចេញបានដោយប្រពៃ បានដល់ ចែកបានល្អ គឺ វៀរអំពីទោស គឺ បទដែលធ្លាក់ចុះខាងក្រោយនិងច្របូកច្របល់គ្នា ។

បទថា សុប្បវត្តិនី : ចាំស្ទាត់រត់មាត់ បានដល់ ជំនាញ រត់មាត់ ។

ពីរបទថា សុវិនិច្ឆិតានិ សុត្តសោ : កាត់សេចក្តីបានដោយល្អដោយសុត្ត បានដល់ មានវិនិច្ឆ័យល្អហើយ ដោយអំណាចនៃសូត្រដែលនឹងគប្បីនាំមកពីខន្ធកៈ និងបរិវារ ។

បទថា អនុព្យញ្ជនសោ : ដោយអនុព្យញ្ជនៈ បានដល់ វិនិច្ឆ័យបានរៀបរយ ដោយសេចក្តីបរិបូណ៌នៃអក្ខរបទ និងដោយអំណាចនៃសូត្រ គឺ មិនដាច់ធ្លាក់ មិនមានអក្សរដែលខុសផ្លាត ។ អដ្ឋកថា លោកសម្តែងទុកដោយបទថា ដោយអនុព្យញ្ជនៈនេះ ពិតមែនវិនិច្ឆ័យនេះ

រមែងមានមកពីអដ្ឋកថា ។

បទថា កល្យាណវាចោ : មានវាចាពោលត្រឹមត្រូវ មានសេចក្តីថា អ្នកដល់ព្រមដោយវាចារបស់អ្នកក្រុងដែលមានបទនិងព្យញ្ជនៈមូលក្លំ តាមពាក្យដែលសមគួរដល់ការចាត់ជាសិថិលនិងធនិតជាដើម គឺ ប្រកបដោយវាចាឱ្យដឹងច្បាស់នូវអត្ថដែលពីរោះរណ្តំ មិនមានទោស ។

បទថា កល្យាណវាក្ករណោ : មានសំឡេងពីរោះ គឺ មានសំដីផ្អែម ពិតមែន មាតុគ្រាមរមែងជាអ្នកត្រេកអរក្នុងភាពសំបូរនៃសំឡេង; ព្រោះហេតុនោះ ទើបនាងមើលងាយពាក្យនិយាយ ដែលវៀរចាកភាពសំបូរនៃសំឡេង សូម្បីដែលមានបទនិងព្យញ្ជនៈមូលក្លំ ។

ពាក្យថា យេភុយ្យេន ភិក្ខុនីនំ បិយោ ហោតិ មនាបោ : ភិក្ខុនោះ ជាទីស្រឡាញ់ពេញចិត្តនៃភិក្ខុនីទាំងឡាយដោយច្រើន មានសេចក្តីថា ឈ្មោះថា ភិក្ខុដែលជាទីស្រឡាញ់នៃភិក្ខុនីទាំងអស់ មិនបានលំបាក ។ តែត្រូវជាទីស្រឡាញ់ជាទីចម្រើនចិត្តរបស់ពួកភិក្ខុនីអ្នកជាពហុស្សូត ជាបណ្ឌិត ព្រោះការដល់ព្រមនៃ សីលនិងអាចារៈ ។

ពាក្យថា បដិពលោ ហោតិ ភិក្ខុនិយោ ឱវទិតុំ : ភិក្ខុនោះ ជាអ្នកអាចដើម្បីនឹងប្រដៅភិក្ខុនីបាន មានសេចក្តីថា កាលសម្តែងសូត្រនិងហេតុ ឈ្មោះថា ជាអ្នកអាច ដើម្បីគម្រាម ដោយភ័យក្នុងវដ្តៈ ហើយ

ពោលទូន្មានភិក្ខុនីទាំងឡាយ គឺ កាលសម្ដែងធម៌ដល់ភិក្ខុនីទាំងនោះ ។

បទថា កាសាយវត្ថវសនាយ : **អ្នកនៅដោយសំពត់ដែលជ្រលក់ដោយទឹកចត់** គឺ អ្នកស្លៀកសំពត់ជ្រលក់ទឹកចត់ ។

បទថា គរុធម្មំ : **គរុធម៌** មានសេចក្ដីថា ក្នុងកាលដែលលោកនៅជាគ្រហស្ថ មិនធ្លាប់ពាល់ត្រូវកាយសំសគ្គៈនឹងភិក្ខុនី ឬថា មិនធ្លាប់ត្រូវមេថុនធម្មក្នុងសិក្ខមានា និងសាមណេរី ។ ពិតមែន មាតុគ្រាមរលឹកដល់កម្មដែលភិក្ខុធ្វើទុកក្នុងកាលមុន រមែងមិនធ្វើសេចក្ដីគោរពក្នុងធម្មទេសនារបស់ភិក្ខុ សូម្បីអ្នកតាំងនៅក្នុងសំវរៈ ។ ម្យ៉ាងទៀត នាងនឹងញុំាងគំនិតឱ្យកើតឡើងក្នុងអសទ្ធម្មនុ៎ះឯង ។

បទថា វីសតិវស្សោ វា : **មានវស្សាម្ភៃក្ដី** មានសេចក្ដីថា អ្នកមានវស្សា ២០ ដោយឧបសម្បទាឬថា មានវស្សាលើសពី ២០ អំពីឧបសម្បទានោះ ។ ភិក្ខុនោះ សូម្បីនឹងសមាគមប្រប្រូកប្របល់នៅនឹងវត្ថុដែលជាសត្រូវគ្នា មានសភាពបែបនោះរឿយ ៗ ក៏នឹងមិនឆាប់ដល់សេចក្ដីវិនាសសីល ដូចភិក្ខុកម្លោះ ។ ភិក្ខុនោះពិចារណាមើលវ័យរបស់ខ្លួនហើយ រមែងជាអ្នកមានកម្លាំងល្មមនឹងកម្ចាត់ឆន្ទរាគៈ ក្នុងឋានៈដែលមិនសមគួរចេញ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "វីសតិវស្សោ វា ហោតិ អតិរេកវីសតិវស្សោ វា : ភិក្ខុនោះ មាន

វស្សាម្ភៃក្តី មានវស្សាជាងម្ភៃក្តី" ។

ក៏បណ្ដាអង្គ ៨ ទាំងនេះ បណ្ឌិតគប្បីជ្រាបថា ពាក្យថា ភិក្ខុជាអ្នកមានសីលជាដើម ជាអង្គទី ១, ភិក្ខុជាពហុស្សូតជាដើម ជាអង្គទី ២, ពាក្យថា ចំណែកបាដិមោក្ខទាំង ២ ភិក្ខុនោះក៏ចេះដោយពិស្ដារជាដើម ជាអង្គទី ៣, ពាក្យថា ភិក្ខុមានវាចាពោលត្រឹមត្រូវមានសំឡេងពីរោះ ជាអង្គទី ៤, ពាក្យថា ភិក្ខុនោះជាទីស្រឡាញ់ពេញចិត្តនៃភិក្ខុនីទាំងឡាយដោយច្រើន ជាអង្គទី ៥, ពាក្យថា ភិក្ខុនោះជាអ្នកអាចដើម្បីនឹងប្រដៅភិក្ខុនីបាន ជាអង្គទី ៦, ពាក្យថា ភិក្ខុនោះមិនធ្លាប់ប្រព្រឹត្តកន្លងគរុធម៌នឹងភិក្ខុនី ជាអង្គទី ៧, ពាក្យថា ភិក្ខុនោះមានវស្សាម្ភៃ ឬមានវស្សាជាងម្ភៃ ជាអង្គទី ៨ ។

[២៦] បទថា ញត្តិចតុត្ថេន : ដោយញត្តិចតុត្ថកម្ម មានន័យដូចពោលហើយក្នុងរឿងមុន ៗ នុ៎ះឯង ។

## គរុធម៌ ៨ របស់នាងភិក្ខុនី

[២៧] បទថា គរុធម្មេហិ : ដោយគរុធម៌ គឺ ដោយធម៌ដែលធ្ងន់ ៗ ពិតមែន ធម៌ទាំងនោះ ព្រះមានព្រះភាគត្រាស់ហៅថា គរុធម៌ ព្រោះជាធម៌ដែលភិក្ខុនីទាំងឡាយ គប្បីធ្វើសេចក្ដីគោរពទទួលព្រម ។

ក្នុងពាក្យថា ឯកតោ ឧបសម្បន្នំ : ភិក្ខុនីដែលបានឧបសម្បទា

ក្នុងសំណាក់សង្ឃតែមួយចំណែក នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុណា រមែងពោលទូន្មានដោយគរុធម៌ដល់ភិក្ខុនីអ្នកឧបសម្បទាក្នុងសំណាក់នៃភិក្ខុនីទាំងឡាយតែមួយផ្នែក ជាទុក្កដដល់ភិក្ខុនោះ ។ តែជាអាបត្តិតាមវត្ថុតែម្តង (ដល់ភិក្ខុដែលប្រៀនប្រដៅនាងភិក្ខុនី) អ្នកឧបសម្បទាក្នុងសំណាក់របស់ពួកភិក្ខុ ។

[២៨] ពីរបទថា **បរិវេណំ សម្មជ្ជិត្វា : គប្បីបោសប្រាសបរិវេណ** មានសេចក្តីថា បើបរិវេណ មិនស្អាតឬសូម្បីស្អាតហើយក្នុងវេលាព្រឹក ត្រឡប់មិនស្អាត ព្រោះស្មៅ និងស្លឹកឈើជាដើម និងកើតមានខ្សាច់ខ្ចាត់ខ្ចាយ ព្រោះត្រូវជើងជាន់ឈ្លី, ភិក្ខុដែលបានទទួលសន្មតគប្បីបោស ។ ពិតមែន ភិក្ខុនីទាំងឡាយនោះ ឃើញបរិវេណនោះមិនស្អាត ហើយមិនជាស់តឿន គប្បីជួចជាអ្នកមិនចង់ស្តាប់ ដោយសម្គាល់ថា លោកម្ចាស់មិនដឹកនាំសូម្បីពួកភិក្ខុកម្លោះ អ្នកជានិស្សិតរបស់ខ្លួនក្នុងវត្តបដិបត្តិ, ល្អតែសម្តែងធម៌តែម៉្យាង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ពាក្យថា “បរិវេណំ សម្មជ្ជិត្វា” ។

ក៏ភិក្ខុនីទាំងឡាយ ដើរមកពីខាងក្នុងស្រុក រមែងក្តៅស្រេកទឹក និងហត់នឿយ ។ ភិក្ខុនីទាំងនោះ ទើបប្រាថ្នាផឹកទឹក និងការធ្វើឱ្យដៃជើង និងមុខត្រជាក់ ។ ក៏កាលទឹកនោះមិនមាន ភិក្ខុនីទាំងនោះ កើត

សេចក្តីមិនគោរពដោយន័យមុននុ៎ះឯង ហើយជាអ្នកមិនប្រាថ្នានឹងស្តាប់ធម៌ ក៏បាន ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា "ធានីយំ បរិភោជនីយំ ឧបដ្ឋបេត្វា : រួបតាំងទឹកឆាន់និងទឹកប្រើប្រាស់" ។

បទថា អាសនំ : នូវអាសនៈ មានសេចក្តីថា ក៏ភិក្ខុដែលបានទទួលសន្មតនោះ គប្បីចាត់តាំងទីអង្គុយមានប្រភេទតាំងតូច តាំងផែនក្តារ កន្ទេលទន់ និងកន្ទេលផែនជាដើម ដោយហោចទៅ សូម្បីមែកឈើល្មមនឹងកាច់បាន ដោយគិតយ៉ាងនេះថា "នេះនឹងជាទីអង្គុយរបស់ភិក្ខុនីទាំងនោះ" ហើយគប្បីមានបុរសជីងក្តីជាសម្លាញ់ ដើម្បីដោះអាបត្តិដែលត្រូវព្រោះការសម្តែងធម៌ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ទុតិយំ គហេត្វា : ហើយនាំយកភិក្ខុជាគម្រប់ពីរទៅ" ដូច្នេះ ។

បទថា និសីទិតព្វំ : អង្គុយនៅចុះ មានសេចក្តីថា មិនគប្បីអង្គុយក្នុងទីបំផុតនៃវិហារទេ, គប្បីអង្គុយក្នុងស្ថានជំនុំនៃមនុស្សទូទៅជិតទ្វារនៃរោងឧបោសថ ឬរោងឆាន់ ក្នុងវិហារ ។

បទថា សមគ្គត្ថ : ព្រមព្រៀងគ្នា មានសេចក្តីថា នាងទាំងឡាយមកព្រមព្រៀងគ្នាអស់ហើយឬ ?

បទថា វត្តន្តិ : ចាំស្មាត់រត់មាត់ បានដល់ (គរុធម៌ ៨) តើនៅ

ចាំបានទាំងអស់គ្នាហើយឬ ? អធិប្បាយថា ជំនាញរត់មាត់ឬ ?

បទថា និយ្យាទេតព្វោ : គប្បីនាំទៅឱ្យ គឺ គប្បីប្រគល់ឱ្យ ។

បទថា ឱសារេតព្វោ : គប្បីសូធ្យប្រាប់ គឺ គប្បីប្រាប់បាលី ។

ពាក្យថា វស្សសតុបសម្បន្នាយ : ឧបសម្បទាហើយបានមួយរយវស្សា ជាដើម ជាពាក្យសម្ដែងបាលីដែលភិក្ខុបានទទួលសន្ទតនឹងគប្បីប្រាប់ ។

បណ្ដាបទទាំងនោះ បទថា សាមីចិកម្មំ : សាមីចិកម្ម បានដល់វត្តដែលសមគួរមានការបើកមកឱ្យបក់ផ្លិត និងសួរដោយអើពើដោយទឹកផឹកជាដើម ។ ក៏បណ្ដាវត្តមានការអភិវាទជាដើមនេះ ឈ្មោះថា ការក្រាបថ្វាយបង្គំភិក្ខុដែលភិក្ខុនីគប្បីធ្វើពិតខាងក្នុងស្រុកក្ដី ក្រៅស្រុកក្ដី ខាងក្នុងវិហារក្ដី ខាងក្រៅវិហារក្ដី ក្នុងចន្លោះស្រុកក្ដី ក្នុងប្រកមកក្ដី ដោយហោចទៅ សូម្បីកាលការបណ្ដេញ ព្រោះហេតុព្រះរាជាស្ដេចមកប្រព្រឹត្តទៅក្ដី កាលភ្លៀងកំពុងធ្លាក់ក្ដី ក្នុងផែនដីមានភក់ជ្រាំជាដើមក្ដី មានឆត្រនិងបាត្រនៅក្នុងដៃក្ដី[1] ត្រូវដំរីនិងសេះជាដើមដេញតាមក្ដី ។ ភិក្ខុនីឃើញ ពួកភិក្ខុចូលកាន់ទីភិក្ខាចារ ដើរជាជួររៀងគ្នាតែមួយជួរ នឹងថ្វាយបង្គំក្នុងទីតែមួយកន្លែងដោយពោលថា ខ្ញុំម្ចាស់ថ្វាយបង្គំ លោក

---

១, យោជនា. ជា ឆត្តបត្តហត្ថាយបិ ... ។

ម្ចាស់ ដូច្នេះ ក៏គួរ ។ បើភិក្ខុទាំងឡាយដើរដាច់ឆ្ងាយគ្នា ក្នុងរវាង ១២ ហត្ថ គប្បីថ្វាយបង្គំផ្សេងគ្នា ។ នឹងថ្វាយបង្គំភិក្ខុទាំងឡាយ ដែលអង្គុយនៅក្នុងទីប្រជុំធំ ក្នុងទីមួយកន្លែងប៉ុណ្ណោះក៏បាន ។ សូម្បីក្នុងអញ្ញលិកម្ម ក៏ន័យនេះ ។ ក៏ភិក្ខុនីអង្គុយហើយ ក្នុងទីណាមួយគប្បីធ្វើការក្រោកទទួល គប្បីធ្វើកម្មនោះ ៗ ក្នុងទីនិងវេលាដែលសមគួរដល់សាមីចិកម្មនោះ ៗ

បទថា សក្កត្វា : ត្រូវធ្វើឱ្យល្អ គឺ ធ្វើដោយប្រការដែលធម៌ដែលខ្លួនធ្វើហើយ នឹងជាការធ្វើហើយដោយល្អ ។

បទថា គរុកត្វា : គោរព គឺ ឱ្យកើតសេចក្តីគោរពក្នុងកម្មនោះ ។

បទថា មានេត្វា : រាប់អាន គឺ ធ្វើសេចក្តីស្រឡាញ់ដោយចិត្ត ( ពិត ) ។

បទថា បូជេត្វា : បូជា គឺ បូជាដោយករធ្វើកិច្ច ៣ យ៉ាងទាំងនេះឯង ។

បទថា ឆាតិក្កមនីយោ : កុំប្រព្រឹត្តកន្លង គឺ ដែលភិក្ខុនីមិនគប្បីកន្លងល្មើស ។

# ភិក្ខុនីមិនគប្បីចាំវស្សាក្នុងអាវាសមិនមានភិក្ខុ

ក្នុងពាក្យថា អភិក្ខុកេ អាវាសេ : ក្នុងអាវាសដែលគ្មានភិក្ខុ នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

បើភិក្ខុទាំងឡាយ ដែលឱ្យឱវាទមិនបាននៅក្នុងឱកាសចម្ងាយកន្លះយោជន៍អំពីសំណាក់នៃភិក្ខុនី, អាវាសនេះ ឈ្មោះថា អាវាសមិនមានភិក្ខុ ។ ភិក្ខុនីទាំងឡាយ មិនគប្បីនៅចាំវស្សាក្នុងអាវាសមិនមានភិក្ខុនេះ ។ សមពិត ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា "**អភិក្ខុកោ នាម អាវាសោ ន សក្កា ហោតិ ឱវាទាយ វា សំវាសាយ វា គន្តុំ : អាវាសដែលភិក្ខុមិនអាចនឹងទៅឱ្យឱវាទក្តី នៅរួមក្តី ឈ្មោះថា អាវាសឥតភិក្ខុ**"[១] និងមិនអាចដើម្បីទៅទីដទៃក្រៅពីសំណាក់ភិក្ខុនីនោះក្នុងវេលាក្រោយភត្ត ស្តាប់ធម៌ហើយត្រឡប់មក ។ បើពួកញាតិ ឬពួកឧបដ្ឋាក ពោលនឹងភិក្ខុនីទាំងឡាយ ដែលមិនប្រាថ្នានឹងនៅចាំវស្សា ក្នុងអាវាសនោះយ៉ាងនេះថា សូមនៅចុះ នាងជាម្ចាស់ ពួកខ្ញុំនឹងនាំភិក្ខុទាំងឡាយមក ដូច្នេះ គួរ ។

តែបើភិក្ខុទាំងឡាយ មានសេចក្តីប្រាថ្នានឹងនៅចាំវស្សាក្នុងប្រទេសមានប្រមាណដូចយើងពោលហើយ មកឈប់សម្រាកសួម្បីត្រឹងបារាំធ្វើ

១. វិន. ភិក្ខុនី. អារាមវគ្គ. ៥. ៣៥០/៣០៤ ។

ដោយមែកឈើមួយយប់ ត្រូវពួកអ្នកស្រុកនិមន្តទុក ទើបមិនប្រាថ្នានឹងទៅ[1] សូម្បីដោយសេចក្តីប្រាថ្នា ដែលភិក្ខុនឹងមកនៅចាំវស្សាត្រឹមតែប៉ុណ្ណោះ ក៏ឈ្មោះថា អាវាសមានភិក្ខុ ។ ពួកភិក្ខុនីនឹងចូលចាំវស្សាក្នុងអាវាសនេះ ក៏គួរ និងកាលចូលវស្សា គប្បីសូមអង្វរភិក្ខុទាំងឡាយក្នុងថ្ងៃ ១៣ នៃបក្ខនុ៎ះឯងថា បពិត្រលោកម្ចាស់ ពួកខ្ញុំម្ចាស់នឹងនៅដោយឱវាទរបស់លោកទាំងឡាយ ។

ស្ថានទីនៅរបស់ភិក្ខុទាំងឡាយ នៅក្នុងទីកន្លះយោជន៍ ដោយមកត្រង់អំពីសំណាក់ភិក្ខុនីណា អន្តរាយដល់ជីវិត និងអន្តរាយនៃព្រហ្មចរិយៈ មានដល់ពួកភិក្ខុនីអ្នកទៅដោយមកនោះ, កាលទៅដោយមកដទៃ មានចម្ងាយលើសពីកន្លះយោជន៍, អាវាសនេះ រមែងតាំងនៅក្នុងឋានៈនៃអាវាសមិនមានភិក្ខុដូចគ្នា ។ តែបើថា មានលំនៅភិក្ខុនីដទៃនៅក្នុងទីរួចផុតភ័យឆ្ងាយពីលំនៅភិក្ខុនីនោះ ប្រមាណមួយគាវុត, ភិក្ខុនីទាំងនោះ គប្បីសូមអង្វរភិក្ខុនីទាំងនោះ ហើយត្រឡប់ទៅសូមអង្វរភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ទាំងឡាយ មានអន្តរាយក្នុងមកត្រង់ដល់ពួកខ្ញុំម្ចាស់, កាលទៅមកដទៃមានចម្ងាយលើសពីកន្លះយោជន៍ តែក្នុងចន្លោះមក មានលំនៅភិក្ខុនីដទៃ ឆ្ងាយពីលំនៅរបស់ពួកខ្ញុំម្ចាស់ប្រមាណ

---

១. ប្រែតាមដីកានិងយោជនា ។

មួយគាវុត, ពួកខ្ញុំម្ចាស់នឹងនៅដោយឱវាទដែលមកហើយក្នុងសំណាក់ភិក្ខុនីនោះអំពីសំណាក់លោកម្ចាស់ទាំងឡាយ ។ ភិក្ខុទាំងនោះ គប្បីទទួលព្រម ។ តាំងពីនោះទៅភិក្ខុនីទាំងនោះ គប្បីមកកាន់លំនៅភិក្ខុនីនោះធ្វើឧបោសថ, ឬថា សួរសុខទុក្ខភិក្ខុនីទាំងនោះហើយ ត្រឡប់ទៅកាន់លំនៅរបស់ខ្លួនទុំះឯង ធ្វើឧបោសថក៏បាន ។

ក៏បើថា ភិក្ខុទាំងឡាយប្រាថ្នានឹងនៅចាំវស្សា មកកាន់វិហារក្នុងថ្ងៃ ១៤ និងពួកភិក្ខុនីសួរថា លោកម្ចាស់នឹងនៅចាំវស្សាក្នុងទីនេះឬ ? ហើយពោលថា អើ ភិក្ខុនីទាំងនោះក្រាបទូលតទៅថា លោកម្ចាស់បើយ៉ាងនោះ សូម្បីពួកខ្ញុំម្ចាស់ក៏នឹងនៅអាស្រ័យឱវាទ របស់លោកម្ចាស់ទាំងឡាយ ដូច្នេះ, ក្នុងថ្ងៃស្អែក មិនឃើញសេចក្ដីបរិបូរនៃអាហារក្នុងស្រុក គិតថា យើងមិនអាចនៅក្នុងទីនេះបាន ទើបជៀសទៅ, បើថា ភិក្ខុនីទាំងនោះ ទៅកាន់វិហារក្នុងថ្ងៃឧបោសថ មិនឃើញភិក្ខុទាំងនោះ, សួរថា ក្នុងអាវាសដូច្នេះ នឹងគប្បីធ្វើយ៉ាងណា ? ឆ្លើយថា ភិក្ខុទាំងឡាយ នៅក្នុងអាវាសណា គប្បីទៅចូលវស្សាក្នុងថ្ងៃចូលវស្សាក្រោយក្នុងអាវាសនោះ, ឬ ថា ធ្វើសេចក្ដីចង់ចិត្តថា ភិក្ខុទាំងឡាយនឹងមកចូលវស្សាក្នុងថ្ងៃចូលវស្សាក្រោយ ហើយគប្បីនៅដោយឱវាទក្នុងសំណាក់របស់ពួកភិក្ខុដែលមកហើយ ។

ក៏បើថា សូម្បីក្នុងថ្ងៃចូលបច្ឆិមិកាវស្សាក៏មិនមានភិក្ខុរូបខ្លះមក,

និងក្នុងចន្លោះមក មានរាជភ័យ ចោរភ័យ ឬទុព្ភិក្ខភ័យ, ជាអាបត្តិដល់ភិក្ខុនី អ្នកនៅក្នុងអាវាសមិនមានភិក្ខុ, សូម្បីអ្នកដាច់វស្សាទៅ ក៏ជាអាបត្តិ, គប្បីរក្សាអាបត្តិ មានការដាច់វស្សាជាហេតុនោះទុក ។ ពិតមែនក្នុងអន្តរាយទាំងឡាយ លោកពិន័យជាអនាបត្តិដល់ភិក្ខុនីអ្នកនៅក្នុងអាវាសដែលមិនមានភិក្ខុ ។

បើភិក្ខុទាំងឡាយមកចូលវស្សាហើយ ជៀសចេញទៀត ដោយហេតុយ៉ាងណាមួយក៏ដោយ, ពួកភិក្ខុនីគប្បីនៅតទៅ ។ សមពិត ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា "វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺ ភិក្ខុទាំងឡាយនៅចាំវស្សាហើយ ចៀសចេញទៅក្តី សឹកទៅក្តី ស្លាប់ក្តី ចូលពួក(គឺចូលទៅសាសនាដទៃ) ក្តី១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១"[១] ។ តែកាលទីងបវារណា គប្បីទៅបវារណាក្នុងអាវាសដែលមានពួកភិក្ខុ ។

បទថា អន្វឌ្ឍមាសំ : គ្រប់កន្លះខែ គឺ រាល់ ៗកន្លះខែ ។

បីបទថា ទ្វេ ធម្មា បច្ចាសីសិតព្វា : ត្រូវប្រាថ្នាធម៌ពីរប្រការ គឺ គប្បីប្រាថ្នាធម៌ ២ យ៉ាង ។

បទថា ឧបោសថបុច្ឆកំ : សាកសួរនូវឧបោសថ គឺ សួរដល់

១. វិន. ភិក្ខុនី. អារាមវគ្គ. ៥. ៣៥១/៣០៤ ។

ឧបោសថ ។ ក្នុងការសួរដល់ឧបោសថនោះ ក្នុងឧបោសថ ១៥ គប្បីទៅសួរឧបោសថក្នុងថ្ងៃ ១៤ នៃបក្ខក្នុងឧបោសថ ១៤ គប្បីទៅសួរឧបោសថក្នុងថ្ងៃ ១៣ នៃបក្ខ ។ តែក្នុងមហាបច្ចរីពោលថា គប្បីទៅសួរក្នុងតិថីទី ១៣ នៃបក្ខទាំងឯងថា ឧបោសថនេះ ១៤ ឬ ១៥ ។ ក្នុងថ្ងៃឧបោសថ គប្បីចូលទៅដើម្បីប្រយោជន៍ដល់ឱវាទ ។ ក៏តាំងពីថ្ងៃ ១ រោចទៅ គប្បីទៅដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ ។ ព្រះមានព្រះភាគទ្រង់មិនប្រទានឱកាសដល់កម្មដទៃ ទ្រង់បញ្ញត្តិការទៅជាប់តគ្នា ក្នុងលំនៅរបស់ភិក្ខុទាំងឡាយប៉ុណ្ណោះ ដល់ពួកភិក្ខុនីដោយប្រការយ៉ាងនេះ ។ ព្រោះហេតុអ្វី ? ព្រោះ មាតុគ្រាម មានបញ្ញាតិច ។ ពិតមែន មាតុគ្រាមមានបញ្ញាតិច ការស្តាប់ធម៌ជានិច្ច មានឧបការៈច្រើនដល់នាង (ដល់មាតុគ្រាមនោះ) ។ ក៏កាលបើមានហេតុយ៉ាងនេះ ភិក្ខុនីទាំងឡាយនឹងមិនធ្វើមានះថា លោកម្ចាស់ទាំងឡាយ រមែងដឹងធម៌ដែលពួកយើងដឹងហើយប៉ុណ្ណោះ ហើយនឹងចូលទៅអន្ទយ ជិតភិក្ខុសង្ឃ ធ្វើការបព្វជ្ជាឱ្យមានប្រយោជន៍ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់បានធ្វើ (ការបញ្ញត្តិ) យ៉ាងនោះ ចំណែកភិក្ខុនីទាំងឡាយ សម្គាល់ថា យើងទាំងឡាយនឹងបដិបត្តិតាមដែលទ្រង់ទូន្មាន ទើបចូលទៅកាន់វិហារមិនដាច់ទាំងអស់តែម្តង ។

## ភិក្ខុនីសង្ឃចូលទៅរកភិក្ខុសង្ឃដើម្បីទទួលឱវាទ

សមពិត ដូចពាក្យដែលព្រះធម្មសង្គាហកាចារ្យបានពោលទុកថា "សម័យនោះឯង ភិក្ខុនីសង្ឃទាំងអស់នាំគ្នាទៅទទួលឱវាទ ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងនេះ ជាប្រពន្ធរបស់ភិក្ខុទាំងនេះ, ភិក្ខុនីទាំងនេះជាសហាយរបស់ភិក្ខុទាំងនេះ, ឥឡូវនេះ ភិក្ខុទាំងនេះនឹងត្រេកត្រអាលជាមួយភិក្ខុនីទាំងនេះ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃមិនត្រូវទៅទទួលឱវាទ (ព្រមគ្នា)ទាំងអស់ទេ, បើទៅ ត្រូវទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុនី ៤-៥ រូប ទៅទទួលឱវាទ(ម្តង ៗបាន)"[១] ដូច្នេះ ។ ទោះជាយ៉ាងនោះ ពួកអ្នកស្រុកក៏ពោលទោសដូចគ្នាទៀត ។ ព្រះមានព្រះភាគត្រាស់ទៀតថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ៤-៥ រូប មិនត្រូវទៅទទួលឱវាទទេ, បើទៅ ត្រូវទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុនី ២-៣ រូប ទៅទទួលឱវាទ"[២] ដូច្នេះ ។

ព្រោះហេតុនោះឯង ភិក្ខុនីសង្ឃគប្បីសូមអង្វរភិក្ខុនី ២-៣ រូប ហើយបញ្ជូនទៅថា ទៅចុះនាងជាម្ចាស់ ចូរសូមការចូលទៅទទួលឱវាទ

១-២ វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ២០៧-៨/២៩២ ។

ចំពោះភិក្ខុសង្ឃថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃសូមការចូលទៅដើម្បីទទួល ឱវាទចំពោះភិក្ខុសង្ឃ ដូច្នេះ ។ ភិក្ខុនីទាំងនោះ គប្បីទៅកាន់អារាម តពីនោះ គប្បីចូលទៅរកភិក្ខុមួយរូប អ្នកទទួលឱវាទថ្វាយបង្គំហើយ, ភិក្ខុនីមួយរូប គប្បីក្រាបទូលភិក្ខុនោះយ៉ាងនេះថា "បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃ សូមថ្វាយបង្គំព្រះបាទានៃភិក្ខុសង្ឃ និងសូមការចូលមកដើម្បីទទួលឱវាទ បពិត្រលោកម្ចាស់ឮថា ភិក្ខុនីសង្ឃចូរបានការចូលមកដើម្បីទទួលឱវាទ" ដូច្នេះ ។

ភិក្ខុនោះ គប្បីចូលទៅរកភិក្ខុដែលសម្ដែងបាដិមោក្ខ ហើយគប្បីពោលយ៉ាងនេះថា "លោកដ៏មានអាយុ ភិក្ខុនីសង្ឃ សូមថ្វាយបង្គំព្រះបាទារបស់ភិក្ខុសង្ឃ និងសូមការចូលមកដើម្បីទទួលឱវាទ, លោកដ៏មានអាយុ បានឮថា ភិក្ខុនីសង្ឃ ចូរបាននូវការចូលមកដើម្បីទទួលឱវាទ" ដូច្នេះ ។ ភិក្ខុដែលសម្ដែងបាដិមោក្ខគប្បីពោលថា មានភិក្ខុរូបខ្លះដែលសង្ឃសន្មតឱ្យជាអ្នកប្រៀនប្រដៅភិក្ខុនីឬ ? បើមានភិក្ខុរូបណា ដែលសង្ឃសន្មតឱ្យជាអ្នកប្រៀនប្រដៅភិក្ខុនី, ភិក្ខុដែលសម្ដែងបាដិមោក្ខគប្បីពោលថា ភិក្ខុឈ្មោះឯណោះ សង្ឃសន្មតឱ្យជាអ្នកប្រៀនប្រដៅភិក្ខុនី, ភិក្ខុនីសង្ឃចូរចូលទៅរកភិក្ខុនោះ ដូច្នេះ ។

បើមិនមានភិក្ខុដែលសង្ឃសន្មតឱ្យជាអ្នកប្រៀនប្រដៅភិក្ខុនី, ភិក្ខុដែលសម្ដែងបាដិមោក្ខ គប្បីពោលថា លោកអ្នកមានអាយុរូបណា នឹង

អាចប្រៀនប្រដៅពួកភិក្ខុនី ? បើមានភិក្ខុរូបខ្លះអាចនឹងប្រៀនប្រដៅពួកភិក្ខុនី និងភិក្ខុនោះ ជាអ្នកប្រកបដោយអង្គ ៨ គប្បីសន្មតភិក្ខុនោះ ហើយពោលថា ភិក្ខុឈ្មោះឯណោះ សង្ឃសន្មតឱ្យជាអ្នកប្រៀនប្រដៅភិក្ខុនី, ភិក្ខុនីសង្ឃចូរចូលទៅរកភិក្ខុនោះចុះ ។

តែបើភិក្ខុណាមួយ ក៏មិនអាចប្រៀនប្រដៅពួកភិក្ខុនី, ភិក្ខុអ្នកសម្តែងបាដិមោក្ខគប្បីពោលថា មិនមានភិក្ខុរូបខ្លះដែលសង្ឃសន្មតឱ្យជាអ្នកប្រៀនប្រដៅភិក្ខុនី, ភិក្ខុនីសង្ឃចូរឱ្យដល់ព្រមដោយកម្ម ដែលគួរជ្រះថ្លាចុះ ។ ពិតមែន ដោយពាក្យត្រឹមតែប៉ុណ្ណេះ សាសនាសង្គ្រោះ ដោយត្រៃសិក្ខាទាំងអស់ ជាសិក្ខាដែលលោកប្រាប់ហើយ ។ ភិក្ខុនោះទទួលថា "ល្អណាស់" ហើយគប្បីប្រាប់ដល់ភិក្ខុនីទាំងឡាយក្នុងថ្ងៃ ១ រោច ។

សូម្បីភិក្ខុនីសង្ឃ គប្បីបញ្ជូនភិក្ខុនីទាំងនោះទៅថា "ទៅចុះនាងម្ចាស់ ចូរសួរថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃ រមែងបានការចូលមកដើម្បីទទួលឱវាទឬ ?" ភិក្ខុនីទាំងនោះទទួលថា "ល្អណាស់ ព្រះនាងជាម្ចាស់" ហើយទៅកាន់អារាម ចូលទៅរកភិក្ខុនោះ គប្បីពោលយ៉ាងនេះថា "បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃ រមែងបានការចូលមកដើម្បីទទួលឱវាទឬ ?" ភិក្ខុនោះ គប្បីពោលថា "មិនមានភិក្ខុរូបណាដែលសង្ឃសន្មតឱ្យជាអ្នកប្រៀនប្រដៅភិក្ខុនី, ភិក្ខុនីសង្ឃ ចូរឱ្យដល់ព្រមដោយកម្មដែលគួរ

ជ្រះថ្លាចុះ”, ភិក្ខុនីទាំងនោះ គប្បីទទួលថា “ល្អណាស់ លោកម្ចាស់” ។

ក៏លោកពោលពាក្យពហុវចនៈថា **តាហិ : ទាំងនោះ** ដោយអំណាចនៃភិក្ខុនីទាំងឡាយអ្នកមកព្រមគ្នា ។ ក៏បណ្ដាភិក្ខុនីទាំងនោះ ភិក្ខុនីមួយរូប គប្បីពោលនិងគប្បីទទួល ។ ភិក្ខុនីក្រៅនេះ គប្បីជាសម្លាញ់របស់ភិក្ខុនីនោះ ។ ក៏បើថា ភិក្ខុនីសង្ឃក្តី ភិក្ខុសង្ឃក្តី មិនគ្រប់ (អន្តជាសង្ឃ) ។ ឬទាំង ២ ចំណែកត្រឹមតែជាគណៈឬបុគ្គលប៉ុណ្ណោះក្តី ភិក្ខុនីតែមួយរូបត្រូវបញ្ជូនទៅ អំពីលំនៅភិក្ខុនីច្រើនកន្លែង ដើម្បីប្រយោជន៍ដល់ឱវាទក្តី ។ ក្នុងពាក្យថា ភិក្ខុនីសង្ឃោ វា ន បូរតិ ជាដើមនោះ មានវចនានុក្រមដូចតទៅនេះ ៖

## លំដាប់ពាក្យសូមទាំងពីរចំណែកដែលគ្រប់សង្ឃនិងមិនគ្រប់សង្ឃ

១. ថា “បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយ សូមថ្វាយបង្គំព្រះបាទារបស់ភិក្ខុសង្ឃ និងសូមការចូលមកដើម្បីទទួលឱវាទ, បពិត្រលោកម្ចាស់ បានឮថា ពួកភិក្ខុនីចូរបានការចូលមកដើម្បីទទួលឱវាទ” ។

២. ថា “បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់សូមថ្វាយបង្គំព្រះបាទាភិក្ខុសង្ឃ និងសូមការចូលមកដើម្បីទទួលឱវាទ, បានឮថា ខ្ញុំម្ចាស់ចូរបានការចូលមកដើម្បីទទួលឱវាទ” ។

៣. ថា “បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃថ្វាយបង្គំព្រះបាទាលោក

ម្ចាស់ទាំងឡាយ និងសូមការចូលមកដើម្បីទទួលឱវាទ, បពិត្រលោកម្ចាស់ បានឮថា ភិក្ខុនីសង្ឃចូរបានការចូលមកដើម្បីទទួលឱវាទ” ។

៤. ថា “បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយថ្វាយបង្គំព្រះបាទាលោកម្ចាស់ទាំងឡាយ និងសូមការចូលមកដើម្បីទទួលឱវាទ, បពិត្រលោកម្ចាស់ បានឮថា ភិក្ខុនីទាំងឡាយ ចូរបានការចូលមកដើម្បីទទួលឱវាទ” ។

៥. ថា “បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់ថ្វាយបង្គំព្រះបាទារបស់លោកម្ចាស់ទាំងឡាយ និងសូមការចូលមកដើម្បីទទួលឱវាទ, បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់ចូរបានការចូលមកដើម្បីទទួលឱវាទ” ។

៦. ថា “បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃថ្វាយបង្គំព្រះបាទារបស់លោកម្ចាស់និងសូមការចូលមកដើម្បីទទួលឱវាទ, បពិត្រលោកម្ចាស់ បានឮថា ភិក្ខុនីសង្ឃចូរបានការចូលមកដើម្បីទទួលឱវាទ” ។

៧. ថា “បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយ ថ្វាយបង្គំព្រះបាទារបស់លោកម្ចាស់ និងសូមការចូលមកដើម្បីទទួលឱវាទ, បពិត្រលោកម្ចាស់ បានឮថា ភិក្ខុនីទាំងឡាយចូរបានការចូលមកដើម្បីទទួលឱវាទ” ។

៨. ថា “បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់ថ្វាយបង្គំព្រះបាទាលោកម្ចាស់និងសូមការចូលមកដើម្បីទទួលឱវាទ, បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់ចូរបានការចូលមកដើម្បីទទួលឱវាទ” ។

៩. ថា "បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃថ្វាយបង្គំ ភិក្ខុនីទាំងឡាយថ្វាយបង្គំ និងភិក្ខុនីថ្វាយបង្គំព្រះបាទារបស់ភិក្ខុសង្ឃ របស់លោកម្ចាស់ទាំងឡាយ របស់លោកម្ចាស់ និងសូម សូម សូមការចូលមកដើម្បីទទួលឱវាទ, បពិត្រលោកម្ចាស់ បានឮថា ភិក្ខុនីសង្ឃចូរបាន ... បានឮថា ភិក្ខុនីទាំងឡាយចូរបាន ... ។ និងឮថា ភិក្ខុនីចូរបានការចូលមកដើម្បីទទួលឱវាទ"[១] ។

ភិក្ខុនោះ គប្បីពោលក្នុងវេលាធ្វើឧបោសថយ៉ាងនេះថា "បពិត្រលោកដ៏ចម្រើន ភិក្ខុនីទាំងឡាយ ថ្វាយបង្គំព្រះបាទារបស់ភិក្ខុសង្ឃ និងសូមការចូលមកដើម្បីទទួលឱវាទ, បពិត្រលោកដ៏ចម្រើន បានឮថា ភិក្ខុនីទាំងឡាយ ចូរបានការចូលមកដើម្បីទទួលឱវាទ" ។

ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ភិក្ខុនីថ្វាយបង្គំព្រះបាទាភិក្ខុសង្ឃ និងសូមការចូលមកដើម្បីទទួលឱវាទ, បពិត្រលោកម្ចាស់ដ៏ចម្រើន បានឮថា ភិក្ខុនីចូរបានការចូលមកដើម្បីទទួលឱវាទ" ។

ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ភិក្ខុនីសង្ឃ ។ល ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ភិក្ខុនីថ្វាយបង្គំព្រះបាទារបស់លោកអ្នកមានអាយុទាំងឡាយ និងសូមការចូលមកដើម្បីទទួលឱវាទ, បពិត្រលោកម្ចាស់

១. សេចក្តីនេះ ដាក់ជាបេយ្យាលទុក ដោយន័យដូចខាងដើម, បើបំបែកមាន ៩ ។

ដ៏ចម្រើន បានឮថា ភិក្ខុនីចូរបានការចូលមកដើម្បីទទួលឱវាទ ។

ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ភិក្ខុនីសង្ឃថ្វាយបង្គំ ភិក្ខុនីទាំងឡាយថ្វាយបង្គំ និងភិក្ខុនីថ្វាយបង្គំព្រះបាទារបស់ភិក្ខុសង្ឃ របស់លោកអ្នកមានអាយុទាំងឡាយ និងសូម សូម សូមការចូលមកដើម្បីទទួលឱវាទ, ឮថា ភិក្ខុនីសង្ឃចូរបាន ... ឮថា ភិក្ខុនីទាំងឡាយចូរបាន ... ... និងឮថា ភិក្ខុនីចូរបានការចូលមកដើម្បីទទួលឱវាទ[១] ។

ចំណែកភិក្ខុដែលសូត្របាដិមោក្ខ បើមានភិក្ខុដែលសង្ឃសន្មតគប្បីពោលដោយន័យមុនទុំះឯងថា ភិក្ខុនីសង្ឃ ចូរចូលទៅរកភិក្ខុនោះ, ភិក្ខុនីទាំងឡាយ ចូរចូលទៅរកភិក្ខុនោះ, ភិក្ខុនីចូរចូលទៅរកភិក្ខុនោះ, ដូច្នេះ ។ បើភិក្ខុដែលបានទទួលសន្មតមិនមាន, គប្បីពោលថា ភិក្ខុនីសង្ឃចូរឱ្យដល់ព្រមដោយកម្មដែលគួរជ្រះថ្លាចុះ ភិក្ខុនីទាំងឡាយចូរឱ្យដល់ព្រម ... ។ ភិក្ខុនីចូរឱ្យដល់ព្រមដោយកម្មដែលគួរជ្រះថ្លាចុះ ។ ភិក្ខុដែលទទួលឱវាទ គប្បីនាំត្រឡប់ទៅប្រាប់ដូចយ៉ាងនោះ ក្នុងថ្ងៃបាដិបទ ។

ក៏ភិក្ខុដទៃ វៀរភិក្ខុពាល អ្នកអាពាធ និងអ្នកត្រៀមនឹងចេញទៅប្រសិនបើថា ជាអ្នកនៅព្រៃជាវត្ត ទឹងមិនទទួលឱវាទមិនបាន ។ សម

---

១, សេចក្តីនេះ ត្រូវចែកប្រែជាសេចក្តីដូចខាងដើម ឱ្យគ្រប់ទាំង ៩ រូមជា ១៧ ។

ពិត ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យលើកលែងភិក្ខុល្វង់ លើកលែងភិក្ខុឈឺ និងភិក្ខុផ្ញើដំណើរ ឱ្យភិក្ខុដែលនៅក្រៅពីនេះទទួលឱវាទ”[១] ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុដែលមានសេចក្តីប្រាថ្នានឹងទៅក្នុងថ្ងៃឧបោសថទី ១៤១៥ ឬក្នុងថ្ងៃបាដិបទ ឈ្មោះថា អ្នកត្រៀមនឹងទៅ ។ នឹងទៅក្នុងថ្ងៃនៃបក្ខទី ២ នឹងមិនទទួលក៏មិនបាន គឺ ត្រូវអាបត្តិដែលត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រកែកមិនព្រមទទួលឱ្យឱវាទទេ, ភិក្ខុណាមិនទទួល, ត្រូវទុក្កដ”[២] ដូច្នេះនុ៎ះឯង ។

ភិក្ខុទទួលឱវាទហើយ មិនប្រាប់ក្នុងពេលឧបោសថ ឬមិននាំត្រឡប់ទៅប្រាប់ដល់ភិក្ខុនីទាំងឡាយក្នុងថ្ងៃបាដិបទ រមែងមិនគួរ ។ សមពិតដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុមិនប្រាប់ឱវាទ( ដល់ភិក្ខុនី )ទេ, ភិក្ខុណាមិនប្រាប់, ត្រូវទុក្កដ”[៣] ។ សូម្បីពាក្យដទៃក៏ត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវមិនផ្ចាស់ទី ( តាមសង្កេត )ទេ, ភិក្ខុណាមិនផ្ចាស់, ត្រូវទុក្កដ”[៤] ដូច្នេះ ។

---

១. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ២១២/២៩៦ ។ ២. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ២០៩/២៩៤ ។ ៣. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ២១៤/២៩៧ ។ ៤. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ២១៥/២៩៧ ។

បណ្ដាភិក្ខុដែលនាំឱវាទទៅប្រាប់ទាំងនោះ ភិក្ខុដែលកាន់អរញ្ញិកធុតង្គ គប្បីធ្វើការកំណត់ដើម្បីនាំទៅប្រាប់ ។ សមពិត ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុអ្នកនៅក្នុងព្រៃទទួល ឱ្យឱវាទផង ឱ្យធ្វើសង្កេត (ការកំណត់)ផងថា អាត្មាអញនឹងផ្ទាស់ទៅក្នុងទីនោះ"[១] ដូច្នេះ ។ ព្រោះហេតុនោះ ភិក្ខុដែលនៅព្រៃជាវត្ត ប្រសិនបើបានភិក្ខាក្នុងស្រុកជាទីនៅរបស់ភិក្ខុនីទាំងឡាយ, គប្បីត្រាច់ទៅក្នុងស្រុកនោះឯង ជួបពួកភិក្ខុនីប្រាប់ហើយ សឹមទៅ ។ បើស្រុកនោះ រកភិក្ខាបានដោយលំបាក សម្រាប់លោក, គប្បីត្រាច់ទៅក្នុងស្រុកជិត ៗ ហើយមកស្រុករបស់ពួកភិក្ខុនី ធ្វើដូចយ៉ាងនោះឯង ។ ប្រសិនបើនឹងត្រូវទៅឆ្ងាយគប្បីធ្វើការកំណត់ថា "យើងនឹងចូលទៅកាន់សភា មណ្ឌប ឬគល់ឈើ ឈ្មោះឯណោះ ជិតទ្វារស្រុករបស់ពួកនាង, ពួកនាងគប្បីមកទីសភាជាដើមនោះ" ។ ពួកភិក្ខុនីគប្បីទៅត្រង់សភាជាដើមនោះ នឹងមិនទៅមិនបាន ។ សមពិត ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវខានទៅកាន់ទីដែលសង្កេតកំណត់ហើយទេ ភិក្ខុនីណាមិនទៅ, ត្រូវទុក្កដ"[២] ដូច្នេះ ។

---

១. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ២១៣/២៩៦ ។

២. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ២១៦/២៩៧ ។

## ការបវារណាក្នុងឧភតោសង្ឃ

ក្នុងពាក្យថា ឧភតោសង្ឃេ តីហិ ឋានេហិ បវារេតុំ : ត្រូវបវារណាក្នុងឧភតោសង្ឃ ដោយហេតុ ៣ យ៉ាង នេះ មានវិនិច្ឆ័យថា ភិក្ខុនីទាំងឡាយ បវារណាដោយខ្លួនឯងក្នុងថ្ងៃ ១៤ ហើយ គប្បីបវារណាក្នុងភិក្ខុសង្ឃក្នុងថ្ងៃឧបោសថ ។ សមពិត ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុនីបវារណា នឹងភិក្ខុនីសង្ឃក្នុងថ្ងៃនេះ ហើយបវារណានឹងភិក្ខុសង្ឃក្នុងថ្ងៃស្អែកទៀត"[១] ដូច្នេះ ។

ក៏បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនេះ ដោយន័យដូចដែលត្រាស់ទុកក្នុងភិក្ខុនីខន្ធកៈនុ៎ះឯង ។ សមពិត ដូចពាក្យដែលព្រះឧបាលីពោលទុកថា "សម័យនោះឯង ភិក្ខុនីសង្ឃទាំងអស់ នាំគ្នាបវារណា ធ្វើឱ្យកោលាហល ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យសន្មតភិក្ខុនី១រូប ដែលឆ្លាសប្រតិពលឱ្យបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ(ជំនួសភិក្ខុនីសង្ឃ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវសន្មតយ៉ាងនេះ គប្បីសូមអង្វរភិក្ខុនីជាមុន ។

---

១. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ២៥១/៣២៦ ។

លុះសូមអង្វររួចហើយ ភិក្ខុនីដែលឆ្លាសប្រតិពល ត្រូវប្រកាសសង្ឃថា បពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ, សង្ឃគប្បីសន្មតភិក្ខុនីឈ្មោះនេះ ឱ្យជាអ្នកបវារណាទឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ, នេះជាញត្តិ ។ បពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ សង្ឃនឹងសន្មតភិក្ខុនីឈ្មោះនេះ ឱ្យជាអ្នកបវារណាទឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ, ការសន្មតិភិក្ខុនីឈ្មោះនេះ ឱ្យជាអ្នកបវារណាទឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ សមគួរដល់នាងជាម្ចាស់អង្គណា, នាងជាម្ចាស់អង្គនោះគប្បីស្ងៀម, មិនសមគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីឆ្លើយមក ។ ភិក្ខុនីឈ្មោះនេះ សង្ឃបានសន្មតឱ្យជាអ្នកបវារណាទឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃហើយ ។ ការសន្មតសមគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម, ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ”[១] ។

ភិក្ខុនីដែលសង្ឃសន្មតនោះ នាំភិក្ខុនីសង្ឃចូលទៅរកភិក្ខុសង្ឃហើយ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ផ្គងអញ្ជលី គប្បីពោលយ៉ាងនេះថា “បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃ រមែងបវារណាចំពោះភិក្ខុសង្ឃ

១. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ២៥២/៣២៦ ។

ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី, បពិត្រលោកម្ចាស់ សូមភិក្ខុសង្ឃចូរអាស្រ័យសេចក្តីអនុគ្រោះពោលនឹងភិក្ខុនីសង្ឃ, ភិក្ខុនីសង្ឃឃើញនឹងសម្តែង, បពិត្រលោកម្ចាស់ ជាគម្រប់ពីរដងផង ... ។ បពិត្រលោកម្ចាស់ ជាគម្រប់ពីរដងផង ភិក្ខុនីសង្ឃ ។ល ។ នឹងសម្តែង" ដូច្នេះ ។

បើភិក្ខុនីសង្ឃ មិនគ្រប់ ( អង្គជាសង្ឃ ), នាងភិក្ខុនីដែលសង្ឃសន្មត គប្បីពោល ៣ ដងយ៉ាងនេះថា "បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយ បវារណាភិក្ខុសង្ឃ ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី, បពិត្រលោកម្ចាស់ សូមភិក្ខុសង្ឃ អាស្រ័យសេចក្តីអនុគ្រោះពោលប្រាប់ពួកភិក្ខុនី, ភិក្ខុនីទាំងឡាយបានឃើញ នឹងសម្តែង", ឬថា "បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់បវារណាភិក្ខុសង្ឃ ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី, បពិត្រលោកម្ចាស់ សូមភិក្ខុសង្ឃ អាស្រ័យសេចក្តីអនុគ្រោះ ពោលប្រាប់ខ្ញុំម្ចាស់, ខ្ញុំម្ចាស់បានឃើញ នឹងសម្តែង" ដូច្នេះ ។

បើភិក្ខុមិនគ្រប់ ( សង្ឃ ) គប្បីពោល ៣ ដងយ៉ាងនេះថា "បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃបវារណាចំពោះលោកម្ចាស់ទាំងឡាយ ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី, សូមលោកម្ចាស់ទាំងឡាយ អាស្រ័យសេចក្តីអនុគ្រោះ ពោលប្រាប់ភិក្ខុនីសង្ឃ, ភិក្ខុនី

សង្ឃបានឃើញ នឹងសម្តែង", ឬថា "បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃបវារណាចំពោះលោកម្ចាស់ ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី, សូមលោកម្ចាស់ អាស្រ័យសេចក្តីអនុគ្រោះ ពោលប្រាប់ភិក្ខុនីសង្ឃ, ភិក្ខុនីសង្ឃបានឃើញ នឹងសម្តែង" ដូច្នេះ ។

កាលមិនគ្រប់សង្ឃសូម្បីទាំង ២ ចំណែក គប្បីពោល ៣ ដងយ៉ាងនេះថា "បពិត្រលោកម្ចាស់ទាំងឡាយ ភិក្ខុនីទាំងឡាយបវារណាចំពោះលោកម្ចាស់ទាំងឡាយ ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី, សូមលោកម្ចាស់ទាំងឡាយ អាស្រ័យសេចក្តីអនុគ្រោះ ពោលប្រាប់ភិក្ខុនីទាំងឡាយ, ភិក្ខុនីទាំងឡាយបានឃើញ នឹងសម្តែង", ឬថា "បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយបវារណាចំពោះលោក ម្ចាស់ ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី, បពិត្រលោកម្ចាស់ សូមលោកម្ចាស់ អាស្រ័យសេចក្តីអនុគ្រោះ ពោលប្រាប់ភិក្ខុនីទាំងឡាយ, ភិក្ខុនីទាំងឡាយបានឃើញ នឹងសម្តែង" ដូច្នេះ, ថា "បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់បវារណាចំពោះលោកម្ចាស់ទាំងឡាយ ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី, សូមលោកម្ចាស់ទាំងឡាយ អាស្រ័យសេចក្តីអនុគ្រោះ ពោលប្រាប់ខ្ញុំម្ចាស់, ខ្ញុំម្ចាស់បានឃើញ នឹងសម្តែង", ឬថា "បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់បវារណាចំពោះលោកម្ចាស់ ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី សូមលោកម្ចាស់

អាស្រ័យសេចក្ដីអនុគ្រោះ ពោលប្រាប់ខ្ញុំម្ចាស់, ខ្ញុំម្ចាស់បានឃើញ នឹងសម្ដែង" ដូច្នេះ ។

ការប្រព្រឹត្តមានគ្គ និងការស្វែងរកការឧបសម្បទា នឹងមានច្បាស់ក្នុងទីតាមគួរដល់ឋានៈនុ៎ះឯង ។

ពាក្យថា ន ភិក្ខុនិយា កេនចិ បរិយាយេន : ភិក្ខុនីមិន(ត្រូវ ជេរ មិនត្រូវប្រទេចផ្ដាសាភិក្ខុ)ដោយបរិយាយណាមួយឡើយ មានសេចក្ដីថា ភិក្ខុនី កុំគប្បីជេរ កុំគប្បីបរិភាស(ជេរ)ភិក្ខុដោយអក្កោសវត្ថុ ១០ ឬដោយពាក្យប្រៀបផ្ទឹមអ្វីយ៉ាងដទៃ និងមិនគប្បីគម្រាមភិក្ខុដោយភ័យ ។

បទថា ឱវដោ : ស្ដី បានដល់ បិទ គឺ ការពារ ហាម ។ ពាក្យនុ៎ះឯង ឈ្មោះថា វចនបថោ : ប្រដៅ ។

បទថា អនោវដោ : មិនត្រូវស្ដី បានដល់ មិនបិទ គឺមិនការពារ មិនហាម ។ ព្រោះហេតុនោះ ភិក្ខុនីតាំងនៅក្នុងឋាននៃភាពជាអ្នកធំ គឺក្នុងឋាននៃអ្នកជាប្រធាន កុំគប្បីពោលប្រាប់ កុំគប្បីប្រៀនប្រដៅភិក្ខុដោយបរិយាយណា ៗថា លោកចូរដើរទៅមុខយ៉ាងនេះ, ចូរថយត្រឡប់យ៉ាងនេះ, ចូរស្លៀកយ៉ាងនេះ, ចូរដណ្ដប់យ៉ាងនេះ ។ តែឃើញទោសហើយ នឹងសម្ដែងទោសដែលមានដោយន័យជាដើមថា ព្រះមហាថេរៈ

ទាំងឡាយ ក្នុងកាលមុន រមែងមិនដើរទៅខាងមុខ មិនថយក្រោយ មិនស្លៀក មិនដណ្តប់យ៉ាងនេះ, រមែងមិនទ្រទ្រង់សូម្បីសំពត់កាសាវៈ ដូច្នេះ មិនបន្តក់ភ្នែកយ៉ាងនេះ ដូច្នេះ គួរ ។

ចំណែកភិក្ខុទាំងឡាយ ទូន្មានប្រៀនប្រដៅភិក្ខុនី តាមសប្បាយថាសមណីចាស់នេះ រមែងស្លៀកយ៉ាងនេះ រមែងដណ្តប់យ៉ាងនេះ, កុំស្លៀកយ៉ាងនេះ កុំដណ្តប់យ៉ាងនេះ, កុំធ្វើកម្មជាប់ដោយគ្រាប់ល្ង និងជាប់ដោយស្លឹកឈើជាដើម គួរ ។

ពីរបទថា សមគ្គម្ហយ្យាតិ ភណន្តំ : ភិក្ខុនីពោលថា បពិត្រលោកម្ចាស់ យើងទាំងឡាយ ព្រមព្រៀងគ្នាហើយ បានដល់ចំពោះភិក្ខុនីសង្ឃដែលពោលថា ពួកខ្ញុំម្ចាស់ព្រមព្រៀងគ្នា លោកម្ចាស់ ។

ពាក្យថា អញ្ញំ ធម្មំ ភណតិ : ភិក្ខុពោលធម៌ដទៃវិញ បានដល់ (ប្រៀនប្រដៅ) សូត្រ ឬអភិធម្មយ៉ាងដទៃ, ក៏ពួកភិក្ខុនី រមែងប្រាថ្នាចំពោះឱវាទដោយពាក្យថា សមគ្គម្ហយ្យ ព្រោះហេតុនោះ ទើបជាទុក្កដដល់ភិក្ខុដែលពោលធម៌ដទៃ វៀរឱវាទចេញ ។

ពីរបទថា ឱវាទំ អនិយ្យាទេត្វា : ភិក្ខុមិនបានប្រគល់ឱវាទដល់ភិក្ខុនី បានដល់ មិនពោលថា "ម្នាលប្អូនស្រី នេះឱវាទ" ។

[២៩] កម្ម គឺ ភិក្ខុនោវាទកសម្មតិ (ការសម្មតិភិក្ខុដែលប្រៀនប្រដៅភិក្ខុនី) អ្នកសិក្សាគប្បីជ្រាបថា កម្ម ក្នុងពាក្យថា អធម្មកម្មេ : **កម្មមិនមែនជាធម៌** ជាដើម ។ បណ្តាកម្ម មានកម្មមិនជាធម៌ជាដើមនោះ ក្នុងកម្មមិនជាធម៌ជាបាចិត្តិយ ១៨ ដោយអំណាចនៃពួកប្រាំបួន ២ ពួក ។ ក្នុងកម្មជាធម៌មិនជាអាបត្តិ ក្នុងបទចុងបង្អស់នៃពួកប្រាំបួន ពួកទី ២ ។ ក្នុងបទដែលនៅសល់ជាទុក្កដ ១៧ ។

[៤១] ពីរបទថា ឧទ្ទេសំ ទេន្តោ : **ដល់ភិក្ខុដែលសម្តែងនូវឧទ្ទេស** បានដល់ អ្នកសម្តែងបាលីនៃគរុធម៌ ៨ ។

ពីរបទថា បរិបុច្ឆំ ទេន្តោ : **ដល់ភិក្ខុដែលសម្តែងនូវបរិបុច្ឆា** មានសេចក្តីថា អ្នកពោលអដ្ឋកថានៃបាលីគរុធម៌ដែលស្ទាត់ជំនាញនោះឯង ។

ច្រើនបទថា ឱសារេហិ អយ្យាតិ វុច្ចមានោ ឱសារេតិ : **ដល់ភិក្ខុដែលភិក្ខុនីពោលថា លោកម្ចាស់ ចូរសូធ្យទៅ ភិក្ខុក៏សូធ្យ** មានសេចក្តីថា ភិក្ខុដែលភិក្ខុនីទាំងឡាយពោលយ៉ាងនេះ រមែងសូត្របាលីគរុធម៌ ៨ ភិក្ខុដែលឱ្យឧទ្ទេសអ្នកឱ្យបរិបុច្ឆាយ៉ាងនេះ និងភិក្ខុដែលភិក្ខុនីពោលថា និមន្តសូត្រចុះ សូត្រគរុធម៌ ៨, មិនជាអាបត្តិបាចិត្តិយដល់ភិក្ខុនោះ មិនជាអាបត្តិទុក្កដដល់ភិក្ខុដែលពោលធម៌ដទៃ ។

ច្រើនបទថា បញ្ហំ បុច្ឆតិ បញ្ហំ បុដ្ឋោ កថេតិ : ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នា ហើយឆ្លើយដោះស្រាយ មានសេចក្ដីថា ភិក្ខុនីរមែងសួរបញ្ហាអាស្រ័យគរុធម៌ ឬអាស្រ័យធម៌មានខន្ធជាដើម ។ មិនជាអាបត្តិសូម្បីដល់ភិក្ខុដែលពោលពន្យល់បញ្ហានោះ ។

ពីរបទថា អញ្ញស្សត្ថាយ ភណន្តំ : ដល់ភិក្ខុដែលសម្ដែងធម៌ឱ្យអ្នកដទៃស្ដាប់ មានសេចក្ដីថា ភិក្ខុនីទាំងឡាយ ចូលទៅរកភិក្ខុដែលកំពុងសម្ដែងធម៌ក្នុងបរិស័ទ ៤ ហើយស្ដាប់ ។ សូម្បីក្នុងការពោល ដើម្បីប្រយោជន៍ដល់អ្នកដទៃនោះ មិនជាអាបត្តិដល់ភិក្ខុ ។

ពីរបទថា សិក្ខមានាយ សាមណេរិយា : ដល់ភិក្ខុប្រដៅធម៌ដល់សិក្ខមានាឬសាមណេរី គឺ មិនជាអាបត្តិសូម្បីដល់ភិក្ខុដែលសម្ដែងដល់សិក្ខមានា និងសាមណេរីទាំងនោះ ។ បទដែលនៅសល់ មានអត្ថងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបទសោធម្មសិក្ខាបទ កើតឡើងមកវាចា ១ វាចាចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឱវាទសិក្ខាបទវណ្ណនា ចប់

## ២. អត្ថុទ្ធតសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

### ពន្យល់គាថារបស់ព្រះចូឡបន្ថកត្ថេរ

[៤២] បទថា បរិយាយេន : ដោយវេនជាលំដាប់ ៗ គឺ តាមវារៈ សេចក្តីថា តាមលំដាប់ ។

បទថា អធិចេតសោ : ដែលមានអធិចិត្ត គឺ អ្នកមានអធិចិត្ត អធិប្បាយថា អ្នកប្រកបដោយចិត្តដែលក្រៃលែងជាងចិត្តទាំងអស់ គឺ អរហត្តផលចិត្ត ។

បទថា អប្បមជ្ជតោ : មិនប្រមាទ គឺ មិនមែនអ្នកប្រមាទ ។ មានពាក្យអធិប្បាយថា អ្នកប្រកបដោយការបំពេញកុសលធម៌ជាប់តគ្នាដោយសេចក្តីមិនប្រមាទ ។

បទថា មុនិនោ : ដល់មុនី មានសេចក្តីថា ញាណ ត្រាស់ហៅថា មោនៈ ព្រោះដឹងលោកទាំង ២ យ៉ាងនេះថា "បុគ្គលណា ដឹងប្រយោជន៍ទាំងពីរក្នុងលោក បុគ្គលនោះ ហៅថា មុនី ដោយហេតុនោះ"[១]

---

១. ខុ. ធម្ម. ធម្មដ្ឋវគ្គ. ៥២. ២៤/៧៧ ។

ឬព្រះខីណាស្រពត្រាស់ហៅឈ្មោះថា មុនី ព្រោះប្រកបដោយញាណនោះ ដល់មុនីនោះ ។

ពីរបទថា មោនេយ្យសុ សិក្ខតោ : សិក្សានៅក្នុងមគ្គនៃមោនធម៌ មានសេចក្តីថា អ្នកសិក្សានៅក្នុងមគ្គនៃញាណ ឈ្មោះមោនៈ ពោល គឺ អរហត្តមគ្គញាណ គឺ ក្នុងពោធិបក្ខិយធម៌ ៣៧ ឬក្នុងត្រៃសិក្ខា ។ ក៏ពាក្យនេះ ព្រះមានព្រះភាគត្រាស់ សំដៅយកបដិបទាជាចំណែកខាងដើម ។ ព្រោះដូច្នោះ អ្នកសិក្សាគប្បីឃើញសេចក្តីក្នុងពាក្យថា មុនិនោ មោនេយ្យសុសិក្ខតោ : ដល់មុនីដែលសិក្សានៅក្នុងមគ្គនៃមោនធម៌ នេះ យ៉ាងនេះថា ដល់មុនីអ្នកសិក្សានៅក្នុងធម៌ ជាចំណែកខាងដើមយ៉ាងនេះ សម្រេចភាពជាមុនីដោយការសិក្សានេះ ។

បាទព្រះគាថាថា សោកា ន ភវន្តិ តាទិនោ : សេចក្តីសោកទាំងឡាយ រមែងមិនមានដល់មុនី មានសេចក្តីថា សេចក្តីសោកទាំងឡាយ ព្រោះរឿងមានការព្រាត់ប្រាស់ចាកឥដ្ឋារម្មណ៍ជាដើមខាងក្នុង(ចិត្ត) រមែងមិនមានដល់ព្រះខីណាស្រវមុនីអ្នកមាំទាំ ។ ម្យ៉ាងទៀត ក្នុងបទថា តាទិនោ នេះ មានសេចក្តីសូម្បីយ៉ាងនេះថា សេចក្តីសោកទាំងឡាយ

រមែងមិនមានដល់មុនីអ្នកប្រកបដោយលក្ខណៈមាំទាំបែបនេះ ។

បទថា ឧបសន្តស្ស : មានចិត្តស្ងប់ បានដល់ អ្នកស្ងប់រម្ងាប់ ព្រោះស្ងប់កិលេសមានរាគៈជាដើមបាន ។

បទថា សទា សតីមតោ : តែងមានស្មារតីជានិច្ច បានដល់ អ្នកមិនវៀរចាកសតិ រហូតដល់អស់កាលជានិច្ច ព្រោះជាអ្នកដល់សេចក្តីបរិបូណ៌នៃសតិ ។

[៤៣] ពីរបទថា អាកាសេ អន្តលិក្ខេ : ឰដ៏អាកាស បានដល់ ក្នុងអាកាស ពោលគឺ វេហា, មិនមែនអាកាសបើកកសិណ មិនមែនអាកាសជាគ្រឿងកំណត់រូប ។

ពីរបទថា ចង្កមតិបិ តិដ្ឋតិបិ : ចង្រ្កមខ្លះ ឈរខ្លះ មានសេចក្តីថា ព្រះចូឡប័ន្ថកត្ថេរ បានស្តាប់ពាក្យរបស់ភិក្ខុនីទាំងនោះ គិតថា "ភិក្ខុនីទាំងនេះ មើលងាយយើងថា ព្រះថេរៈរូបនេះ ដឹងធម៌ត្រឹមតែប៉ុណ្ណោះឯង, ណ្ហើយចុះ ឥឡូវនេះ យើងនឹងសម្តែងអានុភាពរបស់ខ្លួនដល់ភិក្ខុនីទាំងនេះ" ទើបញុំាងសេចក្តីគោរពច្រើន ក្នុងធម៌ឱ្យកើតឡើងហើយ ចូលចតុត្ថឈាន មានអភិញ្ញាជាបាទ ចេញហើយបានសម្តែងឥទ្ធិ

បាដិហារ្យបែបនេះ គឺដើរចង្ក្រមក្នុងអាកាសវេហាខ្លះ ។ល។ បាត់ខ្លួនទៅក្នុងចន្លោះខ្លះ ។

បណ្តាបទទាំងនោះ បទថា អន្តរធាយតិបិ : បំបាត់ខ្លួនទៅខ្លះ មានសេចក្តីថា បាត់ខ្លួនទៅខ្លះ គឺ ទៅមិនប្រាកដឱ្យឃើញខ្លះ ។

ពាក្យថា តញ្ចោវ ឧទានំ ភណតិ អញ្ញញ្ច ពហុំ ពុទ្ធវចនំ : ហើយពោលឧទាននោះទៀតផង និងពុទ្ធវចនៈដទៃជាច្រើនផង មានសេចក្តីថា បានឮថា ព្រះថេរៈត្រូវឱ្យរៀនគាថានេះក្នុងសំណាក់របស់ព្រះថេរៈជាបងរបស់ខ្លួនថា ៖

បទុមំ យថា កោកនុទំ សុគន្ធំ បាតោ សិយា ផុល្លមវីតគន្ធំ
អង្គីរសំ បស្ស វិរោចមានំ តបន្តមាទិច្ចមិវន្តលិក្ខេ ។

ផ្កាឈូក(ក្រហមប្រាល) រីកក្នុងវេលាព្រឹក មានក្លិន
ក្រអូបមិនប្រាសចាកក្លិន យ៉ាងណា, អ្នកចូរមើលព្រះសម្មា
សម្ពុទ្ធ មានរស្មីផ្សាយចេញអំពីព្រះអង្គ កំពុងរុងរឿងដូច
ព្រះអាទិត្យដែលរុងរឿងក្នុងអាកាស យ៉ាងនោះឯង[១] ។

---

១. សំយុ. សគា. ២៩. ៣៦៦/២២២ ។

បានស្វាធ្យាយដល់ ៤ ខែ តែមិនអាចធ្វើឱ្យស្ទាត់ជំនាញបាន ។

គ្រានោះ ព្រះថេរៈ (ជាបង) ទើបបណ្តេញព្រះចូឡបន្ថកៈនោះចេញទៅអំពីវិហារ ដោយពោលថា លោកជាអ្នកអាភ័ព្វ ក្នុងព្រះសាសនានេះ ។ លោកបានឈរស្រែកយំនៅត្រង់ក្លោងទ្វារ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រួតមើលពុទ្ធវេនេយ្យសត្វ ទតឃើញលោកហើយ ទើបទ្រង់យាងទៅជិតលោក ដូចយាងទៅកាន់វិហារចារិកត្រាស់ថា "ចូឡបន្ថកៈ ហេតុដូចម្តេចបានជាអ្នកស្រែកយំ ?" លោកទើបក្រាបទូល

រឿងរ៉ាវនោះ ។ លំដាប់នោះ ទើបព្រះមានព្រះភាគទ្រង់ប្រទានកំណាត់សំពត់ដែលស្អាតដល់លោក ត្រាស់ថា "លោកចូរស្ទាបអង្អែលសំពត់នេះថា សំពត់ជូតធូលី" ។ លោកទទួលថា សាធុ ហើយអង្គុយក្នុងទីនៅរបស់ខ្លួន ស្ទាបអង្អែលទីបំផុតផ្នែកមួយនៃសំពត់នោះ ។ កន្លែងដែលត្រូវស្ទាបអង្អែលនោះ បានក្លាយជាពណ៌ខ្មៅ ។ លោកត្រឡប់បានសេចក្តីតក់ស្លុតថា សំពត់ឈ្មោះថា សូម្បីបរិសុទ្ធយ៉ាងនេះ អាស្រ័យអត្តភាពនេះ ត្រឡប់ក្លាយជាពណ៌ខ្មៅ ដូច្នេះ ហើយទើបប្រារព្ធវិបស្សនា ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា លោកប្រារព្ធសេចក្តីព្យាយាម បានទ្រង់ត្រាស់ឱភាសគាថា នេះថា អធិចេតសោ ជា

ដើម ។ ព្រះថេរៈសម្រេចព្រះអរហត្តផលក្នុងវេលាចប់គាថា ។ ព្រោះហេតុនោះ ទើបព្រះថេរៈគោរពស្រឡាញ់គាថានេះ តាមប្រក្រតីតែម្ដង ។ លោកពោលគាថានោះឯង ដើម្បីឱ្យជ្រាបសេចក្ដីគោរពស្រឡាញ់គាថានោះ ក៏នាំពុទ្ធវចនៈដទៃជាច្រើនមកពោលនៅក្នុងចន្លោះ ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ទើបពោលថា ពោលឧទាននោះឯង និងព្រះពុទ្ធវចនៈយ៉ាងដទៃជាច្រើន ។

[៤៥] ពីរបទថា ឯកតោ ឧបសម្បន្នាយ[១] : ភិក្ខុនីដែលឧបសម្បទាហើយក្នុងជំនុំសង្ឃមួយចំណែក បានដល់ ភិក្ខុនីអ្នកឧបសម្បទាក្នុងភិក្ខុនីសង្ឃ ។ តែជាបាចិត្តិយ ដល់ភិក្ខុដែលពោលទូន្មានភិក្ខុនីអ្នកឧបសម្បទាក្នុងភិក្ខុសង្ឃ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះងាយយល់ទាំងអស់ ។ និងសមុដ្ឋានសិក្ខាបទនេះ ។ មានសមុដ្ឋានដូចបទសោធម្មសិក្ខាបទនុ៎ះឯង ។

អដ្ឋមសិក្ខាបទវណ្ណនា ចប់

---

១. បិដកខ្មែរ. ឧបសម្បន្នំ ។

# ៣. ភិក្ខុនីឧបស្សយសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[៥០] ក្នុងពាក្យជាដើមថា អញ្ញត្រ សមយា ឱវទតិ អាបត្តិ បាចិត្តិយស្ស : ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យជាដើម បណ្ឌិតគប្បីជ្រាបថា ជាបាចិត្តិយដល់ភិក្ខុដែលពោលទូន្មានដោយគរុធម៌ ៨ ប៉ុណ្ណោះ, ពោលទូន្មានដោយធម៌ដទៃជាទុក្កដ ។

ពីរបទថា ឯកតោ ឧបសម្បន្នាយ[1] : ភិក្ខុនីដែលបានឧបសម្បទាក្នុងជំនុំសង្ឃតែមួយចំណែក បានដល់ ភិក្ខុនីដែលឧបសម្បទាក្នុងភិក្ខុនីសង្ឃ ។ តែជាបាចិត្តិយពិត ដល់ភិក្ខុដែលពោលទូន្មានភិក្ខុនីដែលឧបសម្បទាក្នុងភិក្ខុសង្ឃ ។ មួយទៀត ខាងមុខពីនេះទៅ ក្នុងទីគ្រប់កន្លែងដែលលោកពោលពាក្យថា ឯកតោ ឧបសម្បន្នាយ ទុកបណ្ឌិតគប្បីឃើញសេចក្ដីយ៉ាងនេះដូចគ្នា ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងមកកាយវាចា ១ វាចាចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

---

១. បិដកខ្មែរ. ឧបសម្បន្នំ ។

# សេចក្តីបន្ថែម

ក៏ឯក្នុងសិក្ខាបទទី ៣ នេះ លោកពោលបកិណ្ណកៈទុកក្នុងមហាបច្ចរី ដូចតទៅនេះ ៖

បើថា ភិក្ខុដែលមិនបានទទួលសម្មតិ កាលព្រះអាទិត្យអស្តង្គតហើយ ចូលទៅកាន់សំណាក់ភិក្ខុនី ពោលទូន្មានដោយគរុធម៌ ៨ ជាបាចិត្តិយ៣ ។

កាលទូន្មានដោយធម៌ដទៃ ជាទុក្កដ ២, ជាបាចិត្តិយ ១ ។ គឺយ៉ាងណា ? គឺ ថា ទុក្កដ មានការមិនបានទទួលសម្មតិជាមូល ១, ទុក្កដ មានការទៅកាន់សំណាក់ភិក្ខុនីហើយ ពោលទូន្មានដោយធម៌ដទៃជាមូល ១, បាចិត្តិយ មានការពោលទូន្មានកាលព្រះអាទិត្យអស្តង្គតហើយជាមូល១ ។

ភិក្ខុដែលបានទទួលសម្មតិហើយ កាលព្រះអាទិត្យអស្តង្គតហើយ ទៅក្នុងសំណាក់ភិក្ខុនីនោះ ៗ ពោលទូន្មានដោយគរុធម៌ ៨ ជាអនាបត្តិ ១ ជាបាចិត្តិយ ២ ។ តើយ៉ាងណា ? គឺ ថា ជាអនាបត្តិ ព្រោះជាអ្នកបានទទួលសម្មតិ, ជាបាចិត្តិយ ២ គឺ ជាបាចិត្តិយ មានការពោលទូន្មានកាលព្រះអាទិត្យអស្តង្គតហើយជាមូល ១, បាចិត្តិយ មានការទៅ

ពោលទូន្មានដោយគរុធម៌ ៨ ជាមូល ១ ។

ភិក្ខុដែលពោលទូន្មានដោយធម៌ដទៃនុ៎ះឯង ជាអនាបត្តិ១ ជាទុក្កដ១ ជាបាចិត្តិយ១ ។ គឺ យ៉ាងណា ? គឺថា ជាអនាបត្តិ ព្រោះបានទទួលសម្មតិ, ជាទុក្កដមានការទៅពោលទូន្មានដោយធម៌ដទៃជាមូល១, ជាបាចិត្តិយ មានការពោលទូន្មានកាលព្រះអាទិត្យអស្តង្គតហើយជាមូល១ ។

តែសម្រាប់ភិក្ខុដែលបានទទួលសន្មតក្តី មិនបានទទួលសន្មតក្តី ទៅពោលទូន្មានក្នុងពេលថ្ងៃ បណ្ឌិតគប្បីនាំចេញនូវអាបត្តិបាចិត្តិយ ដែលមានការពោលទូន្មានក្នុងវេលាយប់ជាមូល ១ ហើយជ្រាបអាបត្តិ និងអនាបត្តិ ដែលនៅសល់ដូច្នេះឯង ។

សេចក្តីបន្ថែម ចប់

ភិក្ខុនីឧបស្សយសិក្ខាបទវណ្ណនា ចប់

# ៤. អាមិសកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

[៥២] បទថា ន ពហុកតា : **មិនសូវយកចិត្តទុកដាក់** គឺ មិនធ្វើសេចក្តីតាំងចិត្ត( ទូន្មានពិត ) ។ អធិប្បាយថា មិនធ្វើសេចក្តីគោរពច្រើនក្នុងធម៌ពោលទូន្មាន ។

[៥៤] អ្នកសិក្សាគប្បីជ្រាបអត្ថនៃបទទាំងឡាយថា ភិក្ខុនោវាទកំ អវណ្ណំ កត្តុកាមោ : ប្រាថ្នាដើម្បីនឹងធ្វើនូវពាក្យដំនៀល អ្នកប្រដៅភិក្ខុនី ជាដើម ដោយន័យដូចដែលពោលហើយក្នុងឧជ្ឈាបនកសិក្ខាបទនុ៎ះឯង ។

[៥៦] ភិក្ខុដែលបានទទួលសន្មត ឬសង្ឃប្រគល់ភារៈឱ្យទុក គប្បីជ្រាបថា ឈ្មោះថា ភិក្ខុមិនបានទទួលសន្មត ក្នុងពាក្យថា ឧបសម្បន្នំ សង្ឃេន អសម្មតំ : **ចំពោះឧបសម្បន្នដែលសង្ឃមិនបានសន្មត** នេះ ។

[៥៧] ចំណែកក្នុងពាក្យថា អនុបសម្បន្នំ សង្ឃេន សម្មតំ វា អសម្មតំ វា : **ចំពោះអនុបសម្បន្នបុគ្គលដែលសង្ឃសន្មតក្តី មិនបាន**

សន្ទុតក្តី នេះ អនុបសម្បន្នដែលបានទទួលសន្ទុតកាលនៅជាភិក្ខុ ហើយត្រឡប់មកតាំងនៅក្នុងភូមិនៃសាមណេរ គប្បីជ្រាបថា អនុបសម្បន្នដែលបានទទួលសន្ទុត ។ សាមណេរពហុស្សុតដែល ភិក្ខុអ្នកបានទទួលសន្ទុត ឬសង្ឃប្រគល់នាទីទុកគប្បីជ្រាបថា អ្នកមិនបានទទួលសន្ទុត ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ព្រោះមានន័យដូចពោលហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងមកកាយនិងចិត្ត ១ មកវាចាចិត្ត ១ មកកាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

អាមិសសិក្ខាបទវណ្ណនា ចប់

# ៥. ចីវរទានសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[៦០] បទថា វិសិខាយ : តាមមកឬច្រក គឺ ក្នុងច្រកមក ។

ពីរបទថា បិណ្ឌាយ ចរតិ : ត្រាច់ទៅបិណ្ឌបាត មានសេចក្ដីថា រមែងត្រាច់ទៅរឿយ ៗ ដោយអំណាចនៃការត្រាច់ទៅជាប្រចាំ ។

បទថា សន្ទិដ្ឋា : ស្គាល់គ្នា គឺ បានជាសម្លាញ់ធ្លាប់ឃើញគ្នា ។

បទដែលនៅសល់ក្នុងសិក្ខាបទនេះ ដោយវិនិច្ឆ័យនូវបទមានអត្ថងាយយល់ គប្បីជ្រាបដោយន័យដូចពោលហើយក្នុងចីវរបដិគ្គហណសិក្ខាបទនុ៎ះឯង ព្រមទាំងសមុដ្ឋានជាដើម ។ ពិតមែន ក្នុងចីវរបដិគ្គហណសិក្ខាបទនោះ ភិក្ខុជាអ្នកទទួល, ក្នុងសិក្ខាបទនេះ ភិក្ខុនីជាអ្នកទទួល នេះជាសេចក្ដីប្លែកគ្នា ។ ពាក្យដែលនៅសល់ដូចគ្នាដូច្នេះឯង ។

ចីវរទានសិក្ខាបទវណ្ណនា ចប់

# ៦. ចីវរសិព្វនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

## ពន្យល់រឿងដេរចីវរឱ្យភិក្ខុនីអ្នកមិនមែនជាញាតិ

[៦៥] ពាក្យថា ឧទាយី បានដល់ ព្រះលោឡុទាយី ។

បទថា បដ្ឋោ : ប្រសប់ បានដល់ អ្នកមានសេចក្ដីអាច ។ មានពាក្យអធិប្បាយថា ជាអ្នកយល់ថា ទីងអាច

ពីរបទថា អញ្ញតរា ភិក្ខុនី : មានភិក្ខុនីមួយរូប បានដល់ ភិក្ខុនីអ្នកជាករិយាចាស់របស់ព្រះឧទាយីនោះឯង ។

បទថា បដិភាណចិត្តំ : រូបគំនូរ បានដល់ មានសេចក្ដីស្រស់ល្អដែលធ្វើដោយបដិភាណរបស់ខ្លួន ។ បានឮថា ព្រះលោឡុទាយីនោះ ជ្រលក់ចីវរហើយ បានធ្វើរូបស្រីនិងប្រុសកំពុងធ្វើសណ្ឋវៈគ្នា ដោយពណ៌ផ្សេង ៗ ក្នុងកណ្ដាលនៃចីវរនោះ ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ទើបបានពោលថា មជ្ឈេ បដិភាណចិត្តំ វុដ្ឋាបេត្វា : រូបធ្វើរូបគំនូរត្រង់កណ្ដាលចីវរ ជាដើម ។

បទថា យថាសំហដំ ទាំងផ្នត់ គឺ តាមដែលបត់ទុកហើយនុះ

ឯង ៗ

បទថា ចីវរំ : ចីវរ បានដល់ ចីវរដែលភិក្ខុអាចស្លៀក ឬ ដណ្ដប់បាន ៗ ពិតមែន ក្នុងមហាបច្ចរីជាដើម លោកក៏បានពោលទុកយ៉ាងនេះ ៗ

[៦៦] ក្នុងពាក្យថា សយំ សិព្វេតិ : ភិក្ខុដេរដោយខ្លួនឯងនេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុធ្វើក្ដី កាត់ក្ដី ដោយតាំងចិត្តថា យើងនឹងដេរ ជាទុក្កដ ៗ តែជាបាចិត្តិយព្រោះការដេរប៉ាក់មួយ ៗ គ្រប់ ៗ គ្រាដែលដេរប៉ាក់ដល់ភិក្ខុដែលដេរហើយ ព្រោះព្រះបាលីថា ត្រូវអាបត្តិបាចិត្តិយរាល់ ៗ មកមួយ ៗ ដូច្នេះ ៗ តែបើថា ភិក្ខុមិនទាំមួយចេញអស់ទាំងក្បាល ចាក់ម្ជុរទៅសូម្បីច្រើនរយដង ដើម្បីដានអំបោះនោះហើយទើបនាំចេញ ជាបាចិត្តិយតែមួយ ៗ

ពាក្យថា សកឹ អាណត្តោ : ភិក្ខុបង្គាប់តែម្ដង បានដល់ ភិក្ខុពោលម្ដងថា ចូរដេរចីវរ ៗ

ពាក្យថា ពហុកំបិ សិព្វតិ : អ្នកទទួលបង្គាប់ដេរច្រើនដង

មានសេចក្ដីថា ប្រសិនបើថា អ្នកទទួលបង្គាប់ឱ្យសុចិកម្មទាំងអស់សម្រេចអស់ហើយ ឱ្យចីវរសម្រេច ក៏ជាបាចិត្តិយត្រឹមតែមួយ ។ តែបើលោកបានទទួលពាក្យបង្គាប់ថា កម្មដែលនឹងគប្បីធ្វើក្នុងចីវរនេះ ជាភារៈរបស់លោក ដូច្នេះ ហើយទើបធ្វើ ជាបាចិត្តិយដល់អ្នកបង្គាប់គ្រប់មកម្ដង ។ ជាបាចិត្តិយសូម្បីច្រើន ព្រោះពាក្យនិយាយតែមួយដល់ភិក្ខុដែលបង្គាប់ ។ ចំណែកក្នុងការបង្គាប់រឿយ ៗ មិនមានពាក្យដែលនឹងគប្បីពោលឡើយ ។

បើកាលអាចារ្យនិងឧបជ្ឈាយ៍ កំពុងដេរចីវរ ដើម្បីពួកភិក្ខុនីជាញាតិរបស់ខ្លួន, ចំណែកនិស្សិតពួកណារបស់លោកទាំងនោះ ដេរដោយតាំងចិត្តថា ពួកយើងនឹងធ្វើអាចរិយវត្តឧបជ្ឈាយ៍វត្ត ឬកឋិនវត្ត, ជាអាបត្តិច្រើនសូម្បីដល់និស្សិតទាំងនោះតាមចំនួនមកម្ដង ។ អាចារ្យនិងឧបជ្ឈាយ៍ប្រើឱ្យពួកអន្តេវាសិកដេរ ( ចីវរ ) ដើម្បីពួកភិក្ខុនីអ្នកជាញាតិរបស់ខ្លួន, ជាទុក្កដដល់អាចារ្យនិងឧបជ្ឈាយ៍ ។ ជាបាចិត្តិយដល់ពួកអន្តេវាសិក ។ ពួកអន្តេវាសិកនិមន្តឱ្យអាចារ្យ និងឧបជ្ឈាយ៍ ជួយដេរ ( ចីវរ ) ដើម្បីពួកភិក្ខុនីជាញាតិរបស់ខ្លួន, សូម្បីក្នុងការដែលអន្តេវាសិកនិមន្តឱ្យអាចារ្យនិងឧបជ្ឈាយ៍ឱ្យជួយដេរនោះ ក៏ន័យនេះឯង ។ ចីវរជា

របស់ភិក្ខុនីអ្នកជាញាតិ ទាំងចំណែកអន្តេវាសិក ទាំងចំណែកអាចារ្យនិងឧបជ្ឈាយ៍ ។ តែអាចារ្យនិងឧបជ្ឈាយ៍ លួងលោមពួកអន្តេវាសិកឱ្យដេរ (ចីវរ), ជាទុក្កដសូម្បីដល់ទាំង ២ ចំណែក ។ ព្រោះហេតុអ្វី ? ព្រោះចីវរពួកអន្តេវាសិកដេរដោយសេចក្តីសម្គាល់ថា មិនមែនញាតិ (និង) ព្រោះអាចារ្យនិងឧបជ្ឈាយ៍ក្រៅនេះ ដឹកនាំក្នុងវត្ថុដែលមិនគួរ ។ ព្រោះដូច្នោះ ទើបគួរប្រាប់ថា នេះជាចីវររបស់មាតាអ្នក និងនេះជាចីវររបស់ប្អូនស្រី ហើយឱ្យពួកលោកជួយដេរ ។

[៦៨] ពីរបទថា អញ្ញំ បរិក្ខារំ : នូវបរិក្ខារដទៃ បានដល់បរិក្ខារយ៉ាងណាមួយ មានថង់យាម ស្បែកជើងជាដើម ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

ចីវរសិព្វនសិក្ខាបទវណ្ណនា ចប់

# ៧. សំវិធានសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[៧០] ពាក្យថា បច្ឆា គច្ឆន្តីនំ ចោរា អច្ឆិន្ទឹសុ : ដើរទៅជាខាងក្រោយ ចោរទាំងឡាយក៏ដណ្ដើមយក (បាត្រនិងចីវរ) មានសេចក្ដីថា កាលពួកភិក្ខុនីទៅក្នុងកាលជាខាងក្រោយ ពួកចោរបានដណ្ដើមយកបាត្រនិងចីវរទៅ ។

បទថា ទូសេសុំ : ប្រទូស្ត បានដល់ ពួកចោរប្រទូស្តពួកភិក្ខុនីទាំងនោះ ។ អធិប្បាយថា ឱ្យដល់សេចក្ដីវិនាសសីល ។

បទថា សំវិធាយ : បបួល គឺ បបួលគ្នា, អធិប្បាយថា ធ្វើការណាត់ចាំគ្នាក្នុងវេលានឹងទៅ ។

## អធិប្បាយស្រុកចម្ងាយមាន់ហើរដល់ជាដើម

[៧១] មាន់ចេញចាកស្រុកណា ហើយដើរទៅកាន់ស្រុកដទៃ, ស្រុកនេះលោកហៅថា ចម្ងាយមាន់ទៅដល់ ក្នុងបទថា កុក្កុដសម្បាតេ : ចម្ងាយល្មមមាន់ហើរទៅដល់ នេះ ។ ក្នុងបទនោះ មានអត្ថដូចតទៅនេះ ៖

មាន់ទាំងឡាយ រមែងត្រាច់ទៅដល់ទីស្រុកនេះ; ហេតុនោះ ស្រុក

នេះ ទើបឈ្មោះថា ជាទីទៅដល់ ។ ពួកណាទៅដល់ ? ពួកមាន់ ។ ការត្រោច់ទៅដល់របស់ពួកមាន់ ឈ្មោះថា កុក្កុដសម្បាទៈ ។ ម្យ៉ាងទៀត ការទៅដល់ ឈ្មោះថា សម្បាទៈ ។ ការទៅដល់របស់ពួកមាន់មាននៅត្រង់ស្រុកនេះ; ព្រោះហេតុនោះ ស្រុកនេះទើបឈ្មោះថា កុក្កុដសម្បាទៈ ។ បាលីថា កុក្កុដសម្បាតេ ក៏មាន ។ មាន់ហើរឡើងពីដំបូលផ្ទះនៃស្រុកណា ហើយទៅធ្លាក់ចុះលើដំបូលផ្ទះនៃស្រុកដទៃ, ស្រុកនេះលោកហៅថា ចម្ងាយមាន់ហើរដល់ ក្នុងបាលីថា កុក្កុដសម្បាតេនោះ ។ ចំណែកសេចក្តីនៃពាក្យក្នុងបទនេះ បណ្ឌិតគប្បីជ្រាបដោយរាប់ដូចពោលហើយនុ៎ះឯង ។

ក៏ស្រុកសូម្បីមានប្រការដូចពោលហើយ ២ យ៉ាងនេះ ជិតកៀកគ្នាពេក រមែងមិនបានឧបចារ ។ ក្នុងអដ្ឋកថា លោកពោលទុកថា ក៏សំឡេងមាន់ដែលរងាវនៅវេលាជិតភ្លឺក្នុងស្រុកណា បានឮទៅដល់ស្រុកដែលបន្ទាប់ទៅ, ត្រូវបាចិត្តិយគ្រប់ ៗ ចន្លោះស្រុក ក្នុងរដ្ឋដែលច្រើនកុះករដោយពួកស្រុកដូច្នោះ ។ លោកបានពោលពាក្យនោះ ទុកហើយ ក៏ពិតមែន, តែក៏នៅតែជាអាបត្តិដូចគ្នា ដល់ភិក្ខុដែលឈានចុះកាន់ឧបចារនៃស្រុក ប្រសិនបើថា មានចម្ងាយឆ្ងាយពីគ្នាប្រមាណ ១ ហត្ថក្តាប់ដែល

ពួកអ្នកស្រុកវៀរទុក ព្រោះបាលីថា ត្រូវអាបត្តិបាចិត្តិយ គ្រប់ចន្លោះស្រុក ដូច្នេះ ។ ពាក្យនោះមិនសមដោយព្រះបាលី ។ បើថា ស្រុកសូម្បីបែបនេះ ដោយវោហារដែលបានហើយយ៉ាងនោះ ព្រោះមិនជិតកៀកគ្នា រមែងបានវោហារថា ចម្ងាយមាន់ហើរដល់ ដូច្នេះក្តី, ថាចម្ងាយមាន់ហើរមិនដល់ ដូច្នេះក្តី ព្រោះជាស្រុកជិតកៀកគ្នា; ព្រោះដូច្នោះ ទើបមិនសមគ្នានឹងបាលី ដូច្នេះឯង ។ ចំណែកក្នុងស្រុកក្រៅនេះការដើរហួសឧបចារស្រុកនេះទៅ និងឈានចុះកាន់ឧបចារៈស្រុកដទៃប៉ុណ្ណោះមិនប្រាកដ ។ ព្រោះដូច្នោះ ដែលលើកអាបត្តិឡើងពិន័យ ទើបមិនប្រាកដដូចគ្នា ។

## ការបបួលគ្នាធ្វើដំណើររួមគ្នា

វិនិច្ឆ័យអាបត្តិក្នុងពាក្យថា គាមេ គាមន្តរេ[១] អាបត្តិ បាចិត្តិយស្ស : ក្នុងទីជាចន្លោះនៃស្រុក ក្នុងស្រុក ត្រូវអាបត្តិបាចិត្តិយ នោះ ដូចតទៅនេះ ៖

ពិតមែន ក្នុងវេលាបបួលគ្នា បើថា ភិក្ខុនិងភិក្ខុនីសូម្បីទាំង ២ ឈរបបួលគ្នា ក្នុងសំណាក់ភិក្ខុនីក្តី ក្នុងចន្លោះវត្តក្តី ក្នុងរោងឆាន់ក្តី ក្នុង

១. ឱ. ម. គាមន្តរេ គាមន្តរេ ។

ទីនៅនៃតិរ្ថិយក្តី មិនជាអាបត្តិ ។ បានឮថា ភូមិនេះ ជាកប្បិយភូមិ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យទាំងឡាយមិនពិន័យអាបត្តិទុក្កដ ព្រោះការបបួលជាបច្ច័យ ក្នុងលំនៅនៃភិក្ខុនីជាដើមនេះ ជាបាចិត្តិយ តាមវត្ថុតែម្តង ដល់ភិក្ខុដែលដើរទៅ ។

តែបើថា ភិក្ខុនីនិងភិក្ខុនីបបួលគ្នា ខាងក្នុងស្រុក ទីត្រង់ជួល់ជិតទ្វារលំនៅរបស់ភិក្ខុនីក្តី ក្នុងទីដទៃ មានមកបែកជា ៤ បែកជា ៣ និងរោងជំរឺជាដើមក្តី, ភិក្ខុត្រូវអាបត្តិទុក្កដ ។ គ្រាបបួលគ្នាយ៉ាងនេះហើយ ទើបចេញចាកស្រុកទៅ ។ មិនជាអាបត្តិព្រោះការចេញចាកស្រុក ។ តែព្រោះការឈានចុះកាន់ឧបចារនៃស្រុកដែលបន្ទាប់ទៅ ជាបាចិត្តិយដល់ភិក្ខុ ។ លោកពោលទុកក្នុងមហាបច្ចរីថា សូម្បីក្នុងការឈានចុះកាន់ឧបចារនោះ ជាទុក្កដក្នុងជំហានទី ១ ជាបាចិត្តិយក្នុងជំហានទី ២ ។ ក៏ភិក្ខុចេញចាកស្រុកហើយ តែមិនទាន់ឈានចុះកាន់ឧបចារនៃស្រុកបន្ទាប់ទៅត្រឹមណា, សូម្បីកាលបបួលគ្នាក្នុងចន្លោះនេះ ក៏ជាទុក្កដដល់ភិក្ខុត្រឹមនោះ ។ ក្នុងការឈានចុះកាន់ឧបចារៈនៃស្រុកបន្ទាប់ទៅ ជាអាបត្តិដោយន័យមុនដូចគ្នា ។ បើភិក្ខុនិងភិក្ខុនី មានសេចក្តីប្រាថ្នានឹងទៅកាន់ស្រុកឆ្ងាយច្រើន, ត្រូវអាបត្តិគ្រប់ជំហាន ដែលឈានចុះ (កាន់

ឧបចារៈនៃស្រុក )ដោយរាប់ឧបចារៈនៃស្រុក ។

លោកពោលទុកក្នុងមហាបច្ចរីថា តែមិនត្រូវអាបត្តិព្រោះការដើរហួសស្រុកនោះ ៗ ទៅ ។ តែបើភិក្ខុនីគិតថា "អាត្មាអញនឹងទៅកាន់ស្រុកឈ្មោះឯណោះ" ហើយដើរចេញចាកលំនៅទៅ, ចំណែកភិក្ខុក៏គិតថា "អាត្មាអញនឹងទៅកាន់ស្រុកឯណោះ" ហើយដើរចេញចាកវិហារប្រាថ្នាទៅកាន់ស្រុកនោះឯង, បើភិក្ខុនិងភិក្ខុនីទាំង ២ ទៅជួបគ្នាត្រង់ទ្វារស្រុកហើយ សួរគ្នាថា "នាងនឹងទៅណា ?" "នឹងទៅស្រុកឯណោះ", លោកម្ចាស់នឹងទៅណា ? ពោលថា "សូម្បីយើងក៏នឹងទៅក្នុងស្រុកនោះដែរ" ទើបបបួលគ្នាថា "មកចុះលោក ពួកយើងនឹងទៅជាមួយគ្នាឥឡូវនេះ" ហើយដើរទៅ, មិនជាអាបត្តិ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ភិក្ខុនិងភិក្ខុនីនាំគ្នាចេញទៅដោយដាក់ចិត្តថា "យើងនឹងទៅតាំងពីដំបូងនុ៎ះឯង" ។ ពាក្យដែលពោលក្នុងមហាបច្ចរីនោះ មិនសមដោយបាលី និងមិនសមដោយអដ្ឋកថាដ៏សេស ។

ពីរបទថា អទ្ធយោជនេ អទ្ធយោជនេ : គប់ ៗកន្លះយោជន៍ មានសេចក្តីថា ភិក្ខុដើរហួសកន្លះយោជន៍មួយ ៗទៅក្នុងខណៈដែលគិតថា "ឥឡូវនេះ យើងនឹងដើរហួសទៅ" ជាទុក្កដក្នុងជំហានទី ១ ជា

បាចិត្តិយក្នុងជំហានទី ២ ។ ពិតមែន ន័យនេះ ជាអាបត្តិក្នុងខណៈដែលដើរហួសទៅ មិនជាអាបត្តិក្នុងខណៈឈានចុះ ។

[៧២] ពីរបទថា ភិក្ខុ សំវិធហាតិ : ភិក្ខុបបួល មានសេចក្ដីថា ភិក្ខុឃើញភិក្ខុនីទៀបទ្វារក្រែងក្ដី ត្រង់ផ្លូវក្ដី ពោលថា "នាងធ្លាប់ទៅកាន់ស្រុកឈ្មោះឯណោះទេ ?" ភិក្ខុនីឆ្លើយថា "ខ្ញុំព្រះករុណាមិនធ្លាប់ទៅទេ លោកម្ចាស់" ភិក្ខុពោលថា "មកចុះ យើងនឹងទៅជាមួយគ្នា" ឬថា "ខំឥតនឹងទៅស្រុកនេះ សូម្បីនាងក៏គប្បីមកជាមួយដែរ" ដូច្នេះក្ដី ។

[៧៣] ពីរបទថា ភិក្ខុនី សំវិធហាតិ : ដល់ភិក្ខុដែលភិក្ខុនីបបួល មានសេចក្ដីថា ភិក្ខុនីឃើញភិក្ខុចេញអំពីស្រុក ដើម្បីថ្វាយបង្គំព្រះចេតិយក្នុងស្រុកដទៃ ទើបពោលថា "លោកម្ចាស់ និមន្តទៅណា ?" ភិក្ខុឆ្លើយថា "ខំឥតព្រះករុណាទៅកាន់ស្រុកឯណោះ ដើម្បីថ្វាយបង្គំព្រះចេតិយ" ដូច្នេះ ។ ភិក្ខុនីទុំះឯង បបួលសូម្បីយ៉ាងនេះថា "លោកម្ចាស់ សូម្បីខ្ញុំព្រះករុណាក៏នឹងទៅជាមួយដែរ", ភិក្ខុមិនបានបបួល ។

វិនិច្ឆ័យក្នុងពាក្យថា វិសង្កេតេន : ដោយខុសសង្កេត នេះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុនិងភិក្ខុនីពោលថា យើងនឹងទៅជាមួយគ្នាក្នុងពេលមុនឆាន់

ហើយទៅខាងក្រោយឆាន់, ពោលថា "យើងនឹងមកជាមួយគ្នាក្នុងថ្ងៃនេះ" ហើយចេញទៅថ្ងៃស្អែក, យ៉ាងនេះ មិនជាអាបត្តិ ព្រោះខុសណាត់វេលានោះឯង ។ តែសូម្បីកាលមានការខុសកំណត់ទ្វារ ឬខុសកំណត់មក ជាអាបត្តិពិត ។

បទថា អាបទាសុ : ដល់ភិក្ខុដែលទៅ(ជាមួយភិក្ខុនី)ដោយមានអន្តរាយ មានសេចក្តីថា ព្រោះខាងក្នុងរដ្ឋត្រូវចោរប្លន់ អ្នកជនបទទាំងឡាយនាំគ្នាធ្វើដំណើរជាក្រុមច្រើនជើងឬជាក្រុមរទេះកៀសខ្លួនទៅ, មិនជាអាបត្តិ ក្នុងអន្តរាយយ៉ាងនេះ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន ៤ គឺ កាយ ១ កាយវាចា ១ កាយចិត្ត ១ កាយវាចានឹងចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សំវិធានសិក្ខាបទវណ្ណនា ចប់ ។

# ៨. នាវាភិរូហនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

## ការបបួលគ្នាដោយសារទូកជាមួយគ្នា

[៧៤] បទថា សំវិធាយ **:** បបួល បានដល់ បបួលគ្នាប្រាថ្នាការលេងជាប្រធាន ដោយអំណាចមិត្តសណ្ឋវៈដែលជាសេចក្ដីត្រេកអររបស់សត្វលោក ។

[៧៥-៦] បទថា ឧទ្ធង្គាមិនឹ **:** ទៅប្រាសទឹក គឺ ធ្វើដំណើរតាមទូកបញ្ច្រាសក្រសែរបស់ទន្លេឡើងទៅ ។ ក៏ព្រោះអ្នកដែលលេងកីឡាមកទូកដែលត្រាច់ឡើងបញ្ច្រាសទឹក ដោយបែរបញ្ច្រាសឡើងទៅ លោកហៅថា ដោយសារទូកឡើងទឹកទៅ ។ ព្រោះហេតុនោះ ក្នុងបទភាជនៈនៃបទថា ឧទ្ធង្គាមិនឹ នោះ ដើម្បីសម្ដែងចំពោះអត្ថប៉ុណ្ណោះ ទើបត្រាស់ថា ឧជ្ជវនិកាយ **:** នាវាទៅទិវាងលើទឹក ដូច្នេះ ។

បទថា អធោគាមិនឹ **:** ទៅបណ្ដោយទឹក គឺ ទៅតាមក្រសែទឹកចុះទៅ ។ ក៏ព្រោះអ្នកដែលលេងកីឡាមកទូកដែលត្រាច់ចុះតាមទឹកដោយត្រាច់ចុះទៅមកក្រោម លោកហៅថា ដោយសារទូកចុះទៅក្រោមខ្សែទឹក ។ ព្រោះហេតុនោះ ក្នុងបទភាជនៈសូម្បីនៃបទថា អធោគាមិនឹ

នោះដើម្បីសម្តែងតែអត្ថដូចគ្នា ទើបត្រាស់ថា ឧជវនិកាយ : **នាវាទៅទីខាងក្រោមទឹក** ដូច្នេះ ។ ក្នុងទូកនោះជនទាំងឡាយ រមែងថែវទូកទៅខាងលើ ឬទៅខាងក្រោមដើម្បីឱ្យដល់កំពង់ចតទូក, មិនជាអាបត្តិក្នុងការលេងទូកនោះទៅត្រង់នោះ ។

ពាក្យថា តិរិយន្តរណាយ : **ការឆ្លងទទឹង** នេះ ជាបញ្ចមីវិភត្តិចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។

ក្នុងពាក្យថា គាមន្តរេ គាមន្តរេ : **គ្រប់ ៗចន្លោះស្រុក** នេះ មានវិនិច្ឆ័យដូច្នេះ ៖

ស្ទឹងណាមានត្រើយម្ខាងតជាប់គ្នាដោយពួកស្រុក កំណត់ចម្ងាយមាន់ហើរធ្លាក់, ត្រើយខាងមុខជាព្រៃមិនមានស្រុក, ក្នុងវេលាទៅមកមាត់ច្រាំងដែលមានពួកស្រុកនៃស្ទឹងនោះ ជាបាចិត្តិយច្រើនដោយចំនួនចន្លោះស្រុក ។ ក្នុងវេលាទៅមកខាងមាត់ច្រាំងដែលមិនមានស្រុក ជាបាចិត្តិយច្រើន ដោយករាប់កន្លះយោជន៍ ៗ ។ តែទន្លេណាមានទទឹង ១ យោជន៍ សូម្បីក្នុងការទៅដោយក្នុងកណ្តាលនៃទន្លេនោះ ក៏គប្បីជ្រាបបាចិត្តិយច្រើន ដោយករាប់កន្លះយោជន៍ ៗ ។

[៧៨] ក្នុងពាក្យថា អនាបត្តិ តិរិយន្តរណាយ : **អាបត្តិមិនមានដល់ភិក្ខុដែលឆ្លងទទឹង** នេះ មានវិនិច្ឆ័យដូច្នេះ ៖

មិនមែនក្នុងស្ទឹងតែម្យ៉ាងទេ, សូម្បីភិក្ខុណាចេញចាកកំពង់ឈ្មោះមហាតិត្ថ ទៅកាន់កំពង់ឈ្មោះតាម្ពលិតតិត្ថ ឈ្មោះសុវណ្ណភូមិត្ថ មិនជាអាបត្តិសូម្បីដល់ភិក្ខុនោះ ។ ពិតមែន ក្នុងអដ្ឋកថាទាំងអស់ លោកវិចារណ៍អាបត្តិទុកក្នុងស្ទឹងប៉ុណ្ណោះ មិនមែនក្នុងសមុទ្រ ។

ក្នុងពាក្យថា វិសង្កេតេន **:** ដោយខុសសង្កេត សូម្បីនេះ ក៏មិនជាអាបត្តិ ព្រោះខុសណាត់វេលាប៉ុណ្ណោះ ។ តែកាលទៅដោយខុសណាត់កំពង់ទូក ដោយខុសណាត់ទូកជាអាបត្តិតែម្តង ។ ពាក្យដែលនៅសល់ព្រមដោយសមុដ្ឋានជាដើម ជាដូចនឹងបឋមសិក្ខាបទទាំងនោះឯង ។

នាវាភិរូហនសិក្ខាបទវណ្ណនា ចប់

# ៩. បរិបាចនសិក្ខាបទវណ្ណនា

*សេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖*

## បិណ្ឌបាតដែលភិក្ខុនីណែនាំឱ្យប្រគេន

[៧៩] ពាក្យថា មហានាគេ តិដ្ឋមានេ : **កាលព្រះមហានាគដ៏ប្រសើរនៅមានទេតើ** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ អធិប្បាយថា កាលព្រះមហាថេរៈទាំងឡាយ នៅមានប្រាកដ ។ ម្យ៉ាងទៀត អ្នកសិក្សាគប្បីឃើញបាលីដ៏សេសក្នុងពាក្យនេះ ដូច្នេះថា ឃើញព្រះមហាថេរៈទាំងឡាយ នៅមានប្រាកដ ។ សេចក្ដីពិត កាលពោលនូវសេចក្ដីក្រោយនេះ សេចក្ដីមិនទាន់សមគួរ ។

ពាក្យដែលមិនទាន់ដល់ទីបំផុត ដល់ពាក់កណ្ដាលនៃការចាប់ផ្ដើមនិងទីបំផុត ឈ្មោះថា អន្តរាកថា ។

បទថា វិប្បកតា : **កំពុងតែនិយាយ** គឺ កំពុងធ្វើការនិយាយ ។

ពាក្យថា សច្ចំ មហានាគា ខោ តយា គហបតិ វា : **ម្នាលគហបតី ព្រះថេរៈមហានាគដ៏ប្រសើរទាំងឡាយ អ្នកបាននិមន្តហើយពិតមែនឬ** មានសេចក្ដីថា ភិក្ខុនីថុល្លនន្ទា បើកភ្នែកម្ខាងមើលឃើញព្រះថេរៈទាំងឡាយកំពុងចូលមក ជ្រាបថា ព្រះថេរៈទាំងនោះបានឮហើយ

ទើបពោលយ៉ាងនេះ ។

បទថា ភិក្ខុនីបរិបាចិតំ : ដែលភិក្ខុនីចាត់ចែង បានដល់ ដែលភិក្ខុនីណែនាំឱ្យប្រគេន ។ អធិប្បាយថា ដែលភិក្ខុនីឱ្យសម្រេច គឺ ធ្វើឱ្យជារបស់គួរបានដោយករប្រកាសគុណ តែក្នុងបទភាជនៈនៃបទនោះ ដើម្បីទ្រង់សម្ដែងភិក្ខុនី និងអាការដែលភិក្ខុនីនោះណែនាំឱ្យប្រគេន ទើបព្រះមានព្រះភាគត្រាស់ពាក្យថា "ដែលហៅថា ភិក្ខុនី គឺ ស្ត្រីដែលបានឧបសម្បទាក្នុងសំណាក់ឧភតោសង្ឃ ។ ដែលហៅថា ចាត់ចែង គឺ (ភិក្ខុនីនិយាយប្រាប់ដល់ជន) ដែលមិនចង់ឱ្យ មិនចង់ធ្វើទានក្នុងកាលមុន" ដូច្នេះជាដើម ។

[៨១-២] ក្នុងពាក្យ បុព្វេ គិហិសមារម្ភា : ចង្ហាន់ដែលគ្រហស្ថបានប្រារព្ធជាមុន នេះ មានវិនិច្ឆ័យដូច្នេះ ៖

បទថា បុព្វេ : ជាមុន គឺ តាំងពីចាប់ផ្ដើមដំបូង, ភត្តដែលគេផ្ដួចផ្ដើមទុកហើយ ហៅថា សមារទ្ធៈ ។ ពាក្យថា សមារម្ភៈ នេះ ជាឈ្មោះនៃភត្តដែលគេត្រៀមទុកហើយ ។ ការផ្ដួចផ្ដើមនៃពួកគ្រហស្ថឈ្មោះថា គិហិសមារម្ភៈ ។ ភត្តណាដែលពួកគ្រហស្ថត្រៀមទុកមុនទាំងភិក្ខុនីចាត់ចែងឱ្យប្រគេន, ភិក្ខុឆាន់បិណ្ឌបាតដទៃក្រៅអំពីភត្តនោះគឺ វៀរបិណ្ឌបាតនោះចេញ ជាអាបត្តិ ។ មានពាក្យអធិប្បាយថា តែមិនជា

អាបត្តិដល់ភិក្ខុអ្នកឆាន់បិណ្ឌបាតដែលពួកគ្រហស្ថចាត់ចែងទុកនោះ ។ ចំណែកក្នុងបទភាជនៈ ព្រះឧបាលីពោលទុកថា “គិហិសមារម្ភោ ឆាម ញាតកា វា ហោន្តិ បវារិតា : ដែលហៅថា គ្រហស្ថបានប្រារព្ធ គឺជនទាំងឡាយ ជាញាតិក្តី បិណ្ឌបាតដែលគេបវារណាក្តី” ដូច្នេះ ដើម្បីសម្តែងតែអត្ថប៉ុណ្ណោះ មិនអើពើដល់ព្យញ្ជនៈ ព្រោះបិណ្ឌបាត សូម្បីដែលពួកញាតិនិងអ្នកបវារណាមិនបានប្រារព្ធទុក ដើម្បីប្រយោជន៍ដល់ភិក្ខុ ក៏ឈ្មោះថា គេប្រារព្ធទុកហើយ ដោយអត្ថ ព្រោះគប្បីឱ្យនាំមកបានតាមសប្បាយ ។

បទថា បកតិបដ្ឋិយត្តំ : ចង្ហាន់ដែលគេតាក់តែងជាប្រក្រតីក្តី មានសេចក្តីថា ជាភត្តដែលគេចាត់ចែងទុកដើម្បីប្រយោជន៍ដល់ភិក្ខុនោះឯង តាមប្រក្រតីថា ពួកយើងនឹងប្រគេនដល់ព្រះថេរៈ ដូច្នេះ ។

តែក្នុងមហាបច្ចរីពោលទុកដោយមិនប្លែកគ្នាថា ជាភត្តដែលគេចាត់ចែងទុកថា នឹងប្រគេនដល់ពួកភិក្ខុ មិនបានបញ្ជាក់ថា ភិក្ខុរូបនោះឬរូបដទៃ ។

[៨៣] ពាក្យថា បញ្ច ភោជនានិ ឋបេត្វា សព្វត្ថ អនាបត្តិ : អាបត្តិមិនមានដល់ភិក្ខុដែលឆាន់ភោជនទាំងពួង ក្រៅពីភោជនប្រាំយ៉ាងបានដល់ មិនជាអាបត្តិក្នុងយាគូរបស់គួរទំពា និងផ្លែឈើតូចធំទាំងអស់

សូម្បីដែលនាងភិក្ខុនីណែនាំឱ្យប្រគេន ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក កើតឡើងមកកាយចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បរិបាចនសិក្ខាបទវណ្ណនា ចប់

# ១០. រហោនិសជ្ជសិក្ខាបទវណ្ណនា

សេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[៨៤] អត្ថនៃបាលីនិងវិនិច្ឆ័យទាំងអស់ អ្នកសិក្សាគប្បីជ្រាបដោយន័យដូចបានពោលហើយក្នុងអនិយតសិក្ខាបទទី ២ នុ៎ះឯង ។ ពិតមែន សិក្ខាបទនេះ មានសេចក្ដីកំណត់ដូចគ្នានឹងអនិយតសិក្ខាបទទី ២ និងសិក្ខាបទទី ៤ នៃព្រះឧបនន្ទៈខាងដើម ។ តែព្រះមានព្រះភាគទ្រង់បញ្ញត្តិទុកមួយផ្នែក ដោយអំណាចនៃហេតុដែលកើតឡើងដូច្នេះឯង ។

រហោនិសជ្ជសិក្ខាបទវណ្ណនា ចប់

## ចំនួនសិក្ខាបទក្នុងភិក្ខុនីវគ្គនោះ គឺ

១. ឱវាទសិក្ខាបទ ការប្រៀនប្រដៅភិក្ខុនី
២. អត្ថង្គតសិក្ខាបទ ការប្រដៅភិក្ខុនីក្នុងកាលអស្តង្គត
៣. ភិក្ខុនីឧបស្សយសិក្ខាបទ ការចូលទៅប្រដៅភិក្ខុនីក្នុងលំនៅ
៤. អាមិសសិក្ខាបទ ការប្រដៅភិក្ខុនីព្រោះហេតុតែអាមិស
៥. ចីវរទានសិក្ខាបទ ការឱ្យចីវរដល់ភិក្ខុនីមិនមែនញាតិ
៦. ចីវរសិព្វនសិក្ខាបទ ការដេរចីវរឱ្យភិក្ខុនីមិនមែនញាតិ
៧. សំវិធានសិក្ខាបទ ការបបួលភិក្ខុនីដើរទៅកាន់មកឆ្ងាយ
៨. នាវាភិរុហនសិក្ខាបទ ការបបួលភិក្ខុនីឡើងជិះទូក
៩. បរិបាចនសិក្ខាបទ ការឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង
១០. រហោនិសជ្ជសិក្ខាបទ ការអង្គុយក្នុងទីស្ងាត់ជាមួយ នឹងភិក្ខុនី

អដ្ឋកថា ភិក្ខុនីវគ្គទី ៣ ចប់ ។

# ៤. ភោជនវគ្គ

## ១. អាវសថបិណ្ឌសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី១ នៃភោជនវគ្គ ដូចតទៅនេះ ៖

### ការឆាន់អាហារក្នុងរោងទាន

[៨៨] ដុំបាយ ( អាហារ ) ក្នុងរោងទាន ឈ្មោះថា **អាវសថបិណ្ឌបាត**, អធិប្បាយថា អាហារដែលគេសាងរោងទាន ព័ទ្ធរបងដោយជុំវិញ មានកំណត់បន្ទប់និងយ៉ៈមុខទុកច្រើនណាស់ ទើបតាំងគ្រែនិងតាំងទុកតាមសមគួរ ដល់ពួកអ្នកធ្វើដំណើរ អ្នកជម្ងឺ ស្រីមានគភ៌ និងបព្វជិត ហើយចាត់ចែងទុកក្នុងរោងទាននោះ ព្រោះជាអ្នកមានសេចក្ដីត្រូវការបុណ្យ, គឺ វត្ថុយ៉ាងណាមួយ មានបបរ បាយ និងភេសជ្ជៈជាដើម ជារបស់ដែលគេចាត់តាំងទុកដើម្បីត្រូវការឱ្យទានដល់ពួកអ្នកធ្វើដំណើរជាដើមនោះ ៗ ។

បទថា តតោ ភិយ្យោបិ[១] : **សូម្បីច្រើន** គឺ **សូម្បីស្អែកទៀត** ។

បទថា អបសក្កន្តិ : **ថយទៅ** គឺ **រមែងជៀសចេញទៅ** ។

---

១. ភូមា. ហិយ្យោបិ; ខ្មែរមិនមានប្រែ, មានតែពាក្យថា ប៉ុណ្ណោះបានហើយ ។

ពីរបទថា មនុស្សា ឧជ្ឈាយន្តិ : មនុស្សទាំងឡាយ ពោលទោស មានសេចក្តីថា ពួកអ្នកស្រុកមិនឃើញពួកតិរ្ថិយ ទើបសួរថា ពួកតិរ្ថិយទៅណា ? បានស្តាប់ថា ពួកតិរ្ថិយឃើញឆព្វគ្គិយភិក្ខុទាំងនេះ ជៀសចេញទៅហើយ ទើបនាំគ្នាលើកទោស ។

[៨៩] បទថា កុក្កុច្ចាយន្តោ : មានសេចក្តីសង្ស័យ មានសេចក្តីថា ធ្វើសេចក្តីរង្កៀស គឺ ឱ្យកើតសេចក្តីសម្គាល់ថា មិនគួរ ។

[៩០] ច្រើនបទថា សក្កោតិ តម្ហា អាវសថា បក្កមិតុំ : ភិក្ខុអាចដើម្បី ចៀសចេញពីរោងទាននោះទៅបាន មានសេចក្តីថា រមែងអាចទៅបានកន្លះយោជន៍ ឬមួយយោជន៍ ។

បទថា ន សក្កោតិ : ភិក្ខុដែលមិនអាច គឺ រមែងមិនអាចទៅ រហូតដល់អស់ទីប្រមាណប៉ុណ្ណោះនុ៎ះឯង ។

បទថា អនោទិស្ស[១] : មិនចំពោះបុគ្គលណា មានសេចក្តីថា ជារបស់ដែលគេចាត់តាំងទុក ដើម្បីមនុស្សគ្រប់ជំពូក មិនចំពោះលទ្ធិយ៉ាងនេះថា ដល់មេលទ្ធិទាំងនេះប៉ុណ្ណោះ ឬថា ដល់ពួកអ្នកបួសមានប្រមាណប៉ុណ្ណោះប៉ុណ្ណោះ ។

បទថា យាវទត្ថោ : កំណត់ល្មមមួយឆ្អែត មានសេចក្តីថា ជា

១. ថៃ. អនុទ្ទិស្ស ។

របស់ដែលគេចាត់តាំងទុក មានល្មមដល់សេចក្ដីត្រូវការ មិនកំណត់សូម្បី ភោជនថា ត្រឹមតែប៉ុណ្ណោះ ។

បទថា សកឹ ភុញ្ជិតព្វំ : ត្រូវបានឆាន់តែម្ដង គឺ គប្បីឆាន់បាន មួយថ្ងៃ ។ តាំងពីថ្ងៃទី ២ ទៅ ជាទុក្កដក្នុងការទទួលប្រគេន ជា បាចិត្តិយ គ្រប់ ៗម៉ាត់ដែលលេប ។

ចំណែកសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទនេះ មានដូចតទៅនេះ ៖

ភោជនដែលត្រកូលតែមួយ ឬត្រកូលផ្សេង ៗរួមគ្នា ចាត់ចែងទុក ក្នុងស្ថានទីតែមួយកន្លែង ឬក្នុងស្ថានទីផ្សេង ៗគ្នាក្ដី ក្នុងស្ថានទីមិនពិតប្រាកដយ៉ាងនេះ គឺ ថ្ងៃនេះ ១ កន្លែង ថ្ងៃស្អែក ១ កន្លែង ក្ដី ។ ភិក្ខុឆាន់មួយថ្ងៃ ក្នុងទីមួយកន្លែងហើយ ក្នុងថ្ងៃទី ២ នឹងឆាន់ក្នុងទីនោះ ឬក្នុងទីដទៃ មិនគួរ ។ តែភោជនដែលត្រកូលផ្សេង ៗ ចាត់ចែងទុកក្នុងទីផ្សេង ៗគ្នា, ភិក្ខុឆាន់មួយថ្ងៃក្នុងទីមួយកន្លែងហើយ ក្នុងថ្ងៃទី ២ នឹងឆាន់ក្នុងទីដទៃ គួរ ។ ក្នុងមហាបច្ចរីពោលថា ក៏ភិក្ខុឆាន់អស់លំដាប់ហើយនឹងចាប់ផ្ដើមទៅថ្មី មិនគួរ ដូច្នេះ ។ សូម្បីក្នុងគណៈជាមួយគ្នា គណៈផ្សេងគ្នាស្រុកជាមួយគ្នា និងផ្សេងស្រុកគ្នា ក៏ន័យនេះឯង ។ ចំណែកភត្តាហារណាដែលត្រកូលតែមួយចាត់ចែង ឬត្រកូលផ្សេង ៗរួមគ្នាចាត់ចែងទុក ជាចំរយៈទៅក្នុងចន្លោះព្រោះមិនមានអន្តរជាដើម, សូម្បី

ភត្តាហារនោះ ក៏មិនគួរឆាន់ ។ លោកពោលទុកក្នុងមហាបច្ចរីថា ក៏បើថា ត្រកូលទាំងឡាយកត់ដាច់ថា ពួកយើងនឹងមិនអាចឱ្យ កាលកើតទឹកចិត្តល្អឡើង ទើបផ្តើមឱ្យថ្មី, នឹងត្រឡប់ឆាន់ទៀត មួយថ្ងៃម្តង ក៏បាន ។

[៩២] ពីរបទថា អនាបត្តិ គិលានស្ស : **អាបត្តិមិនមានដល់ភិក្ខុមានជម្ងឺ** បានដល់ មិនជាអាបត្តិដល់ភិក្ខុអាពាធដែលនៅសម្រាកឆាន់ ។

បទថា គច្ឆន្តោ វា : **ដើរទៅក្តី** មានសេចក្តីថា ភិក្ខុណា កាលទៅឆាន់មួយថ្ងៃ ក្នុងចន្លោះមក, និងក្នុងទីទៅដល់ហើយឆាន់មួយថ្ងៃទៀត មិនជាអាបត្តិសូម្បីដល់ភិក្ខុនោះ ។ សូម្បីភិក្ខុដែលដើរមក ក៏ន័យនេះឯង ។ ពិតមែន ភិក្ខុដែលទៅហើយត្រឡប់មក រមែងបានដើម្បីឆាន់ក្នុងចន្លោះមកមួយថ្ងៃ និងក្នុងទីដែលត្រឡប់មកមួយថ្ងៃទៀត ។ កាលភិក្ខុគិតថា នឹងទៅឆាន់ ហើយចេញទៅ ទឹកទន្លេជន់ឡើងពេញ ឬថា មានភ័យ គឺចោរជាដើម, លោកត្រឡប់មកហើយជ្រាបថា រួចផុតភ័យហើយទៅ រមែងបានឆាន់មួយថ្ងៃទៀត, ពាក្យទាំងអស់ដូចពោលមកនេះ លោកពោលទុកក្នុងមហាបច្ចរីជាដើម ។

ពាក្យថា ឱទិស្ស បញ្ញត្តោ ហោតិ : **ដល់ភិក្ខុឆាន់បិណ្ឌបាតដែលគេតាក់តែងចំពោះ** មានសេចក្តីថា ជារបស់ដែលគេចាត់ចែងទុក

ចំពោះ ដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយប៉ុណ្ណោះ ។

បទថា ន យាវទត្ថោ : **មិនដល់មួយចំអែត** មានសេចក្ដីថា មិនមែនជារបស់ដែលគេចាត់ចែងទុកល្មមដល់សេចក្ដីត្រូវការទេ គឺ មានត្រឹមតែបន្តិចបន្តួច, ទឹងឆាន់ភោជន សូម្បីដូច្នោះជានិច្ចក៏គួរ ។

ច្រើនបទថា បញ្ច ភោជនានិ ឋបេត្វា សព្វត្ថ : **ដល់ភិក្ខុព្រោះឆាន់ភោជនទាំងពួង ក្រៅពីភោជន ៥ យ៉ាង បានដល់** មិនជាអាបត្តិក្នុងរបស់គ្រប់ប្រភេទ ដូច យាគូ របស់គួរទំពា និងផ្លែឈើតូចធំជាដើម, ពិតមែន ភិក្ខុទឹងឆាន់ភោជនមានយាគូជាដើម សូម្បីជានិច្ចក៏គួរ ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ កើតឡើងមកកាយ ១ កាយចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អាវសថបិណ្ឌសិក្ខាបទវណ្ណនា ចប់

# ២. គណភោជនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

## ពន្យល់រឿងភិក្ខុទេវទត្ត

[៩៣] បទថា បរិហីនលាភសក្ការោ **:** មានលាភសក្ការសាបសូន្យហើយ មានសេចក្ដីថា បានឮថា ភិក្ខុទេវទត្តនោះ ណែនាំឱ្យព្រះបាទអជាតសត្តុឱ្យផ្ដាច់ព្រះជន្មព្រះរាជាក្ដី បង្គាប់នាយខ្មាន់ធ្នូទៅ (ដើម្បីផ្ដាច់ព្រះជន្មព្រះតថាគត)ក្ដី ធ្វើលោហិតុប្បាទក្ដី បានជាអ្នកលាក់បិទបាំង, តែក្នុងកាលបញ្ចូនដំរីធនបាលក៍ ទៅក្នុងពេលថ្ងៃក្ដៅថែសន្ទុះឯង បានបើកបង្ហាញលេចចេញឡើង ។

គឺ យ៉ាង ? គឺ ព្រោះថា កាលកើតនិយាយគ្នាឡើងថា ភិក្ខុទេវទត្តបញ្ចូនដំរីទៅ (ដើម្បីផ្ដាច់ព្រះជន្មព្រះតថាគត) ក៏បានប្រាកដច្បាស់ថា មិនមែនតែបញ្ចូនដំរីតែម្យ៉ាង សូម្បីព្រះរាជា ភិក្ខុទេវទត្តក៏ឱ្យគេទៅផ្ដាច់ព្រះជន្មសូម្បីពួកនាយខ្មាន់ធ្នូក៏បញ្ចូនទៅ សូម្បីថ្មក៏ប្រមៀល, ភិក្ខុទេវទត្តជាមនុស្សលាមកបានប្រាកដហើយ ។ កាលបើមានអ្នកសួរថា ភិក្ខុទេវទត្តបានធ្វើកម្មនេះ ជាមួយនឹងអ្នកណា ? អ្នកក្រុងពោលថា ជាមួយនឹងព្រះបាទអជាតសត្តុ ។ ក្នុងលំដាប់នោះ អ្នកក្រុងក៏បះបោរឡើងនិយាយថា ដូចម្ដេចហ្ន៎ ទើបព្រះរាជាសេពគប់ចោរ ដែលជាចម្រូង

ចម្រាសចំពោះព្រះសាសនាបែបនេះហ្ន៎ ? ព្រះរាជាទ្រង់ជ្រាបការកម្រើករបស់អ្នកក្រុង ទើបទ្រង់បណ្ដេញភិក្ខុទេវទត្តចេញទៅ ចាប់តាំងពីពេលនោះមកក៏ទ្រង់កាត់ចង្ហាន់ ៥០០ សម្រាប់នៃភិក្ខុទេវទត្តនោះចេញ ។ សូម្បីទីទំនុកបម្រុងភិក្ខុទេវទត្តនោះ ក៏ស្ដេចមិនបានទៅ, សូម្បីពួកអ្នកស្រុកដទៃក៏មិនសម្គាល់របស់អ្វី ៗ ដែលនឹងគប្បីប្រគេន ឬគប្បីធ្វើដល់ភិក្ខុទេវទត្តនោះ ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា មានលាភនិងសក្ការៈសាបសូន្យអស់ហើយ ។

ពាក្យថា កុលេសុ វិញ្ញាបេត្វា វិញ្ញាបេត្វា ភុញ្ជន្តិ : សូមរឿយ ៗក្នុងត្រកូល ហើយឆាន់ មានសេចក្ដីថា ភិក្ខុទេវទត្តនោះ ត្រិះរិះថា គណៈរបស់យើងកុំបានបែកគ្នាឡើយ កាលនឹងចិញ្ចឹមបរិស័ទ ទើបបានត្រាច់ទៅព្រមដោយបរិស័ទសូមអាហារឆាន់នៅក្នុងត្រកូលទាំងឡាយយ៉ាងនេះថា "លោកចូរប្រគេនភត្តដល់ភិក្ខុ ១ រូប លោកចូរប្រគេនដល់ភិក្ខុ ២ រូប" ដូច្នេះ ។

[៩៥] ពាក្យថា ចីវរំ បរិត្តំ ឧប្បជ្ជតិ : ចីវរក៏កើតឡើងដល់ភិក្ខុដោយស្ដួចស្ដើង មានសេចក្ដីថា អ្នកស្រុកទាំងឡាយ មិនប្រគេនចីវរដល់ភិក្ខុដែលមិនទទួលភត្តាហារ; ព្រោះហេតុនោះ ចីវរទើបកើតឡើងបន្តិចបន្តួច ។

[៩៦] ពាក្យថា ចីវរការកេ ភិក្ខូ ភត្តេន និមន្តេន្តិ : មនុស្សទាំងឡាយ និមន្តភិក្ខុដែលជាអ្នកធ្វើចីវរដោយចង្ហាន់ មានសេចក្តីថា អ្នកស្រុកឃើញភិក្ខុទាំងឡាយ អ្នកត្រាច់ទៅបិណ្ឌបាតក្នុងស្រុក ហើយធ្វើចីវរឱ្យសម្រេចយឺតយូរ ទើបនិមន្តដោយសេចក្តីប្រាថ្នាបុណ្យថា "ភិក្ខុទាំងឡាយនឹងញ៉ាំងចីវរឱ្យសម្រេច ហើយប្រើប្រាស់ដោយអាការយ៉ាងនេះ" ។

[៩៩] បទថា នានាវេរជ្ជកេ : វជ្ជសីមាផ្សេងគ្នា បានដល់អ្នកមកពីប្រទេសផ្សេង ៗ គឺ អំពីរាជអាណាចក្រដទៃ ៗ បាលីថា នានាវេរញ្ជកេ : ស្រុកផ្សេងគ្នា ក៏មាន ។ សេចក្តីក៏យ៉ាងនេះដូចគ្នា ។

## អត្ថាធិប្បាយការឆាន់ជាគណៈ

បទថា គណភោជនេ : ព្រោះគណភោជន គឺ ក្នុងការឆាន់នូវភោជនជាក្រុម ៗ ក៏ក្នុងសិក្ខាបទនេះ ទ្រង់ប្រាថ្នាយកភិក្ខុតាំងពី ៤ រូបឡើងទៅ ឈ្មោះថា គណៈ ( ពួក, ក្រុម ) ។

[១០០] ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងកំណត់ចំនួនយ៉ាងទាបបំផុតដោយពាក្យនោះឯង ទើបត្រាស់ថា "យត្ថ ចត្តារោ ភិក្ខូ បញ្ចន្នំ ភោជនានំ អញ្ញតរេន ភោជនេន និមន្តិតា ភុញ្ជន្តិ ឯតំ

គណភោជនំ នាម : ភិក្ខុ ៤ រូប ដែលគេនិមន្តចេញឈ្មោះ ភោជនទាំង ៥ ដោយភោជនណាមួយ ហើយឆាន់ភោជនណាមួយ ភោជនទុំះ ហៅថា គណភោជន” ដូច្នេះ ។

ក៏គណភោជននោះ រមែងប្រព្រឹត្តទៅដោយអាការ ២ យ៉ាង គឺ ដោយករនិមន្ត ១យ៉ាង, ដោយវិញ្ញត្តិ ១យ៉ាង ។ តើប្រព្រឹត្តទៅដោយករនិមន្តយ៉ាងណា ? គឺទាយកចូលទៅរកភិក្ខុ ៤ រូប ហើយនិមន្តបញ្ចេញឈ្មោះភោជនទាំង ៥ ដោយវេវចនៈយ៉ាងណាមួយ ឬដោយភាសាដទៃ យ៉ាងនេះថា “លោកម្ចាស់ដ៏ចម្រើន ខ្ញុំនិមន្តលោកដោយបាយ, លោកចូរកាន់យកបាយរបស់ខ្ញុំ, ចូរប្រាថ្នា ចូរត្រួតមើល ចូរទទួល ចូររាប់អាននូវបាយរបស់ខ្ញុំ” ដូច្នេះ ។ ភិក្ខុតាំងពី ៤ រូបឡើងទៅ ទទួលនិមន្តរួមគ្នា យ៉ាងនេះ ទៅព្រមគ្នាដើម្បីឆាន់ក្នុងថ្ងៃនេះ ឬដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ដោយអំណាចនៃវេលាដែលគេកំណត់ទុកទទួលរួមគ្នា ឆាន់រួមគ្នា ចាត់ជាគណភោជន, ជាអាបត្តិដល់ភិក្ខុទាំងអស់ ។

ភិក្ខុទាំងឡាយទទួលនិមន្តរួមគ្នា នឹងទៅព្រមគ្នា ឬអ្នកនិមន្តផ្សេងគ្នា ទៅផ្សេងគ្នាក៏ដោយ, ទទួលប្រគេនរួមគ្នា អ្នកប្រគេនផ្សេងគ្នាឆាន់ផ្សេងគ្នា ក៏ជាអាបត្តិដូចគ្នា ។ ពិតមែន ការទទួលប្រគេនទុំះឯងជាប្រមាណក្នុងសិក្ខាបទនេះ ។ ភិក្ខុទាំងឡាយទទួលនិមន្តរួមគ្នា នឹងទៅព្រម

គ្នា ឬទៅផ្សេងគ្នាក៏ដោយ, ទទួលប្រគេនផ្សេងគ្នា នឹងឆាន់រួមគ្នា ឬឆាន់ផ្សេងគ្នាក៏ដោយ មិនជាអាបត្តិ ។

ភិក្ខុទាំងឡាយទៅកាន់បរិវេណ ឬវិហារ ៤ កន្លែង ទទួលនិមន្តផ្សេងគ្នា ឬ បណ្តាភិក្ខុដែលឈរនៅក្នុងទីកន្លែងជាមួយគ្នានុ៎ះឯង ទទួលនិមន្តផ្សេងគ្នា សូម្បីយ៉ាងនេះគឺ កូនប្រុសនិមន្ត ១ រូប បិតានិមន្ត ១ រូប នឹងទៅព្រមគ្នា ឬទៅផ្សេងគ្នាក៏ដោយ, នឹងឆាន់ព្រមគ្នា ឬឆាន់ផ្សេងគ្នាក៏ដោយ បើទទួលប្រគេនរួមគ្នា ចាត់ជាគណភោជន, ជាអាបត្តិដល់ភិក្ខុទាំងអស់ ។ រមែងប្រព្រឹត្តទៅដោយការនិមន្តយ៉ាងនេះមុន ។

រមែងប្រព្រឹត្តទៅដោយវិញ្ញត្តិយ៉ាងណា ? គឺ ភិក្ខុ ៤ រូប ឈរ ឬអង្គុយនៅជាមួយគ្នា ឃើញឧបាសកហើយសូមថា លោកចូរប្រគេនភត្តាហារដល់ពួកយើងទាំង ៤ រូប ដូច្នេះ ក្តី (ពួកភិក្ខុ)ឃើញមនុស្សផ្សេង ៗគ្នា ហើយសូមរួមគ្នា ឬសូមផ្សេងគ្នាយ៉ាងនេះថា "លោកចូរប្រគេនដល់យើង, លោកចូរប្រគេនដល់យើង" ដូច្នេះក្តី នឹងទៅព្រមគ្នា ឬទៅផ្សេងគ្នាក៏ដោយ, សូម្បីទទួលប្រគេនភត្តហើយ នឹងឆាន់រួមគ្នាឬឆាន់ផ្សេងគ្នាក៏ដោយ, បើទទួលប្រគេនរួមគ្នា, ចាត់ជាគណៈភោជន, ជាអាបត្តិដល់ភិក្ខុទាំងអស់ ។ រមែងប្រព្រឹត្តទៅដោយវិញ្ញត្តិយ៉ាងនេះ ។

## សម័យដែលទ្រង់អនុញ្ញាតឱ្យឆាន់គណៈភោជនបាន

[១០១] ពីរបទថា បាទាបិ ផាលិតា : សូម្បីជើងទាំងឡាយដែលបែក មានសេចក្តីថា ( ជើងទាំង ២ ) បែកដោយអាការដែលសាច់ប្រាកដឱ្យឃើញខាងមុខស្បែកធំ ត្រឹមតែខ្សាច់ ឬគ្រួសប៉ះខ្ទប់ ក៏បង្ករឱ្យកើតទុក្ខឡើង មិនអាចដើម្បីត្រាច់ទៅបិណ្ឌបាតខាងក្នុងស្រុកបាន ។ អាពាធដូច្នោះ គួរឆាន់បានដោយគិតថា ជាពេលអាពាធ ( តែ ) មិនគួរធ្វើឱ្យជាកប្បិយដោយលេស ។

ពីរបទថា ចីវរេ ការិយមានេ : កាលដែលភិក្ខុកំពុងធ្វើចីវរ មានសេចក្តីថា ក្នុងពេលដែលពួកភិក្ខុបានសំពត់និងអំបោះហើយធ្វើចីវរ ។ ពិតមែន ឈ្មោះថា ចីវរការសម័យ មួយផ្នែកមិនមាន ។ ព្រោះហេតុនោះ ភិក្ខុណាធ្វើការយ៉ាងណាមួយ ដែលគួរធ្វើក្នុងចីវរនោះ សមដូចដែលលោកពោលទុកក្នុងមហាបច្ចរីថា ដោយហោចទៅសូម្បីភិក្ខុដែលដោតម្ជុល ដូច្នេះក៏មាន, ភិក្ខុនោះ គួរឆាន់បានដោយគិតថា ជាចីវរការសម័យ ។

ចំណែកក្នុងកុរុន្ទីលោកពោលទុកដោយពិស្តារតែម្តងថា ភិក្ខុណា ចាត់ចែងចីវរ កាត់ចីវរ តម្កល់ទុកនូវអំបោះសុទ្ធ ដេរដាន ផ្អបសំពត់ថ្មី ដេរសង្កត់ថ្នេរ ភ្ជាប់សំពត់ផ្អប កាត់អនុវាទ តអំបោះ ដេរជាយថ្នេរក្នុង ចីវរនោះ ខារអំបោះ រុំអំបោះ ( បញ្ចូលអំបោះ ) សំលៀងកាំបិតតូច ធ្វើ

គ្រឿងវេញអំបោះ, ភិក្ខុសូម្បីទាំងអស់នេះ លោកហៅថា ធ្វើចីវរដែរ, តែភិក្ខុណា អង្គុយជិត ៗពោលជាតកក្ដី ធម្មបទក្ដី ភិក្ខុនេះមិនមែនអ្នកធ្វើចីវរ, វៀរលែងភិក្ខុនេះចេញ មិនជាអាបត្តិដល់ភិក្ខុដែលនៅសល់ ព្រោះគណភោជន ។

បទថា អឌ្ឍយោជនំ **: មកឆ្ងាយប្រមាណកន្លះយោជន៍** បានដល់អ្នកប្រាថ្នានឹងដើរមកឆ្ងាយសូម្បីប្រមាណប៉ុណ្ណេះ ។ ក៏ភិក្ខុណាប្រាថ្នានឹងដើរមកឆ្ងាយ, ក្នុងភិក្ខុនោះ មិនមានពាក្យដែលនឹងត្រូវពោលឡើយ ។

បទថា គច្ឆន្តេន **: កាលភិក្ខុកំពុងដើរទៅ** មានសេចក្ដីថា ភិក្ខុដែលដើរមកឆ្ងាយ នឹងឆាន់សូម្បីក្នុងទីមួយគាវុតខាងក្នុងកន្លះយោជន៍ ក៏គួរ ។

ពីរបទថា គតេន[១] ភុញ្ជិតព្វំ **:........ ក៏គប្បីឆាន់គណភោជនបាន** គឺ អ្នកទៅហើយគប្បីឆាន់បានមួយថ្ងៃ ។

សូម្បីក្នុងវេលាដោយសារទូកទៅ ក៏ន័យនេះឯង ។ ចំណែកសេចក្ដីប្លែកគ្នាដូចតទៅនេះ ៖

ក្នុងមហាបច្ចរីពោលថា ភិក្ខុអ្នកដោយសារទូកទៅ សូម្បីដល់កន្លែងដែលខ្លួនប្រាថ្នាហើយ គប្បីឆាន់បានរហូតដល់អស់វេលាដែលខ្លួនមិនទាន់ឡើង (ពីទូក) ។

---

១. បិដកខ្មែរ. **អាគតេន : កាលភិក្ខុមកវិញ** ។

កំណត់ថា ចតុត្ថេ អាគតេ : **មួយអង្គមកទៀត ត្រូវជាប្អូនអង្គ**នេះ ជាកំណត់យ៉ាងទាបទីបំផុត ។ សូម្បីកាលភិក្ខុរូបទី ៤ មក ភិក្ខុទាំងឡាយមិនល្មមក្នុងការឆាន់ ក្នុងសម័យណា, សម័យនោះ ចាត់ជាគ្រាប្រជុំធំបាន ។ ក៏ក្នុងគ្រាដែលភិក្ខុប្រជុំគ្នាទាំងរយរូប ឬពាន់រូប មិនមានពាក្យដែលនឹងត្រូវពោលឡើយ, ព្រោះ ដូច្នោះ ក្នុងកាលដូច្នោះ ភិក្ខុគប្បីអធិដ្ឋានថា ជាសម័យប្រជុំធំ ហើយឆាន់ចុះ ។

ពាក្យថា យោ កោចិ បរិព្វាជកសមាបន្នោ : **អ្នកណាមួយដែលរាប់បញ្ចូលក្នុងពួកអ្នកបួស** បានដល់ បណ្ដាពួកសហធម្មិកក្ដី ពួកតិរ្ថិយក្ដី អ្នកបួសពួកណាមួយ, ក៏កាលអ្នកបួសមានសហធម្មិកជាដើមទាំងនេះ រូបណាមួយ ធ្វើភត្តាហារហើយ ភិក្ខុគប្បីអធិដ្ឋានថា ជាសម័យភត្តរបស់សមណៈ ហើយឆាន់ចុះ ។

[១០៣] ពីរបទថា អនាបត្តិ សមយេ : **អាបត្តិមិនមានដល់ភិក្ខុមាន**សម័យ បានដល់ មិនជាអាបត្តិ ក្នុងសម័យទាំង៧ ណាមួយ ។

ពាក្យថា ទ្វេ តយោ ឯកតោ : **ដល់ភិក្ខុទាំងឡាយពីរឬបីអង្គឆាន់ជាមួយគ្នា** មានសេចក្ដីថា សូម្បីភិក្ខុពួកណា ត្រេកអរការនិមន្តដែលមិនសមគួរ ទទួលរួមគ្នា ២ រូប ឬ ៣ រូប ហើយឆាន់, មិនជាអាបត្តិសូម្បីដល់ភិក្ខុទាំងនោះ ។

# ចតុក្កៈ ៥ ពួកមានអនិមន្តិតចតុក្កៈជាដើម

ក្នុងពាក្យថា ទ្វេ តយោ ឯកតោ : **ពីរឬបីអង្គឆាន់ជាមួយគ្នា**នោះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយអំណាចចតុក្កៈ ៥ ពួក គឺ អនិមន្តិតចតុក្កៈ (មានភិក្ខុមិនបាននិមន្តជាគម្រប់ ៤)១ បិណ្ឌបាតិកចតុក្កៈ (មានភិក្ខុកាន់បិណ្ឌបាតជាវត្តជាគម្រប់ ៤) ១ អនុបសម្បន្នចតុក្កៈ (មានអនុបសម្បន្នជាគម្រប់ ៤) ១ បត្តចតុក្កៈ (មានបាត្រជាគម្រប់ ៤) ១ គិលានចតុក្កៈ (មានភិក្ខុអាពាធជាគម្រប់ ៤) ១ ។

តើយ៉ាងណា ? គឺ អ្នកខ្លះក្នុងលោកនេះ និមន្តភិក្ខុ ៤ រូបថា និមន្តលោកទទួលភត្ត (បាយ) ។ ក្នុងភិក្ខុ ៤ រូបនោះ ទៅ ៣ រូប, មិនទៅ ១ រូប ឧបាសកសួរថា "លោកដ៏មានអាយុ ព្រះថេរៈមួយរូបទៅណា ?" ភិក្ខុឆ្លើយថា "មិនមកទេ ឧបាសក" ឧបាសកនោះនិមន្តភិក្ខុដទៃរូបណា ដែលមកដល់ចូលក្នុងខណៈនោះ ឱ្យចូលអង្គុយរួមថា "និមន្តលោកម្ចាស់មកចុះ" ហើយប្រគេនភត្តដល់ភិក្ខុទាំង ៤ រូប ។ មិនជាអាបត្តិដល់ភិក្ខុសូម្បីទាំងអស់ ។ ព្រោះហេតុអ្វី ? ព្រោះភិក្ខុគណបូរកៈ (ភិក្ខុដែលបង្គ្រប់គណៈ)គេមិនបាននិមន្ត ។ ពិតមែន ក្នុងភិក្ខុ ៤ រូបនោះ ភិក្ខុ ៣ រូប ប៉ុណ្ណោះគេនិមន្តបានទទួលប្រគេនហើយ, គណៈមិនទាន់គ្រប់ដោយភិក្ខុ ៣ រូបនោះ, និងរូបដែលបង្គ្រប់គណៈគេមិនបាន

និមន្ត, គណៈទើបបែក ព្រោះភិក្ខុនោះ, ភិក្ខុ ចតុត្ថៈដូចពោលមកនេះ ឈ្មោះថា អនិមន្តិតចតុត្ថៈ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបិណ្ឌបាតិកចតុត្ថៈ ៖

ក្នុងវេលានិមន្ត មានភិក្ខុកាន់បិណ្ឌបាតជាវត្តមួយរូប, លោកទើបមិនទទួល ។ តែក្នុងវេលានឹងទៅ កាលពួកភិក្ខុទទួលនិមន្តពោលថា "លោកម្ចាស់ និមន្តលោកមកចុះ" ហើយនាំយកភិក្ខុនោះសូម្បីអ្នកមិនទៅ ព្រោះមិនបានទទួលនិមន្ត ទៅដោយពោលថា "មកចុះ លោកនឹងបានភិក្ខា" ។ ភិក្ខុនោះធ្វើគណៈនោះឱ្យបែកគ្នា ។ ព្រោះដូច្នោះ ទើបមិនជាអាបត្តិដល់ភិក្ខុទាំងអស់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអនុបសម្បន្នចតុត្ថៈ ៖

ពួកភិក្ខុទទួលនិមន្តព្រមនឹងសាមណេរ ។ សូម្បីសាមណេរនោះក៏ធ្វើគណៈឱ្យបែកគ្នាបាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបត្តចតុត្ថៈ ៖

ភិក្ខុមួយរូបមិនទៅដោយខ្លួនឯង បញ្ជូនបាត្រទៅ ។ សូម្បីដោយអាការយ៉ាងនេះ គណៈក៏បែក ។ ព្រោះដូច្នោះ ទើបមិនជាអាបត្តិដល់ភិក្ខុគ្រប់រូប ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគិលានចតុត្ថៈ; ពួកភិក្ខុទទួលនិមន្តរួមជាមួយភិក្ខុអាពាធ ។ ក្នុងភិក្ខុ ៤ រូបនោះ ភិក្ខុអាពាធប៉ុណ្ណោះមិនជាអាបត្តិ តែ

លោកជាគណបូរកៈរបស់ភិក្ខុក្រៅនេះបាន, គណៈទើបមិនបែក ព្រោះភិក្ខុអាពាធឡើយ ។ ព្រោះដូច្នោះ ទើបជាអាបត្តិដល់ភិក្ខុទាំងនោះពិត ។ តែក្នុងមហាបច្ចរីលោកពោលទុក ដោយមិនប្លែកគ្នាថា ភិក្ខុអាពាធបានសម័យ ទើបរួចផុតទៅបានដោយខ្លួនឯងនោះ, ធ្វើឱ្យជាអាបត្តិដល់ភិក្ខុដែលនៅសល់ ព្រោះជាគណបូរកៈ ។ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបចតុក្កៈ ដោយអំណាចនៃភិក្ខុ ដែលបានចីវរទានសម័យជាដើម ។

ក៏បើថា ភិក្ខុដែលឆ្លាតមួយរូបក្នុងភិក្ខុ ៤ រូប សូម្បីទទួលនិមន្តហើយ ទៅពោលថា ខ្ញុំនឹងបែកគណៈរបស់ពួកលោក, សូមពួកលោកចូរទទួលការនិមន្ត កាលពួកអ្នកស្រុកនឹងទទួលបាត្រដើម្បីប្រយោជន៍ដល់ភត្តក្នុងទីបំផុតនៃយាគូនិងរបស់គួរទំពាមិនឱ្យ (បាត្រ) ពោលថា "ពួកលោកឱ្យភិក្ខុទាំងនេះឆាន់ ហើយបញ្ជូនត្រឡប់ទៅមុន, អាត្មាធ្វើអនុមោទនាហើយនឹងទៅតាមក្រោយ" ហើយនៅអង្គុយ, កាលភិក្ខុទាំងនោះ ឆាន់រួចសម្រេចហើយទៅ, កាលឧបាសកពោលថា "មេត្តាឱ្យបាត្រចុះលោកម្ចាស់ ហើយទទួលបាត្រទៅប្រគេនភត្ត ឆាន់សម្រេចធ្វើអនុមោទនាហើយ ទើបទៅ, មិនជាអាបត្តិដល់ភិក្ខុគ្រប់រូប ។

ពិតមែន សេចក្តីខុសសង្កេតក្នុងគណភោជន រមែងមិនមានដោយអំណាចនៃភោជន ៥ យ៉ាងឡើយ ។ ពួកភិក្ខុទទួលនិមន្តដោយបាយសូម្បីទទួលទំកុម្ចាស ក៏ត្រូវអាបត្តិ ក៏ភោជនទាំងនោះ ភិក្ខុទាំងនោះមិន

បានទទួលរួមគ្នា ។ តែមានសេចក្តីខុសសង្កេតដោយអាហារវត្ថុមានយាគូជាដើមទាំងនោះ ។ យាគូជាដើមទាំងនោះ ភិក្ខុទាំងនោះ ទទួលរួមគ្នាបាន ។ ភិក្ខុដែលឆ្លាតមួយរូប រមែងធ្វើមិនឱ្យជាអាបត្តិ សូម្បីដល់ភិក្ខុពួកដទៃ ដោយប្រការយ៉ាងនេះ ។

## វិធីនិមន្តភិក្ខុទទួលភិក្ខា

ព្រោះដូច្នោះ បើអ្នកប្រាថ្នានឹងធ្វើសង្ឃភត្ត ពឹងអ្នកណាឱ្យទៅដើម្បីត្រូវការនិមន្ត (ភិក្ខុ), មកកាន់វិហារ មិនពោលថា "លោកម្ចាស់ថ្ងៃស្អែកនិមន្តទទួលភិក្ខាក្នុងផ្ទះរបស់ពួកខ្ញុំ" ពោលថា "និមន្តលោកទទួលភត្តក្តីថា និមន្តលោកទទួលសង្ឃភត្តក្តី ថា សូមសង្ឃទទួលភត្តក្តី, ភត្តុទ្ទេសកៈគប្បីជាអ្នកឆ្លាត ។ គប្បីដោះពួកភិក្ខុដែលទទួលនិមន្តអំពីគណភោជន, គប្បីដោះពួកភិក្ខុកាន់បិណ្ឌបាតិកធុតង្គពីការបែកធ្លាយនៃធុតង្គ ។

តើយ៉ាងណា ? គឺ ភត្តុទ្ទេសកៈ គប្បីពោលយ៉ាងនេះមុនថា "ថ្ងៃស្អែក មិនអាច(ទទួល)បានទេ ឧបាសក" កាលឧបាសកពោលថា "ថ្ងៃខានស្អែក លោកម្ចាស់" គប្បីពោលថា "ថ្ងៃខានស្អែក ក៏មិនអាច(ទទួលបាន)" សូម្បីឧបាសកបង្ខិតទៅយ៉ាងនេះ ដរាបដល់កន្លះខែ ភត្តុទ្ទេសកៈ គប្បីនិយាយទៀតថា "លោកនិយាយអ្វី ?" ប្រសិនបើ

ឧបាសកនិយាយដដែលទៀតថា "និមន្តលោកទទួលសង្ឃភត្ត" លំដាប់នោះ ភត្តុទ្ទេសកៈគប្បីឆ្លើយលប្រែទូរទៅយ៉ាងនេះថា "ឧបាសក ចូរធ្វើផ្កាឈើនេះ ចូរធ្វើស្មៅនេះ ឱ្យជាកប្បិយ"សិន ហើយសាកសួរទៀតថា "លោកនិយាយអ្វី ?" ប្រសិនបើគេនៅតែនិយាយដដែលនោះឯង, គប្បីពោលថា "លោកមានអាយុ លោកនឹងមិនបានព្រះមហាថេរៈអ្នកកាន់បិណ្ឌបាតជាវត្ត, លោកនឹងបានពួកសាមណេរ" ។ មួយទៀត កាលគេសួរថា "លោកដ៏មានអាយុ ពួកមនុស្សក្នុងស្រុកឯណោះ និងស្រុកឯណោះ និមន្តឱ្យព្រះគុណម្ចាស់ដ៏ចម្រើនឆាន់ មិនមែនឬ ? ខ្ញុំនឹងមិនបាន ព្រោះហេតុអ្វី ? គប្បីពោលថា "ពួកគេស្គាល់កិច្ចនិមន្ត, (ចំណែក)លោកមិនស្គាល់កិច្ចនិមន្ត" ។ គេសួរថា "លោកម្ចាស់ ពួកគេនិមន្តយ៉ាងណា ?" គប្បីពោលថា "ពួកគេពោលយ៉ាងនេះថា និមន្តទទួលភិក្ខារបស់ពួកខ្ញុំលោកម្ចាស់" ប្រសិនបើថា គេពោលដូចដែលនិយាយនោះឯង, ការនិមន្តនោះ សមគួរ ។

បើគេនៅពោលដដែលទៀតថា "និមន្តទទួលភត្ត" គប្បីពោលថា "អ្នកមានអាយុ គ្រានេះលោកនឹងមិនបានភិក្ខុច្រើន, នឹងបានត្រឹមតែ ៣ រូបប៉ុណ្ណោះ" ។ បើគេសួរថា "លោកដ៏មានអាយុ ពួកអ្នកស្រុកក្នុងស្រុកឯណោះនិងស្រុកឯណោះ និមន្តភិក្ខុសង្ឃទាំងអស់ឱ្យឆាន់មិនមែនឬ ? ព្រោះហេតុអ្វី ទើបខ្ញុំមិនបាន ?" គប្បីពោលថា "លោកមិនស្គាល់កិច្ច

និមន្ត" ។ បើគេសួរថា "លោកម្ចាស់ ពួកគេនិមន្តយ៉ាងណា" គប្បីពោលថា ពួកគេពោលយ៉ាងនេះថា "លោកម្ចាស់ និមន្តទទួលភិក្ខារបស់ពួកខ្ញុំ" ។ ប្រសិនបើគេពោលដូចដែលនិយាយនោះឯង, ការនិមន្តនោះសមគួរ ។

បើគេនិយាយថា ភត្តប៉ុណ្ណោះ សូម្បីទៀត ។ ពេលនោះភត្តុទ្ទេសកៈ គប្បីពោលថា "ចេញទៅចុះលោក, ពួកយើងមិនត្រូវការដោយភត្តរបស់លោក, ស្រុកនេះជាទីត្រាច់ទៅបិណ្ឌបាត ប្រចាំរបស់ពួកយើង, ពួកយើងនឹងត្រាច់ទៅបិណ្ឌបាតក្នុងស្រុកនេះ" ។ គេពោលថា "និមន្តលោកត្រាច់ទៅកាន់ស្រុកនោះចុះ លោកម្ចាស់" ហើយត្រឡប់មកអ្នកស្រុកសួរថា "អ្នកដ៏ចម្រើន លោកបានភិក្ខុហើយឬ ?" គេនិយាយថា "ក្នុងរឿងនិមន្តនេះ មានពាក្យនឹងត្រូវនិយាយច្រើន, និងមានប្រយោជន៍អ្វី ដោយពាក្យដែលនិយាយឱ្យច្រើននេះ" ។ ព្រះថេរៈទាំងឡាយ និយាយថា "ពួកយើងនឹងត្រាច់ទៅបិណ្ឌបាតស្អែកនេះ, គ្រានេះពួកលោកកុំប្រមាទ" ។

ក្នុងថ្ងៃស្អែក ព្រះសង្ឃថេរៈគប្បីប្រាប់ភិក្ខុទាំងឡាយ ដែលឈរធ្វើវត្តចំពោះចេតិយថា "លោកម្ចាស់ក្នុងស្រុកជិតមានសង្ឃភត្ត, តែមនុស្សមិនឆ្លាតបានទៅហើយ, និមន្តទៅចុះពួកយើងនឹងត្រាច់ទៅបិណ្ឌបាត ក្នុងស្រុកជិត" ។ ពួកភិក្ខុគប្បីធ្វើតាមពាក្យរបស់ព្រះថេរៈមិនគប្បី

ជាអ្នកប្រដៅក្រ, គប្បីត្រាច់ទៅបិណ្ឌបាត កុំឈរត្រង់ទ្វារស្រុកឡើយ ។ កាលអ្នកស្រុកទាំងនោះ ទទួលបាត្រនិមន្តឱ្យអង្គុយឆាន់ គប្បីឆាន់ចុះ ។ បើគេចាត់ដាក់ភត្តទុកត្រង់សាលាឆាន់ហើយត្រាច់ទៅប្រាប់ក្នុងថ្នល់ថា "និមន្តទទួលភត្តក្នុងសាលាឆាន់ លោកម្ចាស់" មិនសមគួរ ។

តែបើគេកាន់យកភត្តទៅក្នុងទីនោះ ៗ ប្រាប់ថា និមន្តទទួលភត្តចុះ ឬប្រញាប់នាំទៅកាន់វិហារតែម្តង ដាក់ទុកក្នុងទីដ៏សមគួរ ហើយប្រគេនដល់ពួកភិក្ខុដែលមកដល់ហើយ ៗ, ភិក្ខានេះ ឈ្មោះថា ភិក្ខាដែលគេនាំមកចំពោះ រមែងសមគួរ ។ តែបើគេត្រៀមទានទុកត្រង់រោងភត្ត ហើយទៅកាន់បរិវេណនោះ ៗ ទូលថា និមន្តទទួលភត្តឯរោងភត្ត មិនសមគួរ ។ តែពួកអ្នកស្រុកណា លុះឃើញពួកភិក្ខុចូលទៅបិណ្ឌបាត ក៏នាំគ្នា បោសសាលាឆាន់ និមន្តឱ្យអង្គុយឆាន់ក្នុងសាលាដូច្នោះ ។ មិនគប្បីបដិសេធជនទាំងនោះ ។ តែជនពួកណា ឃើញពួកភិក្ខុដែលមិនបានភិក្ខាក្នុងស្រុកកំពុងចេញចាកស្រុកទៅ ប្រាប់ថា "និមន្តទទួលភត្តចុះ លោកម្ចាស់" មិនគប្បីបដិសេធអ្នកទាំងនោះ ។ ឬថា មិនគប្បីត្រឡប់ បើពួកគេនិយាយថា "និមន្តត្រឡប់ចុះ លោកម្ចាស់ សូមនិមន្តទទួលភត្ត" នឹងត្រឡប់ទៅក្នុងបទដែលគេពោលថា "និមន្តត្រឡប់ចុះ" ក៏បាន ។

អ្នកស្រុកពោលថា "និមន្តត្រឡប់ចុះលោកម្ចាស់ ភត្តក្នុងផ្ទះឆ្អិនរួចហើយ, ភត្តក្នុងស្រុកឆ្អិនរួចហើយ" ។ នឹងត្រឡប់ទៅដោយគិតថា ភត្ត

ក្នុងផ្ទះនិងក្នុងស្រុក រមែងមានដើម្បីអ្នកណាមួយក៏បាន សមគួរ ។ គេពោលឱ្យសម្ព័ន្ធគ្នាដោយពាក្យថា និមន្តត្រឡប់ទៅទទួលភត្តចុះ ដូច្នេះ នឹងត្រឡប់ទៅមិនគួរ ។ សូម្បីក្នុងពាក្យដែលអ្នកស្រុកឃើញពួកភិក្ខុអ្នកកំពុងចេញពីរោងឆាន់ទៅដើម្បីត្រាច់បិណ្ឌបាត ហើយពោលថា "និមន្តអង្គុយចុះលោកម្ចាស់ សូមនិមន្តទទួលភត្ត" ដូច្នេះ ក៏ន័យនុ៎ះឯង ។

ភត្តប្រចាំ ហៅថា និច្ចភត្ត ។ អ្នកស្រុកនិយាយថា "និមន្តទទួលនិច្ចភត្ត" នឹងទទួលរួមគ្នាច្រើនរូប ក៏គួរ ។ សូម្បីក្នុងសលាកភត្តជាដើម ក៏ន័យនេះដែរ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា សញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

គណភោជនសិក្ខាបទវណ្ណនា ចប់

# ៣. បរម្បរភោជនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

## ពន្យល់រឿងបរម្បរភោជន

[១០៤] ពាក្យថា ន ខោ ឥធំ ឱរកំ ភវិស្សតិ យថា ឥមេ មនុស្សា សក្កច្ចំ ភត្តំ ករោន្តិ : មនុស្សទាំងឡាយធ្វើភត្តដោយគោរពតាមទំនងយ៉ាងណា នេះមិនមែនថោកថយឡើយ មានសេចក្ដីថា មនុស្សទាំងនេះធ្វើភត្តាហារ ដោយគោរពតាមទំនងដែលជាហេតុឱ្យព្រះសាសនានេះ ឬទានក្នុងព្រះសង្ឃមានព្រះពុទ្ធជាប្រធាននេះ ប្រាកដច្បាស់ នឹងមិនជាទានថោកថយឡើយ គឺ មិនមែនជាកុសលបន្តិចបន្តួចអាក្រក់ថោកទាបឡើយ ។

ពាក្យថា ភិរ ក្នុងបទដែលថា ភិរបតិកោ នេះ ជាឈ្មោះរបស់កុលបុត្រនោះ ។ ក៏កុលបុត្រនោះ គេហៅថា កិរបតិក: ព្រោះអត្ថថាជាអធិបតី (ជាធំ) ។ បានឮថា គេជាធំ ជាអធិបតី ឱ្យតម្លៃឈ្នួលប្រើកម្មករធ្វើការងារដោយកំណត់ជាប្រចាំខែ រដូវ និងឆ្នាំ ។ កម្មករអ្នកក្រលំបាកនោះ ពោលពាក្យថា ពធរា បដិយត្តា : ផ្លែពុទ្រា ខ្ញុំបានចាត់ចែងហើយ នេះ ដោយអំណាចវោហាររបស់មនុស្សលោក ។

បទថា ពធរមិស្សកេន : លាយដោយផ្លែពុទ្រា គឺ ផ្សំដោយផ្លែ

ពគ្រា ។

[១០៩] ពីរបទថា ឧស្សូរេ អាហរិយិត្ថ : ដែលគេនាំមកប្រគេនភិក្ខុនោះក្នុងពេលថ្ងៃពេក គឺ ទាយកនាំបិណ្ឌបាត មកប្រគេនថ្ងៃពេក ។ ការវិកប្បនេះថា ខ្ញុំឱ្យភត្តាហារដែលប្រាថ្នានឹងបានរបស់ខ្ញុំ ដល់លោកអ្នកមានឈ្មោះនេះ ឈ្មោះថា ការវិកប្បភត្តាហារ ។ ការវិកប្បភត្តាហារគួរទាំងចំពោះមុខ ទាំងកំបាំងមុខ ។ ឃើញ (ភិក្ខុ) ចំពោះមុខគប្បីពោលថា "ខ្ញុំវិកប្បដល់លោក" ហើយឆាន់ចុះ ។ មិនឃើញគប្បីពោលថា "ខ្ញុំវិកប្បដល់សហធម្មិកទាំង ៥ អ្នកមានឈ្មោះនេះ" ហើយឆាន់ចុះ ។ តែក្នុងអដ្ឋកថាទាំងឡាយមានមហាបច្ចរីជាដើម លោកពោលទុកតែវិកប្បកំបាំងមុខប៉ុណ្ណោះ ។ ក៏ព្រោះការវិកប្បភត្តាហារនេះ ទ្រង់សង្គ្រោះដោយវិន័យកម្ម; ដូច្នោះ ទើបមិនគួរវិកប្បដល់ព្រះមានព្រះភាគ ។ ពិតមែន កាលព្រះមានព្រះភាគគង់ប្រថាប់ក្នុងព្រះគន្ធកុដិក្តី គង់ប្រថាប់ក្នុងកណ្តាលសង្ឃក្តី កម្មនោះ ៗ ដែលសង្ឃរមភិក្ខុគ្រប់គណៈហើយធ្វើ ជាការធ្វើល្អហើយ ។ ព្រះមានព្រះភាគទ្រង់មិនធ្វើឱ្យខូចកម្ម ទ្រង់មិនធ្វើឱ្យកម្មបរិបូណ៌, ទ្រង់មិនធ្វើឱ្យខូចកម្ម ព្រោះព្រះអង្គមានភាពជាធំដោយធម៌, ទ្រង់មិនធ្វើឱ្យកម្មបរិបូណ, ក៏ព្រោះព្រះអង្គមិនបានជាគណបូរកៈ (អ្នកធ្វើគណៈឱ្យគ្រប់ចំនួន) ។

[១១១] ពាក្យថា ទ្វេ តយោ និមន្តនេ ឯកតោ ភុញ្ជតិ :

ដល់ភិក្ខុឆាន់នូវនិមន្តនភត្ត២-៣ ជាមួយគ្នា មានសេចក្តីថា ដាក់ចុះ គឺ រួមនិមន្តនភត្ត ២-៣ ចុះក្នុងបាត្រតែមួយ គឺ ធ្វើឱ្យរួមគ្នាតែមួយហើយឆាន់ ។

លោកពោលទុកក្នុងមហាបច្ចរីថា ត្រកូល ២-៣ ត្រកូល និមន្តភិក្ខុឱ្យអង្គុយក្នុងទីតែមួយកន្លែង ហើយនាំ (ភត្តាហារ) មកអំពីទីនេះនិងទីនោះ ហើយចាក់បាយ សម្លនិងម្ហូបក្រៀមជាមួយបាយចុះទៅ, ភត្តជារបស់សម្រូបចូលតែមួយ, មិនជាអាបត្តិក្នុងភត្តសម្រូបនេះ ។

ក៏បើថា និមន្តនភត្តគ្រាដំបូងនៅខាងក្រោម និមន្តនភត្តពេលក្រោយនៅខាងលើ, ជាអាបត្តិដល់ភិក្ខុដែលឆាន់និមន្តនភត្តពេលក្រោយនោះតាំងពីខាងលើចុះទៅ ។ តែមិនជាអាបត្តិដល់ភិក្ខុដែលឆាន់ដោយអាការយ៉ាងណាមួយ ចាប់ផ្តើមតាំងពីពេលលោកយកដៃលូកចុះទៅខាងក្នុងហើយចាប់ពំនូតបាយសូម្បីមួយពំនូតពីនិមន្តនភត្តគ្រាដំបូងឡើងមកហើយឆាន់ ។ លោកពោលទុកក្នុងមហាបច្ចរីថា សូម្បីបើថា ត្រកូលទាំងឡាយស្រោចទឹកដោះស្រស់ ឬរសចុះទៅក្នុងភត្តនោះ, ភត្តដែលត្រូវទឹកដោះស្រស់និងរសណាស្រោចសព្វ មានរសតែមួយដូចគ្នានឹងទឹកដោះស្រស់និងរសនោះ, មិនជាអាបត្តិដល់ភិក្ខុដែលឆាន់តាំងពីកំពូលចុះទៅ ។

តែក្នុងមហាអដ្ឋកថាពោលថា "ភិក្ខុបានខីរភត្ត (ភត្តលាយទឹកដោះស្រស់) ឬរសភត្ត (ភត្តមានរសសម្ល) អង្គុយហើយ សូម្បីពួក

អ្នកស្រុកដទៃចាក់ខីរភត្ត ឬ រសភត្ត (ដទៃ)ចុះទៅលើខីរភត្តនិងរសភត្ត នោះឯង (ទៀត), មិនជាអាបត្តិ ដល់ភិក្ខុដែលផឹកទឹកដោះស្រស់, ឬ រស, តែភិក្ខុដែលកំពុងឆាន់ នឹងបៀមដុំសាច់ឬដុំបាយដែលបានមុនចូលមាត់ ហើយឆាន់តាំងពីកំពូលចុះទៅ គួរ, សូម្បីក្នុងបាយបាយាសលាយទឹកដោះថ្លា ក៏ន័យនេះដូចគ្នា” ។

លោកពោលទុកក្នុងមហាអដ្ឋកថាថា ឧបាសកអ្នកជំនិមន្តភិក្ខុទុក, កាលភិក្ខុទៅកាន់ត្រកូលហើយ ឧបាសកក្តី អន្តោជនមានបុត្រ ភរិយា និងបងប្អូនប្រុស បងប្អូនស្រីរបស់ឧបាសកនោះក្តី នាំយកភត្តចំណែករបស់ខ្លួន ៗមកដាក់ក្នុងបាត្រ, ជាអាបត្តិ ដល់ភិក្ខុដែលមិនឆាន់ភត្តចំណែកដែលឧបាសកប្រគេនមុន ឆាន់ចំណែកដែលបានពេលក្រោយ ។ ក្នុងអដ្ឋកថាកុរុន្ទីពោលថា គួរ ។ ក្នុងមហាបច្ចរីពោលថា បើពួកគេចែកគ្នាចំអិន, នាំមកប្រគេនអំពីភត្តដែលចំអិនដើម្បីខ្លួន ៗ, បណ្តាភត្តទាំងនោះ ជាបាចិត្តិយ ដល់ភិក្ខុដែលឆាន់ភត្តដែលគេនាំមកពេលក្រោយមុន, តែបើពួកគេទាំងអស់ចំអិនរួមគ្នា, មិនជាបរម្បរភោជន ។

ឧបាសកអ្នកជំនិមន្តភិក្ខុឱ្យអង្គុយរង់ចាំ ។ អ្នកស្រុកដទៃនឹងទទួលយកបាត្រ, ភិក្ខុកុំគប្បីឱ្យ ។ គេសួរថា “ហេតុដូចម្តេច លោកម្ចាស់ទើបលោកមិនឱ្យ ?” គប្បីពោលថា “ឧបាសក លោកនិមន្តពួកយើងទុកមិនមែនឬ ?” គេពោលថា “ណ្ហើយចុះលោកម្ចាស់ និមន្តលោកឆាន់

របស់ដែលលោកបានហើយ ៗចុះ" ។ ទឹងឆាន់ ក៏គួរ ។ ក្នុងកុរុន្ទី ពោលថា កាលអ្នកជទៃនាំភត្តមកប្រគេន ភិក្ខុសូម្បីប្រាប់ហើយឆាន់ក៏គួរ ។ ពួកអ្នកស្រុកទាំងអស់ចង់ស្តាប់ធម៌ ទើបនិមន្តភិក្ខុដែលធ្វើអនុមោទនាហើយ ទឹងទៅថា បពិត្រលោកម្ចាស់ សូម្បីស្អែកនេះ ក៏និមន្តលោកមកទៀត ។ ក្នុងថ្ងៃស្អែក ភិក្ខុទឹងមកឆាន់ភត្តដែលបានហើយ ៗ គួរ ។ ព្រោះហេតុអ្វី ? ព្រោះអ្នកស្រុកទាំងអស់និមន្តទុក ។

ភិក្ខុមួយរូបត្រាច់ទៅបិណ្ឌបាតបានភត្តាហារមក ។ ឧបាសកជទៃនិមន្តភិក្ខុនោះឱ្យអង្គុយរង់ចាំនៅក្នុងផ្ទះ ទិងភត្តមិនទាន់សម្រេច ។ បើភិក្ខុនោះឆាន់ភត្តដែលខ្លួនត្រាច់បិណ្ឌបាតបានមក ជាអាបត្តិ ។ កាលលោកមិនឆាន់ អង្គុយចាំ, ឧបាសកសួរថា "ហេតុដូចម្តេច ទើបលោកម្ចាស់មិនឆាន់ ?" លោកពោលថា "ព្រោះលោកនិមន្តទុកហើយ" គេឆ្លើយប្រាប់ថា "និមន្តលោកម្ចាស់ឆាន់ភត្តដែលលោកបានហើយ ៗ ចុះ" ដូច្នេះ ទឹងឆាន់ក៏បាន ។

ពីរបទថា សកលេន គាមេន **:** អ្នកស្រុកទាំងអស់ មានសេចក្តីថា មិនជាអាបត្តិដល់ភិក្ខុដែលអ្នកស្រុកទាំងមូល រួមគ្នានិមន្តទុកប៉ុណ្ណោះ ដែលឆាន់នៅក្នុងទីកន្លែងណាមួយ ។ សូម្បីក្នុងពួកគណៈ ក៏ន័យនេះឯង ។

ពាក្យថា និមន្តិយមានោ ភិក្ខុំ គណ្ហិស្សាមីតិ ភណតិ **:** ដល់

ភិក្ខុដែលគេនិមន្តហើយពោលថា អាត្មាទទួលតែភិក្ខា មានសេចក្តីថា ភិក្ខុដែលត្រូវគេនិមន្តថា "និមន្តលោកទទួលភត្តាហារ" ពោលថា "អាត្មាមិនមានសេចក្តីត្រូវការភត្តរបស់លោក, អាត្មានឹងទទួលភិក្ខា" ។ ក្នុងពាក្យថា "ភត្តំ គណ្ហាតិ និមន្តិយមានោ ន មយ្ហំ តវ ភត្តេនត្ថោ, ភិក្ខំ គណ្ហិស្សាមីតិ វទតិ : ... "[១] នេះព្រះមហាបទុមថេរៈពោលថា ភិក្ខុដែលពោលយ៉ាងនេះ អាចធ្វើមិនឱ្យជានិមន្តនភត្ត ក្នុងសិក្ខាបទនេះបាន, តែបានធ្វើឱកាសដើម្បីប្រយោជន៍ដល់ការឆាន់; ព្រោះដូច្នោះ ភិក្ខុនោះ ទើបមិនផុតពីគណភោជន និងមិនផុតពីចារិត្តសិក្ខាបទ ។ ព្រះមហាសុមនត្ថេរពោលថា ភិក្ខុអាចនឹងធ្វើឱ្យមិនជានិមន្តនភត្ត ដោយចំណែកណា, មិនជាគណភោជនមិនជាចារិត្តៈ ដោយចំណែកនោះ ។ ពាក្យដ៏សេសដូចដែលពោលហើយនុ៎ះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងតាមមកកាយវាចា ១ កាយវាចាចិត្ត ១ ជាកិរិយានិងជាអកិរិយា, ពិតមែន ក្នុងកិរិយានិងអកិរិយានេះ ការឆាន់ជាកិរិយា ការមិនវិកប្បជាអកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បរម្បរភោជនសិក្ខាបទវណ្ណនា ចប់

---

១. ពាក្យប្រែនៅខាងលើបន្ទាប់ ។

# ៤. កាណមាតាសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

## ពន្យល់រឿងមាតារបស់នាងកាណា

[១១២] ពាក្យថា **កាណមាតា** គឺ មាតារបស់នាងកាណា ។ បានឮថា នាងកាណានោះ ជាធីតារូបល្អគួរសរសើររបស់អ្នកជាមាតានោះ ។ អធិប្បាយថា ជនពួកណា ៗឃើញនាង ពួកជននោះ ៗក្លាយជាមនុស្សខ្វាក់ ព្រោះសេចក្ដីតម្រេក គឺ ជាអ្នកងងឹតព្រោះរាគៈ ព្រោះហេតុនោះ នាងទើបបានប្រាកដឈ្មោះថា កាណា ព្រោះធ្វើជនទាំងនោះឱ្យជាអ្នកខ្វាក់ ។ សូម្បីមាតា ក៏ប្រាកដឈ្មោះថា កាណមាតា ដោយអំណាចនៃនាង ។

បទថា អាគតំ **:** ត្រឡប់មកវិញ គឺ ការមក ។

បទថា កិស្មឹ វិយ **:** ដូចម្ដេចនឹងកើត គឺ មើលម្ដេចបាន អធិប្បាយថា មើលទៅដូចជាគួរឱ្យខ្មាស ។

ពីរបទថា រិត្តហត្ថំ គន្តុំ **:** ទៅដោយដៃទទេ បានដល់ ក្នុងការទៅលើកនេះ មានដៃទាំងពីរទទេ (ព្រោះហេតុនោះ) ការទៅលើកនោះ ទើបឈ្មោះថា មានដៃទទេ ។ មានអធិប្បាយថា ការទៅដៃទទេនោះ ឃើញថា ជាការទៅដែលគួរឱ្យខ្មាស ។

ពីរបទថា បរិក្ខយំ អគមាសិ : **នំទាំងប៉ុន្មានក៏អស់គ្មានសល់** មានសេចក្តីថា ឧបាសិកា ជាអរិយសាវិកាឃើញភិក្ខុទាំងឡាយហើយ មិនអាចថា នឹងមិនប្រគេនរបស់ដែលមាន; ព្រោះហេតុនោះ ទើបឧបាសិកាបង្គាប់ឱ្យប្រគេននំទាំងអស់ ដរាបដល់អស់ទៅ ។

ក្នុងពាក្យថា ធម្មិយា កថាយ : **ដោយពុទ្ធភាសិតប្រកបដោយធម៌** នេះ មានវិនិច្ឆ័យថា សូម្បីនាងកាណាស្តាប់ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែង ដើម្បីប្រយោជន៍ដល់មាតា ក៏បានជាសោតាបន្នក្នុងវេលាចប់ទេសនា ។

ពីរបទថា ឧដ្ឋាយាសនា បក្កាមិ : **ហើយក្រោកចាកអាសនៈយាងទៅវិញ** មានសេចក្តីថា ព្រះមានព្រះភាគទ្រង់ក្រោកអំពីអាសនៈហើយស្តេចយាងទៅ ។ សូម្បីបុរសនោះ បានស្តាប់ថា "បានឮថា ព្រះសាស្តាបានស្តេចទៅផ្ទះរបស់មាតានាងកាណា" ទើបនាំនាងកាណាមកតាំងទុកក្នុងតំណែងតាមប្រក្រតីដើម ។

(១១៣) តែល្មមកាលរឿងកើតឡើងហើយ ព្រះមានព្រះភាគមិនទាន់បានបញ្ញត្តិសិក្ខាបទឡើយ រឿងស្បៀងមកក៏បានកើតឡើង ។ ព្រោះហេតុនោះ ដើម្បីសម្តែងរឿងនេះជាប់តគ្នាទៅនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ទើបបានពោលពាក្យថា តេន ខោ បន

សមយេន ជាដើម ។ សូម្បីឧបាសកនោះ ក៏បានបង្គាប់ឱ្យប្រគេនរបស់ទាំងអស់ដូចគ្នា ព្រោះខ្លួនជាអរិយសាវក ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យ ទើបបានពោលពាក្យថា បរិក្ខយំ អគមាសិ : ក៏អស់គ្មានសល់ ។

[១១៤] ពីរបទថា យង្កិញ្ចិ បហិណកត្ថាយ : វត្ថុអ្វីនីមួយដើម្បីបញ្ជូនទៅ មានសេចក្ដីថា អាហារវត្ថុយ៉ាងណាមួយ មាននំស្ងោរនិងនំដាក់ស្ករអំពៅ[១]ជាដើម ដែលមានរសល្អក្រៃលែង ដែលគេចាត់ត្រៀមទុក ដើម្បីត្រូវការជារបស់ជំនូន ដល់ការរាប់ថា នំទាំងអស់ក្នុងសិក្ខាបទនេះ ។

ពីរបទថា យង្កិញ្ចិ ធាេយ្យត្ថាយ : វត្ថុអ្វីនីមួយ ដើម្បីជាស្បៀង មានសេចក្ដីថា អាហារវត្ថុយ៉ាងណាមួយ មានសដូវដុំ សដូវផង់ល្ង និងអង្ករជាដើមទាំងអស់ដែលពួកអ្នកដំណើរ ចាត់ត្រៀមទុកដើម្បីត្រូវការជាស្បៀងតាមមក ដល់ការរាប់ថា "សដូវផង់" ទាំងអស់ក្នុងសិក្ខាបទនេះ ។

១.. អ្នកឥណ្ឌាហៅនំមោទកៈនេះថា "លឌ្ឌូ" ន័យថា ធ្វើពីម្សៅជាដុំមូល ៗ ខាងក្នុងដាក់ស្ករអំពៅ ឬស្ករត្នោត ដូចនំផ្លែអាយ ។

ពីរបទថា តតោ ចេ ឧត្តរឹ : បើហួសពីនោះទៅ មានសេចក្ដីថា បើភិក្ខុទទួលយកបាត្រទី ៣ ឱ្យកំពុងឡើងមក ( ឱ្យជាកំពូលឡើងមកដូចសថូប ) ជាបាចិត្តិយ ដោយយករាប់នំ ។

ពីរបទថា ទ្វិត្តិបត្តបូរេ បដិគ្គហេត្វា : គប្បីទទួលបានត្រឹមពេញពីរបីបាត្រ បានដល់ ទទួលបាត្រពេញស្មើស្នាមខាងក្រោមកណ្ដាប់មាត់បាត្រ ។

ក្នុងពាក្យថា អមុត្រ មយា ទ្វិត្តិបត្តបូរា : ក្នុងទីឯណោះ ខ្ញុំទទួល( នំឬសជូវ )ពេញពីរបីបាត្រមកហើយ, នេះ មានវិនិច្ឆ័យថា បើថា ភិក្ខុទទួលពេញ ២ បាត្រហើយ គប្បីប្រាប់ថា "ក្នុងស្ថានទីឯណោះខ្ញុំទទួលពេញ ២ បាត្រហើយ, លោកគប្បីទទួលតែមួយបាត្រ" ។ សូម្បីភិក្ខុដែលមកក្រោយនោះ ឃើញភិក្ខុដទៃហើយក៏គប្បីប្រាប់ថា "ភិក្ខុដែលមកដល់មុនទទួលពេញ ២ បាត្រហើយ, ខ្ញុំទទួលពេញមួយបាត្រ, លោកកុំទទួល" ។ សូម្បីក្នុងការដែលភិក្ខុទទួលមុនមួយបាត្រហើយប្រាប់គ្នាត ៗ ទៅ ក៏ន័យនេះឯង ។ ចំណែកភិក្ខុដែលទទួលនោះ គ្រប់ ៣ បាត្រហើយ ឃើញភិក្ខុដទៃគប្បីប្រាប់ថា "លោកកុំទទួលក្នុងផ្ទះនេះឡើយ" ដូច្នេះ ។

[១១៥] ពីរបទថា បដិក្កមនំ នីហរិត្វា : ក្នុងពេលត្រឡប់មក

**នាំយក (ទំបូសដូវ)នោះមកហើយ** គឺ នាំទៅកាន់រោងឆាន់, ក៏ភិក្ខុដែលនឹងទៅកាន់សាលាឆាន់ កុំគេចទៅសាលាដែលគេបោះបង់ចោល ។ គប្បីទៅក្នុងស្ថានទីដែលភិក្ខុសង្ឃចំនួនច្រើនអង្គុយនៅ ។ តែក្នុងមហាបច្ចរីពោលថា "រោងយ៉ាងណានៅជិតនឹងស្ថានដែលខ្លួនបានបិណ្ឌបាតមក គប្បីទៅត្រង់រោងដូច្នោះ, នឹងទៅក្នុងរោងឆាន់ដទៃដោយប្រាថ្នាថា "យើងនឹងប្រគេនដល់ភិក្ខុដែលធ្លាប់ឃើញគ្នា ធ្លាប់ជួបគ្នា ឬអ្នករួមនិកាយជាមួយគ្នារបស់ខ្លួន" រមែងមិនបាន, តែបើថា រោងដូច្នោះជាស្ថានទីដែលលោកអង្គុយជាប្រចាំ សូម្បីឆ្ងាយ ក៏គួរទៅ"

បទថា សំវិភជិតព្វំ : **ត្រូវចែកគ្នា** មានសេចក្តីថា បើភិក្ខុទទួលពេញ ៣ បាត្រហើយ គប្បីទុកមួយបាត្រដើម្បីខ្លួនឯង ហើយប្រគេនពេញ ២ បាត្រដល់ភិក្ខុសង្ឃ ។ បើទទួល ២ បាត្រគប្បីទុកដើម្បីខ្លួនមួយបាត្រ ហើយប្រគេនមួយបាត្រដល់សង្ឃ ។ តែរមែងមិនបានដើម្បីឱ្យតាមមិត្តសម្លាញ់ ។ ភិក្ខុដែលទទួលតែមួយបាត្រ មិនប្រាថ្នានឹងឱ្យអ្វីក៏មិនគប្បីឱ្យ គឺ គប្បីធ្វើតាមពេញចិត្ត ។

[១១៦] ពីរបទថា គមនេ បដិប្បស្សទ្ធេ : **មានដំណើរប្រុងនឹងទៅហើយខានវិញ** មានសេចក្តីថា កាលគេរម្ងាប់ គឺកាត់ការចេញទៅយ៉ាងនេះថា ឥឡូវនេះ យើងនឹងមិនបញ្ជូនទៅទេ ឬថា យើងនឹងមិន

ទៅទេ ដូច្នេះ ព្រោះឃើញអន្តរាយក្នុងចន្លោះមក ឬព្រោះមិនមានសេចក្តីត្រូវការ ។

ពីរបទថា ញាតកានំ បវារិតានំ : របស់ញាតិ របស់ជនដែលបវារណា បានដល់ មិនជាអាបត្តិដល់ភិក្ខុដែលទទួលរបស់ពួកញាតិ និងអ្នកបវារណាទាំងនោះ អ្នកប្រគេនសូម្បីច្រើន ។ តែក្នុងអដ្ឋកថាទាំងឡាយពោលថា គួរនឹងទទួលតែល្មមប្រមាណអំពីរបស់ដែលពួកញាតិនិងអ្នកបវារណាសូម្បីទាំងនោះ ចាត់ត្រៀមទុកដើម្បីត្រូវការជាស្បៀងតាមមក និងជារបស់រង្វាន់ ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

កាណមាតាសិក្ខាបទវណ្ណនា ចប់

# ៥. បឋមបវារណាសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

## ពន្យល់រឿងការហាមភត្ត

[១១៧] ច្រើនបទថា ភិក្ខូ ភុត្តាវី បវារិតា : ពួកភិក្ខុឆាន់ហើយ បានហាមភត្តហើយ មានសេចក្តីថា ភិក្ខុទាំងឡាយដែលព្រាហ្មណ៍បវារណា ដោយបវារណាល្មមដល់សេចក្តីត្រូវការយ៉ាងនេះថា "បពិត្រលោកដ៏ចម្រើន លោកទាំងឡាយ ចូរទទួលតាមសេចក្តីត្រូវការចុះ" និងហាមដោយខ្លួនឯងដោយករហាមគឺ ការបដិសេធថា "ប៉ុណ្ណឹងចុះ អាវុសោ ចូរប្រគេនតែបន្តិចបានហើយ" ។

បទថា បដិវិស្សកោ : ពួកជនជាអ្នកស្និទ្ធស្នាល គឺ ពួកសម្លាញ់ក្នុងស្រុកដែលនៅផ្ទះជិតខាង ។

[១១៨] បទថា កាកោរវសទ្ទំ : សំឡេងកញ្ជ្រៀវនៃក្អែក បានដល់ សំឡេងពួកក្អែកខ្ញៀវខ្ញារ គឺ សំឡេងហ្វូងសត្វក្អែករួមផ្គុំគ្នាស្រែកទ្រហឹងកងរំពង ក្នុងពាក្យថា អលមេតំ សព្វន្តិ : ភោជនទាំងអស់នេះ

---

ក្នុងសិក្ខាបទនេះ ស័ត្វទូទៅ និងឈ្មោះរុក្ខជាតិផ្សេង ៗ ប្រែតាមដែលអាចរកស័ត្វឃើញ, ស័ត្វណាប្រែមិនរួច សូមផ្ញើទុកឱ្យលោកអ្នកដឹងពិចារណា ពន្យល់ខែចុះ ។

សមគួរហើយ នេះទឹងមិនត្រាស់ តិ អក្សរឡើយ ត្រាស់ត្រឹមតែ **អលមេតំ** សព្វំ ប៉ុណ្ណេះ ក៏សមគួរ ។

បទថា កុត្តាវី : **ឆាន់ហើយ** គឺ ជាអ្នកឆាន់រួចស្រេច ។ ក៏ព្រោះភិក្ខុណាទំពាក់ដោយ មិនទំពាក់ដោយ លេបគ្រាប់បាយចូលទៅសូម្បីតែមួយគ្រាប់, ភិក្ខុនោះដល់ការរាប់ថា អ្នកឆាន់រួចហើយ ក្នុងបទថា កុត្តាវី នោះ ។ ព្រោះហេតុនោះ ក្នុងបទភាជនៈនៃបទនោះ ទើបត្រាស់ពាក្យថា កុត្តាវី នាម បញ្ចន្នំ ភោជនានំ : **ដែលហៅថា ឆាន់ហើយ គឺ ឆាន់ភោជន ៥ យ៉ាង** ដូច្នេះជាដើម ។

បទថា បវារិតោ : **ហាមភោជន** គឺ អ្នកមានការហាម (ភត្ត) ដែលធ្វើហើយ គឺ មានការបដិសេធដែលធ្វើហើយ ។ ក៏សូម្បីព្រោះការហាមនោះ មិនមែនថា ទឹងធ្វើសម្រេចបានដោយហេតុត្រឹមតែការបដិសេធ, ដោយពិត រមែងសម្រេចបានដោយអំណាចអង្គ ៥ ។ ព្រោះហេតុនោះ ក្នុងបទភាជនៈនៃបទនោះ ព្រះមានព្រះភាគត្រាស់ពាក្យថា បវារិតោ នាម អសនំ បញ្ញាយតិ : **ដែលហៅថា ហាមភោជន គឺ ភិក្ខុកំពុងឆាន់** ជាដើម ។

ព្រោះបណ្តាអង្គ ៥ នោះ ដោយអង្គថា អសនំ បញ្ញាយតិ : **ភិក្ខុកំពុងឆាន់** នេះ ភិក្ខុអ្នកឆាន់មិនទាន់ឈប់ ទើបហៅថា អ្នកហាមភត្ត,

ចំណែកភិក្ខុណា ឈ្មោះថា អ្នកឆាន់មិនទាន់ឈប់, ភោជនខ្លះភិក្ខុនោះឆាន់ហើយ ខ្លះមិនទាន់បានឆាន់, និងព្រោះសំដៅយកភោជនដែលលោកឆាន់ហើយ ទើបដល់ការរាប់ថា អ្នកឆាន់រួចហើយ; ព្រោះដូច្នោះ ដោយពាក្យថា ភុត្តាវី យើងទើបមិនឃើញសេចក្ដីសម្រេចប្រយោជន៍អ្វីមួយផ្សេង ៗ ក៏ពាក្យថា ភុត្តាវីនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហើយ ដោយភាពជាបទបរិវារនៃបទថា **បវារិតៈ** និងដោយភាពជាព្យញ្ជនៈពីរោះរណ្ដំ ( ស្រួលមាត់ ) ដូចពាក្យថា ២ យប់ជាដើម ក្នុងពាក្យថា ២-៣ យប់ ... ។ ៥-៦ ម៉ាត់ ... ជាដើម ។

[ ១១៩ ] ក្នុងអង្គថា អសនំ បញ្ញាយតិ ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ការឆាន់មិនទាន់ឈប់ប្រាកដ, អធិប្បាយថា បើបុគ្គលដែលកំពុងឆាន់នេះនៅមាន ។

អង្គថា ភោជនំ បញ្ញាយតិ : **គេនាំយកភោជនមកប្រគេនទៀត** បានដល់ ភោជនត្រឹមតែល្មមដល់ការហាមប្រាកដ ។ អធិប្បាយថា បើភោជនមានបាយជាដើមណាមួយ ដែលទឹងគប្បីហាមនៅមាន ។

អង្គថា ហត្ថបាសេ ឋិតោ : **គេនៅក្នុងហត្ថបាស** មានសេចក្ដីថា បើទាយកកាន់យកភោជនត្រឹមតែល្មមដល់ការហាមក្នុងឱកាសប្រមាណ ២ ហត្ថ ១ចំអាម ។

អដ្ឋកថា អភិហរតិ : **គេបង្អោនមកចំពោះ** មានសេចក្ដីថា បើទាយកនោះ បង្អោនភត្តនោះ ប្រគេនដល់ភិក្ខុនោះ ដោយកាយ ។

អដ្ឋកថា បដិក្ខេបោ បញ្ញាយតិ : **ភិក្ខុហាមភោជន** គឺ ការហាមប្រាកដ ។ មានអធិប្បាយថា បើភិក្ខុនោះបដិសេធភោជន ដែលគេបង្អោនប្រគេននោះ ដោយកាយក្ដី ដោយវាចាក្ដី ។ ភិក្ខុ រមែងជាអ្នកឈ្មោះថា ហាមភត្តហើយ ដោយអំណាចនៃអង្គ ៥ ដោយប្រការយ៉ាងនេះឯង ។ សមដូចពាក្យនេះដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលឧបាលី ការហាមភោជន ប្រាកដដោយអាការ ៥ យ៉ាង ។ អាការ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺការកំពុងឆាន់ប្រាកដ១ ភោជនប្រាកដ១ បុគ្គលឋិតនៅក្នុងហត្ថបាស១ បង្អោនមកប្រគេន១ ការហាមឃាត់ប្រាកដ១"[១] ។

## ភោជននិងធញ្ញជាតិ ៧ ប្រភេទ

ក្នុងបវារណាធិការនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អសនំ ជាដើមមុន ៖

ភិក្ខុឆាន់ភោជនណា និងហាមភោជនណា ដែលទាយកនៅក្នុងហត្ថបាសបង្អោនប្រគេន, ភោជននោះ បណ្ឌិតគប្បីជ្រាបថា ជាភោជន

១. វិន. បរិ. ឧបាលិបញ្ហក. ១៣. ២៥៨/២៨២ ។

ទាំងនេះ គឺ បាយ នំស្រស់ នំក្រៀម ត្រី សាច់ យ៉ាងណាមួយនុ៎ះឯង ។

បណ្តាភោជនមានបាយជាដើមនោះ ដែលឈ្មោះថា បាយ បាន ដល់ បាយដែលកើតអំពីធញ្ញជាតិ ៧ ប្រភេទ គឺ ស្រូវសាលី ស្រូវខ្សាយ ស្រូវដំណើប ស្រូវស្រងែ ស្រូវថ្លៅ ស្រូវស្កួយ ស្មៅគែលលក ។

បណ្តាធញ្ញជាតិ ៧ ប្រភេទ មានស្រូវសាលីជាដើមនោះ កំណើត ស្រូវសាលី សូម្បីគ្រប់ជំពូក ដោយហោចទៅ សូម្បីស្កួយ ក៏ឈ្មោះថា ស្រូវសាលី ។ កំណើតស្រូវខ្សាយសូម្បីគ្រប់ប្រភេទ ឈ្មោះថា វីហិ ។ ក្នុងស្រូវដំណើបនិងស្រូវស្រងែ មិនមានសេចក្តីផ្សេងគ្នា ។ គ្រាប់ស្រូវ ថ្លៅ មានពណ៌ស ពណ៌ក្រហម និងពណ៌ខ្មៅ សូម្បីគ្រប់ប្រភេទ ឈ្មោះ ថា កង្គុ ។ គ្រាប់ស្កួយ មានពណ៌ស សូម្បីគ្រប់ប្រភេទដែលលោកកាន់ យក ដោយហោចទៅ សូម្បីស្កួយនិងពោត ឈ្មោះថា វរកៈ ។ ស្មៅ គែលលកខ្មៅ និងតិណធញ្ញជាតិសូម្បីគ្រប់ប្រភេទ មានសាមាកជាដើម ឈ្មោះថា កុទ្រូសកៈ ។

អាចារ្យពួកខ្លះពោលថា ក៏ក្នុងពួកស្រូវសាលី និងស្កួយនេះ ស្កួយ និងពោត អនុលោមចូលនឹងធញ្ញជាតិ ។ ទោះជាធញ្ញជាតិឬធញ្ញជាតិ អនុលោមក្តី, ពួកអ្នកស្រុកយកអង្ករនៃធញ្ញជាតិទាំង ៧ មានប្រភេទដូច ពោលហើយនេះ ចំអិនសំដៅឱ្យជាភោជនយ៉ាងណាមួយថា យើងនឹង

ដាំបាយ ឬថា យើងនឹងដាំបបរ ឬថា យើងនឹងក្កូរបបរ ឬថា យើងនឹងក្កូរបាយបាយាសជូរជាដើម យ៉ាងណាមួយក្តី ។ បើកាលពួកភិក្ខុឆាន់ភត្តនោះ ទោះជាក្តៅឬត្រជាក់ក៏ដោយ ស្អាម រមែងប្រាកដក្នុងទីដួសយក ឬដួសយកក្នុងវេលាឆាន់ភត្តនោះ ក៏ដល់ការសង្គ្រោះជាបាយតែម្តង បន្តុំឱ្យកើតការហាម (ភត្ត), បើស្អាមមិនប្រាកដ, ដល់ការសង្គ្រោះចូលជាយាគូ, មិនឱ្យកើតការហាម (ភត្ត) ។

បាយបាយាស ឬបបរយាគូដែលផ្សំដោយស្លឹកឈើ ផ្លែឈើ និងពន្លកឈើ ត្រអៅ សូម្បីយ៉ាងណា លុះមលើកចុះអំពីចង្ក្រានទៅក្តៅ, អាចនឹងហុត (ផ្ទៀងផ្ទាំងផឹក)បាន សូម្បីក្នុងឱកាសដែលមានដៃក្បង់យក ក៏មិនសម្តែងស្អាម(ឱ្យប្រាកដ), យាគូជាដើមនោះ មិនឱ្យកើតការហាម (ភត្ត) ។ តែបើចំហាយកម្តៅអស់ទៅរហូតដល់ត្រជាក់ហើយ បើកករឹងជាដុំ សម្តែងស្អាមឱ្យប្រាកដ, ត្រឡប់បន្តុំឱ្យកើតការ ហាម (ភត្ត) បាន ។ ភាពជារបស់រាវ ៗក្នុងខាងដើមរក្សា (អាបត្តិ) មិនបាន ។

បើគេថែមទឹកដោះជូរ និងខ្ទាញ់ជាដើមចុះទៅហើយ ដាក់បន្លែផ្លែឈើនិងពន្លកឈើជាច្រើនចុះទៅ បន្ថែមអង្ករចុះទៅសូម្បីត្រឹមតែមួយក្តាប់ ។ បើក្នុងវេលាឆាន់មានស្អាមប្រាកដ, បន្តុំឱ្យកើតការហាម(ភត្ត) ។

# ភោជនផ្សេងៗ ជាហេតុហាមនិងមិនហាមភត្ត

ក្នុងនិមន្តនភត្ត មិនមានយាគូ អ្នកស្រុកចាក់ទឹកបាយ និង ទឹកដោះស្រស់ចុះទៅក្នុងភត្ត ដោយតាំងចិត្តថា នឹងប្រគេនយាគូ ហើយប្រគេនថា និមន្តលោកទទួលយាគូ ។ សូម្បីយាគូជារបស់រាវក៏ពិត, តែក៏បង្ករឱ្យកើតការហាម (ភត្ត) ដែរ ។ ក៏បើថា ពួកគេដាក់ (បាយ) ចុះក្នុងទឹកដែលក្តៅឧណ្ហៗជាដើម ចំអិនប្រគេន, ភោជននោះក៏ដល់ការសង្គ្រោះចូលជាយាគូដូចគ្នា ។ គេដាក់ត្រី សាច់ ចុះក្នុងភត្តសូម្បីដល់ការសង្គ្រោះចូលជាយាគូនោះ ឬក្នុងយាគូដទៃណា, បើដុំត្រី និងសាច់ ឬសរសៃប្រាកដ សូម្បីប្រមាណប៉ុនគ្រាប់ស្ពៃ, យាគូនោះ បង្ករឱ្យកើតការហាម (ភត្ត)ដែរ ។ អាហារមានរសសុទ្ធៗ ឬយាគូមានរសមិនឱ្យកើតការហាមភត្ត ។ សូម្បីភត្តដែលជនពួកណាមួយ ធ្វើដោយវត្ថុមានផ្លៃ ឬស្សីជាដើមយ៉ាងដទៃ វៀរលែងតែអង្ករនៃធញ្ញជាតិដែលពោលហើយចេញ ឬដោយក្រអៅ មើម និងផ្លែឈើ រមែងមិនបង្ករ ឱ្យកើតការហាម (ភត្ត) ។ ចាំបាច់ពោលទៅថ្វីដល់យាគូខាប់ ។ តែបើគេដាក់ត្រី សាច់ ចុះក្នុងយាគូនេះ ធ្វើឱ្យកើតការហាម(ភត្ត)បាន ។

ក្នុងមហាបច្ចរីពោលថា សូម្បីភត្តដើម្បីប្រយោជន៍ដល់ខុត្តី[១] ក៏ធ្វើ

---

១. ខុត្តី ស័ត្តុនេះ មិនជ្រាបថា អ្វី ? ទើបប្រែប្រថាប់ស័ត្តុទុក ។

ឱ្យកើតការហាម ( ភត្ត ) ។ លោកហៅអន្នរដែលដាក់ចុះក្នុងទឹកក្តៅចំហុយ ( បបរ ) ឱ្យឆ្អិន ដើម្បីប្រយោជន៍ដល់បង្អែមខុព្វី ឈ្មោះថា ភត្ត ដើម្បីប្រយោជន៍ដល់ខុព្វី[១] ។ ក៏បើហាលបាយទាំងនោះ ឱ្យស្ងួតហើយឆាន់គួរ ។ បាយទាំងនោះ មិនដល់ការរាប់ថា នំក្រៀម ( និង ) មិនដល់ការរាប់ថា ភត្តឡើយ ។ តែភត្តដែលគេធ្វើដោយបាយចំហុយហើយទាំងនោះទៀត ហាម ( ភត្ត ) តែម្តង ។ ជនទាំងឡាយចាក់បាយទាំងនោះ ក្នុងទឹកដោះថ្លា និងប្រេងជាដើម ឬធ្វើជានំ មិនហាម ( ភត្ត ) អំបុកក្តី នំក្រៀម និងបាយដែលធ្វើអំពីបាយចំហុយទាំងនោះក្តី មិនហាម ( ភត្ត ) ។

នំកុម្មាស ដែលគេធ្វើអំពីពួកស្រូវខ្សាយ ឈ្មោះថា នំស្រស់ ។ នំកុម្មាសដែលគេធ្វើអំពីវត្ថុដទៃ មានសណ្តែកបាយជាដើម មិនឱ្យកើតការហាម ( ភត្ត ) ។

នំក្រៀមដែលគេធ្វើពីពួកស្រូវសាលី ស្រូវខ្សាយ និងស្រូវដំណើប ឈ្មោះថា សត្តុ ។ ជនទាំងឡាយលីងគ្រាប់ស្រូវខ្ចៅ ស្លួយ និងស្មៅគែលលក ហើយអុំពោយអង្កាមចេញហើយកិនឱ្យល្អិតម៉ដ្ឋធ្វើជាម្សៅ ។ ប្រសិនបើថា វត្ថុនោះនៅជាប់គ្នា ព្រោះនៅស្រស់ ក៏ដល់ការសង្គ្រោះ

១. មិនដឹងថា ភត្តប្រភេទណា ? លក្ខណៈស្រដៀងបាយខៅតាក ជាស្បៀងទុកដើម្បីបរិភោគពេលអត់អាហារ ។

ចូលជានំក្រៀមតែម្តង ។ គេកិនអង្ករខ្សាយដែលលីងឱ្យឆ្អិនស្រួយប្រគេន ។ សូម្បីម្សៅនោះ ក៏ដល់ការសង្គ្រោះចូលជាសដូវ ( នំក្រៀម ) ដែរ ។

ចំណែកអង្ករនៃស្រូវខ្សាយ ដែលគេលីងឱ្យឆ្អិនស្មើគ្នា ឬនៃបាយស្រួយ ( ដែលមិនបានលីង ) ឬអង្ករដែលលីងទៅហើយទូទៅ មិនហាម ( ភត្ត ) ។ តែម្សៅអង្ករទាំងនោះ ហាម ( ភត្ត ) បាន ។ សូម្បីកន្ទក់របស់ស្រូវដំណើបដែលគេលីងឱ្យក្រៀមហើយ ក៏ហាម ( ភត្ត ) បាន ។ ចំណែកកន្ទក់នៃស្រូវដែលគេលីងឱ្យឆ្អិនស្មើគ្នា ឬឆ្អិនព្រោះកម្តៅថ្ងៃ មិនហាម ( ភត្ត ) ។

លាជឬបាយក្រៀម និងនំក្រៀមជាដើម ដែលគេធ្វើអំពីលាជពួកនោះ រមែងមិនហាម ( ភត្ត ) ។ ម្សៅដែលលីងហើយ ឬរបស់ទំពាសុទ្ធ ៗប្រភេទណាមួយ មិនហាម ( ភត្ត ) ។ តែរបស់ទំពាដែលបញ្ចុះត្រីសាច់ ( មានត្រីសាច់នៅខាងក្នុង ) ក្តី សដូវឆៅឬសដូវដុំមិនចូលភ្លើង[1] ( ដុំនំក្រៀមមិនទាន់ចំអិនក្តី ) រមែងហាម ( ភត្ត ) ចំណែកត្រី សាច់ប្រាកដច្បាស់ហើយឯង ។ តែមានសេចក្តីប្លែកគ្នាដូចតទៅនេះ ៖

ប្រសិនបើកាលភិក្ខុកំពុងផឹកយាគូ អ្នកស្រុកប្រគេនដុំត្រី ឬដុំសាច់

---

១, សារត្ថទីបនី ៣/៣២៣ ឆ្លើយថា សត្តុមោទកោតិសត្តុយោ បិណ្ឌេត្វា កតោ អបក្កោ សត្តុគុឡោ សដូវឆៅ ឬ សដូវដុំដែលគេសូនបាយសដូវផងជាដុំ មិនទាន់ចូលភ្លើង ឈ្មោះថា សត្តុមោទកៈ ។

មួយមុខ ៗ ២ ដុំ មានខ្នាតប៉ុនគ្រាប់យាគូទុំៈឯង ក្នុងភាជនៈជាមួយគ្នា ឬក្នុងភាជនៈផ្សេងគ្នា, បើភិក្ខុមិនឆាន់ដុំត្រីសាច់ទាំងនោះ ហាមភោជន យ៉ាងណាមួយដទៃ ដែលល្មមដល់ការហាមភត្ត មិនឈ្មោះថា ហាម (ភត្ត) ។ បណ្ដាដុំទាំង ២ នោះ លោកឆាន់ដុំមួយហើយ មួយដុំទៀត នៅក្នុងដៃ ឬក្នុងបាត្រ ។ បើលោកហាមមំសៈដទៃ ឈ្មោះថា ហាម (ភត្ត) ។

ទាំង ២ ដុំនោះលោកឆាន់អស់ហើយ, ក្នុងមាត់សូម្បីប៉ុនគ្រាប់ ស្ពៃក៏មិនមានសល់ ។ សូម្បីបើលោកហាមមំសៈដទៃ មិនឈ្មោះថា ហាម (ភត្ត) ។

ភិក្ខុកំពុងឆាន់កប្បិយមំសៈ ហាមកប្បិយមំសៈ ឈ្មោះថា ហាម (ភត្ត) កំពុងឆាន់កប្បិយមំសៈ ហាមអកប្បិយមំសៈ មិនឈ្មោះថា ហាម (ភត្ត) ។ ព្រោះហេតុអ្វី ? ព្រោះមិនមែនវត្ថុ ។ ពិតមែន មំសៈដែលភិក្ខុគួរឆាន់បានប៉ុណ្ណោះ ទើបជាហេតុហាមភត្តដល់ភិក្ខុដែល ហាម ។ តែកាលភិក្ខុដឹងអកប្បិយមំសៈនេះ ទើបហាមចេញព្រោះជា របស់មិនគួរ ។ សូម្បីមិនដឹង ក៏ឈ្មោះថា ហាមវត្ថុដែលតាំងនៅក្នុង ឋានៈដែលគួរហាមតែម្ដង; ព្រោះហេតុនោះ ទើបមិនឈ្មោះថា ហាម (ភត្ត) ។

តែបើភិក្ខុឆាន់អកប្បិយមំសៈ ហាមកប្បិយមំសៈ ឈ្មោះថា

ហាម (ភត្ត) ព្រោះហេតុអ្វី ? ព្រោះជាវត្ថុ (នៃការហាម) ។ ពិតមែន មំសៈ ដែលភិក្ខុនោះហាមនោះឯង ជាវត្ថុ (ទីតាំង) នៃការហាមភត្ត ។ ចំណែកអកប្បិយមំសៈដែលភិក្ខុឆាន់តាំងនៅក្នុងឋានដែលគួរហាម សូម្បីក៏ពិត, តែបើថា មំសៈដែលកំពុងឆាន់ ក៏មិនទាន់លះភាវៈនៃមំសៈ; ព្រោះហេតុនោះ ទើបឈ្មោះថា ហាម(ភត្ត) ។ ឆាន់អកប្បិយមំសៈ ហាមអកប្បិយមំសៈ មិនឈ្មោះថា ហាម(ភត្ត) ដោយន័យមុននុ៎ះឯង ។

ឆាន់កប្បិយមំសៈក្ដី អកប្បិយមំសៈក្ដី ហាមភោជនទាំង ៥ យ៉ាងណាមួយ ដែលជាកប្បិយភោជន ឈ្មោះថា ហាម (ភត្ត) ។ ហាមអកប្បិយភោជន ដែលកើតអំពីមិច្ឆាជីវមានកុលទូសកកម្ម វេជ្ជកម្ម ការអួតឧត្តរិមនុស្សធម្ម និងការត្រេកអរប្បិយៈជាដើម (និង) ដែលកើតពីការស្វែងរកមិនសមគួរដែលព្រះពុទ្ធទ្រង់រង្កៀស មិនឈ្មោះថា ហាម (ភត្ត) ។

សូម្បីកំពុងឆាន់កប្បិយភោជនក្ដី អកប្បិយភោជនក្ដី ហាមកប្បិយភោជន ឈ្មោះថា ហាម (ភត្ត) ។ ហាមអកប្បិយភោជន មិនឈ្មោះថា ហាម (ភត្ត), បណ្ឌិតគប្បីជ្រាបហេតុក្នុងគ្រប់ ៗបទយ៉ាងនេះ ដោយន័យដូចពោលហើយនុ៎ះឯង ។

## ការឆាន់និងការហាមភោជន

បណ្ឌិតកាលជ្រាបភោជនដែលភិក្ខុឆាន់ ក្នុងពាក្យថា អសនំ ជាដើម និងភោជនដែលទាយកនៅក្នុងហត្ថបាសបង្អោនប្រគេន កាលភិក្ខុហាម ទើបដល់ការហាម (ភត្ត)ដោយន័យដូចពោលមកយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីជ្រាបអាការដែលជាហេតុឱ្យដល់ (ការហាមភត្ត) គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អសនំ ភោជនំ នេះមុន ៖

ភិក្ខុណាលេបភត្តចូលទៅ សូម្បីគ្រាប់តែមួយ, បណ្តាភោជនទាំង ៥ ភោជនណាមួយមាននៅក្នុងបាត្រ មាត់ និង ដៃ ទីណាមួយ ភិក្ខុនោះហាមភោជនទាំង ៥ សូម្បីយ៉ាងណាមួយដទៃ ក៏ឈ្មោះថា ហាម (ភត្ត) ។ មិនមានភោជនក្នុងទីណា ៗ មានបាត្រជាដើម, ប្រាកដត្រឹមតែក្លិនអាមិស, មិនឈ្មោះថា ហាម (ភត្ត) ។ មិនមានភោជនក្នុងមាត់និងក្នុងដៃ, តែមាននៅក្នុងបាត្រ, ចំណែកភិក្ខុមិនប្រាថ្នា នឹងឆាន់ត្រង់អាសនៈនោះ ប្រាថ្នានឹងចូលទៅកាន់វិហារហើយឆាន់ ឬប្រាថ្នាប្រគេនដល់ភិក្ខុដទៃ, បើបដិសេធភោជនយ៉ាងណាមួយក្នុងចន្លោះនោះ មិនទាន់ចាត់ហាម (ភត្ត) ។ ព្រោះហេតុអ្វី ? ព្រោះភាពជាភោជន ដែលឆាន់ពាក់កណ្តាលនោះ ដាច់ទៅ ។

ក្នុងមហាបច្ចរីពោលទុកថា សូម្បីភិក្ខុណាប្រាថ្នានឹងទៅឆាន់ក្នុងទីដទៃ លេបភត្តក្នុងមាត់ហើយ កាន់យកចំណែកនៅសល់ដើរទៅ ហាមភោជនដទៃក្នុងចន្លោះមក, ការហាមភត្តសូម្បីរបស់ភិក្ខុនោះ ក៏មិនមាន ។

ក៏បើថា ភិក្ខុមិនប្រាថ្នានឹងលេបចូលទៅភោជនដែលមាន សូម្បីក្នុងដៃ ឬសូម្បីក្នុងមាត់ដូចក្នុងបាត្រ, និងហាមភោជនដទៃក្នុងខណៈនោះ មិនឈ្មោះថា ហាម( ភត្ត ) ។ ពិតមែន លក្ខណៈដែលពោលទុកហើយក្នុងបទតែមួយ ជាលក្ខណៈដែលបណ្ឌិតគួរជ្រាបក្នុងគ្រប់ ៗបទ ។

ម្យ៉ាងទៀត ក្នុងកុរុន្ទីក៏បានសម្តែងន័យនេះទុកដូចគ្នា ។ សមដូចដែលលោកពោលទុកក្នុងកុរុន្ទីនោះថា ភិក្ខុលេបភត្តក្នុងមាត់ហើយ ប្រាថ្នានឹងឱ្យភត្តក្នុងដៃដល់អ្នកស៊ីដែល ប្រាថ្នានឹងឱ្យភត្តក្នុងបាត្រដល់ភិក្ខុ, បើហាម ( ភោជនដទៃ ) ក្នុងខណៈនោះ មិនឈ្មោះថា ហាម ( ភត្ត ) ។

## អង្គទាយកនៅក្នុងហត្ថបាសបង្អោនប្រគេន

ក៏ក្នុងពាក្យថា ហត្ថបាសេ ឋិតោ : គេនៅក្នុងហត្ថបាស នេះ មានវិនិច្ឆ័យដូច្នេះ ៖

២ ហត្ថ ១ចំអាម គប្បីជ្រាបថា ហត្ថបាស បើភិក្ខុអង្គុយកំណត់តាំងពីជាយបំផុតផ្នែកក្រោយរបស់អាសនៈទៅ បើឈរកំណត់តាំងពីទីបំផុតកែងជើងទៅ បើដេកកំណត់តាំងពីទីបំផុតផ្នែកឆ្អឹងខ្នងដែលដេកទៅ

ដោយហោចទៅ ផ្ទៃកក្ដុងនៃអវយវៈដែលជិតជាង វៀរដៃដែលលាត ចេញរបស់ទាយកដែលអង្គុយក្ដី ឈរក្ដី ដេកក្ដី ។ ការហាមភត្ត រមែង មានដល់ភិក្ខុអ្នកហាមភោជន ដែលទាយកនៅក្នុងហត្ថបាសនោះ បង្អោន ប្រគេនប៉ុណ្ណោះ, ក្រៅអំពីនោះទៅ មិនមានទេ ។

បទថា អភិហរតិ : **គេបង្អោនភោជនមកចំពោះ** មានសេចក្ដីថា ទាយកនៅខាងក្នុងហត្ថបាសបង្អោន (ភោជន)ចូលទៅដើម្បីទទួល (ប្រគេន) ។ ក៏បើថា ភិក្ខុដែលអង្គុយបន្ទាប់ មិននាំបាត្រដែលនៅក្នុង ដៃ ឬដែលដាក់នៅលើភ្លៅ ឬ លើជើងបាត្រចេញទៅឡើយ ពោលថា និមន្តលោកទទួលភត្តាហារ កាលភិក្ខុបដិសេធភត្តនោះ មិនជាការហាម (ភត្ត) ។ សូម្បីក្នុងទាយកអ្នកនាំល្អិភត្តមកដាក់លើផែនដីខាងមុខ ហើយពោលថា "និមន្តលោកម្ចាស់ទទួលចុះ" ក៏ន័យនេះដូចគ្នា ។

តែកាលគេចាប់លើកឡើង ឬបង្អោនចូលទៅពោលថា "និមន្ត លោកម្ចាស់ ទទួលចុះ" កាលភិក្ខុបដិសេធ ចាត់ជាការហាម (ភត្ត) ។ ព្រះថេរៈអង្គុយនៅលើថេរាសនៈ បញ្ជូនបាត្រទៅឱ្យដល់ភិក្ខុកម្លោះអ្នក អង្គុយនៅក្នុងទីឆ្ងាយ ពោលថា "លោកចូរទទួលយកបាយអំពី បាត្រនេះ" ។ ចំណែកភិក្ខុដែលទទួល(បាត្រ) ទៅឈរស្ងៀម, ភិក្ខុ កម្លោះហាមថា "ខ្ញុំល្មមហើយ" មិនឈ្មោះថា ហាម (ភត្ត) ។ ព្រោះ

ហេតុអ្វី ? ព្រោះព្រះថេរៈនៅឆ្ងាយ និងព្រោះទូតមិននាំទៅឱ្យ ។ បើភិក្ខុដែលទទួល(បាត្រ) មកពោលថា “លោកចូរទទួលភត្តនេះ” កាលភិក្ខុកម្លោះបដិសេធភត្តនោះ ចាត់ជាការហាម (ភត្ត) ។

ក្នុងស្ថានទីអង្គាស ទាយកម្នាក់អង្គាសភិក្ខុច្រើនរូប ដៃម្ខាងកាន់ល្ពីបាយ ម្ខាងទៀតកាន់វែក ។ បើក្នុងស្ថានទីអង្គាសនោះ មានអ្នកដទៃមកនិយាយថា ខ្ញុំនឹងជួយកាន់ល្ពី, លោកចូរប្រគេនបាយ ហើយធ្វើកិច្ចត្រឹមតែចាប់ប៉ុណ្ណោះ, ក៏ទាយកអ្នកអង្គាសនុ៎ះឯង លើកល្ពីបាយនោះ; ព្រោះដូច្នោះ ល្ពីនោះ ចាត់ថា ដែលគេនាំមកចំពោះពិត ។ ចាត់ជាការហាម (ភត្ត) ដល់ភិក្ខុដែលហាមអ្នកអង្គាស អ្នកកាន់(ភត្ត) អំពីល្ពីនោះ ដោយជាអ្នកមានសេចក្តីត្រូវការនិងប្រគេន ។ តែបើអ្នកអង្គាសត្រឹមតែប៉ះពាល់(ល្ពី)ប៉ុណ្ណោះ, អ្នកក្រៅនេះឯងជួយលើកល្ពីនោះ, មិនចាត់ថាជាការហាម(ភត្ត) ដល់ភិក្ខុដែលហាមអ្នកអង្គាស ដែលកាន់(ភត្ត) អំពីល្ពីនោះដោយជាអ្នកមានបំណងនឹងប្រគេន ។ តែល្មមគេយកវែកដួសភត្ត (ការហាមភត្ត) រមែងមានដល់ភិក្ខុដែលហាម ។ ពិតមែន ការបង្អោនចូលមកដោយត្រង់ដោយវែកនុ៎ះឯង ចាត់ជាការបង្អោនប្រគេនភត្តនោះ ។ ក្នុងមហាបច្ចរីពោលថា សូម្បីក្នុងភត្តដែលមនុស្ស ២ នាក់ជួយគ្នាលើក កាលភិក្ខុបដិសេធ រមែងឈ្មោះថា ហាមភត្តដូចគ្នា ។

កាលទាយកប្រគេនភត្តដល់ភិក្ខុដែលអង្គុយបន្ទាប់ ភិក្ខុមួយរូប

ទៀត យកដៃបិទបាត្រមិនជាការហាម (ភត្ត) ។ ព្រោះហេតុអ្វី ? ព្រោះហាមភត្តដែលគេបង្អោនប្រគេនភិក្ខុរូបដទៃ ។

## ការហាមភត្តមានការហាមដោយកាយជាដើម

ក្នុងពាក្យថា បដិក្ខេបោ បញ្ញាយតិ : ភិក្ខុហាមភោជន នេះ គប្បីជ្រាបវិនិច្ឆ័យថា ភិក្ខុបដិសេធភត្ត ដែលគេប្រាប់ប្រគេនដោយវាចា មិនចាត់ជាការហាម (ភត្ត), តែកាលភិក្ខុបដិសេធដោយកាយ ឬដោយវាចានូវភត្តដែលគេបង្អោនប្រគេនដោយកាយ ទើបជាការហាមភត្ត ។

ក្នុងការហាមដោយកាយនិងវាចានោះ ដែលឈ្មោះថា ការហាមដោយកាយ គឺ ភិក្ខុរាដៃ ឬបក់ដៃ ឬបក់ជាយចីវរដេញ ធ្វើអាការក្រញូវ ឬសម្លឹងមើលដោយក្រោធ ។ ដែលឈ្មោះថា ហាមដោយវាចា គឺ ភិក្ខុពោលថា "ល្មមហើយ ឬថា ខ្ញុំមិនទទួល ថា កុំចាក់ចុះ ឬថា ចូរថយទៅ" ។ កាលភិក្ខុហាមភត្តដោយកាយ ឬដោយវាចា ដោយអាការណាមួយ យ៉ាងនេះ ឈ្មោះថា ការហាម (ភត្ត) ។

ភិក្ខុមួយរូប កាលទាយកបង្អោនប្រគេនភត្ត ខ្ពចចំពោះការហាមភត្ត ទាញដៃចេញនិយាយចំពោះជនអ្នកចាក់បាយចុះក្នុងបាត្រហើយ ហើយពោលថា លោកចូរចាក់ទៅ ៗ ចូរញាត់ទៅ ៗ បញ្ចូលឱ្យពេញ, សួរថា ក្នុងពាក្យនេះនិងថា យ៉ាងណា ?

ព្រះមហាសុមនត្ថេរពោលថា ចាត់ជាការហាម (ភត្ត) ព្រោះភិក្ខុនិយាយដើម្បីមិនចាក់ចូល ។

ព្រះមហាបទុមត្ថេរពោលថា ធម្មតាភិក្ខុដែលពោលថា "ចូរចាក់ទៅ ៗ ចូរញាត់ទៅ ៗ បញ្ចូលឱ្យពេញ" ដូច្នេះ, ភិក្ខុរូបខ្លះក៏ឈ្មោះថាហាម (ភត្ត) ហើយទើបពោលថា មិនទាន់ឈ្មោះថា ហាម (ភត្ត) ។

ភិក្ខុមួយរូបទៀត សង្កេតឃើញភិក្ខុដែលកំពុងនាំភត្តទៅ ពោលថា អ្នកមានអាយុ លោកនឹងទទួលអ្វីយ៉ាងណាមួយអំពីបាត្ររបស់ខ្ញុំនេះខ្លះទេ ? ខ្ញុំនឹងប្រគេនអ្វី ដល់លោកទេ ? ក្នុងពាក្យសួរនោះ ព្រះមហាសុមនត្ថេរក៏ពោលថា ចាត់ជាការហាម (ភត្ត)ព្រោះភិក្ខុនោះពោលដោយតាំងចិត្តថា "ភិក្ខុនេះនឹងមិនមក (កាន់លំនៅរបស់យើង) ដោយករពោលយ៉ាងនេះ" ។

ចំណែកព្រះមហាបទុមត្ថេរពោលថា ធម្មតាភិក្ខុដែលពោលថា លោកនឹងទទួលទេ ? រូបខ្លះក៏ជាការហាម (ភត្ត) ទើបពោលថា មិនទាន់ឈ្មោះថា ហាមភត្ត ។

ទាយកម្នាក់បង្អោនប្រគេនរសមានសាច់ ពោលថា និមន្តលោកទទួលរសចុះ ។ កាលភិក្ខុបានស្តាប់ពាក្យនោះហើយបដិសេធទៅ មិនចាត់ជាការហាម (ភត្ត) កាលគេពោលថា រសត្រី រសសាច់ ជាការហាមភត្តដល់ភិក្ខុដែលបដិសេធ ។ សួម្បីកាលគេពោលថា សូមនិមន្ត

លោកទទួលរសត្រីសាច់នេះ ក៏ជាការហាមភត្តដល់ភិក្ខុដែលបដិសេធដូចគ្នា ។ គេចែកសាច់ទុកផ្សេងដទៃពោលថា និមន្តលោកទទួលរសមានសាច់ ។ បើថា ក្នុងរសនោះមានដុំសាច់សូម្បីប៉ុនគ្រាប់ស្ពៃ, ជាការហាមភត្តដល់ភិក្ខុដែលបដិសេធរសនោះ ។ តែបើជារសដែលគេត្រងហើយគួរពិត ដូច្នេះឯង ។

ព្រះអភយត្ថេរពោលថា ព្រះមហាថេរៈពោលថា "ចូរវង់ចាំមួយភ្លែត" ចំពោះអ្នកសួរដោយអើពើដោយរសសាច់ ហើយពោលថា "នាំជាសមកចុះ" តើក្នុងពាក្យនេះ ទឹងពោលយ៉ាងណា ?

ព្រះមហាសុមនថេរៈពោលទុកមុនថា ការទៅរបស់អ្នកបង្អោនប្រគេន ( ភត្ត ) ដាច់ទៅមុនហើយ; ព្រោះដូច្នោះ ទើបឈ្មោះថា ហាម ( ភត្ត ) ។

តែព្រះមហាបទុមត្ថេរពោលថា ព្រះមហាថេរៈនេះនឹងទៅទីណា ? ការទៅរបស់អ្នកបង្អោនប្រគេន ( ភត្ត )នោះ ដូចម្ដេច ? ការហាមភត្តរមែងមានសូម្បីដល់អ្នកទទួល ហើយពោលតទៅថា មិនទាន់ឈ្មោះថាហាម ( ភត្ត ) ។

ពួកទាយកស្លត្រីនិងសាច់ ផ្សំដោយទំពាំងនិងខ្នុរជាដើម ។ គេកាន់យកសម្លនោះមកពោលថា និមន្តលោកទទួលសម្លទំពាំង, និមន្តលោកទទួលសម្លខ្នុរ ។ សូម្បីសម្លនោះ ក៏មិនហាម ( ភត្ត ) ។ ព្រោះ

ហេតុអ្វី ? ព្រោះគេពោលដោយឈ្មោះនៃសូបព្យញ្ជនៈ ដែលគួរជល់ការមិនហាម ( ភត្ត ) ។ តែបើពួកគេពោលថា សម្លត្រីសម្លសាច់ក្តី, ថា និមន្តលោកទទួលសម្លត្រីនិងសាច់នេះក្តី, ពាក្យនោះ រមែងហាម ( ភត្ត ) ។

មានអាហារ ឈ្មោះថា មំសករម្ពក[១] ( ញាំសាច់ ), សូម្បីអ្នកប្រាថ្នា នឹងប្រគេនមំសករម្ពក ( ញាំសាច់ ) នោះ ពោលថា សូមនិមន្តលោកទទួលករម្ពក ( ញាំ )សមគួរទទួលមិនឈ្មោះថា ហាម ( ភត្ត ) ។ តែកាលគេពោលថា ញាំសាច់ ឬថា ញាំសាច់នេះ ពាក្យនោះ រមែងហាមភត្ត ។ សូម្បីក្នុងភោជនដែលផ្សំដោយត្រីនិងសាច់គ្រប់ ៗ យ៉ាងក៏ន័យនេះដូចគ្នា ។

ក្នុងមហាបច្ចរីពោលថា ក៏ភិក្ខុណា ឆាន់នៅក្នុងថាសដែលនិមន្តសម្គាល់សាច់ដែលគេបង្អោនប្រគេនថា ជាសាច់ដែលគេធ្វើចំពោះ ទើបហាម ភិក្ខុនោះ ចាត់ថា ជាអ្នកហាមភត្តដូចគ្នា ។

---

១. សារត្ថទីបនី. ករម្ពកោតិមិស្សកាធិវចនមេតំ ។ យំ ហិ អញ្ញេនេ មិស្សេត្វា ករោន្តិ សោ ករម្ពកោតិ វុច្ចតិ ប្រែថា ពាក្យថា ករម្ពក នោះ ជាឈ្មោះរបស់អាហារផ្សំគ្នា ។ ពិតមែន អាការដែលពួកអ្នកស្រុកធ្វើផ្សំគ្នា ដោយរបស់មួយយ៉ាង នឹងរបស់ម្យ៉ាងទៀតហៅថា ករម្ពក គួរនឹងត្រូវនឹងពាក្យថា ញាំ របស់ខ្មែរយើង ទើបប្រែទុកយ៉ាងនោះ ។

## ការហាមភត្តដែលលាយគ្នា

ចំណែកមិស្សកកថា (ពោលអំពីភោជនលាយគ្នា) លោកពោលទុកដោយល្អិតល្អន់ក្នុងកុរុន្ទី ។ សមដូចដែលលោកពោលទុកក្នុងកុរុន្ទីនោះយ៉ាងនេះថា ភិក្ខុដែលកាន់ត្រាច់បិណ្ឌបាតជាវត្ត នាំយាគូលាយដោយបាយមកហើយ ពោលថា និមន្តលោកទទួលយាគូ មិនទាន់ឈ្មោះថាហាម (ភត្ត) ។ កាលលោកពោលថា សូមនិមន្តលោកទទួលភត្ត ទើបឈ្មោះថា ហាម (ភត្ត) ។ ព្រោះហេតុអ្វី ? ព្រោះភត្តដែលភិក្ខុត្រាច់បិណ្ឌបាតសួរដោយអើពើ (ប្រាប់ប្រគេន)មាន ។

ក្នុងពាក្យថា សូមនិមន្តលោកទទួលភត្តនេះ មានអធិប្បាយដូចតទៅនេះ ៖

ភិក្ខុត្រាច់បិណ្ឌបាតជាវត្តពោលថា សូមនិមន្តលោកទទួលភត្តលាយដោយយាគូ ។ ក្នុងភត្តលាយយាគូនោះ បើយាគូមានច្រើនជាង ឬមានស្មើគ្នា មិនទាន់ឈ្មោះហាម (ភត្ត) ។ បើយាគូមានតិច ភត្តមានច្រើនជាង ឈ្មោះថា ហាម (ភត្ត) និងពាក្យនេះអ្នកណា ៗ មិនអាចជំទាស់បាន ព្រោះលោកពោលទុកគ្រប់ ៗអដ្ឋកថា, តែហេតុក្នុងពាក្យនេះឃើញបានលំបាក ។

អ្នកប្រគេនពោលថា និមន្តលោកទទួលយាគូលាយដោយភត្ត ។

ភត្តមានច្រើនជាងក្តី មានស្មើគ្នាក្តី មានតិចជាងក្តី រមែងឈ្មោះថា ហាម (ភត្ត) ដូចគ្នា ។ គេមិនបញ្ជាក់ដល់ភត្តឬយាគូ ពោលថា និមន្តលោកទទួលភោជនលាយគ្នា ។ ក្នុងភោជនលាយគ្នានោះ បើភត្តមានច្រើនជាងឬមានស្មើគ្នាចាត់ថា ហាម (ភត្ត), មានតិចជាង មិនទាន់ចាត់ថា ហាម (ភត្ត) ។ ក៏ភោជនលាយគ្នានេះ មិនដូចគ្នានឹងញាំ ។ ព្រោះថា ញាំទោះជាញាំសាច់ក្តី ញាំមិនមានសាច់ក្តី; ដូច្នោះ កាលគេពោលពាក្យថា ញាំ មិនទាន់ជាការហាម (ភត្ត) ។ តែភោជនលាយគ្នានេះ ក្លាយជាយាគូផ្សំភត្តទៅ រមែងជាការហាម (ភត្ត) ដោយន័យដូចពោលហើយនុ៎ះឯង ក្នុងភោជនលាយគ្នានេះ ។

ទាយកពោលប្រគេនដោយញែកចេញពីគ្នា ក្នុងភត្តដែលមានរសច្រើនថា និមន្តលោកទទួលរស, ក្នុងភត្តដែលមានទឹកដោះស្រស់ច្រើនថា និមន្តលោកទទួលទឹកដោះស្រស់, និងក្នុងបាយបាយាសដែលមានទឹកដោះថ្លាច្រើនថា និមន្តលោកទទួលទឹកដោះថ្លា ។ កាលភិក្ខុហាមភត្តនោះ មិនចាត់ថា ជាការហាម (ភត្ត) ។

ចំណែកភិក្ខុណា ហាមភត្តក្នុងពេលកំពុងដើរ, ភិក្ខុនោះ រមែងបានដើម្បីឆាន់ទាំងដើរនុ៎ះឯង ដើរទៅដល់ទីមានភក់ឬទន្លេឈប់ឈរហើយ គប្បីឱ្យធ្វើជាបេសសល់ ។ ប្រសិនបើថា ទឹកក្នុងចន្លោះឡើងពេញប្រាំង គប្បីដើរវិលជុំវិញគុម្ពឈើសូម្បីត្រង់ប្រាំងដែលមានទឹកឆាន់

ចុះ ៗ បើមានទូកឬស្ពាននោះហើយ គប្បីដើរទៅមកឆាន់ចុះ, មិនគប្បីកាត់ការដើរឱ្យដាច់រយៈ ៗ ភិក្ខុអង្គុយហាមភត្តលើយានក្តី លើខ្នងដំរីនិងសេះក្តី លើព្រះចន្ទក្តី លើព្រះអាទិត្យក្តី គប្បីឆាន់ទាំងដែលអង្គុយនៅលើយានជាដើមទាំងនោះ សូម្បីដែលកំពុងឃ្លាតទៅដរាបដល់វេលាថ្ងៃត្រង់ ៗ

ភិក្ខុណាឈរហាមភត្ត ភិក្ខុនោះគប្បីឆាន់ទាំងឈរដូចគ្នា, ភិក្ខុណាអង្គុយហាមភត្ត ភិក្ខុនោះ គប្បីឆាន់ទាំងដែលអង្គុយយ៉ាងនេះឯង ៗ កាលធ្វើឥរិយាបថនោះឱ្យខូច គប្បីឱ្យធ្វើឱ្យជារបស់សល់ ៗ

ភិក្ខុណាអង្គុយប្រហោងហាមភត្ត ភិក្ខុនោះ គប្បីឆាន់ទាំងដែលអង្គុយប្រហោងនុ៎ះឯង តែគប្បីឱ្យតាំងចំបើង ឬកំណល់អង្គុយយ៉ាងណាមួយទុកខាងក្រោមដល់ភិក្ខុដែលអង្គុយប្រហោងនោះ ៗ ភិក្ខុអង្គុយលើតាំងតូចហាមភត្ត រមែងបានដើម្បីឆាន់វិលទៅរួមទាំង ៤ ទិស មិនធ្វើឱ្យអាសនៈឃ្លាតចាកទី ៗ ភិក្ខុអង្គុយលើគ្រែហាមភត្ត រមែងមិនបានដើម្បីនឹងរំកិលទៅមកឯណោះឬមកនេះ ៗ តែបើជនទាំងឡាយលើកលោកឡើងព្រមទាំងគ្រែ សែងទៅក្នុងទីដទៃ គួរ ៗ ភិក្ខុដែលដេកហាមភត្ត គប្បីឆាន់ទាំងដេកនុ៎ះឯង ៗ កាលនឹងត្រឡប់ខ្លួន កុំគប្បីឱ្យហួសឋាននៃកាយខាងដែលខ្លួនដេកទៅ ៗ

## លក្ខណៈរបស់ជាសំណល់ជាដើម

បទថា អនតិរិត្តំ : **មិនជាដែល** គឺ មិនជារបស់សល់, សេចក្ដីថា មិនបរិបូណ៌ពោរពាស, តែរបស់មិនជារបស់សល់នោះ ព្រោះតែមិនធ្វើឱ្យជារបស់សល់ ដោយអាការនៃវិន័យកម្ម ៧ យ៉ាង មានរបស់មិនបានធ្វើឱ្យជាកប្បិយជាដើម ឬមិនជារបស់សំណល់នៃភិក្ខុអាពាធ; ព្រោះដូច្នោះ ក្នុងបទភាជនៈ ទើបត្រាស់ពាក្យថា អកប្បិយកតំ : **គេមិនបានធ្វើឱ្យជាវត្ថុគួរ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា អកប្បិយកតំ : **គេមិនបានធ្វើឱ្យជាវត្ថុគួរ** មានសេចក្ដីថា ក្នុងផ្លៃឈើជាដើម ផ្លៃឈើ ឬដំឡូងជាដើមណា មិនទាន់បានធ្វើឱ្យជាកប្បិយដោយសមណវោហារទាំង ៥ និងអកប្បិយមំសៈ ឬអកប្បិយភោជនយ៉ាងណាដែលមាន, ផ្លៃឈើជាដើមដែលមិនទាន់បានធ្វើកប្បិយ និងអកប្បិយមំសៈ អកប្បិយភោជននេះឈ្មោះថា របស់ជាអកប្បិយ, របស់ជាអកប្បិយនោះ ភិក្ខុធ្វើឱ្យជារបស់សំណល់យ៉ាងនេះថា ទាំងអស់នោះល្មមហើយ គប្បីជ្រាបថា អកប្បិយកតំ : វត្ថុដែលគេមិនបានធ្វើឱ្យជាកប្បិយ ។

បទថា អបដិគ្គហិតកតំ : **របស់ដែលភិក្ខុមិនបានទទួលហើយធ្វើឱ្យជារបស់គួរ** បានដល់ របស់ដែលភិក្ខុមិនទាន់បានទទួលប្រគេនធ្វើ

ឱ្យជារបស់សំណល់ដោយន័យមុននុ៎ះឯង ។

បទថា អនុច្ចារិតកតំ : របស់ដែលភិក្ខុមិនបានលើកឡើង បានដល់ របស់ដែលភិក្ខុយកមក ដើម្បីឱ្យធ្វើកប្បិយមិនទាន់បានចាប់លើកឱ្យឬបង្អោនប្រគេនសូម្បីតែបន្តិច ។

ពីរបទថា អហត្ថបាសេ កតំ : ភិក្ខុមិនឋិតនៅក្នុងហត្ថបាសហើយធ្វើ បានដល់ ឈរធ្វើក្រៅហត្ថបាសរបស់ភិក្ខុអ្នកមកដើម្បីឱ្យធ្វើកប្បិយ ។

ពីរបទថា អភុត្តាវិនា កតំ : ភិក្ខុមិនទាន់បានឆាន់ហើយធ្វើ បានដល់ ភិក្ខុដែលធ្វើឱ្យជារបស់សំណល់ថា ទាំងអស់នោះល្មមហើយ មិនទាន់បានឆាន់ភោជនដែលល្មមដល់ការហាមធ្វើហើយ ។

ពាក្យថា ភុត្តាវិនា បវារិតេន អាសនា វុដ្ឋិតេន កតំ : ភិក្ខុឆាន់ហើយ ហាមភត្តហើយ ក្រោកចាកអាសនហើយធ្វើ នេះ ងាយស្រួលយល់ទាំងអស់ហើយ ។

ពាក្យថា អលមេតំ សព្វន្តិ អវុត្តំ : របស់ដែលភិក្ខុមិនបានពោលថា របស់ទាំងអស់នេះ គួរហើយ បានដល់ មិនថ្លែងវាចានិយាយយ៉ាងនោះ (និយាយយ៉ាងនេះថា ទាំងអស់នោះ គួរហើយ) ។ របស់ជាសំណល់យ៉ាងណាមិនទាន់បានធ្វើឱ្យជាកប្បិយ ដោយអាការនៃ

វិន័យកម្មទាំង ៧ យ៉ាងនេះ និងរបស់ណាមិនជារបស់សំណល់នៃភិក្ខុអាពាធ ។ សូម្បីរបស់ទាំង ២ យ៉ាងនោះ គប្បីជ្រាបថា មិនជារបស់សំណល់ ដោយប្រការដូច្នេះ, ចំណែករបស់សំណល់ ក៏គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងរបស់មិនជាសំណល់នោះឯង ។

ម្យ៉ាងទៀត នៅមានពាក្យដទៃដែលនឹងគប្បីពោលនៅក្នុងរបស់សំណល់នេះ ។ ពាក្យថា ភុត្តាវិនា កតំ ហោតិ : **ភិក្ខុឆាន់រួចហើយទើបធ្វើ** មានសេចក្ដីថា ដល់ភោជនដែលភិក្ខុឆាន់បាយសូម្បីតែមួយគ្រាប់ ឬទំពាសាច់សូម្បីតែមួយដុំ អំពីបាត្ររបស់ភិក្ខុជាសភាគគ្នា ដែលអង្គុយបន្ទាប់ទៅធ្វើហើយ បណ្ឌិតក៏គប្បីជ្រាបថា ជាការដែលភិក្ខុអ្នកឆាន់រួចស្រេចនោះឯងធ្វើ ។

ចំណែកក្នុងពាក្យថា អាសនា អវុដ្ឋិតេន : **របស់ដែលភិក្ខុឆាន់ហើយ ហាមភោជនហើយ មិនទាន់ក្រោកចាកអាសនៈ ហើយធ្វើ** នេះ ដើម្បីសេចក្ដីមិនវង្វេង មានវិនិច្ឆ័យដូចតទៅ ៖

ភិក្ខុ ២ រូបឆាន់តាំងពីព្រឹកព្រលឹម ជាអ្នកហាមភត្តហើយ ។ ភិក្ខុមួយរូបគប្បីអង្គុយក្នុងទីហាមភត្តនុ៎ះឯង ។ មួយរូបទៀត នាំនិច្ចភត្ត ឬសលាកភត្តមក ហើយចាក់ចូលក្នុងបាត្ររបស់ភិក្ខុនោះពាក់កណ្ដាលលាងដៃហើយ ឱ្យភិក្ខុនោះ ធ្វើចំណែក( ពាក់កណ្ដាល )ដែលនៅសល់

ឱ្យជាកប្បិយហើយឆាន់ចុះ ។ ព្រោះហេតុអ្វី ? ព្រោះថា ភត្តដែលជាប់នៅក្នុងដៃរបស់ភិក្ខុដែលនាំភត្តមកនោះ ជាអកប្បិយ តែបើភិក្ខុដែលនៅអង្គុយតាំងពីដំបូង យកដៃទទួលយកអំពីបាត្ររបស់ភិក្ខុដែលនាំភត្តមកនោះ ដោយខ្លួនឯងនុ៎ះឯង, មិនមានកិច្ចចាំបាច់ត្រូវលាងដៃ ។ តែបើកាលភិក្ខុឱ្យធ្វើជាកប្បិយយ៉ាងនោះហើយឆាន់ ពួកទាយកដាក់សម្ល ឬរបស់ទំពាយ៉ាងណាមួយចុះក្នុងបាត្រទៀត, ភិក្ខុដែលធ្វើឱ្យជាកប្បិយគ្រាមុនរមែងមិនបានដើម្បីធ្វើទៀត ។ ភិក្ខុដែលមិនទាន់បានធ្វើ (ឱ្យជាកប្បិយ) គប្បីធ្វើ ។ និងគប្បីធ្វើវត្ថុដែលមិនទាន់បានធ្វើប៉ុណ្ណោះ (ឱ្យជាកប្បិយ) ។

ពីរបទថា យេន អកតំ : **ភិក្ខុដែលមិនទាន់បានធ្វើ** គឺ ភិក្ខុដទៃដែលមិនទាន់បានធ្វើ គប្បីធ្វើ (ឱ្យជាកប្បិយ) ។

ពីរបទថា យញ្ច អកតំ : **វត្ថុដែលមិនទាន់បានធ្វើ** មានសេចក្តីថា របស់ដែលនៅមិនបានធ្វើ (ឱ្យជាកប្បិយ) សូម្បីភិក្ខុដែលបានធ្វើកប្បិយ គ្រាដំបូង ក៏គួរធ្វើ (ឱ្យជាកប្បិយ) ។ តែរមែងមិនបានដើម្បីធ្វើក្នុងភាជន៍ដំបូង ។ អធិប្បាយថា ព្រោះថា របស់ដែលភិក្ខុធ្វើនៅក្នុងភាជន៍ដំបូងនោះ រមែងជាការធ្វើរួមគ្នានឹងរបស់ដែលធ្វើទុកគ្រាដំបូង; ព្រោះដូច្នោះ ទើបគួរធ្វើក្នុងភាជន៍ដទៃ ។ តែរបស់ដែលធ្វើហើយយ៉ាង

នេះ ភិក្ខុនោះនឹងឆាន់រួម ជាមួយរបស់ធ្វើទុកគ្រាដំបូង គួរ ។ មួយទៀត កាលនឹងធ្វើកប្បិយ គប្បីធ្វើក្នុងបាត្រតែម្យ៉ាងប៉ុណ្ណោះក៏ទេ, គប្បីដាក់ទុកក្នុងឆ្នាំងខ្លះ ក្នុងល្អីខ្លះ ក្នុងទីណាមួយហើយ គប្បីធ្វើក្នុងភាជនៈដែលគេបង្អោនចូលមកចុះ ។ ប្រសិនបើថា ភិក្ខុទាំង ១០០ រូបហាមភត្ត, គ្រប់រូបនឹងឆាន់ភត្តដែលធ្វើកប្បិយហើយនោះក៏គួរ ។ សូម្បីពួកភិក្ខុដែលមិនហាមភត្តក៏គួរឆាន់ ។ តែមិនគួរដល់ភិក្ខុដែលធ្វើឱ្យកប្បិយ ។

បើអ្នកស្រុកឃើញភិក្ខុដែលហាមភត្តចូលទៅបិណ្ឌបាត ទទួលបាត្រហើយឱ្យអង្គុយក្នុងស្ថានដែលនិមន្តដើម្បីត្រូវការមង្គល ដែលនឹងត្រូវមានការឆាន់ពិតប្រាកដ, គប្បីឱ្យធ្វើឱ្យជារបស់សំណល់ជាមុនហើយឆាន់ចុះ ។ បើក្នុងស្ថានដែលនិមន្តនោះមិនមានភិក្ខុដទៃ, គប្បីបញ្ជូនបាត្រទៅកាន់សាលាឆាន់ ឬវិហារហើយ ឱ្យធ្វើ (ឱ្យជារបស់សល់) ។ តែកាលនឹងធ្វើកប្បិយមិនគួរធ្វើរបស់ដែលនៅក្នុងដៃអនុបសម្បន្ន ។ បើក្នុងបន្ទប់ឆាន់មានភិក្ខុមិនឆ្លាត គប្បីទៅឱ្យធ្វើកប្បិយខ្លួនឯងហើយនាំមកឆាន់ចុះ ។

ក្នុងពាក្យថា គិលានាតិរិត្តំ : វត្ថុដែលជារបស់សល់អំពីភិក្ខុឈឺនេះ ភត្តដែលភិក្ខុអាពាធឆាន់នៅសល់តែម្យ៉ាង ទើបឈ្មោះថា ភត្តជារបស់សំណល់របស់ភិក្ខុអាពាធក៏ទេ, ពិតមែន វត្ថុយ៉ាងណាមួយដែលគេនាំមកចំពោះភិក្ខុអាពាធ ដោយតាំងចិត្តថា លោកនឹងឆាន់ក្នុងថ្ងៃនេះ ឬ

ក្នុងថ្ងៃស្អែក ឬក្នុងវេលាដែលលោកត្រូវការ, វត្ថុទាំងអស់នោះ បណ្ឌិតគប្បីជ្រាបថា របស់សល់របស់ភិក្ខុអាពាធ ។

ទុក្កដដែលត្រូវគ្រប់ ៗម៉ាត់ដែលលេបចូល ក្នុងកាលិកទាំងឡាយមានយាមកាលិកជាដើម លោកពិន័យដោយអំណាចកាលិកមិនលាយគ្នា ។ តែបើថា ជាកាលិកលាយគ្នានឹងអាមិស ជាបាចិត្តិយទាំងនោះ ដល់ភិក្ខុទទួលប្រគេនដើម្បីប្រយោជន៍ដល់អាហារក្តី ដើម្បីប្រយោជន៍មិនមែនអាហារក្តី លេបចូល ។

[១២១] ពាក្យថា សតិ បច្ចយេ : ដោយមានហេតុ មានសេចក្តីថា ភិក្ខុឆាន់យាមកាលិកដើម្បីកម្ចាត់សេចក្តីស្រេក ក្នុងកាលមានសេចក្តីស្រេក ឆាន់សត្តាហកាលិកនិងយាវជីវិក ដើម្បីរម្ងាប់អាពាធនោះ ក្នុងកាលមានអាពាធដែលនឹងគប្បីឱ្យរម្ងាប់បាន ដោយកលិកនោះ ៗ មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងមកកាយវាចា១ កាយវាចាចិត្ត១ ជាកិរិយានិងអកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បឋមបវារណាសិក្ខាបទវណ្ណនា ចប់

# ៦. ទុតិយបវារណាសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

## ពន្យល់រឿងភិក្ខុពីររូប

[១២២] ពីរបទថា អនាចារំ អាចរតិ : ប្រព្រឹត្តអនាចារ បានដល់ ធ្វើការប្រព្រឹត្តកន្លងព្រះបញ្ញត្តិ ។

បទថា ឧបនន្ធិ[១] : ចងពៀរ មានសេចក្តីថា កាលឱ្យការចូលទៅចងកំហឹងកើតឡើង ឈ្មោះថា បានចងសេចក្តីក្រោធរបស់ខ្លួនទុកក្នុងបុគ្គលនោះ ។ អធិប្បាយថា ឱ្យសេចក្តីអាឃាតកើតឡើងរឿយ ៗ ។

ពីរបទថា ឧបនន្ធោ ភិក្ខុ : ភិក្ខុដែលចងពៀរ បានដល់ ភិក្ខុដែលកើតមានការចងកំហឹងនោះ ។

ពីរបទថា អភិហដ្ឋុំ បវារេយ្យ : នាំភត្តទៅបវារណា មានសេចក្តីថា គប្បីនាំទៅបវារណាយ៉ាងនេះ និមន្តចុះភិក្ខុ ទំពាក៏ដោយ ឆាន់ក៏ដោយ ។ តែក្នុងបទភាជនៈ ព្រះឧបាលីមិនលើកពាក្យថា ហន្ទ ភិក្ខុ : នៃភិក្ខុ ជាដើមឡើងដើម្បីសម្តែងអត្ថនៃការនាំទៅបវារណា ដែលទូទៅតែម្យ៉ាង ទើបបានពោលថា និមន្តទទួលរបស់តាមសេចក្តីត្រូវការរបស់លោក ។

---

១. ថៃ. ឧបនទ្ធិ ។

បទថា ជានំ : កាលដឹងហើយ គឺ ដឹងហើយថា "ភិក្ខុនោះជាអ្នកហាមភត្តហើយ" ។ ក៏ព្រោះការដឹងនោះរបស់ភិក្ខុនោះ រមែងមានដោយអាការ ៣ យ៉ាង ; ដូច្នោះ ទើបព្រះឧបាលីពោលបទភាជនៈដោយន័យជាដើមថា ជាណាតិ ណាម សាមំ វា ជាណាតិ : ដែលហៅថា ដឹង គឺ ភិក្ខុដឹងខ្លួនឯងក្តី ដូច្នេះ ។

បទថា អាសាទនាបេក្ខោ : រំពៃរកទោស បានដល់ រំពៃរកទោស គឺការចោទប្រកាន់ បានដល់ ភាវៈដែលធ្វើឱ្យជាអ្នកអាប់យស ។

[១២៣] ពាក្យថា បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស : ទទួលត្រូវអាបត្តិទុក្កដ មានសេចក្តីថា កាលភិក្ខុអ្នកដែលខ្លួនបង្អោនប្រគេនភត្តទទួលយក ជាទុក្កដដល់ភិក្ខុដែលបង្អោនប្រគេន ។ ចំណែកសេចក្តីផ្សេងនៃអាបត្តិគ្រប់យ៉ាងរបស់ភិក្ខុដែលទទួលក្រៅនេះ ពោលទុកហើយក្នុងបឋមសិក្ខាបទ ។ តែក្នុងសិក្ខាបទនេះ ព្រះវិន័យធរគប្បីពិន័យអាបត្តិទាំងអស់ ដល់ភិក្ខុដែលបង្អោនប្រគេនភត្តប៉ុណ្ណោះ ។ បទដែលនៅសល់ប្រាកដច្បាស់ហើយ ព្រោះមានន័យដូចពោលហើយក្នុងសិក្ខាបទមុន ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងមកកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ទុតិយបវារណាសិក្ខាបទវណ្ណនា ចប់

# ៧. វិកាលភោជនសិក្ខាបទវណ្ណនា

ក្នុងសិក្ខាបទទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖

## ពន្យល់រឿងភិក្ខុសត្តរសវគ្គិយទៅមើលមហោស្រពលើកំពូលភ្នំ

[១២៦] បទថា គិរគ្គសមជ្ជោ : លេងមហោស្រពលើកំពូលភ្នំ គឺ មហោស្រពដ៏ល្អលើកំពូលភ្នំ ។ ម្យ៉ាងទៀត បានដល់ មហោស្រព (ដែលសម្តែង) លើកំពូលនៃភ្នំ ។ ពួកនគរធ្វើការឃោសនាក្នុងក្រុងថា ព្ទថា មហោស្រពនោះនឹងមានក្នុងថ្ងៃទី ៧ ។ ពួកជនជាច្រើនបានជំនុំគ្នា ត្រង់ម្លប់នៃភ្នំ លើភូមិភាគដែលរាបស្មើល្អខាងក្រៅក្រុង ការរាំរបាំរបស់ពួកអ្នករបាំ មានច្រើនប្រភេទច្រើនយ៉ាងប្រព្រឹត្តទៅ ។ ជនទាំងឡាយបានចង់គ្រែត្រួតគ្រែដើម្បីមើលការរាំរបាំរបស់ពួកអ្នករបាំទាំងនោះ ។ ពួកភិក្ខុសត្តរសវគ្គិយឧបសម្បទាតាំងពីនៅក្មេង ៗ ក្នុងកាលសិក្ខាបទមិនទាន់បានទ្រង់បញ្ញត្តិ ។ ភិក្ខុទាំងនោះបបួលគ្នាថា "អ្នកមានអាយុ ពួកយើងនឹងទៅមើលរាំរបាំជាមួយគ្នា" ហើយបានទៅក្នុងទីនោះ ។ គ្រានោះ ពួកញាតិរបស់ពួកលោកមានចិត្តត្រេកអរថា "លោកម្ចាស់របស់ពួកយើង

---

ស័ព្ទឈ្មោះខាទនីយៈ ភោជនីយៈ និងភេសជ្ជៈជាដើម ប្រែទុកក្នុងសិក្ខាបទនេះ តាមដែលស្វែងរកបាន មិនទាន់ពិតប្រាកដទេ សូមផ្ញើឱ្យអ្នកដឹងពិចារណា ពន្យល់ចុះ ។

ក៏មកដែរ” ទើបឱ្យផ្ទូតទឹកលាបស្រឡាប ឱ្យឆាន់ហើយ បានប្រគេនសូម្បីរបស់ដទៃ មានទំនិញរបស់គួរទំពាជាដើមជាប់ដៃទៅផង ។ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ សំដៅដល់ញាតិទាំងនោះ ទើបបានពោលថា មនុស្សទាំងឡាយ បានឃើញពួកសត្តរសវគ្គិយភិក្ខុហើយជាដើម ។

បទថា វិកាលេ : ក្នុងពេលដែលមិនគួរ គឺ ក្នុងកាលកន្លងទៅហើយ ។ កាលនៃភោជនរបស់ភិក្ខុទាំងឡាយលោកប្រាថ្នាយកថា កាល, ក៏កាលនៃភោជននោះ ដោយកំណត់យ៉ាងដល់ទីបំផុត គឺថ្ងៃត្រង់, អធិប្បាយថា វេលាថ្ងៃត្រង់នោះកន្លងហួសទៅហើយ ។ ព្រោះហេតុនោះ ឯង ក្នុងបទភាជនៈនៃបទថា វិកាលេនោះ ព្រះឧបាលី ទើបពោលថា កាលថ្ងៃត្រង់កន្លងទៅហើយ ដរាបដល់អរុណោរះ ឈ្មោះថា វិកាល សូម្បីវេលាត្រង់ក៏ដល់ការសង្គ្រោះចូលជាកាល ។ ចាប់ផ្តើមតាំងពីវេលាថ្ងៃត្រង់ផុតទៅ ភិក្ខុមិនអាចទំពាឬឆាន់បាន (តែ) អាចផឹកបាន, ចំណែកភិក្ខុដែលមានសេចក្តីរង្កៀសមិនគប្បីធ្វើ ។ និងដើម្បីដឹងកំណត់កាលវេលា គួរបោះសសរគ្រឿងកំណត់កាលវេលាទុក ។ មួយទៀតគប្បីធ្វើភត្តកិច្ចខាងក្នុងកាល ។

[១២៧] ក្នុងពាក្យថា អវសេសំ ខាទនីយំ នាម : បានដល់របស់ទាំងអស់ ហៅថា ខាទនីយៈ នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ក្នុងអាហារវត្ថុមាននំស្ងោរជាដើម[១] ដែលសម្រេចមកពីបុព្វណ្ណជាតិ និងអបរណ្ណជាតិមានពាក្យដែលគួរទឹងពោលមុនយ៉ាងនេះ ៖

សូម្បីវត្ថុណា មានប្រភេទដូចស្លឹកនិងឫសឫមើមជាដើម ជារបស់មានគតិដូចអាមិស, នេះ គឺ យ៉ាងណា ? គឺ វត្ថុសូម្បីនេះ ជាដើមថា ឫសគួរទំពា មើមគួរទំពា ក្រអៅគួរទំពា ចុងឫត្រួយគួរទំពា ដើមគួរទំពា សំបកគួរទំពា ស្លឹកគួរទំពា ផ្កាគួរទំពា ផ្លែគួរទំពា គ្រាប់គួរទំពា ម្សៅគួរទំពា ជ័រគួរទំពា រមែងដល់ការសង្គ្រោះចូលក្នុងខាទនីយៈ (របស់គួរទំពា) ទាំងនោះ ៗ ក៏ក្នុងមូលខាទនីយៈជាដើមនោះ ដើម្បីកំណត់ដឹងរបស់គួរទំពាមានគតិដូចអាមិស មានរបស់គួរទំពាដែលទឹងបញ្ជាក់ឱ្យឃើញល្អមជាឧបមាដូចតទៅនេះ ៖

## អធិប្បាយរបស់គួរទំពាដែលចាត់ជាកាលិកផ្សេងៗ

គប្បីជ្រាបវិនិច្ឆ័យក្នុងមូលខាទនីយៈមុន ៖

ស្លឹក និងឫសដែលគួរជាសូបៈ(ម្ហូប)បាន មានជាដើមយ៉ាងនេះ គឺ មូលកមូល វារកមូល បុច្ចុមូល តម្ពកមូល តណ្ឌុលេយ្យកមូល

---

១. អត្ថយោជនា ២/៧០ សក្ខលិមោទកោតិ វដ្តមោទកោ ៗ ឥណ្ឌាហៅនំប្រភេទនេះថា លឌ្ឌូ ន័យថា ធ្វើអំពីម្សៅជាដុំមូល ៗ ខាងក្នុងដាក់ស្ករលហើយដាក់ទឹកដំឡូងមានលក្ខណៈដូចនំគម ៗ

វត្ថុលេយ្យកមូល វជ្ជកលិមូល ជជ្ឈរិមូល[១] មានគតិដូចអាមិស ។ ក៏បណ្ឌាខាទនីយៈ មានមូលកមូលជាដើមនេះ ជនទាំងឡាយ កាត់ក្បាលខ្ទិក្នុងវជ្ជកលិមូល( ក្បាលដំឡូងធំ ) ចោល, ក្បាលខ្ទិនោះជាយាវជីវិក ។ មើមសូម្បីយ៉ាងដទៃបែបនេះ ក៏គប្បីជ្រាបដោយន័យនេះឯង ។ លោកពោលទុកថា ចំណែកក្បាលរបស់មូលកៈ វារកៈ និងជជ្ឈរិ ( ត្រាវ ដំឡូងដូង និងដំឡូងគ ) សូម្បីនៅខ្ទិ ក៏មានគតិដូចអាមិសដែរ ។

ចំណែកភេសជ្ជៈពួកណាដែលត្រាស់ទុកក្នុងព្រះបាលីថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវឫសឬមើមជាភេសជ្ជៈ គឺ មើមរមៀត មើមខ្ញី មើមលំពាន់ មើមប្រស់ មើមអាចម៍ឆ្កែស មើមរំដេង មើមស្បូវភ្លាំង មើមស្មៅក្រវាញជ្រូក ម្យ៉ាងទៀត មើមដទៃជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈក្នុងភោជនីយៈ"[២] ដូច្នេះ, ភេសជ្ជៈទាំងនោះ ជាយាវជីវិក ។ ភេសជ្ជៈជាយាវជីវិកទាំងនោះ កាលគណនារាប់ដោយន័យជាដើមថា ចូឡបញ្ចមូល មហាបញ្ចមូល ( ឫសទាំង ៥ តូច ឫសទាំង ៥ ធំ ) មិនមានទីបំផុត

---

១, ត្រាវ ផ្ទៅ ដំឡូងដូង ដំឡូងក្រហម ដំឡូងខ្វា ដំឡូងគ ដំឡូងធំ ដំឡូងជ្រៅ ឬ ដំឡូងជ្រូក វជិរពុទ្ធិដីកាច្បាប់ភូមា ខាឌកខ្ញុំមូលន្តិ យូបសមូលំ ។ ចច្ចមូលំ = នេឡិយមូលំ ។ តម្គកំ = វចំ ។ តណ្ឌុលេយ្យកំ = ចូឡកុហុ ។ វត្ថុលេយ្យកំ = មហាកុហុ វជកលិ = ឩកោដ្ឋំ ។ ជជ្ឈរិ = ហិរវេតា ។ ២. វិន. មហា. ៧. ៧៦/២២៦ ។

ដោយករោប ។ ក៏ភាវៈ គឺ សេចក្ដីមិនសម្រេចប្រយោជន៍ដល់ខាទនីយៈ និងប្រយោជន៍ដល់ភោជនីយៈនុ៎ះឯង ជាលក្ខណៈនៃមូលភេសជ្ជៈដែលជាយាវជីវិកទាំងនោះ ។

ព្រោះដូច្នោះ[១] ឫសឬមើមប្រភេទណាមួយ សម្រេចប្រយោជន៍ដល់ខាទនីយៈនិងប្រយោជន៍ដល់ភោជនីយៈរបស់ពួកមនុស្ស ដោយអំណាចនៃអាហារតាមប្រក្រតីក្នុងជនបទនោះ ៗ, ឫសឬមើមនោះ គប្បីជ្រាបថា ជាយាវកាលិក, ឫសឬមើមក្រៅនេះ គប្បីជ្រាបថា ជាយាវជីវិក, សូម្បីពួកយើងនឹងពោលឱ្យល្អិតល្អន់ច្រើនទៅ ក៏ចាំបាច់ត្រូវអះអាងនៅក្នុងលក្ខណៈនេះឯង ។ តែកាលនឹងពោលនាមសញ្ញា( គ្រឿងកំណត់ឈ្មោះ ) ទាំងឡាយ ទុកក៏នឹងជាសេចក្ដីស្រពិចស្រពិលខ្លាំងឡើង ដល់ពួកជនអ្នកមិនដឹងឈ្មោះនោះ ៗ ។ ព្រោះដូច្នោះ ខ្ញុំទើបមិនធ្វើសេចក្ដីអើពើក្នុងនាមសញ្ញាសម្ដែងទុកតែលក្ខណៈប៉ុណ្ណោះ ។ មួយទៀត គប្បីជ្រាបវិនិច្ឆ័យដោយអំណាចនៃលក្ខណៈ ដែលបានសម្ដែងទុកក្នុងមើមជំឡូងជាដើមនុ៎ះឯង ដូចក្នុងឫសឬមើម ដូច្នោះ ។ មួយទៀត សូម្បីដើម សំបក ផ្កា និងម្សៅនៃមើម ៨ ប្រភេទ មានរមៀតជាដើម ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងព្រះបាលីទាំងអស់ លោកក៏ពោលថា ជាយាវជីវិក ។

១. យោជនាបាឋៈ ២/៧២ ជា តស្មា ប្រែតាមនោះ ឃើញថា ត្រូវជាង ។

ក្នុងមើមគួរទំពា មានវិនិច្ឆ័យដូច្នេះ ៖

មើមជំឡូង (មើមក្រោមដី) មាន ២ ប្រភេទគឺ ប្រភេទវែង ១ ប្រភេទមូល ១ មើមឈូក និងឫសរបស់កីសុក(ចារ)ជាដើម មានទាំងប្រភេទវែង និងប្រភេទខ្លី, មើមឈូកនិងមើមក្រចាប់ជាដើម ដែលអាចារ្យពួកខ្លះ ហៅថា គណ្ឌីក៏មាន ជាមើមប្រភេទមូល ។ បណ្ដាមើមទាំងនោះដែលចាស់ និងខ្ទីរបស់មើម ក្រមរ និងពួកឫសតូច ៗ នៃមើមគ្រប់យ៉ាង ចាត់ជាយាវជីវិក ។

ចំណែកពួកឫស ដែលសម្រេចប្រយោជន៍ដល់ខាទនីយៈ និងប្រយោជន៍ដល់ ភោជនីយៈរបស់ពួកមនុស្ស ដោយអំណាចអាហារតាមប្រក្រតីក្នុងជនបទនោះ ៗ មានជាដើមយ៉ាងនេះ គឺ ពន្លកឫសនៃដើមសាលកល្យាណី ដែលនៅខ្ចី ស្រួលទំពា ពន្លកឫសដើមកីសុក មើមដើមអម្ពាដក ឫសរំចេក ឫសជ្រៃ ក្រអៅឈូកក្រហម និងឈូកសដែលគេហៅថា ក្រអៅឈូក វល្លិមានវល្លិក្អួងនិងវល្លិត្រចៀកប្រើសជាដើម ឫសវល្លិទឹកដោះ[1] ឫសជ្រៃ ឫសម្រុំ ឫសត្នោត ឫសព្រលិតខៀវ ព្រលិត ក្រហម កុមុទ និងស្គន្ធ ឫសចេក ឫសឫស្សី ឫសក្រចាប់(កសេរុក)ខ្ចីស្រួលទំពា ចាត់ជាយាវកាលិក ។ មើមក្តួច (ឬវល្លិទឹកដោះ) ដែលមិនទាន់លាងសំអាត ជាយាវជីវិក, ដែលលាង

១. ឥណ្ឌាហៅថា អាលូជាមើមប្រភេទមួយ សម័យនេះហៅ ដំឡូងបារាំង ។

សំអាតហើយជាយាវកាលិក ។

ចំណែកមើមរបស់ ខ្ទាយ ខ្ញី និងខ្ទឹមជាដើម ជាយាវជីវិក ។ មើមទាំងនោះ លោកសង្គ្រោះចូលទីងមូលភេសជ្ជៈនុ៎ះឯង ក្នុងព្រះបាលីយ៉ាងនេះថា "យានិ វា បនញ្ញានិបិ អត្ថិ មូលានិ ភេសជ្ជានិ : ម្យ៉ាងទៀត មើមដទៃជាភេសជ្ជៈ" ។

ក្នុងមូលឡាលខាទនីយៈ មានវិនិច្ឆ័យដូច្នេះ ៖

ក្រអៅឈូកធំ ដូចគ្នានឹងក្រអៅឈូកសន្ទុ៎ះឯង ។ ក្រអៅដែលសម្រេចប្រយោជន៍ដល់ខាទនីយៈ និងប្រយោជន៍ដល់ភោជនីយៈរបស់ពួកមនុស្ស ដោយអំណាចអាហារតាមប្រក្រតីក្នុងជនបទនោះ ៗ មានជាដើមយ៉ាងនេះ គឺ ឫសវែទឹក ឫសវល្លិគ្នា ជាយាវកាលិក ។

ចំណែកឫសរបស់រមៀត ខ្ញី ប្រស់ លំពាន់ រំចេក ត្នោត ទន្សេដើមរឹត ដូង ស្លា ជាដើម ចាត់ជាយាវជីវិក ។ មើមល្មៀតជាដើមសូម្បីទាំងអស់នោះ លោកសង្គ្រោះចូលទឹងមូលភេសជ្ជៈដូចគ្នា ក្នុងព្រះបាលីយ៉ាងនេះថា "យានិ វា បនញ្ញានិបិ អត្ថិ មូលានិ ភេសជ្ជានិ : ម្យ៉ាងទៀត មើមដទៃជាភេសជ្ជៈ" ។

ក្នុងមត្ថកខាទនីយៈ មានវិនិច្ឆ័យដូច្នេះ ៖

ត្រួយឫពន្លកនៃឈើនិងវល្លិជាដើម ដែលសម្រេចប្រយោជន៍ដល់ខាទនីយៈ និងប្រយោជន៍ដល់ភោជនីយៈរបស់ពួកមនុស្ស ដោយ

អំណាចអាហារតាមប្រក្រតីក្នុងជនបទនោះ ៗ មានជាដើមយ៉ាងនេះ គឺ ចុងដែលគេហៅថា បណ្តូលរបស់ត្នោត ទន្សែ រីត ជ្រៃ ទ្រាំង ដូង ស្លា ផ្តៅ ស្ងែ និងចេក ពន្លកឫស្សី ពន្លកបបុស ពន្លកអំពៅ ពន្លកត្រាវ ពន្លកគ្រាប់ស្ពៃ និងពន្លកនៃធញ្ញជាតិ ៧ ប្រភេទ ចាត់ជាយាវកាលិក ។ ឫស ខ្ទឹ (ចុងខ្ទឹ) នៃពន្លករមៀត ខ្ទី លំពាន់ ខ្ញី ខ្ទឹម និងនៃបណ្តូលត្នោត ទន្សែ ទ្រាំង ដើមរីត ដូង ដែលគេកាត់ឱ្យដាច់ធ្លាក់ទៅជាយាវជីវិក ។

## ដើម សំបក និង ស្លឹក ដែលគួរទំពា

ក្នុងខុទ្ទខាទនីយៈ មានវិនិច្ឆ័យដូច្នេះ ៖

ដើមមានជាដើមយ៉ាងនេះ គឺ ដើមអំពៅ ឈូកក្រហម កោមុទ និងចង្កូលនីដែលនៅខាងក្នុងដី ដែលសម្រេចប្រយោជន៍ដល់ខាទនីយៈ និងប្រយោជន៍ដល់ ភោជនីយៈរបស់ពួកមនុស្ស ដោយអំណាចនៃអាហារតាមប្រក្រតីក្នុងជនបទនោះ ៗ ចាត់ជាយាវកាលិក ។ ទងស្លឹកនៃឈូកប្រភេទឧប្បលជាតិក្តី ទងទាំងអស់នៃឈូក ប្រភេទបទុមជាតិក្តី និងទងឈូកដែលនៅសល់គ្រប់ ៗយ៉ាង មានទងឈូកធំជាដើម ចាត់ជាយាវជីវិក ។

ក្នុងតចខាទនីយៈ មានវិនិច្ឆ័យដូច្នេះ ៖

សំបកអំពៅតែម្យ៉ាងប៉ុណ្ណោះលោកចាត់ជាយាវកាលិក ។ សំបក

អំពៅសូម្បីនោះ នៅជារបស់មានរស (ផ្អែម) ។ សំបកដែលនៅសល់គ្រប់យ៉ាងជាយាវជីវិក ។ ក៏ត្រួយ ដើម និងសំបកទាំង ៣ នោះ គប្បីជ្រាបថា សង្គ្រោះចូលទឹកសាវភេសជ្ជៈ ក្នុងព្រះបាលី ។ សមដូចពាក្យដែលព្រះមានព្រះភាគ ត្រាស់ទុកនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកចត់ជាភេសជ្ជៈ គឺ ទឹកចត់ដែលកើតអំពីដើមស្ដៅ ទឹកចត់ដែលកើតអំពីដើមខ្វៃគន់ ទឹកចត់ដែលកើតអំពីដើមអប្រែងថ្ងៃ ទឹកចត់ដែលកើតអំពីវល្លិបណ្ដូលពេជ្រ ទឹកចត់ដែលកើតអំពីដើមទន្លា ឬថ្នាន់, ម្យ៉ាងទៀត ទឹកចត់ដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈក្នុងភោជនីយៈ"[១] ការសង្គ្រោះត្រួយ ដើម និងសំបកទាំងនេះ ចូលក្នុងព្រះពុទ្ធានុញ្ញាតនេះ រមែងសម្រេច (រមែងប្រើបាន) ។ និងពួកទឹកចត់ដែលពោលហើយ បណ្ឌិតគប្បីជ្រាបថា ជារបស់សមគួរដោយប្រការគ្រប់យ៉ាង ។

ក្នុងបត្តខាទនីយៈ មានវិនិច្ឆ័យដូច្នេះ ៖

ស្លឹកទាំងឡាយនៃរុក្ខជាតិទាំងនេះ គឺ ត្រាវ ខ្ទូរ[២] ជំឡូងដូង និងជំឡូងក្រហម ទន្លាប់ បុន្នាគ ជំឡូងជ្រៅ ជំឡូងធំ ម្កាក់ ប្រស់ សណ្ដែកខៀវ សណ្ដែកសៀង សណ្ដែករាជមាស ញព្រៃដែលនៅសល់

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ៧៧/២២៧ ។ ២. ខ្វះហៅថា ផ្ទៅ ។

វៀរញធំ( ញស្រែក )ចេញ ពិលង្គ បញ្ចមាស ដូង តែកើតលើដី និងស្លឹកឈើពួកដទៃបែបនេះ ដែលសម្រេចប្រយោជន៍ដល់របស់គួរទំពា និងសម្រេចប្រយោជន៍ដល់របស់គួរបរិភោគរបស់ពួកមនុស្ស ដោយអំណាចអាហារតាមប្រក្រតីក្នុងជនបទនោះ ៗ ចាត់ជាយាវកាលិកដោយចំណែកតែមួយ ។

តែមានស្លឹកខ្លាតប៉ុនខ្លងក្រចកទ្រើស សូម្បីដទៃណា វាឡើងលើដើមឈើ ឬគុម្ពឈើ, ពួកអាចារ្យអ្នកកោះ ( អ្នកជម្ពូទ្វីប ឬអ្នកលង្កាទ្វីប ) ពោលស្លឹកតែនោះថា ជាយាវជីវិក និងស្លឹកព្រហ្មីថា ជាយាវជីវិក ។ ស្លឹកស្វាយខ្ចី ជាយាវកាលិក ។ ចំណែកស្លឹកអសោកខ្ចី ជាយាវជីវិក ។

ឬស្លឹកដទៃណា ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងព្រះបាលីថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្លឹកឈើជាភេសជ្ជៈ គឺ ស្លឹកស្ដៅ ស្លឹកខ្លែងគង់ ស្លឹកអម្បែងថ្ងៃ ស្លឹកម្រះព្រៅ ឬជីលីងលាក់ ស្លឹកកប្បាស, ម្យ៉ាងទៀត ស្លឹកដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ ក្នុងភោជនីយៈ"[១] ដូច្នេះ, ស្លឹកទាំងនោះ ជាយាវជីវិក ។ និងមិនមែនតែស្លឹកតែម្យ៉ាង សូម្បីផ្កានិង

---

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ៧៨/២២៨ ។

ផ្លែរបស់ស្ដៅជាដើមពួកនោះ ក៏ជាយាវជីវិក (ដូចគ្នា) ។ ពួកស្លឹកដែលជាយាវជីវិក ទីងមិនមានទីបំផុតដោយអំណាចការរាប់យ៉ាងនេះថា ស្លឹកខ្ទឹមគន់ ឬមូលកា ស្លឹកស្ដៅ ឬស្លឹកអម្បែងថ្ងៃ ស្លឹកជីលីងលាក់ ឬពោន ស្លឹកស្ពៃ ស្លឹកម្ទូ ស្លឹកឈូកជាដើម ។

## ផ្កា ផ្លែ ក្រាប់ មើម និងជ័រដែលគួរទំពា

ក្នុងបុប្ផខាទនីយៈ មានវិនិច្ឆ័យដូច្នេះ ៖

ផ្កាដែលសម្រេចប្រយោជន៍ដល់របស់គួរទំពា និងដែលសម្រេចប្រយោជន៍ដល់របស់ដែលគួរបរិភោគរបស់ពួកមនុស្ស ដោយអំណាចនៃអាហារតាមប្រក្រតីក្នុងជនបទនោះ ៗ មានជាដើមយ៉ាងនេះ គឺ ផ្កាត្រាវ ផ្កាស្លួយ ផ្កាជំឡូងដូង ផ្កាជំឡូងក្រហម ផ្កាជំឡូងធំ ផ្កាញព្រៃ ផ្កាញធំ (ញស្រុក) ផ្កាក្រចាប់ ផ្កាខ្ទឹរបស់ដូង ត្នោត និងរំចេក ផ្កាម្រុំ ផ្កាឈូកប្រភេទឧប្បល និងបទុម ផ្កាកណ្ណិកា ផ្កាមិនមានក្លិន ផ្កាចប្ការ ផ្កាទៀនស ជាយាវកាលិក ។

ចំណែកផ្ការបស់ពួករុក្ខជាតិ ដូច អសោក ពិកុល ក្រពៅ បុន្នាគ ចម្ប៉ា ចប្ការ កណ្ណិការ រំចេក (តាលិទ្ធ) ម្ទេះលា ម្ទេះរួតជាដើម ជាយាវជីវិក ។ ផ្កាឈើដែលជាយាវជីវិកនោះ មិនមានទីបំផុតដោយការរាប់ ។ តែអ្នកសិក្សាគប្បីជ្រាបថា សង្គ្រោះផ្កាឈើដែលជាយាវជីវិក

នោះ ចូលទឹកសាវភេសជ្ជៈក្នុងព្រះបាលីនោះឯង ។

ក្នុងផ្លែខាទនីយៈ មានវិនិច្ឆ័យដូច្នេះ ៖

ផ្លែឈើទាំងឡាយ មានខ្នុរ ខ្នុរសម្ល ត្នោត ដូង ស្វាយ ព្រីង ម្កាក់ អំពិល ក្រូច ខ្វិត ឃ្លោក ត្រឡាច ត្រសក់ ទន្លាប់ ឪឡឹក ត្រប់ បេកមានគ្រាប់ បេកមិនមានគ្រាប់ និងស្រគាំជាដើម ( និង )ពួកផ្លែឈើ ដែលសម្រេចប្រយោជន៍ដល់របស់គួរទំពា និងដែលសម្រេចប្រយោជន៍ ដល់របស់គួរបរិភោគ របស់ពួកមនុស្សដោយអាហារតាមប្រក្រតី ក្នុងជនបទនោះ ៗក្នុងលោក គ្រប់ ៗយ៉ាងជាយាវកាលិក ។ និងដោយអំណាចការរាប់ឈ្មោះ អ្នកណា ៗ ក៏មិនអាចនឹងសម្តែងផ្លែឈើដែលជាយាវកាលិកទាំងនោះឱ្យអស់បំផុតបាន ។

ក៏ឯផ្លែពួកណា ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងព្រះបាលីថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លែឈើជាភេសជ្ជៈ គឺ ផ្លែពិលង្គ ផ្លែជីប្លី ផ្លែម្រេច ផ្លែសម៉ ផ្លែសម៉ពិភេក ផ្លែកន្ទួតព្រៃ ផ្លែក្រវាញ, ម្យ៉ាងទៀត ផ្លែដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈក្នុងភោជនីយៈ”[១] ដូច្នេះ, ផ្លែទាំងនោះជាយាវជីវិក ។ សូម្បីផ្លែឈើដែលជាយាវជីវិកទាំងនោះ អ្នកណា ៗ

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ៧៩/២២៨ ។

ក៏មិនអាចនឹងសម្តែងឱ្យអស់បាន ដោយអំណាចនៃឈ្មោះយ៉ាងនេះ គឺពួកផ្លែនៃស្វាក្រើន ផ្លែជ្រៃ ឬបាស រំចេក ល្ពៅ ជាដើមដែលមិនទាន់ទុំ ផ្លែចន្ទទេស ម្រេច (ម្ទេស) ក្រវាញធំ ក្រវាញ (តូច) ជាដើម ។

ក្នុងអដ្ឋិខាទនីយៈ មានវិនិច្ឆ័យដូច្នេះ ៖

គ្រាប់ទាំងឡាយ មានជាដើមយ៉ាងនេះ គឺគ្រាប់ខ្នុរសម្ល គ្រាប់ខ្នុរ គ្រាប់ម្កាក់ គ្រាប់ត្រចៀកប្រើស គ្រាប់របស់ផ្លែដែលនៅខ្ទីនៃពួកបេង រំចេកទន្សាប់ គ្រាប់អំពិល គ្រាប់បាស គ្រាប់សង្ស័រ គ្រាប់ឈូក (ផ្លែឈូក) ប្រភេទឧប្បល និងបទុមជាតិទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈក្នុងភោជនីយៈ ដោយអំណាចនៃអាហារតាមប្រក្រតីរបស់ពួកមនុស្សក្នុងជនបទនោះ ៗ ចាត់ជាយាវកាលិក ។ គ្រាប់មានជាដើមយ៉ាងនេះ គឺ គ្រាប់ស្រគាំ គ្រាប់បុន្នាគ គ្រាប់ពួកសម៉ជាដើម គ្រាប់ស្ពៃ គ្រាប់ជីក្រហម ចាត់ជាយាវជីវិក ។ គ្រាប់ដែលជាយាវជីវិកទាំងនោះ អ្នកសិក្សាគប្បីជ្រាបថាសង្គ្រោះចូលជាមួយនឹងផ្លែភេសជ្ជៈក្នុងព្រះបាលីនុ៎ះឯង ។

ក្នុងបិដ្ឋខាទនីយៈ មានវិនិច្ឆ័យដូច្នេះ ៖

ម្សៅទាំងឡាយមានជាដើមយ៉ាងនេះ គឺម្សៅនៃធញ្ញជាតិ ៧ ប្រភេទ ធញ្ញជាតិអនុលោមនិងអបរណ្ណជាតិ ម្សៅខ្នុរ ម្សៅខ្នុរសម្ល ម្សៅម្កាក់ ម្សៅជ្រៃ ម្សៅត្នោត ដែលលាងជម្រះហើយ ម្សៅល្ងទឹកដោះ

ដែលសម្រេច ប្រយោជន៍ដល់របស់គួរទំពា និងដែលសម្រេចប្រយោជន៍ដល់របស់គួរបរិភោគនៃពួកមនុស្ស ដោយអំណាចនៃអាហារតាមប្រក្រតីក្នុងជនបទនោះ ចាត់ជាយាវកាលិក ។ មើមឈ្នោតដែលនៅមិនបានលាងជម្រះ មើមល្វីទឹកដោះ មើមសាគូជាដើម (ដែលនៅមិនបានលាងជម្រះ) ចាត់ជាយាវជីវិក ។ មើមដែលជាយាវជីវិកទាំងនោះ អ្នកសិក្សាគប្បីជ្រាបថា សង្គ្រោះចូលទីងពួកទឹកចត់និងពួកឫសផ្លែ ។

ក្នុងនិយាសខាទនីយៈ មានវិនិច្ឆ័យដូច្នេះ ៖

ជ័រអំពៅ (តាំងមែស្ករអំពៅ) តែមួយយ៉ាង ជាសត្តាហកាលិក ។ ជ័រដែលនៅសល់ដែលត្រាស់ទុកក្នុងព្រះបាលី យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជ័រឈើជាភេសជ្ជៈ គឺ ជ័រដែលហូរចេញអំពីដើមហិង្គុ១ ជ័រដែលគេយកស្លឹកនឹងមែកហិង្គុមករំងាស់១ ជ័រដែលគេយកស្លឹកហិង្គុតែម្យ៉ាងមករំងាស់១ ជ័រដែលហូរចេញអំពីត្រួយឈើ ១ ជ័រដែលហូរចេញអំពីស្លឹកឈើ១ ជ័រដែលគេបេះស្លឹកឈើមកធ្វើ១ កំញាន ១ ម្យ៉ាងទៀត ជ័រឈើដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈក្នុងភោជនីយៈ"[១] ដូច្នេះ ចាត់ជាយាវជីវិក ។ អ្នកណា ៗក៏មិនអាចនឹងសម្តែងជតុភេសជ្ជៈ

---

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ៨០/២២៩ ។

ដែលលោកសង្គ្រោះដោយយេវាបទកន័យ ក្នុងព្រះបាលីនោះ ឱ្យអស់ ដោយអំណាចនៃឈ្មោះយ៉ាងនេះ គឺ ជវកណ្ណិការ ជវស្វាយជាដើម ។

បណ្តាខាទនីយៈ មានមូលខាទនីយៈជាដើមទាំងនេះ ដូចពោលមកនេះ យាវកាលិកប្រភេទណាមួយសូម្បីទាំងអស់ លោកសង្គ្រោះចូលក្នុងអត្ថនេះថា ដែលនៅសល់ ឈ្មោះថា ខាទនីយៈ (របស់គួរទំពា) ។ ចំណែកពាក្យដែលគួរពោលក្នុងពាក្យថា ភោជន ៥ យ៉ាង ឈ្មោះថា ភោជនីយៈ (របស់គួរបរិភោគ) ជាដើម ខ្ញុំបានពោលហើយឯង ។

ពាក្យថា ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស : ភិក្ខុទទួលវត្ថុទាំងនោះ ដោយគិតថា អញនឹងទំពារស៊ី នឹងបរិភោគត្រូវអាបត្តិទុក្កដ មានសេចក្តីថា ភិក្ខុណាទទួលប្រគេនខាទនីយៈ និងភោជនីយៈនោះក្នុងវេលាវិកាល, ភិក្ខុនោះត្រូវអាបត្តិទុក្កដព្រោះការទទួលមុន ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ កើតឡើងមកកាយ ១ មកកាយចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្មមានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

វិកាលភោជនសិក្ខាបទវណ្ណនា ចប់

# ៨. សន្និធិការកសិក្ខាបទវណ្ណនា

ក្នុងសិក្ខាបទទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖

## រឿងព្រះវេឡដ្ឋសីសៈធ្វើការសន្សំ

[១៣០] ព្រះមហាថេរៈ ដែលរួមនៅខាងក្នុងនៃភិក្ខុជដិល ១ ពាន់រូប ឈ្មោះថា វេឡដ្ឋសីសៈ ។

ពីរបទថា អរញ្ញេ វិហរតិ : គង់នៅក្នុងព្រៃ បានដល់ នៅក្នុងអាវាសមួយកន្លែងដែលជាផ្ទះជាទីបំពេញព្យាយាមជិតព្រះជេតវនវិហារ ។

បទថា សុក្ខកូរំ : បាយស្ងួត បានដល់ បាយតែម្យ៉ាង មិនមានសម្លនិងម្ហូបក្រៀមទេ ។ បានពួថា ព្រះថេរៈនោះឆាន់ខាងក្នុងស្រុកហើយ ខាងក្រោយត្រាច់បិណ្ឌបាត នាំយកបាយដូច្នោះមក ។ ក៏ឯព្រះថេរៈនាំយកបាយនោះ មកព្រោះភាពជាអ្នកប្រាថ្នាតិច មិនមែនព្រោះភាពជាអ្នកជាប់ក្នុងបច្ច័យ ។ បានពួថា ព្រះថេរៈសម្រាកនៅដោយនិរោធសមាបត្តិរហូតដល់អស់ ៧ ថ្ងៃចេញចាកសមាបត្តិហើយ យកបិណ្ឌបាតនោះចាក់លាយទឹកឆាន់, រមែងអង្គុយចូលសមាបត្តិតពី ៧ ថ្ងៃនោះទៅ ៧ ថ្ងៃទៀត, លោកនៅសម្រាករហូតដល់ ២ សប្ដាហ៍ខ្លះ ៣ សប្ដាហ៍ខ្លះ ៤ សប្ដាហ៍ខ្លះ ដោយប្រការយ៉ាងនេះ ទើបចូលកាន់ស្រុកដើម្បីបិណ្ឌបាត ។

ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ទើបពោលថា “យូរ ៗ បានលោកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្តង” ។

ពាក្យថា ការ ការណ៍ កិរិយា (ទាំង ៣ នេះ) ដោយអត្ថតែមួយដូចគ្នា ។ ការធ្វើសេចក្តីសន្សំមានដល់ខាទនីយៈ និងភោជនីយៈនោះ ; ដូច្នោះ ទើបឈ្មោះថា សន្និធិការ ។ សន្និធិការនុ៎ះឯង ឈ្មោះថា សន្និធិការក, សេចក្តីថា សន្និធិកិរិយា (ការធ្វើការសន្សំ) ។ ពាក្យថា សន្និធិការកនោះ ជាឈ្មោះ (នៃខាទនីយៈភោជនីយៈ) ដែលភិក្ខុទទួលប្រគេនទុក ឱ្យកន្លងមួយយប់ ។ ព្រោះហេតុនោះឯង ទើបព្រះឧបាលីពោលទុកក្នុងបទភាជនៈនៃបទថា សន្និធិការកំ នោះថា “ដែលឈ្មោះថាខ្លួនទុកដាក់ឱ្យកន្លងរាត្រី បានដល់ (ខាទនីយៈភោជនីយៈ) ដែលខ្លួនទទួលក្នុងថ្ងៃនេះ ហើយឆាន់ក្នុងថ្ងៃខាងក្រោយ” ។

[១៣២] ពាក្យថា បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស : ទទួលត្រូវអាបត្តិទុក្កដ មានសេចក្តីថា កាលភិក្ខុទទួលយាវកាលិក ឬយាមកាលិកយ៉ាងណាមួយដែលធ្វើសន្និធិយ៉ាងនេះ ដោយសេចក្តីប្រាថ្នានឹងលេបចូលទៅ ត្រូវទុក្កដ ព្រោះការទទួលប្រគេនមុន ។ តែកាលលេបចូលទៅជាបាចិត្តិយ គ្រប់ ៗម៉ាត់ដែលលេបចូល ។ ប្រសិនបើថា

បាត្រលាងមិនស្អាត ដែលកាលស្ទាបដោយម្រាមដៃ ស្នាមប្រាកដ, រំអិលជ្រាបចូលទៅក្នុងចន្លោះថ្នេរនៃបាត្រដែលមានថ្នេរ, រំអិលនោះកាលពេលកម្តៅឱ្យក្តៅរមែងជ្រាបចេញ ឬថា ទទួលបាយយាគូក្តៅ នឹងប្រាកដ, ជាបាចិត្តិយដល់ភិក្ខុដែលឆាន់សូម្បីក្នុងបាត្រដូច្នោះក្នុងថ្ងៃស្អែក ។ ព្រោះដូច្នោះ ភិក្ខុគប្បីលាងបាត្រហើយ ចាក់ទឹកថ្លាចុះទៅក្នុងបាត្រនោះ ឬស្ទាបដោយម្រាមដៃ ទើបនឹងដឹងបានថា មិនមានរំអិល ។ ប្រសិនបើថា មានរំអិលលើទឹកក្តី ស្នាមម្រាមដៃប្រាកដក្នុងបាត្រក្តី, បាត្រ រមែងជាការលាងមិនស្អាត ។ តែក្នុងបាត្រមានពណ៌ប្រេង ស្នាមម្រាមដៃ រមែងប្រាកដ, ស្នាមម្រាមដៃនោះជាអព្វោហារិក ។ ភិក្ខុទាំងឡាយមិនស្តាយ លះបង់ភោជនណាឱ្យដល់សាមណេរ, បើសាមណេររក្សាភោជននោះទុកប្រគេនដល់ភិក្ខុ គួរគ្រប់យ៉ាង ។ តែដែលខ្លួនឯងទទួលប្រគេនហើយមិនលះបង់ចេញមុន រមែងមិនគួរក្នុងថ្ងៃស្អែក ។ ពិតមែន កាលភិក្ខុលេបចូលទៅបាយសូម្បីតែមួយគ្រាប់អំពីភោជនដែលមិនលះបង់នោះ ជាបាចិត្តិយដូចគ្នា ។

បណ្តាសាច់ដែលជាអកប្បិយ ក្នុងសាច់មនុស្សជាបាចិត្តិយ និងថុល្លច្ច័យ ។ ក្នុងសាច់ដែលនៅសល់ជាបាចិត្តិយនិងទុក្កដ ។ កាលផឹក

យាមកាលិកចូលទៅក្នុងកាលមានហេតុជាបាចិត្តិយ ។ កាលផឹកចូលទៅដើម្បីប្រយោជន៍ជាអាហារ ជាបាចិត្តិយនិងទុក្កដ ។ បើភិក្ខុជាអ្នកហាមភត្ត លេបភោជនដែលមិនបានធ្វើឱ្យជាសំណល់ចូលទៅ, ក្នុងអាមិសតាមប្រក្រតី ជាបាចិត្តិយ ២ ។ ក្នុងសាច់មនុស្ស ជាបាចិត្តិយ ២ និងថុល្លច្ច័យ ។ ក្នុងអកប្បិយមំសៈដែលនៅសល់ ជាបាចិត្តិយ និងទុក្កដ ។ កាលលេបចូលទៅយាមកាលិក មកមាត់ដែលមានអាមិសកាលមានហេតុ ជាបាចិត្តិយ ២ ។ មកមាត់មិនមានអាមិសជាបាចិត្តិយតែមួយប៉ុណ្ណោះ ។ កាលលេបចូលទៅដើម្បីប្រយោជន៍ជាអាហារ ទុក្កដបន្ថែមឡើងសូម្បីក្នុងវិកប្បទាំង ២ ។ បើភិក្ខុលេបចូលទៅក្នុងវេលាវិកាល, ក្នុងភោជនតាមប្រក្រតី ជាបាចិត្តិយ២ ព្រោះការសន្និធិជាបច្ច័យ ១ ព្រោះឆាន់ក្នុងវិកាលជាបច្ច័យ ១ ។ ក្នុងអកប្បិយមំសៈ ថុល្លច្ច័យនិងទុក្កដបន្ថែមឡើង ។ ក្នុងពួកយាមកាលិកមិនជាអាបត្តិ ព្រោះឆាន់ក្នុងវិកាលជាបច្ច័យ ។ តែមិនជាអាបត្តិក្នុងវិកប្បគ្រប់យ៉ាង ក្នុងវេលាវិកាល ព្រោះសេចក្តីមិនជារបស់សល់ក្នុងយាមកាលិកជាបច្ច័យ ។

ពាក្យថា សត្តាហកាលិកំ យាវជីវិកំ អាហារត្ថាយ : (ទទួលវត្ថុជា) សត្តាហកាលិក យាវជីវិក ដើម្បីប្រយោជន៍ជាអាហារ

មានសេចក្តីថា កាលភិក្ខុទទួលប្រគេនដើម្បីប្រយោជន៍ជាអាហារ ជាទុក្កដ ព្រោះការទទួលប្រគេនជាបច្ច័យមុន ។ តែកាលលេបចូលទៅ បើជារបស់មិនមានអាមិសជាទុក្កដ គ្រប់ ៗម៉ាត់ដែលលេបចូល ។ បើសត្តាហកាលិកយាវជីវិក លាយដោយអាមិសជារបស់ដែលភិក្ខុទទួលប្រគេនរក្សាទុកជាបាចិត្តិយតាមវត្ថុពិត ។

[១៣៣] ក្នុងពាក្យថា អនាបត្តិ យាវកាលិកំ : **មិនមានអាបត្តិ ដល់ភិក្ខុដែលទុកដាក់វត្ថុជាយាវកាលិក** ជាដើម មានវិនិច្ឆ័យថា ខាទនីយៈភោជនីយៈ ដែលព្រះមានព្រះភាគទ្រង់សម្តែងពង្រីកទុកហើយក្នុងវិកាលភោជនសិក្ខាបទ ហៅថា យាវកាលិក ព្រោះជារបស់ដែលភិក្ខុគប្បីឆាន់បានមួយវេលា គឺ ថ្ងៃត្រង់, បានៈ ៨ យ៉ាង នឹងពួកអនុលោមបានៈ ហៅថា យាមកាលិក ដោយអត្ថថា មានវេលាជាមួយយាម ព្រោះជារបស់ដែលភិក្ខុគប្បីឆាន់បានរហូតដល់អស់មួយយាម គឺ បច្ឆិមយាមនៃរាត្រី, ភេសជ្ជៈ ៥ យ៉ាង មានសប្បិជាដើម ហៅថា សត្តាហកាលិក ដោយអត្ថថា មានវេលា ៧ ថ្ងៃ ព្រោះជារបស់ដែលភិក្ខុគប្បីរក្សាទុកបានដល់ ៧ ថ្ងៃ, កាលិកដែលនៅសល់ សូម្បីទាំងអស់ វៀរទឹកចេញ ហៅថា យាវជីវិក ព្រោះជារបស់ដែលភិក្ខុគប្បីរក្សាទុកឆាន់បានរហូតដល់

អស់ជីវិតកាលមានហេតុ ។

បណ្តាកាលិកទាំងនោះ ភិក្ខុរក្សាយាវកាលិកដែលទទួលប្រគេនក្នុងវេលាអរុណរះទុក ឆាន់បានទាំងវេលាថ្ងៃត្រង់ ដរាបប៉ុនដែលកាលវេលាមិនទាន់កន្លងទៅ, ឆាន់យាមកាលិកបានរហូតដល់អស់មួយថ្ងៃ ១ នឹងយប់ ១, ឆាន់សត្តាហកាលិកបាន ៧ យប់ ឆាន់យាវជីវិកក្រៅនេះបាន រហូតដល់អស់ជីវិត កាលមានហេតុ មិនជាអាបត្តិ, បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយស្រួលទាំងអស់នោះឯង ។

តែក្នុងឋានៈនេះ ក្នុងអដ្ឋកថាទាំងឡាយ លោកពោលបែបកថាកប្បិយានុលោមកថា កថាមានជាដើមថា យាមកាលិក និងយាវកាលិកលាយគ្នា គួរឬទេ ? និងកប្បិយភូមិកថាទុកពិស្តារហើយ ។ ខ្ញុំនឹងពោលកថានោះ ៗ ក្នុងអាគតស្ថាននោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ កើតឡើងមកកាយ ១ កាយចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្មមានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សន្និធិការកសិក្ខាបទទី ៨ ចប់

# ៩. បណីតភោជនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

## ពន្យល់រឿងភោជនដែលប្រណីត

[១៣៤] បទថា បណីតភោជនានិ : ភោជនដ៏ឧត្តមទាំងឡាយ បានដល់ ភោជនយ៉ាងល្អក្រៃលែង ។

ពាក្យថា កស្ស សម្បន្នំ ន មនាបំ : អ្នកណាមួយមិនគាប់ចិត្តនឹងភោជនដែលសម្បូរ បានដល់ ភោជនដែលប្រកបដោយគុណសម្បត្តិ អ្នកណានឹងមិនពេញចិត្ត ។

បទថា សាធុំ[១] : មានរសឆ្ងាញ់ គឺ រសល្អ ។

[១៣៥] ក្នុងពាក្យថា យោ បន ភិក្ខុ ឯវរូបានិ បណីត-ភោជនានិ អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជេយ្យ : ភិក្ខុណាមួយ គ្មានជម្ងឺ សូមភោជនដ៏ឧត្តមទាំងឡាយ មានសភាពយ៉ាងនេះ ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុសូមភោជនដែលល្អសុទ្ធ ៗ មានសប្បិជាដើមមកឆាន់ មិនត្រូវបាចិត្តិយ ។ ត្រូវទុក្កដ ព្រោះសូមសម្លនិងបាយក្នុងសេក្ខិយវត្ត ។

១. ថៃ. សាទូ ។

តែភិក្ខុដែលសូមបណីតភោជន ដែលលាយនឹងបាយមកឆាន់ បណ្ឌិតគប្បីជ្រាបថា ត្រូវបាចិត្តិយ ។

ជ្រាបថា ក្នុងពាក្យនេះ មានអធិប្បាយដូចតទៅនេះ ៖

ក៏ព្រោះហេតុនោះឯង ព្រះមានព្រះភាគទើបមិនត្រាស់ថា បណីតានិ : ដ៏ឧត្តមទាំងឡាយ ត្រាស់ក្នុងសូត្រថា បណីតភោជនានិ : ភោជនដ៏ឧត្តមទាំងឡាយ ។ ពិតមែន កាលព្រះអង្គត្រាស់ថា បណីតានិ រមែងរួមយកសប្បិជាដើមចូលផង ។ តែកាលត្រាស់ថា បណីតភោជនានិ រមែងមានសេចក្តីប្រាកដដូច្នេះថា ភោជនដែលកើតអំពីធញ្ញជាតិ ៧ ប្រភេទ លាយដោយរបស់ប្រណីត ឈ្មោះថា ភោជនប្រណីត ។

[១៣៧] ឥឡូវនេះ ក្នុងពាក្យថា វិញ្ញាបេតិ បយោគេ ទុក្កដំ : សូម ត្រូវអាបត្តិរាល់ប្រយោគ ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

កាលភិក្ខុសូមថា លោកចូរឱ្យភត្តនឹងទឹកដោះថ្លា, ចូរចាក់ទឹកដោះថ្លាឱ្យ, នឹងធ្វើឱ្យលាយទឹកដោះថ្លាហើយឱ្យ, ចូរឱ្យទឹកដោះថ្លា, ចូរឱ្យទឹកដោះថ្លានិងភត្ត ដូច្នេះជាទុក្កដ ព្រោះការសូម, ជាទុក្កដ ព្រោះទទួលប្រគេន, ជាបាចិត្តិយ ព្រោះលេបចូលទៅ ។ តែកាលភិក្ខុពោលថា "លោកចូរឱ្យសប្បិភត្ត" ព្រោះធម្មតាថា សប្បិភត្តដូចសាលីភត្តមិនមានដូច្នោះ បណ្ឌិតគប្បីជ្រាបថា ជាទុក្កដ ព្រោះសូមសម្លនិងបាយតែ

ម្យ៉ាង ។

ក៏បើកាលភិក្ខុពោលថា "ចូរឱ្យភត្តនិងទឹកដោះថ្លា" តែទាយក ប្រគេនភត្តហើយ ប្រគេនទឹកដោះខាប់ ទឹកដោះស្រស់ ឬទឹកដោះជូរ ដោយពោលថា "និមន្តលោកធ្វើទឹកដោះថ្លាឆាន់ចុះ" ក៏ឬប្រគេនមូលតម្លៃ ពោលថា "និមន្តលោកទទួលយកទឹកដោះថ្លាដោយមូលតម្លៃនេះឆាន់ចុះ" ( ជាបាចិត្តិយ ) តាមវត្ថុតែម្តង ។

តែកាលភិក្ខុពោលថា "ចូរឱ្យភត្តព្រមទាំងសប្បិគោ" ទាយក ប្រគេនដោយសប្បិគោ ឬកាលសប្បិគោមិនមាន ប្រគេនទឹកដោះគោខាប់ ជាដើម ដោយន័យមុននោះឯង ឬប្រគេនមេគោតែម្តងក៏ដោយ ពោលថា "និមន្តលោកឆាន់ដោយទឹកដោះថ្លាអំពីមេគោនេះ" ( ជាបាចិត្តិយ ) តាម វត្ថុដូចគ្នា ។

តែបើទាយកត្រូវភិក្ខុសូមដោយសប្បិគោ ប្រគេនដោយសប្បិពពែ ជាដើមជាការខុសសង្កេត ។ ពិតមែន កាលមានការប្រគេនយ៉ាងនេះ ទើបជាការដែលទាយកត្រូវភិក្ខុសូម មួយយ៉ាង, ប្រគេនទៅ មួយយ៉ាង ទៀត ព្រោះដូច្នោះ ទើបមិនជាអាបត្តិ ។ សូម្បីក្នុងពាក្យថា ចូរឱ្យដោយ សប្បិពពែជាដើម ក៏ន័យនេះ ។ កាលភិក្ខុពោលថា "ចូរឱ្យដោយ កប្បិយទឹកដោះថ្លា" ទាយកប្រគេនដោយអកប្បិយទឹកដោះថ្លា ជាការខុស សង្កេតដូចគ្នា ។

កាលភិក្ខុពោលថា “ចូរឱ្យដោយអកប្បិយទឹកដោះថ្លា” ទាយក ប្រគេនដោយអកប្បិយទឹកដោះថ្លា ជាទុក្កដដូចគ្នា ទាំងក្នុងការទទួលទាំងក្នុងការបរិភោគ ។ កាលអកប្បិយទឹកដោះថ្លាមិនមាន គេប្រគេនដោយអកប្បិយទឹកដោះខាប់ជាដើម ដោយន័យមុននុ៎ះឯង ដោយពោលថា “និមន្តលោកធ្វើទឹកដោះថ្លាឆាន់ចុះ” ជាការដែលគេប្រគេនដោយអកប្បិយទឹកដោះថ្លាពិត ។

កាលភិក្ខុពោលថា “ដោយអកប្បិយទឹកដោះថ្លា” គេប្រគេនដោយកប្បិយទឹកដោះថ្លា ជាការខុសសង្កេតដូចគ្នា ។ កាលពោលថា “ដោយទឹកដោះថ្លា” គេប្រគេនដោយរបស់យ៉ាងណាមួយ មានទឹកដោះខាប់ជាដើមដែលនៅសល់ ជាការខុសសង្កេតដូចគ្នា ។ សូម្បីក្នុងពាក្យថា “ចូរប្រគេនដោយទឹកដោះខាប់”ជាដើម ក៏ន័យនេះដូចគ្នា ។

ពិតមែន មានការសូមដោយវត្ថុណា ៗ កាលភិក្ខុបានវត្ថុនោះ ឬមូលតម្លៃនៃវត្ថុនោះហើយ ចាត់ថា បានវត្ថុនោះ ៗហើយដូចគ្នា ។ តែបើគេប្រគេនរបស់ដទៃដែលមកក្នុងព្រះបាលី ឬមិនបានមកក៏ដោយ ជាខុសសង្កេត ។ កាលភិក្ខុសូមដោយទឹកដោះខាប់ជាដើមយ៉ាងដទៃ វៀរលែងតែទឹកដោះខាប់ដែលមកក្នុងព្រះបាលីជាដើមចេញ ជាទុក្កដ ។ ដូចដែលលោកពោលទុកថា កាលភិក្ខុពោលថា “ចូរឱ្យសប្បិភត្ត” ការសូម

សមូទិនបាយ ជាទុក្កដប៉ុណ្ណោះ ព្រោះសប្បិកត្តមិនមានដូចសាលីកត្ត យ៉ាងណា សូម្បីក្នុងពាក្យថា ចូរឱ្យនវនីតកត្តជាដើម ក៏យ៉ាងនោះ (គឺត្រឹមតែជាទុក្កដដែរ) ។

ពិតមែន សូម្បីកាលនឹងពោលទឹកដោះខាប់ជាដើមទីមួយ ៗ ឱ្យពិស្តារតាមលំដាប់ (នៃទឹកដោះខាប់) ក៏នឹងត្រូវពោលសេចក្តីនេះឯង ។ និងសេចក្តីពិស្តារនោះ បណ្ឌិតអាចដឹងបានសូម្បីដោយសេចក្តីសង្ខេប, នឹងមានប្រយោជន៍អ្វីដោយសេចក្តីពិស្តារក្នុងទឹកដោះខាប់តែមួយយ៉ាងជាដើមនោះ ។ ព្រោះហេតុនោះ ខ្ញុំទើបបានពោលថា សូម្បីក្នុងពាក្យថា ចូរឱ្យដោយទឹកដោះខាប់ជាដើម ក៏ន័យនេះដូចគ្នា ។

តែបើភិក្ខុសូមក្នុងទីជាមួយគ្នា ឬក្នុងទីផ្សេងគ្នា ដោយវត្ថុមានទឹកដោះថ្លាជាដើមសូម្បីទាំងអស់ ចាក់របស់ដែលបានហើយចូលក្នុងភាជនៈជាមួយគ្នា ធ្វើឱ្យមានរសតែមួយ សូម្បីយកចុងស្បូវជ្រលក់យកមួយតំណក់ដាក់លើចុងអណ្តាត អំពីរសនោះ ហើយលេបចូលទៅ ត្រូវអាបត្តិបាចិត្តិយ ៩ ។ សមពិត ដូចពាក្យសូម្បីនេះ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងគម្ពីរបរិវារៈថា ៖

"ភិក្ខុត្រូវបាចិត្តិយទាំងអស់ ៩ ដែលមានវត្ថុផ្សេង ៗគ្នា
ក្នុងខណៈមួយ មិនមុន មិនក្រោយ", ប្រស្នានេះ ពួក

លោកអ្នកឈ្លាសវៃបានគិតមកហើយ ។[១]

[១៣៨] ក្នុងពាក្យថា អគិលានោ គិលានសញ្ញី : ខុទមិនឈឺ សំគាល់ថា ខុទឈឺ នេះ មានវិនិច្ឆ័យដូច្នេះ ៖

បើភិក្ខុសូម្បីជាអ្នកមានសេចក្តីសម្គាល់ថា អាពាធ សូមភេសជ្ជៈ ៥ ដើម្បីប្រយោជន៍ដល់ភេសជ្ជៈ, ព្រះវិន័យធរគប្បីពិន័យ លោកដោយមហានាមសិក្ខាបទ ។ តែកាលសូមភោជនប្រណីត ៩ យ៉ាង គប្បីពិន័យដោយសិក្ខាបទនេះ ។ តែភោជនប្រណីត ៩ យ៉ាងនេះ ជាបាដិទេសនីយវត្ថុសម្រាប់ពួកភិក្ខុនី ។ ព្រោះការសូមសម្លនិងបាយជាទុក្កដដែលត្រាស់ទុកក្នុងសេក្ខិយបញ្ញត្តិប៉ុណ្ណោះ ដល់ភិក្ខុនិងភិក្ខុនីសូម្បីទាំង ២ ពួក បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៤ កើតឡើងមកកាយ ១ កាយវាចា ១ កាយចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បណីតភោជនសិក្ខាបទវណ្ណនា ចប់

---

១. វិន. បរិ. ទុតិយគាថាសង្គណិក. ១៣. ៣៤១/៣៨០ ។

# ១០. ឧន្ទោណសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

## ពន្យល់រឿងភិក្ខុកាន់បង្សុកូលគ្រប់យ៉ាង

[១៤០] ភិក្ខុនោះ ឈ្មោះថា សព្វបង្សុកូលិកៈ (អ្នកមានប្រក្រតីកាន់បង្សុកូលគ្រប់យ៉ាង) ព្រោះអត្ថថា ភិក្ខុនោះមានបណ្ដាបច្ច័យ ៤ គ្រប់យ៉ាង ដោយហោចទៅ សូម្បីឈើជម្រះធ្មេញក៏ជាបង្សុកូលទាំងនោះ ។ បានឮថា ភិក្ខុនោះ ធ្វើភាជនៈដែលគេចោលក្នុងព្រៃជាទីចោលសាកសពនោះឯងឱ្យជាបាត្រ ធ្វើចីវរដោយកំណាត់សំពត់ដែលគេចោលក្នុងព្រៃជាទីចោលសាកសពនោះឯង កាន់យកគ្រែនិងតាំងដែលគេចោលក្នុងព្រៃជាទីចោលសាកសពនោះដែរ មកប្រើប្រាស់ ។

ជីដូនទនិងជីតារបស់បិតាស្លាប់ទៅហើយ ហៅថា អយ្យៈ ក្នុងពាក្យថា អយ្យវោសាដិតកានិ : **កាន់យកនូវសំណែន** នេះ ។ ខាទនីយៈ និងភោជនីយៈ ដែលគេសែនទុកចោលក្នុងព្រៃ ជាទីចោលសាកសពជាដើម ដើម្បីប្រយោជន៍ដល់បុព្វបុរសទាំងនោះ ហៅថា វោសាដិតកៈ (សំណែន) ។ បានឮថា ពួកមនុស្សបានធ្វើរបស់ដែលជាទីស្រឡាញ់នៃពួកញាតិទាំងនោះ ក្នុងវេលាដែលនៅមានជីវិត ឱ្យជាដុំបាយឧទ្ទិសជូនពួកញាតិដែលស្លាប់ទៅហើយ សែនដាក់ទុកក្នុងទីទាំង

ឡាយ មានព្រៃជាទីបោលសាកសពជាដើមនោះ ដោយតាំងចិត្តថា "ពួកញាតិរបស់ពួកយើង ចូរបរិភោគចុះ" ។

ភិក្ខុនោះ យកដុំបាយនោះមកឆាន់, មិនប្រាថ្នារបស់ដទៃ សូម្បីប្រណីតដែលគេប្រគេន ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ទើបពោលថា "ភិក្ខុនោះកាន់យកនូវសំណែនក្នុងព្រៃស្មសានខ្លះ ទៀបគល់ឈើខ្លះ ទៀបធរណីទ្វារខ្លះ ដោយខ្លួនឯង ហើយឆាន់" ដូច្នេះ ។

បទថា ថេរោ : ជាថេរៈ មានសេចក្ដីថា មាំមួន គឺ រឹងប៉ឹង ។

បទថា វធរោ[1] : មានកាយធាត់ គឺ ធាត់ត្រលុក ។ មានពាក្យអធិប្បាយថា ភិក្ខុនេះ ធាត់ផង មានរាងកាយរឹងមាំផង ។

បីបទថា មនុស្សមំសំ មញ្ញេ ខាទតិ : ទំនងជាស៊ីសាច់មនុស្សទេដឹង មានសេចក្ដីថា ពួកយើងសម្គាល់ភិក្ខុនោះថា "ពេលខ្លះនឹងឆាន់សាច់មនុស្សហើយមើលទៅ" ។ ប្រជាជនទាំងនោះមានសេចក្ដីសម្គាល់ដូច្នេះថា "ពិតណាស់ ពួកអ្នកស៊ីសាច់មនុស្ស រមែងធាត់យ៉ាងនេះ" ។

[១៤១] ក្នុងពាក្យថា ឧទកទន្តបោណេ កុក្កុច្ចាយន្តិ : មានសេចក្ដីសង្ស័យក្នុងទឹកនិងឈើស្ទន់ នេះ មានវិនិច្ឆ័យដូច្នេះ ៖

១. ថៃ. វធ្ធរោ ។

ពួកភិក្ខុទាំងនោះ មិនបានសង្កេតអត្ថនៃបទថា "លេបនូវអាហារតាមទ្វារមាត់ជាអាហារដែលគេមិនបានប្រគេន" ឱ្យបានត្រឹមត្រូវ ទើបនាំគ្នារង្កៀស ។ ចំណែកព្រះមានព្រះភាគកាលនឹងទ្រង់ញ៉ាំងភិក្ខុទាំងនោះឱ្យយល់ព្រម ដោយអំណាចនៃរឿងតាមដែលកើតឡើងហើយ ដូចបិតាពន្យល់ឱ្យពួកកូន ៗយល់ព្រម ដូច្នោះ ទើបទ្រង់តាំងអនុប្បញ្ញត្តិទុក ។

បទថា អទិន្នំ : **ដែលមិនបានប្រគេន** មានសេចក្ដីថា គេមិនបានឱ្យដោយកាយ របស់ជាប់ដោយកាយ និងការបោះឱ្យយ៉ាងណាមួយដល់ភិក្ខុដែលទទួល ដោយកាយ ឬដោយរបស់ជាប់ដោយកាយ ។ ពិតមែន ព្រះឧបាលី សំដៅយករបស់ដែលគេមិនបានឱ្យនេះឯង ទើបបានពោលទុកក្នុងបទភាជនៈថា "ដែលហៅថា គេមិនបានប្រគេន គឺសំដៅយកវត្ថុដែលភិក្ខុនៅមិនបានទទួលប្រគេន" ។ តែក្នុងទុតិយបារាជិកត្រាស់ថា "ដែលឈ្មោះថា ទ្រព្យដែលគេមិនបានឱ្យ (នោះ) គឺ របស់ណាដែលគេមិនទាន់ឱ្យ មិនទាន់លះបង់ឱ្យ ... ... ទ្រព្យនោះ ឈ្មោះថាទ្រព្យដែលគេមិនបានឱ្យ"[១] ។ ចំណែកបទថា "របស់ដែលគេឱ្យ" នេះលោកលើកឡើងទុក ដើម្បីសម្ដែងលក្ខណៈនៃរបស់ដែលគេមិនបានឱ្យនោះឯង ដោយអំណាចនៃន័យដែលផ្ទុយគ្នា ។

---

១. វិន. បារា. អទិន្នាទាន. ១. ៨៥/១៥១-២ ។

## ការប្រគេននិងការទទួលប្រគេន

[១៤២] ក៏ក្នុងនិទ្ទេសនៃបទថា ទិន្នំ នោះ មានវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា កាយេន វា កាយបដិពទ្ធេន វា និស្សគ្គិយេន វា ទេន្តេ : កាលបើទាយកឱ្យរបស់ណាដោយកាយក្តី ដោយរបស់ជាប់នឹងកាយក្តី ដោយបោះឱ្យក្តី បានដល់ កាលអ្នកដទៃគេឱ្យយ៉ាងនេះ (គឺ ឱ្យនៅដោយកាយ ឬដោយរបស់ជាប់ដោយកាយ ឬដោយករបោះឱ្យ) ។

ពាក្យថា ហត្ថបាសេ ឋិតោ កាយេន វា កាយបដិពទ្ធេន វា បដិគ្គណ្ហាតិ : ភិក្ខុស្ថិតនៅក្នុងហត្ថបាសបានទទួលដោយកាយ ឬដោយរបស់ដែលជាប់នឹងកាយ មានសេចក្តីថា បើភិក្ខុនៅក្នុងហត្ថបាសមានលក្ខណៈ ដូចពោលហើយខាងដើម ទទួលប្រគេនរបស់នោះ ដែលគេឱ្យយ៉ាងនោះ ដោយហោចទៅ សូម្បីល្អងនៃរថ ដោយកាយ ឬដោយរបស់ជាប់ដោយកាយ ។ វត្ថុនោះ ដែល ទទួលប្រគេនហើយ យ៉ាងនេះលោកហៅថា របស់ដែលគេឱ្យ ។ របស់ដែលគេលះបង់ឱ្យដោយពាក្យថា "លោកចូរកាន់យករបស់នេះ, របស់នេះចូរជារបស់លោក"ជាដើម លោកមិនហៅថា របស់ដែលគេឱ្យទេ ។

បណ្តានិទ្ទេសទាំងនោះ បទថា កាយេន : ដោយកាយ មាន

សេចក្តីថា ដែលគេឱ្យដោយបណ្តាសរីរាវយវៈមានដៃជាដើម យ៉ាងណាមួយ ដោយហោចទៅ សូម្បីដោយម្រាមជើង ក៏ឈ្មោះថា គេឱ្យហើយដោយកាយ ។ សូម្បីក្នុងការទទួលប្រគេន ក៏ន័យនេះឯង ។ ពិតមែនរបស់ដែលភិក្ខុទទួលប្រគេនដោយសរីរាវយវៈ (ចំណែកនៃរាងកាយ) ចំណែកណាមួយចាត់ថា ទទួលប្រគេនហើយដោយកាយដូចគ្នា ។ ប្រសិនបើថា គេឱ្យរបស់ដែលត្រូវធ្វើការនត្ថុ ភិក្ខុអាពាធមិនអាចនត្ថុចូលតាមរន្ធច្រមុះបានឡើយ ទទួលចូលតាមមាត់បាន (ទទួលប្រគេនតាមមាត់បាន) ។ សេចក្តីពិត ត្រឹមតែការដាក់ចិត្តប៉ុណ្ណោះ ជាប្រមាណក្នុងការទទួលប្រគេននេះ ។ ន័យនេះ លោកពោលទុកក្នុងមហាបច្ចរី ។

បទថា កាយបដិពទ្ធេន : ដោយរបស់ដែលជាប់នឹងកាយ មានសេចក្តីថា របស់ដែលគេឱ្យដោយឧបករណ៍យ៉ាងណាមួយ បណ្តាឧបករណ៍ មានវែកជាដើម ឈ្មោះថា គេឱ្យដោយរបស់ជាប់ដោយកាយ ។ សូម្បីក្នុងការទទួលប្រគេន ក៏ន័យដូចគ្នា ។ របស់ដែលភិក្ខុទទួលដោយវត្ថុយ៉ាងណាមួយដែលជាប់ដោយរាងកាយ មានបាត្រនិងថាសជាដើម ចាត់ថា ទទួលប្រគេនដោយរបស់ជាប់ដោយកាយដូចគ្នា ។

បទថា និស្សគ្គិយេន : ដោយបោះឱ្យ មានសេចក្តីថា ក៏របស់ដែលគេប្រគេនដោយបោះឱ្យផុតពីកាយ និងឱ្យផុតពីរបស់ជាប់ដោយ

កាយ ដល់ភិក្ខុដែលនៅក្នុងហត្ថបាសដោយកាយ ឬរបស់ជាប់ដោយកាយ ឈ្មោះថា គេប្រគេនដោយប្រយោគដែលបោះឱ្យ ។ នេះជាការពណ៌នាតាមព្រះបាលី ។

## បាលីមុត្តកវិនិច្ឆ័យ

ក៏ក្នុងសិក្ខាបទនេះ គប្បីជ្រាបបាលីមុត្តកវិនិច្ឆ័យដូចតទៅនេះ ៖

## ការទទួលប្រគេនមានអង្គ ៥ យ៉ាង

ការទទួលប្រគេន រមែងឡើងដោយអង្គ ៥ គឺ របស់ល្មមមជ្ឈិមបុរសលើកបាន ១ ហត្ថបាសប្រាកដ (គេនៅក្នុងហត្ថបាស) ១ ការបង្អោនប្រគេនប្រាកដ (គេបង្អោនប្រគេន) ១ ទេវតាក៏ដោយ មនុស្សក៏ដោយ តិរច្ឆានក៏ដោយ ប្រគេន ១ និងភិក្ខុទទួលប្រគេនរបស់នោះដោយកាយ ឬដោយរបស់ជាប់ដោយកាយ ១ ការទទួលប្រគេន រមែងឡើងដោយអង្គ ៥ ដោយប្រការយ៉ាងនេះ ។ ក្នុងអង្គ ៥ នោះ ហត្ថបាសនៃភិក្ខុដែលឈរអង្គុយនិងដេក បណ្ឌិតគប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងបវារណាសិក្ខាបទ ។

ក៏បណ្ដាអ្នកឱ្យនិងអ្នកទទួលប្រគេន ចំណែកមួយនៅលើអាកាស ចំណែកមួយនៅលើផែនដី, គប្បីកំណត់ប្រមាណហត្ថបាសខាងសីសៈ

របស់អ្នកឈរលើផែនដី និងខាងផ្នែកចុងក្នុងនៃអវយវៈដែលជិតជាង របស់អ្នកឈរលើអាកាស វៀរលែងតែដៃដែលលាតចេញ ដើម្បីប្រគេន ឬដើម្បីទទួល ។ ប្រសិនបើថា មួយផ្នែកនៅក្នុងរណ្ដៅ មួយផ្នែកទៀតនៅមាត់រណ្ដៅ ឬមួយផ្នែកនៅលើដើមឈើ មួយផ្នែកទៀតនៅលើផែនដី ក៏គប្បីកំណត់ប្រមាណហត្ថបាស ដោយន័យដូចពោលហើយនុ៎ះឯង ។

ប្រសិនបើថា បក្សីយកចំពុះពាំផ្កាឈើ ឬផ្លែឈើប្រគេន ឬដំរីយកប្រមោយចាប់ផ្កាឈើ ឬផ្លែឈើប្រគេននៅក្នុងហត្ថបាសបែបនេះ, ការទទួលប្រគេន រមែងឡើង (ឆាន់បាន) ។ ក៏បើភិក្ខុអង្គុយនៅលើកដំរីសូម្បីខ្ពស់ ៧ហត្ថ ១ចំអាម ទឹងទទួលរបស់ដែលដំរីនោះ ប្រគេនដោយប្រមោយក៏គួរដែរ ។ ទាយកម្នាក់ទូលភាជន៍បាយ និងម្ហូបក្រៀមយ៉ាងច្រើនទុកលើសីសៈ មកកាន់លំនៅរបស់ភិក្ខុនិយាយទាំងឈរថា និមន្តលោកទទួលចុះការបង្អោនប្រគេនមិនទាន់ប្រាកដ ព្រោះដូច្នោះ ទើបមិនគួរទទួល ។ តែបើគេបង្អោនចុះមកសូម្បីត្រឹមតែបន្តិចបន្តួច, ភិក្ខុគប្បីលាតដៃចេញទៅទទួលភាជនៈពីខាងក្រោម សូម្បីដោយឯកទេស ។ ដោយការទទួលត្រឹមតែប៉ុណ្ណោះ ភាជនៈទាំងអស់ជាការទទួលប្រគេនហើយ ។ តាំងពីទទួលប្រគេននោះទៅ ទឹងលើកចុះ ឬបន្ធិតចេញ ហើយចាប់យករបស់ដែលខ្វនត្រូវការសមគួរ ។ ចំណែកក្នុងភាជន៍ជា

មួយគ្នាមានកញ្ចប់បាយក្រៀមជាដើម មិនមានពាក្យដែលនឹងគប្បីពោលឡើយ ។

សូម្បីទាយកវែកកត្តាហារទៅ បើបង្អោនសង្រ្កេចុះប្រគេន សមគួរ ។ ប្រសិនបើថា មានឫស្សីប្រវែង ៣០ហត្ថ, នៅចុងម្ខាងចងបន្តោងឆ្នាំងទឹកអំពៅទុក នៅចុងម្ខាងចងបន្តោងឆ្នាំងទឹកដោះថ្លាទុក, បើភិក្ខុទទួលប្រគេនដើមឫស្សីនោះ ឈ្មោះថា ទទួលប្រគេនរបស់ទាំងអស់ដូចគ្នា ។

បើទាយកពោលថា និមន្តលោកទទួលទឹកអំពៅដែលកំពុងហូរចេញអំពីចុងទឹកអំពៅ ការបង្អោនចូលមកប្រគេន មិនទាន់ប្រាកដ ព្រោះដូច្នោះ ទើបមិនសមគួរទទួល ។ តែបើគេយកកាកចោលហើយយកដៃក្បង់ឡើងប្រគេន គួរ ។

បាត្រជាច្រើន គេដាក់លើគ្រែក្តី លើតាំងក្តី លើកន្ទេលផែនក្តី លើស្នូកឈើក្តី លើផែនក្តារក្តី ។ ទាយក (អ្នកឱ្យ) នៅក្នុងហត្ថបាសនៃភិក្ខុដែលនៅក្នុងទីណា, របស់ដែលគេឱ្យក្នុងបាត្រទាំងនោះ ដែលភិក្ខុនៅក្នុងទីនោះ សូម្បីយកម្រាមចុចគ្រែជាដើម ដោយកំណត់ថា ទទួលប្រគេនទីងឈរក្តី អង្គុយក្តី ដេកក្តី ឈ្មោះថា ទទួលប្រគេនហើយទាំងអស់ ។ ប្រសិនបើថា ភិក្ខុឡើងអង្គុយលើគ្រែជាដើម ដោយកំណត់ថា យើងនឹងទទួលប្រគេន ក៏គួរដូចគ្នា ។

ក៏ប្រសិនបើថា គេដាក់បាត្រទាំងឡាយទុកលើផែនដី យកក្អេងនិងក្អេងទល់គ្នា, របស់ដែលគេប្រគេនក្នុងបាត្រដែលភិក្ខុអង្គុយយកម្រាមដៃ ឬម្ដូលចុចទុកប៉ុណ្ណោះ ជាការទទួលប្រគេនហើយ ។ លោកពោលទុកក្នុងទីកន្លែងខ្លះថា ការទទួលប្រគេនក្នុងបាត្រដែលគេតាំងទុកលើកន្ទេលផែងផ្ទាំងធំ និងកម្រាលលើខ្នងដំរីជាដើម រមែងមិនឡើង ។ ពាក្យនោះ គប្បីជ្រាបថា លោកពោលសំដៅយកការកន្លងហួសហត្ថបាសទៅ ។ តែកាលមានហត្ថបាសក្នុងទីណាមួយក៏គួរ ក្រៅអំពីរបស់ដែលកើតនៅនឹងថ្កល់ក្នុងទីនោះ ។

ក៏ការទទួលប្រគេនលើស្លឹកឈូក ឬលើស្លឹកចាជាដើម ដែលកើតនៅនឹងទីនោះ រមែងមិនគួរ ។ ព្រោះស្លឹកឈូកជាដើមនោះ មិនដល់ការរាប់ថា របស់ជាប់ដោយកាយ ។ ដូចយ៉ាងថា ក្នុងរបស់កើត នឹងថ្កល់ក្នុងទីនោះ ការទទួលប្រគេនមិនឡើង យ៉ាងណា, ក្នុងគ្រែដែលភ្ជាប់នៅត្រង់ជង្គត់ឈើជាដើម ក្នុងបន្ទះក្ដារ ឬ ក្នុងថ្មដែលជាអសង្ហារិមៈការទទួលប្រគេន ក៏មិនឡើងដូចគ្នា ដូច្នោះ ។ ពិតមែន គ្រែដែលភ្ជាប់នឹងគល់ជង្គត់ជាដើមសូម្បីនោះ ជារបស់គួរសង្គ្រោះចូលនឹងរបស់ដែលកើតនៅទីនោះ ។

សូម្បីលើស្លឹកអំពិលជាដើម ដែលជាស្លឹកតូច ៗរាយពេញនៅ

លើផែនដី ការទទួលប្រគេនក៏មិនឡើង ។ ព្រោះថា ស្លឹកអំពិលជាដើមទាំងនោះ មិនអាចទឹងតាំងទុកបានដោយល្អ ។ តែលើស្លឹកដែលធំមានស្លឹកបទុមជាដើម (ទទួលប្រគេន) ឡើង ។

បើទាយក (អ្នកឱ្យ) ឈរហួសហត្ថបាសក្នុងទីនោះ យកវែកដងវែងជួសប្រគេន, ភិក្ខុគប្បីប្រាប់គេថា "ចូលមកប្រគេនជិត ៗ" ។ គេមិនបានឮពាក្យនិយាយ ឬមិនអើពើចាក់ចុះទៅក្នុងបាត្រតែម្តង, ភិក្ខុគប្បីទទួលប្រគេនថ្មី ។ សូម្បីក្នុងបុគ្គលអ្នកឈរឆ្ងាយបោះដុំបាយទៅប្រគេន ក៏ន័យនេះដូចគ្នា ។ បើក្នុងបាត្រដែលនាំចេញពីថង់បាត្រ មានលំអិតទឹកជ្រលក់ កាលទឹកមានគប្បីលាងចេញសិន កាលទឹកមិនមានគប្បីជូតលំអិតទឹកជ្រលក់ ឬទទួលប្រគេនហើយ ទើបត្រាច់ទៅបិណ្ឌបាត ។ បើកាលត្រាច់ទៅបិណ្ឌបាត ធូលីធ្លាក់ចូលក្នុងបាត្រ គប្បីទទួលប្រគេនសិន សឹមទទួលភិក្ខា ។ តែកាលមិនទទួលប្រគេន ទទួល (ភិក្ខា) ជាវិន័យទុក្កដ ។ តែមិនជាអាបត្តិដល់ភិក្ខុដែលទទួលប្រគេនធូលីដែលធ្លាក់នោះថ្មី ហើយឆាន់ ។ ក៏បើកាលភិក្ខុពោលថា ទទួលប្រគេនមុនចូរថ្វាយ ពួកគេមិនបានឮពាក្យនិយាយ ឬមិនអើពើប្រគេនភិក្ខុឡើយ, មិនជាវិន័យទុក្កដ ។ ភិក្ខុទទួលប្រគេនថ្មីហើយ គប្បីទទួលភិក្ខាដទៃចុះ ។

## វិធីបដិបត្តិកាលមានរបស់ធ្លាក់ចុះក្នុងបាត្រក្នុងវេលាផ្សេងៗ

បើខ្យល់ខ្លាំងបក់ធូលីឱ្យហុយទៅធ្លាក់អំពីទីនោះ ៗ, ភិក្ខុមិនអាចទទួលភិក្ខាបាន, ទើងតាំងចិត្តទទួលដោយចិត្តបរិសុទ្ធថា យើងនឹងឱ្យដល់អនុបសម្បន្ន គួរ, ត្រាច់ទៅបិណ្ឌបាតយ៉ាងនោះ ហើយត្រឡប់ទៅកាន់វិហារ ឬអាសនសាលា ឱ្យភិក្ខានោះដល់អនុបសម្បន្នហើយ នឹងទទួលយកភិក្ខាដែលអនុសម្បន្ននោះប្រគេនថ្មី ឬនឹងទទួលប្រគេនរបស់អនុបសម្បន្ននោះដោយវិស្សាសៈឆាន់ ក៏បាន ។

បើភិក្ខុឱ្យបាត្រដែលមានធូលីដល់ភិក្ខុ ក្នុងវេលាត្រាច់ភិក្ខាចារ, គប្បីប្រាប់ភិក្ខុម្ចាស់របស់បាត្រនោះថា លោកទទួលប្រគេនបាត្រនេះហើយគប្បីទទួលភិក្ខា ឬគប្បីឆាន់ ។ ភិក្ខុម្ចាស់របស់បាត្រនោះ គប្បីធ្វើយ៉ាងនោះ ។ បើធូលីអណ្តែតនៅខាងលើ, គប្បីបង្ហូរទឹកបាយចេញ ហើយឆាន់ចំណែកដែលនៅសល់ចុះ ។ បើធូលីហុយចូលខាងក្នុងគប្បីប្រគេនថ្មី ។ កាលមិនមានអនុបសម្បន្ន កុំលែង(បាត្រ) អំពីដៃឡើយ គប្បីនាំទៅក្នុងទីដែលមានអនុសម្បន្ន ហើយទទួលប្រគេនថ្មី ។ នឹងនាំធូលីដែលធ្លាក់ចុះក្នុងបាយស្ងួតចេញហើយឆាន់ ក៏គួរ ។ តែបើជាធូលីល្អិតច្រើន គប្បីនាំចេញព្រមនឹងបាយចំណែកខាងលើ ឬគប្បីទទួលប្រគេនថ្មីហើយឆាន់ចុះ ។

កាលអ្នកស្រុកដាក់យាគូឬសម្លទុកខាងមុខហើយគួរ តំណក់សម្ល

ខ្វាយចេញអំពីភាជនៈធ្លាក់ចូលក្នុងបាត្រ, ភិក្ខុគប្បីទទួលប្រគេនបាតជាថ្មី ។ កាលពួកគេយកបបាយដួសមកប្រគេន តំណក់ស្ទបៈជាដើមស្រក់ចេញចាកបបាយ ធ្លាក់ចូលទៅក្នុងបាត្រមុន, ជាការធ្លាក់ចូលទៅដោយល្អ មិនមានទោស ព្រោះគេបង្អោនចូលមកប្រគេន ។

ប្រសិនបើថា កាលគេកំពុងយកពែងទឹកកៀរបបាយចុះ ម្រែងភ្លើង ឬផេះធ្លាក់ចុះទៅអំពីពែងទឹក មិនមានទោសដូចគ្នា ព្រោះគេបង្អោនប្រគេន របស់ដែលគេកំពុងប្រគេនដល់ភិក្ខុរូបបន្ទាប់ទៅ របូតចេញចាកបាត្រទៅធ្លាក់ក្នុងបាត្ររបស់ភិក្ខុមួយរូបទៀត ជាការធ្លាក់ទៅដោយល្អ ចាត់ថា ទទួលប្រគេនហើយដូចគ្នា ។

កាលគេចាត់ជ្រក់ជាដើមប្រគេនដល់ភិក្ខុមួយរូប តំណក់ទឹកជ្រក់ធ្លាក់ចុះទៅក្នុងបាត្ររបស់ភិក្ខុដទៃ, លោកគប្បីទទួលប្រគេនបាត្រថ្មី ។ ពួកគេកំពុងចាប់ខាងលើបាត្ររបស់ភិក្ខុណា, កាលតំណក់ទឹកជ្រក់ធ្លាក់ចុះទៅក្នុងបាត្ររបស់ភិក្ខុនោះ មិនមានទោស ព្រោះគេបង្អោនចូលមកដោយបំណងនឹងប្រគេន ។

ពួកអ្នកស្រុកប្រគេនបាត្រពេញដោយបាយបាយាស, ភិក្ខុមិនអាចចាប់ខាងក្រោមបានព្រោះវាក្តៅ, នឹងចាប់ស្ទម្បត្រង់កណ្តាប់មាត់ ក៏គួរដូចគ្នា ។ ប្រសិនបើថា យ៉ាងនោះក៏មិនអាច ( ចាប់បាន ) គប្បីទទួលដោយជើងទ្របាត្រ ( ជើងបាត្រ ) ។

ភិក្ខុអង្គុយកន់បាត្រលង់លក់នៅក្នុងសាលាឆាន់ ។ លោកមិនដឹងថា គេកំពុងនាំភោជនមកឡើយ គេប្រគេនក៏មិនដឹង, ភោជនចាត់ថាមិនទាន់បានទទួលប្រគេន ។ តែបើលោកអង្គុយដោយដាក់ចិត្តទុក ( ពីខាងដើម ) គួរ ។ ប្រសិនបើថា លោកដកដៃចេញពីជើងបាត្រហើយយកជើងកៀបសឹងលក់ទៅ សមគួរដូចគ្នា ។ តែកាលលោកយកជើងជាន់ជើងបាត្រទុកទទួលប្រគេន កាលភ្ញាក់ឡើងហើយ ក៏ឈ្មោះថា ទទួលប្រគេនដោយមិនអើពើ, ព្រោះដូច្នោះ ទើបមិនគួរធ្វើ ។

អាចារ្យពួកខ្លះពោលថា ការទទួលប្រគេនដោយជើងទ្របាត្រយ៉ាងនេះ ឈ្មោះថា ទទួលប្រគេនដោយរបស់ជាប់នឹងបាត្រដែលជាប់ដោយកាយ ព្រោះដូច្នោះ ទើបមិនគួរ ។ ពាក្យនោះ ត្រឹមតែជាពាក្យនិយាយប៉ុណ្ណោះ ។ តែដោយអត្ថ ទាំងនោះ ក៏ជារបស់ជាប់ដោយកាយទាំងអស់ ។ និងសូម្បីក្នុងកាយសំសគ្គសិក្ខាបទ ក៏បានសម្តែងន័យនេះទុកហើយ ។ សូម្បីចាប់យករបស់ធ្លាក់ដែលគេកំពុងប្រគេនដល់ភិក្ខុ ឡើងមកឆាន់ដោយខ្លួនឯង ក៏គួរ ។

ក្នុងការចាប់យករបស់ធ្លាក់ដូច្នោះ មានសូត្រជាគ្រឿងសាធកដូចតទៅនេះថា "ម្នាលភិក្ខុទាំងឡាយ គ្រប់បាយណា ដែលគេកំពុងឱ្យហើយធ្លាក់ចុះ តថាគតអនុញ្ញាតឱ្យភិក្ខុរើសគ្រាប់បាយនោះខ្លួនឯង ហើយឆាន់ចុះ, ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា គ្រាប់បាយនោះ

ទាយកគេលះ គឺប្រគេនរួចស្រេចហើយ”[១] ។ ក៏ឯព្រះសូត្រនេះ មានអត្ថគួរអធិប្បាយ ព្រោះដូច្នោះ ក្នុងព្រះសូត្រនេះ គប្បីជ្រាបអធិប្បាយយ៉ាងនេះ របស់ណាដែលគេកំពុងប្រគេន របូតអំពីដៃរបស់អ្នកប្រគេន ធ្លាក់ចុះទៅលើផ្ទៃដីស្អាត ឬលើស្លឹកឈូក សំពត់កន្ទេលផែនជាដើម, របស់នោះនឹងចាប់ឡើងមកឆាន់ឯងក៏គួរ ។ តែរបស់ណាធ្លាក់ចុះទៅលើផ្ទៃដីមានលម្អងធូលី, របស់នោះគប្បីជូត ឬលាងធូលីលម្អងចេញហើយ ឬទទួលប្រគេនហើយឆាន់ចុះ ។ បើរបស់រមៀលទៅកាន់លំនៅរបស់ភិក្ខុដទៃ, សូម្បីភិក្ខុម្ចាស់របស់ ៗនោះនឹងឱ្យនាំយកមកក៏គួរ ។ បើលោកពោលនឹងភិក្ខុនោះថា “និមន្តលោកទុំះឯងឆាន់ចុះ” សូម្បីភិក្ខុនោះនឹងឆាន់ ក៏គួរ ។ តែភិក្ខុនោះ ដែលភិក្ខុជាម្ចាស់របស់មិនបានបង្គាប់ មិនគួរទទួល ។

ក្នុងកុរុន្ទីពោលថា សូម្បីនឹងមិនបានទទួលពាក្យបង្គាប់ នឹងទទួលដោយតាំងចិត្តថា “នឹងប្រគេនភិក្ខុដែលជាម្ចាស់របស់គ្រៅនេះ” ក៏គួរ ។

សួរថា ក៏ព្រោះហេតុអ្វី របស់នោះ ទើបមិនគួរដល់ភិក្ខុក្រៅនេះនឹងទទួល ?

ឆ្លើយថា ព្រោះព្រះមានព្រះភាគទ្រង់មិនបានអនុញ្ញាតទុក ។

ពិតមែន កាលព្រះមានព្រះភាគត្រាស់ថា “តថាគតអនុញ្ញាតឱ្យភិក្ខុ

---

១. វិន. ចុល្ល. ខុទ្ទកវត្ថុក្ខន្ធក. ១០. ២៥៥/២១២ ។

រើសគ្រាប់បាយនោះខ្លួនឯង ហើយឆាន់ចុះ”[១] ដូច្នេះ ក៏ទ្រង់អនុញ្ញាតដល់ភិក្ខុដែលគេកំពុងប្រគេនរបស់ដែលរបូតធ្លាក់ទៅនោះប៉ុណ្ណោះ ឱ្យចាប់យករបស់នោះ សូម្បីមិនបានទទួលប្រគេនឆាន់បាន ។ តែដោយពាក្យថា “ម្នាលភិក្ខុទាំងឡាយ ព្រោះថា គ្រាប់បាយនោះ ទាយកគេលះ គឺប្រគេនរួចស្រេចហើយ”[២] ទើបទ្រង់សម្តែងសេចក្តីមិនជារបស់អ្នកដទៃ ក្នុងព្រះតម្រាស់នេះ; ព្រោះដូច្នោះ ភិក្ខុដទៃចាប់ឆាន់ដោយខ្លួនឯង ទើបមិនគួរ, តែសមគួរ ព្រោះការបង្គាប់របស់ភិក្ខុដែលជាម្ចាស់របស់នៃវត្ថុនោះ ។ ន័យថា នេះជាអធិប្បាយក្នុងពាក្យថា អនុជានាមិ ភិក្ខវេ ជាដើមនេះ ។

ក៏ព្រោះរបស់ដែលរបូតធ្លាក់នោះ ទ្រង់អនុញ្ញាតទុក ព្រោះជារបស់មិនទាន់បានទទួលប្រគេន ; ដូច្នោះ ភិក្ខុមិនចាប់ពាល់របស់តាមដែលតាំងនៅទុំះឯងទេ យករបស់យ៉ាងណាមួយបិទទុក ហើយឆាន់សូម្បីក្នុងថ្ងៃស្អែក ក៏គួរ, មិនជាអាបត្តិ ព្រោះសន្និធិជាបច្ច័យ ។ តែគួរទទួលប្រគេនជាមុនហើយ សឹមឆាន់ ។ ពិតមែន ព្រះមានព្រះភាគទ្រង់អនុញ្ញាតការចាប់ឆាន់ដោយខ្លួនឯងដល់ភិក្ខុនោះ តែក្នុងថ្ងៃនោះ ក្រៅពីថ្ងៃនោះទៅ ទ្រង់មិនអនុញ្ញាត, ជ្រាបថា អត្តសូម្បីនេះ ក៏ជាអធិប្បាយក្នុងព្រះតម្រាស់ថា អនុជានាមិ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ជាដើមនេះ ។

---

១.២. វិន. ចុល្ល. ខុទ្ទកវត្ថុក្ខន្ធក. ១០. ២៥៥/២១២ ។

## អព្វោហារិកន័យដោយទូទៅ

ឥឡូវនេះ ខ្ញុំនឹងពោលអព្វោហារិកន័យតទៅ ៖

ពិតមែន កាលភិក្ខុទាំងឡាយឆាន់នោះ ធ្មេញទាំងឡាយ រមែងសឹករិចរិល, ក្រចកទាំងឡាយ រមែងសឹករិចដាច់ ពណ៌(សម្បុរ)បាត្ររមែងរបេក, ទាំងអស់ជាអព្វោហារិក ។ កាលភិក្ខុសកអំពៅជាដើមដោយយកកំបិតស្នឹម រមែងប្រាកដ ។ ស្នឹមនោះ ធម្មតាជារបស់កើតឡើងថ្មី គួរទទួលប្រគេនជាមុនទើបឆាន់ ។ កាលភិក្ខុលាងកាំបិតហើយទើបសកស្នឹមមិនប្រាកដ, មានត្រឹមតែថា ក្លិនលោហៈ, ត្រឹមតែក្លិនលោហៈនោះជាអព្វោហារិក ។ សូម្បីក្នុងពួករបស់ដែលពុះដោយកំបិតតូច ដែលពួកភិក្ខុរក្សាទុក ក៏ន័យនេះឯង ។ ពិតមែន ភិក្ខុទាំងឡាយនឹងរក្សាកាំបិតនោះទុក ដើម្បីត្រូវការប្រើប្រាស់ ក៏មិនមែន ។

កាលភិក្ខុទាំងឡាយកិន ឬបុកនូវថ្នាំ មានឫសថ្នាំជាដើម ថ្មកិនកូនថ្មកិន (ត្បាល់ និងអង្រែ)ជាដើម រមែងសឹកដាច់ទៅ ។ ភិក្ខុទាំងឡាយ នឹងដុតកាំបិតដែលរក្សាទុក ហើយដាក់ចុះក្នុងទឹកដោះជូរ ឬទឹកដោះស្រស់ដើម្បីប្រយោជន៍ជាថ្នាំ ពណ៌ខៀវរមែងប្រាកដក្នុងទឹកដោះជូរ ឬទឹកដោះស្រស់នោះ ។ មានវិនិច្ឆ័យដូចគ្នានឹងដែលពោលហើយក្នុងកាំបិតនោះឯង ។ បើថា ជ្រមុជចូលទៅ រមែងជាសាមបក្កៈ ។

កាលភិក្ខុត្រាច់ទៅបិណ្ឌក្នុងវេលាភ្លៀងធ្លាក់ ទឹកស្មោកគ្រោកស្រក់ចេញពីខ្លួន ឬ ពីចីវរចូលទៅក្នុងបាត្រ គប្បីឱ្យគេប្រគេនបាត្រនោះម្តងទៀត ។ សូម្បីតំណក់ទឹកដែលស្រក់ចូលក្នុងវេលាដែលកំពុងឆាន់នៅក្រោមដើមឈើជាដើម ក៏ន័យនេះដែរ ។ ក៏បើថា កាលភ្លៀងធ្លាក់រហូតដល់ ៧ ថ្ងៃ ជាទឹកបរិសុទ្ធ ឬទឹកភ្លៀងដែលធ្លាក់ក្នុងទីវាល គួរ ។

កាលបើជួសបាយឱ្យដល់សាមណេរ កុំដាក់វែកប៉ះពាល់បាយក្នុងបាត្រសាមណេរនោះឱ្យសោះ ។ ឬថា គប្បីឱ្យគេប្រគេនបាត្រសាមណេរនោះសិន ។ កាលភិក្ខុប៉ះពាល់បាយ ក្នុងបាត្រដែលមិនទាន់ប្រគេនហើយជួសបាយក្នុងបាត្ររបស់ខ្លួនទៀត បាយជាឧគ្គហិតក៍ ។ តែបើភិក្ខុជាអ្នកប្រាថ្នានឹងឱ្យពោលថា "នែសាមណេរ អ្នកចូរយកបាត្រមក, ចូរទទួលបាយ" ដូច្នេះ ; តែសាមណេរនោះ បដិសេធថា "ខ្ញុំព្រះករុណាគ្រប់គ្រាន់ហើយ" និងកាលភិក្ខុពោលទៀតថា "បាយនោះ ខ្ញុំព្រះករុណាលះដល់អ្នកហើយ" សាមណេរក៏នៅតែពោលថា "ខ្ញុំព្រះករុណាមិនត្រូវការបាយនោះទេ" ដូច្នេះ; ទោះជាលះបង់រាប់រយដងក៏ដោយ រហូតអស់កាលដែលបាយនៅជាប់នឹងដៃខ្លួន ចាត់ថា ជារបស់ដែលទទួលប្រគេនហើយ, មិនដាច់ប្រគេនទេ, មិនបាច់ឱ្យគេប្រគេនទៀតឡើយ ។

តែបើបាយតាំងនៅលើជើងបាត្រ ភិក្ខុមិនមានការស្តាយពោលថា

"លោកចូរយកទៅ" ដាច់ប្រគេនហើយ ។ បើភិក្ខុនៅអាល័យពោលនឹងសាមណេរថា "លោកចូរយកនំ ឬបាយពីក្នុងបាត្រនេះ" ដូច្នេះ សាមណេរលាន់ដៃហើយ សូម្បីថា ចាប់យកទៅរាប់រយដង ដាក់ចូលទៅដោយមិនប៉ះពាល់នំ ឬបាយក្នុងបាត្ររបស់ខ្លួនទេ មិនមានកិច្ចត្រូវឱ្យប្រគេនឡើយ ។ តែបើសាមណេរចាប់ប៉ះពាល់នំឬបាយក្នុងបាត្ររបស់ខ្លួនធ្វើឱ្យនំ ឬបាយក្នុងបាត្រទាំងពីរលាយច្របល់គ្នា គប្បីទទួលប្រគេនថ្មី ។

តែកេចិអាចារ្យទាំងឡាយពោលថា "ប្រសិនបើថា របស់ដែលសាមណេរចាប់យក ដាច់ធ្លាក់ចូលក្នុងបាត្រនោះ គប្បីទទួលប្រគេនថ្មី" ពាក្យនោះ បណ្ឌិតគប្បីជ្រាបក្នុងដុំបាយជាដើម ដែលភិក្ខុពោលកំណត់ទុកយ៉ាងនេះថា "លោកចូរចាប់យកដុំបាយមួយដុំ ចូរចាប់យកនំមួយដុំ ចូរចាប់យកដុំស្ករអំពៅចំណែកប៉ុណ្ណេះ" ចំណែកក្នុងពាក្យនេះថា "លោកចូរយកនំ ឬបាយពីក្នុងបាត្រនេះ" មិនមានការកំណត់; ព្រោះដូច្នោះ របស់ដែលធ្លាក់ចូលក្នុងបាត្ររបស់សាមណេរប៉ុណ្ណោះ ទើបដាច់ប្រគេនចំណែកបាយដែលនៅក្នុងដៃ របស់សាមណេរ នៅជារបស់ភិក្ខុនោះ ដរាបដល់សាមណេរនោះ មិនបានប្រាប់ថា "ឈប់យកហើយ" ឬភិក្ខុមិនទាន់បានហាមថា "យកប៉ុណ្ណឹងបានហើយ" ព្រោះដូច្នោះ ទើបមិន

ទាន់ដាច់ប្រគេន ។

បើភិក្ខុដាក់បាយចូលក្នុងភាជន៍សម្រាប់បបររបស់ខ្លួន ឬរបស់ភិក្ខុទាំងឡាយ ដើម្បីសាមណេរពួកខ្លះ គប្បីពោលថា "នែសាមណេរលោកចូរដាក់ដៃលើភាជន៍" ហើយជួសដាក់លើដៃរបស់សាមណេរនោះ ។ របស់ដែលធ្លាក់ពីដៃសាមណេរចូលទៅក្នុងភាជន៍, របស់ដែលធ្លាក់ទៅនោះ រមែងមិនធ្វើឱ្យភាជន៍ជាអប្បិយក្នុងថ្ងៃស្អែកទេ ព្រោះបាយនោះភិក្ខុលះហើយ បើភិក្ខុមិនធ្វើយ៉ាងនេះ ជួសចាក់ទៅ គប្បីធ្វើភាជន៍ឱ្យប្រាសចាកអាមិសដូចបាត្រហើយ ឆាន់ចុះ ។

ពួកទាយកដាក់បបរទុកហើយចេញទៅ ។ សាមណេរតូចមិនអាចប្រគេន ភាជន៍បបរនោះដល់ភិក្ខុបាន, ភិក្ខុផ្អៀងបាត្រចូលទៅ សាមណេរដាក់ភាជន៍លើមាត់បាត្រហើយផ្អៀងចាក់ ។ បបរដែលហូរចូលក្នុងបាត្រនោះ ជាការប្រគេនហើយ ។ មួយទៀត ភិក្ខុដាក់ដៃលើផ្ទៃ សាមណេរបង្អិលទៅដាក់លើដៃរបស់ភិក្ខុនោះ គួរ ។ សូម្បីក្នុងល្ពីនំ ល្អិបាយ និងបាច់អំពៅជាដើម ក៏មានន័យដូចគ្នា ។ បើសាមណេរ ២-៣ រូប ជួយគ្នាប្រគេនវត្ថុដែលមានទំងន់គួរប្រគេន, ឬភិក្ខុ ២-៣ រូប ទីងជួយគ្នាទទួលវត្ថុដែលមានទម្ងន់ល្មមបុរសកណ្តាលលើករួច គួរ ។

## វត្ថុជាឧគ្គហិតក៏ និងមិនជាឧគ្គហិតក៏

ជនទាំងឡាយព្យួរឆ្នាំងប្រេង ឬឆ្នាំងទឹកអំពៅ ទុកលើគ្រែឬតាំង, ភិក្ខុនីងអង្គុយលើគ្រែក្តី លើតាំងក្តី គួរ ។ ប្រេងជាដើមនោះ មិនឈ្មោះថា ឧគ្គហិតក៏ទេ ។ ឆ្នាំងប្រេង ២ គេព្យួរត្រួតគ្នាលើឈើធ្មេញមង្គរ ឬលើធ្នឹម, ឆ្នាំងនៅខាងលើបានទទួលប្រគេនហើយ ឆ្នាំងនៅខាងក្រោមមិនទាន់ទទួលប្រគេន, បើចាប់ឆ្នាំងលើ គួរ ។ តែបើឆ្នាំងនៅខាងក្រោមបានទទួលប្រគេនហើយ ឆ្នាំងនៅខាងលើ មិនទាន់ទទួលប្រគេនទេ, កាលភិក្ខុចាប់លើកឆ្នាំងលើហើយលើកយកឆ្នាំងក្រោម; ឆ្នាំងលើជាឧគ្គហិតក៏ ។ ខាងក្រោមគ្រែមានកែវប្រេងដែលមិនទាន់បានប្រគេន បើភិក្ខុយកអំបោសបោសប៉ះត្រូវកែវប្រេង, ប្រេងនោះ មិនទាន់ជាឧគ្គហិតក៏ ។

ភិក្ខុតាំងចិត្តថា "យើងចាប់យកតែរបស់ដែលយើងទទួលប្រគេនហើយ" ប្រឡំទៅចាប់យករបស់ដែលមិនបានទទួលប្រគេន ដឹងហើយក៏ទុកក្នុងទីដែលខ្លួនចាប់យកមកវិញ, របស់នោះមិនជាឧគ្គហិតក៏ ។ នាំយកមកខាងក្រៅហើយទើបដឹង កុំទុកនៅខាងក្រៅ ត្រូវនាំទៅទុកក្នុងទីដើមវិញ, ទើបមិនមានទោស ។ បើប្រេងនោះ កាលមុនបើកចំហ មិនគួរបិទ គប្បីដាក់ឱ្យដូចដើមវិញ ។ បើដាក់នៅខាងក្រៅកុំទៅប៉ះទៀត ។ បើភិក្ខុកំពុងចុះមកកាន់ប្រាសាទខាងក្រោម ប្រេងនៅពាក់កណ្តាលជណ្តើរ បើមិនមានឱកាស គប្បីនាំទៅទុកខាងលើ ឬខាងក្រោម ក៏បាន ។

ផ្សិតកើតឡើងក្នុងប្រេងដែលទទួលប្រគេនហើយ, ផង់ផ្សិតកើតឡើងលើខ្នែងខ្ញីជាដើម ; ផ្សិតឬផង់ផ្សិតនោះ ជារបស់ដែលកើតពីប្រេងនិងខ្ញីនោះឯង មិនមានកិច្ចដែលត្រូវប្រគេនថ្មី ។ មនុស្សឡើងលើដើមត្នោត ឬដើមដូង យកខ្សែចងសម្រុតធ្លាយផ្លែត្នោតឬដូងចុះមក ខ្លួនឯងនៅខាងលើពោលថា “និមន្តលោកម្ចាស់ទទួលចុះ” កុំទទួលឡើយ ។ មនុស្សដទៃឈរនៅលើដី ចាប់ចំណងខ្សែលើកប្រគេន ទឹងទទួលគួរ ។ ភិក្ខុឱ្យធ្វើមែកឈើធំដែលមានផ្លែឱ្យជាកប្បិយៈ ហើយទទួលប្រគេន ។ ផ្លែទាំងឡាយ ឈ្មោះថា ភិក្ខុទទួលប្រគេនដូចគ្នា ។ គួរបរិភោគតាមសប្បាយ ។

ជនទាំងឡាយឈរនៅក្រៅរបង ហែករបងប្រគេនអំពៅឬផ្លែទន្លាប់ កាលបានហត្ថបាស គួរ ។ កាលភិក្ខុទទួលអំពៅឬផ្លែទន្លាប់ត្រង់ប្រហោងចេញមក មិនប៉ះ (គងលើ)របង ទើបគួរ ។ ដែលប៉ះ (គងលើ)របង លោកមិនសម្ដែងទុកក្នុងអដ្ឋកថាទាំងឡាយ; តែពួកយើងយល់ឃើញថា “ហានដែលដើមអំពៅជាដើមប៉ះត្រូវ ដូចគ្នានឹងការចាប់លើករបស់ដែលធ្លាក់ឡើងដោយខ្លួនឯង” ។ សូម្បីពាក្យនោះ រមែងប្រើបានក្នុងកាលរបស់ចេញទៅមិនឈប់ ដូចភណ្ឌៈដែលបោះឱ្យធ្លាក់ទៅខាងក្រៅដែនគយ ដូច្នោះ ។

ពួកជនបោះរបស់រំលងរបង ឬកំពែងប្រគេន, បើកំពែងមិន

ក្រាស ល្មមគ្រប់ហត្ថបាសដល់ជនដែលឈរខាងក្នុងកំពែង ឬខាងក្រៅកំពែង, ភិក្ខុនឹងទទួលរបស់ដែលគេបោះឡើងខ្ពស់ សូម្បីតាំងរយហត្ថហើយធ្លាក់មកដល់ គួរ ។

ភិក្ខុលីសាមណេរអាពាធទៅ (ឱ្យសាមណេរអាពាធជិះកទៅ) ។ លោកឃើញផ្លែឈើតូចធំ បេះប្រគេន ទាំងដែលអង្គុយនៅលើក, ភិក្ខុគួរទទួល ។ បុគ្គលដទៃលីភិក្ខុទៅ ប្រគេនផ្លែឈើដល់ភិក្ខុដែលនៅអង្គុយលើក, សមគួរទទួលដូចគ្នា ។ ភិក្ខុកាន់មែកឈើមានផ្លែ ដើម្បីត្រូវការម្លប់ដើរទៅ ។ កាលកើតសេចក្តីគិតចង់នឹងឆាន់ផ្លែឡើង នឹងឱ្យអនុបសម្បន្នប្រគេនហើយ គួរ ។ ភិក្ខុឱ្យធ្វើកប្បិយៈមែកឈើដើម្បីដេញរុយ ហើយទទួលប្រគេនទុក ។ បើថា មានសេចក្តីប្រាថ្នានឹងឆាន់, ការទទួលប្រគេនទុកពីដើមនុ៎ះឯងនៅប្រើបាន, មិនមានទោសដល់ភិក្ខុដែលទំពាឆាន់ ។

ភិក្ខុដាក់ភណ្ឌៈដែលគួរទទួលប្រគេន ទុកលើយានរបស់ពួកអ្នកស្រុកធ្វើដំណើរទៅ ។ យានជាប់ភក់, ភិក្ខុកម្លោះចាប់កង់ទាញឡើង គួរ, វត្ថុមិនឈ្មោះថា ជាឧគ្គហិតក៍ ។ ភិក្ខុដាក់របស់ដែលគួរប្រគេនទុកក្នុងទូក យកច្រវ៉ាចែវទូកទៅ ឬយកដៃកកាយទៅ គួរ ។ សូម្បីក្នុងផែឬក្បូន ក៏ន័យនេះដែរ ។ ភិក្ខុសូម្បីដាក់ភណ្ឌៈទុកក្នុងថាសក្តី ក្នុងបានក្តី ក្នុងឆ្នាំងក្តី ហើយប្រើឱ្យអនុបសម្បន្នកាន់ភណ្ឌៈនោះ ចាប់ដើមដៃ

អនុសម្បន្នឆ្លង (ទឹក) ទៅគួរ ។ សូម្បីកាលថាសជាដើមមិនមាន ឱ្យអនុបសម្បន្នកាន់ហើយ ចាប់អនុបសម្បន្ននោះត្រង់ដើមដៃឆ្លងទៅ ក៏គួរ ។

ពួកឧបាសកប្រគេនអង្ករជាស្បៀង ដល់ពួកភិក្ខុដែលត្រៀមទឹងធ្វើដំណើរ ។ ពួកសាមណេរជួយកន់អង្ករភិក្ខុទាំងឡាយ ហើយមិនអាចកាន់អង្ករចំណែករបស់ខ្លួនឯង ។ ទើបពួកភិក្ខុជួយកន់អង្កររបស់សាមណេរនេះដាំបបរ តម្កល់បាត្ររបស់ភិក្ខុសាមណេរទាំងអស់ទុក តាមលំដាប់ហើយ ចាក់បបរចុះ ។ សាមណេរអ្នកឆ្លាតយកបាត្ររបស់ខ្លួនប្រគេនដល់ព្រះថេរៈ ប្រគេនបាត្ររបស់ព្រះថេរៈដល់ព្រះថេរៈរូបទី ២ ផ្លាស់បាត្រគ្នាទាំងអស់ យ៉ាងនេះជាដើមដរាបដល់គ្រប់រូប ។ ឈ្មោះថា ភិក្ខុទាំងអស់ឆាន់បបររបស់សាមណេរ គួរ ។ ប្រសិនបើថា សាមណេរជាអ្នកមិនឆ្លាត ផ្តើមទឹងផឹកបបរក្នុងបាត្ររបស់ខ្លួន ដោយខ្លួនឯងប៉ុណ្ណោះ, ពួកព្រះថេរៈគួរទឹងសូមផឹកទៅតាមលំដាប់យ៉ាងនេះថា "អ្នកមានអាយុចូរឱ្យបបររបស់អ្នកដល់យើង" ដូច្នេះ ឈ្មោះថា ភិក្ខុទាំងអស់មិនត្រូវទោសព្រោះឧគ្គហិតកៈជាបច្ច័យ មិនត្រូវទោសព្រោះសន្និធិជាបច្ច័យទេ ។

តែក្នុងការផ្លាស់បាត្រគ្នានេះ សេចក្តីប្លែកគ្នានៃភិក្ខុទាំងឡាយ អ្នកនាំប្រេងជាដើមទៅ ដើម្បីមាតាបិតា និងនាំមែកឈើជាដើម ដើម្បីត្រូវការម្ជប់ជាដើម ទឹងភិក្ខុដែលផ្លាស់ប្តូរបាត្រគ្នាទាំងនេះ មិនប្រាកដ; ព្រោះដូច្នោះ បណ្ឌិតគប្បីពិចារណារកហេតុ ។

សាមណេរប្រាថ្នានឹងដាំបាយ មិនអាចនឹងរើសអង្ករឱ្យអស់គ្រួស[១] ខ្សាច់បាន ។ ភិក្ខុគប្បីទទួលប្រគេនអង្ករនឹងភាជនៈ រើសអង្ករឱ្យអស់គ្រួសខ្សាច់ហើយលើកភាជន៍ឡើងកាន់ចង្ក្រានចុះ ។ កុំគប្បីបង្កាត់ភ្លើង ។ ក្នុងវេលាដាំនឹងត្រូវបើកមើល ទើបដឹងថា បាយឆ្អិនឬមិនឆ្អិនបាន ។ បាយមិនទាន់ឆ្អិនល្អ បើបិទដើម្បីត្រូវការឱ្យឆ្អិន មិនគួរ ។ បើបិទដើម្បីត្រូវការមិនឱ្យផង់ធូលី ឬកំទេចផេះធ្លាក់ចុះទៅ គួរ ។ កាលវេលាឆ្អិនហើយ នឹងដាក់ចុះក្តី នឹងឆាន់ក្តី គួរ ។ ចាប់តាំងពីនោះទៅ មិនមានកិច្ចដែលនឹងត្រូវទទួលប្រគេនថ្មី ។

សាមណេរអាចស្លបាន, តែលោកមិនមានវេលា, លោកប្រាថ្នានឹងទៅក្នុងទីដទៃ, ភិក្ខុទទួលប្រគេនភាជន៍ព្រមទាំងអង្ករ និងទឹកហើយលើកឡើងកាន់ចង្ក្រាន គប្បីពោលថា "ចូរអ្នកបង្កាត់ភ្លើងឱ្យឆេះហើយទៅចុះ" ។ បន្ទាប់ពីភ្លើងឆេះហើយ នឹងធ្វើកិច្ចគ្រប់យ៉ាង សមគួរ ដោយន័យមុនដូចគ្នា ។ ភិក្ខុតាំងភាជន៍ស្អាតដាំទឹកក្តៅទុក ដើម្បីប្រយោជន៍ដល់បបរគួរ ។ កាលទឹកក្តៅហើយ សាមណេរចាក់អង្ករចុះ ។ ក៏ចាប់តាំងពីនោះទៅ ភិក្ខុកុំគប្បីរុកភ្លើង ។ នឹងទទួលប្រគេនបបរដែលឆ្អិនហើយផឹក គួរ ។

---

១. សារត្ថទីបនី ៣. និច្ចាលេតុំ ន សក្កោតីតិ និច្ចាលេត្វា សក្ខរា អបនេតុំ ន សក្កោតិ ។

សាមណេរកំពុងដាំបបរ ។ ភិក្ខុរើសដៃលេង ចាប់ភាជន៍, ចាប់គម្របឆ្នាំង, ចូកពពុះដែលកកឡើងចោលទៅ ។ ចំពោះភិក្ខុនោះ មិនគួរនឹងផឹក, ជាទុក្កដ ឈ្មោះទុរុបចិណ្ណៈ ។ ក៏បើថា ភិក្ខុចាប់វែក ឬបោយហើយ អ្នកមិនលើកឡើង បបរនោះមិនគួរដល់ភិក្ខុទាំងអស់, រមែងជាសាមបក្កៈផង ជាទុរុបចិណ្ណៈផង, បើលើកឡើង ក៏ជាឧគ្គហិតក៏ទៀត ។ ភិក្ខុត្រាច់បិណ្ឌបាតដាក់បាត្រទុកលើជើងបាត្រ ។ បើភិក្ខុឡេះឡោះ ដទៃដើរទៅក្នុងទីនោះ ចាប់ពាល់បាត្រ, ចាប់ពាល់គម្របបាត្រ ។ ភត្តដែលបានអំពីបាត្រនោះមិនគួរចំពោះដល់ភិក្ខុឡេះឡោះនោះ ។ តែបើលោកលើកបាត្រឡើងហើយដាក់ទុក មិនគួរដល់ភិក្ខុគ្រប់ ៗរូប ។ ភិក្ខុចាប់មែកឈើឬវល្លិ អង្រួនផ្លែឈើដែលកើតនៅលើដើមឈើជាដើមនោះ ។ ផ្លែដែលបានអំពីមែកឈើ ឬវល្លិនោះ មិនគួរដល់ភិក្ខុដែលអង្រួននោះដូចគ្នា ។ និងលោករមែងត្រូវទុរុបចិណ្ណទុក្កដផង ។ លោកពោលទុកក្នុងមហាបច្ចរីថា ភិក្ខុនឹងទល់ដើមឈើមានផ្លែ ឬចងបន្ទាទុកត្រង់ដើមឈើនោះ គួរពិត មិនជាទុរុបចិណ្ណទុក្កដ ។

ចំណែកភិក្ខុឃើញផ្លែឈើ មានផ្លែស្វាយជាដើមដែលជ្រុះក្នុងព្រៃតាំងចិត្តថា យើងនឹងឱ្យដល់សាមណេរ ហើយនាំមកឱ្យ គួរ ។ ភិក្ខុឃើញសាច់របស់សល់ពីសីហៈជាដើម គិតថា យើងនឹងឱ្យដល់សាមណេរ ទទួលប្រគេនក៏ដោយ មិនបានទទួលប្រគេនក៏ដោយ នាំមកឱ្យ

គួរ ៗ ក៏បើអាចនឹងជម្រះវិតក្កឱ្យហ្មត់ចត់បាន សូម្បីឆាន់អាហារដែលបានមកពីសាច់សំណល់សីហៈជាដើមនោះ ក៏គួរ ៗ មិនត្រូវទោសព្រោះទទួលប្រគេនសាច់ឆៅជាបច្ច័យ និងមិនត្រូវទោសព្រោះរបស់ឧគ្គហិតក៍ ជាបច្ច័យឡើយ ៗ

កាលភិក្ខុកាន់ប្រេងជាដើមដើរទៅ ដើម្បីប្រយោជន៍ដល់មាតា និងបិតាកើតព្យាធិឡើងក្នុងចន្លោះមក នឹងទទួលប្រគេនវត្ថុដែលខ្លួនប្រាថ្នា ពីប្រេងជាដើមនោះហើយឆាន់ គួរ ៗ តែបើជារបស់ភិក្ខុទទួលប្រគេនទុកសូម្បីក្នុងគ្រាដំបូង, មិនមានកិច្ចដែលនឹងត្រូវទទួលប្រគេនថ្មី ៗ

ភិក្ខុនាំអង្ករមកឱ្យ ដើម្បីប្រយោជន៍ដល់មាតា និងបិតា ៗ មាតានិងបិតានោះ ចាត់ផ្សំបបរជាដើម ពីអង្ករនោះឯង ប្រគេនដល់ភិក្ខុនោះ គួរ ៗ មិនមានទោសព្រោះសន្និធិជាបច្ច័យ ឬព្រោះរបស់ឧគ្គហិតក៍ជាបច្ច័យ ៗ ភិក្ខុបិទគម្របដាំទឹកឱ្យក្ដៅ, គួរបរិភោគបានដរាបដល់អស់ ៗ តែបើផេះធ្លាក់ចុះក្នុងទឹកក្ដៅនេះ គប្បីទទួលប្រគេន ៗ កាលភិក្ខុយកដង្កៀបដងវែងចាប់ចានស្លប្រេងផេះធ្លាក់ចុះទៅ, កុំលេងដៃចេញ រម្ងាស់ទៅដរាបបានពេលដាក់ចុះហើយ គប្បីទទួលប្រគេនថ្មី ៗ ប្រសិនបើថារងើកក្ដី ឧសក្ដី ភិក្ខុទទួលប្រគេនដាក់ទុក, ការទទួលប្រគេនពីខាងដើមនោះឯង នៅប្រើបាន ៗ

ភិក្ខុទំពា ( ឆាន់ ) អំពៅ ៗ សាមណេរពោលថា "លោកម្ចាស់

ឱ្យខ្ញុំខ្លះ" ។ ភិក្ខុប្រាប់លោកថា "ចូរកាត់យកអំពីចំណែកនេះទៅ" ហើយកន់យក, ក៏ក្នុងចំណែកដែលនៅសល់ មិនមានកិច្ចដែលនឹងត្រូវទទួលប្រគេនថ្មី ។ សូម្បីសម្រាប់ភិក្ខុដែលឆាន់ជុំស្កររអំពៅ ក៏ន័យនេះដូចគ្នា ។ ពិតមែន អំពៅចំណែកដែលនៅសល់ពីសាមណេរកាត់យកត្រង់ឱកាសដែលភិក្ខុប្រាប់ទុក មិនទាន់លះ ( មិនដាច់ ) ការទទួលប្រគេនទៅឡើយ ។

ភិក្ខុកាលចែកដុំស្កររអំពៅ ដែលទទួលប្រគេនហើយចាត់ទុកជាចំណែក ៗ ។ ពួកភិក្ខុក្តី ពួកសាមណេរក្តី មកហើយនឹងកាន់យកម្នាក់មួយចំណែក ៗ ដោយករចាប់មួងប៉ុណ្ណោះ ។ ចំណែកដែលនៅសល់ពីភិក្ខុសាមណេរចាប់យកទៅហើយ នៅជារបស់ប្រគេនដដែល ។ បើសាមណេររុករើចាប់ដាក់ ៗ, ចំណែកដែលនៅសល់ពីសាមណេរនោះកាន់យកទៅ ជារបស់មិនបានទទួលប្រគេន ។

ភិក្ខុទទួលប្រគេនខ្សៀរ ហើយជក់ថ្នាំ ។ មាត់និងក ដូចលាបដោយមនោសិលា ។ នឹងឆាន់យាវកាលិក បាន ។ មិនមានទោសជាប់ដោយយាវជីវិក និងយាវកាលិកលាយគ្នា ។ កាលភិក្ខុដុតបាត្រ ឬស្មោរទឹកជ្រលក់ ផ្សែងចូលទៅតាមត្រចៀក ច្រមុះនិងមាត់, នឹងផឹកទឹកផ្កាឈើឬផ្លែឈើ ព្រោះសេចក្តីឈឺចុកចាប់ជាបច្ច័យ, គួរពិត ព្រោះជាអព្ពោហារិក ។

អាហារដែលឆាន់ហើយកើចេញមកប៉ះខ្ទប់ពិតាន ត្រឡប់ចូលទៅក្នុងខាងក្នុងវិញ គួរពិត ព្រោះជាហេតុផុតវិស័យ ។ ដែលកើចេញមកដល់មាត់ហើយលេបចូលទៅទៀត ជាអាបត្តិ ព្រោះវិកាលភោជនសិក្ខាបទ ។ រសរបស់អាមិសដែលជាប់នៅក្នុងប្រហោងធ្មេញចូលទៅ (ក្នុងបំពង់ក) ជាអាបត្តិដូចគ្នា ។ បើអាមិសល្អិត រសមិនប្រាកដ, ចាត់ចូលបក្ខពួកនៃអព្វោហារិក ។

កាលថ្ងៃជិតត្រង់ ភិក្ខុឆាន់អាហារក្នុងទីមិនមានទឹក ខាកខ្ពុរទឹកមាត់ចោលទៅ ២-៣ ដុំ ហើយគប្បីទៅកាន់ទីមានទឹកខ្ពុរមាត់ចុះ ។ ពន្លកខ្ចីដែលទទួលប្រគេនរក្សាទុកជាដើមដុះចេញ, មិនមានកិច្ចដែលត្រូវទទួលប្រគេនថ្មី ។ មិនមានអំបិលនឹងធ្វើអំបិលដោយទឹកសមុទ្រ គួរ ។ ទឹកប្រៃដែលភិក្ខុទទួលប្រគេនរក្សាទុកក្លាយជាអំបិល ឬអំបិលក្លាយជាទឹក, ទឹកអំពៅស្រស់ក្លាយជាកកឬទឹកអំពៅកកលាយជាទឹកអំពៅរាវទៅ ការទទួលប្រគេនពីដើមនុ៎ះឯងនៅប្រើបាន ។ ហិមៈ( សន្សើម )និងគ្រាប់ព្រិល មានគតិដូចទឹកនុ៎ះឯង ។

ពួកភិក្ខុកូរទឹកឱ្យថ្លា ដោយគ្រាប់ផ្លែឈើដែលធ្វើឱ្យថ្លា (គ្រាប់តុមកា) ដែលថែរក្សាទុក, ទឹកដែលកូរឱ្យថ្លាជាដើមនោះ ជាអព្វោហារិកលាយនឹងអាមិស ក៏គួរ ។ ទឹកដែលកូរឱ្យថ្លាដោយខ្វិតជាដើម មានគតិដូចអាមិស គួរតែក្នុងវេលាមុនឆាន់ប៉ុណ្ណោះ ទឹកក្នុងស្រះបោក្ខរណីជា

ដើម ល្អក់កករខាប់ ក៏គួរ តែបើថា ទឹកល្អក់កករខាប់នោះ ជាប់មាត់និងដៃ មិនគួរ ។ ទឹកនោះគួរទទួលប្រគេនហើយទើបបរិភោគ ។ ទឹកល្អក់កករខាប់ក្នុងស្ថានទីត្រូវភ្ជួរក្នុងស្រែទាំងឡាយ គប្បីទទួលប្រគេន ។ បើទឹកហូរចុះកាន់ប្រឡាយជាដើម ហើយពេញទន្លេ គួរ ។

ជលាល័យមានបឹងដែលមានដើមកុម្ពជាដើម មានទឹកដែលដេរជាស់ទៅដោយផ្កាឈើដែលជ្រុះអំពីដើម ។ បើរសផ្កាឈើមិនប្រាកដ, មិនមានកិច្ចដែលនឹងត្រូវទទួលប្រគេន ។ បើទឹកតិច មានរសប្រាកដគប្បីទទួលប្រគេន ។ សូម្បីក្នុងទឹកដែលគ្របដណ្តប់ដោយស្លឹកឈើពណ៌ខ្មៅក្នុងប្រឡាយទាំងឡាយ មានញកភ្នំជាដើម ក៏ន័យនេះដូចគ្នា ។ ផ្កាឈើទាំងឡាយមានកេសរក្តី មានទឹកជមត្រង់ទងក្តី (មានទងនិងទឹកដោះក្តី) គេដាក់ក្នុងឆ្នាំងទឹកផឹក, គប្បីទទួលប្រគេន ។ ឬថា ផ្កាឈើទាំងឡាយភិក្ខុទទួលប្រគេនហើយគប្បីដាក់ចុះទៅ ។ ជ្រនៀងផ្កាចម្ប៉ា និងផ្កាម្ទេះជារបស់ដែលគេដាក់ត្រាំទុក, ទឹកគង់នៅត្រឹមតែអប់ក្លិន ។ ទឹកនោះជាអព្វោហារិក គួរជាមួយនឹងអាមិសសូម្បីក្នុងថ្ងៃស្អែក ។

សាមណេរដងទឹកផឹកមកពីទឹកដែលអប់ផ្កាឈើ ដែលភិក្ខុរក្សាទុកហើយ ចាក់ទឹកដែលនៅសល់ពីខនផឹកហើយ ចុះក្នុងទឹកផឹកនោះទៀត, គប្បីទទួលប្រគេនថ្មី ។ ភិក្ខុនឹងយកឆ្នាំងវាចកេសរផ្កាឈើ ដែលអណ្តែតលើទឹកនៅក្នុងស្រះឈូកជាដើម ចេញទៅហើយ ដួសយកតែទឹក

គួរ ។

ឈើស្ទន់ដែលភិក្ខុឱ្យធ្វើជាកប្បិយហើយទទួលប្រគេនរក្សាទុក ។ បើភិក្ខុប្រាថ្នានឹងជញ្ជក់រសនៃឈើស្ទន់នោះ, ការទទួលប្រគេនពីមុនទុំនុះឯងសមគួរ ។ ដែលមិនបានទទួលប្រគេនទុក ត្រូវទទួលប្រគេន ។ សូម្បីកាលរសចូលទៅក្នុងបំពង់ក ក៏ជាអាបត្តិដល់ភិក្ខុដែលមិនដឹងដូចគ្នា ។ ពិតមែន សិក្ខាបទនេះជាអចិត្តកៈ ។

សួរថា បណ្ដាមហាភូតរូប អ្វីគួរ អ្វីមិនគួរ ?

ឆ្លើយថា ទឹកដោះស្រស់ សមគួរមុន ។ នឹងជាទឹកដោះស្រស់នៃសត្វដែលមានមំសៈជាកប្បិយ ឬទឹកដោះស្រស់នៃសត្វដែលមានមំសៈជាអកប្បិយ ក៏ដោយ, ភិក្ខុផឹក មិនជាអាបត្តិ ។ វត្ថុនេះ គឺ ទឹកភ្នែក ទឹកមាត់ សម្បោរ មូត្រ លាមក ស្លេស្ម អាចម៍ធ្មេញ អាចម៍ភ្នែក អាចម៍ត្រចៀក ញើស កើតក្នុងរាងកាយ គួរគ្រប់យ៉ាង ។

តែបណ្ដាវត្ថុទាំងនេះ វត្ថុណាឃ្លាតចាកកន្លែង (របស់វា) ហើយធ្លាក់ចុះក្នុងបាត្រក្ដី លើដៃក្ដី វត្ថុនោះត្រូវទទួលប្រគេន ។ វត្ថុដែលនៅជាប់នៅក្នុងអវយវៈ ជាការដែលទទួលប្រគេនហើយពិត ។ តែភិក្ខុឆាន់បាយបាយាសក្ដៅញើសដែលជាប់តាមម្រាមដៃហើយ ជាប់នៅត្រង់បាយបាយាស ឬថា កាលភិក្ខុត្រាច់បិណ្ឌបាតញើសហូរចេញពីដៃដល់គណ្ដាប់មាត់បាត្រ ហូរចូលក្នុងបាត្រ ។ ក្នុងបាត្រនេះ មិនមានកិច្ចដែលនឹងត្រូវ

ទទួលប្រគេន, ក្នុងមហាភូតដែលដុតហើយ មិនមានពាក្យថា ចំណែកឈ្មោះនេះ មិនគួរ ។ តែដែលដុតមិនល្អ (ឆេះមិនស្និទ្ធ) មិនគួរ ។ ក៏ភិក្ខុនឹងកិនសូម្បីឆ្អឹងមនុស្ស ដែលដុតសុសហើយឱ្យជាផង់ ហើយរោយចុះក្នុងរបស់ភ្លក្សរសគួរ ។

[១៨៤] កាលមិនមានកប្បិយការក នឹងកាន់យកថ្នាំមហាវិក័តិ ៤ ឆាន់សូម្បីដោយខ្លួនឯង ក៏គួរ ។ ក៏ក្នុងអធិការនៃថ្នាំមហាវិក័តិនេះ កប្បិយការកជាអ្នកប្រដៅក្រក្តី ជាអ្នកមិនអាចក្តី រមែងតាំងនៅក្នុងផ្នែកពួកមិនមានដូចគ្នា ។ កាលផេះមិនមាន ភិក្ខុគប្បីដុតឈើស្ងួតយកផេះ ។ កាលឧសស្ងួតមិនមាន សូម្បីនឹងកាត់ឧសស្រស់អំពីដើមឈើធ្វើផេះក៏គួរ ។ ក៏ថ្នាំមហាវិក័តិទាំង ៤ យ៉ាង ឈ្មោះថា អនុញ្ញាតចំពោះកាលគួរតែក្នុងវេលាត្រូវពស់ខាំប៉ុណ្ណោះ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡុកលោមសិក្ខាបទ កើតមកកាយ ១ កាយចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ទន្តបោណសិក្ខាបទវណ្ណនា ចប់

ចំនួនសិក្ខាបទក្នុងភោជនវគ្គនោះ គឺ

១. អាវសថបិណ្ឌសិក្ខាបទ ការឆាន់ចង្ហាន់ក្នុងរោងទាន
២. គណភោជនសិក្ខាបទ ការឆាន់គណភោជន
៣. បរម្បរភោជនសិក្ខាបទ ការឆាន់ភោជនដទៃ
៤, កាណមាតាសិក្ខាបទ ការទទួលនំនិងសង្ហារ
៥. បឋមបវារណាសិក្ខាបទ ការហាមភោជនហើយ ឆាន់
៦. ទុតិយបវារណាសិក្ខាបទ ការបង្ខំភិក្ខុដែលហាមភោជន ឱ្យឆាន់
៧. វិកាលភោជនាសិក្ខាបទ ការឆាន់ភោជនក្នុងវេលាវិកាល
៨. សន្និធិការកសិក្ខាបទ ការឆាន់ភោជនដែលសន្សំទុក
៩. បណីតភោជនសិក្ខាបទ ការសូមភោជនដ៏ឧត្តម
១០. ទន្តបោណសិក្ខាបទ ការឆាន់អាហារ ដែលមិនប្រគេនក្រៅពីទឹក និងឈើស្ទន់

អដ្ឋកថា ភោជនវគ្គទី ៤ ចប់ ។

# ៥. អចេលកវគ្គ

## ១. អចេលកសិក្ខាបទវណ្ណនា

ក្នុងសិក្ខាបទទី ១ នៃអចេលកវគ្គ មានវិនិច្ឆ័យដូចតទៅនេះ ៖

### ពន្យល់រឿងឱ្យរបស់ស៊ីដល់អ្នកបួសក្រៅសាសនា

[១៤៥] បទថា បរិវេសនំ : ទីដែលគេអង្គាស គឺ ស្ថានទីអង្គាស ។

[១៤៦] បទថា បរិព្វាជកសមាបន្នោ : បុរសដែលបួសជាបរិព្វាជកទាំងអស់ គឺ អ្នកចូលដល់ការបួស ។

[១៤៦] បីបទថា ទេតិ អាបត្តិ បាចិត្តិយស្ស : ភិក្ខុឱ្យ ត្រូវអាបត្តិបាចិត្តិយ មានសេចក្ដីថា ភិក្ខុឱ្យបបរនិងបាយ ល្មមផ្អែតដោយប្រយោគតែមួយ ជាបាចិត្តិយតែមួយ, ឱ្យដាច់ជារយៈ ៗ ជាបាចិត្តិយគ្រប់ប្រយោគ ។ សូម្បីក្នុងនំនិងបាយជាដើម ក៏ន័យនេះដូចគ្នា ។

[១៤៧] ពីរបទថា តិត្ថិយេ តិត្ថិយសញ្ញី : ជនជាតិរិយ ភិក្ខុក៏សំគាល់ថា ជាតិរិយ មានសេចក្ដីថា មាតាក្ដី បិតាក្ដី(របស់ភិក្ខុ) បួសក្នុងពួកតិរិយ ។ សូម្បីភិក្ខុ (ជាបុត្រ) កាលឱ្យដល់តិរិយទាំងនោះដោយសម្គាល់ថា មាតានិងបិតា ជាបាចិត្តិយ ដូចគ្នា ។

[១៤៨] បទថា ធាបេតិ : ភិក្ខុប្រើគេឱ្យ(យកទៅ)ឱ្យ គឺភិក្ខុបង្គាប់ឱ្យអនុបសម្បន្នយកទៅជូន ។

ពីរបទថា ឧបនិក្ខិបិត្វា ទេតិ : ភិក្ខុដែលដាក់វត្ថុទុកឱ្យ មានសេចក្តីថា ដាក់លើភាជនៈបែបនោះហើយ ដាក់ភាជន៍នោះឱ្យលើផែនដីជិតតិរ្ថិយទាំងនោះ ឬថា ប្រើឱ្យដាក់ភាជន៍របស់តិរ្ថិយទាំងនោះចុះហើយឱ្យលើភាជន៍នោះ សូម្បីទឹងតម្កល់បាត្រទុកលើជើងទ្រ ឬលើផែនដីហើយពោលថា "អ្នកទាំងឡាយចូរកាន់យកពីបាត្រនេះ" ក៏គួរ ។ បើថា តិរ្ថិយនិយាយថា "របស់វត្ថុនេះជារបស់យើងពិត, សូមលោកមេត្តាដាក់អាមិសនោះចុះក្នុងភាជនៈនេះ" គប្បីដាក់ចុះទៅ ។ ព្រោះជារបស់តិរ្ថិយនោះ ទើបមិនឈ្មោះថា ជាការឱ្យដោយដៃខ្លួនឯង ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយស្រួលទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អចេលកសិក្ខាបទវណ្ណនា ចប់

# ២. ឧយ្យោជនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

## ពន្យល់បឋមបញ្ញត្តិរបស់សិក្ខាបទ

[១៤៩] បទថា បដិក្កមនេបិ : សូម្បីគ្រាន់ត្រឡប់មក គឺសូម្បីក្នុងរោងឆាន់ ។

បទថា ភត្តវិស្សគ្គំ : ការធ្វើភត្តចេញ បានដល់ ភត្តកិច្ច ។

បទថា ន សម្ភាវេសិ : ក៏មិនទាន់ បានដល់ មិនទាន់វេលា ។

[១៥០] បទថា អនាចារំ : អនាចារ បានដល់ ការប្រព្រឹត្តកន្លងតាមមក កាយ និងមកវាចាដែលនៅសល់អំពីអនាចារដែលពោលហើយ ។

ក្នុងពាក្យថា ឧស្សន្នុបចារំ វា សវនុបចារំ វា វិជហន្តស្ស : កាលភិក្ខុនោះកំពុងលះបង់នូវទីល្មមមើលគ្នាឃើញ ឬទីល្មមស្តាប់ឮ នេះមានវិនិច្ឆ័យថា បើភិក្ខុឈរ ឬអង្គុយបណ្តេញ, ភិក្ខុណាត្រូវបណ្តេញ, ភិក្ខុនោះកំពុងលះឧបចារទៅ, និងឈ្មោះថា អាបត្តិមិនមានដល់ភិក្ខុនោះ, តែកាលភិក្ខុត្រូវបណ្តេញនោះ សូម្បីកំពុងលះ( ឧបចារ )ទៅ ដោយអត្ថក៏គឺ ភិក្ខុដែលបណ្តេញក្រៅនេះលះទៅហើយតែម្តង ; ព្រោះដូច្នោះ ភិក្ខុដែលបណ្តេញប៉ុណ្ណោះជាអាបត្តិនេះ ។ បណ្តាអាបត្តិទាំងនោះ បើថា

ជើងម្ខាងនៅខាងក្នុងឧបចារជាទុក្កដ ។ ក្នុងខណៈកន្លងព្រំប្រទល់ទៅ ជាបាចិត្តិយ ។

ក៏បណ្ដាឧបចារការឃើញនិងឧបចារការបានឮនេះ ប្រមាណ ១២ ហត្ថក្នុងឱកាសទីវាល ជាប្រមាណនៃឧបចារការឃើញ, ឧបចារការបានឮក៏មានប្រមាណប៉ុនគ្នា ។ ក៏បើថា មានជញ្ជាំង ទ្វារ និងកំពែងជាដើមបិទបាំង, ភាវៈដែលជញ្ជាំង ទ្វារ និងកំពែងជាដើមនោះបាំងទុកនុ៎ះឯងជាការកន្លងហួសទស្សនូបចារៈ ។ បណ្ឌិតគប្បីជ្រាបអាបត្តិ ដោយអំណាចការកន្លងហួសទស្សនូបចារៈនោះ ។

ពាក្យថា **ន អញ្ញោ កោចិ បច្ចយោ ហោតិ : មិនមានហេតុនីមួយដទៃជាបច្ច័យ** មានសេចក្ដីថា វៀរអនាចារដូចដែលបានពោលមកហើយ មិនមានហេតុចាំបាច់អ្វីយ៉ាងដទៃ ។

[១៥១] ពីរបទថា **គលិសាសនំ អារោបេតិ : ភិក្ខុលើកឡើងនូវពាក្យបញ្ឈឺចិត្ត** មានសេចក្ដីថា សេចក្ដីក្រោធ ឈ្មោះថា គលិ ។ លើករឿងនៃសេចក្ដីក្រោធនោះឡើង គឺ លើកអាជ្ញានៃសេចក្ដីក្រោធឡើង ។ អធិប្បាយថា សម្ដែងទោសក្នុងការឈរនិងការអង្គុយជាដើមដោយអំណាចនៃសេចក្ដីក្រោធ ពោលពាក្យដែលមិនចម្រើនចិត្ត យ៉ាងនេះថា លោកដ៏ចម្រើន ចូរមើល ការឈរ ការអង្គុយ ការមើលការក្រឡេករបស់ភិក្ខុនេះ, លោកឈរដូចជង្គត់ឈើ, អង្គុយដូចសុនខ,

ក្រឡេកមើលខាងណោះខាងណោះឡើងឡង់ដូចស្វា ដោយតាំងចិត្តថា ធ្វើដូចម្តេច ? អ្នកនេះត្រូវយើងរកកូន ដោយពាក្យដែលមិនចម្រើនចិត្តយ៉ាងនេះហើយ គប្បីជៀសចេញទៅ ។ បទដែលនៅសល់ងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងមកកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

ឧយ្យោជនសិក្ខាបទវណ្ណនា ចប់

# ៣. សភោជនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ មានវិនិច្ឆ័យដូច្នេះ ៖

## ពន្យល់បឋមបញ្ញត្តិនៃសិក្ខាបទ

[១៥៣] បទថា សយនីឃរេ : ផ្ទះសម្រាប់ដេក គឺ ក្នុងផ្ទះជាទីដេក

យតោ អយ្យស្ស ភិក្ខា ទិន្នា : សូមលោកម្ចាស់និមន្តទៅចុះ ព្រោះយើងខ្ញុំបានប្រគេនចង្ហាន់ដល់លោកម្ចាស់ហើយ គឺ ព្រោះខ្ញុំបានប្រគេនទូវភិក្ខាហើយ ។ អធិប្បាយថា វត្ថុណាដែលអ្នកមកហើយគប្បីបាន, លោកបានវត្ថុនោះហើយ, និមន្តលោកត្រឡប់ទៅចុះ ។

បទថា បរិយុដ្ឋិតោ : មានរាគៈគ្របសង្កត់ហើយ គឺ ជាអ្នកដែលរាគៈរួបរឹតហើយ, សេចក្តីថា មានសេចក្តីប្រាថ្នាក្នុងមេថុន ។

បទថា សភោជនេ : ដែលមានជនតែពីរនាក់ បានដល់ ត្រកូលដែលប្រព្រឹត្តទៅមួយអន្លើដោយមនុស្ស ២ នាក់ ឈ្មោះថា សភោជន ។ ក្នុងត្រកូលមានមនុស្ស ២ នាក់នោះ ។ ម្យ៉ាងទៀត បទថា សភោជនេ : មានភោជន គឺក្នុងត្រកូលមានភោគៈ(គ្រឿងបរិភោគ) ។ ព្រោះថា ស្ត្រីជាភោគៈរបស់បុរសដែលរាគៈរួបរឹតហើយ និងបុរសក៏ជាភោគៈរបស់ស្ត្រី (អ្នកអន្ទះអន្ទែងដោយរាគៈ), ព្រោះហេតុនោះឯង

ក្នុងបទភាជនៈនៃបទថា សភោជនេ នោះ ព្រះមានព្រះភាគទើបត្រាស់ថា "ឥត្ថី ចេវ ហោតិ បុរិសោ ច : មានតែស្រីនិងប្រុសប៉ុណ្ណោះ" ។

[១៥៤] ពីរបទថា មហល្លកេ ឃរេ : ក្នុងផ្ទះធំ គឺ ក្នុងផ្ទះដេកមួយខ្នងធំ ។

បីបទថា បិដ្ឋិសង្ឃាដស្ស ហត្ថបាសំ វិជហិត្វា : ភិក្ខុលះហត្ថបាសនៃទ្វារឬធរណី មានសេចក្ដីថា លះហត្ថបាសនៃសន្ទះទ្វារបន្ទប់ក្នុងផ្ទះដេកនោះ ហើយអង្គុយក្នុងទីជិត ខាងក្នុងទីដេក ។ ក៏ផ្ទះដេកដូច្នេះ មានក្នុងសាលាធំមុខ ៤ ជាដើម ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងការកន្លងហួសពីកណ្ដាលដោយពាក្យនេះថា បិដ្ឋិវំសំ អតិក្កមិត្វា : ភិក្ខុចូលហួសមេដំបូលទៅ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបអាបត្តិព្រោះហួសពីទីកណ្ដាលនៃផ្ទះដេក ខ្នងតូចដែលគេសាងទុក យ៉ាងណាមួយ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មានវេទនា ២ ដូច្នេះឯង ។

សភោជនាសិក្ខាបទវណ្ណនា ចប់

# ៤. ៥. អោបជិច្ចនូរហោនិសង្ជសិក្ខាបទវណ្ណនា

[១៥៧-១៦៤] ពាក្យដែលនឹងគប្បីពោលក្នុងសិក្ខាបទទី៤ និងទី ៥ ទាំងអស់ មានន័យដូចពោលហើយក្នុងអនិយតសិក្ខាបទទាំង ២ នោះ ឯង ។ សកោជនសិក្ខាបទ មានសមុដ្ឋានដូចបឋមបារាជិកយ៉ាងណា សូម្បីសិក្ខាបទទី៤ និងទី៥នេះ ក៏មានសមុដ្ឋានដូចបឋមបារាជិកយ៉ាងនោះ ដែរ ដូច្នេះឯង ។

សិក្ខាបទទី៤-៥ ចប់

# ៦. ចារិតសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

## ពន្យល់បឋមបញ្ញត្តិនិងអនុប្បញ្ញត្តិ

[១៦៥] ក្នុងពាក្យថា ធេថាវុសោ ភត្តំ : ម្នាលអាវុសោទាំង ឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់(មក) នេះ មានវិនិច្ឆ័យថា បាន ឮថា ភត្តនោះ ជារបស់ដែលពួកអ្នកស្រុកបង្អោននាំមកហើយ; ព្រោះ ហេតុនោះ ពួកភិក្ខុទើបបានពោលយ៉ាងនោះ ។ តែក្នុងភត្តាហារដែលពួក អ្នកស្រុកមិនបានបង្អោននាំមក ភិក្ខុមិនអាចនឹងពោលយ៉ាងនោះ (ពោល

ថា ឱ្យភត្តាហារចុះ អាវុសោ) ជាបយុត្តវាចា (ការសូមរបស់) ។

ក៏ព្រះមានព្រះភាគត្រាស់ពាក្យនេះថា "ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយត្រូវទទួលហើយតម្កល់ទុក ទម្រាំឧបនន្ទត្រឡប់មកវិញ" ដូច្នេះ ដើម្បីត្រូវការរក្សាសទ្ធារបស់ត្រកូល ។ ក៏បើថា ព្រះមានព្រះភាគគប្បីត្រាស់ថា "អ្នកទាំងឡាយបែងចែកគ្នាឆាន់ចុះ", ពួកអ្នកស្រុកនឹងគប្បីបាត់បង់សេចក្ដីជ្រះថ្លា ។

[១៦៦] បទថា ឧស្សារិយិត្ថ[១] : គេក៏ផ្ញើត្រឡប់ទៅវិញ គឺត្រូវបាននាំត្រឡប់ទៅ ។ មានពាក្យអធិប្បាយថា ពួកអ្នកស្រុកបាននាំខាទនីយៈនោះត្រឡប់ទៅកាន់ផ្ទះដូចដើមវិញ ។

[១៦៩] ក្នុងពាក្យថា សន្តំ ភិក្ខុំ : ភិក្ខុដែលមាននៅ នេះមានវិនិច្ឆ័យដូច្នេះ ៖

មានសេចក្ដីគិតថា នឹងចូលទៅសួរសុខទុក្ខត្រកូល, ចាប់តាំងពីនោះទៅ ឃើញភិក្ខុណានៅខាង ៗ ឬនៅខាងមុខ ឬភិក្ខុណា ដែលខ្លួនអាចនឹងប្រាប់ដោយពាក្យនិយាយតាមប្រក្រតីបាន, ភិក្ខុនេះ ឈ្មោះថា មាន ។ តែមិនមានកិច្ចដែលនឹងត្រូវត្រាច់ទៅពោលលាក្នុងទីឯណោះឯណោះ ។

ភិក្ខុឈ្មោះថា មាននៅដោយហេតុមានប្រមាណប៉ុនណា ? ឈ្មោះថា មិនមាន ដោយហេតុមានប្រមាណប៉ុនណា ? គឺ ភិក្ខុអ្នកនៅក្នុងស្ថាន

១. ឱ. ឧស្សាធិយិត្ថ ថៃ. ឧស្សាធយិត្ថ ។
ទីខាងក្នុងវិហារ កើត ពិតមែន ភិក្ខុដែលខ្វនត្រូវត្រាច់រកពោលលាយ៉ាង នេះ ឈ្មោះថា មិនមានទុំះឯង ។ ន័យមួយទៀត ភិក្ខុទៅដោយធ្វើក្នុង ចិត្តថា យើងជួបភិក្ខុខាងក្នុងឧបចារសីមាហើយ ទើងពោលលា គប្បី ពោលលាភិក្ខុដែលខ្វនឃើញខាងក្នុងឧបចារសីមានោះ បើមិនជួបភិក្ខុ ឈ្មោះថា ជាអ្នកចូលទៅមិនពោលលាភិក្ខុដែលមិនមាន ។

[១៧២] បទថា អន្តរារាមំ : កាន់អារាមដែលមាននៅក្នុង ចន្លោះស្រុក បានដល់ ទៅកាន់វិហារដែលមាននៅខាងក្នុងស្រុក ។

បទថា ភត្តិយឃរំ : ផ្ទះនៃទាយកជាម្ចាស់ភត្ត បានដល់ ផ្ទះ ដែលគេនិមន្ត ឬផ្ទះរបស់ពួកអ្នកស្រុកអ្នកប្រគេនសលាកភត្តជាដើម ។

បទថា អាបទាសុ : ភិក្ខុដែលមានអន្តរាយ មានសេចក្តីថា កាលមានអន្តរាយនៃជីវិត និងព្រហ្មចរិយទើងទៅក៏គួរ ។ បទដែលនៅ សល់ក្នុងសិក្ខាបទនេះ ងាយស្រួលទាំងអស់នោះ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងមកកាយ វាចា ១ កាយវាចាចិត្ត ១ ជាកិរិយានិងជាអកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

## ចារិតសិក្ខាបទវណ្ណនា ចប់

# ៧. មហានាមសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

## ពន្យល់រឿងស្តេចមហានាមបវារណាភេសជ្ជៈ

[១៧៣] ព្រះឱរសនៃព្រះបិតុលារបស់ព្រះមានព្រះភាគ ចាស់ជាងព្រះមានព្រះភាគត្រឹមតែមួយខែ ជាព្រះអរិយសាវក តាំងនៅក្នុងផល ទាំង ២ ទ្រង់ព្រះនាមថា ស្តេចមហានាម ។

បីបទថា ភេសជ្ជំ ឧស្សន្នំ ហោតិ : មានថ្នាំសម្រាប់កែរោគដ៏បរិបូណ៌, មានសេចក្តីថា ទឹកដោះថ្លាដែលគេនាំមកពីក្រោលរក្សាទុកមានជាច្រើន ។

[១៧៥] បទថា សាទិតញ្ញា : ត្រូវត្រេកអរ មានសេចក្តីថា ភិក្ខុមិនគប្បីបដិសេធក្នុងសម័យនោះថា មិនមានរោគ គប្បីទទួលទុកដោយដាក់ចិត្តថា យើងនឹងសូមក្នុងកាលមានរោគ ។

[១៧៦] បីបទថា ឯត្តកេហិ ភេសជ្ជេហិ បវារេមិ : ខ្ញុំព្រះករុណា សូមបវារណាដោយភេសជ្ជៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ មានសេចក្តីថា គេបវារណាដោយអំណាចឈ្មោះ គឺ ដោយភេសជ្ជៈ ២-៣ យ៉ាង មានទឹកដោះថ្លា និងប្រេងជាដើម ឬដោយអំណាចចំនួន គឺដោយកម្ពង់ ១ នាឡិ ១ អាឡ្ហកៈ ១ ជាដើម ។

[១៧៨] បីបទថា អញ្ញានិ[1] ភេសជ្ជំ វិញ្ញាបេតិ : ហើយភិក្ខុទៅសូមភេសជ្ជៈឯទៀតវិញ មានសេចក្តីថា គេបវារណាដោយទឹកដោះថ្លា សូមប្រេង គេបវារណាដោយអាឡ្ហកៈ សូមទោណៈ ។

[១៧៨] ពីរបទថា ន ភេសជ្ជេន ករណីយេ : កាលបើភិក្ខុមិនមានដោយភេសជ្ជៈ មានសេចក្តីថា បើភិក្ខុអាចដើម្បីញុំាងអត្តភាពឱ្យប្រព្រឹត្តទៅបាន សូម្បីដោយភត្តលាយគ្នា ឈ្មោះថា កិច្ចនឹងគប្បីធ្វើដោយភេសជ្ជៈ មិនមាន ។

[១៧៩] បទថា បវារិតានំ : ដល់ភិក្ខុដែលសូមអំពីទាយកដែលគេបានបវារណា មានសេចក្តីថា មិនជាអាបត្តិដល់ពួកភិក្ខុដែលមនុស្សរបស់ខ្លួនបវារណាទុក ដោយការបវារណាជាចំណែកបុគ្គល ព្រោះការសូមតាមសមគួរដល់ភេសជ្ជៈ ដែលបវារណាទុក ។ តែក្នុងភេសជ្ជៈដែលគេបវារណាដោយអំណាចនៃសង្ឃ គួរ កំណត់ដឹងប្រមាណ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។

ក្នុងសិក្ខាបទនេះ មានសមុដ្ឋាន៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

មហានាមសិក្ខាបទវណ្ណនា ចប់

១. ថៃ. អញ្ញំ ។

# ៨. ឧយ្យុត្តសិក្ខាបទវណ្ណនា

ក្នុងសិក្ខាបទទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖

## កងទ័ព ៤ ពួកសម័យបុរាណ

[១៨០] បទថា អព្ភុយ្យាតោ : លើកចេញទៅ គឺ ទ្រង់លើកកងទ័ពចេញទៅ, មានសេចក្តីថា កងទ័ពចេញទៅអំពីព្រះនគរ ដោយតាំងព្រះទ័យថា យើងនឹងទៅប្រឈមមុខសត្រូវ ។

បទថា ឧយ្យុត្តំ : លើកចេញទៅ បានដល់ កងទ័ពដែលធ្វើការលើកចេញទៅហើយ, មានសេចក្តីថា កងទ័ពដែលចេញចាកពួកស្រុកទៅហើយ ។

[១៨២] ពីរបទថា ទ្វាទសបុរិសោ ហត្ថី : ពលដំរី (មួយ ៗ) មានបុរស ១២ នាក់ មានសេចក្តីថា ដំរី ១ មានទាហានប្រចាំ ១២ នាក់ យ៉ាងនេះ គឺ ពលជិះ ៤ នាក់, ពលរក្សាប្រចាំ ជើងដំរីជើងមួយ ៗ ២ នាក់ ។

ពីរបទថា តិបុរិសោ អស្សោ : ពលសេះ (មួយ ៗ) មានបុរសបីនាក់ មានសេចក្តីថា សេះ ១ មានទាហានប្រចាំ ៣ នាក់ យ៉ាងនេះ គឺ ពលជិះ ១ នាក់, ពលរក្សាជើង ២ នាក់ ។

ពីរបទថា ចតុប្បុរិសោ រថោ : ពលរថ (មួយ ៗ) មានបុរស

បួននាក់ មានសេចក្តីថា រថ ១ មានទាហានប្រចាំ ៤ នាក់ យ៉ាងនេះ គឺ សារថី (ពលបរ) ១ នាក់ អ្នកចម្បាំង (នាយទាហាន) ១ ពលរក្សាជែកកន្ទាស់ភ្លៅ ២ នាក់ ។

ពាក្យថា ចត្តារោ បុរិសា សរហត្ថា : ពលថ្មើរជើង (មួយ ៗ) មានបុរសបួន នាក់កាន់ធ្នូសរ បានដល់ ពលថ្មើរជើង មានពលយ៉ាងនេះ គឺ ទាហានកាន់អាវុធគ្រប់ដៃ ៤ នាក់ ៗ កងទ័ពប្រកបដោយអង្គ ៤ នេះដោយកំណត់យ៉ាងទាប ឈ្មោះថា សេនា ។ កាលទៅមើលសេនា ដូច្នេះ ជាទុក្កដ គ្រប់ ៗជំហាន ។

ពីរបទថា ទស្សនូបចារំ វិជហិត្វា : ភិក្ខុលះបង់នូវឧបចារសម្រាប់មើលឃើញ មានសេចក្តីថា កងទ័ពត្រូវអ្វីបាំងទុក ឬថា ចុះកាន់ទីទំនាប មើលមិនឃើញ, គឺ ភិក្ខុឈរក្នុងទីនេះ ហើយមិនអាចមើលឃើញព្រោះហេតុនោះ កាលភិក្ខុទៅកាន់ស្ថានទីដទៃមើល ជាបាចិត្តិយ គ្រប់ ៗប្រយោគ ។

[១៨៣] បទថា ឯកមេកំ : មួយ ៗ មានសេចក្តីថា បណ្តាអង្គ ៤ មានដំរីជាដើមនោះ តែមួយអង្គ ៗ ដោយហោចទៅ ពលដំរី ១ មានពលដេញ ១ នាក់ក្តី ពលថ្មើរជើងកាន់អាវុធ ១ នាក់ក្តី ។ ព្រះរាជាឈ្មោះថា មិនបានស្តេចយាត្រាទ័ព ស្តេចទៅប្រពាតព្រះរាជឧទ្យាន

ឬទន្លេ យ៉ាងនេះ ឈ្មោះថា មិនបាន ទ្រង់យាត្រាទ័ព ។

[១៨៤] បទថា អាបទាសុ : ដល់ភិក្ខុដែលមានសេចក្ដីអន្តរាយកើតឡើង មានសេចក្ដីថា កាលមានអន្តរាយនៃជីវិត និងអន្តរាយនៃព្រហ្មចរិយ មិនជាអាបត្តិដល់ភិក្ខុដែលទៅដោយគិតថា យើងទៅក្នុងកងទ័ពនេះនឹងរួចផុតទៅបាន ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

ឧយ្យុត្តសិក្ខាបទវណ្ណនា ចប់

# ៩. សេនាវាសសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

## ហេតុត្រូវនៅក្នុងកងទ័ពលើស ៣ រាត្រី

[១៨៦] ពាក្យថា អត្ថង្គតេ សុរិយេ សេនាយ វសតិ : កាលព្រះអាទិត្យអស្តង្គត ភិក្ខុចេះតែនៅក្នុងកងទ័ពនោះ មានសេចក្តីថា ប្រសិនបើថា ភិក្ខុសម្រេចឥរិយាបថណាមួយលើអាកាសដោយឫទ្ធិ នឹងឈរឬអង្គុយ ឬដេកក៏ដោយ ជាបាចិត្តិយទាំងអស់នោះ ។

[១៨៨] ពាក្យថា សេនា បដិសេនាយ រុទ្ធា ហោតិ : ដល់ភិក្ខុដែលនៅក្នុងកងទ័ព ហើយមានកងទ័ពជាសត្រូវមកលោមព័ទ្ធកងទ័ព មានសេចក្តីថា កងទ័ពត្រូវទ័ពសត្រូវឡោមព័ទ្ធទុក ធ្វើឱ្យដាច់មកសញ្ចារ ។

បទថា បលិពុទ្ធោ : ដែលជាប់ជំពាក់ គឺ ត្រូវសត្រូវឬឥស្សរជនឃាត់ឃាំងទុក ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សេនាវាសសិក្ខាបទវណ្ណនា ចប់

# ១០. ឧយ្យោធិកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

## ការចាត់ក្បួនទ័ពសម័យបុរាណ

[១៨៩] ជនទាំងឡាយលើកពួកទៅច្បាំងគ្នាក្នុងទីនេះ ព្រោះដូច្នោះ ទីនោះ ទើបឈ្មោះថា សមរភូមិប្រយុទ្ធ ។ ពាក្យថា ឧយ្យោធិកៈនេះ ជាឈ្មោះនៃទីសមរភូមិប្រហារគ្នា ( យុទ្ធភូមិឬសមរភូមិ ) ។

ពួកជន រមែងស្គាល់ទីសម្រាករបស់ពលច្បាំងក្នុងទីនេះ ដូច្នោះ ទីនោះ ទើបឈ្មោះថា ដែលសម្រាកពល ។ បានសេចក្តីថា ស្ថានទីត្រួតពិនិត្យពល ។

ការចាត់ក្បួនទ័ព ឈ្មោះថា សេនាព្យូហៈ ។ ពាក្យថា សេនាព្យូហៈ នេះជាឈ្មោះនៃការចាត់ក្បួនទ័ព ។

ពាក្យថា កងទ័ពដំរីយ៉ាងទាបមានដំរី ៣ នោះ បានដល់ ដំរី ៣ រួម នឹងដំរីដែលមានទាហានប្រចាំ ១២ នាក់ ដូចពោលហើយក្នុងខាងដើម ។ សូម្បីក្នុងបទដែលនៅសល់ ក៏ន័យនេះឯង ។ ពាក្យដែលនៅសល់ព្រមដោយសមុដ្ឋានជាដើម បណ្ឌិតគប្បីជ្រាបដោយន័យដូចពោលហើយក្នុងឧយ្យុត្តសិក្ខាបទនុ៎ះឯង ។

ឧយ្យោធិកសិក្ខាបទវណ្ណនា ចប់

ចំនួនសិក្ខាបទក្នុងអចេលកវគ្គនោះ គឺ

១. អចេលកសិក្ខាបទ ការឱ្យខាទនីយនិងភោជនីយដល់អចេលកជាដើម

២. ឧយ្យោជនសិក្ខាបទ ការបបួលទៅបិណ្ឌបាតហើយបញ្ជូនឱ្យត្រឡប់វិញ

៣. សភោជនសិក្ខាបទ ការអង្គុយក្នុងផ្ទះដែលមានជនតែពីរនាក់

៤. រហោបដិច្ឆន្នសិក្ខាបទ ការអង្គុយលើអាសនៈស្ងាត់

៥. រហោនិសជ្ជសិក្ខាបទ ការអង្គុយក្នុងទីស្ងាត់

៦. ចារិតសិក្ខាបទ ការមិនលាហើយទៅកាន់ត្រកូលទាំងឡាយ

៧. មហានាមសិក្ខាបទ ការត្រេកអរនឹងបច្ច័យតាមកំណត់នៃការបវារណា

៨. ឧយ្យុត្តសិក្ខាបទ ការទៅមើលក្បួនទ័ព

៩. សេនាវាសសិក្ខាបទ ការនៅក្នុងលំនៅកងទ័ព

១០. ឧយ្យោធិកសិក្ខាបទ ការទៅកាន់ទីចម្បាំងជាដើម

អដ្ឋកថា អចេលកវគ្គទី ៥ ចប់ ។

# ៦. សុរាបានវគ្គ

## ១. សុរាបានសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃសុរាបានវគ្គ ដូចតទៅនេះ ៖

### ពន្យល់រឿងសុរាមេរ័យ

[១៩៣] ពួកស្រុកមួយកន្លែង ឈ្មោះថា ភទ្ទវតិកា ។ ពួកស្រុកនោះបានឈ្មោះយ៉ាងនេះ ព្រោះប្រកបដោយរបងល្អស្អាត ។

បទថា បថាវិនោ : អ្នកដើរតាមមក គឺ អ្នកធ្វើដំណើរ ។

ពីរបទថា តេជសា តេជំ : តេជះ ដោយតេជះ បានដល់ (គ្របសង្កត់) តេជះនៃនាគដោយតេជះ គឺ ដោយអានុភាពរបស់ខ្លួន ។

បទថា កាបោតិកា : ពួកសត្វព្រាប គឺ មានពណ៌ក្រហមស្មើដូចគ្នានឹងពណ៌ជើងនៃពួកសត្វព្រាប ។

ពាក្យថា បសន្នំ[១] : ថ្លា នេះ ជាឈ្មោះនៃសុរាថ្លា ។

បីបទថា អននុច្ឆវិកំ ភិក្ខវេ សាគតស្ស : ម្នាលភិក្ខុទាំងឡាយ កម្មរបស់សាគតភិក្ខុមិនសមគួរ មានសេចក្ដីដែលលោកពោលទុកថា

---

១. ថៃ. ភូមា. បសន្នា ។

ឈ្មោះថា ការផឹកទឹកស្រវឹង ជាការមិនសមគួរដល់សាគតៈអ្នកសម្រេច អភិញ្ញា ៥ ។

[១៩៤] មេរ័យដែលគេធ្វើដោយរសនៃផ្កាស្រគំជាដើម ឈ្មោះថា បុប្ផាសវៈ ។ មេរ័យដែលគេច្របាច់ផ្លែច័នជាដើមហើយ ធ្វើដោយរសនៃផ្លែច័នជាដើមនោះ ឈ្មោះថា ផលាសវៈ ។ មេរ័យដែលគេធ្វើដោយរសជាតិនៃផ្លែច័ន (ឬទំពាំងបាយជូរ)ជាដើម ឈ្មោះថា មធ្វាសវៈ ។ អាចារ្យពួកខ្លះពោលថា គេធ្វើដោយទឹកឃ្មុំក៏មាន ។ មេរ័យដែលឈ្មោះថា គុឡាសវៈ គេធ្វើដោយទឹកអំពៅស្រស់ជាដើម ។

ធម្មតាសុរា ដែលគេដាក់មេម្សៅ ធ្វើដោយរសសូម្បីនៃផ្កាដូងជាដើម រមែងដល់ការរាប់ថា សុរាទាំងអស់ ។ អាចារ្យពួកខ្លះពោលថា កាលដួសយកទឹកថ្លានៃសុរាដាក់មេហើយទុំះឯង (ដែលនៅសល់) រមែងដល់ការរាប់ថា មេរ័យទាំងអស់ ។

បីបទថា អន្តមសោ កុសគ្គេនាបិ បិវតិ : ដោយហោចទៅសូម្បីតែភិក្ខុផឹកប្រមាណប៉ុនចុងស្បូវ មានសេចក្តីថា ភិក្ខុផឹកសុរាឬមេរ័យនោះតាំងពីមេ សូម្បីដោយចុងស្បូវ ជាបាចិត្តិយ ។ តែកាលផឹកសូម្បីច្រើនដោយប្រយោគតែមួយ ជាអាបត្តិតែមួយ ។ កាលផឹកដាច់ ៗ ជាអាបត្តិច្រើនដោយរាប់ប្រយោគ ។

[១៩៦] ពាក្យថា អមជ្ជញ្ច ហោតិ មជ្ជវណ្ណំ មជ្ជគន្ធំ មជ្ជរសំ : ភិក្ខុផឹកទឹកមិនស្រវឹង តែទឹកនោះមានពណ៌ដូចទឹកស្រវឹង មានក្លិនដូចទឹកស្រវឹង មានរសដូចទឹកស្រវឹង មានសេចក្ដីថា ជាថ្នាំត្រាំទឹកអំបិលក្ដី មានពណ៌ក្រហមចាស់ក្ដី ។

បទថា សូបសំបាកេ : លាយនឹងសម្ល មានសេចក្ដីថា ជនទាំងឡាយដាក់ទឹកស្រវឹងចុះបន្តិចបន្តួចដើម្បីអប់ក្លិន ហើយស្លសម្ល, ជាអនាបត្តិ ព្រោះសម្លដាក់ទឹកស្រវឹងបន្តិចបន្តួចនោះ ។ សូម្បីក្នុងស្ងោរសាច់ក៏ន័យនេះដូចគ្នា ។ ក៏ជនទាំងឡាយ រមែងចំហៀវប្រេងនឹងទឹកស្រវឹងសូម្បីដើម្បីជាថ្នាំរម្ងាប់ខ្យល់, មិនជាអាបត្តិក្នុងប្រេងសូម្បីនោះ ដែលមិនបានលាយទឹកស្រវឹងដរាបលើសទៅប៉ុណ្ណោះ ។ ក្នុងប្រេងដែលលាយទឹកស្រវឹងខ្លាំងទៅ ដរាបមានពណ៌មានក្លិន និងរសនៃទឹកស្រវឹងប្រាកដជាអាបត្តិពិត ។

ពីរបទថា អមជ្ជំ អរិដ្ឋំ : ថ្នាំអរិដ្ឋមិនស្រវឹង មានសេចក្ដីថា ក្នុងថ្នាំត្រាំឈ្មោះអរិដ្ឋៈ ដែលមិនមែនទឹកស្រវឹង មិនជាអាបត្តិ ។ បានឮថា ជនទាំងឡាយ ធ្វើថ្នាំត្រាំឈ្មោះអរិដ្ឋៈ ដោយរសនៃកន្ទួតព្រៃជាដើមនុ៎ះឯង ។ ថ្នាំត្រាំនោះមានពណ៌, ក្លិន និងរសស្រដៀងទឹកស្រវឹងតែមិនស្រវឹង ។ ព្រះមានព្រះភាគទ្រង់សំដៅយកថ្នាំត្រាំឈ្មោះអរិដ្ឋៈនោះ ទើប

ត្រាស់ពាក្យនេះ ។ តែថ្នាំត្រាំអរិដ្ឋៈដែលគេផ្សំដោយគ្រឿងផ្សំចាត់ជាទឹកស្រវឹង មិនគួរតាំងពីមេ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

ក្នុងសិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។ ក៏ក្នុងសមុដ្ឋានជាដើមនេះ បណ្ឌិតគប្បីជ្រាបថា ជាអចិត្តកៈ ព្រោះមិនដឹងវត្ថុ ។ គប្បីជ្រាបថា ជាលោកវជ្ជៈ ព្រោះនឹងគប្បីផឹកដោយអកុសលចិត្តប៉ុណ្ណោះ ដូច្នេះឯង ។

សុរាបានសិក្ខាបទវណ្ណនា ចប់

## ២. អង្គុលិបតោទកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

### ពន្យល់ការចាក់ក្រឡេកដោយម្រាមដៃ

[១៩៧] ដោយបទថា អង្គុលិប្បតោទកេន **:** ដោយជន្លួញគឺម្រាមដៃ នេះ ត្រាស់យកម្រាមដៃចាក់ក្រឡេកត្រង់ក្លៀកជាដើម ។

បទថា ឧត្តសន្តោ **: សើចគាំង** គឺ ហត់ដោយការសើចពេកទៅ ។

បទថា អនស្សាសកោ **: ដកដង្ហើមមិនរួច** គឺ ជាអ្នកមានខ្យល់ អស្សាសៈ បស្សាសៈ ដាច់ការសញ្ចារទៅមក ។

[២០១] បីបទថា អនុបសម្បន្នំ កាយេន កាយំ **: ភិក្ខុពាល់ត្រូវកាយរបស់អនុបសម្បន្ន ដោយកាយ ( របស់ខ្លួន )** មានសេចក្ដីថា សូម្បីនាងភិក្ខុនី ក៏តាំងនៅក្នុងឋានៃអនុបសម្បន្ន ក្នុងសិក្ខាបទនេះ ។ កាលភិក្ខុពាល់ត្រូវនាងភិក្ខុនីសូម្បីនោះ ដោយប្រាថ្នាទីងលេង ក៏ជាទុក្កដ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិកសិក្ខាបទ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មានវេទនា ២ ដូច្នេះឯង ។

អង្គុលិបតោទកសិក្ខាបទវណ្ណនា ចប់

## ៣. ហស្សធម្មសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

### ពន្យល់អំពីការលេងសើចក្នុងទឹក

[២០៤] បទថា អបញ្ញត្តេ : ជាអ្នកមិនដឹងនូវសិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តរួចហើយ មានសេចក្ដីថា ភិក្ខុទាំងនោះនឹងមិនទាន់ដឹងសិក្ខាបទដែលព្រះមានព្រះភាគទ្រង់តែងតាំងទុក គឺ ទ្រង់បញ្ញត្តិទុកហើយ ។ ការលេងទឹក ព្រះមានព្រះភាគត្រាស់ហៅថា ធម៌ គឺការសើចក្នុងទឹក ។

[២០៥] បទថា ឧបរិគោប្ផកេ : ដែលជ្រៅជាងភ្នែកគោឡើងទៅ គឺ ក្នុងទឹកជ្រៅលិចភ្នែកគោទាំង ២ ។

បទថា ហស្សាធិប្បាយោ : មានបំណងនឹងលើច គឺ មានសេចក្ដីប្រាថ្នានឹងលេង ។

ក្នុងពាក្យថា និមុជ្ជតិ វា : ទោះមុជចុះក្ដី ជាដើម មានវិនិច្ឆ័យថា កាលធ្លាក់ចុះ ដើម្បីត្រូវការនឹងមុជចុះ ជាទុក្កដ គ្រប់ជំហាន, ក្នុងការមុជចុះនិងងើបឡើង ជាបាចិត្តិយគ្រប់ប្រយោគ ។ ភិក្ខុមុជចុះហែលក្នុងទឹកទុំះឯង ជាបាចិត្តិយ គ្រប់គ្រាដែលវាសដៃ វាសជើងក្នុងទីទាំងពួង ។

បទថា បលវតិ : ហែល បានដល់ ហែលឆ្លងទៅ ។ កាលប្រើដៃទាំង ២ ហែលឆ្លងទៅជាបាចិត្តិយ គ្រប់វារៈដែលវាសដៃ ។ សូម្បីក្នុងជើងទាំង ២ ក៏ន័យនេះឯង ភិក្ខុហែលឆ្លងទៅដោយអវយវៈណា ៗ ជាបាចិត្តិយគ្រប់ប្រយោគនៃអវយវៈនោះ ៗ ។ ភិក្ខុលោតចុះក្នុងទឹក អំពីច្រាំងក្តី អំពីដើមឈើក្តី ជាបាចិត្តិយដូចគ្នា ។

[២០៧] ពីរបទថា នាវាយ កីឡតិ : លេងទឹកដោយទូក មានសេចក្តីថា ភិក្ខុលេងទូកដោយច្រវានិងថ្នោលជាដើម ឬអូសទូកឡើងលើមាត់ច្រាំង ឈ្មោះថា លេងទូក ជាទុក្កដ ។

សូម្បីក្នុងបទថា ហត្ថេន វា : ដោយដៃក្តី ជាដើម បណ្ឌិតគប្បីជ្រាបថា ជាទុក្កដ គ្រប់ប្រយោគ ។ អាចារ្យពួកខ្លះពោលថា កាលភិក្ខុយកដៃគប់ក្បឿងទៅលើទឹក ជាទុក្កដ គ្រប់វារៈដែលក្បឿងធ្លាក់ចុះនិងផែលឡើង ។ ពាក្យនោះមិនគួរកាន់យក ពិតមែន ការដែលក្បឿងធ្លាក់ចុះទៅក្នុងទឹកនោះ ជាទុក្កដតែមួយប៉ុណ្ណោះ ព្រោះមានប្រយោគតែមួយ ។

ន័យមួយទៀត ភិក្ខុឆ្លងទឹក ឬមិនបានឆ្លង លេងទឹកដែលដក់នៅក្នុងទឹកន្លែងណាមួយ ដោយអាការយ៉ាងណាមួយដទៃ វៀរការមុជងើបជាដើម ដែលពោលហើយក្នុងទឹកផុតភ្នែកគោឡើងទៅ ដោយហោចទៅសូម្បីលេងក្បន់ទឹកបាចក៏ជាទុក្កដដូចគ្នា ។ តែនឹងសរសេរអក្សរពន្យល់

សេចក្តី គួរ ។ ក្នុងសិក្ខាបទនេះ មានវិនិច្ឆ័យប៉ុណ្ណេះ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

ហស្សធម្មសិក្ខាបទវណ្ណនា ចប់

# ៤. អនាទរិយសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

## ពន្យល់អំពីការមិនអើពើក្នុងធម៌

[២១១] ពាក្យថា កថាយំ នស្សេយ្យ : ធ្វើដូចម្តេចហ្ន៎ ធម៌នេះបាត់ទៅ មានសេចក្តីថា ដូចម្តេច ? ធម៌ គឺ បែបផែនប្រពៃណីនេះ នឹងគប្បីសាបសូន្យទៅ ។

ពាក្យថា តំ វា ន សិក្ខិតុកាមោ : ឬមិនចង់សិក្សាធម៌នោះ មានសេចក្តីថា អ្នកមិនប្រាថ្នា នឹងសិក្សាព្រះបញ្ញត្តិ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិទុក ដែលជាហេតុឱ្យពួកភិក្ខុហៅ (លោកថា អ្នកមិនអើពើ) ។

[២១៣] បទថា អបញ្ញត្តេន : ដែលមិនមែនជាវិនយបញ្ញត្តិ គឺ មិនបានមកក្នុងព្រះសូត្រ ឬក្នុងព្រះអភិធម្ម ។

[២១៤] ក្នុងពាក្យថា ឯវំ អម្ហាកំ អាចរិយានំ ឧគ្គហោ : បាលីនៃអាចារ្យទាំងឡាយរបស់យើងយ៉ាងនេះ នេះ មិនគួរកាន់យកការរៀនរបស់អាចារ្យដែលគួរតិះដៀល ។ គួរកាន់យកការរៀនរបស់អាចារ្យដែលមកតាមប្រពៃណីប៉ុណ្ណោះ ។ ក្នុងកុរុន្ទីពោលថា ការរៀនតាមអាចារ្យក្នុងមកលោកវជ្ជៈមិនគួរ, តែក្នុងមកបណ្ណត្តិវជ្ជៈ គួរ ។ ក្នុងមហា

បច្ចុប្បន្នពោលថា ការរៀនរបស់ពួកអាចារ្យអ្នករៀនសូត្រ និងសុត្តានុលោម ប៉ុណ្ណោះ ចាត់ជាប្រមាណបាន, ពាក្យរបស់ពួកអាចារ្យអ្នកមិនដឹង (សូត្រនិងសុត្តានុលោម) មិនជាប្រមាណបានទេ ។ ពាក្យទាំងអស់នោះ ក៏រួមចុះក្នុងការរៀនដែលមកតាមប្រពៃណី ។ បទដែលនៅសល់ងាយ យល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងមកកាយចិត្ត ១ វាចា ចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

អនាទរិយសិក្ខាបទវណ្ណនា ចប់

# ៥. ភឹសាបនសិក្ខាបទវណ្ណនា

[២១៩] ការនាំរូបចូលទៅសម្តែងជាដើម ក្នុងសិក្ខាបទទី ៥ គប្បីជ្រាបដោយន័យ ដូចពោលហើយ ក្នុងមនុស្សវិគ្គហសិក្ខាបទនុ៎ះឯង ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។ បកិណ្ណកៈមានសមុដ្ឋានជាដើម ដូចអនាទរិយសិក្ខាបទនោះឯង ។

ភឹសាបនសិក្ខាបទវណ្ណនា ចប់

# ៦. ជោតិសមាទហនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

## ពន្យល់អំពីការដុតភ្លើងអាំង

[២២២] ពាក្យថា ភគ្គះ នេះ ជាឈ្មោះរបស់ជនបទ ។ ពាក្យថា សុង្សុមារគីរៈ ជាឈ្មោះរបស់ក្រុង ។ ពាក្យថា ភេសកឡាវ័ន ជាឈ្មោះនៃព្រៃដែលអាស្រ័យក្រុងនោះ (ឧទ្យានដែលតាំងនៅជិតក្រុងនោះ) ។ ក៏ព្រៃនោះហៅថា មិគទាយៈ ព្រោះជាទីព្រះរាជទានអភ័យដល់ពួកម្រឹគ ដើម្បីត្រូវការឱ្យនៅសប្បាយ ។

បទថា សមាទហិត្វា : បង្កាត់ គឺ ឱ្យឆេះសន្ធោសន្ធៅឡើង ។

បទថា បរិឡាគេសិ : ឱ្យជួលជាសពាស គឺ ដេញជាប់តាមទៅ ។

[២២៤] បទថា បធីបេបិ : ប្រទីបក្តី គឺ ក្នុងការអុជប្រទីបក្តី ។

បទថា ជោតិកេបិ : បង្កាត់ភ្លើងក្តី បានដល់ ការបង្កាត់ភ្លើងក្នុងកិច្ចមានការដុតបាត្រ និងកម្តៅខ្លួនជាដើមក្តី ។

បទថា តថារូបប្បច្ចយា : មានហេតុ មានសភាពយ៉ាងនោះ គឺ មានការអុចប្រទីបជាដើមជាបច្ច័យ ។

[២២៥] ក្នុងពាក្យថា សយំ សមាទហាតិ : ភិក្ខុបង្កាត់ខ្លួនឯងនេះ មានវិនិច្ឆ័យថា ផ្តើមតាំងពីដុតឈើពួតភ្លើង ដោយសេចក្តីប្រាថ្នាទឹង

បន្ទាត់ភ្លើងទៅដរាបដល់អណ្តាតភ្លើងមិនទាន់ឆេះឡើង ជាទុក្កដ គ្រប់ ៗ ប្រយោគ ។

[២២៦] ពីរបទថា **បដិលាតំ ឧក្ខិបតិ : ភិក្ខុចាប់អង្គត់ភ្លើងលើកឡើង** មានសេចក្តីថា ភិក្ខុលើកគប់ភ្លើងកំពុងឆេះ ដែលធ្លាក់ឡើងមក, អធិប្បាយថា លើកទុកក្នុងទីដើមទៀត កាលភិក្ខុចាប់គប់ភ្លើងដែលមិនរលត់យ៉ាងនេះ ដាក់ចុះទៅប៉ុណ្ណោះ ជាទុក្កដ តែជាបាចិត្តិយពិត ដល់ភិក្ខុបន្ទាត់ភ្លើងដែលភ្លើងរលត់ ហើយឱ្យឆេះទៀត ។

[២២៧] បទថា តថារូបប្បច្ចយា : **ភិក្ខុមានហេតុ មានសភាពយ៉ាងនោះ** បានដល់ មិនជាអាបត្តិដល់ភិក្ខុដែលដុតភ្លើង ព្រោះបច្ច័យបែបនោះ សូម្បីយ៉ាងដទៃ វៀរការអុជប្រទីបជាដើមចេញ ។

បទថា អាបទាសុ : **ភិក្ខុមានសេចក្តីអន្តរាយ** មានសេចក្តីថា មានអន្តរាយព្រោះត្រូវពស់ខាំ ត្រូវចោរឡោមព័ទ្ធ ម្រឹគកាចប្រទូស្ត និងអមនុស្សបៀតបៀន, មិនជាអាបត្តិសូម្បីដល់ភិក្ខុដែលឆេះភ្លើងព្រោះឧបទ្រវៈនោះ ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

ជោតិសមាទហនសិក្ខាបទវណ្ណនា ចប់

# ៧. ន្ហានសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[២៣៤] ក្នុងពាក្យថា ចុណ្ណេន វា មត្តិកាយ វា : ដោយលំអិតក្តី ដោយដីស្អិតក្តី នេះ មានវិនិច្ឆ័យថា ជាទុក្កដ គ្រប់ប្រយោគ ចាប់ផ្តើតាំងពីវេលាដែលត្រៀមម្សៅ និងដីជាដើម ។

[២៣៦] ក្នុងពាក្យថា ធារំ គច្ឆន្តោ ន្ហាយតិ : ភិក្ខុឆ្លងទៅត្រើយម្ខាងហើយងូត នេះ មានវិនិច្ឆ័យថា ភិក្ខុនឹងងូតទឹកក្នុងរណ្តៅ (អាង) ដែលខ្ទួនកកាយខ្សាច់ឡើងធ្វើទុកក្នុងទន្លេស្ងួត គួរ ។

បទថា អាបទាសុ : ភិក្ខុមានសេចក្តីអន្តរាយ មានសេចក្តីថា ភិក្ខុត្រូវឃ្មុំជាដើមដេញទិច នឹងមុជចុះក្នុងទឹក ក៏គួរ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ន្ហានសិក្ខាបទវណ្ណនា ចប់

# ៨. ទុព្វណ្ណករណសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

## ការពិន្ទុចីវរដែលបានមកថ្មីមុនប្រើ

[២៣៧] ក្នុងពាក្យថា នវំ បន ភិក្ខុនា ចីវរលាភេន : ភិក្ខុបានចីវរថ្មីមកហើយ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុបានចីវរណា, ព្រោះហេតុនោះ ចីវរនោះ ទើបឈ្មោះថា លភៈ, លភៈនុ៎ះឯង គឺលាភ ។ បានអ្វី ? បានចីវរ ។ ចីវរយ៉ាងណា ? ចីវរថ្មី ។ កាលគួរត្រាស់ដោយន័យយ៉ាងនេះថា នវចីវរលាភេន មិនលុបនិគ្គហិតត្រាស់ថា នវំ ចីវរលាភេន ដូច្នេះ ។ មានអត្ថន័យថា បានចីវរថ្មីមក សព្ទថា បន ក្នុងបទទាំង ២ ដាក់ទុកនៅកណ្តាល ជានិបាត ។

ពាក្យថា ភិក្ខុនា ជាការសម្តែងដល់ភិក្ខុដែលបានចីវរ ។ តែក្នុងបទភាជនៈ ទ្រង់មិនអើពើព្យញ្ជនៈ ដើម្បីសម្តែងតែចីវរដែលភិក្ខុបាន ទើបត្រាស់ពាក្យថា ចីវរំ ឆាម ឆន្នំ ចីវរានំ : ដែលហៅថា ចីវរ គឺបណ្តាចីវរទាំង ៦ ជាដើម ។

ក៏ក្នុងបទថា (អញ្ញតរំ) ចីវរំ : ចីវរ(ណាមួយ) នេះ គប្បីជ្រាបថា ជា(ប្រភេទ)ចីវរដែលអាចស្លៀក ឬ ដណ្តប់បានប៉ុណ្ណោះ ។

ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគមិនត្រាស់ថា "វិកប្បនុបគបច្ឆិមំ : ចីវរយ៉ាងតូចដែលគួរវិកប្បបាន"ទេ ។

[២៣៨] ពាក្យថា ទុព្វណ្ណករណំ អាទាតព្វំ : ភិក្ខុត្រូវធ្វើពិន្ទុកប្ប នេះ ព្រះមានព្រះភាគត្រាស់សំដៅយកកប្បពិន្ទុ (ចុចចំណាំ) មិនបានត្រាស់សំដៅដល់ការធ្វើចីវរទាំងផ្ទាំងឱ្យខូចពណ៌, ដោយពណ៌ខៀវជាដើម ។

បទថា កំសនីលំ : ពណ៌ខៀវដូចសំរិទ្ធិ គឺ ពណ៌ខៀវរបស់ជាងស្បែក ។ តែក្នុងមហាបច្ចរីពោលថា ស្នឹមដែក ស្នឹមលោហៈនោះ មានឈ្មោះថា ពណ៌ខៀវដូចសំរិទ្ធិ ។

បទថា បលាសនីលំ : ពណ៌ខៀវដូចស្លឹកឈើ បានដល់ ទឹកស្លឹកឈើប្រភេទណាមួយដែលមានពណ៌ខៀវចាស់ ។

ក៏ឯភិក្ខុកាលនឹងកាន់យកកប្បៈនោះ ជ្រលក់ចីវរហើយគប្បីឱ្យកប្បៈពិន្ទុប៉ុនវង្វង់ភ្នែកក្ងោក ឬថា ខ្នងសង្កើច ត្រង់មុំទាំង ៤ ឬត្រង់មុំទាំង ៣ ទាំង ២ ឬមុំតែមួយក៏បាន ។

តែក្នុងមហាបច្ចរីពោលថា នឹងកាន់យកពិន្ទុកប្បៈត្រង់ផ្ទាំងសំពត់ ឬត្រង់ក្តុំមិនគួរ ។ ចំណែកក្នុងមហាអដ្ឋកថាពោលថា គួរ ។ ក៏កប្បៈដែលជាជួរ និងកប្បៈដែលជាចង្កោមជាដើម លោកហាមទុកក្នុងគ្រប់ ៗ

អដ្ឋកថា ; ព្រោះដូច្នោះ ទើបមិនគួរធ្វើកប្បៈ ដោយវិការសូម្បីអ្វីយ៉ាង ដទៃ វៀរពិន្ទុមូលតែមួយ ។

[២៤០] ក្នុងពាក្យថា អគ្គឡេ : ចីវរដែលប៉ះដោយបំណះថ្មី ជាដើម មានវិនិច្ឆ័យថា មិនមានកិច្ចដែលនិងបន្ថែមសំពត់ពោះជាដើមនេះ ក្នុងចីវរដែលធ្វើកប្បៈហើយ ធ្វើកប្បៈថ្មីខាងក្រោយ ។ បទដែលនៅសល់ងាយស្រួលយល់ទាំងនោះ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយានិង ជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូចនេះឯង ។

ទុព្វណ្ណករណសិក្ខាបទវណ្ណនា ចប់

# ៩. វិកប្បនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

## ការប្រើចីវរមិនទាន់បានដកវិកប្ប

[២៤២] ពីរបទថា តស្ស វា អធិន្នំ : ភិក្ខុជាម្ចាស់ចីវរប្រើប្រាស់ចីវរដែលភិក្ខុអ្នកទទួលវិកប្បនោះ មិនបានប្រគល់ឱ្យក្ដី បានដល់ (ចីវរ) ដែលភិក្ខុអ្នកទទួលវិកប្ប មិនទាន់ពោលឱ្យដល់ភិក្ខុម្ចាស់ចីវរយ៉ាងនេះថា "លោកចូរប្រើប្រាស់ក៏ដោយ ចូរលះបង់ក៏ដោយ ចូរធ្វើតាមបច្ច័យក៏ដោយ" ។

ពីរបទថា តស្ស វា អវិស្សាសេន្តោ : មិនស្និទ្ធស្នាលនឹងភិក្ខុជាអ្នកទទួលវិកប្បនោះ ហើយប្រើប្រាស់ក្ដី មានសេចក្ដីថា ឬ ដោយមិនវិស្សាសៈដល់ភិក្ខុដែលធ្វើវិន័យកម្ម ។ តែមិនជាអាបត្តិ ដល់ភិក្ខុដែលប្រើប្រាស់ចីវរដែលភិក្ខុដែលទទួលវិកប្បនោះឱ្យហើយ ឬដោយវិស្សាសៈដល់ភិក្ខុដែលទទួលវិកប្បនោះ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ព្រោះមានន័យដូចដែលបានពោលហើយ ក្នុងតីសកកណ្ឌវណ្ណនានោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងមកកាយវាចា១ វាចាចិត្ត១ ជាកិរិយានិងជាអកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

វិកប្បនសិក្ខាបទវណ្ណនា ចប់

# ១០. ចីវរាបនិធានសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[២៨៥] បទថា អបនិធេន្តិ : លាក់ទុក គឺ នាំទៅរក្សាទុក ។

បទថា ហសាបេក្ខោ : មានបំណងនឹងលេងសើច គឺ មានសេចក្តីប្រាថ្នានឹងសើច ។

[២៨៧] ពីរបទថា អញ្ញំ បរិក្ខារំ : បរិក្ខារដទៃ បានដល់បរិក្ខារដទៃមានថង់បាត្រជាដើម ដែលមិនបានមកក្នុងព្រះបាលី ។

[២៨៨] បីបទថា ធម្មឹ កថំ កត្វា : អញនឹងធ្វើធម្មីកថា មានសេចក្តីថា កាលភិក្ខុរក្សាទុកដោយធ្វើចិត្តថា យើងនឹងពោលធម្មកថាយ៉ាងនេះថា "ឈ្មោះថា សមណៈជាអ្នកមិនរក្សាទុកដាក់បរិក្ខារ មិនគួរ" ហើយទើបឱ្យ ដូច្នេះ មិនជាអាបត្តិ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា៣ ដូច្នេះឯង ។

ចីវរាបនិធានសិក្ខាបទវណ្ណនា ចប់

## ចំនួនសិក្ខាបទក្នុងសុរាបានវគ្គនោះ គឺ

| | |
|---|---|
| ១. សុរាបានសិក្ខាបទ | ការផឹកសុរា |
| ២. អង្គុលិបតោទកសិក្ខាបទ | ការចាក់ក្រឡេក |
| ៣. ហសធម្មសិក្ខាបទ | ការលេងទឹក |
| ៤. អនាទរិយសិក្ខាបទ | ការមិនអើពើ |
| ៥. ភឹសាបនសិក្ខាបទ | ការបន្លាចឲ្យខ្លាច |
| ៦. ជោតិសមាទាទហនសិក្ខាបទ | ការអាំងកម្តៅខ្លួន |
| ៧. ន្ហានសិក្ខាបទ | ការងូតទឹក |
| ៨. ទុព្វណ្ណករណសិក្ខាបទ | ការធ្វើចីវរឲ្យខូចពណ៌ |
| ៩. វិកប្បបនសិក្ខាបទ | ការវិកប្បចីវរ |
| ១០. ចីវរាបនិធានសិក្ខាបទ | ការលាក់ចីវរ |

អដ្ឋកថា សុរាបានវគ្គទី ៦ ចប់ ។

# ៧. សប្បាណកវគ្គ

## ១. សញ្ចិច្ចបាណសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃសប្បាណវគ្គ ដូចតទៅនេះ ៖

### ពន្យល់រឿងការក្លែងសម្លាប់សត្វ

[២៤៩] ពីរបទថា ឥស្សាសោ ហោតិ : ជានាយខ្មាន់ធ្នូ សេចក្តីថា ធ្លាប់ជាអាចារ្យរបស់ពួកនាយខ្មាន់ធ្នូក្នុងកាលនៅជាគ្រហស្ថ ។

ពីរបទថា ជីវិតា វោរោបិតា : សម្លាប់សត្វ បានដល់ ផ្តាច់ចេញចាកជីវិត ។ សូម្បីក្នុងសិក្ខាបទ ពាក្យថា វោរោបេយ្យ ក៏ប្រែថា គប្បីផ្តាច់ចេញ ។ ក៏ព្រោះពាក្យថា វោរោបេយ្យ នោះ ត្រឹមតែជាវោហារប៉ុណ្ណោះ, ព្រោះថា កាលសត្វត្រូវផ្តាច់ចាកជីវិតហើយ មិនមានជីវិតណា ៗ នឹងតាំងនៅផ្សេងដទៃក្នុងសត្វនេះទេ គឺ នឹងដល់សេចក្តីអន្តរធានទៅពិតប្រាកដ ដូចសិរ្សៈកាលត្រូវផ្តាច់គ្រឿងប្រដាប់សិរ្សៈ ដូច្នោះ; ព្រោះដូច្នោះ ដើម្បីសម្តែងអត្ថនោះ ក្នុងបទភាជនៈ ព្រះមានព្រះភាគទើបបានត្រាស់ពាក្យថា ជីវិតិន្ទ្រិយំ ឧបច្ឆិន្ទតិ : ផ្តាច់បង់នូវជីវិតិន្ទ្រិយជាដើម ។ ក៏ក្នុងសិក្ខាបទនេះ ចំពោះសត្វតិរច្ឆានប៉ុណ្ណោះ បណ្ឌិតគប្បី

ជ្រាបថា បាណៈ (ប្រាណ) ។ ភិក្ខុសម្លាប់សត្វតិរច្ឆាននោះ តូចខ្លះ ធំខ្លះ ជាអាបត្តិប៉ុនគ្នា, មិនមានសេចក្តីផ្សេងគ្នា ។ តែក្នុងសត្វធំជាអកុសលច្រើន ព្រោះមានសេចក្តីព្យាយាមច្រើន ។

[២៥១] ពីរបទថា ចាណោ ចាណសញ្ញី : សត្វ(តិរច្ឆាន) ភិក្ខុសំគាល់ថា សត្វ(តិរច្ឆាន) មានសេចក្តីថា ដោយហោចទៅសូម្បីភិក្ខុនឹងធ្វើការសំអាតគ្រែ និងតាំង មានសេចក្តីសម្គាល់សូម្បីក្នុងពងសង្កើចថា ជាសត្វតូច ញិចពងសង្កើចនោះឱ្យបែក ព្រោះដាច់សេចក្តីករុណា ជាបាចិត្តិយ ។ ព្រោះហេតុនោះ ភិក្ខុគប្បីតាំងសេចក្តីករុណាទុកក្នុងឋានៈដូច្នោះ ជាអ្នកមិនប្រមាទធ្វើវត្តចុះ ។ បទដែលនៅសល់ព្រមទាំងសមុដ្ឋានជាដើម បណ្ឌិតគប្បីជ្រាបដោយន័យដូចបានពោលហើយក្នុងមនុស្សវិគ្គហសិក្ខាបទនុ៎ះឯង ។

សញ្ចិច្ចបាណសិក្ខាបទវណ្ណនា ចប់

# ២. សប្បាណកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

## ពន្យល់អំពីការបរិភោគទឹកមានសត្វ

[២៥៣] បទថា សប្បាណកំ **:** មានសត្វ បានដល់ ទឹកមានសត្វដោយពួកសត្វតូច ៗដែលស្លាប់ព្រោះការបរិភោគ ។ អធិប្បាយថា ក៏ភិក្ខុកាលដឹងហើយ បរិភោគទឹកដូច្នោះ ត្រូវបាចិត្តិយគ្រប់ប្រយោគ ។ កាលភិក្ខុផឹកទឹកសូម្បីពេញបាត្រ ដោយប្រយោគតែមួយមិនដាច់ ក៏ជាអាបត្តិតែមួយ ។ ភិក្ខុយកទឹកដូច្នោះគ្រវែងលាងបាត្រមានអាមិសក្តី ផ្ញើបាត្រឋបរក្តៅឱ្យត្រជាក់ក្នុងទឹកដូច្នោះក្តី យកដៃក្បង់ ឬយកបោយដងទឹកនោះងូតក្តី ជាបាចិត្តិយ គ្រប់ប្រយោគ ។

សូម្បីភិក្ខុចូលទៅកាន់ត្រពាំងទឹកក្តី ស្រះបោក្ខរណីក្តី ឱ្យរលកធំកើតឡើងដើម្បីត្រូវការឱ្យទឹកហៀរហូរចេញមកខាងក្រៅ (ជាបាចិត្តិយ) ។ ពួកភិក្ខុកាលជម្រះត្រពាំងឬស្រះបោក្ខរណី គប្បីបន្ទោបង់ចាក់ទឹកដែលដួសពីត្រពាំង ឬពីស្រះបោក្ខរណីនោះ ចុះក្នុងទឹកប៉ុណ្ណោះ ។ កាលក្នុងទីជិតមិនមានទឹក គប្បីចាក់ទឹកដែលជាកប្បិយ ៨ ឆ្នាំង ឬ ១០ ឆ្នាំងចុះក្នុងប្រទេសដែលឃាំងទឹកបាន (អាងទឹក) ហើយគប្បីចាក់ចុះក្នុងទឹកជាកប្បិយដែលចាក់ទុកនោះ ។ កុំគប្បីចាក់ទឹកចុះលើថ្មដែលក្តៅដោយ

សម្គាល់ថា ទឹងហូរត្រឡប់ចុះទៅក្នុងទឹក ។ តែទឹងស្រោចឱ្យថ្មត្រជាក់ដោយទឹកដែលជាកប្បិយ គួរ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយស្រួលយល់ទាំងអស់ទុំះឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។ តែក្នុងសិក្ខាបទនេះ បណ្ឌិតគប្បីជ្រាបថា ជាបណ្ណត្តិវជ្ជៈ ព្រោះភិក្ខុសូម្បីដឹងថា ទឹកមានសត្វហើយបរិភោគដោយសម្គាល់ថា ជាទឹក ដូចក្នុងការដែលសូម្បីដឹងថា កណ្តាបទិងសត្វតូចទឹងធ្លាក់ចុះទៅហើយ អុជប្រទីបដោយចិត្តបរិសុទ្ធិ ដូច្នោះឯង ។

សប្បាណកសិក្ខាបទវណ្ណនា ចប់

# ៣. ឧក្កោដនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

## ការសើរើអធិករណ៍ដែលធ្វើសម្រេចហើយតាមធម៌

[២៥៧] បទថា ឧក្កោដេន្តិ : សើរើ មានសេចក្តីថា ពួកឆព្វគ្គិយភិក្ខុទៅកាន់លំនៅរបស់ភិក្ខុនោះ ៗហើយ និយាយពាក្យកិចកុចទៅមកមានជាដើមថា កម្មមិនជាការធ្វើ គឺ មិនឱ្យការអេះអាងដោយភាពជារឿងគួរអេះអាង ។

បទថា យថាធម្មំ : តាមធម៌ហើយ មានសេចក្តីថា ដោយធម៌ដែលព្រះមានព្រះភាគត្រាស់ហើយ ដើម្បីជាគ្រឿងរម្ងាប់អធិករណ៍ណាហ្នុំ ។

បទថា និហតាធិករណំ : អធិករណ៍ដែលសង្ឃរម្ងាប់ គឺអធិករណ៍ដែលសង្ឃវិនិច្ឆ័យហើយ, អធិប្បាយថា អធិករណ៍ដែលរម្ងាប់ហើយដោយធម៌ ដែលព្រះសាស្តាត្រាស់ហើយនុ៎ះឯង ។

[២៦០] ពីរបទថា ធម្មកម្មេ ធម្មកម្មសញ្ញី : កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ មានសេចក្តីថា អធិករណ៍នោះសង្ឃរម្ងាប់ហើយដោយកម្មណា, បើកម្មនោះជាកម្មប្រកបដោយធម៌, សូម្បីភិក្ខុនេះក៏ជាអ្នកមានសេចក្តីសម្គាល់ក្នុងកម្មដែលជាធម៌

នោះថា ជាកម្មប្រកបដោយធម៌ បើសើររើអធិករណ៍នោះ ត្រូវអាបត្តិបាចិត្តិយ ។ សូម្បីបទដែលនៅសល់ បណ្ឌិតគប្បីជ្រាបដោយន័យនេះ ។ នេះជាសេចក្តីសង្ខេបក្នុងសិក្ខាបទនេះ ។ ចំណែកសេចក្តីពិស្តារព្រះមានព្រះភាគត្រាស់ទុកក្នុងគម្ពីរបរិវារៈ ដោយន័យមានជាដើមថា "អធិករណ៍ ៤ យ៉ាងនេះ មានការសើររើ គឺ ហាមឃាត់ប៉ុន្មានយ៉ាង ?"[១] ដូច្នេះ ។

ព្រះអដ្ឋកថាចារ្យនាំពាក្យដែលត្រាស់ទុកក្នុងគម្ពីរបរិវារនោះទាំងអស់មក ហើយពណ៌នាអត្ថនៃពាក្យនោះឯង ទុកក្នុងអដ្ឋកថាទាំងឡាយ តែពួកយើងនឹងពណ៌នាពាក្យនោះ ក្នុងគម្ពីរបរិវារៈនុ៎ះឯង ។ ព្រោះកាលយើងនឹងនាំមកពណ៌នាក្នុងសិក្ខាបទនេះ នឹងគប្បីឱ្យស្មុកស្មាញខ្លាំងឡើង; ដូច្នោះ ពួកយើងទើបមិនបានពណ៌នាពាក្យនោះ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម ជាទុក្ខវេទនា ដូច្នេះឯង ។

ឧក្កោដនសិក្ខាបទវណ្ណនា ចប់

១. វិន. បរិ. អធិករណភេទ. ១៣. ១២៩/១៤១ ។

# ៤. ទុដ្ឋុល្លសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

## ពន្យល់អំពីការបិទបាំងអាបត្តិអាក្រក់

[២៦៣] ក្នុងពាក្យថា ទុដ្ឋុល្លា នាម អាបត្តិ : ដែលហៅថាអាបត្តិអាក្រក់ នេះ ព្រះមានព្រះភាគទ្រង់សម្ដែងបារាជិក ៤ ទុក ដោយអំណាចនៃការទ្រង់ពន្យល់សេចក្ដី, តែទ្រង់ប្រាថ្នាអាបត្តិសង្ឃាទិសេស ។ កាលភិក្ខុបិទបាំងអាបត្តិសង្ឃាទិសេសនោះ ជាបាចិត្តិយ ។

ពីរបទថា ធុរំ និក្ខិត្តមត្តេ : គ្រាន់តែដាក់ធុរៈចុះ គឺ កាលត្រឹមតែថា ដាក់ធុរៈសម្រេច ។ ប្រសិនបើថា ដាក់ធុរៈហើយ ប្រាប់ក្នុងខាងក្រោយ, រក្សាមិនបាន ។ មានពាក្យអធិប្បាយថា ល្មមដាក់ធុរៈសម្រេចប៉ុណ្ណោះ ក៏ជាបាចិត្តិយ ។ តែបើថា ភិក្ខុដាក់ធុរៈហើយយ៉ាងនោះ ប្រាប់ដល់ភិក្ខុដទៃដើម្បីបិទបាំងទុកនូវឯង, សូម្បីភិក្ខុដែលទទួលប្រាប់នោះហ្នឹងក៏ប្រាប់ដល់ភិក្ខុដទៃដោយឧបាយដូចពោលមកនេះ សមណៈតាំងរយក្ដី សមណៈតាំងពាន់ក្ដី រមែងត្រូវអាបត្តិទាំងនោះដរាបប៉ុនទីបំផុតមិនទាន់ដាច់ចុះ ។

សួរថា ទីបំផុតនឹងដាច់កាលណា ?

ឆ្លើយថា លោកមហាសុមត្ថេរពោលទុកមុនថា ភិក្ខុត្រូវអាបត្តិ

ហើយប្រាប់ដល់ភិក្ខុមួយរូប, ភិក្ខុដែលទទួលប្រាប់នោះ ត្រឡប់មកប្រាប់ ដល់លោកអ្នកត្រូវអាបត្តិនោះទៀត, ទីបំផុត រមែងដាច់ចុះយ៉ាងនេះ ។ ឯព្រះមហាបទុមថេរៈពោលថា ព្រោះថា ភិក្ខុនេះជាវត្ថុបុគ្គលតែម្នង (បុគ្គលដែលត្រូវអាបត្តិ), តែត្រូវអាបត្តិហើយក៏ប្រាប់ដល់ភិក្ខុមួយរូប, ភិក្ខុទី២ នេះក៏ប្រាប់ដល់ភិក្ខុតទៅ, ភិក្ខុទី៣ នោះត្រឡប់មក ប្រាប់រឿង ដែលភិក្ខុទី២ ប្រាប់លោកដល់ភិក្ខុទី២ នោះឯង, កាលបុគ្គលទី៣ ត្រឡប់ មកប្រាប់ដល់បុគ្គលទី២ យ៉ាងនេះ ទីបំផុត រមែងដាច់ចុះហើយ ។

[២៦៤] ពីរបទថា អទុដ្ឋុល្លំ អាបត្តិំ : **អាបត្តិមិនអាក្រក់** បាន ដល់ អាបត្តិ ៥ កង ដែលនៅសល់ ។

អជ្ឈាចារ្យនេះ គឺ សុក្កវិស្សដ្ឋិ និងកាយសំសគ្គៈ ឈ្មោះថា អជ្ឈាចារ្យដែលអាក្រក់សម្រាប់អនុបសម្បន្ន ក្នុងពាក្យថា អនុបសម្បន្នស្ស ទុដ្ឋុល្លំ វា អទុដ្ឋុល្លំ វា អជ្ឈាចារំ : **ភិក្ខុបិទបាំងសេចក្តីប្រព្រឹត្ត ល្មើសអាក្រក់ក្តី មិនអាក្រក់ក្តី** នេះ ។ បទដែលនៅសល់ងាយយល់ទាំង អស់នោះឯង ។

សិក្ខាបទនេះ ក៏ការដាក់ធុរៈជាសមុដ្ឋាន កើតឡើងមកកាយវាចា ចិត្ត ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ទុដ្ឋុល្លសិក្ខាបទវណ្ណនា ចប់

# ៥. ឱនវីសតិវស្សសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងបឋមបញ្ញត្តិ

[២៦៦] ពាក្យថា អង្គុលិយោ ទុក្ខា ភវិស្សន្តិ : ម្រាមដៃនឹងរួយ មានសេចក្ដីថា មាតាបិតារបស់ក្មេងប្រុសឧបាលីគិតថា កាលឧបាលីសរសេរសំបុត្រ ម្រាមដៃនឹងចុករួយ ។

ពីរបទថា ឧរស្ស ទុក្ខោ : លំបាកដល់ទ្រូង មានសេចក្ដីថា មាតាបិតារបស់ឧបាលីសម្គាល់ថា កាលឧបាលីរៀនវិជ្ជាគណនា ចាំបាច់នឹងត្រូវគិតសូម្បីច្រើន; ព្រោះហេតុនោះ គេនឹងតឹងទ្រូង ។

ពីរបទថា អក្ខីនិស្ស ទុក្ខានិ : ភ្នែកលំបាក មានសេចក្ដីថា មាតាបិតារបស់ ឧបាលីសម្គាល់ថា ឧបាលីកាលរៀនតម្រាមើលរូបភាព ចាំបាច់ត្រូវត្រឡប់ទៅត្រឡប់មកមើលហិរញ្ញកហាបណៈ; ព្រោះហេតុនោះ នេត្រាទាំង ២ របស់គេនឹងស្រវាំង ។ ក្នុងបទថា ឌំសៈ ជាដើមពួកសត្វល្អិតពណ៌លឿង ឈ្មោះថា ឌំសៈ ( របោម ) ។

[២៦៨] បទថា ទុក្ខានំ : ទុក្ខ គឺ អត់ធន់បានលំបាក ។

បទថា តិព្វានំ : ដ៏ក្លៀវក្លា គឺ ដ៏ច្រើន ។

បទថា ខរានំ : រឹង គឺ ដ៏ខ្លាំងក្លា ។

បទថា កដុកានំ : អាក្រក់ បានដល់ ក្តៅក្រហាយ ។ មួយទៀត សេចក្តីថា ដូចទឹកសេហ៊ី ព្រោះមិនជាទីចម្រើនចិត្ត ។

បទថា អសាតានំ : មិនស្រួល បានដល់ មិនជាទីត្រេកអរ ។

បទថា បាណហរានំ : ជាទីនាំបង់នូវជីវិតដែលកើតឡើងហើយ គឺ អាចបំផ្លាញជីវិតបាន ។

[២៦៩] ពីរបទថា សីមំ វា សម្ភេទតិ : សន្ទូតសីមាក្តី បានដល់ ចងសីមាថ្មី ។ តែក្នុងកុរុន្ទីលោកពិន័យជាទុក្កដ សូម្បីក្នុងការកំណត់ក្បាលទឹកបាច ។

[២៧០] បទថា បរិបុណ្ណវីសតិវស្សេ[១] : កុលបុត្រមានវស្សាគ្រប់ ២០ បានដល់ អ្នកមានអាយុគ្រប់ ២០ ឆ្នាំ បរិបូណ៌រាប់ពីចុះចាប់បដិសន្ធិមក ។

## បុគ្គលអ្នកមានអាយុខ្វះនិងគ្រប់ ២០ ឆ្នាំ

សេចក្តីពិត សូម្បីអ្នកមានអាយុគ្រប់ ២០ ឆ្នាំ ទាំងនៅក្នុងគភ៌ ក៏ដល់ការរាប់ថា អ្នកមានអាយុគ្រប់ ២០ ឆ្នាំដូចគ្នា ។ ដូចយ៉ាងដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា "សម័យនោះឯង ព្រះកុមារកស្សបដ៏មានអាយុ មានឆ្នាំ២០ ដោយរាប់យកឆ្នាំតាំងពីនៅក្នុងគភ៌ផង បានឧបសម្បទា ។

---

១. ថៃ. បរិបុណ្ណវីសតិវស្សោ ។

ទើបកុមារកស្សបដ៏មានអាយុ មានសេចក្តីត្រិះរិះថា ព្រះមានព្រះភាគបញ្ញត្តិហើយថា ភិក្ខុមិនត្រូវឱ្យឧបសម្បទាដល់បុគ្គលមានអាយុមិនទាន់គ្រប់២០ឆ្នាំ ដូច្នេះ ក៏អាត្មាអញមានឆ្នាំ២០ រាប់ទាំងឆ្នាំដែលនៅក្នុងគភ៌ផង បានឧបសម្បទា, អាត្មាអញជាឧបសម្បន្ន ឬមិនបានជាអនុបសម្បន្នទេ”[១] ។

ពួកភិក្ខុបានក្រាបទូលរឿងនោះ ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ចិត្តជាបឋមណា កើតឡើងហើយ វិញ្ញាណជាបឋមណា កើតប្រាកដហើយ ក្នុងផ្ទៃនៃមាតា កំណើតរបស់សត្វនោះឯង ត្រូវរាប់អំពីបឋមចិត្តនោះ ឬបឋមវិញ្ញាណនោះ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុឱ្យឧបសម្បទា ដល់កុលបុត្រមានអាយុ ២០ ឆ្នាំ រាប់ទាំងឆ្នាំដែលនៅក្នុងផ្ទៃ”[២] ។

ក្នុងពាក្យថា អនុជានាមិ ភិក្ខវេ គព្ភវីសំ ឧបសម្បាទេតុំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុឱ្យឧបសម្បទា ដល់កុលបុត្រមានឆ្នាំ ២០ រាប់ទាំងឆ្នាំដែលនៅក្នុងផ្ទៃ នោះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

អ្នកណានៅក្នុងផ្ទៃរបស់មាតាដល់ ១២ ខែកើត (ប្រសូត)ក្នុងថ្ងៃមហាបវារណា, តាំងពីថ្ងៃមហាបវារណានោះទៅ ដរាបដល់ថ្ងៃមហា

---

១. វិន. មហា. មហាខន្ធកៈ. ៦. ១៤១/៣០៥ ។ ២. វិន. មហា. មហាខន្ធក. ៦. ១៤១/៣០៦ ។

បវារណាក្នុងឆ្នាំទី ១៩ គប្បីឱ្យអ្នកនោះឧបសម្បទាក្នុងថ្ងៃបាដិបទ (១ រោច) ហួសថ្ងៃមហាបវារណានោះទៅ ។ គប្បីជ្រាបការថយចុះ និងបន្ថែមឡើងដោយឧបាយនោះ ។

តែពួកព្រះថេរៈគ្រាមុនឱ្យសាមណេរអាយុ ១៩ ឆ្នាំឧបសម្បទាក្នុងថ្ងៃបាដិបទ (ថ្ងៃ ១ រោច) ហួសថ្ងៃពេញបូណ៌មីខែ ៩ ទៅ ។

សួរថា ការឧបសម្បទានោះមានបាន ព្រោះហេតុអ្វី ?

ខ្ញុំនឹងពោលឆ្លើយ ក្នុងឆ្នាំមួយ មានចាតុទ្ទសីឧបោសថ (ឧបោសថថ្ងៃ១៤) ៦ ថ្ងៃ, ព្រោះដូច្នោះ ក្នុង២០ ឆ្នាំ នឹងមានខែបាត់អស់ ៤ ខែ, ស្តេចគ្រប់គ្រងព្រះនគរ នឹងបង្ខិតកាលភ្លៀងចេញទៅគ្រប់ ៗ ៣ ឆ្នាំ (បន្ថែមអធិកមាស ៣ ឆ្នាំម្តង), ដូច្នោះ ក្នុង១៨ ឆ្នាំ នឹងបន្ថែម ៦ ខែ (បន្ថែមអធិកមាស ៦ ខែ) ។ ដក ៤ ខែដែលបាត់ទៅដោយអំណាចឧបោសថ (មកដក) ចេញអំពី ៦ ខែដែលបន្ថែមចូលមកក្នុង១៨ ឆ្នាំនោះ នៅសល់ ២ ខែ ។ យក ២ ខែនោះមកបន្ថែម (២ខែ+១០ខែ=១ឆ្នាំ +១៩ឆ្នាំ) ទើបជា ២០ ឆ្នាំបរិបូណ៌ដោយប្រការយ៉ាងនេះ ព្រះថេរៈទាំងឡាយ ទើបអស់សេចក្តីសង្ស័យឧបសម្បទាឱ្យ (សាមណេរអាយុ ១៩ ឆ្នាំ) ក្នុងថ្ងៃបាដិបទហួសថ្ងៃពេញបូណ៌មីខែ ៩ ទៅ ។

ក៏ក្នុងពាក្យថា សាមណេរមានអាយុ ១៩ ឆ្នាំ ជាដើមនេះ លោកពោលពាក្យថា មានអាយុ ១៩ ឆ្នាំ សំដៅយកសាមណេរដែលបវារណា

ហើយ ទើងមានអាយុគ្រប់ ២០ ឆ្នាំ ។ ព្រោះដូច្នោះ អ្នកដែលនៅក្នុងផ្ទៃមាតាដល់ ១២ ខែ ទើងជាអ្នកមានអាយុគ្រប់ ២១ ឆ្នាំ ។ អ្នកដែលនៅ (ក្នុងផ្ទៃមាតា) ៧ ខែ ទើងជាអ្នកមានអាយុ ២០ ឆ្នាំ ទើង ៧ ខែ ។ តែអ្នក(នៅក្នុងផ្ទៃមាតា) ៦ ខែប្រសូត ទើងមិនរួច ។

[២៧០] ក្នុងពាក្យថា អនាបត្តិ ឩនវីសតិវស្សំ បុគ្គលំ បរិបុណ្ណសញ្ញី : ភាវៈដែលមិនត្រូវអាបត្តិ គឺ ភិក្ខុសំគាល់បុគ្គលដែលមានវស្សាមិនទាន់គ្រប់ ២០ ថា មានវស្សាគ្រប់ ២០ នេះ មានវិនិច្ឆ័យថា មិនជាអាបត្តិដល់ឧបជ្ឈាយ៍ដែលឱ្យឧបសម្បទាសូម្បីដោយពិត ។ ទោះជាយ៉ាងនេះបុគ្គលក៏មិនឈ្មោះថា ឧបសម្បទាឡើយ ។ តែបើបុគ្គលនោះ ឱ្យអ្នកដទៃឧបសម្បទាដោយកន្លងទៅ ១០ វស្សា, បើថាវៀរបុគ្គលនោះចេញគណៈគ្រប់, បុគ្គលអ្នកនោះឈ្មោះថា ឧបសម្បទាល្អហើយ ។ និងសូម្បីបុគ្គលមិនមែនឧបសម្បន្ននោះ មិនទាន់ដឹងត្រឹមណា មិនទាន់ជាអន្តរាយចំពោះសួគ, មិនជាអន្តរាយចំពោះព្រះនិព្វានដល់គេត្រឹមនោះ ។ តែកាលដឹងហើយ គប្បីឧបសម្បទាថ្មី ។ បទដែលនៅសល់ ងាយយល់ទាំងអស់ឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

ឩនវីសតិវស្សសិក្ខាបទវណ្ណនា ចប់

# ៦. ថេយ្យសត្ថសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

## ការធ្វើដំណើររួមពួកឈ្មួញរទេះអ្នកជាចោរ

[២៧២] បទថា បដិយាលោកំ : ប្រទេសឈ្មោះ បដិយាលោក សេចក្តីថា ត្រង់មុខពន្លឺព្រះអាទិត្យ គឺ ទិសខាងលិច ។

បទថា កម្មិកា : ពួកអ្នកធ្វើការគយ បានដល់ អ្នកធ្វើការងារនៅទីស្នាក់ការគយ ។

[២៧៣] ពាក្យថា រាជានំ វា ថេយ្យំ គច្ឆន្តិ : ដល់នូវកិរិយាលួច(របស់) ស្តេចក្តី មានសេចក្តីថា ពួកចោរលួចរបស់ស្តេច គឺលបលួចយករបស់ស្តេចយ៉ាងណាមួយទៅ ដោយតាំងចិត្តថា គ្រានេះយើងនឹងមិនថ្វាយស្តេច ។

[២៧៥] បទថា វិសង្កេតេន : ដោយខុសសង្កេត មានសេចក្តីថា មិនជាអាបត្តិដល់ភិក្ខុដែលទៅខុសវេលាណាត់កំណត់ និងខុសថ្ងៃណាត់កំណត់ ។ តែទៅខុសមកដែលណាត់កំណត់ ឬខុសដូចទីណាត់ជាអាបត្តិដូចគ្នា ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ព្រោះមានន័យដូចពោលហើយក្នុងភិក្ខុនីវគ្គ ។

សិក្ខាបទនេះ មានពួកឈ្មួញរទេះចោរជាសមុដ្ឋាន កើតឡើងមក

កាយចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ថេយ្យសត្ថសិក្ខាបទវណ្ណនា ចប់

# ៧. សំវិធានសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[២៧៦] ពីរបទថា បច្ចុបេន្តោ និសីទិ : ទ្រមគ្រាំគ្រាអង្គុយ មានសេចក្តីថា ភិក្ខុនោះអង្គុយសំកុក គឺតិះដៀលខ្លួនឯងនៅ ។

ពាក្យថា ឆាយ្យ[១] សោ ភិក្ខុ មំ និប្បាទេសិ : នែអ្នក ភិក្ខុនោះមិនមែនបបួលណែនាំខ្ញុំមកទេ មានសេចក្តីថា នែនាយ ភិក្ខុនេះមិនបានឱ្យខ្ញុំចេញទៅ គឺ មិនបាននាំខ្ញុំទៅ ។ ពាក្យដែលនៅសល់ ក្នុងសិក្ខាបទនេះព្រមទាំងសមុដ្ឋានជាដើម បណ្ឌិតគប្បីជ្រាបដោយន័យ ដូចពោលហើយក្នុងសិក្ខាបទពោលពីការបបួលធ្វើដំណើររួមគ្នានឹងនាងភិក្ខុនីនុ៎ះឯង ។

សំវិធានសិក្ខាបទវណ្ណនា ចប់

១. ថៃ. នាយ្យោ ។

# ៨. អរិដ្ឋសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

[២៨០] ពួកជនដែលឈ្មោះថា ព្រានត្មាត ព្រោះអត្ថថា បានសម្លាប់ត្មាតទាំងឡាយ ។ ភិក្ខុអរិដ្ឋៈឈ្មោះថា អ្នកធ្លាប់ជាព្រានត្មាត ព្រោះអត្ថថា លោកមានបុព្វបុរសជាព្រានត្មាត ។ បានសេចក្ដីថា ជាបុត្ររបស់ត្រកូលធ្លាប់ជាព្រានត្មាត គឺ កើតពីត្រកូលព្រានត្មាតនោះ ។

## ធម៌ធ្វើអន្តរាយដល់អ្នកសេព

ធម៌ពួកណា រមែងធ្វើអន្តរាយដល់សួគ៌និងនិព្វាន; ព្រោះហេតុនោះ ធម៌ទាំងនោះ ឈ្មោះថា អន្តរាយិកធម៌ ។ អន្តរាយិកធម៌ទាំងនោះមាន ៥ យ៉ាងដោយអំណាចកម្ម កិលេស វិបាក ឧបវាទ និងអាណាវីតិក្កមៈ ។ បណ្ដាអន្តរាយិកធម៌ មានកម្មជាដើមនោះ អន្តរាយិកធម៌ គឺ កម្ម ។ ភិក្ខុនីទូសកកម្ម ក៏យ៉ាងនោះ ។ តែភិក្ខុនីទូសកកម្មនោះ រមែងធ្វើអន្តរាយដល់ព្រះនិព្វានប៉ុណ្ណោះ មិនធ្វើអន្តរាយដល់សួគ៌ទេ ។ ធម៌គឺនិយតមិច្ឆាទិដ្ឋិ ឈ្មោះថា អន្តរាយិកធម៌ គឺ កិលេស ។ ធម៌ គឺបដិសន្ធិរបស់ពួកបណ្ឌកៈ តិរច្ឆាន និងឧភតោព្យញ្ជនកៈ ឈ្មោះថា អន្តរាយិកធម៌គឺ វិបាក ។ ការចូលទៅថា ការប្រទូសរ៉ាយព្រះអរិយៈ ឈ្មោះថា អន្តរាយិកធម៌ គឺ ឧបវាទៈ ។ តែឧបវាទន្តរាយិកធម៌

ទាំងនោះ ជាអន្តរាយរហូតដល់ព្រះអរិយៈទាំងឡាយ អត់ទោសប៉ុណ្ណោះ, ក្រោយអំពីឱ្យលោកអត់ទោសទៅ មិនជាអន្តរាយទេ ។ អាបត្តិដែលក្លែងត្រូវ ឈ្មោះថា អន្តរាយិកធម៌គឺ អាណាវីតិក្កមៈ ។ អាបត្តិសូម្បីពួកដទៃក៏ជាអន្តរាយរហូតដរាបដល់ភិក្ខុនោះ នៅបដិញ្ញាភាពជាភិក្ខុឬមិនទាន់ចេញ ឬមិនទាន់សម្តែងប៉ុណ្ណោះ ក្រោយពីសម្តែងតាមករណីនោះ ៗ ហើយ មិនជាអន្តរាយទេ ។

បណ្តាអន្តរាយិកធម៌តាមដែលពោលហើយនោះ ភិក្ខុនេះ ជាពហុស្សុត ជាធម្មកថិក ស្គាល់អន្តរាយិកធម៌ដែលនៅសល់បាន តែព្រោះមិនឆ្លាតក្នុងព្រះវិន័យ ទើបមិនដឹងអន្តរាយិកធម៌ គឺ ការកន្លងល្មើសព្រះបញ្ញត្តិ ។ ព្រោះដូច្នោះ លោកទៅនៅក្នុងទីកំបាំងបានគិតយ៉ាងនេះថា បុគ្គលអ្នកគ្រប់គ្រងផ្ទះទាំងនេះ នៅបរិភោគកាមគុណ ៥ ជាព្រះសោតាបន្នក៏មាន ជាព្រះសកទាគាមីក៏មាន ជាព្រះអនាគាមីក៏មាន សូម្បីភិក្ខុទាំងឡាយដែលឃើញរូបដែលពេញចិត្ត គប្បីដឹងបានមកចក្ខុ ។ល ។ រមែងពាល់ត្រូវផោដ្ឋព្វៈ ដែលគួរពេញចិត្តគប្បីដឹងបានមកកាយ បរិភោគកម្រាល និងគ្រឿងស្លៀកដណ្តប់ជាដើម សូម្បីដែលទន់ ៗសភាពនោះគួរគ្រប់យ៉ាង ព្រោះហេតុអ្វី រូបស្ត្រីទាំងឡាយ ។ល ។ ផោដ្ឋព្វៈ គឺស្ត្រីទាំងឡាយ ទើបមិនគួរយ៉ាងនេះហ្ន៎ ? សូម្បីរូបស្ត្រីជាដើមទាំងនេះក៏គួរ ។ លោកប្រៀបធៀបរសនឹងរសយ៉ាងនេះហើយ ធ្វើការបរិភោគ

កាមគុណដែលប្រព្រឹត្តទៅដោយឆន្ទរាគៈ ជាមួយនឹងការបរិភោគកាមគុណ ដែលមិនមានឆន្ទរាគៈ ឱ្យដូចគ្នាតែមួយ ញ៉ាំងទិដ្ឋិដ៏លាមកឱ្យកើតឡើង ដូចបុគ្គលតភ្ជាប់អំបោះល្អិតឆ្មារក្រៃលែង ជាមួយនឹងសរសៃធ្មៃដែលគ្រោតគ្រាត ដូចយកកូនសិណោរុធៀបនឹងគ្រាប់ស្ពៃ ដូច្នោះ ទើបទាស់ចិត្តនឹងសព្វញ្ញុតញ្ញាណថា "ហេតុដូចម្តេច ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តិបឋមបារាជិក ដោយសេចក្តីឧស្សាហ៍ច្រើន ដូចទ្រង់ការពារមហាសមុទ្រ ទោសក្នុងកាមទាំងនេះ មិនមាន" ដូច្នេះ កាត់សេចក្តីប្រាថ្នារបស់ពួកកព្វបុគ្គល បានឱ្យការប្រហារក្នុងអាណាចក្រនៃព្រះជិនស្រី ។ ព្រោះហេតុនោះ អរិដ្ឋភិក្ខុ ទើបពោលថា តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ : ខ្ញុំដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគសំដែងហើយជាដើម ។

ក្នុងពាក្យថា អដ្ឋិកង្កលូបមា : មានឧបមាដោយរាងឆ្អឹង ជាដើម មានវិនិច្ឆ័យថា កាមទាំងឡាយប្រៀប.....

ដូចគ្រោងឆ្អឹង ព្រោះអត្ថថា មានរសឆ្ងាញ់( សេចក្តីត្រេកអរ )តិច ។
ដូចដុំសាច់ ព្រោះអត្ថថា ជាកាយទូទៅដល់សត្វច្រើន ។
ដូចគប់ភ្លើងធ្វើពីស្មៅ ព្រោះអត្ថថា តាមដុតពោល ។
ដូចរណ្តៅរងើកភ្លើង ព្រោះអត្ថថា ក្តៅផ្សាក្រៃលែងណាស់ ។

ដូចអ្នកយល់សប្តិ ព្រោះអត្ថថា ប្រាកដក្នុងវេលាបន្តិចបន្តួច ។
ដូចរបស់ដែលខ្ចីគេ ព្រោះអត្ថថា ប្រព្រឹត្តទៅមួយកាលមួយគ្រា ។
ដូចផ្លែឈើ ព្រោះអត្ថថា កាត់បន្ថយអវយវៈតូចធំទាំងពួង ។
ដូចកាំបិតនិងជ្រុញ ( ចិញ្ច្រាំសាច់ )ព្រោះអត្ថថាជាទីទទួលរងការគ្រោះថ្នាក់ ។
ដូចលំពែង ( មានដៀង )និងដែកស្រួច ព្រោះអត្ថថា ចាក់ដោត ។
ដូចក្បាលពស់ ព្រោះអត្ថថា គួររង្កៀសនិងមានភ័យចំពោះមុខនោះឯង ។

នេះសេចក្តីសង្ខេបក្នុងសិក្ខាបទនេះ ។ ចំណែកសេចក្តីពិស្តារ បណ្ឌិតគប្បីមើលក្នុងបបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ ។

និបាតសមុហៈថា ឯវំ ព្យាខោ គឺ ឯវំ វិយ ខោ : ដូចដែលទ្រង់សម្តែងយ៉ាងនេះឯង ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ព្រោះមានន័យដូចពោលហើយខាងដើម ។

សិក្ខាបទនេះ មានការសូធ្យសមនុភាសនៈជាសមុដ្ឋាន កើតឡើងមកកាយវាចាចិត្ត ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

អរិដ្ឋសិក្ខាបទវណ្ណនា ចប់

# ៩. ឧក្ខិត្តសម្ភោគសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងសិក្ខាបទទី ៩

[២៨៧] បទថា អកដានុធម្មេន **: មិនបានធ្វើតាមធម៌** មានសេចក្តីថា ឱសារណា (ការហៅចូលពួក) ដែលសង្ឃឃើញវត្តដ៏សមគួរធ្វើហើយដល់ភិក្ខុដែលត្រូវសង្ឃលើកវត្ត ព្រោះការមិនឃើញអាបត្តិក្តី ព្រោះការមិនសម្តែងអាបត្តិក្តី ព្រោះការមិនលះបង់ទិដ្ឋិលាមកក្តី ដោយធម៌ ដោយវិន័យ ដោយសត្ថុសាសនៈ ព្រះមានព្រះភាគត្រាស់ហៅថា តាមធម៌ ។ តាមធម៌ ពោលគឺ ឱសារណានោះ សង្ឃមិនបានធ្វើដល់ភិក្ខុណា, ភិក្ខុនេះឈ្មោះថា អ្នកដែលសង្ឃមិនបានធ្វើតាមធម៌ ។ សេចក្តីថា (មិនទាន់បានធ្វើ) ជាមួយនឹងភិក្ខុដូច្នោះ ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា អកដានុធម្មេន នោះ ទើបត្រាស់ថា "ភិក្ខុណា ដែលសង្ឃលើកវត្តហើយ សង្ឃមិនបានហៅចូលពួកទេ ភិក្ខុនោះហៅថា មិនធ្វើតាមធម៌" ។

[២៨៨] ពីរបទថា ទេតិ វា បដិគ្គណ្ហាតិ វា **: ភិក្ខុឱ្យ(អាមិសដល់ភិក្ខុនោះ)ក្តី ទទួល(អាមិសអំពីភិក្ខុនោះ)ក្តី** មានសេចក្តីថា ភិក្ខុឱ្យក្តី ទទួលក្តី នូវអាមិស សូម្បីជាច្រើន ដោយប្រយោគតែមួយ ជា

បាចិត្តិយតែមួយ ។ កាលឱ្យនិងទទួលដាច់ ៗ ជាបាចិត្តិយច្រើន ដោយរាប់ប្រយោគ ។ បទដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឧក្ខិត្តសម្ភោគសិក្ខាបទទី ៩ ចប់

# ១០. កណ្ឌកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី១០ មានវិនិច្ឆ័យ ដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងសិក្ខាបទទី ១០

[២៩១] ពីរបទថា ទិដ្ឋិគតំ ឧប្បន្នំ : ទិដ្ឋិកើតឡើង គឺ សមណុទ្ទេសសូម្បីនេះ កាលធ្លាក់ចុះទៅ ដោយមិនមែនឧបាយនៃប្រាជ្ញា ក៏កើតសេចក្ដីឃើញខុសឡើងមក ដូចអរិដ្ឋភិក្ខុដូច្នោះ ។

នាសនៈដែលត្រាស់ទុកក្នុងពាក្យថា នាសេតុ : ឱ្យវិនាសចុះនេះ មាន ៣ យ៉ាង គឺ សំវាសនាសនៈ ១ លិង្គនាសនៈ ១ ទណ្ឌកម្មនាសនៈ ១ ។ បណ្ដានាសនៈ ៣ យ៉ាងនោះ ការលើកវត្តព្រោះការមិនឃើញអាបត្តិជាដើម ឈ្មោះថា សំវាសនាសនៈ ។ នាសនៈនេះថា សាមណេរដែលប្រទូសរ៉ាយ (នាងភិក្ខុនី) សង្ឃគប្បីឱ្យនាសនៈចេញ, "អ្នកទាំងឡាយ ចូរឱ្យមេត្តិយាភិក្ខុនីសឹកចេញ" ឈ្មោះថា លិង្គនាសនៈ ។ នាសនៈនេះថា "នៃអាវុសោកណ្ឌកៈ កាលមានថ្ងៃនេះជាដើម អ្នកឯងមិនត្រូវអាងព្រះមានព្រះភាគអង្គនោះថា ជាសាស្ដារបស់អ្នកឡើយ" ឈ្មោះថា ទណ្ឌកម្មនាសនៈ ។ ទណ្ឌកម្មនាសនៈនេះ ទ្រង់ប្រាថ្នាយកក្នុងសិក្ខាបទនេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា

“ឯវញ្ច ភិក្ខវេនាសេតព្វោ ។បេ ។ ចរ បិរេ វិនស្ស : ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ត្រូវឱ្យវិនាសយ៉ាងនេះ ។ល ។ នែមនុស្សក្រៅការ អ្នកឯងចូរចៀសចេញទៅ អ្នកចូរវិនាសទៅ” ជាដើម ។

បណ្ដាបទទាំងនោះ បទថា ចរ : អ្នកឯងចូរត្រាច់ទៅ គឺ លោកចូរជៀសចេញទៅ ។

បទថា បិរេ : នែមនុស្សក្រៅការ គឺ មនុស្សដទៃ មានសេចក្ដីថា អ្នកឯងមិនមែនពួកយើង ។

បទថា វិនស្ស : អ្នកចូរវិនាសទៅ សេចក្ដីថា អ្នកឯងចូរទៅឱ្យបាត់ គឺ ចូរទៅក្នុងទីដែលពួកយើងនឹងមិនឃើញអ្នកឯង ។

[២៩២] បទថា ឧបលាបេយ្យ : បញ្ចុះបញ្ចូល បានដល់គប្បីសង្គ្រោះ ។

បទថា ឧបដ្ឋាបេយ្យ : ឱ្យបម្រើ គឺ គប្បីឱ្យសមណុទ្ទេសនោះធ្វើការបម្រើខ្លួន ។ បទដែលនៅសល់ព្រមទាំងសមុដ្ឋានជាដើម គប្បីជ្រាបដោយន័យដូចពោលហើយក្នុងអរិដ្ឋសិក្ខាបទនោះឯង ។

កណ្ឌកសិក្ខាបទវណ្ណនា ចប់

ចំនួនសិក្ខាបទក្នុងសប្បាណវគ្គនោះ គឺ

១. សញ្ចិច្ចបាណសិក្ខាបទ ការក្លែងសម្លាប់សត្វ

២. សប្បាណកសិក្ខាបទ ការបរិភោគទឹកមានសត្វ

៣. ឧក្កោដនសិក្ខាបទ ការសើររើអធិករណ៍

៤. ទុដ្ឋុល្លសិក្ខាបទ ការបិទអាបត្តិអាក្រក់

៥. ឩនវីសតិវស្សសិក្ខាបទ ការឧបសម្បទាកុលបុត្រ មានអាយុមិនគ្រប់ ២០ ឆ្នាំ

៦. ថេយ្យសត្ថសិក្ខាបទ ការធ្វើដំណើររួមនឹងឈ្មួញចោរ

៧. សំវិធានសិក្ខាបទ ការបបួលមាតុគ្រាមធ្វើដំណើរ តាមមកជាមួយគ្នា

៨. អរិដ្ឋសិក្ខាបទ អរិដ្ឋភិក្ខុមានទិដ្ឋិអាក្រក់

៩. ឧក្ខិត្តសម្ភោគសិក្ខាបទ ការសេពគប់ជាមួយនឹងភិក្ខុដែលត្រូវសង្ឃលើកវត្ត

១០. កណ្ឌកសិក្ខាបទ ការបញ្ចុះបញ្ចូលជាដើមនូវសមណុទ្ទេសឈ្មោះកណ្ឌកៈ

អដ្ឋកថា សប្បាណវគ្គទី ៧ ចប់ ។

# ៨. សហធម្មិកវគ្គ

## ១. សហធម្មិកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃសហធម្មិកវគ្គ ដូចតទៅនេះ ៖

### ពន្យល់អត្ថក្នុងសិក្ខាបទទី ១

[២៩៨] ពីរបទថា ឯតស្មឹ សិក្ខាបទេ **:** **សិក្ខាបទនេះ** មានសេចក្ដីថា ខ្ញុំនឹងមិនទាន់សិក្សាពាក្យដែលព្រះមានព្រះភាគត្រាស់ទុកក្នុងសិក្ខាបទនេះមុន ។

[៣០០] ក៏ក្នុងពាក្យថា អាបត្តិ បាចិត្តិយស្ស **:** **ត្រូវអាបត្តិបាចិត្តិយ** នេះ បណ្ឌិតគប្បីជ្រាបថា ជាអាបត្តិគ្រប់ ៗម៉ាត់ ៗ

ពាក្យថា សិក្ខមានេន ភិក្ខវេ ភិក្ខុនា **:** **ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកសិក្សា** មានសេចក្ដីថា ភិក្ខុជាអ្នកប្រាថ្នាដើម្បីសិក្សាទទួលព្រះឱវាទដោយសិរសាទុំះឯង គប្បីដឹងទូទៅ គប្បីសាកសួរ និងគប្បីពិចារណា ។

បទដែលនៅសល់ក្នុងសិក្ខាបទនេះ បណ្ឌិតគប្បីជ្រាបអំពីសេចក្ដីចំពោះបទ ដោយន័យដូចពោលហើយក្នុងទុតិយកណ្ឌកររណសិក្ខាបទទុំះ

ឯង ។ ពោលដោយវិនិច្ឆ័យ ឆាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

សហធម្មិកសិក្ខាបទវណ្ណនា ចប់

# ២. វិវណ្ណនសិក្ខាបទវណ្ណនា

ក្នុងសិក្ខាបទទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

## ពន្យល់អំពីអានិសង្សមានការរៀនវិន័យជាមូល

[៣០៣] ពីរបទថា វិនយកថំ កថេតិ : ទ្រង់សម្តែងវិនយកថា មានសេចក្តីថា ព្រះមានព្រះភាគត្រាស់កថា ដែលជាប់ទាក់ទងដោយកប្បិយៈ និងអកប្បិយ អាបត្តិ និងអនាបត្តិ សំវរៈ អសំវរៈ និងបហានៈ ដែលឈ្មោះថា វិន័យកថា ។

ពាក្យថា វិនយស្ស វណ្ណំ ភាសតិ : សម្តែងគុណនៃវិន័យ មានសេចក្តីថា ព្រះមានព្រះភាគត្រាស់ការដាក់មាតិកាដោយអំណាចនៃអាបត្តិ ៥ កង១ៈ ៧ កង១ៈ ហើយទ្រង់ពណ៌នាដោយបទភាជនៈ ដែលឈ្មោះថា សរសើរព្រះវិន័យ ។

ពាក្យថា វិនយបរិយត្តិយា វណ្ណំ ភាសតិ : ទ្រង់សម្ដែងគុណនៃការរៀនវិន័យ មានសេចក្ដីថា ព្រះមានព្រះភាគត្រាស់សរសើរ គឺពណ៌នាគុណ បានដល់ អានិសង្សមានការរៀនព្រះវិន័យ ជាមូលនៃពួកភិក្ខុដែលរៀនព្រះវិន័យ ។ អធិប្បាយថា ពិតមែន ព្រះមានព្រះភាគត្រាស់អានិសង្ស៥ អានិសង្ស៦ អានិសង្ស៧ អានិសង្ស៨ អានិសង្ស៩ អានិសង្ស១០ អានិសង្ស១១ ដែលមានការរៀនព្រះវិន័យជាមូលទាំងអស់ ដែលព្រះវិន័យធរបាន ។

សួរថា ព្រះវិន័យធរ រមែងបានអានិសង្សទាំង ៥ អ្វីខ្លះ ?

ឆ្លើយថា រមែងបានអានិសង្ស ៥ មានការគ្រប់គ្រងសីលក្ខន្ធជាដើមរបស់ខ្លួន ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកនេះថា

"បញ្ចិមេ ភិក្ខវេ អានិសំសា វិនយធរេ បុគ្គលេ ។ អត្តនោ សីលក្ខន្ធោ សុគុត្តោ ហោតិ សុរក្ខិតោ កុក្កុច្ចបកតានំ បដិសរណំ ហោតិ វិសារទោ សង្ឃមជ្ឈេ វោហរតិ បច្ចត្ថិកេ សហធម្មេន សុនិគ្គហិតំ និគ្គណ្ហាតិ សទ្ធម្មដ្ឋិតិយា បដិបន្នោ ហោតិ : ភិក្ខុអ្នកទ្រទ្រង់វិន័យ តែងបានអានិសង្ស ៥ ប្រការ គឺ សីលក្ខន្ធរបស់ខ្លួន ឈ្មោះថាភិក្ខុនោះបានគ្រប់គ្រងរក្សាដោយល្អ១ ភិក្ខុនោះ តែងជាទីពឹងនៃពួកភិក្ខុដែលមានសេចក្ដីសង្ស័យជាប្រក្រតី១ ភិក្ខុនោះ ជាអ្នកក្លៀវក្លានិយាយ

ក្នុងកណ្តាលសង្ឃ១ ភិក្ខុនោះរមែងសង្កត់សង្កិនដោយល្អនូវសត្រូវដោយសហធម៌ គឺ សិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិទុក១ ភិក្ខុនោះឈ្មោះថា ជាអ្នកបតិបត្តិ ដើម្បីញ៉ាំងព្រះសទ្ធម្មឱ្យតាំងនៅ១” ។[1]

## អធិប្បាយអានិសង្ស ៥ និងការត្រូវអាបត្តិ ៦ យ៉ាង

អត្តនោ សីលក្ខន្ធោ សុគុត្តោ ហោតិ សុរក្ខិតោ : សីលក្ខន្ធរបស់ខ្លួន ឈ្មោះថា ភិក្ខុនោះបានគ្រប់គ្រងរក្សាដោយល្អ តើយ៉ាងណា ? គឺ ភិក្ខុរបខ្លះក្នុងធម្មវិន័យនេះ កាលត្រូវអាបត្តិ រមែងត្រូវដោយអាការ៦យ៉ាង គឺ ដោយមិនមានខ្មាស១ ដោយមិនស្គាល់អាបត្តិ១ ដោយសង្ស័យហើយធ្វើបំពាន១ ដោយសម្គាល់ថា គួរ ក្នុងវត្ថុដែលមិនគួរ១ ដោយសម្គាល់ថា មិនគួរ ក្នុងវត្ថុដែលគួរ១ ដោយភ្លេចស្មារតី១ ។[2]

ភិក្ខុត្រូវអាបត្តិ ដោយមិនមានខ្មាស តើយ៉ាងណា ? គឺ ភិក្ខុដឹងថា ជាអកប្បិយ ល្មើសបំពាន ធ្វើការកន្លងល្មើស ។ សមពិតដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកនេះថា

សញ្ចិច្ច អាបត្តឹ អាបជ្ជតិ អាបត្តឹ បរិគូហតិ
អគតិគមនញ្ច គច្ឆតិ ឯទិសោ វុច្ចតិ អលជ្ជិបុគ្គលោ

១. វិន. បរិ. ឯកុត្តរិក. ១៣, ៦៩/៧៣ ។ ២. វិន. បរិ. វិសតិវារ:. ១២. ៨៨៨/៤១២ ។

បុគ្គលមានចិត្តក្លែងត្រូវអាបត្តិ រួចបិទបាំងអាបត្តិទុកក្តី លុះតាមអំណាចអគតិក្តី បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ហៅថា អលជ្ជីបុគ្គល ។ [១]

ភិក្ខុត្រូវអាបត្តិ **ដោយមិនស្គាល់អាបត្តិ** តើយ៉ាងណា ? គឺ ព្រោះថា បុគ្គលអ្នកមិនមានសេចក្តីដឹងជាអ្នកវង្វេង ជាអ្នកល្ងង់ មិនដឹងវត្ថុដែលគួរធ្វើនិងវត្ថុដែលមិនគួរធ្វើ រមែងធ្វើវត្ថុដែលមិនគួរធ្វើ ធ្វើវត្ថុដែលគួរធ្វើឱ្យខុស, ដោយអាការយ៉ាងនេះ ឈ្មោះថា ត្រូវដោយសេចក្តីមិនដឹង ។

ភិក្ខុត្រូវអាបត្តិ **ដោយសង្ស័យហើយធ្វើបំពាន** តើយ៉ាងណា ? គឺ កាលកើតសេចក្តីសង្ស័យឡើង ព្រោះអាស្រ័យរបស់ដែលគួរនិងមិនគួរ ល្មើសបំពានកន្លងល្មើសតែម្តងដោយសម្គាល់ថា សួរព្រះវិន័យធរហើយ បើជាកប្បិយ ជាវត្ថុដែលគួរធ្វើ បើជាអកប្បិយ ជាវត្ថុដែលមិនគួរធ្វើ, តែយ៉ាងនេះ សមគួរពិត ដោយអាការយ៉ាងនេះ ឈ្មោះថា ត្រូវដោយសេចក្តីសង្ស័យហើយនៅតែប្រឹងធ្វើ ។

ភិក្ខុត្រូវអាបត្តិ **ដោយសម្គាល់ថា គួរ ក្នុងវត្ថុដែលមិនគួរ** តើយ៉ាងណា ? គឺ ភិក្ខុឆាន់សាច់ខ្លាឃ្មុំ ដោយសម្គាល់ថា សាច់ជ្រូក, ឆាន់

១. វិន. បរិ. គាថាសង្គណិកជាតំណមក. ១៣. ១៥៣/១៧៣ ។

សាច់ខ្លាដំបងដោយសម្គាល់ថា សាច់ម្រឹគ, ឆាន់ភោជនដែលជាអកប្បិយដោយសម្គាល់ថា ភោជនជាកប្បិយ, ឆាន់ក្នុងវេលាវិកាលដោយសម្គាល់ថា ជាកាល, ផឹកបានៈដែលជាអកប្បិយ ដោយសម្គាល់ថា បានៈជាកប្បិយ ដោយអាការយ៉ាងនេះ ឈ្មោះថា ត្រូវដោយសេចក្ដីសម្គាល់ក្នុងវត្ថុដែលមិនគួរថា គួរ ។

ភិក្ខុត្រូវអាបត្តិ **ដោយសម្គាល់ថា មិនគួរ ក្នុងវត្ថុដែលគួរ** តើយ៉ាងណា ? គឺ ភិក្ខុឆាន់សាច់ជ្រូក ដោយសម្គាល់ថា សាច់ខ្លាឃ្មុំ, ឆាន់សាច់ម្រឹគដោយសម្គាល់ថា សាច់ខ្លាដំបង, ឆាន់ភោជនដែលជាកប្បិយដោយសម្គាល់ថា ភោជនជាអកប្បិយៈ, ឆាន់ក្នុងកាល ដោយសម្គាល់ថា ជាវិកាល, ផឹកបានៈដែលជាអកប្បិយដោយសម្គាល់ថា បានៈជាអកប្បិយ, ដោយអាការយ៉ាងនេះ ឈ្មោះថា ត្រូវដោយភាពជាអ្នកមានសេចក្ដីសម្គាល់ក្នុងវត្ថុដែលគួរថា មិនគួរ ។

ភិក្ខុត្រូវអាបត្តិ **ដោយភ្លេចស្មារតី** តើយ៉ាងណា ? គឺ ភិក្ខុកាលត្រូវអាបត្តិ ព្រោះការដេករួម ការនៅប្រាសចាកត្រៃចីវរ និងភេសជ្ជៈ នឹងចីវរកន្លងកាលវេលាជាបច្ច័យឯង ឈ្មោះថា ត្រូវដោយសេចក្ដីវង្វេងភ្លេចសតិ ។ ភិក្ខុរូបខ្លះក្នុងសាសនានេះ រមែងត្រូវអាបត្តិដោយអាការ ៦ យ៉ាងទាំងនេះ ដោយប្រការយ៉ាងនេះ ។

## អ្នកទ្រង់វិន័យមិនត្រូវអាបត្តិដោយអាការ ៦ យ៉ាង

តែព្រះវិន័យធរមិនត្រូវអាបត្តិដោយអាការ ៦ យ៉ាងទាំងនេះ ។ មិនត្រូវអាបត្តិ ដោយមានខ្មាស តើយ៉ាងណា ? គឺ ព្រោះសូម្បីកាលលោករក្សាការត្មះតិះដៀលរបស់អ្នកដទៃនេះថា "អញ្ជើញលោកដ៏ចម្រើនមើលចុះ ភិក្ខុនេះដឹងវត្ថុដែលគួរ និងមិនគួរពិត ៗ នៅតែប្រព្រឹត្តកន្លងព្រះបញ្ញត្តិ" ដូច្នេះបាន ក៏ឈ្មោះថា មិនត្រូវ, ដោយអាការយ៉ាងនេះឈ្មោះថា **លជ្ជិតាយ នាបជ្ជតិ : មិនត្រូវអាបត្តិ ដោយមានខ្មាស** ។ សម្តែងអាបត្តិជាទេសនាគាមិនីសូម្បីដែលភ្លាំងភ្លាត់ត្រូវចូល ចេញហើយអំពីអាបត្តិដែលជាវុដ្ឋានគាមិនី តាំងនៅក្នុងសេចក្តីបរិសុទ្ធ ។ ចាប់ផ្តើមតាំងពីនោះ រមែងជាអ្នកតាំងនៅក្នុងភាពជាលជ្ជីបុគ្គលនេះតែម្តងថា

**សញ្ចិច្ច អាបត្តឹ ន អាបជ្ជតិ អាបត្តឹ ន បរិគូហតិ**
**អគតិគមនញ្ច ន គច្ឆតិ ឯទិសោ វុច្ចតិ លជ្ជិបុគ្គលោ**

បុគ្គលមិនក្លែងឱ្យត្រូវអាបត្តិ មិនបានបិទបាំងអាបត្តិ មិនលុះអំណាចអគតិ, បុគ្គលយ៉ាងនេះ ដែលព្រះមានព្រះភាគ ត្រាស់ហៅថា លជ្ជីបុគ្គល[១] ។

---

១. វិន. បរិ គាថាសង្គណិកជាតំណាមក. ១៣. ១៥៤/១៧៣-៤ ។

ភិក្ខុ មិនត្រូវអាបត្តិ ព្រោះស្គាល់អាបត្តិ តើយ៉ាងណា ? គឺ ព្រោះលោកដឹងនូវវត្ថុដែលគួរនិងមិនគួរ ; ដូច្នោះ លោករមែងធ្វើតែវត្ថុដែលគួរ មិនធ្វើវត្ថុដែលមិនគួរ, ដោយអាការយ៉ាងនេះ ឈ្មោះថា **ញាណតាយ នាបជ្ជតិ** : មិនត្រូវអាបត្តិ ព្រោះស្គាល់អាបត្តិ ។

មិនត្រូវអាបត្តិ ដោយមិនសង្ស័យហើយធ្វើ តើយ៉ាងណា ? គឺ ព្រោះលោកកាលកើតសេចក្ដីខាចក្រែង ព្រោះអាស្រ័យវត្ថុដែលជាកប្បិយនិងអកប្បិយ ពិនិត្យមើលវត្ថុពិនិត្យមើលមាតិកា បទភាជនៈ អន្តរាបត្តិ អនាបត្តិ ហើយបើជាកប្បិយទើបធ្វើ, បើជាអកប្បិយមិនធ្វើ, ដោយអាការយ៉ាងនេះ ឈ្មោះថា **អកុក្កុច្ចបកតតាយ នាបជ្ជតិ** : មិនត្រូវអាបត្តិ ដោយមិនសង្ស័យហើយធ្វើ ។

មិនត្រូវអាបត្តិ ដោយសម្គាល់ក្នុងវត្ថុដែលមិនគួរជាដើម តើយ៉ាងណា ? គឺ ព្រោះលោកដឹងនូវវត្ថុដែលគួរនិងមិនគួរ; ដូច្នោះ ទើបមិនជាអ្នកមានសេចក្ដីសម្គាល់ក្នុងវត្ថុដែលមិនគួរថា គួរ មិនជាអ្នកមានសេចក្ដីសម្គាល់ក្នុងវត្ថុដែលគួរថា មិនគួរនិងលោកមានសតិតាំងមាំដោយល្អ, អធិដ្ឋានសំពត់ចីវរដែលគួរអធិដ្ឋាន, វិកប្បចីវរដែលគួរវិកប្ប ។

វិន័យធរបុគ្គល ឈ្មោះថា មិនត្រូវអាបត្តិដោយអាការ ៦ យ៉ាងនេះ ដោយប្រការយ៉ាងនេះ ។ លោកកាលមិនត្រូវ ( អាបត្តិ ) រមែងជា

អ្នកមានសីលមិនដាច់ មានសីលបរិសុទ្ធិ ។ សីលក្ខន្ធរបស់ខ្លួន ឈ្មោះថា ភិក្ខុនោះបានគ្រប់គ្រងរក្សាដោយល្អ ដោយអាការយ៉ាងនេះ ។

សួរថា វិន័យធរបុគ្គល តែងជាទីពឹងនៃពួកភិក្ខុដែលមានសេចក្តីសង្ស័យជាប្រក្រតី តើយ៉ាងណា ?

ឆ្លើយថា បានឮថា ភិក្ខុទាំងឡាយក្នុងរដ្ឋក្រៅនិងក្នុងជនបទក្រៅ កើតមានសេចក្តីសង្ស័យឡើង ជ្រាបថា បានឮថា ព្រះវិន័យធរ នៅក្នុងវិហារឯណោះ ហើយមកកាន់លំនៅរបស់លោក សូម្បីអំពីទីឆ្ងាយសួរសេចក្តីវង្វៀសសង្ស័យ ។ លោករមិលមើលវត្ថុនៃកម្មដែលភិក្ខុទាំងនោះធ្វើហើយ កំណត់ប្រភេទមានអាបត្តិ អនាបត្តិ គរុកាបត្តិ និងលហុកាបត្តិជាដើម ទើបឱ្យសម្តែងអាបត្តិដែលជាទេសនាគាមិនី ឱ្យចេញចាកអាបត្តិជាវុដ្ឋានគាមិនី ឱ្យតាំងនៅក្នុងសេចក្តីបរិសុទ្ធិ ។ ឈ្មោះថា តែងជាទីពឹងនៃពួកភិក្ខុដែលមានសេចក្តីសង្ស័យជាប្រក្រតី ដោយអាការយ៉ាងនេះ ។

ពាក្យថា វិសារទោ សង្ឃមជ្ឈេ វោហរតិ : ភិក្ខុនោះ ជាអ្នកក្លៀវក្លានិយាយក្នុងកណ្តាលសង្ឃ មានសេចក្តីថា ពិតមែន អ្នកមិនមែនវិន័យធរនិយាយក្នុងកណ្តាលសង្ឃ សេចក្តីខ្លាច គឺ អ្នករអែង រមែងគ្របសង្កត់, សេចក្តីខ្លាចនោះនឹងមិនមានដល់វិន័យធរបុគ្គល ។ ព្រោះហេតុអ្វី ? ព្រោះដឹងថា កាលនិយាយយ៉ាងនេះ មានទោស និយាយយ៉ាង

នេះមិនមានទោស ហើយទើបនិយាយ ។

ក្នុងពាក្យថា បច្ចត្ថិកេ សហធម្មេន សុនិគ្គហិតំ និគ្គណ្ហាតិ : ភិក្ខុនោះរមែងសង្កត់សង្កិនដោយល្អនូវសត្រូវដោយសហធម៌ គឺសិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តទុក នេះ ឈ្មោះថា ជនជាសត្រូវមាន ២ ពួក គឺ អ្នកជាសត្រូវដល់ខ្លួនឯងពួក ១ នាក់ ជាសត្រូវដល់ព្រះសាសនាពួក ១ ។ បណ្ដាជនអ្នកជាសត្រូវ ២ ពួកនោះ ពួកភិក្ខុឈ្មោះមេត្តិយៈ និងភុម្មជកៈ នឹងស្ដេចលិច្ឆវី ឈ្មោះ វឌ្ឍៈ ចោទដោយអន្ទិមវត្ថុដែលមិនមានមូល, ជនទាំងនេះ ឈ្មោះថា អ្នកជាសត្រូវដល់ខ្លួនឯង ក៏ឬជនអ្នកទ្រុស្តសីលសូម្បីពួកដទៃដែលជាអ្នកមានធម៌ដ៏លាមកទាំងអស់ ឈ្មោះថា អ្នកជាសត្រូវដល់ខ្លួនឯង ។ ចំណែកអរិដ្ឋភិក្ខុ កណ្ឌកសាមណេរ ភិក្ខុវជ្ជីបុត្រក្នុងក្រុងវេសាលី មានការឃើញវិបរិត និងពួកភិក្ខុចំណែកមហាយាននិកាយមហាសង្ឃិកៈជាដើម ដែលជាអ្នកមានលទ្ធិបរូបហារ អញ្ញាណ កង្ខា និងបរវិតរណា[1] ធ្វើការលើកតម្កើង ពោលអាងពាក្យទូន្មានមិនមែនពុទ្ធសាសនាថា ពុទ្ធសាសនា

---

១. សារត្ថទីបនី. ព្រះអរហន្តនៅមានអសុចិ ព្រះអរហន្តនៅមានសេចក្ដីមិនដឹង ព្រះអរហន្តនៅមានសេចក្ដីសង្ស័យ ព្រះអរហន្តអស់សង្ស័យព្រោះអ្នកដទៃ ។

ឈ្មោះថា អ្នកជាសត្រូវដល់សាសនា ។ វិន័យធរបុគ្គលទឹងសង្កត់សង្កិន ជនជាសត្រូវទាំងនោះ សូម្បីទាំងអស់ឱ្យស្ងប់ស្ងាត់ ដោយប្រការដែល ពួកគេមិនអាចប្រតិស្ឋានអសទ្ធម្មឡើងបាន ដោយសហធម៌ គឺ ដោយ ពាក្យជាហេតុរួមគ្នា ។

## អធិប្បាយព្រះសទ្ធម្ម ៣ យ៉ាង

ក៏ក្នុងពាក្យថា សទ្ធម្មដ្ឋិតិយា បដិបន្នោ ហោតិ : ភិក្ខុនោះ ឈ្មោះថា ជាអ្នកបតិបត្តិ ដើម្បីញុំាងព្រះសទ្ធម្មឱ្យតាំងនៅ នេះ សទ្ធម្ម មាន ៣ ដោយអំណាចនៃបរិយត្តិ បដិបត្តិ និងអធិគម ។ បណ្ដាសទ្ធម្ម ទាំង ៣ នោះពុទ្ធវចន គឺ បិដក ៣ ឈ្មោះថា បរិយត្តិសទ្ធម្ម ។ ធម៌ នេះ គឺ ធុតង្គគុណ ១៣ ខន្ធកវត្ត ១៤ មហាវត្ត ៨២ ឈ្មោះថា បដិបត្តិសទ្ធម្ម ។ មគ្គ ៤ ផល ៤ នេះឈ្មោះថា អធិគមសទ្ធម្ម ។

បណ្ដាសទ្ធម្មមានបរិយត្តិធម៌ជាដើមនោះ ព្រះថេរៈទាំងឡាយ ពួក ខ្លះពោលថា បរិយត្តិជាឫសគល់របស់សាសនា ដោយព្រះសូត្រនេះថា "ម្នាលអានន្ទ ធម៌ណាក្ដី វិន័យណាក្ដី ដែលតថាគតសម្ដែងហើយ បញ្ញត្តិហើយ ដល់អ្នកទាំងឡាយ, លុះអំណើះតអំពីតថាគតទៅ ធម៌និង វិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ"[១] ដូច្នេះ ។

១. ទីឃ. មហា. មហាបរិនិព្វានសូត្រ. ១៦. ១៤១/៣២១ ។

ព្រះថេរៈពួកខ្លះពោលថា បដិបត្តិជាមូលរបស់សាសនា ដោយសូត្រនេះថា “ម្នាលសុភទ្ទៈ មួយទៀត ភិក្ខុទាំងនេះ គប្បីនៅដោយប្រពៃ, លោកនឹងមិនបានសូន្យចាកពួកអរហន្តឡើយ”[១] ហើយពោលថា ភិក្ខុទាំងឡាយ ៥ រូប អ្នកបដិបត្តិដោយប្រពៃនៅមាននៅត្រឹមណា, សាសនា ចាត់ថា តាំងនៅត្រឹមនោះ ដូច្នេះ ។

ចំណែកព្រះថេរៈមួយពួកទៀត ពោលថា កាលបរិយត្តិអន្តរធានហើយ សូម្បីបុគ្គលអ្នកបដិបត្តិល្អ ក៏មិនមានការសម្រេចធម៌ ហើយពោលថា ប្រសិនបើថា ភិក្ខុ ៥ រូបនឹងជាអ្នករក្សាបារាជិកទុកបាន, ភិក្ខុទាំងនោះឱ្យកុលបុត្រទាំងឡាយ អ្នកមានសទ្ធាបព្វជ្ជាហើយឱ្យឧបសម្បទាសូម្បីក្នុងបច្ចន្តប្រទេស, ឱ្យគ្រប់គណៈទសវគ្គ ហើយនឹងធ្វើការឧបសម្បទា សូម្បីក្នុងមជ្ឈិមប្រទេស, ឱ្យភិក្ខុសង្ឃគ្រប់វីសតិវគ្គហើយនឹងធ្វើអព្ភានកម្មសូម្បីដើម្បីខ្លួន ញ៉ាំងសាសនាឱ្យដល់សេចក្តីរីកចម្រើនល្អបរិបូណ៌ដោយឧបាយយ៉ាងនេះ ។

ព្រះវិន័យធរនេះ ជាអ្នកបដិបត្តិដើម្បីសេចក្តីតាំងមាំនៃព្រះសទ្ធម្មទាំង ៣ ដោយប្រការយ៉ាងនេះឯង ។ បណ្ឌិតគប្បីជ្រាបថា ព្រះវិន័យធរនេះ រមែងបានអានិសង្ស ៥ យ៉ាងទាំងនេះ ដោយប្រការដូច្នេះ ។

---
១. ទីឃ. មហា. ១០. ១៣៩/៣១៧ ។

សួរថា ព្រះវិន័យធរ រមែងបានអានិសង្ស ៦ ពួកណា ?

ឆ្លើយថា ឧបោសថ បវារណា សង្ឃកម្ម បព្វជា ឧបសម្បទាជានាទីរបស់ព្រះវិន័យធរនោះ លោករមែងឱ្យនិស្ស័យ ឱ្យសាមណេរឧបដ្ឋាក ។

ពិតមែន ឧបោសថ ៩ ទាំងនេះ គឺ ចាតុទ្ទសីឧបោសថ បណ្ណរសីឧបោសថ សាមគ្គីឧបោសថ សង្ឃឧបោសថ គណឧបោសថ បុគ្គលឧបោសថ សុត្តុទ្ទេសឧបោសថបារិសុទ្ធិឧបោសថ អធិដ្ឋានឧបោសថទាំងអស់នោះ ជាប់ដោយព្រះវិន័យធរ ។ និងសូម្បីបវារណា ៩ ទាំងនេះគឺ ចាតុទ្ទសីបវារណា បណ្ណរសីបវារណា សាមគ្គីបវារណា សង្ឃបវារណា គណៈបវារណា បុគ្គលបវារណា តេវាចិកាបវារណា ទ្វេវាចិកាបវារណា សមានវស្សិកាបវារណា ក៏ជាប់ដោយព្រះវិន័យធរ លោកជាធំនៃបវារណា ៩ នោះ ព្រោះជានាទីរបស់លោក ដោយប្រការដូច្នេះ ដល់សង្ឃកម្មទាំង ៤ នេះគឺ អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្មក្តី ទាំងបព្វជា និងឧបសម្បទានៃកុលបុត្រទាំងឡាយ ដែលលោកជាឧបជ្ឈាយ៍ធ្វើនេះក្តី ក៏ជាប់ដោយព្រះវិន័យធរទាំងនោះ ។ អ្នកដទៃទោះជាទ្រទ្រង់បិដក ២ ក៏មិនបានដើម្បីធ្វើកម្មនេះឡើយ លោកបុណ្ណោះឱ្យនិស្ស័យ មិនបានដើម្បីឱ្យសាមណេរឧបដ្ឋាក

ឡើយ ។ តែកាលប្រាថ្នាចំពោះការឧបដ្ឋាករបស់សាមណេរ រមែងបានដើម្បីឱ្យកាន់ឧបជ្ឈាយ៍ ក្នុងលំនៅរបស់ព្រះវិន័យធរ ជាមុនហើយ ទើបត្រេកអរនឹងវត្តបដិបត្តិ ។

ក៏បណ្តាសង្ឃកម្មមានឧបោសថកម្មជាដើមនេះ ការឱ្យនិស្ស័យ និងការឱ្យសាមណេរឧបដ្ឋាកជាអង្គតែមួយ ។ អានិសង្ស ៥ យ៉ាងនោះឯង រួមនឹងអានិសង្សមួយក្នុងអានិសង្ស ៦ ទាំងនេះ ទើបជា ៦ ដោយប្រការដូច្នេះ ។ រួមនឹងអានិសង្ស២ ទើបជា ៧, រួមនឹងអានិសង្ស ៣ ទើបជា ៨, រួមនឹងអានិសង្ស ៤ ទើបជា ៩ រួមនឹងអានិសង្ស ៥ ទើបជា ១០, រួមនឹងអានិសង្សទាំងអស់នោះ ទើបជា ១១, ដោយប្រការដូចពោលមកនេះ បុគ្គលអ្នកទ្រទ្រង់វិន័យ បណ្ឌិតគប្បីជ្រាបថា រមែងបានអានិសង្ស ៥-៦-៧-៨-៩-១០ និង ១១ យ៉ាងនេះ ។

## គោលបំណងក្នុងការសរសើរវិន័យបរិយត្តិ

ព្រះមានព្រះភាគកាលទ្រង់សម្តែងអានិសង្សទាំងនេះ យ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា ទ្រង់ពណ៌នាគុណនៃការរៀនព្រះវិន័យ ។

ពីរបទថា អាធិស្ស អាធិស្ស : ទ្រង់កាន់យក ៗ បានដល់ ទ្រង់កំណត់រឿយ ៗ គឺ ទ្រង់ធ្វើឱ្យជាផ្នែកមួយផ្សេងដទៃ ។

ច្រើនបទថា អាយស្មតោ ឧបាលិស្ស វណ្ណំ ភាសតិ ៖ ទ្រង់សម្តែងគុណរបស់ព្រះឧបាលីដ៏មានអាយុ មានសេចក្តីថា ព្រះមានព្រះភាគទ្រង់អាស្រ័យវិន័យបរិយត្តិ ត្រាស់សរសើរគុណនៃព្រះឧបាលី ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ទ្រង់សរសើរព្រោះហេតុថា ធ្វើដូចម្តេចហ្ន៎ ភិក្ខុទាំងឡាយ សូម្បីបានស្តាប់ការសរសើររបស់យើងហើយ នឹងគប្បីសម្គាល់វិន័យថា ខ្លួនគួររៀនគួរសិក្សាក្នុងសំណាក់នៃឧបាលី សាសនានេះនឹងតាំងនៅបានយូរ នឹងប្រព្រឹត្តទៅរហូតដល់អស់ ៥,០០០ ឆ្នាំដោយប្រការយ៉ាងនេះ ។

ក្នុងពាក្យថា តេ ច[1] ពហូ ភិក្ខូ ៖ ទើបភិក្ខុទាំងឡាយនោះ (ជាថេរៈ)ខ្លះ ច្រើនរូប នេះ មានសេចក្តីយ៉ាងនេះថា ភិក្ខុជាច្រើននោះ ជាថេរៈក៏មាន ជានវកៈក៏មាន ជាមជ្ឈិមៈក៏មាន បានស្តាប់ការសរសើររបស់ព្រះមានព្រះភាគនេះហើយ កើតមានឧស្សាហ៍ ព្រោះបានសម្រេចអានិសង្ស តាមដែលព្រះអង្គទ្រង់ប្រកាសទុក ដោយយល់ថា បានឮថា ភិក្ខុដែលទ្រទ្រង់វិន័យ រមែងបានអានិសង្សទាំងនេះ ភិក្ខុទាំងឡាយអ្នកទ្រទ្រង់សុត្តន្តៈ និងអ្នកទ្រទ្រង់អភិធម្មមិនបានទេ ទើបនាំគ្នារៀនព្រះ

១. ថៃ. តេធ ។

វិន័យក្នុងសំណាក់របស់ព្រះឧបាលី ។

បទថា ៩៨ ត្រឹមតែជានិបាតប៉ុណ្ណោះ ។

បទថា ឧទ្ទិស្សមានេ : កាលបើភិក្ខុសម្តែងឡើង បានដល់កាលអាចារ្យសម្តែងដល់អន្តេវាសិក ។ ក៏ព្រោះថា បាដិមោក្ខនោះ កាលអាចារ្យស្វាធ្យាយតាមសេចក្តីពេញចិត្តរបស់ខ្លួនក្តី អន្តេវាសិកសូមអង្វរអាចារ្យនោះឱ្យស្វាធ្យាយក្តី កាលភិក្ខុដែលទ្រទ្រង់ចាំបាដិមោក្ខនោះ កំពុងធ្វើការស្វាធ្យាយក្តី ឈ្មោះថា មានភិក្ខុលើកបាដិមោក្ខឡើងសម្តែង; ដូច្នោះព្រះមានព្រះភាគ ទើបត្រាស់បទភាជនៈថា ឧទ្ទិសន្តេ វា ឧទ្ទិសាបេន្តេ វា សជ្ឈាយំ វា ករោន្តេ : កាលបើភិក្ខុសម្តែងឡើងឯងក្តី ឱ្យគេ សម្តែងឡើងក្តី ធ្វើស្វាធ្យាយក្តី ដូច្នេះ ។

បទថា ខុទ្ទានុខុទ្ទកេហិ : ដោយសិក្ខាបទតូច ៗទាំងនេះ គឺដោយសិក្ខាបទតូច( ខុទ្ទក )ផង ដោយសិក្ខាបទតូចបន្ទាប់( ខុទ្ទានុខុទ្ទក )ផង ។

ពាក្យថា យាវទេវ : ប៉ុណ្ណោះឯង ជាពាក្យកំណត់ព្រំប្រទល់ប្រព្រឹត្តទៅនៃសិក្ខាបទតូច ៗទាំងនោះ ។ មានពាក្យអធិប្បាយថា ក៏ភិក្ខុពួកណា សូធ្យក្តី ឱ្យសូធ្យក្តី ស្វាធ្យាយក្តីនូវសិក្ខាបទតូចនិងតូចបន្ទាប់នោះ សិក្ខាបទតូច ៗ នោះ រមែងប្រព្រឹត្តទៅឱ្យកើតសេចក្តីក្តៅក្រហាយគឺ សេចក្តីលំបាកដែលហៅថា សេចក្តីរង្កៀសសង្ស័យ និងសេចក្តីរវើម

វារាមក្នុងចិត្តដែលហៅថា វិចិកិច្ឆា ដល់ភិក្ខុទាំងនោះតែម្តងថា គួរ ឬមិនគួរហ្ន៎ ។

ម្យ៉ាងទៀត ពាក្យថា យាវទេវ ជាពាក្យកំណត់ដោយសេចក្តីច្រើនក្រៃលែង ។ ពាក្យថា យាវទេវ នោះ ភ្ជាប់សេចក្តីចូលទីងបទថា សំវត្តន្តិ : ប្រព្រឹត្តទៅ នេះ ។ មានពាក្យអធិប្បាយថា ប្រព្រឹត្តទៅដើម្បីសេចក្តីក្តៅក្រហាយ ដើម្បីសេចក្តីលំបាក ដើម្បីសេចក្តីស្មុគស្មាញហួសប្រមាណ ។

[៣០៤] ពាក្យថា ឧបសម្បន្នស្ស វិនយំ វិវណ្ណេតិ : ភិក្ខុពោលបន្ថាប់វិន័យដល់ភិក្ខុផងគ្នា មានសេចក្តីថា ភិក្ខុដែលប្រាថ្នានឹងឱ្យកើតសេចក្តីងឿងឆ្ងល់ក្នុងវិន័យនោះ ដល់ឧបសម្បន្ននោះ ទើបពោលទោស គឺ តិះដៀលព្រះវិន័យក្នុងសំណាក់នៃឧបសម្បន្ន ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

វិវណ្ណនសិក្ខាបទវណ្ណនា ចប់

# ៣. មោហនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[៣០៧] បទថា អន្វឌ្ឍមាសំ : រាល់កន្លះខែ បានដល់ តាមលំដាប់ គឺ គ្រប់កន្លះខែ ៗ ។ ក៏ព្រោះបាដិមោក្ខនោះដែលភិក្ខុ រមែងសូត្រក្នុងថ្ងៃឧបោសថ; ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ទុកក្នុងបទភាជនៈថា "រាល់ថ្ងៃឧបោសថ" ។

បទថា ឧទ្ទិស្សមានេ : កាលភិក្ខុកំពុងសម្ដែង គឺ កាលបាដិមោក្ខកំពុងសម្ដែង ។ ក៏ព្រោះបាដិមោក្ខនោះ ដែលភិក្ខុអ្នកសូធ្យបាដិមោក្ខកំពុងលើកឡើងសម្ដែង ឈ្មោះថា ភិក្ខុកំពុងសម្ដែង ; ដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ទុកក្នុងបទភាជនៈថា "កាលភិក្ខុកំពុងសូធ្យបាដិមោក្ខ" ។

[៣០៩] ពាក្យថា យញ្ច តត្ថ អាបត្តិំ អាបន្នោ : ភិក្ខុនោះត្រូវអាបត្តិណាក្នុងរឿងអនាចារនោះ បានដល់ ភិក្ខុដែលត្រូវអាបត្តិណាក្នុងអនាចារដែលខ្លួនប្រព្រឹត្តហើយនោះ ។

ពីរបទថា យថាធម្មោ ការេតព្វោ : សង្ឃគប្បីញ៉ាំងភិក្ខុនោះឱ្យធ្វើនូវអាបត្តិនោះ ដោយគួរតាមធម៌ បានដល់ ព្រោះជាអ្នកត្រូវអាបត្តិដោយមិនដឹង ទើបលោកមិនមានសេចក្ដីផុតពីអាបត្តិ ។ ក៏ឯសង្ឃគប្បីពិន័យលោកតាមធម៌និងវិន័យដែលដាក់ទុក ។ អធិប្បាយថា លោកត្រូវ

អាបត្តិទេសនាគាមិនី សង្ឃគប្បីឱ្យសម្តែងនិងត្រូវអាបត្តិវុដ្ឋានគាមិនី គប្បីឱ្យប្រព្រឹត្តវុដ្ឋានវិធី ។

បទថា សាធុកំ : ដ៏ល្អ គឺ ដោយស្រួល ។

បទថា អដ្ឋិកត្វា : ឱ្យសម្រេចនូវប្រយោជន៍ គឺ ធ្វើឱ្យមានប្រយោជន៍ ។ មានពាក្យអធិប្បាយថា ជាធម៌ប្រកបដោយប្រយោជន៍ ។

[៣១១] ក្នុងពាក្យថា ធម្មកម្មេ : កម្មប្រកបដោយធម៌ ជាដើម លោកប្រាថ្នាយកមោហារោបនកម្ម ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

មោហនសិក្ខាបទវណ្ណនា ចប់

# ៤. បហារសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

## ការវាយដោយបាតដៃ

[៣១៣] ពីរបទថា បហារំ ទេន្តិ : ហើយឱ្យប្រហារ មានសេចក្ដីថា ពួកភិក្ខុឆព្វគ្គិយពោលពាក្យជាដើមថា អ្នកមានអាយុ ពួកលោកចូររៀបតាំងតួច ចូរជងទឹកលាងជើងមកទុក ហើយវាយ (នូវភិក្ខុពួកសត្តរសវគ្គិយ) អ្នកមិនធ្វើតាម ។

[៣១៥] ក្នុងពាក្យថា បហារំ ទេតិ អាបត្តិ ចាចិត្តិយស្ស : ឱ្យប្រហារ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ នេះ មានវិនិច្ឆ័យថា កាលភិក្ខុវាយដោយបំណងត្រឹមតែវាយ[១]ប៉ុណ្ណោះ សូម្បីអ្នកនោះស្លាប់ ក៏ត្រឹមតែជាអាបត្តិបាចិត្តិយ ។ ព្រោះការវាយ(នោះ) ដៃ ឬជើងកាច់បំបាក់ ឬសិរ្សៈបែក ក៏ជាបាចិត្តិយប៉ុណ្ណោះ ។ កាត់ត្រចៀក ឬកាត់ច្រមុះ ដោយសេចក្ដីប្រាថ្នានឹងធ្វើឱ្យខូចសម្ផស្សយ៉ាងនេះថា "យើងនឹងធ្វើឱ្យលោកអស់សម្រស់ក្នុងកណ្ដាលសង្ឃ" ក៏ជាទុក្កដ ។

បទថា អនុបសម្បន្នស្ស : ដល់អនុបសម្បន្ន មានសេចក្ដីថា

---

១. វច. ជួនណាត. ពាក្យថា ប្រហារ ន. (សំ; បា. បហារ) ការទះ តប់ ទាត់ ធាក់ វាយ សំពង កាប់ ចាក់ ។ ខ្មែរយើងច្រើនប្រើជា កិ. "កាប់ សម្លាប់" ប្រហារជីវិត, សម្លាប់; ប្រហារដោយដំបង វាយនឹងដំបង ។ ដើម្បីកុំឱ្យច្រឡំថា សម្លាប់, ទើបប្រើពាក្យថា "វាយ" វិញ ។

ភិក្ខុវាយនូវគ្រហស្ថ ឬបព្វជិត នូវស្ត្រីឬបុរស ដោយហោចទៅ សូម្បីវាយនូវសត្វតិរច្ឆាន ត្រូវអាបត្តិទុក្កដ, តែបើថា មានចិត្តតម្រេកវាយស្រីជាសង្ឃាទិសេស ។

[៣១៦] ពីរបទថា កេនចិ វិហេឋិយមានោ : ភិក្ខុដែលជនណាមួយបៀតបៀន បានដល់ ត្រូវមនុស្ស ឬសត្វតិរច្ឆានបៀតបៀន ។

បទថា មោក្ខាធិបបាយោ : ហើយមានសេចក្តីប្រាថ្នាដើម្បីនឹងឱ្យរួចខ្លួន គឺ ប្រាថ្នាការរួចផុតដល់ខ្លួនឯង អំពីមនុស្សជាដើមនោះ ។

ពីរបទថា បហារំ ទេតិ : ក៏ឱ្យប្រហារទៅវិញ មានសេចក្តីថា ភិក្ខុវាយដោយកាយ របស់ជាប់ដោយកាយ និងរបស់ដែលគេវែងទៅយ៉ាងណាមួយ មិនជាអាបត្តិ ។ ប្រសិនបើថា ភិក្ខុឃើញចោរក្តី សត្រូវក្តី ប្រាថ្នានឹងបៀតបៀនក្នុងរវាងមកពោលថា នែឧបាសក លោកចូរឈប់ក្នុងទីនោះឯង កុំចូលមក, ហើយវាយអ្នកមិនព្រមស្តាប់ កំពុងដើរចូលមកដោយដំបងអន្ទង ឬដោយសស្ត្រាព្រមទាំងនិយាយថា "ចេញទៅវើយ" ហើយទៅ ។ បើគេស្លាប់ព្រោះការវាយនោះ មិនជាអាបត្តិដូចគ្នា ។ សូម្បីក្នុងពួកម្រឹគកាចក៏ន័យនេះដែរ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

ក៏សមុដ្ឋានជាដើម របស់សិក្ខាបទនោះ ដូចគ្នានឹងបឋមបារាជិកតែសិក្ខាបទនេះជាទុក្ខវេទនា ដូច្នេះឯង ។

បហារសិក្ខាបទវណ្ណនា ចប់

## ៥. តលសត្តិកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

### ការងាលំពែង គឺបាតដៃឡើងបំណងនឹងវាយ

[៣១៧] ពីរបទថា តលសត្តិកំ ឧគ្គិរន្តិ : ហើយងាលំពែងគឺបាតដៃឡើង មានសេចក្ដីថា (ពួកឆព្វគ្គិយភិក្ខុ) កាលសម្ដែងអាការវាយ រមែងងាកាយ(ដៃ)ខ្លះ របស់ជាប់ដោយកាយខ្លះ ។

ពាក្យថា តេ បហារសមុច្ចិត្តា រោទន្តិ : សត្តរសវគ្គិយភិក្ខុទាំងនោះ ទើបតែនឹងរួចអំពីប្រហារមកហើយ (មានសេចក្ដីភិតភ័យ) ក៏នាំគ្នាយំ មានសេចក្ដីថា ពួកភិក្ខុសត្តរសវគ្គិយទាំងនោះ ធ្លាប់ចាំនូវការវាយហើយ សម្គាល់ថា ភិក្ខុទាំងនេះ នឹងវាយយើងឥឡូវនេះ ព្រោះជាអ្នកបានទទួលការវាយមកហើយ ក្នុងកាលមុន ទើបស្រែកយំ, អាចារ្យពួកខ្លះស្វាធ្យាយថា បហារស្ស មុច្ចិតា ក៏មាន ។ ក្នុងបាលីនោះ មានសេចក្ដីថា ខ្លាចការវាយ ។

[៣១៩] ក្នុងពាក្យថា ឧគ្គិរតិ អាបត្តិ បាចិត្តិយស្ស : ងាឡើង ត្រូវអាបត្តិបាចិត្តិយ នេះ មានវិនិច្ឆ័យដូច្នេះ ៖

បើភិក្ខុងាភ្លាត់ក៏វាយទៅ កាលភិក្ខុមិនអាចនឹងទប់បានប្រាកដ ទើបវាយទៅដោយរហ័ស ជាទុក្កដ ព្រោះលោកវាយ ដោយមិនមានបំណង

នីងវាយ ។ ព្រោះការវាយនោះ អវយវៈយ៉ាងណាមួយ មានដៃជាដើម បាក់ទៅ ក៏ត្រឹមតែជាទុក្កដ ។ ភិក្ខុដែលប្រាថ្នានឹងវាយ តែការវាយដោយរបស់យ៉ាងណាមួយ មានដើមឈើជាដើម ភ្លាត់ហួសទៅ ឬ ខ្លួនត្រឡប់បានសតិហើយមិនវាយវិញ ជាទុក្កដ ។ ឬកាលវាយ ត្រូវអ្នកណា ៗ ទប់ដៃជាប់ ក៏ជាទុក្កដ ។

[៣២០] ក្នុងពាក្យថា មោក្ខាធិប្បាយោ តលសត្តិកំ ឧគ្គិរតិ : មានសេចក្តីប្រាថ្នាដើម្បីនឹងឱ្យរួចខ្លួន ក៏ផាលំពែងគឺបាតដៃឡើង នេះ មានវិនិច្ឆ័យដូច្នេះ ៖

មិនជាអាបត្តិដល់ភិក្ខុដែលផាលំពែងគឺ បាតដៃដោយន័យមុនទុំះឯង ក្នុងរឿងទាំងឡាយដែលពោលហើយខាងដើម ។ បើថា ភិក្ខុវាយខុស ក៏មិនជាអាបត្តិដូចគ្នា ។ ពាក្យដែលនៅសល់ព្រមទាំងសមុដ្ឋានជាដើម ជាដូចគ្នានឹងសិក្ខាបទមុននោះឯង ។

តលសត្តិកសិក្ខាបទវណ្ណនា ចប់

# ៦. អមូលកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

[៣២១] បទថា អនុទ្ធំសេន្តិ : នាំគ្នាកំចាត់ (គឺចោទ) មានសេចក្ដីថា ក៏ពួកឆព្វគ្គិយភិក្ខុទាំងនោះ ព្រោះខ្លួនឯងជាអ្នកមានទោសដែរដាស់ កាលនឹងធ្វើការការពារថា ភិក្ខុទាំងឡាយនឹងមិនចោទ នឹងមិនញ៉ាំងពួកយើងឱ្យរលឹកដោយអាការយ៉ាងនេះ ទើបប្រញាប់ដណ្ដើមចោទភិក្ខុទាំងឡាយ ដោយសង្ឃាទិសេសមិនមានមូលជាមុន ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះងាយយល់ទាំងអស់ ព្រោះមានន័យដូចដែលយើងពោលហើយក្នុងអមូលកសិក្ខាបទ ក្នុងតេរសកណ្ឌ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈលោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

អមូលកសិក្ខាបទវណ្ណនា ចប់

# ៧. សញ្ចិច្ចសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[៣២៥] បទថា ឧបទហន្តិ : បង្កហេតុឱ្យមាន គឺ បង្កឱ្យកើតឡើង ។

[៣២៧] ពាក្យថា កុក្កុច្ចំ ឧបទហតិ អាបត្តិ ចាចិត្តិយស្ស : ផ្តើមសេចក្តីរង្កៀសសង្ស័យឱ្យកើតឡើង ត្រូវអាបត្តិបាចិត្តិយ បានដល់ ត្រូវអាបត្តិបាចិត្តិយ គ្រប់ពាក្យនិយាយ ។

បទថា អនុបសម្បន្នស្ស : ដល់អនុបសម្បន្ន មានសេចក្តីថា ភិក្ខុបង្កើតសេចក្តីក្តៅក្រហាយដល់សាមណេរ ដោយន័យជាដើមថា ប្រហែលជាលោកអង្គុយ ដេក ស៊ី ផឹក ក្នុងទីកំបាំងរួមទីងមាតុគ្រាម និងលោកធ្វើយ៉ាងនេះ និងយ៉ាងនេះក្នុងកណ្តាលសង្ឃ ។ ជាទុក្កដ គ្រប់ពាក្យនិយាយ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។ សមុដ្ឋានជាដើម ក៏ដូចនឹងអមូលកសិក្ខាបទនោះឯង ។

សញ្ចិច្ចសិក្ខាបទវណ្ណនា ចប់

# ៨. ឧបស្សុតិកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

[៣៣០] បទថា អធិករណជាតានំ : អធិករណ៍កើតឡើង ហើយ បានដល់ កើតវិវាទាធិករណ៍ឡើង ព្រោះការទាស់ទែងគ្នាជាដើម ទាំងនេះ ។

បទថា ឧបស្សុតិ : អែបស្ដាប់ គឺ ជិតល្មមបានឮ, អធិប្បាយថា ក្នុងទីដែលខ្លួនឈរហើយ អាចបានឮពាក្យនិយាយរបស់ភិក្ខុទាំងនោះបាន ។

ក្នុងពាក្យថា គច្ឆតិ អាបត្តិ ទុក្កដស្ស : ភិក្ខុដើរទៅ ត្រូវអាបត្តិទុក្កដ នេះ ជាទុក្កដគ្រប់ ៗជំហាន ។

បទថា មន្តេន្តំ : កំពុងប្រឹក្សាគ្នា គឺ កាលភិក្ខុមួយរូបទៀតប្រឹក្សានឹងភិក្ខុមួយរូបទៀត ។

ម្យ៉ាងទៀតថា បាលីថា មន្តេន្តេ ក៏មានសេចក្ដីក៏យ៉ាងនេះ ។

[៣៣២] បទថា វូបសមិស្សាមិ : នឹងរម្ងាប់ មានសេចក្ដីថា យើងនឹងរម្ងាប់នឹងដល់សេចក្ដីរម្ងាប់ គឺនឹងមិនធ្វើការឈ្លោះគ្នា ។

ពីរបទថា អត្តានំ បរិមោចេស្សាមិ : នឹងដោះខ្លួន មានសេចក្ដីថា យើងនឹងប្រាប់ថា យើងមិនមែនជាអ្នកធ្វើហើយដោះខ្លួន ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចថេយ្យសត្ថសិក្ខាបទ កើតឡើង មកកាយចិត្ត ១ កាយវាចាចិត្ត ១ ពេលខ្លះជាកិរិយា ដោយអំណាចនៃ ការទៅព្រោះសេចក្តីចង់ស្លាប់, ពេលខ្លះជាអកិរិយា ដោយអំណាចនៃការ មិនញ៉ាំងអ្នកទាស់ទែងគ្នាដែលមកកាន់ខ្លួនឈរហើយ ប្រឹក្សាគ្នាឱ្យដឹង ខ្លួន ។ ពិតមែន សិក្ខាបទទាំង ៣ នេះ គឺ រូបិយសិក្ខាបទ អញ្ញវាទ សិក្ខាបទ ឧបស្សុតិកសិក្ខាបទ មានការកំណត់តែម្យ៉ាងដូចគ្នា ជាសញ្ញា វិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខ វេទនា ដូច្នេះឯង ។

ឧបស្សុតិកសិក្ខាបទវណ្ណនា ចប់

# ៩. កម្មបដិពាហនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

[៣៣៣] ពាក្យថា សចេ ច មយំ ជានេយ្យាម **:** ក៏បើយើងទាំងឡាយ ដឹងសោត ប្រែត្រឹមតែ បើយើងទាំងឡាយដឹងសោត ។ ចំណែក ច អក្សរ ត្រឹមតែជានិបាតប៉ុណ្ណោះ ។

បទថា ធម្មិកានំ **:** ដែលប្រកបដោយធម៌ មានវិគ្រោះថា ធម៌មាននៅក្នុងកម្មទាំងនោះ ព្រោះសង្ឃធ្វើដោយធម៌ ដោយវិន័យ ដោយសត្ថុសាសនៈ ; ព្រោះហេតុនោះ កម្មទាំងនោះ ទើបឈ្មោះថា ធម្មិកៈ (កម្មដែលជាធម៌) ។ ដើម្បីសង្ឃកម្ម ៤ ដែលជាធម៌ទាំងនោះ ។

[៣៣៤] ក្នុងពាក្យថា **ខីយតិ អាបត្តិ បាចិត្តិយស្ស :** តិះដៀល ត្រូវអាបត្តិបាចិត្តិយ នេះ ជាបាចិត្តិយ គ្រប់ពាក្យនិយាយ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

កម្មបដិពាហនសិក្ខាបទវណ្ណនា ចប់

# ១០. ឆន្ទំអទត្វាសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[៣៣៨] ពាក្យថា វត្ថុ វា អារោចិតំ ហោតិ : រឿងដែលសង្ឃប្រាប់ហើយ មានសេចក្ដីថា ទាំងអ្នកចោទនិងអ្នកចម្លើយបានពោលពាក្យរបស់ខ្លួនហើយ ភិក្ខុដែលដេញដោលសួរ ក៏បានទទួលសន្មតហើយ សួម្បីដោយអាការត្រឹមតែប៉ុណ្ណោះ វត្ថុជាការប្រាប់ហើយ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន កើតឡើងមកកាយវាចាចិត្ត ជាកិរិយានិងជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ឆន្ទំអទត្វាសិក្ខាបទវណ្ណនា ចប់

# ១១. ទព្វសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១១ ដូចតទៅនេះ ៖

[៣៤២] បទថា **យថាមិត្តតា : តាមបុគ្គលដែលជាមិត្ត** គឺតាមភាពជាមិត្តនឹងគ្នា ។ មានពាក្យអធិប្បាយថា ឱ្យដល់ភិក្ខុដែលជាមិត្តគ្នា ។ ក្នុងបទទាំងពួង ក៏ន័យដូចគ្នា ។ ពាក្យដែលនៅសល់មានសេចក្តីងាយយល់ទាំងអស់ ព្រោះមានន័យដូចពោលហើយ ក្នុងឧជ្ឈាបនកសិក្ខាបទជាដើមនោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ទព្វសិក្ខាបទវណ្ណនា ចប់

# ១២. បរិណាមនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១២ ដូចតទៅនេះ ៖

[៣៤៥] ពាក្យដែលនឹងគប្បីពោលទាំងអស់ មានន័យដូចពោលហើយក្នុងបរិណាមនសិក្ខាបទ ក្នុងតឹសកណ្ឌនោះ ជានិស្សគ្គិយបាចិត្តិយ ព្រោះបង្អោនមកដើម្បីខ្លួន ក្នុងសិក្ខាបទនេះ ជាបាចិត្តិយសុទ្ធ ព្រោះបង្អោនទៅដើម្បីបុគ្គល (ដទៃ) ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា៣ ដូច្នេះឯង ។

បរិណាមនសិក្ខាបទវណ្ណនា ចប់

ចំនួនសិក្ខាបទក្នុងសហធម្មិកវគ្គនោះ គឺ

១. សហធម្មិកសិក្ខាបទ ការពោលពាក្យប្រកបដោយធម៌
២. វិវណ្ណនសិក្ខាបទ ការពោលបន្ទាប់សិក្ខាបទ
៣. មោហនសិក្ខាបទ ការក្លែងធ្វើជាវង្វេង
៤. បហារសិក្ខាបទ ការវាយប្រហារ
៥. តលសត្តិកសិក្ខាបទ ការផាលំពែង គឺ បាតដៃ
៦. អមូលកសិក្ខាបទ ការចោទដោយអាបត្តិមិនមានមូល
៧. សញ្ចិច្ចសិក្ខាបទ ការក្លែងបង្ករហេតុឱ្យកើតសេចក្តីរង្កៀសសង្ស័យ
៨. ឧបស្សុតិកសិក្ខាបទ ការអែបស្តាប់( ពាក្យជាហេតុទាស់ទែងគ្នា )
៩. កម្មបដិពាហនសិក្ខាបទ ការជំទាស់កម្ម
១០. ឆន្ទំអទត្វាសិក្ខាបទ ការមិនឱ្យឆន្ទៈ
១១. ទព្វសិក្ខាបទ ការឱ្យចីវរដល់ព្រះទព្វមល្លបុត្រ
១២. បរិណាមនសិក្ខាបទ ការបង្អោនលាភសង្ឃ

អដ្ឋកថា សហធម្មិកវគ្គទី ៨ ចប់ ។

# ៩. រតនវគ្គ

## ១. អន្តេបុរសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃរតនវគ្គ ដូចតទៅនេះ ៖

### ពន្យល់អត្ថក្នុងសិក្ខាបទទី ១

[៣៤៩] បទថា ឱរកោ : ជាអ្នកថោកទាប គឺ ជាអ្នកតូចតាច ។

[៣៥០] បទថា ឧបរិបា្បសាទវរគតោ : គង់ក្នុងថ្នាក់ខាងលើប្រាសាទដ៏ប្រសើរ គឺប្រថាប់នៅក្នុងថ្នាក់ខាងលើនៃប្រាសាទដ៏ប្រសើរ ។

ពីរបទថា អយ្យានំ វាហសា : ព្រោះនាំមកនូវលោកម្ចាស់ទាំងឡាយ បានដល់ ព្រោះហេតុនៃលោកម្ចាស់ទាំងឡាយ មានពាក្យអធិប្បាយថា ខ្ញុំព្រះករុណាដឹងធម៌ ព្រោះលោកម្ចាស់ទាំងនោះបានជួយឱ្យកើតឡើង ។

[៣៥១] ពីរបទថា បិតរំ បតេ្ថតិ : ប្រាថ្នានឹងបៀតបៀនចំពោះព្រះរាជបិតា បានដល់ ព្រះរាជឱរសត្រូវការនឹងឃើញទោសហើយផ្ដាច់ព្រះជន្មព្រះរាជបិតា ។

ក្នុងពាក្យថា រាជន្តេបុរំ ហត្ថិសម្មទ្ទំ : ខាងក្នុងរាជបុរី តែង

ជ្រួលជ្រើមទៅដោយដំរី ជាដើម មានវិនិច្ឆ័យថា ទីវាំងក្នុងព្រះរាជវាំង នេះ ច្រើនតាន់តាប់ទៅដោយពួកដំរី; ដូច្នោះ ទើបឈ្មោះថា **ហត្ថិសម្មទ្ទំ** ។ អធិប្បាយថា ចង្អៀតទៅដោយដំរី ។ សូម្បីក្នុងបទថា អស្សរថសម្មទ្ទំ ក៏ន័យនេះដូចគ្នា ។ ភិក្ខុពួកខ្លះសូត្រថា សម្មត្តំ ក៏មាន ។ ពាក្យនោះ មិនគួរកាន់យក ។ បាលីថា រញ្ញោ អន្តេបុរេ ហត្ថិសម្មទ្ទំ ក៏មាន ។ ក្នុងបាឋៈនោះ មានអត្ថថា ការជាន់ទៅមកនៃដំរីទាំងឡាយ ឈ្មោះថា **ហត្ថិសម្មទ្ទំ** ។ មានពាក្យអធិប្បាយថា ការដើរជាន់ទៅមកនៃដំរីមាននៅ ក្នុងព្រះរាជវាំង ។ សូម្បីក្នុងបទដែលនៅសល់ក៏ន័យនេះ ។

បទថា រជនីយានិ : **ជាហេតុនៃសេចក្តីត្រេកអរ** បានដល់ អារម្មណ៍មានរូបជាដើមដូច្នេះ មាននៅក្នុងព្រះរាជវាំងជាន់ក្នុងនោះ ។

[៣៥២] បទថា មុទ្ធាភិសិត្តស្ស : **បានមុទ្ធាភិសេកហើយ** គឺ អ្នកទ្រង់បានទទួលអភិសេកស្រោចស្រង់លើព្រះសិរសា ។

បទថា អនិក្ខន្តរាជកេ : **ដែលស្តេចមិនទាន់យាងចេញ** មាន វិគ្រោះថា ព្រះរាជាមិនទាន់ចេញពីព្រះដំណាក់ក្រឡាបន្ទំនេះ; ហេតុនោះ ដំណាក់នោះ ទើបឈ្មោះថា ដែលព្រះរាជាមិនទាន់ចេញ ។ អធិប្បាយ ថា ក្នុងដំណាក់ទីផ្ទុំ មានព្រះរាជាមិនទាន់ស្តេចចេញនោះ ។ ព្រះមហេសី ព្រះមានព្រះភាគហៅថា រតនៈ ។

បទថា និក្ខន្តំ : ចេញហើយ គឺ ចេញទៅហើយ ។ រតន : ស្រីកែវ គឺ ព្រះមហេសី មិនទាន់យាងចេញអំពីដំណាក់ព្រះបន្ទំនេះ ដូច្នោះ ដំណាក់បន្ទំនោះ ទើបឈ្មោះថា ដែលរតនៈមិនទាន់ចេញ ។ អធិប្បាយថា ក្នុងដំណាក់ជាទីផ្ទំ មានរតនៈមិនទាន់ចេញនោះ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងមកកាយវាចា១ កាយវាចាចិត្ត១ ជាកិរិយានិងជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

អន្តេបុរសិក្ខាបទវណ្ណនា ចប់

# ២. រតនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

## ការស្ពានទីនិងរបស់ធ្លាក់ដែលគួររក្សាមិនគួររក្សា

[៣៥៦] បទថា វិស្សរិត្វា : ក៏ភ្លេចថង់ប្រាក់ គឺបានភ្លេចទុក ។ ប្រាំកហាបណៈ អំពីប្រាក់មួយរយ[១] ឈ្មោះថា បុណ្ណបត្តៈ រង្វាន់ ។

[៣៥៧] ពាក្យថា ក្យាហំ ករិស្សាមិ : ចុះអញទៅធ្វើអ្វី គឺយើងនឹងធ្វើយ៉ាងណា ?

ពាក្យថា អាភរណំ ឱមុញ្ចិត្វា : ហើយក៏ដោះនូវគ្រឿងអាភរណៈ គឺបានដោះគ្រឿងប្រដាប់ឈ្មោះមហាលតាមានតម្លៃ៩ កោដិចេញទុក ។

[៣៥៨] បទថា អន្តេវាសី : ក្មួយស្រី បានដល់ ជាអ្នកបម្រើ ។

[៣៥៩] ចម្ងាយ ២ ដុំដីធ្លាក់ដែលគប់ទៅនៃវត្តជាលំនៅ ឈ្មោះថា ឧបចារ ក្នុងពាក្យថា អបរិក្ខិត្តស្ស ឧបចារេ : វត្តដែលមិនមានរបង សំដៅយកត្រឹមទីឧបចារនៃវត្ត នេះ ។ តែក្នុងមហាបច្ចរីពោលថា សម្រាប់ទីនៅសម្រាក ចម្ងាយត្រូវវែងចន្លោះធ្លាក់ ឬចម្ងាយត្រូវវែងអង្រែធ្លាក់ (ឈ្មោះថា ឧបចារ) ។

---

១. ប្រាក់មួយរយសម្រាប់ជារង្វាន់ប្រាំកហាបណៈ ៗ ៥ ដង = ២៥ កហាបណៈ ។

ក្នុងពាក្យថា **គណ្ហាតិ អាបត្តិ បាចិត្តិយស្ស : ភិក្ខុកាន់យកដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ** នេះ មានវិនិច្ឆ័យថា ភិក្ខុទទួលខ្លួនឯងក្តី ឱ្យគេទទួលក្តី នូវមាស និងប្រាក់ ដើម្បីប្រយោជន៍ដល់ខ្លួន ជានិស្សគ្គិយបាចិត្តិយ ។ ទទួលខ្លួនឯងក្តី ឱ្យគេទទួលក្តី ដើម្បីប្រយោជន៍ដល់សង្ឃ គណៈ បុគ្គល ចេតិយ និងនវកម្ម ជាទុក្កដ ។ ភិក្ខុទទួលខ្លួនឯងក្តី ឱ្យគេទទួលក្តី នូវរតនៈមានមុក្តាជាដើមដែលនៅសល់ដើម្បីប្រយោជន៍ដល់ខ្លួន ឬដល់សង្ឃជាដើម ជាទុក្កដ ។ វត្ថុដែលជាកប្បិយវត្ថុក្តី ជាអកប្បិយវត្ថុក្តី ដែលជារបស់គ្រហស្ថ ដោយហោចទៅសូម្បីស្លឹកត្នោតជាគ្រឿងប្រដាប់ត្រចៀកជារបស់មាតា កាលភិក្ខុទទួលរក្សាដោយប្រាថ្នាវត្ថុនៃភណ្ឌាគារិកជាធំ ជាបាចិត្តិយដូចគ្នា ។ តែបើជារបស់មាតាបិតាជាកប្បិយភណ្ឌៈ ដែលគួរដល់ភិក្ខុនឹងរក្សាទុកបានពិតប្រាកដ គប្បីទទួលរក្សាទុកដើម្បីប្រយោជន៍ខ្លួន ។ តែកាលគេពោលថា លោកមេត្តារក្សារបស់នេះទុកឱ្យផង គប្បីហាមថា មិនគួរ ។ បើពួកគ្រហស្ថបោះរបស់ចោលទុកពោលថា និមន្តលោករក្សាទុកឱ្យផង ហើយចេញទៅ, ចាត់ថា ជាធុរៈ សមគួរនឹងរក្សាទុក ។ ពួកអ្នកធ្វើការងារ មានជាងឈើជាដើម អ្នកធ្វើការងារក្នុងវិហារក្តី ពួករាជវល្លភ[1]ក្តី សូមអន្វរឱ្យជួយ

១. អ្នកស្និទ្ធស្នាលនឹងព្រះរាជា ។

រក្សាគ្រឿងដៃ ឬគ្រឿងដេករបស់ខ្លួនថា "និមន្ត លោកជួយរក្សាទុកឱ្យផង" ។ កុំគប្បីធ្វើ ព្រោះសេចក្តីពេញចិត្តនឹងគ្នាខ្លះ ព្រោះខ្លាចខ្លះ ។ តែនឹងសម្តែងទីរក្សាឱ្យ គួរ ។ ចំណែកក្នុងពួកជនអ្នកបោះរបស់ចោលទុកដោយពលការហើយចេញទៅ នឹងរក្សាទុកឱ្យក៏គួរ ។

[៣៦០] ក្នុងពាក្យថា អជ្ឈារាមេ វា អជ្ឈាវសថេ វា : **ខាងក្នុងវត្តក្តី ខាងក្នុងទីស្នាក់ក្តី** នេះ មានវិនិច្ឆ័យដូច្នេះ ៖

បើអារាមធំដូចមហាវិហារ, ភិក្ខុរើសខ្លួនឯងក្តី ប្រើឱ្យគេរើសក្តី នូវរបស់គ្រហស្ថដែលធ្លាក់ក្នុងស្ថានទី ដូចកន្លែងដែលនឹងកើតមានសេចក្តីខ្លាចក្រែងថា "នឹងត្រូវពួកភិក្ខុនិងសាមណេរកាន់យកទៅ" ហើយគប្បីរក្សាទុកក្នុងបរិវេណ ដែលមានកំពែងការពារក្នុងអារាមធំនោះ ។ តែបើធ្លាក់ក្នុងស្ថានទីសញ្ចររបស់មហាជន ដូចជាស៊ុមទ្វារនៃមហាពោធិ និងលានដើមស្វាយ មិនគួរកាន់យក ។ មិនមែនធុរៈនាទី (របស់ភិក្ខុ) ។ តែក្នុងកុរុន្ទីពោលថា ភិក្ខុមួយរូប ធ្វើដំណើរទៅឃើញភណ្ឌៈយ៉ាងណាមួយ ក្នុងស្ថានទីមិនមានមនុស្ស ។ សូម្បីកាលកើតមានមនុស្សក្រុះករពួកអ្នកស្រុកក៏នឹងសង្ស័យភិក្ខុនោះតែម្តង ។ ព្រោះដូច្នោះ ភិក្ខុនោះគប្បីចេញចាកមកហើយឆៀងចូលទៅអង្គុយសម្រាក ។ កាលពួកម្ចាស់របស់មក គប្បីប្រាប់ទ្រព្យនោះ ។ បើមិនជួបម្ចាស់របស់ទេ លោកនឹង

ត្រូវធ្វើឱ្យជារបស់សមគួរ (មានកាន់យកជារបស់បង្សុកូលជាដើម) ។

ក្នុងពាក្យថា រូបេន វា និមិត្តេន វា សញ្ញាណំ កត្វា : ភិក្ខុធ្វើសញ្ញា ដោយរូបក្តី ដោយនិមិត្តក្តី នេះ ដែលឈ្មោះថា រូប បានដល់ភណ្ឌៈខាងក្នុងកញ្ចប់ ។ ព្រោះដូច្នោះ ភិក្ខុគប្បីស្រាយកញ្ចប់ភណ្ឌៈចេញរាប់មើល ហើយកំណត់ទុកថា កហាបណៈប៉ុណ្ណេះ ឬប្រាក់និងមាសប៉ុណ្ណេះ ។

ត្រាគ្រឿងកំណត់ចំណាំជាដើម ឈ្មោះថា និមិត្ត (គ្រឿងសំគាល់) ។

ព្រោះដូច្នោះ ភិក្ខុគប្បីកំណត់គ្រឿងសំដៅគ្រប់យ៉ាង ក្នុងកញ្ចប់ភណ្ឌៈដែលប្រថាប់ត្រាគ្រឿងចំណាំមានជាដើមយ៉ាងនេះ គឺ ប្រថាប់ត្រាដោយដីស្អិត ឬថា ប្រថាប់ត្រាដោយអាចម៍ល័ក្ខ, ខ្ចប់ភណ្ឌៈដែលគេខ្ចប់ដោយពណ៌ខៀវ ឬថា ដែលគេខ្ចប់ដោយសំពត់ពណ៌លឿង ។

ពីរបទថា ភិក្ខូ បដិរូបា : ភិក្ខុទាំងឡាយណាជាសមគួរ បានដល់ ភិក្ខុទាំងឡាយអ្នកមានសេចក្តីខ្មាសច្រើនខ្លាចក្រែង ។ ព្រោះនឹងប្រគល់ទុកក្នុងដៃរបស់ពួកអ្នកមាននិស្ស័យឡេះឡោះមិនបាន ។ ក៏ភិក្ខុណាមិនទាន់ជៀសចេញពីអាវាសនោះ ឬមិនទាន់ជួបពួកម្ចាស់របស់, សូម្បីភិក្ខុនោះ កុំគប្បីធ្វើឱ្យជាមូលតម្លៃនៃចីវរជាដើម ដើម្បីខ្លួនឯង ។

តែគប្បីឱ្យសាងសេនាសនៈ ឬចេតិយឬស្រះបោក្ខរណីដែលជាថាវរ ។ បើថា ដោយកាលកន្លងទៅយូរ ម្ចាស់របស់ទើបមកទាមទារ, គប្បីប្រាប់គេថា "ឧបាសក របស់ឈ្មោះនេះ គេសាងដោយទ្រព្យរបស់លោក, លោកចូរអនុមោទនាចុះ" ។ ប្រសិនបើថា គេអនុមោទនាផង នោះជាការល្អដោយប្រការដូច្នេះ, តែបើគេមិនអនុមោទនាទេ ត្រឡប់ទាមទារថា "សូមលោកឱ្យទ្រព្យខ្ញុំវិញ" គប្បីបបួលអ្នកដទៃឱ្យចេញទ្រព្យសងគេទៅ ។

[៣៦១] ក្នុងពាក្យថា រតនសម្មតំ វិស្សាសំ គណ្ហាតិ : ភិក្ខុកាន់យកវត្ថុដែលគេសន្មតជារតនៈដោយស្និទ្ធស្នាល ជាដើម ត្រាស់សំដៅយកអាមាសវត្ថុ (របស់គួរចាប់ពាល់បាន) ប៉ុណ្ណោះ ។ របស់អនាមាស មិនគួរឡើយ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ សមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

រតនសិក្ខាបទវណ្ណនា ចប់

# ៣. វិកាលគាមប្បវេសនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

## ការពោលលាមុនចូលស្រុកក្នុងវេលាវិកាល

[៣៦២] បទថា តិរច្ឆានកថំ : ពោលនូវពាក្យទទឹង[១] បានដល់ពាក្យជាហេតុជំទាស់ចំពោះអរិយមគ្គ ។

បទថា រាជកថំ : ពោលអំពីរឿងស្ដេច បានដល់ ពាក្យដែលជាប់ដោយព្រះរាជា ។ សូម្បីក្នុងចោរកថាជាដើម ក៏ន័យនេះដូចគ្នា ។

[៣៦៤] ពាក្យដែលគួរពោលក្នុងពាក្យថា សន្តំ ភិក្ខុំ : ភិក្ខុដែលមាន នេះ មានន័យដូចពោលហើយក្នុងចារិត្តសិក្ខាបទនុ៎ះឯង ។

បើថា ភិក្ខុច្រើនរូបចូលទៅកាន់ស្រុកដោយករណីយ៉ាងណាមួយ,

---

១. មាន ៣២ គឺ ១.រឿងស្ដេច ២.រឿងចោរ ៣.រឿងមហាមាត្យ ៤.រឿងសេនា ៥.រឿងភ័យ ៦.រឿងចម្បាំង ៧.រឿងបាយ ៨.រឿងទឹកផឹក ៩.រឿងសំពត់ ១០.រឿងទីដេក ១១.រឿងផ្កាកម្រង ១២.រឿងគ្រឿងក្រអូប ១៣.រឿងញាតិ ១៤.រឿងយាន ១៥.រឿងស្រុក ១៦.រឿងនិគម ១៧.រឿងក្រុង ១៨.រឿងជនបទ ១៩.រឿងស្រី ២០.រឿងប្រុស ២១.រឿងកុមារី ២២.រឿងកុមារ ២៣.រឿងសុរា ២៤.រឿងប្រេក ២៥.រឿងកំពង់ទឹក ២៦.រឿងញាតិដែលស្លាប់ទៅ ២៧.រឿងផ្សេង ៗ ២៨.រឿងលោក ២៩.រឿងសមុទ្រ ៣០.រឿងសេចក្ដី សាបសូន្យ និងសេចក្ដីចម្រើន ៣១.រឿងព្រៃ ៣២.រឿងភ្នំ ។

លោកគ្រប់រូបគប្បីពោលលាគ្នានឹងគ្នាថា វិកាលេ គាមប្បវេសនំ អាបុច្ឆាម : ពួកយើងលាចូលស្រុកក្នុងវេលាវិកាល ។ ការងារនោះក្នុងស្រុកនោះមិនទាន់សម្រេច; ហេតុនោះ ភិក្ខុនឹងទៅកាន់ស្រុកដទៃសូម្បីទាំងរយស្រុកក៏ដោយ, មិនមានកិច្ចដែលនឹងត្រូវពោលលាទៀត ។ ក៏បើថា ភិក្ខុរម្ងាប់សេចក្តីតាំងចិត្តហើយ កំពុងលក់ទៅកាន់វិហារ ប្រាថ្នានឹងទៅកាន់ស្រុកដទៃក្នុងចន្លោះមកត្រូវពោលលាដូចគ្នា ។ ធ្វើភត្តកិច្ចក្នុងផ្ទះនៃត្រកូលក្តី ក្នុងសាលាឆាន់ក្តី ហើយប្រាថ្នានឹងត្រាច់ភិក្ខាប្រេង ឬភិក្ខាទឹកដោះថ្លា ។ ក៏បើមានភិក្ខុនៅជិត ៗ គប្បីពោលលាជាមុនហើយទើបទៅ ។ កាលមិនមាន គប្បីទៅដោយដាក់ចិត្តថា “ភិក្ខុមិនមាន” ឈានចុះកាន់មកហើយទើបឃើញភិក្ខុ មិនមានកិច្ចដែលនឹងត្រូវពោលលា ។ សូម្បីមិនពោលលា ក៏គួរត្រាច់ទៅបានដូចគ្នា ។ មានមកកន្លងទៅក្នុងកណ្តាលស្រុក កាលភិក្ខុដើរទៅតាមមកនោះ កើតគំនិតឡើងថា យើងនឹងត្រាច់ភិក្ខាប្រេងជាដើម បើមានភិក្ខុនៅជិត ៗ គប្បីពោលលាជាមុនទើបទៅ ។ តែកាលមិនចេញចាកមកដើរទៅ( តាមមករហូត ) មិនចាំបាច់ត្រូវពោលលា ។ បណ្ឌិតគប្បីជ្រាបឧបចារនៃស្រុក ដែលមិនមានរបងព័ទ្ធ ដោយន័យដូចពោលហើយក្នុងអទិន្នាទានសិក្ខាបទនុ៎ះឯង ។

[៣៦៨] ក្នុងពាក្យថា **អន្តរារាមំ : ចន្លោះអារាម** ជាដើម មិនមែនមិនលាតែម្យ៉ាង, សូម្បីភិក្ខុមិនចង់វត្តពន្ធចង្កេះ មិនជណ្តប់សង្ឃាដិទៅ ក៏មិនជាអាបត្តិ ។

បទថា **អាបទាសុ : មានអន្តរាយ** មានសេចក្តីថា សីហៈក្តី ខ្លាធំក្តី កំពុងមក, មេឃតាំងឡើងក្តី ឧបទ្រវៈណា ៗ យ៉ាងដទៃកើតឡើងក្តី មិនជាអាបត្តិ ។ ក្នុងអន្តរាយបែបនេះ ទឹងទៅកាន់ខាងក្នុងស្រុកអំពីខាងក្រៅស្រុក គួរ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងមកកាយវាចា១ កាយវាចាចិត្ត១ ជាកិរិយានិងជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

វិកាលគាមប្បវេសនសិក្ខាបទវណ្ណនា ចប់

# ៤. សូចិឃរសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

[៣៦៩] ការបំបែកទុំះឯង ឈ្មោះ ភេទនកៈ ។ ភេទនកៈនោះ មានដល់បាចិត្តិយនោះ; ព្រោះហេតុនោះ បាចិត្តិយនោះ ទើបឈ្មោះថា ភេទនកៈ ។

[៣៧២] បទថា អរណិកេ : ធ្វើជារបស់សម្រាប់ពួតភ្លើង បានដល់ ឈើពួតភ្លើងមេ និងឈើពួតភ្លើងកូន ។

បទថា វិធេ : ធ្វើជាក្រវិលវត្តពន្ធចង្កេះ បានដល់ ឡេវក្រវិល ។

ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះ ឯង ។

សូចិឃរសិក្ខាបទវណ្ណនា ចប់

## ៥. មញ្ចបីឋសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[៣៧៣] បាចិត្តិយដែលឈ្មោះថា ឆេទនកៈ មានន័យដូចពោលហើយដូចគ្នា ។

[៣៧៦] ក្នុងពាក្យថា ជិន្ទិត្វា បរិភុញ្ជតិ : កាត់ចេញហើយប្រើប្រាស់ នេះ មានវិនិច្ឆ័យដូច្នេះ ៖

បើភិក្ខុមិនប្រាថ្នានឹងកាត់ នឹងកប់ចុះក្នុងផែនដី សម្តែងប្រមាណទុកខាងលើ ឬពូនដីឱ្យខ្ពស់ឡើងហើយប្រើប្រាស់ ឬនឹងលើកឡើងដាក់លើថ្នឹមធ្វើឱ្យជាគ្រែប្រើប្រាស់ គួរគ្រប់យ៉ាង ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ សិក្ខាបទនេះមានសមុដ្ឋាន ៦ ។

មញ្ចបីឋសិក្ខាបទវណ្ណនា ចប់

## ៦. តូលោនទ្ធសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

[៣៧៧] គ្រែនិងតាំងដែលឈ្មោះថា គ្របសំឡី ព្រោះអត្ថថា ជាទីមានសំឡីត្រូវគ្របទុក ។ មានពាក្យអធិប្បាយថា ភិក្ខុញាត់សំឡីដោយសំពត់ក្រាលផែនដីខាងលើ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។ សិក្ខាបទនេះមានសមុដ្ឋាន ៦ ។

តូលោនទ្ធសិក្ខាបទវណ្ណនា ចប់

# ៧. និសីទនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[៣៨១] ពាក្យថា និសីទនំ អនុញ្ញាតំ ហោតិ : សំពត់និសីទនៈទ្រង់បានអនុញ្ញាតហើយ មានសេចក្តីថា និសីទនៈ (សំពត់ក្រាលអង្គុយ) ព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកក្នុងទីណា ? (ទ្រង់អនុញ្ញាតទុក) ក្នុងរឿងបណីតភោជន ក្នុងចីវរក្ខន្ធកៈ ។ សមពិត ដូចដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងចីវរក្ខន្ធកៈនោះថា "ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតសំពត់និសីទនៈ (សំពត់ទ្រាប់អង្គុយ) ដើម្បីរក្សាកាយ ដើម្បីរក្សាចីវរ ដើម្បីរក្សាសេនាសនៈ"[១] ដូច្នេះ ។

[៣៨២] ពីរបទថា សេយ្យថាបិ បុរាណសិព្វោ : ដូចជាជាងស្បែកពីដើម មានសេចក្តីថា ប្រៀបដូចជាងស្បែកចាស់ ៗ ដូចយ៉ាងថា ជាងធ្វើស្បែកចាស់ទាញចេញ គឺ ច្បូតចេញខាងឯណោះខាងឯណេះ ដោយគិតថា យើងនឹងធ្វើស្បែកឱ្យរីកចេញ យ៉ាងណា, សូម្បីព្រះឧទាយីនោះ ក៏ទាញសំពត់និសីទនៈនោះចេញដូច្នោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ចំពោះព្រះឧទយីនោះយ៉ាងនេះ ។

[៣៨៣] ពាក្យថា និសីទនំ ឆាម សទសំ វុច្ចតិ : ដែលហៅ

---

១. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៦២/១៣៩ ។

ថា សំពត់និសីទនៈ នោះ គឺសំដៅយកសំពត់និសីទនៈដែលមានជាយ មានសេចក្តីថា ភិក្ខុក្រាលសំពត់ដូចទីងសន្ទត់ចុះហើយ ច្រៀក ២ កន្លែង ក្នុងសាច់ដែលប្រមាណ ១ ចំអាមដោយចំអាមព្រះសុគត តែត្រង់ជាយម្ខាង ឱ្យមានជាយ ៣, និសីទនៈនោះគេហៅថា សំពត់មានជាយដោយជាយទាំងនោះ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។ សិក្ខាបទនេះមានសមុដ្ឋាន ៦ ។

និសីទនសិក្ខាបទវណ្ណនា ចប់

# ៨. កណ្ឌុបដិច្ឆាទិសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

[៣៨៦] ពាក្យថា កណ្ឌុបដិច្ឆាទិ អនុញ្ញាតា ហោតិ : សំពត់សម្រាប់គ្របកមទ្រង់បានអនុញ្ញាតហើយ មានសេចក្តីថា សំពត់បិទបូស ព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកក្នុងទីណា ? (ទ្រង់អនុញ្ញាតទុក) ក្នុងរឿងព្រះវេឡដ្ឋសីសៈក្នុងចីវរក្ខន្ធកៈ ។ សមពិត ដូចដែលព្រះមានព្រះភាគត្រាស់ទុកក្នុងទីនោះថា “អនុជានាមិ ភិក្ខវេ យស្ស កណ្ឌុ វា

បិឡកា វា អស្សាវោ វា ថុល្លកច្ឆុ វា អាពាធោ តស្ស កណ្ឌុបដិច្ឆាទិ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមានអាពាធ គឺកមឬរមាសក្តី បូសតូចក្តី ទឹករងៃក្តី បូសធំក្តី តថាគតអនុញ្ញាតសំពត់សម្រាប់គ្របកមជាដើមដល់ភិក្ខុនោះ”[១] ដូច្នេះ ។

[៣៨៧] ពាក្យថា យស្ស អធោនាភិ អព្ភជានុមណ្ឌលំ : តាំងពីខាងក្រោមផ្ចិតចុះមក តាំងពី( ខាងលើ )មណ្ឌលឡើងទៅរបស់ភិក្ខុ បានដល់ សំពត់ដែលទ្រង់អនុញ្ញាតដល់ភិក្ខុអាពាធ នៅខាងក្រោមផ្ចិតចុះទៅ លើមណ្ឌលជង្គង់ទាំង ២ ឡើងមក ។ កមរមាស់ ឈ្មោះថា កណ្ឌុ ។ ពកគ្រាប់តូច ៗ មានគ្រាប់លោហិត ឈ្មោះថា បិឡកា ។ ខ្ទុះមិនស្អាតហូរចេញដោយអំណាចបូសដូងប្រមុះ បូសដូងបាត និងទឹកនោមផ្អែមជាដើម ឈ្មោះថា រោគមានខ្ទុះហូរចេញ ។ អាពាធជាគ្រាប់ចុងធំ លោកហៅថា បូសធំ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។ សិក្ខាបទនេះ មានសមុដ្ឋាន ៦ ។

កណ្ឌុបដិច្ឆាទិសិក្ខាបទវណ្ណនា ចប់

---

១. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៦៣/១៤០ ។

## ៩. វស្សិកសាដិកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

[៣៩០] ពាក្យថា វស្សិកសាដិកា អនុញ្ញាតា ហោតិ : សំពត់វស្សកសាដកទ្រង់បានអនុញ្ញាតហើយ មានសេចក្តីថា សំពត់ងូតទឹកភ្លៀង ព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកក្នុងទីណា ? ទ្រង់អនុញ្ញាតទុកក្នុងរឿងនាងវិសាខាក្នុងចីវរក្ខន្ធកៈ ។ សមពិត ដូចដែលត្រាស់ទុកក្នុងចីវរក្ខន្ធកៈនោះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតវស្សិកាដិកៈ (សំពត់ងូតទឹកភ្លៀង)"[១] ដូច្នេះ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។ សិក្ខាបទនេះ មានសមុដ្ឋាន ៦ ។

វស្សិកសាដកសិក្ខាបទវណ្ណនា ចប់

## ១០. សុគតចីវរសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[៣៩៤] បទថា ចតុរង្គុលោមកោ : ទាបជាង ៤ ធ្នាប់ គឺមានខ្នាតទាបជាង ៤ ធ្នាប់ (ព្រះនន្ទៈមានខ្នាតទាបជាង ព្រះសាស្តា ៤ ធ្នាប់) ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។ សិក្ខាបទនេះ មានសមុដ្ឋាន ៦ ។

សុគតចីវរសិក្ខាបទវណ្ណនា ចប់

---

១. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៦១/១៣៦ ។

ចំនួនសិក្ខាបទក្នុងរតនវគ្គនោះ គឺ

១. អន្តេបុរសិក្ខាបទ ការចូលកាន់ព្រះរាជដ្ឋាន
២. រតនសិក្ខាបទ ការរើសរតនៈ
៣. វិកាលគាមប្បវេសនសិក្ខាបទ ការចូលស្រុកក្នុងវេលាវិកាល
៤. សូចិឃរសិក្ខាបទ ការធ្វើបំពង់ម្ជុល
៥. មញ្ចបីឋសិក្ខាបទ ការធ្វើគ្រែតាំងហួសប្រមាណ ( ៨ធ្នាប់ព្រះសុគត )
៦. តូលោនទ្ធសិក្ខាបទ ការធ្វើគ្រែតាំងញាត់ដោយសំឡី
៧. និសីទនសិក្ខាបទ ការធ្វើសំពត់ទ្រាប់អង្គុយហួសប្រមាណ
៨. កណ្ឌុបដិច្ឆាទិសិក្ខាបទ ការធ្វើសំពត់បិទបូសហួសប្រមាណ
៩. វស្សិកសាដិកាសិក្ខាបទ ការធ្វើសំពត់ងូតទឹកភ្លៀងហួសប្រមាណ
១០. សុគតចីវរសិក្ខាបទ ការធ្វើចីវរប៉ុនសុគតចីវរ ។

អដ្ឋកថា រតនវគ្គទី ៩ ចប់ ។

ពាក្យថា ឧទ្ទិដ្ឋា ខោ ជាដើម មានន័យដូចពោលហើយនោះឯង ។

**បាចិត្តិយកណ្ឌវណ្ណនា ចប់**

# បាដិទេសនិយកណ្ឌវណ្ណនា

បាដិទេសនីយធម៌ពួកណា ដែលព្រះធម្មសង្គាហកាចារ្យទាំងឡាយ តាំងទុកក្នុងលំដាប់ពួកខុទ្ទកសិក្ខាបទ ឥឡូវនេះ នឹងមានការពណ៌នាបាដិទេសនីយធម៌ពួកនោះ ដូចតទៅនេះ ៖

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ក្នុងបាដិទេសនីយសិក្ខាបទទី១ មុន ។

## ១. អញ្ញាតិកាយសិក្ខាបទវណ្ណនា

### ការទទួលរបស់ទំពាររបស់ឆាន់អំពីដៃភិក្ខុនីមិនមែនជាញាតិ

[៣៩៩] បទថា បដិក្កមនកាលេ : កាលដែលត្រឡប់មកវិញ គឺ ក្នុងវេលាជាទីត្រាច់បិណ្ឌបាតហើយត្រឡប់មក ។

ពីរបទថា សព្វេវ អគ្គហេសិ : ក៏ទទួលចង្ហាន់ទាំងអស់ គឺ បានទទួលយកភិក្ខាទៅទាំងអស់ ។

បទថា បវេធេន្តី : ដើរធេងធោង គឺ ដើរញាក់ញ័រ ។

បទថា អបេហិ : ចូរចៀសចេញ បានដល់ ចូរថយទៅ ។ អធិប្បាយថា លោកមិនទាន់ឱ្យឱកាស ។

ពាក្យថា គារយ្ហំ អាវុសោ : ម្នាលអាវុសោ ដែលទ្រង់តិះដៀលហើយ ជាដើម ជាពាក្យសម្ដែងអាការដែលភិក្ខុគប្បីសម្ដែងតប ។

[៤០០] បទថា រថិកា : ច្រករហូត គឺ ថ្នល់ ។

បទថា ព្យូហំ : ច្រកទាល់ បានដល់ ច្រកមកដើមមិនធ្លុះទៅជាប់មកឯទៀត ទៅដល់ហើយ ត្រូវបែរត្រឡប់មកវិញ ។

បទថា សង្ឃាដកំ : ទីប្រជុំមក បានដល់ ត្រង់ប្រជុំមកបែកជា ៤ ឬបែកជា ៣ ។

បទថា ឃរំ : ផ្ទះ បានដល់ ផ្ទះនៃត្រកូល ។

បណ្ដាស្ថានទី មានថ្នល់ជាដើមទាំងនេះ ភិក្ខុឈរទទួលក្នុងទីកន្លែងណាមួយជាទុក្កដ ព្រោះទទួល ។ ជាបាដិទេសនីយៈ ដោយករពប់មាត់ដែលលេបចូល ។ សូម្បីសម្រាប់ភិក្ខុអ្នកទទួលក្នុងស្ថានទីមានរោងដំរីជាដើម ក៏ន័យនេះដូចគ្នា ភិក្ខុនីឈរប្រគេនត្រង់ថ្នល់, ភិក្ខុឈរទទួលក្នុងចន្លោះវត្តជាដើម ជាអាបត្តិដូចគ្នា ។

ក៏បណ្ឌិតគប្បីជ្រាបអាបត្តិក្នុងបាដិទេសនីយសិក្ខាបទទី ១ ដោយអំណាចនៃនាងភិក្ខុនីដែលឈរប្រគេនក្នុងចន្លោះស្រុក ដោយព្រះបាលីថា អន្តរឃរំ បវិដ្ឋាយ : ដែលចូលទៅកាន់ចន្លោះផ្ទះ ដូច្នេះ ។ ក៏កន្លែងដែលភិក្ខុឈរមិនជាប្រមាណ ។ ព្រោះហេតុនោះ ប្រសិនបើថា ភិក្ខុឈរក្នុងថ្នល់ជាដើម ទទួលអំពីនាងភិក្ខុនីដែលប្រគេនក្នុងវត្តជាដើម មិនជាអាបត្តិ ។

ពាក្យថា ភិក្ខុទទួលប្រគេន យាមកាលិក សត្តាហកាលិក យាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ, ត្រូវអាបត្តិទុក្កដគ្រប់ ៗម៉ាត់ដែលលេបចូល នេះ ព្រះមានព្រះភាគត្រាស់សំដៅយកកាលិកដែលមិនបានលាយនឹងអាមិស ។ តែក្នុងកាលិកដែលលាយគ្នា មានរសតែមួយ ជាបាជិទេសនីយៈដូចគ្នា ។

ពីរបទថា ឯកតោ ឧបសម្បន្នាយ : ដែលឧបសម្បទាក្នុងសំណាក់សង្ឃតែម្ខាង បានដល់ ភិក្ខុនីដែលឧបសម្បទាក្នុងសំណាក់នៃភិក្ខុនីទាំងឡាយ (ត្រូវអាបត្តិទុក្កដ) ។ តែភិក្ខុទទួលអំពីដៃភិក្ខុនី ដែលឧបសម្បទាក្នុងសំណាក់នៃភិក្ខុទាំងឡាយ (ទៀត) ត្រូវអាបត្តិបាជិទេសនីយៈ តាមសមគួរដល់វត្ថុ ។

[៤០១] ពីរបទថា ទាបេតិ ន ទេតិ : ភិក្ខុនីមិនមែនជាញាតិឱ្យគេប្រគេន នូវខាទនីយៈនិងភោជនីយៈ មិនបានប្រគេនដោយខ្លួនឯង មានសេចក្ដីថា ភិក្ខុនីមិនមែនជាញាតិ ប្រើអ្នកដទៃណាម្នាក់ឱ្យប្រគេន, មិនជាអាបត្តិដល់ភិក្ខុដែលទទួលខាទនីយភោជនីយៈនោះ ។

ពីរបទថា ឧបនិក្ខិបិត្វា ទេតិ : ភិក្ខុនីមិនមែនជាញាតិបានដាក់ចុះនូវខាទនីយៈ និងភោជនីយៈហើយប្រគេន មានសេចក្ដីថា ភិក្ខុនីដាក់លើផែនដី ហើយពោលថា "លោកម្ចាស់ ខ្ញុំព្រះករុណាប្រគេន

ខាទនីយនិងភោជនីយៈនេះ ដល់លោកម្ចាស់” ។ ភិក្ខុទទួលរបស់ដែលភិក្ខុនីប្រគេនយ៉ាងនេះ ព្រមទឹងពោលថា “អរគុណណាស់ ប្អូន ស្រី” ហើយឱ្យភិក្ខុនីនោះឯង ឬប្រើអ្នកដទៃណាម្នាក់ ទទួលប្រគេនហើយឆាន់គួរ ។

អាចារ្យពួកខ្លះពោលថា ក៏បើថា ភិក្ខុនីកាន់យកអាមិសក្នុងបាត្រដែលនៅក្នុងដៃពោលថា “ខ្ញុំព្រះករុណាលះបង់ប្រគេនលោកម្ចាស់” ភិក្ខុទទួលប្រគេនអាមិសដែលភិក្ខុនីកាន់ទុកដោយពោលថា “ប្អូនស្រី” ជាអាបត្តិដល់ភិក្ខុដែលទទួល ។

ពីរបទថា សិក្ខមានាយ សាមណេរិយា : **ភិក្ខុទទួលយក ខាទនីយៈ និងភោជនីយៈអំពីដៃសិក្ខមានា សាមណេរី** មានសេចក្តីថា កាលសិក្ខមានានិងសាមណេរីទាំងនេះប្រគេន មិនជាអាបត្តិដល់ភិក្ខុដែលទទួល ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយស្រួលយល់ទាំងអស់នោះ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អញ្ញាតិកាយសិក្ខាបទវណ្ណនា ចប់

## ២. នប្បជិតាសេយ្យសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

[៤០២] ពាក្យថា អបសក្ក តាវ ភគិនិ : នែនាង ៗ ចូរចៀសចេញ ជាដើម ជាពាក្យសម្ដែងអាការដែលភិក្ខុគប្បីបណ្ដេញចេញ ។

[៤០៥] ក្នុងពាក្យថា អត្តនោ ភត្តំ ទាបេតិ ន ទេតិ : ភិក្ខុនីបង្គាប់ទាយកឱ្យប្រគេនភត្តរបស់ខ្លួន មិនប្រគេនដោយខ្លួនឯង នេះ មានវិនិច្ឆ័យដូច្នេះ ៖

បើថា ភិក្ខុនីប្រគេនភត្តរបស់ខ្លួន មិនជាអាបត្តិដោយសិក្ខាបទនេះឡើយ ជាអាបត្តិដោយសិក្ខាបទមុន ។

ក៏ក្នុងពាក្យថា អញ្ញស្ស[១] ភត្តំ ទេតិ ន ទាបេតិ : ភិក្ខុនីប្រគេនភត្តរបស់ជនដទៃ មិនបានប្រើឱ្យអ្នកដទៃប្រគេន នេះ មានវិនិច្ឆ័យដូច្នេះ ៖

បើភិក្ខុនីប្រើឱ្យប្រគេន គប្បីជាអាបត្តិដោយសិក្ខាបទនេះ, តែកាលភិក្ខុនីប្រគេនខ្លួនឯង មិនជាអាបត្តិដោយសិក្ខាបទនេះនិងសិក្ខាបទមុនទេ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

---

១. បិដកខ្មែរថា អញ្ញេសំ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ ជាកិរិយានិងជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

នបឋមដិកាសេយ្យសិក្ខាបទវណ្ណនា ចប់

# ៣. សេក្ខសម្មតិសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[៤០៦] ពីរបទថា ឧភតោ បសន្នំ **: មានសេចក្តីជ្រះថ្លាទាំងពីរ** នាក់ មានសេចក្តីថា គេជ្រះថ្លាទាំង ២ នាក់ គឺទាំងឧបាសកទាំងឧបាសិកា ។ បានឮថា ក្នុងត្រកូលនោះ ជនសូម្បីទាំង ២ នោះបានជាព្រះសោតាបន្នដូចគ្នា ។

ពីរបទថា ភោគេន ហាយតិ **: តែសាបសូន្យចាកទ្រព្យសម្បត្តិ** មានសេចក្តីថា ក៏ត្រកូលដូច្នេះ សូម្បីមានទ្រព្យ ៨០ កោដិ ក៏រមែងសាបសូន្យចាកភោគទ្រព្យ ។ ព្រោះហេតុអ្វី ? ព្រោះឧបាសកនិងឧបាសិកាក្នុងត្រកូលនោះ មិនរក្សាភោគទ្រព្យ ។

[៤១១] ពាក្យថា យរតោ ឥីហរិត្វា ទេន្តិ : ពួកជនបាននាំយកខាទនីយៈ ឬភោជនីយៈមកអំពីផ្ទះហើយប្រគេន មានសេចក្តីថា ឧបាសកឧបាសិកានោះ នាំទៅកាន់រោងឆាន់ ឬវិហារហើយប្រគេន ។ ប្រសិនបើថា កាលភិក្ខុមិនទាន់មក ពួកគេនាំចេញមកមុនតែម្តង ដាក់ទុកត្រង់ទ្វារហើយប្រគេនដល់ភិក្ខុដែលមកដល់ខាងក្រោយ គួរ ។ លោកពោលទុកក្នុងមហាបច្ចរីថា ក៏ភត្តដែលត្រកូលនោះឃើញភិក្ខុហើយ នាំចេញមកប្រគេនតាំងពីខាងក្នុងផ្ទះ មិនគួរ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សេក្ខសម្មតិសិក្ខាបទវណ្ណនា ចប់

# ៤. អរញ្ញកសេនាសនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

## អធិប្បាយរបស់គួរទំពាដែលគេមិនបានប្រាប់ទុកមុន

[៤១២] ពីរបទថា អវរុទ្ធា ហោន្តិ : ជាមនុស្សខ្ជូចកាច គឺពួកអ្នកបម្រើរបស់ស្តេចសក្យៈទាំងឡាយ ជាអ្នកបង្ករការប្រទូសរ៉ាយ ។

[៤១៤] ពីរបទថា បញ្ចន្នំ បដិសំវិទិតំ : ទោះបីសហធម្មិកបុគ្គលទាំង ៥ បានឱ្យដំណឹងហើយក្តី មានសេចក្តីថា សូម្បីខាទនីយៈភោជនីយៈដែលគេបញ្ជូនសហធម្មិក ៥ អ្នកណាមួយឱ្យទៅប្រាប់ឱ្យដឹងថា "ពួកយើងនឹងនាំខាទនីយៈ ឬ ភោជនីយៈមកប្រគេន" ដូច្នេះ ក៏មិនឈ្មោះថា គេប្រាប់ឱ្យដឹងឡើយ ។

ពាក្យថា អារាមំ អារាមូបចារំ ឋបេត្វា : ក្រៅពីអារាម ឬឧបចារៈរបស់អារាមក្តី មានសេចក្តីថា ទោះជាខាទនីយៈភោជនីយៈដែលគេជួបភិក្ខុដែលចេញទៅចាកពីឧបចារ ក្នុងរវាងមកប្រាប់ឱ្យដឹងក្តី ប្រាប់ដល់ភិក្ខុដែលមកកាន់ស្រុកឱ្យដឹងក្តី វៀរលែងតែអារាម គឺសេនាសនៈព្រៃ និងឧបចារនៃអារាម គឺ សេនាសនៈព្រៃនោះចេញ ក៏គប្បីជ្រាបថា គេមិនប្រាប់ឱ្យដឹងដូចគ្នា ។

ពាក្យថា សចេ សាសង្កំ ហោតិ សាសង្កន្តិ អាចិក្ខិតព្វំ : បើ

ទីប្រកបដោយរង្កៀស ភិក្ខុត្រូវប្រាប់ថា ទីប្រកបដោយរង្កៀស សេចក្ដីថា ភិក្ខុគប្បីប្រាប់ (ពួកអ្នកស្រុក) ព្រោះហេតុអ្វី ? (គប្បីប្រាប់) ដើម្បីដោះពាក្យថា ពួកចោរនៅក្នុងវត្ត ភិក្ខុទាំងឡាយមិនប្រាប់ឱ្យពួកយើងជ្រាប ។

ពាក្យថា ចោរា វត្តញ្ញា មនុស្សា ឥធូបចរន្តិ : ភិក្ខុត្រូវនិយាយនឹងពួកចោរថា ជ្រិតមានពួកមនុស្សគេនឹងចូលមកក្នុងទីនេះ មានសេចក្ដីថា ភិក្ខុទាំងឡាយគប្បីប្រាប់ពួកចោរ ព្រោះហេតុអ្វី ? គប្បីប្រាប់ដើម្បីដោះពាក្យថា ភិក្ខុទាំងឡាយប្រើពួកឧបដ្ឋាករបស់ខ្លួនចាប់ពួកយើង ។

ពាក្យថា យាគុយា បដិសាំវិធិតេ តស្សា បរិវារោ អាហរីយតិ : កាលទាយកឱ្យដំណឹងថា នឹងប្រគេនបបរ តែទាយកនោះ ត្រឡប់ជានាំយកបរិវាររបស់បបរនោះមកប្រគេនវិញ សេចក្ដីថា ពួកអ្នកស្រុកប្រាប់ឱ្យដឹងចំពោះយាគូហើយ នាំវត្ថុយ៉ាងណាមួយមកដោយពោលយ៉ាងនេះថា "តើមានប្រយោជន៍អ្វីដោយយាគូសុទ្ធ ៗ ដែលពួកយើងប្រគេន ពួកយើងនឹងធ្វើសូម្បីទំនិងបាយជាដើម ឱ្យជាបរិវាររបស់យាគូហើយប្រគេន", របស់គ្រប់យ៉ាង ជាការដែលគេប្រាប់ឱ្យដឹងហើយទាំងនោះ ។

សូម្បីក្នុងពាក្យថា ភត្តេន បដិសាំវិធិតេ : កាលទាយកឱ្យដំណឹងថា នឹងប្រគេនភត្ត ជាដើម ក៏ន័យនេះដូចគ្នា ។ ពួកត្រកូល

សូម្បីដទៃបានឮថា ត្រកូលឈ្មោះឯណោះ ធ្វើការប្រាប់ឱ្យដឹងហើយ កំពុងកាន់យកខាទនីយៈជាដើមមក ទើបនាំយកទេយ្យធម៌របស់ខ្លួនចូលរួមមកជាមួយនឹងត្រកូលនោះ សមគួរ ។ ក្នុងកុរុន្ទីពោលថា ត្រកូលទាំងឡាយប្រាប់ឱ្យដឹងចំពោះយាគូហើយ នាំនំឬបាយមកប្រគេន, សូម្បីនំនិងបាយនោះ ក៏គួរ ។

[៤១៦] ពាក្យថា គិលានស្ស : ភិក្ខុមានជម្ងឺ បានដល់ សូម្បីក្នុងខាទនីយៈភោជនីយៈ ដែលគេមិនបានប្រាប់ឱ្យដឹងមុន ក៏មិនជាអាបត្តិដល់ភិក្ខុអាពាធ ។

ពាក្យថា បដិសំវិទិតេ វា គិលានស្ស វា សេសកំ : ភិក្ខុឆាន់ខាទនីយៈ ឬ ភោជនិយដែលសល់អំពីភិក្ខុដែលគេបានឱ្យដំណឹង ឬអំពីភិក្ខុមានជម្ងឺ មានសេចក្តីថា ខាទនីយៈភោជនីយៈ ដែលគេប្រាប់ឱ្យដឹងហើយនាំមកប្រគេន ដើម្បីប្រយោជន៍ដល់ភិក្ខុមួយរូប, សូម្បីភិក្ខុដទៃនឹងឆាន់របស់ជារបស់សល់នៃភិក្ខុនោះ គួរ ។ ខាទនីយៈ ភោជនីយៈជារបស់ដែលគេប្រាប់ឱ្យដឹងហើយ នាំមកប្រគេនជាច្រើន ដល់ភិក្ខុ ៤ រូប ឬ ៥ រូប, ពួកលោកប្រាថ្នា នឹងប្រគេនសូម្បីដល់ភិក្ខុពួកដទៃ សូម្បីខាទនីយៈ ភោជនីយៈនោះ ក៏ជាសំណល់របស់ភិក្ខុដែលបានទទួលនិមន្តទុកដូចគ្នា ទើបសមគួរសូម្បីដល់ភិក្ខុគ្រប់រូប ។ បើរបស់នោះមានបរិបូណ៌ពោរពាសតែម្តង, រក្សាទុកឱ្យផុតសន្និធិហើយ រមែងគួរសូម្បី

ក្នុងថ្ងៃស្អែក ។ សូម្បីក្នុងរបស់ជារបស់សល់ដែលគេនាំមកប្រគេនដល់ភិក្ខុអាពាធ ក៏ន័យនេះដូចគ្នា ។

ចំណែកខាទនីយភោជនីយៈដែលគេមិនបានប្រាប់ឱ្យដឹងឡើយ នាំមកប្រគេន ភិក្ខុគប្បីបញ្ជូនទៅកាន់ខាងក្រៅវត្ត ហើយឱ្យធ្វើជារបស់ប្រាប់ឱ្យដឹងមុនហើយ ទើបឱ្យនាំត្រឡប់មក ។ ឬពួកភិក្ខុគប្បីទៅទទួលយកក្នុងចន្លោះមកក៏បាន ។ សូម្បីរបស់ណាពួកអ្នកស្រុកដើរឆ្លងកាត់វត្តនាំមកប្រគេន ឬពួកព្រានព្រៃជាដើម នាំមកប្រគេនអំពីព្រៃ, របស់នោះភិក្ខុគប្បីឱ្យគេធ្វើឱ្យជារបស់ដែលគេប្រាប់ឱ្យដឹងដោយន័យមុននុ៎ះឯង ។

ពីរបទថា តត្ថ ជាតកំ : **ដែលដុះនៅខាងក្នុងអារាមនោះ** មានសេចក្តីថា ភិក្ខុឆាន់របស់ដែលកើតឡើងក្នុងវត្តនុ៎ះឯង មានមូលខាទនីយៈជាដើម ដែលអ្នកដទៃធ្វើឱ្យជាកប្បិយហើយប្រគេន មិនជាអាបត្តិ ។ ក៏បើថា ពួកអ្នកស្រុកនាំយករបស់នោះទៅកាន់ស្រុក ចំអិនសម្លហើយនាំមកប្រគេន មិនគួរ ។ ភិក្ខុគប្បីឱ្យគេធ្វើឱ្យជារបស់ប្រាប់ឱ្យដឹងជាមុន ។ ពាក្យដែលសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ ជាកិរិយានិងជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អរញ្ញកសេនាសនសិក្ខាបទវណ្ណនា ចប់

ចំនួនសិក្ខាបទក្នុងបាដិទេសនីយនោះ គឺ

១. អញ្ញាតិកាយសិក្ខាបទ ការទទួលខាទនីយ ឬភោជនីយអំពីដៃភិក្ខុនី មិនមែនញាតិក្នុងចន្លោះផ្ទះ

២. នបរ្បជិកាសេយ្យសិក្ខាបទ ការមិនបានពោលបណ្ដេញភិក្ខុនី ដែលឈរ បង្គាប់គេ

៣. សេក្ខសម្មតិសិក្ខាបទ ការសន្មតិត្រកូលដែលជាព្រះសេក្ខ

៤. អរញ្ញកសេនាសនសិក្ខាបទ ការនៅក្នុងសេនាសនៈព្រៃ

## បាដិទេសនីយវណ្ណនា ចប់

# សេក្ខិយកណ្ឌវណ្ណនា

សិក្ខាបទពួកណា ដែលព្រះសម្មាសម្ពុទ្ធ មានសិក្ខាដែលទ្រង់សិក្សាមក ត្រាស់ហៅថា សេក្ខិយៈ ឥឡូវនេះ នឹងមានលំដាប់ការពណ៌នាសេក្ខិយៈ សូម្បីទាំងនោះ ដូចតទៅនេះ ។ គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសេក្ខិយៈទាំងនោះ ដូចតទៅនេះ ៖

## បរិមណ្ឌលវគ្គទី ១

### សារុប្បៈ មាន ២៦

[៤១៨] បទថា បរិមណ្ឌលំ : ជាបរិមណ្ឌល គឺ ជាមណ្ឌលដោយជុំវិញ ។

ពីរបទថា នាភិមណ្ឌលំ ជាណុមណ្ឌលំ : មណ្ឌលផ្ចិត មណ្ឌលជង្គង់ មានសេចក្តីថា ភិក្ខុស្លៀកបិទលើមណ្ឌលផ្ចិត ក្រោមមណ្ឌលជង្គង់ឱ្យសំពត់ស្លៀកស្រូយចុះមកខាងក្រោមមណ្ឌលជង្គង់ តាំងពីឆ្អឹងស្មងទៅប្រមាណ ៨ ធ្នាប់ ។ លោកពិន័យទុក្កដដល់ភិក្ខុដែលស្លៀកឱ្យស្រូយចុះលើសពីប្រមាណនោះ ។

ក្នុងមហាបច្ចរី លោកពោលថា សម្រាប់ភិក្ខុដែលអង្គុយ នឹងបិទ

បាំងខាងក្រោមមណ្ឌលជង្គង់ប្រមាណ ៤ធ្នាប់[១] ។ តែសំពត់ស្លៀករបស់ភិក្ខុដែលស្លៀកយ៉ាងនេះបានប្រមាណ ទើបគួរ ។

សំពត់ស្លៀកនោះ មានប្រមាណដូចតទៅនេះ ៖

ផ្នែកបណ្ដោយ ៥ ហត្ថក្ដាប់ ផ្នែកទទឹង ២ហត្ថ ១ចំអាម ។ តែព្រោះមិនបានសំពត់ស្លៀកមានប្រមាណដូច្នោះ សូម្បីសំពត់ស្លៀកខាតទទឹង ២ហត្ថ ក៏គួរ ដើម្បីបិទមណ្ឌលជង្គង់បាន, តែអាចដើម្បីបិទមណ្ឌលផ្ចិតបានសូម្បីដោយចីវរឯង ។ បណ្ដាចីវរមួយជាន់ និង ២ជាន់នោះ ចីវរមួយជាន់សូម្បីដែលភិក្ខុស្លៀកហើយយ៉ាងនេះ រមែងមិនតាំងនៅក្នុងទីបាន, តែចីវរ ២ ជាន់ ទើបនឹងតាំងនៅបាន ។

ក្នុងពាក្យថា ឱលម្ពេន្ដោ និវាសេតិ អាបត្តិ ទុក្កដស្ស : ហើយស្លៀកឱ្យស្ទុយ ត្រូវអាបត្តិទុក្កដ នេះ មានវិនិច្ឆ័យដូច្នេះ ៖

មិនមែនជាទុក្កដ ដល់ភិក្ខុដែលស្លៀកស្ទុយលយខាងក្រោយតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីភិក្ខុដែលស្លៀកប្រភេទដែលមានទោសយ៉ាងដទៃក៏ត្រូវអាបត្តិទុក្កដដែរ ដែលត្រាស់ទុកក្នុងខន្ធកៈដោយន័យជាដើមថា "សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុស្លៀកស្បង់ដូចសំលៀករបស់គ្រហស្ថ គឺស្លៀកឱ្យស្ទុយមុខ ដូចប្រមោយដំរី (ដូចសំលៀកមនុស្សស្រីក្នុង

---

១. ពេលអង្គុយទើចមកនៅសល់តែ ៤ ធ្នាប់ ។

ចោទ្យកប្រទេស ) ស្លៀកមានសណ្ឋានដូចកន្ទុយត្រី ស្លៀកឱ្យមានជ្រុង៤ (ស្លៀកបញ្ចេញជ្រុងស្បង់ទាំង៤ឱ្យប្រាកដ ) ស្លៀកដោយអាការដូចធាងត្នោត (ស្លៀកសំឡុយសាដកឱ្យស្រុយចុះ) ស្លៀកអង្កាញ់ឱ្យមានផ្នត់ច្រើន"[១] ដូច្នេះ, ទោសការស្លៀកទាំងអស់នោះ រមែងមិនមានដល់ភិក្ខុដែលស្លៀកជាបរិមណ្ឌល ដោយន័យដូចពោលហើយនុ៎ះឯង ។ នេះសេចក្ដីសង្ខេបក្នុងសិក្ខាបទនេះ ។ ចំណែកសេចក្ដីពិស្ដារ នឹងមានច្បាស់ក្នុងខន្ធកៈនុ៎ះឯង ។

បទថា **អសញ្ចិច្ច : ភិក្ខុមិនក្លែង** មានសេចក្ដីថា ភិក្ខុដែលមិនក្លែងស្លៀកយ៉ាងនេះថា យើងនឹងស្លៀកឱ្យស្រុយលយខាងមុខ ឬខាងក្រោយ គឺតាំងចិត្តថា នឹងស្លៀកឱ្យជាបរិមណ្ឌលនោះឯង តែស្លៀកខុសទៅមិនបានបរិមណ្ឌល មិនជាអាបត្តិ ។

បទថា **អសតិយា : ភិក្ខុមិនមានសតិ បានដល់** សូម្បីភិក្ខុដែលបញ្ជូនចិត្តទៅទីដទៃស្លៀកយ៉ាងនោះ ក៏មិនជាអាបត្តិ ។

ក្នុងពាក្យថា **អជានន្តស្ស : ភិក្ខុមិនដឹងខ្លួន** នេះ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុដែលមិនដឹងទំនៀមការស្លៀក ក៏មិនផុតអាបត្តិ ។ ពិតណាស់

---

១. វិន. ចុល្ល. ខុទ្ទកវត្ថុក្ខន្ធក. ១០. ២៧៩/២២៤ ។

ភិក្ខុគប្បីរៀនយកធម្មទំនៀមការស្លៀកឱ្យល្អ, ការមិនរៀនយកធម្មទំនៀមការស្លៀកនោះឯង ចាត់ជាសេចក្តីមិនអើពើនោះ គួរដល់ភិក្ខុដែលក្លែងមិនរៀនប៉ុណ្ណោះ ។ ព្រោះដូច្នោះ ភិក្ខុណាសូម្បីរៀនយកទំនៀមហើយមិនទាន់ស្គាល់ថា សំពត់ស្លៀកខើចឡើង ឬស្រុយចុះ, មិនជាអាបត្តិដល់ភិក្ខុនោះ ។ តែក្នុងកុរុន្ទីលោកពោលថា ភិក្ខុដែលមិនដឹងនូវការស្លៀកឱ្យជាបរិមណ្ឌល ក៏មិនជាអាបត្តិ ចំណែកភិក្ខុដែលមានកំភួនស្វិតក្តី មានពងសាច់កំភួន ស្មងធំក្តី នឹងស្លៀកឱ្យស្រុយចុះអំពីមណ្ឌលជង្គង់លើសពី ៨ ធ្នាប់ ដើម្បីត្រូវការឱ្យសមរម្យ ក៏គួរ ។

បទថា គិលានស្ស : **ភិក្ខុមានជម្ងឺ** មានសេចក្តីថា ភិក្ខុមានដំបៅកើតត្រង់ស្មង ឬត្រង់ជើងនឹងស្លៀកឱ្យខើចឡើង ឬឱ្យស្រុយចុះ គួរ ។

បទថា អាបទាសុ : **ភិក្ខុមានសេចក្តីអន្តរាយ** មានសេចក្តីថា ម្រឹគកាចក្តី ពួកចោរក្តី ដេញជាប់តាមមក, ក្នុងអន្តរាយបែបនេះ មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត ទុក្ខវេទនា ដូច្នេះឯង ។

ព្រះបុស្សទេវត្ថេរ ពោលថា ជាសចិត្តកៈ បណ្ណត្តិវជ្ជៈ មានវេទនា ៣, ចំណែកព្រះឧបតិស្សត្ថេរពោលថា ជាលោកវជ្ជៈ អកុសលចិត្ត ទុក្ខ

វេទនា ព្រោះលោកអាស្រ័យសេចក្តីមិនអើពើពោលទុក ។

[៤១៩] ពីរបទថា **បរិមណ្ឌលំ ឆាទេតព្វំ :** **ភិក្ខុគប្បីដណ្តប់ឱ្យជាបរិមណ្ឌល** មានសេចក្តីថា ភិក្ខុមិនដណ្តប់ដូចគ្រហស្ថ មានប្រការច្រើនយ៉ាងនេះថា "សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដណ្តប់ដូចគ្រហស្ថ"[១] ជាដើម គប្បីធ្វើជ្រុងទាំង២ របស់ចីវរឱ្យស្មើគ្នា ដណ្តប់ឱ្យជាបរិមណ្ឌល ត្រូវធម្មទំនៀមការដណ្តប់ ដោយន័យដូចពោលហើយ ក្នុងសិក្ខាបទនេះឯង ។ ក៏សិក្ខាបទទាំង២ នេះត្រាស់ទុកដោយមិនប្លែកគ្នា ។ ព្រោះដូច្នោះ ភិក្ខុគប្បីស្លៀកនិងគប្បីដណ្តប់ឱ្យជាបរិមណ្ឌលនុ៎ះឯង ទាំងក្នុងវត្តទាំងក្នុងចន្លោះស្រុក ដូច្នេះឯង ។ សមុដ្ឋានជាដើម ព្រមទាំងថេរវាទ បណ្ឌិតគប្បីជ្រាប ដោយន័យដូចបានពោលហើយ ក្នុងសិក្ខាបទមុននុ៎ះឯង ។

[៤២០] ពីរបទថា **កាយំ វិវរិត្វា :** **បើកចំហនូវកាយ** គឺបើកដងខ្លួនខ្លះ ទ្រូងខ្លះ ។

បទថា **សុបដិច្ឆន្នេន :** **ភិក្ខុត្រូវបិទបាំងឱ្យល្អ** មានសេចក្តីថា មិនមែនថា ឃុំគ្របក្បាល, តាមសេចក្តីពិត ភិក្ខុគប្បីដណ្តប់ដាក់ក្តំហើយ យកជាយអនុវាទទាំង ២ ខាងបិទកបាត់មុំទាំង ២ (នៃចីវរ) ឱ្យស្មើគ្នា មូរចូលមកបិទដរាបដល់កដៃហើយ ទើបទៅក្នុងចន្លោះស្រុក ។

---

១. វិន. ចុល្ល. ខុទ្ទកវត្ថុក្ខន្ធក. ១០. ២៨០/២២៥ ។

[៤២១] សេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី២* គប្បីជ្រាបថា ៖

ភិក្ខុគប្បីអង្គុយបើកសិរ្សៈតាំងពីក បើកដៃទាំង ២ តាំងពីកដៃ បើកជើងទាំង ២ តាំងពីស្មង (ក្នុងចន្លោះស្រុក) ។

បទថា វាសូបគតស្ស : ភិក្ខុចូលទៅកាន់លំនៅ មានសេចក្ដីថា ភិក្ខុដែលចូលទៅ ដើម្បីនៅសម្រាកដល់ទីនអង្គុយបើកកាយខាងក្នុងពេលថ្ងៃ ឬ ពេលយប់ ក៏មិនជាអាបត្តិ ។

[៤២២] បទថា សុសំវុតោ : ភិក្ខុត្រូវតែសង្រួមឱ្យល្អ បានដល់មិនរពឹសដៃ ឬជើង, សេចក្ដីថា ជាអ្នករៀបរយ (ហ្វឹកហាត់មកល្អ) ។

[៤២៤] បទថា ឱក្ខិត្តចក្ខុ : មានចក្ខុសម្លឹងចុះ គឺ ជាអ្នកមានចក្ខុសម្លឹងចុះខាងក្រោម ។

ពីរបទថា យុគមត្តំ បេក្ខន្តេន : ក្រឡេកមើលត្រឹមតែមួយជួរនឹម មានសេចក្ដីថា សេះអាជានេយ្យដែលទូន្មានហើយ ដែលគេទឹមទុកត្រង់នឹម រមែងសម្លឹងមើលមួយជួរនឹម គឺ ក្រឡេកមើលភាគផែនដីទៅខាងមុខប្រមាណ ៤ ហត្ថ, សូម្បីភិក្ខុនេះ ក៏គប្បីដើរក្រឡេកមើលចម្ងាយប្រមាណប៉ុណ្ណោះ ។

ពាក្យថា យោ អនាទរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ : ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយក្រឡេកមើលត្រង់ទីនោះ ៗ

* . សិក្ខាបទទី២នៃសុប្បដិច្ឆន្ន, ច្បាប់ខ្លះ តតិយសិក្ខាបទ ។

មានសេចក្ដីថា ភិក្ខុណាដើរក្រឡេកមើលទិសាភាគ ប្រាសាទ ផ្ទះកំពូល ថ្នល់នោះ ៗទៅបណ្ដើរ, ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ តែបើឈប់ឈរក្នុងទីមួយកន្លែង ត្រូតមើលថា មិនមានអន្តរាយអំពីដំរី សេះជាដើម គួរ ។ សូម្បីភិក្ខុដែលនឹងអង្គុយ ក៏គួរអង្គុយមានចក្ខុទតចុះដូចគ្នា ។

[៤២៦] បទថា ឧក្ខិត្តកាយ : **សើយចីវរ** គឺ មានការសើយចីវរឡើង ។ ពាក្យនេះ ជាតតិយាវិភត្តិ ចុះក្នុងលក្ខណៈនៃឥត្ថម្ភូត ។ អធិប្បាយថា ជាអ្នកមានចីវរសើយឡើងតែម្ខាង ឬទាំងពីរខាង ។ ដែលភិក្ខុកុំគប្បីដើរទៅយ៉ាងនោះ តាំងពីខាងក្នុងសរសេរខឿន (ខាងក្នុងធរណីទ្វារ) ។ ក្នុងវេលាអង្គុយហើយ សូម្បីកាលនឹងនាំធម្មក្រកចេញ កុំសើយចីវរឡើងមុនហើយ ទើបនាំចេញ ដូច្នេះឯង ។

បរិមណ្ឌលវគ្គទី ១ ចប់

# ឧជ្ជគ្ឃិកវគ្គទី ២

[៤២៨] បទថា ឧជ្ជគ្ឃិកាយ : **សើចខ្លាំង** គឺ សើចលាន់ឮ ។ ក្នុងបទថា ឧជ្ជគ្ឃិកាយនេះ ជាតតិយាវិភត្តិ ដោយន័យដូចបានពោលហើយដូចគ្នា ។

[៤៣០] ក្នុងពាក្យថា អប្បសទ្ទោ អន្តរឃរេ : មានសំឡេង

តិចក្នុងចន្លោះផ្ទះ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ចាត់ថា ជាអ្នកមានសំឡេងតិចដោយប្រមាណប៉ុនណា ? បណ្ដាព្រះថេរៈទាំងឡាយអង្គុយក្នុងផ្ទះទំហំ ១២ហត្ថយ៉ាងនេះ គឺ ព្រះសង្ឃថេរៈអង្គុយខាងដើម ព្រះថេរៈទី២ អង្គុយនៅកណ្ដាល ព្រះថេរៈទី៣ អង្គុយខាងចុង, ព្រះសង្ឃថេរៈ ប្រឹក្សាទីងព្រះថេរៈទី២ ។ ព្រះថេរៈទី២ ស្ដាប់សំឡេងនិងកំណត់ពាក្យរបស់ព្រះសង្ឃថេរៈនោះបាន ។ ចំណែកព្រះថេរៈទី៣ បានឮសំឡេងកំណត់ពាក្យមិនបាន ។ ដោយប្រមាណត្រឹមប៉ុណ្ណោះ ចាត់ជាអ្នកមានសំឡេងតិច ។ តែបើថា ព្រះថេរៈទី៣ កំណត់ពាក្យ បានឈ្មោះថា ជាអ្នកមានសំឡេងខ្លាំងនោះឯង ។

[៤៣២] ពីរបទថា កាយំ បគ្គហេត្វា : ផ្គត់ផ្គងកាយ មានសេចក្ដីថា ភិក្ខុគប្បីដើរ និងគប្បីអង្គុយ មិនយោគយ្លីងយ្លោង គឺដោយកាយត្រង់ ដោយឥរិយាបថរៀបរយ ។

[៤៣៤] ពីរបទថា ពាហុំ បគ្គហេត្វា : ត្រូវដាក់ដៃឱ្យស្រួល គឺ ធ្វើដៃឱ្យស្មៀម ៗ ។

[៤៣៦] ពីរបទថា សីសំ បគ្គហេត្វា : ត្រូវតែផ្គងតម្រង់ក្បាលឱ្យស្រួល គឺ តាំងសិរ្សៈមិនផ្ទៀងងាកទៅមក បានដល់ ឱ្យត្រង់ (មិនអង្គុយបត់ក) ។

ខុជ្ជគ្ឃិកវគ្គទី ២ ចប់

## ខម្ពកវគ្គទី ៣

[៤៣៨] ការលើកដៃដាក់លើចង្កេះធ្វើដូចជន្ទល់ ឈ្មោះថា ស៊ីមចង្កេះ (ប្រត់ចង្កេះ) ។

[៤៤០] បទថា ឱគុណ្ឋិតោ : ទទូរក្បាល គឺ គ្របក្បាល ។

[៤៤២] កិរិយាដែលភិក្ខុលើកកែងជើងទាំង ២ ចុចផែនដីដោយចុងជើងទាំង ២ ឬចំអើតចុងជើងទាំង ២ ចុចផែនដីដោយកែងជើងទាំង ២ ដើរទៅ ព្រះមានព្រះភាគត្រាស់ថា ឧក្កុដិកា : ចំអើតជើង ។ ក្នុងពាក្យថា ឧក្កុដិកាយ នេះ ក៏តតិយាវិភត្តិ ក្នុងពាក្យថា ឧក្កុដិកាយ នេះ មានលក្ខណៈដូចពោលហើយនុ៎ះឯង ។

[៤៤៣] សូម្បីការរឹតជង្គង់ដោយខ្សែយោគ ក៏ឈ្មោះថា ការរឹតជង្គង់ដោយសំពត់ដូចគ្នា ក្នុងពាក្យថា ទុស្សបល្លត្ថិកាយ : ដោយរឹតនឹងសំពត់ នេះ ។

## ភោជនប្បដិសំយុត្ត ៣០

[៤៤៤] បទថា សក្កច្ចំ : ដោយគោរព គឺ តាំងសតិទុក ។

[៤៤៥] បទថា អាគិរន្តេបិ : កាលបើមានជនកំពុងដាក់បាត្រក្តី គឺ សូម្បីកាលគេកំពុងប្រគេនបិណ្ឌបាត ។

បទថា បត្តសញ្ញី : សម្គាល់ក្នុងបាត្រ គឺ ធ្វើសេចក្តីសម្គាល់ក្នុងបាត្រ ។

[៤៤៦] បិណ្ឌបាតដែលមានម្ហូបប្រមាណប៉ុនចំណែកទី ៤ នៃបាយ ឈ្មោះថា បិណ្ឌបាតមានស្ទូបៈស្មើគ្នា ។

និងក្នុងមហាបច្ចរីលោកពោលទុកថា ស្ទម្បីសម្លដែលផ្សំដោយសណ្តែកជាដើម ក៏ដល់ការសង្គ្រោះចូលក្នុងពាក្យថា មុគ្គសូបោ មាសសូបោ : សម្លសណ្តែកបាយ១ សម្លសណ្តែករាជមាស១ នេះ ។ ម្ហូបមានរសនាំឱ្យត្រេកអរ[១] សម្លបន្លែផ្កា រសត្រី និងរសសាច់ជាដើម ដែលនៅសល់ វៀរម្ហូប ២ យ៉ាងចេញ គប្បីជ្រាបថា រសរស (ម្ហូបប្រភេទផ្សេង ៗ) ក្នុងពាក្យថា រសរសេ នេះ ។ មិនជាអាបត្តិដល់ភិក្ខុដែលទទួលម្ហូបប្រភេទផ្សេង ៗនោះស្ទម្បីច្រើន ។

១. សារត្ថទីបនី ពន្យល់ថា ឱលោណីតិ ឯកា ព្យញ្ជនវិកតិ ។ យោ កោចិ សុទ្ធោ កញ្ជិកតក្កាទិរសោតិ កេចិ : ម្ហូបមួយប្រភេទ ឈ្មោះថា ឱលោណី ។ អាចារ្យពួកខ្លះ ពោលថា បានដល់ រសទឹកបាយនិងខ្ទាញ់ជាដើមសុទ្ធ ៗ ណាមួយ ។ វិមតិ. ពន្យល់ដូចគ្នាថា ឱលោណីតិ ឯកា ព្យញ្ជនវិកតិ ។ កញ្ជិកតក្កាទិរសោតិ កេចិ ។ អត្ថយោជនាថា អវលិយតិ សាទិយតីតិ ឱលោណំ លិ សាទនេ ណាប្បច្ចយោ : ម្ហូបដែលឈ្មោះថា ឱលោណៈ ដោយ

អត្ថថា គួរឆ្ងាញ់ គួរត្រេកអរ លិធាតុ ចុះក្នុងអត្ថថា គួរត្រេកអរ ចុះ ណ បច្ច័យ ។

[៤៤៧] បទថា សមតិត្តិកំ : ស្មើត្រឹមកណ្តាប់មាត់បាត្រ បានដល់ ពេញស្មើ គឺ ប្រៀបស្មើ ។ ក្នុងពាក្យថា ថូបីកតំ បិណ្ឌបាតំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស : ទទួលបិណ្ឌបាត្រឱ្យកំពុងលើសកណ្តាប់មាត់បាត្រទៅ នេះ សេចក្តីថា បិណ្ឌបាតដែលភិក្ខុធ្វើឱ្យហៀរស្នាមកណ្តាប់ ខាងក្នុងមាត់បាត្រឡើងមក ឈ្មោះថា ឱ្យកំពុងលើសកណ្តាប់មាត់បាត្រ គឺ ដាក់បន្ថែមឱ្យពេញណែនក្នុងបាត្រ ។ ភិក្ខុមិនទទួលបិណ្ឌបាតដែលធ្វើយ៉ាងនោះ គប្បីទទួលល្មមប្រមាណស្មើស្នាមខាងក្នុងកណ្តាប់មាត់បាត្រ ។

ក្នុងពាក្យថា ថូបីកតំ : ឱ្យកំពុងលើសកណ្តាប់មាត់បាត្រ នោះ ព្រះអភយត្ថេរពោលថា ដែលឈ្មោះថា ធ្វើឱ្យហៀរបាត្រ បានដល់ ធ្វើ (ឱ្យហៀរបាត្រ) ដោយភោជនទាំង ៥ ។ តែព្រះចូឡនាគថេរៈអ្នកទ្រទ្រង់ត្រៃបិដកពោលសូត្រនេះថា "យាគូក្តី ភត្តក្តី ខាទនីយៈក្តី ដុំម្សៅក្តី ឈើជម្រះធ្មេញក្តី អំបោះជាយសំពត់ក្តី ឈ្មោះថា បិណ្ឌបាត" ហើយពោលថា "សូម្បីអំបោះជាយសំពត់ធ្វើឱ្យកំពុងជាកំពូលដូចសថូប ក៏មិនគួរ" ។

ពួកភិក្ខុ ស្តាប់ពាក្យរបស់ព្រះថេរៈទាំងនោះហើយ ទៅភេហាណជនបទ ទូលសួរព្រះចូឡសុមនត្ថេរថា "លោកដ៏មានអាយុ បិណ្ឌបាតដែលហៀរបាត្រ តើកំណត់ដោយអ្វី ?" និងបានទូលប្រាប់ឱ្យជ្រាបវាទៈ

របស់ព្រះថេរៈទាំងអស់នោះ ។

ព្រះថេរៈបានស្តាប់ហើយពោលថា "ចំណែតម្តងហើយ ព្រះចូឡនាគ បានឃ្លាតអំពីសាសនា, ឱ ព្រះចូឡនាគនោះ បានឱ្យមកដល់ភិក្ខុជាច្រើន, យើងបង្រៀនវិន័យឱ្យដល់ព្រះចូឡនាគនេះដល់ ៧ ដង ក៏មិនបានពោល យ៉ាងនេះត្រឹមតែម្តង, ព្រះចូឡនាគនេះបានមកពីណា ទើបពោលយ៉ាង នេះ" ។ ពួកភិក្ខុសូមអង្វរព្រះថេរៈថា "មេត្តាប្រាប់ក្នុងពេលឥឡូវនេះចុះ លោកម្ចាស់ (បិណ្ឌបាតដែលហៀរបាត្រ) តើកំណត់ដោយអ្វី ?" ព្រះ ថេរៈពោលថា "កំណត់ដោយយាវកាលិកណាៈ អ្នកមានអាយុ" ព្រោះ ដូច្នោះ យាគុក្តី ភត្តក្តី ផលាផលក្តី ដែលជាអាមិសយ៉ាងណាមួយ ភិក្ខុ គប្បីទទួលស្មើ (កណ្តាប់មាត់បាត្រ) ប៉ុណ្ណោះ ។ ក៏ឯយាគូនិងភត្ត ឬ ផលាផលនោះគប្បីទទួលស្មើ (កណ្តាប់មាត់បាត្រ) ដោយបាត្រដែលគួរ អធិដ្ឋាន, តែដោយបាត្រក្រៅនេះ សូម្បីទទួលឱ្យកំពុងហៀរឡើងមកដូច ជាកំពូលសថូប ក៏គួរ ។ ចំណែកយាមកាលិក សត្តាហកាលិក និង យាវជីវិក សូម្បីទទួលឱ្យកំពុងដូចកំពូលសថូប ដោយបាត្រគួរអធិដ្ឋាន ក៏បាន ។ ភិក្ខុទទួលភត្តាហារដោយបាត្រ ២ ដាក់ចូលឱ្យពេញមួយ បាត្រហើយបញ្ជូនទៅកាន់វិហារ គួរ ។ តែក្នុងមហាបច្ចរីពោលថា របស់ ស៊ីមានទំ កង់អំពៅ ផ្លែឈើតូចធំជាដើម ដែលគេដាក់ចូលក្នុង បាត្រចន្លោះនៅខាងក្រោម មិនឈ្មោះថា ធ្វើឱ្យហៀរបាត្រ ។

ពួកអ្នកស្រុកប្រគេនបិណ្ឌបាត ដាក់កន្ទោងនំទុក (ខាងលើ) ចាត់ថា ទទួលហៀរបាត្រដូចគ្នា ។ តែកម្រងផ្កាឈើ និងកួងផ្លែក្រវាញ ផ្លែម្ទេសជាដើម ដែលគេប្រគេនដាក់ទុក (ខាងលើ) មិនចាត់ថា ទទួលហៀរបាត្រ ។ ភិក្ខុទទួលពេញហើយដាក់ថាស ឬស្លឹកឈើខាងលើបាយ មិនឈ្មោះថា ទទួលហៀរបាត្រ ។ សូម្បីក្នុងកុរុន្ទីក៏ពោលទុកថា ពួកទាយកដាក់បាយចុះលើថាស ឬលើស្លឹកឈើហើយ ដាក់ប្រគេនថាស ឬស្លឹកឈើហើយ ដាក់ប្រគេនថាស ឬស្លឹកឈើនោះលើទីបំផុតបាត្រ (លើគម្របបាត្រ), ភាជនៈចែកគ្នាគួរ ។ ភិក្ខុអាពាធមិនមានក្នុងអនាបត្តិវារក្នុងសិក្ខាបទនេះ ។ ព្រោះដូច្នោះ ភោជនដែលធ្វើឱ្យកំពុងឡើងដូចសថូប (ដែលទទួលហៀរបាត្រ) មិនគួរសូម្បីដល់ភិក្ខុអាពាធ ។ នឹងទទួលប្រគេនពាសពេញក្នុងភាជនៈទូទៅ ក៏មិនគួរ ។ តែភោជនដែលទទួលប្រគេនទុកហើយ នឹងទទួលប្រគេនថ្មីឱ្យរៀបរយមុនហើយទើបឆាន់ គួរពិត ដូច្នេះឯង ។

ខម្ភកវគ្គទី ៣ ចប់

# សក្កច្ចវគ្គទី ៤

[៤៤៨] សូម្បីក្នុងពាក្យថា សក្កច្ចំ : ដោយគោរព នេះ ក៏ជាអាបត្តិ ព្រោះទទួលដោយមិនបានអើពើដូចគ្នា ។ តែរបស់ដែលទទួលទុកជាការទទួលប្រគេនហើយនោះឯង ។

បទថា សក្កច្ចំ និងបទថា បត្តសញ្ញី ទាំង ២ មានន័យដូចពោលហើយនុ៎ះឯង ។

[៤៥០] បទថា សបទានំ : រាចឱ្យស្មើ បានដល់ តាមលំដាប់មិនធ្វើឱ្យគ្មានរបៀបក្នុងបិណ្ឌបាតនោះ ៗ ពាក្យដែលគួរនឹងពោលក្នុងបិណ្ឌបាត មានសូបៈស្មើគ្នា មានន័យដូចពោលហើយដូចគ្នា ។

[៤៥២] បទថា ថូបតោ : ត្រង់កំពូលបាយ គឺ ពីកំពូលសេចក្តីថា តាំងពីកណ្តាល ។

[៤៥៣] ពីរបទថា បដិច្ឆាទេត្វា ទេន្តិ : គេលុបសម្ល ឬម្ហូបហើយប្រគេន មានសេចក្តីថា ពួកម្ចាស់របស់កប់ចូលក្នុងបាយ ទុកប្រគេនក្នុងសម័យដែលគេហាមមិនឱ្យសម្លាប់សត្វជាដើម ។ ក្នុងរឿងវិញ្ញត្តិមិនមានពាក្យដែលនឹងគប្បីពោល ។ សូម្បីក្នុងឧជ្ឈានសញ្ញីសិក្ខាបទនេះ ភិក្ខុអាពាធក៏មិនផុត ។

[៤៥៧] ពីរបទថា នាតិមហន្តោ កវឡោ : ពំនូតបាយធំពេកមានសេចក្តីថា ពងសត្វក្ងោកធំពេក ឯពងមាន់ក៏តូចពេក, ពំនូតបាយមាន

ទំហំខ្នាតកណ្តាល រវាងពងក្រោកនិងពងមាន់នោះ (ឈ្មោះថា ពំនូតបាយមិនធំពេក) ។

បណ្ឌិតគប្បីកាន់យកខាទនីយៈគ្រប់យ៉ាង មានមូលខាទនីយៈជាដើម ក្នុងពាក្យថា ខជ្ជកេ នេះ ។

សក្កច្ចវគ្គទី ៤ ចប់

# កពឡវគ្គទី ៥

[៤៥៩] បទថា អនាហដេ : មិនទាន់មកដល់ គឺ នាំមកមិនទាន់ដល់ ។ សេចក្តីថា មិនទាន់ដល់ប្រហោងមាត់ ។

[៤៦០] ពីរបទថា សព្វំ ហត្ថំ : ដៃទាំងអស់ បានដល់ ម្រាមដៃគ្រប់ម្រាម ។

[៤៦១] ក្នុងបទថា សកពឡេន : ទាំងពំនូតបាយ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុកំពុងសម្តែងធម៌ដាក់សម៉ ឬវល្លិឈើអែមក្នុងមាត់ សម្តែងធម៌ទៅបណ្តើរ, ពាក្យនិយាយទីងមិនដាច់បាត់ទៅដោយដុំសម៉ជាដើមប៉ុនណា, កាលដុំសម៉ជាដើមប៉ុណ្ណោះមាននៅក្នុងមាត់ ទីងនិយាយក៏គួរ ។

[៤៦២] បទថា បិណ្ឌុក្ខេបកំ : បោះដុំបាយ គឺ ឆាន់បោះពំនូតបាយ ។

[៤៦៣] បទថា កវឡាវច្ឆេទកំ : កាត់ពំនូតបាយ គឺ ឆាន់ខាំពំនូតបាយ ។

[៤៦៤] បទថា អវគណ្ឌការកំ : បៀមពំនូតបាយក្នុងថ្ពាល់បានដល់ ឆាន់ធ្វើថ្ពាល់ឱ្យទូញប៉ោងឡើង ដូចស្វា ។

[៤៦៥] បទថា ហត្ថនិទ្ធូនកំ : ឆាន់រលាស់ដៃ គឺ ឆាន់ហើយរលាស់ដៃ ៗ ។

[៤៦៦] បទថា សិត្ថាវការកំ : ធ្វើគ្រប់បាយឱ្យជ្រុះរាយរាយ គឺ ឆាន់បាចសាចរាយរាយនូវគ្រាប់បាយទាំងឡាយ ។

[៤៦៧] បទថា ជិវ្ហានិច្ឆារកំ : លៀនអណ្តាត គឺ ឆាន់លៀនលឹប ៗ នូវអណ្តាត ។

[៤៦៨] បទថា ចបុចបុការកំ : ធ្វើសំឡេងឱ្យឥផ្ចប់ ៗ បានដល់ ឆាន់ធ្វើសំឡេងដែលធ្វើឱ្យឮខ្លាំងយ៉ាងនេះគឺ ផ្ចប់ ៗ ។

កពឡវគ្គទី ៥ ចប់

# សុរុសុរុវគ្គទី ៦

[៤៦៩] បទថា សុរុសុរុការកំ : ធ្វើសំឡេងឱ្យឮគ្រុក ៗ បាន ដល់ ឆាន់ធ្វើសំឡេងដែលធ្វើឱ្យឮខ្លាំងយ៉ាងនេះ គឺ គ្រុក ៗ ។

បទថា ធវោ : កំប្លែង គឺ ពាក្យសើចចំអក ។ អធិប្បាយថា ភិក្ខុមិនគប្បីពោលពាក្យចំអកនោះ ប្រារព្ធព្រះរតនត្រ័យ ដោយបរិយាយណា ៗ ដោយន័យជាដើមថា “ព្រះពុទ្ធអ្វី ? ព្រះពុទ្ធថ្ម ព្រះពុទ្ធប្លម, ព្រះធម៌អ្វី ? ព្រះធម៌គោ ព្រះធម៌ពពែ, ព្រះសង្ឃអ្វី ? ពួកម្រឹគ ពួកបសុសត្វ” ជាដើម ។

[៤៧០-២] បទថា ហត្ថនិល្លេហកំ : លិទ្ធដៃ គឺ លិទ្ធហើយលិទ្ធទៀតនូវដៃ ។ ពិតមែន ភិក្ខុដែលកំពុងឆាន់នឹងលិទ្ធសូម្បីតែម្រាមដៃក៏មិនគួរ ។ តែភិក្ខុនឹងយកម្រាមដៃទាំងឡាយចាប់យាគូខាប់ ស្ករអំពៅនិងបាយបាយាសជាដើម ហើយស៊កម្រាមដៃចូលក្នុងមាត់ឆាន់ គួរ ។ សូម្បីក្នុងការឆាន់កោសបាត្រ លិទ្ធបបូរមាត់ជាដើម ក៏ន័យនេះដូចគ្នា ។ ព្រោះដូច្នោះ ភិក្ខុមិនគួរយកម្រាមដៃ សូម្បីម្រាមតែមួយកោសបាត្រ ។ សូម្បីបបូរមាត់ខាងលើ ក៏មិនគួរយកអណ្តាតលិទ្ធ ។ តែនឹងយកចំពោះសាច់បបូរមាត់ទាំង២ខាងពាំហើយរំលៀក ឱ្យចូលទៅខាងក្នុងមាត់គួរ ។

[៤៧៣] បទថា កោកនទេ គឺ ក្នុងប្រាសាទមានឈ្មោះយ៉ាងនេះ ។ ផ្កាឈូក គេហៅថា កោកនទ ។ ក៏ប្រាសាទនោះ ដែលជាងធ្វើឱ្យមានសណ្ឋានស្រដៀងផ្កាឈូក ។ ព្រោះហេតុនោះ ជនទាំងឡាយទើប

តាំងឈ្មោះឱ្យប្រាសាទនោះថា កោកនទ[១] (ឈូកក្រហម) នោះតែម្តង ។

ពាក្យថា ន សាមិសេន ហត្ថេន ធានីយថាលកំ : មិនទទួលភាជន៍ទឹកដោយដៃ ភិក្ខុដែលមានដៃប្រលាក់ដោយអាមិស មិនត្រូវ (ទទួល) ភាជន៍ទឹកសម្រាប់ឆាន់ទេ នេះ ព្រះមានព្រះភាគ ត្រាស់ហាមដោយអំណាចនៃសេចក្តីគួរខ្ពើម ។ ព្រោះដូច្នោះ សង្ឃក្តី ផ្តិលទឹកក្តី ភាជន៍ក្តី ជារបស់សង្ឃក៏ដោយ ជារបស់បុគ្គលក៏ដោយ ជារបស់គ្រហស្ថក៏ដោយ ជារបស់ចំណែកខ្លួនក៏ដោយ ក៏មិនគួរយកដៃប្រលាក់អាមិសចាប់ទាំងអស់ ។ កាលចាប់ ជាទុក្កដ ។ តែបើថា ខ្លះចំណែករបស់ដៃ មិនបានប្រលាក់អាមិស, នឹងចាប់ដោយចំណែកនោះ គួរ ។

[៤៧៤] បទថា ឧទ្ធរិត្វា វា : សម្រិតចោលក្តី បានដល់ កៀរគ្រាប់បាយឡើងអំពីទឹក ហើយគរទុកក្នុងទីមួយកន្លែង ទើបចាក់ទឹកចោល ។

បទថា ភិន្ទិត្វា វា : ប្របាច់ក្តី បានដល់ ញីគ្រាប់បាយឱ្យមានគតិដូចទឹក ហើយចាក់ចោលទៅ ។

បទថា បដិគ្គហេ វា : ក្នុងកន្ថោរក្តី បានដល់ យកកន្ថោរទទួលទុក បោលគ្រាប់បាយនោះចុះក្នុងកន្ថោរ ។

---

១. ក្នុងបទានុក្រមធម្មបទថា កោកេ នាទយតីតិ កោកនទំ ជាទីបន្លឺនៃសត្វដែលធ្វើនូវសំឡេងថា កិកិ ។ ម្យ៉ាងទៀត ធម្មជាតិញុំាងពួកសត្វធ្វើនូវសំឡេងថា កិកិ ឱ្យឮឡើង ។

## ធម្មទេសនាបដិសំយុត្ត ១៦

[៤៧៦] បទថា សេតច្ឆត្តំ : ឆត្រពណ៌ស គឺ ឆត្រដែលពាសដោយសំពត់ស ។

បទថា កិលញ្ជច្ឆត្តំ : ឆត្របន្ទះឫស្សី គឺ ឆត្រក្រងដោយបន្ទះឫស្សី ។

បទថា បណ្ណច្ឆត្តំ : ឆត្រស្លឹកឈើ គឺ ឆត្រដែលធ្វើដោយស្លឹកឈើម៉្យាង មានស្លឹកត្នោតជាដើម ។

ក៏ពាក្យថា មណ្ឌលពទ្ធំ សលាកពទ្ធំ : ដែលគេចងឱ្យមានរាងមូល ចងឱ្យជាប់មាំដោយឆ្អឹងឆត្រ នេះ ព្រះមានព្រះភាគត្រាស់ទុកដើម្បីទ្រង់សម្ដែងឆ្អឹងឆត្រទាំង ៣ ប្រភេទ ។ ក៏ឆត្រទាំង ៣ ប្រភេទនោះ ជាឆត្រដែលដេរជាវង់មូល ចងជាប់នឹងឆ្អឹង ។ សូម្បីឆត្រស្លឹកឈើតែមួយស្លឹក ដែលគេធ្វើដោយធាងត្នោតជាដើម ក៏ឈ្មោះថា ឆត្រដូចគ្នា ។ បណ្ដាឆត្រទាំងនេះ ឆត្រប្រភេទណាមួយ ដែលមាននៅក្នុងដៃរបស់បុគ្គលនោះ ; ហេតុនោះ បុគ្គលនោះ ឈ្មោះថា មានឆត្រក្នុងដៃ ។ បុគ្គលនោះបាំងឆត្រក្ដី លីលើស្មាក្ដី ដាក់លើភ្លៅក្ដី មិនទាន់លែងដៃដរាបណា ទឹងសម្ដែងធម៌ដល់គេ មិនគួរដរាបនោះ ជាទុក្កដដល់ភិក្ខុដែលសម្ដែង ដោយន័យដូចដែលពោលហើយនុ៎ះឯង ។ តែបើថា អ្នកដទៃបាំងឆត្រឱ្យគេ ឬឆត្រនោះតាំងនៅលើទ្រូ ល្មមតែឆត្រផុតពីដៃ ក៏មិន

ឈ្មោះថា អ្នកមានឆត្រក្នុងដៃ, ទឹងសម្តែងធម៌ដល់បុគ្គលនោះ គួរ ។ ក៏ការកំណត់ធម៌ក្នុងសិក្ខាបទនេះ បណ្ឌិតគប្បីជ្រាបដោយន័យ ដូចពោលហើយក្នុងបទសោធម្មសិក្ខាបទនុ៎ះឯង ។

[៤៧៧-៨] ឈើដំបងប្រវែង ៤ ហត្ថរបស់មជ្ឈិមបុរស ឈ្មោះថា ដំបង ក្នុងពាក្យថា **ទណ្ឌបាណិស្ស : មានដំបងក្នុងដៃ** នេះ ។ ក៏បណ្ឌិតគប្បីជ្រាបសេចក្តីដែលបុគ្គលនោះមានដំបងក្នុងដៃ ដោយន័យដូចបានពោលហើយ ក្នុងបុគ្គលអ្នកមានឆត្រក្នុងដៃនុ៎ះឯង ។ សូម្បីក្នុងបុគ្គលមានសស្ត្រាក្នុងដៃ ក៏ន័យនេះដូចគ្នា ។ ព្រោះថា សូម្បីបុគ្គលអ្នកឈរចងសិកដាវ មិនទាន់ដល់ការរាប់ថា ជាអ្នកមានសស្ត្រាក្នុងដៃ ។

[៤៧៩] ក្នុងពាក្យថា **អាវុធបាណិស្ស : មានអាវុធក្នុងដៃ** នេះ ព្រះមានព្រះភាគត្រាស់ពាក្យថា "ធ្នូមានដងរាងដំបា (ដូចដងវែក) ឬធ្នូមានដងមូល ហៅថា គ្រឿងអាវុធ" ដូច្នេះ ក៏ពិតមែន តែថា ធ្នូសូម្បីគ្រប់ប្រភេទ ព្រមដោយព្រួញប្រភេទផ្សេង ៗ អ្នកសិក្សាក៏គប្បីជ្រាបថាអាវុធ ព្រោះដូច្នោះ ភិក្ខុទឹងសម្តែងធម៌ដល់បុគ្គលអ្នកមិនមានជម្ងឺ ដែលឈរ ឬ អង្គុយកាន់ធ្នូទឹងព្រួញក្តី កាន់តែព្រួញសុទ្ធក្តី កាន់តែធ្នូមានខ្សែក្តី កាន់តែធ្នូមិនមានខ្សែក្តី រមែងមិនសមគួរ ។ តែបើធ្នូពាក់ប្រដាប់ទុកសូម្បីត្រង់ករបស់គេ, ភិក្ខុទឹងសម្តែងធម៌ដល់គេ រហូតដល់អស់វេលាដែលគេមិនទាន់យកដៃចាប់ (ធ្នូ) គួរពិតនោះឯង ។

សុរុសុរុវគ្គទី ៦ ចប់

# បានុភាវគ្គទី ៧

[៤៨០] បទថា អក្កន្តស្ស : ជាន់ (ទ្រនាប់ជើង) បានដល់អ្នកឈរជាន់ទ្រនាប់ជើងតែម្យ៉ាង មិនបានសិកម្រាមជើងចូលទៅខ្សែទ្រនាប់ជើងដូចជងឆត្រ ។

[៤៨១] បទថា បដិមុក្កស្ស : ពាក់ គឺ អ្នកឈរពាក់ទ្រនាប់ជើង ។ សូម្បីក្នុងស្បែកជើង ក៏ន័យនុ៎ះឯង ។ ក៏ក្នុងពាក្យថា ឱមុក្កោ : **បន្ធើបកែងបន្តិច** នេះ ត្រាស់ហៅបុគ្គលអ្នកឈរពាក់ស្បែកជើងបិទកែង ។

[៤៨២] ក្នុងពាក្យថា យានគតស្ស : **នៅលើយាន** នេះ ប្រសិនបើថា អ្នកដែលត្រូវជន ២ នាក់ រែកទៅដោយដៃប្រទាក់គ្នាក្ដី អ្នកដែលគេដាក់ទុកលើសំពត់ ហើយប្រើស្វាលីទៅក្ដី អ្នកដែលអង្គុយលើយានដែលមិនបានទឹម មានគ្រែស្នែងជាដើមក្ដី អ្នកអង្គុយលើយានដែលគេរុះរើចេញ សូម្បីមានត្រឹមតែកង់ក្ដី រមែងដល់ការរាប់ថា អ្នកទៅក្នុងយានទាំងអស់ ។ តែបើអ្នកទាំងពីរ ២ ផ្នែក អង្គុយទៅលើយានជាមួយគ្នា, ទឹងសម្ដែងធម៌ដល់មួយផ្នែកទៀត គួរ ។ សូម្បីអ្នកទាំង២ អង្គុយបែកគ្នា អ្នកដែលអង្គុយនៅលើយានខ្ពស់ ទឹងសម្ដែងធម៌ដល់អ្នកអង្គុយនៅលើយានទាប គួរ ។ សូម្បីសម្ដែងដល់អ្នកអង្គុយលើយានដែលស្មើគ្នា ក៏គួរ ។ ភិក្ខុដែលអង្គុយលើយាននៅពីខាងក្រោយសូម្បីខ្ពស់ជាង ទឹងសម្ដែងធម៌ដល់អ្នកអង្គុយលើយាននៅពីខាងមុខ (ដែល

មិនមានជម្ងឺ ) មិនគួរ ។

[៤៨៣] បទថា សយនគតស្ស : នៅលើដំណេក មានសេចក្តីថា ភិក្ខុដែលឈរ ឬអង្គុយលើគ្រែក្តី លើតាំងក្តី លើភូមិប្រទេសក្តី សូម្បីខ្ពស់ នឹងសម្តែងធម៌ដល់អ្នក ( មិនមានជម្ងឺ ) ដែលដេកនោះ ដោយហោចទៅសូម្បីលើកន្ទេលផែងក្តី លើផែនដីតាមប្រក្រតីក្តី ក៏មិនគួរ ។ តែភិក្ខុដែលនៅលើទីដេក នឹងដេកលើទីខ្ពស់ជាង ឬមានប្រមាណស្មើគ្នា សម្តែងធម៌ដល់អ្នកមិនមានជម្ងឺនៅលើដែលដេក គួរ ។ ភិក្ខុដែលដេក នឹងសម្តែងធម៌ដល់អ្នកមិនមានជម្ងឺ ឈរក្តី អង្គុយនៅក្តី គួរ ។ សូម្បីភិក្ខុអង្គុយនឹងសម្តែងធម៌ដល់អ្នកឈរ ឬថា អង្គុយ ក៏គួរ ។ ភិក្ខុឈរនឹងសម្តែងធម៌ដល់អ្នកឈរដូចគ្នា ក៏បាន ។

[៤៨៤] បទថា បល្លត្ថិកាយ : ត្របោមក្បាលជង្គង់ មានសេចក្តីថា ភិក្ខុសម្តែងធម៌ដល់អ្នកមិនឈឺអង្គុយត្របោមក្បាលជង្គង់យ៉ាងណាមួយ ទោះជាគ្រឿងត្របោមក្បាលជង្គង់គឺ ខ្សែយោគក៏ដោយ គ្រឿងត្របោមក្បាលជង្គង់ គឺ ដៃក៏ដោយ គ្រឿងត្របោមក្បាលជង្គង់គឺ សំពត់ក៏ដោយ ក៏មិនគួរ ។

[៤៨៥] បទថា វេដ្ឋិតសីសស្ស : ជូតក្បាល មានសេចក្តីថា ដល់អ្នកជូតក្បាលដោយសំពត់សម្រាប់ជូត ឬដោយកម្រងផ្កាឈើជាដើម បិទជើងសក់បាត់ មិនឱ្យឃើញប្រាកដ ។

[៤៨៦] បទថា ឱគុណ្ឋិតសីសស្ស : ទទូរក្បាល គឺ អ្នកដណ្តប់ឃ្លុំទាំងសិរ្សៈ ។

[៤៨៧] ពីរបទថា ឆមាយំ និសីទិត្វា : អង្គុយផ្ទាល់នឹងដី គឺ អ្នកអង្គុយលើផែនដី ។

ពីរបទថា អាសនេ និសិន្នស្ស[១] : នៅលើអាសនៈ គឺ ដោយហោចទៅ សូម្បីតែអ្នកក្រាលសំពត់ ឬស្មៅហើយអង្គុយ ។

[៤៨៩] បទថា ឆវកស្ស[២] : របស់ជនថោកទាប បានដល់បុរសចណ្ឌាល ។

បទថា ឆវកី [៣] : ស្រីថោកទាប បានដល់ ស្រីចណ្ឌាល ។

បទថា និលិនោ : ពួន គឺ ជាអ្នកលាក់ខ្លួន ។

បទថា យត្រ ហិ ណាម គឺ យោ ហិ ណាម : នេះឯងហៅថា

ពាក្យថា សព្វមិទំ ច បរិគតន្តិ ។ តត្ថេវ បរិបតិ : ច្បាប់ទាំងនេះ វាប្រឡូកប្រឡំគ្នាអស់ហើយ ។ បុរសនោះគិតដូច្នោះហើយ ក៏លោតចុះពីដើមស្វាយមកក្នុងទីនោះឯង មានសេចក្តីថា អ្នកចណ្ឌាលនោះពោលពាក្យយ៉ាងនេះថា "លោកនេះទាំងអស់ សាំញ៉ាំ មិនមានព្រំដែន" ហើយសម្រុតចុះមកពីដើមឈើ ក្នុងចន្លោះជនទាំង ២ នោះ ក្នុងទីនោះ

១. ថៃ. និសិន្នេន ។ ២. ភូមា. ឆបកស្ស ។ ៣. ថៃ. ឆវកា ; ភូមា. ឆបកី ។

នោះតែម្តង ៗ ក៏ឯគ្រាសម្រេចចុះមកហើយ ឈរខាងមុខនៃជនសូម្បីទាំង ២ ហើយពោលគាថានេះថា

ឧភោ អត្ថំ ន ជានន្តិ ឧភោ ធម្មំ ន បស្សរេ
យោ ចាយំ មន្តំ វាចេតិ យោ ចាធម្មេនធីយតិ ។

ព្រាហ្មណ៍ណាបង្ហាញមន្ត(ដល់ស្តេច)ក្តី ស្តេចអង្គណា រៀនមន្តមិនប្រកបដោយធម៌ក្តី ជនទាំងពីរនោះ ឈ្មោះថា មិនស្គាល់នូវហេតុ ជនទាំងពីរនោះ ឈ្មោះថា មិនស្គាល់នូវផល ។

បណ្តាបទទាំងនោះ បាទគាថា ថា ឧភោ អត្ថំ ន ជានន្តិ : ជនទាំងពីរនោះ ឈ្មោះថា មិនស្គាល់នូវហេតុ មានសេចក្តីថា ជនសូម្បីទាំងពីរ ក៏មិនដឹងអត្ថនៃបាលី ។

ពាក្យថា ធម្មំ ន បស្សរេ : ឈ្មោះថា មិនស្គាល់នូវផល សេចក្តីថា ជនទាំង២ រមែងមិនឃើញបាលី ។

សួរថា ជនទាំង ២ នោះពួកណា ?

ឆ្លើយថា ជនទាំង ២ គឺ ព្រាហ្មណ៍អ្នកបង្រៀនមន្ត ដោយមិនគោរពធម៌និងស្តេចផែនដីអ្នកទ្រទ្រង់រៀនមន្ត ដោយមិនគោរពធម៌ ។ អធិប្បាយថា មនុស្សចណ្ឌាលតាំងអ្នកទាំង ២ គឺ ព្រាហ្មណ៍និងស្តេចផែនដីទុកក្នុងភាពជាអ្នកមិនប្រព្រឹត្តធម៌ ។

តពីនោះ ព្រាហ្មណ៍ទើបបានពោលគាថាថា ៖

សាលីនំ ឱទនោ ភុត្តោ សុចិមំសូបសេចនោ
តស្មា ធម្មេ ន វត្តាមិ ធម្មោ អរិយេភិ វណ្ណិតោ ។

(នៃចណ្ឌាល) ខ្ញុំបានទទួលទានបាយអង្ករស្រូវសាលី ដែលលាយដោយសាច់ដ៏ស្អាតរបស់ស្ដេច (ជារាល់ថ្ងៃ) ព្រោះហេតុនោះ ខ្ញុំនឹងប្រព្រឹត្តទៅក្នុងធម៌នោះ មិនបានទេ (តែខ្ញុំដឹងថា) ធម៌នេះពួកព្រះអរិយៈតែងសរសើរហើយ ។

គាថានោះ មានសេចក្ដីថា បាដ៏ចម្រើន យើងក៏ដឹងដែរថា នេះមិនជាធម៌, មួយទៀតទុះឯង យើងនឹងបុត្រភរិយាព្រមទាំងបរិវារជនបរិភោគបាយនៃស្រូវសាលីដែលជារបស់ក្នុងហ្លួងមកយូរហើយ ។

បាទគាថាថា សុចិមំសូបសេចនោ : ដែលលាយដោយសាច់ដ៏ស្អាតរបស់ស្ដេច(ជារាល់ថ្ងៃ) មានវិគ្រោះថា ការផ្សំដោយសម្លសាច់ដ៏ស្អាតដែលគេផ្សំដោយប្រភេទមួយកន្លែងគ្រឿងផ្សំមានប្រការផ្សេង ៗ គឺការធ្វើឱ្យលាយនឹងអាមិស មានដល់បាយនៃស្រូវសាលីនោះ; ហេតុនោះបាយស្រូវសាលីនោះ ទើបឈ្មោះថា លាយដោយសាច់ដ៏ស្អាត ។

បាទគាថាថា តស្មា ធម្មេ ន វត្តាមិ : ព្រោះហេតុនោះ ខ្ញុំនឹងប្រព្រឹត្តទៅក្នុងធម៌នោះមិនបានទេ មានសេចក្ដីថា ព្រោះយើងបរិភោគ

បាយរបស់ស្តេច និងបានទទួលព្រះរាជទានលាភដទៃ ៗជាច្រើនយ៉ាងនេះ; ដូច្នោះ យើងទើបមិនប្រព្រឹត្តនៅក្នុងធម៌ ជាអ្នកជាប់នៅក្នុងផ្ទៃ (ឃើញដល់ផ្ទៃ) មិនមែនមិនដឹងធម៌ យើងដឹងថា សេចក្តីពិតធម៌នេះ ព្រះអរិយៈទាំងឡាយសរសើរ ។

លំដាប់នោះ ចណ្ឌាលនោះ ទើបពោលដដែលចំពោះព្រាហ្មណ៍នោះ ដោយ ២ គាថាថា

ធិរត្ថុ តំ ធនលាភំ    យសលាភញ្ច ព្រាហ្មណ
យា វុត្តិ វិនិបាតេន    អធម្មចរណេន វា ។
បរិព្វជ មហាព្រហ្មេ    បចន្តញ្ញេបិ បាណិនោ
មា តុំ អធម្មោ អាចរិតោ    អស្មា កុម្ភមិវាភិទា ។

បពិត្រព្រាហ្មណ៍ ការដែលបានទ្រព្យ និងបានយសបែបនោះ ពាក្យនិន្ទាតែងមាន (ជាធម្មតា) ម្យ៉ាងទៀត ការចិញ្ចឹមជីវិតដែលមិនប្រព្រឹត្តទៅតាមធម៌ ជាហេតុនាំឱ្យធ្លាក់ចុះទៅក្នុងអបាយ ។ បពិត្រមហាព្រហ្ម អ្នកឯងចូរវៀរចេញ សូម្បីសត្វដទៃក៏គង់តែចំអិនបាយបរិភោគ (ដូចគ្នាទេ) អ្នកកុំប្រព្រឹត្តឱ្យខុសធម៌នោះឡើយ បើអ្នកប្រព្រឹត្តខុសធម៌

ហើយ មុខជានឹងបែកធ្លាយដូចជាក្អមទឹកមិនខានទេ ។

ពីរគាថានោះ មានសេចក្តីថា លាភគឺ ទ្រព្យ និងលាភគឺយសយ៉ាងណាដែលលោកបានហើយ, យើងតិះដៀលលាភ គឺ ទ្រព្យនិងលាភគឺ យសយ៉ាងនោះ លោកព្រាហ្មណ៍ ព្រោះហេតុអ្វីហ្ន៎ ? ព្រោះលាភដែលលោកបាននេះ ជាហេតុឱ្យហើយ ដល់ហេតុដែលឱ្យធ្លាក់ទៅក្នុងពួកអបាយតទៅ និងឈ្មោះថា ជាការធ្វើដំណើរជីវិតដោយប្រព្រឹត្តមិនជាធម៌ ។ ក៏ដំណើរជីវិតមានសភាពបែបនេះ នឹងសម្រេចបានដោយជាហេតុឱ្យធ្លាក់ចុះទៅ ឬដោយជាហេតុឱ្យប្រព្រឹត្តមិនមែនធម៌ក្នុងលោកនេះ, និងមានប្រយោជន៍អ្វីដោយដំណើរជីវិតនោះ ។ ព្រោះហេតុនោះ ចណ្ឌាលនោះ ទើបបានពោលថា ៖

បពិត្រព្រាហ្មណ៍ ការដែលបានទ្រព្យនិងបានយសបែបនោះ ពាក្យនិន្ទាតែងមាន ( ជាធម្មតា ) ម្យ៉ាងទៀត ការចិញ្ចឹមជីវិតដែលមិនប្រព្រឹត្តតាមធម៌ ជាហេតុឱ្យធ្លាក់ចុះទៅអបាយ ។

បាទគាថាថា បរិព្វជ មហាព្រហ្មេ : បពិត្រមហាព្រហ្ម អ្នកឯងចូរវៀរចេញ មានសេចក្តីថា បពិត្រមហាព្រាហ្មណ៍ លោកចូរប្រញាប់ចេញពីប្រទេសនេះទៅ ។

បាទគាថាថា បចន្តញ្ញេបិ ធាណិនោ : សូម្បីសត្វដទៃក៏គង់តែ

ចំអិនបាយបរិភោគ (ដូចគ្នាទេ) មានសេចក្ដីថា សូម្បីសត្វពួកដទៃ ក៏តែងចំអិន និងតែងបរិភោគបានដែរ, មិនមែនតែលោកនឹងព្រះរាជាប៉ុណ្ណោះ ។

កន្លះគាថាថា មា តំ អធម្មោ អាចរិតោ អស្មា កុម្ភមិវាភិទា : អ្នកកុំប្រព្រឹត្តឱ្យខុសធម៌នោះឡើយ បើអ្នកប្រព្រឹត្តខុសធម៌ហើយ មុខជានឹងបែកធ្លាយដូចជាក្អមទឹកមិនខានទេ មានសេចក្ដីថា ព្រោះបើថា លោកមិនជៀសចេញពីទីនេះ នឹងប្រព្រឹត្តអធម៌នេះឱ្យក្រៃលែងឡើង, តពីនោះអធម៌ដែលលោកប្រព្រឹត្តក្រៃលែងឡើងនោះ នឹងទម្លាយលោកឯងដូចដុំថ្មទម្លាយឆ្នាំងទឹក ដូច្នោះ ។ ព្រោះហេតុនោះ យើងទាំងឡាយទើបពោលថា ៖

បពិត្រមហាព្រហ្ម អ្នកឯងចូរវៀរចេញ សូម្បីសត្វដទៃក៏គង់តែចំអិនបាយបរិភោគ (ដូចគ្នាទេ) អ្នកកុំប្រព្រឹត្តឱ្យខុសធម៌នោះឡើយ បើអ្នកប្រព្រឹត្តខុសធម៌ហើយ មុខជានឹងបែកធ្លាយដូចជាក្អមទឹកមិនខានទេ ។

[៤៩០] ពីរបទថា ឧច្ចេ អាសនេ : លើអាសនៈខ្ពស់ មានសេចក្ដីថា នឹងសម្ដែងធម៌ដល់អ្នកមិនឈឺ ដែលអង្គុយនៅលើអាសនៈដោយហោចទៅសូម្បីលើភូមិភាគដែលខ្ពស់ជាង ក៏មិនគួរ ។

[៤៩១] ពីរបទថា **ន ឋិតេន និសិន្នស្ស** : **ភិក្ខុមិនត្រូវឈរ (សម្ដែងធម៌) ដល់អ្នកអង្គុយ** មានសេចក្ដីថា ប្រសិនបើថា ព្រះមហាថេរៈអង្គុយលើអាសនៈ សួរបញ្ហាចំពោះភិក្ខុកម្លោះដែលមកកាន់ទីបម្រើរបស់ព្រះថេរៈហើយឈរ, លោកមិនគួរពោល ។ តែដោយសេចក្ដីគោរព លោកក៏មិនអាចពោលនឹងព្រះថេរៈថា និមន្តលោកក្រោកឡើងសួរចុះ ។ នឹងពោលអំពីតាំងចិត្តថា យើងនឹងពោលដល់ភិក្ខុដែលឈរនៅខាង ៗ គួរ ។

[៤៩២] ក្នុងពាក្យថា **ន បច្ឆតោ គច្ឆន្តេន** : **ភិក្ខុមិនត្រូវដើរក្រោយ** នេះ មានវិនិច្ឆ័យថា បើមានអ្នកដើរទៅខាងមុខ សួរបញ្ហាចំពោះភិក្ខុដែលដើរទៅខាងក្រោយ, លោកមិនគួរតប ។ នឹងពោលដោយដាក់ចិត្តថា យើងនឹងពោលដល់ភិក្ខុដែលនៅខាងក្រោយ សមគួរ ។ នឹងស្វាធ្យាយធម៌ដែលខ្លួនរៀនរួមគ្នា គួរ ។ នឹងពោលដល់បុគ្គលអ្នកដើរទន្ទឹមគ្នាទៅ ក៏គួរ ។

[៤៩៣] សូម្បីក្នុងពាក្យថា **ន ឧប្បថេន** : **ភិក្ខុមិនត្រូវ (ដើរ) ក្រៅមក** នេះ ក៏មានវិនិច្ឆ័យថា សូម្បីជនទាំង ២ ដើរទៅទន្ទឹមគ្នាក្នុងមាគ៌ារទេះតាមមកកង់រទេះអ្នកម្ខាង ឬចេញក្រៅមកទៅ, នឹងពោលក៏គួរ ។

# បកិណ្ណកៈ ៣

[៤៩៤] បទថា អសញ្ចិច្ច : ភិក្ខុមិនក្លែង មានសេចក្ដីថា កាលភិក្ខុកំពុងទៅកាន់ទីកំបាំងឧច្ចារៈ ឬបស្សាវៈហូរបាញ់ចេញ(ធ្លាក់ចេញមកយ៉ាងឆាប់រហ័ស) ឈ្មោះថា មិនក្លែងបន្ទោបង់ មិនជាអាបត្តិ ។

[៤៩៥] ក្នុងពាក្យថា ឆ ហរិតេ : មិនត្រូវបន្ទោបង់ នេះមានវិនិច្ឆ័យដូច្នេះ ៖

សូម្បីឫសរបស់ដើមឈើដែលនៅរស់ ដុះចាក់ទៅលើផែនដីប្រាកដឱ្យឃើញក្ដី មែកឈើដែលលូនទៅលើផែនដីក្ដី ទាំងអស់ហៅថារបស់ខៀវស្រស់ទាំងនោះ ។ ភិក្ខុនឹងអង្គុយលើកំណាត់ឈើ បន្ទោបង់ឱ្យធ្លាក់ចុះទៅក្នុងទីប្រាសចាករបស់ខៀវស្រស់ គួរ ។ កាលកំពុងរកមើលទីប្រាសចាករបស់ខៀវស្រស់នុ៎ះឯង ឧច្ចារៈ ឬបស្សាវៈ ហូរធ្លាក់ចេញមកដោយឆាប់រហ័ស ចាត់ថា តាំងនៅក្នុងឋានជាអ្នកអាពាធ គួរ ។

ពីរបទថា អបហរិតេ ករោ : ភិក្ខុបន្ទោបង់ទៅលើទីដែលប្រាសចាកវត្ថុស្រស់ មានសេចក្ដីថា កាលភិក្ខុមិនបានទីប្រាសចាករបស់ខៀវស្រស់ សូម្បីដាក់ពំនូកស្មៅ ឬពំនូកចំបើងទុកហើយ ធ្វើការបន្ទោបង់ឧច្ចារៈបស្សាវៈលើរបស់ខៀវជាខាងក្រោយ ក៏គួរ ដូចគ្នា ។ លោក

ពោលទុកក្នុងមហាបច្ចរីថា សូម្បីសម្បោរ ក៏សង្គ្រោះចូលជាទឹកមាត់ក្នុង សិក្ខាបទនេះ ។

[៤៩៦-៧] ពាក្យថា ន ឧទកេ : មិនត្រូវ(បន្ទោបង់ឬស្តោះ) ដាក់លើទឹក នេះ ព្រះមានព្រះភាគត្រាស់ សំដៅដល់ទឹកបរិភោគ ប៉ុណ្ណោះ ។ តែក្នុងទឹកវច្ចកុដិ និងក្នុងទឹកសមុទ្រជាដើម មិនមែនរបស់ បរិភោគ មិនជាអាបត្តិ ។ កាលភ្លៀងធ្លាក់ជ្រលងទឹកមានពេញទូទៅ ។ កាលភិក្ខុកំពុងមើលរកទីមិនមានទឹកនុ៎ះឯង ឧច្ចារៈ ឬបស្សាវៈហូរចេញ មក គួរ ។ តែក្នុងមហាបច្ចរី លោកពោលថា ក្នុងវេលាដូច្នោះ ភិក្ខុមិន បានទីដែលមិនមានទឹក នឹងធ្វើការបន្ទោបង់ គួរ ។ ពាក្យដែលនៅសល់ ក្នុងសិក្ខាបទទាំងពួង ងាយយល់ទាំងអស់ ។

វគ្គទី ៧ ចប់

## ចំនួនសិក្ខាបទ ៧៥ ក្នុងសេក្ខិយវត្តនោះគឺ

## សារុប្ប: មាន ២៤ សិក្ខាបទ

### ១. បរិមណ្ឌលវគ្គ ទី ១

១. បរិមណ្ឌលនិវាសនៈ ការស្លៀកស្បង់ឱ្យជាបរិមណ្ឌល

២. បរិមណ្ឌលបារុបនៈ ការដណ្តប់ចីវរឱ្យជាបរិមណ្ឌល

៣. សុប្បដិច្ឆន្នគមនៈ ការបិទបាំងកាយឱ្យល្អដើរទៅក្នុងចន្លោះផ្ទះ

៤. សុប្បដិច្ឆន្ននិសីទនៈ ការបិទបាំងកាយឱ្យល្អអង្គុយនៅក្នុងចន្លោះផ្ទះ

៥. សុសំវុតគមនៈ ការសង្រួមឱ្យល្អដើរទៅក្នុងចន្លោះផ្ទះ

៦. សុសំវុតនិសីទនៈ ការសង្រួមឱ្យល្អអង្គុយនៅក្នុងចន្លោះផ្ទះ

៧. ឱក្ខិត្តចក្ខុគមនៈ មានភ្នែកសំឡឹងចុះដើរទៅក្នុងចន្លោះផ្ទះ

៨. ឱក្ខិត្តចក្ខុនិសីទនៈ មានភ្នែកសំឡឹងចុះអង្គុយនៅក្នុងចន្លោះផ្ទះ

៩. នឧក្ខិត្តកគមនៈ ការមិនសើយចីវរដើរទៅក្នុងចន្លោះផ្ទះ

១០. នឧក្ខិត្តកនិសីទនៈ ការមិនសើយចីវរអង្គុយនៅក្នុងចន្លោះផ្ទះ

### ២. ឧជ្ជគ្ឃិកវគ្គ ទី ២

១១. នឧជ្ជគ្ឃិកាយគមនៈ ការមិនសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ

១២. នឧជ្ជគ្ឃិកាយនិសីទនៈ ការមិនសើចខ្លាំងអង្គុយនៅក្នុងចន្លោះផ្ទះ

១៣. អប្បសទ្ទគមនៈ មានសំឡេងតិចដើរទៅក្នុងចន្លោះផ្ទះ

១៤. អប្បសទ្ទនិសីទនៈ មានសំឡេងតិចអង្គុយនៅក្នុងចន្លោះផ្ទះ

១៥. នកាយប្បចាលកគមនៈ ការមិនគ្រលែងកាយដើរទៅក្នុងចន្លោះផ្ទះ
១៦. នកាយប្បចាលកនិសីទនៈ ការមិនគ្រលែងកាយអង្គុយនៅក្នុងចន្លោះផ្ទះ
១៧. នពាហុប្បចាលកគមនៈ ការមិនបង់បោយដើរទៅក្នុងចន្លោះផ្ទះ
១៨. នពាហុប្បចាលកនិសីទនៈ ការមិនឆ្កាដៃអង្គុយនៅក្នុងចន្លោះផ្ទះ
១៩. នសីសប្បចាលកគមនៈ ការមិនគ្រវីក្បាលដើរទៅក្នុងចន្លោះផ្ទះ
២០. នសីសប្បចាលកនិសីទនៈ ការមិនគ្រវីក្បាលអង្គុយនៅក្នុងចន្លោះផ្ទះ

៣. ខម្ភកវគ្គ ទី ៣

២១. នខម្ភកតគមនៈ ការមិនស្ទឹមចង្កេះដើរទៅក្នុងចន្លោះផ្ទះ
២២. នខម្ភកតនិសីទនៈ ការមិនស្ទឹមចង្កេះអង្គុយនៅក្នុងចន្លោះផ្ទះ
២៣. នឱគុណ្ឋិតគមនៈ ការមិនទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ
២៤. នឱគុណ្ឋិតនិសីទនៈ ការមិនទទូរក្បាលអង្គុយនៅក្នុងចន្លោះផ្ទះ
២៥. នឧក្កុដិកាយគមនៈ ការមិនចំអើតជើងដើរទៅក្នុងចន្លោះផ្ទះ
២៦. នបល្លត្ថិកាយនិសីទនៈ ការមិនអង្គុយត្របោមក្បាលជង្គង់ក្នុងចន្លោះផ្ទះ

ភោជនប្បដិសំយុត្ត មាន ៣០ សិក្ខាបទ

២៧. សក្កច្ចបិណ្ឌបាតបដិគ្គហណៈ ការទទួលអាហារបិណ្ឌបាតដោយគោរព
២៨. បត្តសញ្ញីបដិគ្គហណៈ ការសំគាល់ក្នុងបាត្រហើយទទួលបិណ្ឌបាត្រ
២៩. សមសូបកបដិគ្គហណៈ ការទទួលបិណ្ឌបាត្រឱ្យល្មមគ្នានឹងសម្ល
៣០. សមតិត្តិកបដិគ្គហណៈ ការទទួលបិណ្ឌបាត្រឱ្យស្មើនឹងកណ្តាប់មាត់បាត្រ

## ៤. សក្កច្ចវគ្គ ទី ៤

| | |
|---|---|
| ៣១. សក្កច្ចបិណ្ឌបាតភុញ្ជនៈ | ការឆាន់បិណ្ឌបាតដោយគោរព |
| ៣២. បត្តសញ្ញីបិណ្ឌបាតភុញ្ជនៈ | ការសំគាល់តែក្នុងបាត្រឆាន់បិណ្ឌបាត្រ |
| ៣៣. សប្បទានបិណ្ឌបាតភុញ្ជនៈ | ការឆាន់បិណ្ឌបាត្រវាចឱ្យស្មើ |
| ៣៤. សមសូបកបិណ្ឌបាតភុញ្ជនៈ | ការឆាន់បិណ្ឌបាត្រឱ្យល្មមគ្នានឹងសម្ល |
| ៣៥. នថូបិកតោមទ្ទិនភុញ្ជនៈ | ការមិនប្រមត្រង់កំពូលបាយហើយឆាន់ |
| ៣៦. នសូបព្យញ្ជនោទនបដិច្ឆាទនៈ | ការមិនកកាយបាយលុបសម្លឬម្ហូប |
| ៣៧. នសូបោទនវិញ្ញតិ | ការមិនត្រូវសូមសម្លឬបាយ |
| ៣៨. នឧជ្ឈានសញ្ញីបត្តោលោកនៈ | ការមិនសម្លឹងមើលបាត្រពួកភិក្ខុ ដទៃ ដោយប្រុងនឹងលើកទោស |
| ៣៩. នាតិមហន្តកពឡករណៈ | ការមិនធ្វើពុំនូតបាយឱ្យធំពេក |
| ៤០. បរិមណ្ឌលអាលោបករណៈ | ការធ្វើពុំនូតបាយឱ្យជាបរិមណ្ឌល |

## ៥. កពឡវគ្គ ទី ៥

| | |
|---|---|
| ៤១. នអនាហដទ្វារវិវរណៈ | ការមិនហារមាត់ចាំពំនូតបាយ |
| ៤២. នសព្វហត្ថបក្ខិបនៈ | ការឆាន់បាយមិនញាត់ម្រាមដៃទាំងអស់ |
| ៤៣. នសកពឡព្យាហរណៈ | ការមិននិយាយទាំងពំនូតបាយក្នុងមាត់ |
| ៤៤. នបិណ្ឌុក្ខេបកភុញ្ជនៈ | ការមិនឆាន់បោះដុំបាយទៅក្នុងមាត់ |
| ៤៥. នកពឡាវច្ឆេទកៈ | ការមិនឆាន់កាត់ពំនូតបាយ |

៤៦. នអវគណ្ឌការកកុញ្ចន: ការមិនឆាន់បៀមពំនូតបាយក្នុងថ្ពាល់
៤៧. នហត្ថនិទ្ធូនកកុញ្ចន: ការមិនឆាន់រលាស់ដៃ
៤៨. នសិត្ថាវការកកុញ្ចន: ការមិនឆាន់ធ្វើគ្រាប់ឱ្យជ្រុះពាយពាយ
៤៩. នជិវ្ហានិច្ឆារកកុញ្ចន: មិនឆាន់លៀនអណ្តាត
៥០. នចបុចបុការកកុញ្ចន: មិនឆាន់ធ្វើសំឡេងឱ្យឮផ្ចប់ ៗ

៦. សុរុសុរុវគ្គ ទី ៦

៥១. នសុរុសុរុការកកុញ្ចន: មិនឆាន់ធ្វើសំឡេងឱ្យឮគ្រូក ៗ
៥២. នហត្ថនិល្លេហកកុញ្ចន: មិនឆាន់លិទ្ធដៃ
៥៣. នបត្តនិល្លេហកកុញ្ចន: មិនឆាន់កៀសបាត្រ
៥៤. នឱដ្ឋនិល្លេហកកុញ្ចន: មិនឆាន់លិទ្ធបបូរមាត់
៥៥. នសាមិសបដិគ្គហណ: ដៃប្រឡាក់អាមិស មិនត្រូវទទួលភាជនៈទឹកសម្រាប់ឆាន់
៥៦. នសសិត្ថកឆឌ្ឌន: មិនចាក់ទឹកលាងបាត្រទាំងគ្រាប់បាយ

ធម្មទេសនាបដិសំយុត្ត មាន ១៦ សិក្ខាបទ

៥៧. នឆត្តបាណិទេសន: មិនសម្ដែងធម៌ដល់អ្នកមានឆត្រក្នុងដៃ
៥៨. នទណ្ឌបាណិទេសន: មិនសម្ដែងធម៌ដល់អ្នកមានដំបងក្នុងដៃ
៥៩. នសត្ថបាណិទេសន: មិនសម្ដែងធម៌ដល់អ្នកមានគ្រឿងសាស្ត្រាក្នុងដៃ
៦០. នអាវុធបាណិទេសន: មិនសម្ដែងធម៌ដល់អ្នកមានគ្រឿងអាវុធក្នុងដៃ

## បាទុកាវគ្គទី ៧

៦១. នបាទុការុឡ្ហទេសនៈ មិនសម្ដែងធម៌ដល់អ្នកពាក់ទ្រនាប់ជើង
៦២. នឧបាហានទេសនៈ មិនសម្ដែងធម៌ដល់អ្នកពាក់ស្បែកជើង
៦៣. នយានគតទេសនៈ មិនសម្ដែងធម៌ដល់អ្នកនៅលើយាន
៦៤. នសយនគតទេសនៈ មិនសម្ដែងធម៌ដល់អ្នកនៅលើដំណេក
៦៥. នបល្លត្ថិកទេសនៈ មិនសម្ដែងធម៌ដល់អ្នកអង្គុយត្របោមក្បាលជង្គង់
៦៦. នវេដ្ឋិតសីសទេសនៈ មិនសម្ដែងធម៌ដល់អ្នកជួតក្បាល
៦៧. នឱគុណ្ឋិតសីសទេសនៈ មិនសម្ដែងធម៌ដល់អ្នកទទូរក្បាល
៦៨. នឆមាយទេសនៈ មិនសម្ដែងធម៌ដល់អ្នកអង្គុយនៅលើអាសនៈ
៦៩. ននីចាសនទេសនៈ មិនអង្គុយលើអាសនៈទាប ហើយសម្ដែងធម៌ដល់អ្នកអង្គុយលើអាសនៈខ្ពស់
៧០. នឋិតទេសនៈ មិនឈរសម្ដែងធម៌ដល់អ្នកដែលអង្គុយ
៧១. នបច្ឆតោទេសនៈ មិនដើរខាងក្រោយសម្ដែងធម៌ដល់អ្នកដើរខាងមុខ
៧២. នឧប្បថទេសនៈ មិនដើរក្រៅមកសម្ដែងធម៌ដល់អ្នកដើរតាមមក

## បកិណ្ណកៈ មាន ៣ សិក្ខាបទ

៧៣. នឋិតករណៈ មិនឈរបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ
៧៤. នហរិតកណៈ មិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្ដោះទឹកមាត់លើស្មៅស្រស់ ឬឈើស្រស់
៧៥. នឧទកករណៈ មិនបន្ទោបង់ឧច្ចារៈ,បស្សាវៈ,ស្ដោះទឹកមាត់ដាក់លើទឹក

# បកិណ្ណកៈក្នុងសេខិយវណ្ណនា

ក៏ដើម្បីត្រូវការសម្តែងសមុដ្ឋានជាដើម ក្នុងអធិការនៃសេខិយវណ្ណនានេះ ទើបមានសេចក្តីបន្តិចបន្តួចដូចតទៅនេះ ៖

សិក្ខាបទទាំង ១០ នេះ គឺ បួនសិក្ខាបទ ដែលជាប់ដោយករសើច២ និងសំឡេងខ្លាំង២, សិក្ខាបទដែលនិយាយទាំងពំនូតបាយក្នុងមាត់១, ប្រាំសិក្ខាបទ ដែលជាប់ដោយករសម្តែងធម៌អង្គុយលើផែនដី១ ទីអង្គុយទាប១ ការឈរ១ ការដើរខាងក្រោយ១ ការដើរក្រៅមគ១ មានសមុដ្ឋានដូចសមនុភាសនសិក្ខាបទ កើតឡើងមកកាយវាចាចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ។

សូបោទនវិញ្ញត្តិសិក្ខាបទ មានសមុដ្ឋានដូចថេយ្យសត្ថសិក្ខាបទ កើតឡើងមកកាយចិត្ត១ កាយវាចាចិត្ត១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ។

សិក្ខាបទ១១ ដែលមានឈ្មោះថា ឆត្តបាណិសិក្ខាបទ១ ទណ្ឌបាណិសិក្ខាបទ១ សត្ថបាណិសិក្ខាបទ១ អាវុធបាណិសិក្ខាបទ១ បាទុកសិក្ខាបទ១ ឧបាហនសិក្ខាបទ១ យានសិក្ខាបទ១ សយនសិក្ខាបទ១ បល្លត្ថិកសិក្ខាបទ១ វេដ្ឋិតសិក្ខាបទ១ ឱគុណ្ឋិតសិក្ខាបទ១ មានសមុដ្ឋាន

ដូចធម្មទេសនាសិក្ខាបទ កើតឡើងមកវាចាចិត្ត ជាកិរិយានិងជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ។ ដែលនៅសល់ ៥៣ សិក្ខាបទទៀត មានសមុដ្ឋានដូច បឋមបារាជិកនោះឯង ។

ក្នុងសេក្ខិយសិក្ខាបទទាំងអស់ មិនជាអាបត្តិ ព្រោះអាពាធជាបច្ច័យ ។ ក្នុងសិក្ខាបទ៣ គឺ ថូបីកតបិណ្ឌបាតសិក្ខាបទ១ សូបព្យញ្ជនបដិច្ឆាទនសិក្ខាបទ១ ឧជ្ឈានសញ្ញីសិក្ខាបទ១ មិនមាន (ពោលដល់) ភិក្ខុអាពាធឡើយ ។

សេក្ខិយវណ្ណនា ចប់

# អធិករណសមថវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងអធិករណសមថៈទាំងឡាយ ដូច្នេះ ៖

ពាក្យថា **សត្ត** : ៧ ជាគ្រឿងកំណត់រាប់ធម៌ទាំងនោះ ។ ធម៌ ៧ នោះ ឈ្មោះថា អធិករណសមថៈ ព្រោះអត្ថថា ញ៉ាំងអធិករណ៍ ៥ យ៉ាង ឱ្យស្ងប់ គឺឱ្យរម្ងាប់ទៅ ។ សេចក្ដីពិស្ដារនៃអធិករណសមថៈទាំងនោះ ព្រះមានព្រះភាគត្រាស់ទុកហើយក្នុងខន្ធកៈ និងក្នុងបរិវារ ។ ពួកយើងនឹងពណ៌នាអត្ថនៃពាក្យពិស្ដារនោះក្នុងខន្ធកៈ និងបរិវារនោះឯង ។ ពាក្យដែលនៅសល់ក្នុងសិក្ខាទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ភិក្ខុវិភង្គវណ្ណនា ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## បាចិត្តិយាទិ

## ចតុត្ថភាគ ៤

## ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## ភិក្ខុនីវិភង្គ

## បច្ចេកភាគ

## ៥

# ភិក្ខុនីវិភង្គវណ្ណនា

## បារាជិកកណ្ឌវណ្ណនា

មកដល់លំដាប់នៃការពណ៌នាភិក្ខុនីវិភង្គ ដែលព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានចងក្រងទុកក្នុងលំដាប់នៃភិក្ខុវិភង្គ ដូច្នោះ ដើម្បីធ្វើការពណ៌នាបទដែលមិនធ្លាប់មានមកពីមុន ក្នុងបារាជិកនៃភិក្ខុនីវិភង្គនោះ ទើបមានការពណ៌នា ចាប់ផ្ដើមដូចតទៅនេះ ៖

## ១. ឧព្ភជាណុមណ្ឌលិកាសិក្ខាបទវណ្ណនា

### ពន្យល់អត្ថក្នុងឧព្ភជាណុមណ្ឌលិកាសិក្ខាបទ

[១] ក្នុងពាក្យថា តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ។បេ។ សាឡ្ហោ មិគារនត្តា : សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់សម្រេចឥរិយាបថនៅក្នុងជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង មានបុរសម្នាក់ឈ្មោះសាឡ្ហៈ ជាចៅនៃមិគារមាតា ។ នេះ ពាក្យថា សាឡ្ហោ ជាឈ្មោះរបស់មិគារនត្តានោះ ព្រោះគេជាចៅរបស់នាងវិសាខាមិគារមាតា ។ ព្រោះហេតុ

នោះ ព្រះធម្មសង្គាហកាចារ្យទើបពោលថា មិគារនត្តា : ជាចៅនៃមិគារមាតា ។

បទថា នវកម្មិកំ : ជាអ្នកបេះត្រួតត្រានវកម្ម គឺ អ្នកផ្តល់នវកម្ម ។

បទថា បណ្ឌិតា : ជាអ្នកប្រាជ្ញ គឺ អ្នកប្រកបដោយភាពជាបណ្ឌិត ។

បទថា ព្យត្តា : ជាអ្នកវាងវៃ គឺ ប្រកបដោយភាពជាអ្នកវាងវៃ ។

បទថា មេធាវិនី : មានប្រាជ្ញា បានដល់ អ្នកប្រកបដោយបញ្ញាមានសតិជាគោលក្នុងការរៀនបាលី និងដោយសតិបញ្ញាជាគោលក្នុងការរៀនអដ្ឋកថា ។

បទថា ទក្ខា : ឆ្លៀវឆ្លាស គឺ អ្នកឆ្លាត សេចក្តីថា អ្នកមានប្រក្រតីធ្វើការងារដែលគួរធ្វើបានរហ័ស មិនខុសផ្លាត ។

បទថា អនលសា : ឥតមានសេចក្តីខ្ជិលច្រអូស គឺ អ្នកប្រាសចាកសេចក្តីខ្ជិលច្រអូស ។

បទថា តត្រូបាយាយ : យោបល់ សេចក្តីថា ជាមកដើរក្នុងការងារទាំងនោះ ។

បទថា វីមំសាយ : ជាគ្រឿងយល់ សេចក្តីថា ដោយបញ្ញា

ជ្រើសរើសនូវការងារដែលគួរធ្វើ ។

បទថា សមន្នាគតា : ប្រកបដោយ គឺ ប្រកបព្រម ។

ពីរបទថា អលំ កាតុំ : អាចធ្វើ បានដល់ ជាអ្នកអាចដើម្បីធ្វើការងារនោះ ។

ពីរបទថា អលំ សំវិធាតុំ : និងអាចចាត់ចែងបាន បានដល់ ជាអ្នកអាចសូម្បីនឹងចាត់ការយ៉ាងនេះថា ការងារនេះចូរជាយ៉ាងនេះ និងការងារនេះចូរជាយ៉ាងនោះ ។

ពីរបទថា កតាកតំ ជានិតុំ : ដើម្បីដឹងការងារដែលធ្វើរួចហើយ និងមិនទាន់ធ្វើ គឺ ដើម្បីដឹងការងារដែលធ្វើហើយនិងមិនទាន់បានធ្វើ ។

បទថា តេ : នោះ មានសេចក្តីថា ជនទាំងពីរនោះ គឺ ភិក្ខុនីសុន្ទរនន្ទា និងនាយសាឡ្ហៈនោះ ។

បទថា ភត្តគ្គេ : ក្នុងរោងឆាន់ គឺ ក្នុងស្ថានទីអង្គាស ។

បទថា និក្កុដ្ឋេ : ត្រង់កៀនជញ្ជាំង គឺ ជាទីជ្រៅកំបាំងដែលសម្តែងឱ្យឃើញស្រដៀងជ្រុងកែង ។

បីបទថា វិស្សរោ មេ ភវិស្សតិ : សំឡេងឆោឡោនឹងមានដល់យើង មានសេចក្តីថា សំឡេងមិនបានការ នឹងមានដល់យើង គឺ នឹង

មានសំឡេងអាស្រូវផ្សេង ៗ ដល់យើង ។

បទថា បដិមានេន្តិ : គយគន់មើល គឺ រង់ចាំមើល ។

បទថា កយាហំ កាត់បទជា កឹ អហំ : ខ្ញុំមិនមែន សេចក្តីថា រឿងអីដែលថា ខ្ញុំនឹងមិនស្រឡាញ់នាងម្ចាស់ហ្ន៎ ។

បទថា ជរាទុព្វលា : មានកម្លាំងថយព្រោះជរា គឺ ទុព្វលភាពព្រោះជរា ។

បទថា ចរណគិលានា : ឈឺជើង គឺ ប្រកបដោយរោគត្រង់ជើង ។

បទថា អវស្សុតា : ដែលមានតម្រេក មានសេចក្តីថា ជាអ្នកមានតម្រេក គឺ ទទឹកជោកដោយតម្រេក ក្នុងការស្ទាបអង្អែលកាយ ។ តែក្នុងបទភាជនៈនៃបទថា អវស្សុតា នោះ ព្រះមានព្រះភាគ ទ្រង់សំដៅយករាគៈនោះឯង ទើបត្រាស់ពាក្យថា សារត្តា : មានសេចក្តីត្រេកអរព្រម ជាដើម ។

បណ្តាបទទាំងនោះ បទថា សារត្តា : មានសេចក្តីត្រេកអរព្រម គឺ អ្នកមានតម្រេកយ៉ាងខ្លាំងដោយកាយសំសគ្គរាគៈ ដូចសំពត់ត្រូវជ្រលក់ដោយពណ៌, ដូច្នោះ ។

បទថា អបេក្ខវតី : លបសម្លឹងមើល សេចក្តីថា អ្នកប្រកប

ដោយករសម្ទឹងដែលប្រព្រឹត្តទៅក្នុងបុរសនោះ ដោយអំណាចនៃតម្រេក នោះឯង ។

បទថា បដិពទ្ធចិត្តា : មានចិត្តប្រតិព័ទ្ធ បានដល់ ជាអ្នកមានចិត្តដូចត្រូវតម្រេកនោះ ចងក្រៀកទុកក្នុងបុរសនោះ ។ សូម្បីក្នុងវិភង្គនៃបទទី ២ ក៏មានន័យយ៉ាងនេះ ។

បទថា បុរិសបុគ្គលស្ស : បុរសបុគ្គល បានដល់ បុគ្គលពោល គឺ បុរស ។

បទថា អធក្ខកំ : ខាងក្រោមដងកាំបិត គឺ ក្រោមដងកាំបិតចុះទៅ ។

បទថា ឧព្ភជានុមណ្ឌលំ : ខាងលើមណ្ឌលជង្គង់ គឺ លើមណ្ឌលជង្គង់ទាំងពីរឡើងមក ។ តែក្នុងបទភាជនៈ ព្រះមានព្រះភាគត្រាស់ទុកដោយលំដាប់នៃបទតែម្តងថា ហេដ្ឋក្ខកំ ឧបរិជានុមណ្ឌលំ ខាងក្រោមដងកាំបិត ខាងលើមណ្ឌលជង្គង់ ដូច្នេះ ។

[២] ក៏ក្នុងបទថា ឧបរិជានុមណ្ឌលំ : ខាងលើតាំងពីមណ្ឌលជង្គង់ឡើងទៅ នេះ សូម្បីខាងលើកដែងឡើងមក លោកក៏សង្គ្រោះចូលខាងលើមណ្ឌលជង្គង់ឡើងមកដែរ ពាក្យដែលនៅសល់ បណ្ឌិតគប្បីជ្រាបដោយន័យដូចដែលព្រះមានព្រះភាគត្រាស់ទុកហើយក្នុងមហាវិភង្គនុ៎ះឯង ។

ពីរបទថា បុរិមាយោ ឧទ្ទាធាយ : ប្រៀបផ្ទឹមគ្នានឹងពួកភិក្ខុនីមានហើយក្នុងកាលមុន សេចក្ដីថា ទ្រង់ប្រៀបធៀបភិក្ខុនី ៤ រូបអ្នកត្រូវអាបត្តិបារាជិកនឹងដោយបារាជិកដែលទូទៅ (៤មានមេថុនជាដើម) ។

ក៏ពាក្យថា ឧព្ភជានុមណ្ឌលិកា : អវយវៈជាខាងលើមណ្ឌលនៃជង្គង់ នេះ ត្រឹមតែជាឈ្មោះនៃអាបត្តិបារាជិកនេះ; ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់មិនបានចែកទុកក្នុងបទភាជនៈ ។

លុះព្រះមានព្រះភាគចែកសិក្ខាបទ ដែលព្រះអង្គសម្ដែងទុកដោយលំដាប់នៃបទយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងប្រភេទនៃអាបត្តិដោយសេចក្ដីផ្សេងគ្នានៃអ្នកមានតម្រេកជាដើម ទើបបានត្រាស់ពាក្យថា ឧភតោ អវស្សុតេ : កាលបើជនទាំងពីរមានតម្រេកដូចគ្នា ជាដើម ។

## ទាំងពីរចំណែកមានសេចក្ដីតម្រេកចាប់ត្រូវកាយជាដើម

[៣] ក្នុងពាក្យថា ឧភតោ អវស្សុតេ ជាដើមនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ពាក្យថា ឧភតោ អវស្សុតេ : កាលបើជនទាំងពីរមានតម្រេកដូចគ្នា គឺ កាលទាំងពីរផ្នែកមានតម្រេក សេចក្ដីថា "កាលភិក្ខុនី និងបុរសជាអ្នកមានតម្រេកដោយកាយសំសគ្គរាគៈ" ។

បីបទថា កាយេន កាយំ អាមសតិ : ភិក្ខុនីឬបុរសស្ទាបកាយ

ដោយកាយ មានសេចក្ដីថា ភិក្ខុនីចាប់ពាល់កាយរបស់បុរសផ្នែកណាមួយ ដោយកាយតាមដែលកំណត់ទុក ឬថា បុរសចាប់ពាល់កាយរបស់ភិក្ខុនីផ្នែកណាមួយ តាមដែលកំណត់ទុកដោយកាយ (របស់ខ្លួន) ។ ជាបារាជិកដល់ភិក្ខុនីទាំងពីរប្រការ ។

ពីរបទថា កាយេន កាយបដិពទ្ធំ : (ស្ដាប)វត្ថុដែលជាប់នឹងកាយ ដោយកាយ គឺ (ភិក្ខុនីពាល់ត្រូវ) របស់ជាប់ដោយកាយបុរសដោយកាយរបស់ខ្លួន ដូចបានពោលហើយនុ៎ះឯង ។

ក្នុងបទថា អាមសតិ : ស្ដាប នេះ មានវិនិច្ឆ័យថា ភិក្ខុនីចាប់ពាល់ដោយខ្លួនឯង ឬត្រេកអរនឹងការចាប់ពាល់របស់បុរសនោះក៏ដោយជាថុល្លច្ច័យដូចគ្នា ។

ពីរបទថា កាយបដិពទ្ធេន កាយំ : (ស្ដាប)កាយ ដោយវត្ថុដែលជាប់នឹងកាយ បានដល់ ភិក្ខុនីចាប់ពាល់កាយរបស់បុរស ដោយរបស់ជាប់ដោយកាយរបស់ខ្លួន មានប្រការដូចពោលហើយ ។

សូម្បីក្នុងបទថា អាមសតិ នេះ ក៏មានវិនិច្ឆ័យថា ភិក្ខុនីចាប់ពាល់ដោយខ្លួនឯង ឬត្រេកអរការចាប់ត្រូវរបស់បុរសក៏ដោយ ជាថុល្លច្ច័យទាំងអស់ ។ សូម្បីក្នុងបទដែលនៅសល់ ក៏គប្បីជ្រាបវិនិច្ឆ័យដោយន័យនេះឯង ។ តែបើទាំងពីរជាភិក្ខុនិងភិក្ខុនី, បណ្ដាភិក្ខុនីនិងភិក្ខុនីនោះ បើភិក្ខុនីចាប់ពាល់ ភិក្ខុជាអ្នកស្ងៀមមិនកម្រើក គ្រាន់តែ(ទទួល)

ត្រេកអរដោយចិត្ត ព្រះវិន័យធរមិនគួរពិន័យភិក្ខុដោយអាបត្តិ ។ បើភិក្ខុចាប់ពាល់ ភិក្ខុនីជាអ្នកស្ងៀមមិនកម្រើកតែត្រេកអរដោយចិត្តតែម្យ៉ាង សូម្បីមិនឱ្យចំណែកនៃកាយញ័រ ព្រះវិន័យធរក៏គប្បីពិន័យដោយបារាជិកក្នុងខេត្តដែននៃបារាជិក ដោយថុល្លច្ច័យក្នុងខេត្តដែននៃថុល្លច្ច័យ ដោយទុក្កដក្នុងខេត្តទុក្កដ ។ ព្រោះហេតុអ្វី ? ព្រោះព្រះមានព្រះភាគត្រាស់ទុកថា "ត្រេកអរនឹងការស្ទាបក្តី អង្អែលក្តី ... ដោយកាយ" ។ នេះជាសេចក្តីវិនិច្ឆ័យក្នុងអដ្ឋកថាទាំងឡាយ ។ ក៏កាលមានវិនិច្ឆ័យយ៉ាងនេះ សេចក្តីដែលសិក្ខាបទនេះមានការធ្វើជាសមុដ្ឋាននោះ មិនប្រាកដឱ្យឃើញ ព្រោះហេតុនោះ សេចក្តីដែលសិក្ខាបទមានការធ្វើជាសមុដ្ឋាននោះ បណ្ឌិតគប្បីជ្រាបថា ពួកអាចារ្យពោលទុកដោយន័យ គឺ សេចក្តីដែលសិក្ខាបទនោះមានការធ្វើជាសមុដ្ឋានទាំងនោះជាចំណែកច្រើន ។

[៤] បទថា ឧព្ភក្ខកំ : **ខាងលើតាំងពីដងកាំបិទឡើងទៅ** គឺ ខាងលើនៃដងកាំបិតទាំងពីរ ។

បទថា អធោជានុមណ្ឌលំ : **ខាងក្រោមតាំងពីមណ្ឌលជង្គង់ចុះមក** គឺ ខាងក្រោមនៃមណ្ឌលជង្គង់ទាំងពីរ ។ មួយទៀត សូម្បីខាងលើកដៃឡើងមក លោកក៏សង្គ្រោះចូលខាងលើមណ្ឌលជង្គង់ដែរ ក្នុងបទថា អធោជានុមណ្ឌលំ នេះ ។

[៥] ក្នុងពាក្យ ឯកតោ អវស្សុតេ : **កាលបើមានតម្រេកតែ**

ម្ខាង នេះ ព្រះមានព្រះភាគត្រាស់ពាក្យថា ឯកតោ ទុកដោយមិនប្លែកគ្នាក៏ពិតមែន, តែថា បណ្ឌិតគប្បីជ្រាបថា កាលភិក្ខុនីមានតម្រេកប៉ុណ្ណោះ សេចក្តីផ្សេងនៃអាបត្តិនេះ ព្រះមានព្រះភាគទើបត្រាស់ទុក ។

ក្នុងសិក្ខាបទនេះ មានវិនិច្ឆ័យតាំងពីដើមដូចតទៅនេះ ៖

ភិក្ខុនីតម្រេកដោយសេចក្តីតម្រេកក្នុងការស្ទាបអង្អែលកាយ ដល់បុរសក៏យ៉ាងនោះដូចគ្នា កាលមានសេចក្តីត្រេកអរក្នុងការស្ទាបអង្អែលកាយក្នុងកាយប្រទេសតាំងពីដងកាំបិតចុះមក លើមណ្ឌលជង្គង់ឡើងទៅ ជាបារាជិកដល់ភិក្ខុនី ។ ភិក្ខុនីមានសេចក្តីតម្រេកក្នុងការស្ទាបអង្អែលកាយ ។ ចំណែកបុរសមានសេចក្តីតម្រេកក្នុងមេថុន ឬមានសេចក្តីស្រឡាញ់អាស្រ័យផ្ទះ ឬមានចិត្តបរិសុទ្ធិក៏ដោយ ជាថុល្លច្ច័យទាំងអស់ ភិក្ខុនីមានតម្រេកក្នុងមេថុន, ចំណែកបុរសមានតម្រេកក្នុងការស្ទាបអង្អែលកាយ ឬមានតម្រេកក្នុងមេថុន ឬមានសេចក្តីស្រឡាញ់អាស្រ័យផ្ទះ ឬមានចិត្តបរិសុទ្ធិក៏ដោយ ជាទុក្កដ ។ ភិក្ខុនីមានសេចក្តីស្រឡាញ់អាស្រ័យផ្ទះ, ចំណែកបុរសមានចិត្តយ៉ាងណាមួយ ក្នុងឋានៈ ៤ ដូចពោលហើយ ជាទុក្កដដូចគ្នា ។ ភិក្ខុនីមានចិត្តបរិសុទ្ធិ, តែបុរសមានចិត្តយ៉ាងណាមួយក្នុងឋានៈ ៤ ដូចពោលមកហើយ មិនជាអាបត្តិ ។ តែបើជាភិក្ខុ នឹងភិក្ខុនីទាំងពីរចំណែកមានតម្រេកក្នុងការស្ទាបអង្អែលកាយ, ចំណែកភិក្ខុជាសង្ឃាទិសេស, ភិក្ខុនីជាបារាជិក ។ ភិក្ខុនីមានតម្រេកក្នុង

ការស្ទាបអង្អែលកាយ, ចំណែកភិក្ខុមានតម្រេកក្នុងមេថុនក្តី សេចក្តីស្រឡាញ់អាស្រ័យផ្ទះក្តី ជាថុល្លច្ច័យដល់ភិក្ខុនី ជាទុក្កដដល់ភិក្ខុ ។ ទាំងពីរចំណែកមានតម្រេកក្នុងមេថុនក្តី មានសេចក្តីស្រឡាញ់អាស្រ័យផ្ទះក្តី ជាទុក្កដដូចគ្នាសូម្បីទាំងពីរចំណែក ។ ចំណែកណាមានចិត្តបរិសុទ្ធក្នុងឋានៈ( មានការចាប់ត្រូវជាដើម )ណាមួយ, ចំណែកនោះ មិនជាអាបត្តិក្នុងឋានៈនោះ ៗ ។ សូម្បីទាំងពីរចំណែកមានចិត្តបរិសុទ្ធ ក៏មិនជាអាបត្តិទាំងពីរចំណែក ។

[១១] ក្នុងបទថា អនាបត្តិ អសញ្ចិច្ច : **ភិក្ខុនីមិនក្លែង** ជាដើម មានវិនិច្ឆ័យថា ភិក្ខុនីចាប់ត្រូវខុសផ្លាតទៅក្តី បញ្ជូនចិត្តទៅមកដទៃក្តី មិនដឹងថា អ្នកនេះជាប្រុស ឬស្រីក្តី ដល់ត្រូវបុរសនោះពាល់ត្រូវ ក៏មិនត្រេកអរនឹងផស្សៈនោះក្តី សូម្បីកាលមានការចាប់ពាល់ ក៏មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ក្នុងបទទាំងពួង ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក( របស់ភិក្ខុ ) ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មានវេទនា ២ ដូច្នេះឯង ។

ឧព្ភជាណុមណ្ឌលិកាសិក្ខាបទវណ្ណនា ចប់ ។

# ២. វជ្ជប្បដិច្ឆាទិកាសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងបារាជិកបទទី ២ ដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងវជ្ជប្បដិច្ឆាទិកាសិក្ខាបទ

[១២] បទថា កច្ចិំនោ សា កាត់បទជា កច្ចិំ នុ សា : សុទ្ធ វីនន្ទានោះ (មានគតភ៌តាំងអំពីទៅជាភិក្ខុនី) នៅឡើយទេឬ

បទថា អវណ្ណោ : ទោស គឺ មិនមែនគុណ ។

បទថា អកិត្តិ : កេរ្តិ៍ឈ្មោះអាក្រក់ គឺ ការតិះដៀល ។

បទថា អយសោ : សេចក្តីអាប់យស បានដល់ ការបាត់បង់បរិវារ, ម្យ៉ាងទៀត បានដល់ ការតិះដៀលកំបាំងមុខ ។

[១៣] ពាក្យថា សា វា អារោចេតិ : ភិក្ខុនីដែលត្រូវបារាជិកនោះប្រាប់ក្តី បានដល់ នាងភិក្ខុនីអ្នកដែលត្រូវបារាជិកហើយ មកប្រាប់ដោយខ្លួនឯងក្តី ។

ពាក្យថា អដ្ឋន្នំ ធារាជិកានំ អញ្ញតរំ : បណ្តាបារាជិកទាំង ៨ ណាមួយ បានដល់ បារាជិក ៤ ដែលសាធារណៈនឹងភិក្ខុទាំងឡាយ និងបារាជិក ៤ ដែលមិនទូទៅយ៉ាងណាមួយ ។ ម្យ៉ាងទៀត បារាជិកនេះព្រះមានព្រះភាគទ្រង់បញ្ញត្តិជាខាងក្រោយ, ព្រោះដូច្នោះ ទើបត្រាស់ទុកក្នុងវិភង្គថា អដ្ឋន្នំ ។ តែបណ្ឌិតគប្បីជ្រាបថា ព្រះសង្គីតិកាចារ្យទាំង

ឡាយ ចាត់តាំងបារាជិកនេះ ទុកក្នុងឱកាសនេះ ក៏ព្រោះជាគូនឹងសិក្ខាបទមុន ។

[១៦] ពីរបទថា ធុរំ និក្ខិត្តមត្តេ : **គ្រាន់តែដាក់ធុរៈ** គឺ ល្មមកាលលោកដាក់ធុរៈចេញ ។ ក៏កថាពិស្តារក្នុងសិក្ខាបទនេះ បណ្ឌិតគប្បីជ្រាបដោយន័យដូចបានពោលហើយក្នុងទុដ្ឋុល្លសិក្ខាបទ ក្នុងសប្បាណវគ្គនោះឯង ។ ប៉ុន្តែ មានសេចក្ដីប្លែកគ្នាត្រឹមតែប៉ុណ្ណេះថា ពិតមែន ក្នុងទុដ្ឋុល្លសិក្ខាបទនោះ ជាបាចិត្តិយ, ក្នុងសិក្ខាបទនេះ ជាបារាជិក ។ ពាក្យដែលនៅសល់ដូចគ្នាទាំងអស់ ។

សូម្បីពាក្យថា វជ្ជប្បដិច្ឆាទិកា : **ជួយបិទបាំងទោសគេ** នេះ ក៏ត្រឹមតែជាឈ្មោះនៃបារាជិកនេះប៉ុណ្ណោះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបទ្រង់មិនចែកទុកក្នុងបទភាជនៈ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន កើតឡើងមកកាយវាចាចិត្ត ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្មវចីកម្ម អកុសលចិត្ត ទុក្ខវេទនា ដូច្នេះឯង ។

វជ្ជប្បដិច្ឆាទិកាសិក្ខាបទវណ្ណនា ចប់ ។

# ៣. ឧក្កិត្តានុវត្តិកាសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងបារាជិកសិក្ខាបទទី៣ ដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងឧក្ខិត្តានុវត្តិកាសិក្ខាបទ

[១៨] បទថា ធម្មេន : តាមធម៌ បានដល់ តាមវត្ថុដែលពិត ។

បទថា វិនយេន : តាមវិន័យ បានដល់ ចោទហើយឱ្យរលឹក ។ ក៏បទភាជនៈនៃពីរបទថា ធម្មេន វិនយេន : តាមធម៌ តាមវិន័យ នោះ ព្រះមានព្រះភាគត្រាស់ទុក ដើម្បីទ្រង់សម្ដែងត្រឹមតែអធិប្បាយនេះថា អ្នកដែលត្រូវសង្ឃលើកវត្តតាមធម៌ តាមវិន័យ ជាអ្នកត្រូវលើកវត្តដោយប្រពៃហើយ ។

បទថា សត្ថុសាសនេន : តាមសត្ថុសាសនា បានដល់ ដោយញត្តិសម្បទា និងអនុស្សាវនាសម្បទា, តែក្នុងបទភាជនៈនៃបទថា សត្ថុសាសនេន នោះ ត្រាស់ត្រឹមតែពាក្យវេវចនៈប៉ុណ្ណោះថា ដោយជិនសាសន៍ គឺដោយពុទ្ធសាសនៈ ។

[១៩] ក្នុងពាក្យថា សង្ឃំ វា គណំ វា : សង្ឃក្ដី គណៈក្ដី ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

មិនជឿ គឺមិនប្រព្រឹត្តតាមសង្ឃដែលធ្វើកម្ម ឬគណៈ គឺបុគ្គល

ច្រើនរូប ឬបុគ្គលតែម្នាក់ ដែលរាប់បញ្ចូលក្នុងសង្ឃនោះ ឬរាប់បញ្ចូលក្នុងកម្មនោះ អធិប្បាយថា មិនញុំាងសេចក្តីអើពើឱ្យកើតឡើងក្នុងសង្ឃជាដើមនោះ ។

ក្នុងពាក្យថា សមានសំវាសកា ភិក្ខូ វុច្ចន្តិ សហាយា សោ តេហិ សទ្ធឹ នត្ថិ : ភិក្ខុទាំងឡាយ ដែលមានសំវាសស្មើគ្នា តថាគតហៅថា មានការរួបរួមជាមួយគ្នា ការរួបរួមជាមួយគ្នានោះ មិនមានមួយអន្លើដោយភិក្ខុនោះទេ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ធម៌នេះ គឺ កម្មរួមគ្នា ឧទ្ទេសរួមគ្នា ភាពជាអ្នកមានសិក្ខាស្មើគ្នា ឈ្មោះថា សំវាស ។ សំវាសនៃភិក្ខុពួកនោះស្មើគ្នា; ហេតុនោះ ភិក្ខុទាំងនោះ ទើបឈ្មោះថា មានសំវាសស្មើគ្នា ។ ភិក្ខុទាំងឡាយបែបនេះ ត្រាស់ហៅថា សម្លាញ់ ព្រោះមានភាវៈដែលប្រព្រឹត្តទៅរួមគ្នាក្នុងសំវាសនាះនៃភិក្ខុ ។

ឥឡូវនេះ សំវាសដែលជាហេតុឱ្យត្រាស់ហៅភិក្ខុទាំងនោះថា អ្នកមានសំវាសស្មើគ្នា មិនមានដល់ភិក្ខុដែលត្រូវសង្ឃលើកវត្តនោះ រួមទាំងភិក្ខុទាំងនោះ និងពួកភិក្ខុដែលលោកមិនមានសំវាសនោះរួមផង ជាការដែលលោកមិនបានធ្វើឱ្យជាសម្លាញ់របស់ខ្លួន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបបានត្រាស់ថា "ភិក្ខុទាំងឡាយ ដែលមានសំវាសស្មើគ្នា តថាគតហៅថា មានការរួបរួមជាមួយគ្នា, ការរួបរួមជាមួយគ្នានោះ មិន

មានមួយអន្លើដោយភិក្ខុទាំងឡាយនោះទេ ហេតុនោះ ភិក្ខុនោះ ទើបតថាគតហៅថា ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ” ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ព្រោះមានន័យដូចបានពោលហើយក្នុងសង្ឃភេទសិក្ខាបទជាដើម ។

សិក្ខាបទនេះ មានការសូត្រសមនុភាសន៍ជាសមុដ្ឋាន កើតឡើងមកកាយ វាចាចិត្ត ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ដូច្នេះឯង ។

ឧក្ខិត្តានុវត្តិកាសិក្ខាបទវណ្ណនា ចប់ ។

# ៤. អដ្ឋវត្ថុកាសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងបារាជិកសិក្ខាបទទី៤ ដូចតទៅនេះ ៖

## ពន្យល់អត្ថអដ្ឋវត្ថុកាសិក្ខាបទ

[២៦] បទថា អវស្សុតា : មានសេចក្ដីត្រេកអរ បានដល់ អ្នកមានតម្រេក ដោយកាយសំសគ្គរាគៈ ដោយអំណាចមិត្តសន្ថវៈ ពោលគឺសេចក្ដីត្រេកអរក្នុងមកលោកិយ ។ សូម្បីក្នុងបទទី២ ក៏ន័យនេះឯង ។

ក៏ក្នុងពាក្យថា បុរិសបុគ្គលស្ស ហត្ថគ្គហណំ វា : ការចាប់ដៃក្ដី របស់បុរសបុគ្គល ជាដើម មានវិនិច្ឆ័យថា ការចាប់ដៃដែលមនុស្សប្រុសធ្វើហើយត្រាស់ហៅថា "ការចាប់ដៃនៃបុរសបុគ្គល" ។ សូម្បីក្នុងការចាប់ជាយសំពត់សង្ឃាដិ ក៏ន័យនេះដូចគ្នា ។ តែការចាប់ដៃ និងការចាប់សូម្បីយ៉ាងដទៃ ក្នុងខេត្តដែលមិនជាបារាជិក បណ្ឌិតគប្បីជ្រាបថា លោករួមចូលតែមួយ ហៅថា ការចាប់ដៃ ក្នុងពាក្យថា ហត្ថគ្គហណំ : ចាប់ដៃ នេះ ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា ហត្ថគ្គហណំ នោះ ទើបព្រះមានព្រះភាគត្រាស់ថា "ពាក្យថា ហត្ថគ្គហណំ វា សាទិយេយ្យ : ត្រេកអរនឹងការចាប់ដៃក្ដី សេចក្ដីថា ដែលហៅថា ដៃ គឺ វាសតាំងពីដើមដៃរហូតដល់ចុងក្រចក ។ ភិក្ខុនីត្រេកអរនឹងការចាប់

ខាងលើតាំងពីជងកាំបិតឡើងទៅ ខាងក្រោមតាំងពីមណ្ឌលជង្គង់ចុះមក ដើម្បីនឹងសេពអសទ្ធម្មនោះ ត្រូវអាបត្តិថុល្លច្ច័យ” ។ តែក្នុងបទថា អសទ្ធម្មស្ស : ដើម្បីនឹងសេពអសទ្ធម្ម នេះ ការស្ទាបអង្អែលកាយ គប្បីជ្រាបថា “អសទ្ធម្ម” មិនមែនមេថុនធម្ម ។ ពិតមែន ថុល្លច្ច័យមិន ជិតចំពោះមេថុនធម្មទេ ។ មួយទៀត សូម្បីពាក្យថា “ជាអ្នកដឹងភាពជា អ្នកអាចដើម្បីដល់ការស្ទាបអង្អែលកាយ” ក៏ជាគ្រឿងបរិយាយបាន ក្នុង បទថា អសទ្ធម្មោ នេះ ។

បើអ្នកតវ៉ា នឹងគប្បីតវ៉ាថា “ពាក្យដែលលោកពោលថា ការ ស្ទាបអង្អែលកាយ គប្បីជ្រាបថា អសទ្ធម្ម ក៏ខុសពីសេទមោចនគាថា ដែលត្រាស់ទុកក្នុងគម្ពីរបរិវារនេះថា ៖

តិស្សិត្ថិយោ មេថុនំ តំ ន សេវេ
តយោ បុរិសេ តយោ ច អនរិយបណ្ឌកេ
ន ចាចរេ មេថុនំ ព្យញ្ជនស្មឹ
ឆេជ្ជា សិយា មេថុនធម្មប្បច្ចយា
បញ្ហា មេសា កុសលេហិ ចិន្តិតា ។

“ឧបសម្បន្ន មិនសេពមេថុននឹងស្រី ៣ ពួកនោះ នឹង បុរស៣ ពួកទៀត មិនសេពមេថុននឹងអនរិយជន គឺ

ឧភតោព្យញ្ជនក ៣ ពួក និងបណ្ឌកៈ ៣ ពួក, មួយទៀត មិនបានប្រព្រឹត្តមេថុនក្នុងព្យញ្ជនៈ គឺដោយអំណាចនៃអនុលោមបារាជិកសោះឡើយ តែឧបសម្បន្នទោះ ត្រូវឆេជ្ជវត្ថុ ព្រោះមេថុនធម្ម ជាបច្ច័យ, ប្រស្នានេះ លោកអ្នកឈ្លាវៃ បានគិតគ្នាមកហើយ”[១] ដូច្នេះ ។

ឆ្លើយថា មិនខុស ព្រោះកាយសំសគ្គៈ ជាបុព្វភាគនៃមេថុន ។ ពិតមែន ក្នុងបរិវារនុ៎ះឯង បានត្រាស់សិក្ខាបទ ៥ មានសុក្កវិស្សដ្ឋិជាដើមថា ជាបុព្វភាគនៃមេថុនធម្មយ៉ាងនេះថា សេចក្ដីដែលថា គប្បីជ្រាប បុព្វភាគនៃមេថុនធម្ម បានដល់ សុក្កៈមានពណ៌, មានពណ៌ច្រើន កាយសំសគ្គៈ ទុដ្ឋុល្លវាចា អត្តកាមបារិចរិយា (ការឱ្យផ្កាឈើ ស្លឹកឈើឱ្យរបស់ប្រចាំចិត្ត)[២] សញ្ចរិត្តៈ (គប្បីជ្រាបថា បុព្វភាគនៃមេថុនធម្ម) ។ ព្រោះហេតុនោះ កាយសំសគ្គៈ ទើបឈ្មោះថា ជាបច្ច័យព្រោះជាបុព្វភាគនៃមេថុនធម្ម ។

បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងពាក្យថា ឆេជ្ជំ សិយា មេថុនធម្មប្បច្ចយា : តែឧបសម្បន្នទោះ ត្រូវឆេជ្ជវត្ថុ ព្រោះមេថុនធម្មជាបច្ច័យ

១. វិន. បរិ. សេទមោចនគាថា. ១៣. ៤១២/៤១២ ។ ២. វនមនុប្បទានំ វិមតិ; ជា គមនុប្បាទនន្តិ សញ្ចរិត្តំ ។

នេះ ដោយបរិយាយនេះ ដោយប្រការដូច្នេះ ។ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងពួងដោយឧបាយនេះ ។

[២៧] ន័យមួយទៀត ក្នុងបទភាជនៈនៃពីរបទថា សង្កេតំ វា គច្ឆេយ្យ : **ទៅកាន់ទីសង្កេតក្តី** នេះ ពីរបទថា ឥត្ថន្នាមំ អាគច្ឆ : **ចូលមកកាន់ទីឈ្មោះនេះ** មានសេចក្តីថា លោកចូលមកកាន់ស្ថានទីមានឈ្មោះយ៉ាងនេះ ។

[២៨] ពាក្យថា អដ្ឋមំ វត្ថុំ បរិបូរេន្តី អស្សមណី ហោតិ : **ញុំាងវត្ថុទាំង ៨ ឱ្យពេញ ក៏មិនមែនជាសមណី** មានសេចក្តីថា ភិក្ខុនីធ្វើវត្ថុទី៨ ឱ្យពេញបរិបូណ៌ដោយន័យណាមួយ និងដោយអនុលោម ឬដោយបដិលោម ឬដោយវ័ណ្ណជាវគ្គក៏ដោយ ជាអ្នកមិនមែនសមណី ។ ចំណែកភិក្ខុនីណាធ្វើវត្ថុតែមួយ ឬ ៧ វត្ថុឱ្យពេញ សូម្បីទាំង ៧ ជងនឹងជាអ្នកឈ្មោះថា មិនមែនសមណីក៏ទេដែរ ភិក្ខុនីនោះ សម្តែងអាបត្តិដែលត្រូវហើយ រមែងផុតបាន ។ ន័យមួយទៀត ក្នុងសិក្ខាបទនេះ បណ្ឌិតគប្បីជ្រាបអាបត្តិដែលគួររាប់ ។ សមពិត ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា "**អត្ថាបត្តិ ទេសិតា គណនូបិកា, អត្ថាបត្តិ ទេសិតា ន គណនូបិកា** : អាបត្តិដែលសម្តែងហើយ គួររាប់ (ជាសម្តែងហើយ) ក៏មាន អាបត្តិដែលសម្តែងហើយ មិនគួររាប់ (ជាសម្តែងហើយ) ក៏មាន" ។

ក្នុងពាក្យថា ធុរនិក្ខិត្តមត្តេ សម្តែងហើយ គួររាប់ជាដើមនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

អាបត្តិដែលភិក្ខុនីធ្វើការដាក់ធុរៈ សម្តែងថា "ឥឡូវនេះ យើងនឹងមិនត្រូវ" ចាត់ថា គួររាប់ គឺដល់ការរាប់ថា បានសម្តែងហើយ មិនជាអង្គនៃបារាជិក ។ ព្រោះដូច្នោះ ភិក្ខុនីណាត្រូវអាបត្តិមួយ ធ្វើការដាក់ធុរៈសម្តែងហើយត្រឡប់ត្រូវទៀត ដោយអំណាចនៃកិលេស, ត្រឡប់សម្តែងទៀត, ភិក្ខុនីនោះកាលធ្វើវត្ថុទាំង ៨ ឱ្យពេញយ៉ាងនេះ ក៏មិនជាបារាជិក ។ ក៏ភិក្ខុនីណា ត្រូវហើយសម្តែង ទាំងដែលនៅមានសេចក្តីឧស្សាហ៍ថា "យើងនឹងត្រូវវត្ថុយ៉ាងដទៃទៀត, អាបត្តិរបស់ភិក្ខុនីនោះមិនគួររាប់, សូម្បីលោកសម្តែងហើយ ក៏មិនជាការសម្តែងឡើយគឺ មិនទាន់ដល់ការរាប់ថា បានសម្តែងហើយ នៅជាអង្គនៃបារាជិកតែម្តង, លុះមកកាលវត្ថុទី ៨ គ្រប់បរិបូណ៌, លោកក៏ត្រូវបារាជិក ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន កើតឡើងមកកាយវាចាចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្មវចីកម្ម អកុសលចិត្ត មានវេទនា ២ ដូច្នេះឯង ។

អដ្ឋវត្ថុកាសិក្ខាបទវណ្ណនា ចប់បរិបូណ៌តាមវណ្ណនានុក្រម ។

ចំនួនសិក្ខាបទបារាជិកជាអសាធារណសម្រាប់ភិក្ខុនី គឺ

១. ឧព្ភជាណុមណ្ឌលិកាសិក្ខាបទ ការមានតម្រេកក្នុងស្មាបជាដើមត្រង់ខាងក្រោម តាំងពីដងកាំបិតចុះមក និងខាងលើតាំងពីលើមណ្ឌលជង្គង់ឡើងទៅ

២. វជ្ជប្បដិច្ឆាទិកាសិក្ខាបទ ការជួយបិទបាំងទោសគេ

៣. ឧក្ខិត្តានុវត្តិកាសិក្ខាបទ ការប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្ត

៤. អដ្ឋវត្ថុកាសិក្ខាបទ ការមានតម្រេកក្នុងវត្ថុ ៨

# សរុបបារាជិក ៨

[៣០] បណ្ឌិតគប្បីឃើញសេចក្ដីក្នុងពាក្យថា ឧទ្ទិដ្ឋា ខោ អយ្យាយោ អដ្ឋបារាជិកា ធម្មា : បពិត្រលោកអ្នកមានអាយុទាំងឡាយ **អាបត្តិបារាជិកទាំង ៨ ខ្ញុំសម្ដែងឡើងហើយ** នេះ យ៉ាងនេះថា "បពិត្រលោកម្ចាស់អាបត្តិបារាជិទាំងឡាយ ៨ ខ្ញុំសម្ដែងឡើងហើយ, ដោយត្រឹមតែជាបាតិមោក្ខុទ្ទេសយ៉ាងនេះគឺ បារាជិក ៤ ដែលទូទៅ ដែលទ្រង់ប្រារព្ធពួកភិក្ខុបញ្ញត្តិទុក និងបារាជិកទាំង ៤ នេះ" ។ ពាក្យដែលនៅសល់ មានន័យដូចដែលពោលហើយក្នុងមហាវិភង្គនោះឯង ។

អដ្ឋកថា បារាជិកកណ្ឌក្នុងភិក្ខុនីវិភង្គ ចប់ ។

# សត្តរសកសង្ឃាទិសេសកណ្ឌវណ្ណនា

ឥឡូវនេះ នឹងមានការពណ៌នាអត្ថដែលនៅមិនទាន់ជាក់ច្បាស់ នៃ សង្ឃាទិសេសកណ្ឌ ដែលជាលំដាប់បន្ទាប់ពីបារាជិកមកដូចតទៅនេះ ៖

## ១. ឧស្សយវាទិកាសិក្ខាបទវណ្ណនា

### រឿងភិក្ខុនីជាអ្នកដើមចោទនាំឡើងក្តីក្នុងចៅក្រម

[៣១] បទថា ឧទ្ទោសិតំ : ឃ្លាំង បានដល់ រោងរក្សារបស់ ។

ពាក្យថា មាយ្យោ ឯវំ អវច : អ្នកម្ចាស់កុំនិយាយយ៉ាងនេះឡើយ គឺ នាយកុំនិយាយយ៉ាងនេះ ។

បទថា អបិន្ទយ្យា កាត់បទជា អបិ នុ អយ្យា : អ្នកទាំងឡាយ....ខ្លះដែរ

បទថា អច្ចាវទថ : អ្នកទាំងឡាយ ចូរពោលឱ្យក្រៃពេក បានដល់ ពួកលោកចូរពោលកន្លងហួស, មានពាក្យអធិប្បាយថា "ចូរជេរ" ។

បទថា ឧស្សុយ្យវាទិកា[1] : ជាអ្នកប្តឹងប្តល់ បានដល់ ជាអ្នកពេញ

---

១. ភូមា. ឧស្សយវាទិកា; ថៃ. ឧស្សូយវាទិកា ។

ចិត្តពោលរករឿងដោយអំណាចសេចក្តីឫស្សា ព្រោះមានះ ដោយអំណាចសេចក្តីឫស្សា ព្រោះសេចក្តីក្រោធ ។ តែព្រោះចូលទន្ទាភិក្ខុនីនោះ ជាអ្នកចូរចិត្តបង្កក្តីដោយសភាព ដូច្នោះ ទើបបានត្រាស់ទុកក្នុងបទភាជនៈថា "ដែលហៅថា ប្តឹងប្តល់ គឺ សំដៅយក ភិក្ខុនីជាអ្នកក្តី" ។

[៣២] ក៏ក្នុងពាក្យថា អឌ្ឌការិកា : **ភិក្ខុនីជាអ្នកក្តី** នេះ ការវិនិច្ឆ័យរបស់ពួកចៅក្រម លោកហៅថា "ក្តី" ចំណែកខាងបព្វជិត ហៅថា "អធិករណ៍" ខ្លះក៏មាន ។

ពីរបទថា ទុតិយំ វា បរិយេសតិ : **ស្វែងរកគ្នាជាគម្រប់ពីរក្តី** មានសេចក្តីថា ភិក្ខុនីអ្នកបង្កក្តី ស្វែងរកសាក្សី ឬសម្លាញ់ ជាទុក្កដ ។

បទថា គច្ឆតិ វា : **ដើរទៅក្តី** មានសេចក្តីថា នឹងជាលំនៅ ឬមកត្រាច់ភិក្ខាចារក៏ដោយ ភិក្ខុនីដើរចេញកន្លែងដែលខ្លួនឈរឆ្ពោះទៅកាន់កន្លែងការងាររបស់ពួកចៅក្រម ហើយកើតសេចក្តីគិតឡើងថា យើងនឹងដំណើរការរឿងក្តី ជាទុក្កដគ្រប់ ៗជំហាន ។

ពីរបទថា ឯកស្ស អារោចេតិ : **ប្តឹងចៅក្រមម្នាក់** មានសេចក្តីថា បណ្តាជន ២ នាក់ អ្នកណា ប្រាប់ពាក្យរបស់អ្នកណាមួយ គឺរបស់ភាគីម្ខាងទៀត ដល់ពួកចៅក្រម សូម្បីក្នុងពាក្យថា ទុតិយស្ស អារោចេតិ នេះ ក៏ន័យនុះឯង ។

ចំណែកវិត្ថារកថា ដើម្បីប្រយោជន៍ ដល់សេចក្តីមិនស្រពេចស្រពិល ក្នុងពាក្យថា ឯកស្ស អារោចេតិ នេះ ដូចតទៅនេះ ៖

ភិក្ខុនីឃើញពួកចៅក្រម ក្នុងទីកន្លែងណាមួយ ដោយហោចទៅសូម្បីអ្នកមកកាន់លំនៅនៃភិក្ខុនី ហើយឱ្យពាក្យរបស់ខ្លួន ជាទុក្កដដល់ភិក្ខុនី ។ ឧបាសកឱ្យពាក្យរបស់ខ្លួន ជាថុល្លច្ច័យដល់ភិក្ខុនី ។ ឧបាសកឱ្យពាក្យរាយករណ៍របស់ខ្លួនមុន ជាទុក្កដដល់ភិក្ខុនី ។ បើភិក្ខុនីនោះឱ្យពាក្យរបស់ខ្លួនមុន ភិក្ខុនីជាថុល្លច្ច័យ ។

ភិក្ខុនីនិយាយ ចំពោះឧបាសកថា លោកហ្នឹងហើយចូរថ្លែងប្រកាស (ចូរប្រាប់ហេតុការណ៍) របស់ខ្ញុំ និងរបស់លោក ។ ឧបាសកនោះប្រាប់ហេតុការណ៍របស់ខ្លួនមុន ឬចូរប្រាប់ហេតុការណ៍របស់ភិក្ខុនីមុនក៏ដោយ ជាទុក្កដ ព្រោះការប្រាប់លើកទី១, ជាថុល្លច្ច័យព្រោះក្នុងការប្រាប់ការណ៍លើកទី២ ។ សូម្បីក្នុងពាក្យថា “ឧបាសកនិយាយចំពោះភិក្ខុនីថា នាងម្ចាស់ទ្រាំងឯង ចូរប្រាប់ហេតុការណ៍របស់ខ្ញុំ និងរបស់នាងម្ចាស់ចុះ” នេះ ក៏មានន័យដូចគ្នា ។ ភិក្ខុនីប្រើកប្បិយការកៈ ឱ្យអះអាង ។ បណ្តាកប្បិយការកៈ និងឧបាសកនោះ កប្បិយការកៈ ចូរឱ្យលើកពាក្យរបស់ភិក្ខុនីមុនក្តី ឧបាសកក្រៅនេះ ឱ្យលើកពាក្យរបស់ខ្លួនមុនក្តី កប្បិយការកៈ ចូរឱ្យលើកពាក្យរបស់អ្នកទាំង ២ ក្តី ឧបាសកក្រៅនេះ ចូរឱ្យលើក

ពាក្យរបស់អ្នកទាំង ២ ក្តី កាលជនទាំង ២ អះអាងប្រាប់ដោយប្រការណាមួយ ជាទុក្កដដល់ភិក្ខុនី ក្នុងការអះអាងប្រាប់ហេតុការណ៍លើកដំបូង, ជាថុល្លច្ច័យ ក្នុងការអះអាងប្រាប់ហេតុការណ៍លើកទី ២ ។

តែកាលពួកចៅក្រមស្តាប់ពាក្យអះអាងរបស់អ្នកទាំង ២ ផ្អែកដែលអះអាងឱ្យលើកទៅ ដោយប្រការយ៉ាងណាមួយ ធ្វើការវិនិច្ឆ័យហើយ ក្តីជាការដល់ទីបំផុត ។ ក្នុងក្តីដែលដល់ទីបំផុតនោះ ភិក្ខុនីនឹងឈ្នះក្តីក៏ដោយ បរាជ័យក៏ដោយ ជាសង្ឃាទិសេស ។

តែបើថា អធិករណ៍ដែលដំណើរការជាក្តីហើយ ជារឿងដែលពួកចៅក្រមធ្លាប់បានជ្រាបមកមុន បើពួកចៅក្រមទាំងនោះ ល្មមឃើញភិក្ខុនីនិងអ្នកបង្កក្តី ទើបពោលថា “មិនមានកិច្ចដែលនឹងត្រូវដេញដោលសួរពួកលោក, ពួកយើងដឹងរឿងនេះ” ហើយទើបកាត់ក្តីឱ្យដោយខ្លួនឯងតែម្តង ។ សូម្បីក្នុងក្តីដល់ទីបំផុតបែបនេះ ក៏មិនជាអាបត្តិដល់ភិក្ខុនី ។

សង្ឃាទិសេសនេះ មានការត្រូវតាំងពីមុនធ្វើ ព្រោះដូច្នោះ ទើបឈ្មោះថា បឋមបត្តិកៈ ។ សេចក្តីថា “គប្បីត្រូវក្នុងខណៈដែលកន្លងល្មើសទុំះឯង” ។ នូវសង្ឃាទិសេសនោះ មានការត្រូវអាបត្តិខណៈមុនធ្វើ ។ តែក្នុងបទភាជនៈ ដើម្បីសម្តែងត្រឹមតែសេចក្តីប្រាថ្នា ទើបព្រះមានព្រះភាគត្រាស់ថា “ភិក្ខុនីត្រូវអាបត្តិមួយអន្លើដោយករប្រព្រឹត្តកន្លងវត្ថុ

ជាដំបូង មិនមែនដោយការសូធ្យសមនុភាសនកម្មទេ” ។

ក៏ក្នុងពាក្យនេះ មានសេចក្តីដូចតទៅនេះ ៖

ភិក្ខុនីត្រូវអាបត្តិព្រមទាំងការកន្លងល្មើសក្នុងវត្ថុ មិនមែនត្រូវក្នុងវេលាសូធ្យសមនុភាសនៈលើកទី ៣ សង្ឃាទិសេសនេះ ឈ្មោះថា បឋមាបត្តិកៈ ព្រោះនឹងគប្បីត្រូវអាបត្តិព្រមទាំងការប្រព្រឹត្តកន្លងវត្ថុ តាំងពីដំបូងតែម្តងនោះឯង ។

[៣៣] សង្ឃាទិសេសនេះ ឈ្មោះថា និស្សារណីយៈ ព្រោះអត្ថថា ដេញចេញចាកពួកភិក្ខុនី ។ នូវសង្ឃាទិសេសមានការដេញចេញចាកពួកនោះ ។ តែក្នុងបទភាជនៈ ដើម្បីសម្តែងត្រឹមតែសេចក្តីប្រាថ្នា ទើបព្រះមានព្រះភាគត្រាស់ថា សង្ឃម្ហា និស្សារីយតិ ៖ ភិក្ខុនីនោះ ត្រូវភិក្ខុនីឯទៀតនាំចេញអំពីសង្ឃ ក្នុងបទថា និស្សារណីយំ ៖ គួរបណ្តេញចេញចាកសង្ឃ នោះ បណ្ឌិតគប្បីឃើញសេចក្តីយ៉ាងនេះថា ភិក្ខុនីត្រូវសង្ឃាទិសេសណា ត្រូវបណ្តេញចេញចាកពួក, សង្ឃាទិសេសនោះ ឈ្មោះថា និស្សារណីយៈ ។ ពិតមែន ធម៌ គឺ អាបត្តិនោះ អ្នកណានឹងដេញចេញចាកពួកមិនបានឡើយ តែភិក្ខុនីត្រូវធម៌នោះ ដេញចេញទៅ ព្រោះដូច្នោះ ធម៌នោះ ទើបឈ្មោះថា និស្សារណីយៈ ដោយអត្ថថា “ដេញចេញ” ។

[៣៨] ពីរបទថា អាកឌ្ឍិយមានា គច្ឆតិ : កោះនាំទៅ មានសេចក្តីថា ភិក្ខុនីត្រូវពួកអ្នកស្រុកដែលបន្តឹងមកដោយខ្លួនឯង ឬបញ្ជូនទូតមកហៅខ្លួនទៅ កាន់សំណាក់ការងាររបស់ពួកចៅក្រម ។ តពីនោះ អ្នកបន្តឹងនឹងអះអាងពាក្យរបស់ខ្លួនមុន ឬពាក្យរបស់ភិក្ខុនីមុនក៏ដោយ ក្នុងការអះអាងលើកដំបូង ក៏មិនជាទុក្កដឡើយ ក្នុងការអះអាងប្រាប់ការណ៍លើកទី ២ ក៏មិនជាថុល្លច្ច័យ ។ សូម្បីក្នុងក្តី ដែលពួកអាមាត្យធ្វើការវិនិច្ឆ័យសម្រេចដល់ទីបំផុតហើយ ក៏មិនជាអាបត្តិដូចគ្នា ។ បើសូម្បីថា អ្នកបន្តឹងពោលនឹងភិក្ខុនីថា "សូមឱ្យលោកនុ៎ះឯង ចូរអះអាងពាក្យរបស់ខ្ញុំនិងរបស់លោក" ។ សូម្បីកាលភិក្ខុនីអះអាង ពួកអាមាត្របានស្តាប់ពាក្យហើយ ធ្វើក្តីឱ្យសម្រេចដល់ទីបំផុត ក៏មិនជាអាបត្តិដូចគ្នា ។

## ការសូមរក្សាអំពីមកស្រុកក្រុង

ពីរបទថា អារក្ខំ យាចតិ : សូមអារក្ខា បានដល់ សូមរក្សាដែលជាធម៌ មិនជាអាបត្តិ ។ ឥឡូវនេះ ដើម្បីសម្តែងវិធី សូមរក្សាដែលជាធម៌ ព្រះមានព្រះភាគទើបត្រាស់ថា "ភិក្ខុនីមិនប្តឹងចំពោះឈ្មោះ" ។

ក្នុងពាក្យថា អនោទិស្ស[១] អាចិក្ខតិ : ភិក្ខុនីប្តឹងមិនចំពោះ

១. ថៃ. អនុទ្ទិស្ស ។

ឈ្មោះ នោះ មានវិនិច្ឆ័យដូច្នេះ ៖

ប្រារព្ធអតីតប្រាប់ចំពោះខ្លួនក៏មាន ប្រាប់មិនចំពោះខ្លួនក៏មាន សូម្បីប្រារព្ធអនាគតប្រាប់ចំពោះខ្លួនក៏មាន ប្រាប់មិនចំពោះខ្លួនក៏មាន ។

ប្រារព្ធអតីតប្រាប់ចំពោះខ្លួន តើយ៉ាងណា ? គឺ កន្លែងសំណាក់របស់ភិក្ខុនី ពួកក្មេងអ្នកស្រុក ឬពួកមនុស្សអន្ធពាលមានអ្នកលេងជាដើមណាមួយ ប្រព្រឹត្តអនាចារក្តី កាត់ដើមឈើក្តី លួចផ្លែឈើតូចធំក្តី ដណ្តើមយកបរិក្ខារក្តី ។ ភិក្ខុនីចូលទៅរកពួកប្រធានរក្សាច្បាប់ប្រាប់ថា "កន្លែងសំណាក់របស់ពួកយើង មានការធ្វើប្រទូស្តកម្មឈ្មោះនេះ" កាលគេសួរថា "អ្នកណាធ្វើ" ប្រាប់ថា "អ្នកឯណោះ ៗ" ...ដោយអាការយ៉ាងនេះ ចាត់ជាការប្រាប់ចំពោះខ្លួនប្រារព្ធអតីត ។ ការប្រាប់ចំពោះខ្លួននោះ មិនគួរ ។ បើពួកប្រធានរក្សាច្បាប់ទាំងនោះ ស្តាប់ពាក្យនោះហើយធ្វើការពិន័យដល់ជនទាំងនោះ ទ្រព្យទាំងអស់ដែលត្រូវពិន័យ ជាទ្រព្យដែលភិក្ខុនីត្រូវសងដល់ជនទាំងនោះវិញ ។ សូម្បីកាលមានសេចក្តីប្រាថ្នាថា "យើងនឹងទទួលយកទ្រព្យ ក៏ជាទ្រព្យត្រូវសងដូចគ្នា ។ តែបើភិក្ខុនីពោលថា "សូមឱ្យលោកពិន័យអ្នកនោះ" កាលអ្នកពិន័យ យកទ្រព្យប្រមាណ ៥ មាសក ជាបារាជិក ( ដល់ភិក្ខុនី ) ។

តែកាលគេសួរថា "អ្នកណាធ្វើ" ភិក្ខុនីគួរពោលថា "ការដែល

នឹងនិយាយថា  អ្នកឈ្មោះឯណោះ  មិនសមគួរដល់យើង  លោកដឹងដោយខ្លួនឯងចុះ  ព្រោះពួកយើងត្រឹមតែសូមរក្សាតែម្យ៉ាង  លោកមេត្តាឱ្យការរក្សានោះដល់ពួកយើង  និងឱ្យនាំរបស់ដែលត្រូវលួចទៅ  ត្រឡប់មកវិញ” ។  ការសូមការរក្សាមិនចំពោះខ្លួន  រមែងជាយ៉ាងនេះ ។  ការសូមរក្សាមិនចំពោះខ្លួននោះ  គួរ ។

កាលភិក្ខុនីពោលយ៉ាងនោះហើយ  បើសូម្បីពួកអ្នករក្សាច្បាប់ទាំងនោះ  ស៊ើបអង្កេតខ្លួនអ្នកធ្វើហើយ  ធ្វើការពិន័យដល់អ្នកធ្វើទាំងនោះ ។ សូម្បីសម្បត្តិគ្រប់យ៉ាងដែលត្រូវប្រធានពិន័យ  មិនជាទ្រព្យត្រូវសង  ទាំងមិនជាអាបត្តិដល់ភិក្ខុនីឡើយ ។  សូម្បីឃើញពួកចោរលួចបរិក្ខារទៅនឹងពោលថា  “ចោរ ៗ”  ព្រោះត្រូវការសេចក្ដីវិនាសដល់ចោរនោះ  ក៏មិនគួរ ។  ពិតមែន  សូម្បីកាលភិក្ខុនីពោលយ៉ាងនោះ  ទ្រព្យសម្បត្តិដែលអ្នកធ្វើការពិន័យដល់ចោរទាំងនោះ  សូម្បីទាំងអស់  ជាសម្បត្តិដែលភិក្ខុនីត្រូវសង ។  តែនឹងពោលនឹងអ្នកជឿស្ដាប់ពាក្យរបស់ខ្លួនថា  “អ្នកនេះលួចយកបរិក្ខាររបស់យើងទៅ  ចូរឱ្យនាំបរិក្ខារនោះត្រឡប់មកវិញ  និងកុំដាក់ទោសគេ” ដូច្នេះ  គួរ ។

ពួកភិក្ខុនីធ្វើការប្ដឹងក្ដី  ដើម្បីប្រយោជន៍ដល់ទាសប្រុស  ទាសស្រីនិងបឹងជាដើម ។  ក្ដីនេះ  ឈ្មោះថា  ក្ដីជាអកប្បិយៈ  មិនសមគួរ ។

ការប្រាប់ចំពោះខ្លួនប្រារព្ធអនាគត តើយ៉ាងណា ? គឺ កាលជនពួកដទៃធ្វើអនាចារជាដើម ដោយន័យដូចពោលហើយនុ៎ះឯង ភិក្ខុនីនិយាយចំពោះពួកប្រធានអ្នករក្សាច្បាប់យ៉ាងនេះថា "ពួកអ្នកស្រុកធ្វើកម្មនេះ និងកម្មនេះ ក្នុងសំណាក់របស់ពួកយើង, សូមឱ្យការរក្សាដល់ពួកយើង ដើម្បីត្រូវការមិនឱ្យធ្វើតទៅ" កាលគេសួរថា អ្នកណាធ្វើយ៉ាងនេះ" ប្រាប់ថា "អ្នកឯណោះ ៗ" ។ យ៉ាងនេះ ចាត់ជាការប្រាប់ចំពោះខ្លួនប្រារព្ធអនាគត ។ សូម្បីការប្រាប់ចំពោះខ្លួននោះ ក៏មិនគួរ ។ ព្រោះកាលប្រធានអ្នកដែលរក្សាច្បាប់ ធ្វើការពិន័យដល់ជនទាំងនោះ ទ្រព្យដែលត្រូវពិន័យទាំងអស់ជាទ្រព្យដែលភិក្ខុនីត្រូវសង ដោយន័យមុនដូចគ្នា ។ ពាក្យដែលនៅសល់ ដូចគ្នានឹងពាក្យមុន ៗ នុ៎ះឯង ។

តែបើអ្នករក្សាច្បាប់ ឱ្យវាយស្គរប្រកាសថា "នឹងធ្វើទោសឈ្មោះនេះ ដល់ពួកអ្នកធ្វើអនាចារបែបនេះ ក្នុងសំណាក់ភិក្ខុនី" ហើយស្វែងរកអ្នកមិនតាំងនៅក្នុងការបង្គាប់មកដាក់ទោស មិនជាទ្រព្យត្រូវសងវិញទេ ទាំងមិនជាអាបត្តិដល់ភិក្ខុនីឡើយ ។ មួយទៀត សូម្បីពួកភិក្ខុ ក៏មានជួរដំណើរការ ដូចដែលពោលទុកសម្រាប់ពួកភិក្ខុនីនេះដែរ ។

ពិតមែន ការប្រាប់ចំពោះខ្លួន មិនសមគួរសូម្បីដល់ភិក្ខុ ។ កាលភិក្ខុប្រាប់ចំពោះខ្លួនយ៉ាងនោះ ទ្រព្យដែលត្រូវប្រធានធ្វើការពិន័យ ជា

ចំណែករបស់ស្តេចទាំងអស់ ជាទ្រព្យត្រូវសង (ដល់ភិក្ខុ) ។ ជាបារាជិកដល់ភិក្ខុដែលឱ្យប្រធានអ្នករក្សាច្បាប់ពិន័យទ្រព្យ ដោយន័យដូចពោលហើយនុ៎ះឯង ។ ចំណែកភិក្ខុណា ប្រាប់មិនចំពោះខ្លួនទាំងដែលដឹងថា "អ្នកដឹកនាំដែលគេនឹងធ្វើទោស" ។ និងប្រធានអ្នករក្សាច្បាប់ទាំងនោះ តាមរកខ្លួនមកដាក់ទោសទាល់តែបាន ។ មិនមានទោសដល់ភិក្ខុនោះ ។

ការដែលភិក្ខុយកកាំបិតនិងពូថៅជាដើមរបស់ពួកអ្នកស្រុក ដែលលបកាត់ដើមឈើជាដើម ក្នុងព្រៃប្រទល់វត្តមកហើយ យកដុំថ្មដំ មិនគួរ ។ បើមុខឆែបទៅ ភិក្ខុគប្បីឱ្យដុសដុលហើយយកទៅសងវិញ ។ ពួកភិក្ខុរត់ចូលមកចាប់កាន់យកបរិក្ខាររបស់អ្នកទាំងនោះទុក ។ សូម្បីការចាប់កាន់យកបរិក្ខារនោះទុក ក៏មិនគួរធ្វើ ។ ព្រោះចិត្តជាធម្មជាតិត្រឡប់របាស កាលកើតថេយ្យចិត្តឡើង នឹងគប្បីដល់ភាពជាអ្នកដាច់មូលក៏បាន ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ ជាកិរិយា ក្នុងសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឧស្សយវាទិកាសិក្ខាបទវណ្ណនា ចប់ ។

# ២. ចោរិវុដ្ឋាបិកាសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

## រឿងភិក្ខុនីបំបួសស្រីចោរ

[៣៥] បទថា វរភណ្ឌំ : របស់ដែលមានតម្លៃ បានដល់ភណ្ឌៈដែលមានតម្លៃច្រើន ដូចកែវមុក្តា កែវមណី និងកែវពិទូរ្យជាដើម ។

បទថា អបលោកេត្វា : មិនបានប្រាប់ គឺ មិនពោលប្រាប់ ។

បទថា គណំ វា : គណៈក្តី បានដល់ គណៈ មានមល្លគណៈ និងភទ្ទបុត្តគណៈ[១] ជាដើម ។

បទថា បូគំ : ប្រជុំជន បានដល់ ធម្មគណៈ[២] ។

បទថា សេណឹ : ពួកជាង[៣] បានដល់ ពួកជាងធ្វើរបស់ក្រអូប និងពួកជាងតម្បាញជាដើម ។

ពិតមែន ព្រះរាជាទាំងឡាយ រមែងប្រគល់ស្រុក និងនិគមដល់ពួកជនមានគណៈជាដើម ក្នុងស្ថានទីណា ៗថា ពួកលោកប៉ុណ្ណោះ ចូរឃុំ

---

១. សារត្ថទីបនី ឱ្យអត្ថាធិប្បាយថា ពួកអ្នកបំពេញបុញ្ញកម្ម មានការបាត់តាំងនូវទឹកផឹកនិងជីកស្រះទឹកជាដើមទុកក្នុងទីនោះ ៗ ដែលជាអ្នកមានភក្តីភាព( រាប់អាន )ព្រះនារាយណ៍ ឈ្មោះថា មល្លគណៈ ។ ពួកអ្នកមានភក្តីភាព( រាប់អាន )ព្រះកុមារ ឈ្មោះថា ភទ្ទិបុត្តគណៈ ។ ២. គណៈអ្នកបំពេញបុញ្ញកម្មមានប្រការផ្សេង ៗ ដែលមានភក្តីភាពចំពោះព្រះសាសនា ហៅថា ធម្មគណៈ ។ ៣. បិដកប្រែថា សេនា ។

គ្រងនូវស្រុក និងនិគមនេះ ៗ ជនទាំងនោះឯង រមែងជាធំក្នុងស្រុក និងនិគមនោះ ៗ, ព្រោះហេតុនោះ ពាក្យថា គណំ វា ជាដើមនេះ ត្រាស់សំដៅយកជនទាំងនោះ ។

ក៏បណ្ដាឥស្សរជន មានព្រះរាជាជាដើមនេះ ភិក្ខុនីសូម្បីទូលសូមព្រះបរមរាជានុញ្ញាត ឬប្រាប់ពួកជនមានគណៈជាដើមហើយ ត្រូវប្រាប់ភិក្ខុនីសង្ឃផង ។

[៣៦] ពីរបទថា ឋបេត្វា កប្បំ : លើកទុកតែមានសំបុត្រច្បាប់ មានសេចក្ដីថា វៀរស្ត្រីអ្នកបានអាងធ្លាប់បួសហើយក្នុងពួកតិរ្ថិយ ឬក្នុងពួកភិក្ខុនីដទៃ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានការឱ្យស្រីចោរបួសជាសមុដ្ឋាន កើតឡើងមកវាចាចិត្ត សម្រាប់ភិក្ខុនីដែលកាលពួកភិក្ខុនីជៀសទៅ ដោយករណីយ៍យ៉ាងណាមួយ មិនទៅកាន់ខណ្ឌសីមា ឱ្យស្រីចោរបួស នឹងបរិស័ទអ្នកជានិស្សិតរបស់ខ្លួន ក្នុងស្ថានទីតាមដែលខ្លួនអង្គុយនុ៎ះឯង កើតឡើងមកកាយវាចាចិត្ត សម្រាប់ភិក្ខុនីអ្នកទៅកាន់ខណ្ឌសីមា ឬទន្លេហើយបំបួសជាកិរិយានិងជាអកិរិយា ដោយអំណាចការមិនពោលប្រាប់ការឱ្យបួស ជាសញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ចោរិវុដ្ឋាបិកាសិក្ខាបទវណ្ណនា ចប់ ។

# ៣. ឯកគាមន្តរគមនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

## ជំហានដែលធ្វើឱ្យភិក្ខុនីត្រូវអាបត្តិ

[៤៤] ក្នុងពាក្យថា អតិក្កាមេន្តិយា : **ឈានទៅ** នេះ មានវិនិច្ឆ័យថា កាលភិក្ខុនីលើកជើងម្ខាងឈានទៅ ជាថុល្លច្ច័យ, លុមឈានជើងទី ២ កន្លងទៅ ជាសង្ឃាទិសេស ។

ក្នុងពាក្យថា អបរិក្ខិត្តស្ស គាមស្ស ឧបចារំ : **ឧបចារស្រុកដែលមិនមានរបង** នេះ មានវិនិច្ឆ័យថា ភិក្ខុនីដើរកន្លងផុតទីគួរឡោមព័ទ្ធទៅដោយជើងម្ខាង ជាថុល្លច្ច័យ, លុមឈានដើរទៅដោយជើងខាងទី ២ ជាសង្ឃាទិសេស ។ ន័យមួយទៀត ក្នុងពាក្យថា បរិក្ខេបំ អតិក្កាមេន្តិយា : **ឈានចូលទៅកាន់របង** ជាដើមនេះ បណ្ឌិតគប្បីជ្រាបពាក្យពិស្ដារថា ភិក្ខុនីចេញចាកស្រុករបស់ខ្លួនទៅ មិនជាអាបត្តិព្រោះចន្លោះស្រុកជាបច្ច័យ ។ តែគ្រាចេញទៅហើយទៅកាន់ចន្លោះស្រុក (ដទៃ) ជាទុក្កដគ្រប់ ៗ ជំហាន ។ តែកាលកន្លងហួសរបងឡោមព័ទ្ធ ឬ ឧបចារៈរបស់ស្រុកមួយទៀត ទៅដោយជើងម្ខាង ជាថុល្លច្ច័យ, លុមឈានហួសទៅដោយជើងទី ២ ជាសង្ឃាទិសេស ។ សូម្បីភិក្ខុនីអ្នកចេញពីចន្លោះស្រុកនោះទៅ ហើយត្រឡប់ចូលមកកាន់ស្រុករបស់ខ្លួន ក៏

ន័យនេះដូចគ្នា ។

តែបើភិក្ខុនីអាចចូលទៅកាន់ទីវត្តនុ៎ះឯង បានប្រឡោះកំពែងធ្លាយ ឬប្រឡោះរបង, កាលចូលទៅយ៉ាងនេះ ចាត់ជាអ្នកចូលទៅកាន់កប្បិយភូមិ ព្រោះហេតុនោះ ទើបសមគួរ ។ បើសូម្បីថា ភិក្ខុនីនឹងចូលទៅដោយពាហនៈមានខ្នងដំរីជាដើម ឬដោយឫទ្ធិ ក៏គួរដូចគ្នា ។ ព្រោះថាការដើរទៅដោយជើងប៉ុណ្ណោះ លោកប្រាថ្នាយកក្នុងសិក្ខាបទនេះ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **បឋមំ បាទំ អតិក្កាមេន្តិយា : ឈានជំហានដំបូងចូលទៅ** ជាដើម ។

ស្រុកពីរមានរបងជាប់នឹងវត្តរបស់ភិក្ខុនី ។ វត្តរបស់ភិក្ខុនីនៅជិតស្រុកណា, ភិក្ខុនីនឹងត្រាច់ទៅបិណ្ឌបាតក្នុងស្រុកនោះហើយត្រឡប់ចូលកាន់វត្ត ដើរទៅតាមមករបស់ស្រុកមួយទៀត បើមានមកឆ្លងកាត់កណ្ដាលវត្តទៅ ក៏គួរ ។ តែគួរត្រឡប់មកចាកពីស្រុកនោះ ដោយមកនោះដូចគ្នា ។ បើភិក្ខុនីចេញមកមកទ្វារស្រុក ។ គប្បីជ្រាបប្រភេទនៃអាបត្តិដោយន័យមុននុ៎ះឯង ។

កាលភិក្ខុនីចេញចាកស្រុករបស់ខ្លួន ព្រមនឹងពួកភិក្ខុនី ដោយករណីយ៍យ៉ាងណាមួយ ក្នុងវេលាត្រឡប់ចូលមក ដំរីរបូតមកក្ដី មានការបណ្ដេញឱ្យជៀសទៅក្ដី ពួកភិក្ខុនីក្រៅនេះប្រញាប់ចូលទៅកាន់ស្រុក, គប្បីឈរចាំក្រៅទ្វារទាល់តែភិក្ខុនីដទៃមក ។ បើមិនទាន់មក, ភិក្ខុនីជា

សម្លាញ់ ឈ្មោះថា ជៀសទៅហើយ, នឹងចូលទៅ ក៏គួរ ។

កាលមុនជាស្រុកធំ ដែលមានវត្តភិក្ខុនីនៅត្រង់កណ្ដាល ។ ខាងក្រោយមក អ្នកទាំង ៤ បាន (គ្រប់គ្រង) ស្រុកនោះហើយបែងចែកគ្នាប្រើប្រាស់ ការពាររបងឡោមព័ទ្ធទុកជាក្រុម ។ ភិក្ខុនីនឹងចេញពីវត្តទៅកាន់ស្រុកណាមួយ គួរ ។ នឹងចេញពីស្រុកចូលទៅកាន់ស្រុកមួយទៀត ដែលទៅហើយនោះ មកទ្វារស្រុក ឬមកប្រហោងរបង មិនគួរ ។ គួរបែរត្រឡប់មកកាន់វត្តសិន ។ ព្រោះហេតុអ្វី ? ព្រោះវត្តជាទីសាធារណៈដល់ស្រុកទាំង ៤ ។

## លក្ខណៈទន្លេ និងភិក្ខុនីដែលទៅកាន់ត្រើយទន្លេ

ពីរបទថា អន្តរវាសកោ តេមីយតិ : ស្បង់ក៏ទទឹកបាន មានសេចក្ដីថា ស្ថានទីដែលភិក្ខុនីគ្រងសំពត់ដោយអាការបិទមណ្ឌល ៣ លុយឆ្លងទៅក្នុងទឹកទន្លេណាមួយ មកកំពង់ ឬមិនមែនកំពង់ក្នុងរដូវភ្លៀង អន្តរវាសក (សំពត់ស្លៀក) សើមសូម្បីត្រឹមតែមួយធ្នាប់ឬ ២ ធ្នាប់ (ឈ្មោះថា ទន្លេ) ។ លក្ខណៈនៃទន្លេដែលនៅសល់ នឹងមានច្បាស់ក្នុងនទីនិមិត្តកថា ។ ក្នុងវេលាដែលភិក្ខុនីលុយឆ្លងទន្លេមានសភាពបែបនេះ មកកំពង់របស់ទន្លេ ឬ មិនមែនកំពង់ កាលលើកជើងទី ១ ឡើងដាក់លើត្រើយ ជាថុល្លច្ច័យ ក្នុងការលើកជើងទី ២ ជាសង្ឃាទិសេស ។

ដើរទៅតាមស្ពាន មិនជាអាបត្តិ ។ ក្នុងវេលាលុយឆ្លងដោយជើង មិនជាអាបត្តិសូម្បីដល់ភិក្ខុនីដែលតោងស្ពានឆ្លងទៅ ។ តែក្នុងវេលាឆ្លងទៅមកស្ពាន កាលដើរទៅ ជាអាបត្តិដូចគ្នា ។ សូម្បីក្នុងការទៅមកយាន មកទូក និងមកអាកាសជាដើម ក៏ន័យនេះឯង ។

កាលភិក្ខុនី (លោត) ពីត្រើយនេះជាន់ត្រើយឯណោះកន្លងផុត មិនជាអាបត្តិ ។ ពួកភិក្ខុនីទៅដើម្បីធ្វើការជ្រលក់ចីវរ ២-៣ រូប ត្រាច់ទៅទៀបត្រើយទាំងពីរ ដោយកិច្ចមានការជញ្ជូនអុសមកជាដើម គួរ ។ តែបើថា បណ្ដាភិក្ខុនីទាំងនេះ រូបខ្លះបង្កការឈ្លោះគ្នាហើយ ទៅកាន់ត្រើយមួយទៀត ជាអាបត្តិពីររូបឆ្លងទឹកទៅជាមួយគ្នា, មួយរូបធ្វើការឈ្លោះគ្នា, ក្នុងកណ្ដាលទន្លេ ត្រឡប់មកកាន់ត្រើយនេះទៀត ក៏ជាអាបត្តិ ។ តែភិក្ខុនីរូបនេះ ជាអ្នកតាំងនៅក្នុងឋាននៃភិក្ខុនី មានសម្លាញ់របស់ភិក្ខុនីមួយរូបទៀតជៀសទៅ ព្រោះដូច្នោះ ទើបមិនជាអាបត្តិ សូម្បីដល់ភិក្ខុនីអ្នកទៅកាន់ត្រើយឯណោះ ។ ភិក្ខុនីអ្នកចុះកាន់ទន្លេដើម្បីងូត ឬដើម្បីផឹកទឹក ហើយត្រឡប់ឡើងកាន់ត្រើយពីដើមនុ៎ះឯង មិនជាអាបត្តិ ។

ក្នុងពាក្យថា សហ អរុណុគ្គមនា : ព្រមគ្នានឹងអរុណរះឡើងនេះ មានវិនិច្ឆ័យដូច្នេះ ៖

បើភិក្ខុនីធ្វើការស្វាធ្យាយក្ដី សេចក្ដីព្យាយាមក្ដី កម្មអ្វី ៗ យ៉ាងដទៃក្ដី ធ្វើសេចក្ដីនឹកថា "យើងនឹងទៅកាន់លំនៅនៃសម្លាញ់ភិក្ខុនីមុន

អរុណោរះនុ៎ះឯង” ។ តែកាលលោកមិនទាន់ដឹងនុ៎ះឯង អរុណោរះឡើងមុន, មិនជាអាបត្តិ ។ តែបើថា លោកសម្រាកក្នុងឯកទេសនៃវិហារ ដោយសេចក្តីទឹកដល់ ឬដោយមិនបានទឹកដល់ថា “យើងនឹងនៅក្នុងទីនេះឯងដរាបដល់អរុណោរះឡើង” ។ លោកមិនឈានចុះកាន់ហត្ថបាសនៃភិក្ខុនីជាសម្លាញ់ ក្នុងវេលាអរុណោរះ ជាសង្ឃាទិសេស ។ ពិតមែន ហត្ថបាសប៉ុណ្ណោះ ជាប្រមាណក្នុងសិក្ខាបទនេះ ។ ក្នុងការកន្លងហួសហត្ថបាសទៅសូម្បីបន្ទប់ជាមួយគ្នា ក៏ការពារអាបត្តិមិនបាន ។

ក្នុងពាក្យថា អគាមកេ អរញ្ញេ : ក្នុងព្រៃមិនមែនជាស្រុក នេះ មានវិនិច្ឆ័យដូច្នេះ ៖

ដែលឈ្មោះថា ព្រៃចំពោះដែលមានលក្ខណៈ ដូចដែលត្រាស់ទុកយ៉ាងនេះថា “ក្រៅសសរឥន្ទខីលចេញទៅ ទីទាំងអស់នេះ ឈ្មោះថាព្រៃ” ។ ក៏ព្រៃនោះ ព្រះមានព្រះភាគត្រាស់ថា អគាមកំ ព្រោះមិនមានស្រុកតែម្យ៉ាង, មិនមែន ព្រោះដូចគ្នានឹងព្រៃស្រោង ។

កាលភិក្ខុនីឈានចូលព្រៃដូច្នោះ លះឧបចារៈនៃការមើលឃើញទៅហើយ បើសូម្បីឧបចារៈនៃការបានឮ នៅមាន ក៏ជាអាបត្តិ ។ ព្រោះហេតុនោះ ក្នុងអដ្ឋកថា លោកទើបពោលថា “កាលពួកភិក្ខុនីចូលទៅកាន់លានមហាពោធិ× ភិក្ខុនីមួយរូបឈរខាងក្រៅ ជាអាបត្តិសូម្បីដល់ភិក្ខុនីរូបនោះ ។ ក្នុងពួកភិក្ខុនីអ្នកចូលទៅកាន់លោហប្រាសាទក្តី អ្នកចូលទៅ

កាន់បរិវេណក្តី ក៏ន័យដូចគ្នា ។

ក្នុងការថ្វាយបង្គំព្រះមហាចេតិយជាដើម ភិក្ខុនីមួយរូប ចេញទៅតាមទ្វារខាងលើ ជាអាបត្តិសូម្បីដល់ភិក្ខុនីរូបនោះ ។ បណ្តាភិក្ខុនីដែលចូលទៅកាន់ថូបារាម ភិក្ខុនីមួយរូបឈរខាងក្រៅ, សូម្បីភិក្ខុនីនោះ ក៏ជាអាបត្តិ" ។ ក៏បណ្តាឧបចារៈនៃការមើលឃើញ និងឧបចារៈនៃការបានឮនេះ ភិក្ខុនីជាសម្លាញ់ ឃើញភិក្ខុនីឈរក្នុងទីណា ទីនោះឈ្មោះថាឧបចារៈនៃការមើលឃើញ ។ តែបើមានសូម្បីរាំងននការពារនៅចន្លោះភិក្ខុនី ឈ្មោះថា លះឧបចារៈនៃការមើលឃើញ ។ ស្ថានទីដែលភិក្ខុនីជាសម្លាញ់ឈរ បានឮសំឡេងរបស់ភិក្ខុនីអ្នកថ្លែងសំឡេងថា អយ្យេ : នាងម្ចាស់ ដោយសំឡេង ខ្លាំងសំឡេងប្រកួកហៅនៃអ្នកវង្វេងមក និងដោយសំឡេងខ្លាំង សំឡេងស្រែកប្រាប់ឱ្យស្តាប់ធម៌ ឈ្មោះថា ឧបចារៈនៃការបានឮ ។ ទោះជាក្នុងឱកាសទីវាលឆ្ងាយ ក៏ចាត់ជាទស្សនូបចារបាន ។ ទស្សនូបចារនោះ ការពារមិនបាន ក្នុងកាលភិក្ខុនីលះសវនូបចារបែបនោះទៅ ។ លុះមលះសវនូបចារប៉ុណ្ណោះ ក៏ត្រូវអាបត្តិសង្ឃាទិសេស ។

ភិក្ខុនីមួយរូប ធ្វើដំណើរតាមពីក្រោយសម្លាញ់, បើជាអ្នកនៅមានសេចក្តីឧស្សាហ៍ដើរតាមជាប់ទៅដោយតាំងចិត្តថា "យើងនឹងតាមឱ្យទាន់ឥឡូវនេះ" មិនជាអាបត្តិ ។ ប្រសិនបើភិក្ខុនីពួកខាងមុខចេញទៅមកដទៃចាត់ថា ជាអ្នកមានសម្លាញ់ភិក្ខុនីជៀសទៅ មិនជាអាបត្តិដូចគ្នា ។

បណ្តាភិក្ខុនី ២ រូបធ្វើដំណើរទៅជាមួយគ្នា មួយរូបមិនអាចតាមទាន់ដើរតាមពីក្រោយដោយគិតថា "ភិក្ខុនីនេះចូរទៅមុនចុះ", សូម្បីមួយរូបទៀត ក៏ដើរទៅដោយគិតថា "ភិក្ខុនីនេះមកតាមក្រោយចុះ" ត្រូវអាបត្តិទាំងពីររូប ។ តែបើថា ក្នុងភិក្ខុនី ២ រូប អ្នកកំពុងធ្វើដំណើរមួយរូបដើរមុខប្រកាន់យកមកមួយគ្គី មួយរូបដើរក្រោយប្រកាន់យកមកមួយគ្គី, មួយរូបតាំងនៅក្នុងឋាននៃអ្នកមានសម្លាញ់ជៀសទៅរបស់មួយរូបទៀត ទើបមិនជាអាបត្តិសូម្បីទាំងពីររូប ។

[៤៦] បទថា បក្ខសង្កន្ដា វា : ចូលទៅកាន់ពួកតិរ្ថិយគ្គី បានដល់ អ្នកទៅចូលអន្យតិរ្ថិយ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឯកគាមន្តរគមនសិក្ខាបទវណ្ណនា ចប់ ។

# ៤. ឧក្កិត្តកឱសារណសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

[៤៧] ទីដាក់ជើងដែលលាងហើយ ឈ្មោះថា តាំងស្បែកជើង ។ ទីសម្រាប់ស្បែកជើងដែលមិនទាន់លាងឈ្មោះថា កន្សែងជូតជើង ។

ពាក្យថា អនញ្ញាយ គណស្ស ឆន្ទំ **: មិនដឹងសេចក្តីប្រាថ្នារបស់ពួកភិក្ខុនី បានដល់ មិនដឹងឆន្ទៈរបស់ពួកគណៈអ្នកធ្វើនោះឯង ។**

[៥១] ពីរបទថា វត្តេ វត្តន្តឹ **: ភិក្ខុនីដែលប្រព្រឹត្តតាមវត្ត** បានដល់ អ្នកប្រព្រឹត្តប្រពៃក្នុងនេត្ថារវត្ត (វត្តជាហេតុរលាស់ចេញ) ៤៣ ប្រភេទ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន កើតឡើងមកកាយវាចាចិត្ត ជាកិរិយានិងជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ កាយកម្មវចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ឧក្កិត្តកឱសារណសិក្ខាបទវណ្ណនា ចប់ ។

# ៥. ភោជនប្បដិគ្គហណបឋមសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[៥៥] លោកពោលទុកក្នុងមហាបច្ចរីថា "ក្នុងពាក្យថា ឯកតោ អវស្សុតេ : កាលបើមានតម្រេកតែម្ខាង នេះបណ្ឌិតគប្បីឃើញថា ភិក្ខុនីជាអ្នកមានសេចក្តីត្រូវពេញចិត្ត" ។ តែក្នុងអដ្ឋកថា លោកមិនបានពោលពាក្យថា "ចំណែកមួយមានសេចក្តីត្រូវពេញចិត្ត"នេះទុក ពាក្យនោះសមដោយព្រះបាលី ។ ពាក្យដែលនៅសល់ងាយស្រួលយល់ទាំងនោះ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ភោជនប្បដិគ្គហណបឋមសិក្ខាបទវណ្ណនា ចប់ ។

# ៦. ភោជនប្បដិក្ខេបាណត្តិយសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

[៥៧] ពីរបទថា យតោ តុំ : កាលណាបើលោក ខែជា យស្មា តុំ : ព្រោះថា កាលណាបើលោក ។

សួរថា អាបត្តិទាំងឡាយមានជាដើមថា និយាយបញ្ចេញបញ្ចូលបន្ថែម ត្រូវអាបត្តិទុក្កដ មានសង្ឃាទិសេសជាទីបំផុត នឹងមានដល់អ្នកណា ?

ឆ្លើយថា មានដល់ភិក្ខុនីអ្នកនិយាយបញ្ចេញបញ្ចូលបន្ថែម ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក សូម្បីក្នុងគម្ពីរបរិវារៈថា

ឧបសម្បន្នមួយមិនបានឱ្យ ឧបសម្បន្នមួយមិនបានទទួល ព្រោះហេតុនោះ ការទទួលមិនមានទេ, តែឧបសម្បន្ននោះ ត្រូវគរុកាបត្តិ មិនមែន ជាលហុកាបត្តិ កាលដែលនឹងត្រូវ អាបត្តិនោះ ក៏ត្រូវព្រោះការបរិភោគជាបច្ច័យ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃបានគិតមកហើយ”[១] ។

ពិតមែន គាថានេះ ត្រាស់សំដៅយកភិក្ខុនីដែលនិយាយបញ្ចេញបញ្ចូលបន្ថែមក្រៅនេះ ។ ចំណែកសេចក្តីផ្សេងនៃអាបត្តិរបស់ភិក្ខុនី ដែល

---

១. វិន. បរិ. សេទមោចនគាថា. ១៣. ៤១៩/៤១៤ ។

និយាយបញ្ចេញបញ្ចូលបន្ថែមនេះ ទ្រង់ចែកទុកហើយក្នុងសិក្ខាបទទី ១ នោះឯង ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា៣ ដូច្នេះឯង ។

ភោជនប្បដិគ្គហណទុតិយសិក្ខាបទវណ្ណនា ចប់ ។

# ៧. សិក្ខំបច្ចាចិក្ខណសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[៦១] បណ្ឌិតគប្បីជ្រាបអត្ថនៃបទថា យាវតតិយកៈ ដោយន័យដូចដែលខ្ញុំពោលទុកក្នុងមហាវិភង្គនុ៎ះឯង ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ឯង ។

សិក្ខាបទនេះ មានការសូធ្យសមនុភាសនជាសមុដ្ឋាន ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

សិក្ខំបច្ចាចិក្ខណសិក្ខាបទវណ្ណនា ចប់ ។

## ៨. អធិករណក្ខុបិតសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

[៦៩] ពីរបទថា កិស្មិញ្ចិទេវ អធិករណេ : ព្រោះអធិករណ៍អ្វីមួយ បានដល់ ក្នុងបណ្តាអធិករណ៍ ៤ ណាមួយ ។ តែក្នុងបទភាជនៈ ដើម្បីទ្រង់សម្តែងការចែកអធិករណ៍តែម្យ៉ាង ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា "ដែលឈ្មោះថា អធិករណ៍ បានដល់អធិករណ៍ទាំងឡាយ ៤" ដូច្នេះ ។ ពាក្យដែលនៅសល់ព្រមទាំងសមុដ្ឋានជាដើម ងាយយល់ទាំងអស់នោះឯង ។

អធិករណក្ខុបិតសិក្ខាបទវណ្ណនា ចប់ ។

## ៩. ឱបសមាចារបឋមសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

[៧៧] បទថា សំសដ្ឋា : ប្រឡូកប្រឡំដោយគ្រហស្ថ គឺ ជាអ្នកនៅលាយឡំគ្នា ។

[៧៨] បទថា អននុលោមិកេន : ដែលមិនសមគួរ គឺ មិនសមគួរដល់ពួកបព្វជិត ។

បីបទថា **កាយិកេន វាចសិកេន សំសដ្ឋា** : **ប្រឡំដោយកាយកម្ម វចីកម្ម** មានសេចក្ដីថា អ្នកប្របូកប្របល់ ដោយការប្របូកប្របល់ដែលប្រព្រឹត្តទៅតាមមកកាយ មានការស្រិតអ្កែរ ដាំបាយ កិនរបស់ក្រអូប ដោតកម្រងផ្កាឈើជាដើមដើម្បីពួកគ្រហស្ថ និងដោយការប្របូកប្របល់គ្នា ដែលប្រព្រឹត្តទៅតាមមកវាចាដល់ពួកគ្រហស្ថ មានការនាំដំណឹងទៅ និងដំណឹងតបមកវិញ ព្រមទាំងការប្រព្រឹត្តជីកនាំ (បុរសស្ត្រីឱ្យបានគ្នាជាប្ដីប្រពន្ធ) ។ កិត្តិសព្ទរបស់ពួកភិក្ខុទាំងនេះអាក្រក់ ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកមានកិត្តិសព្ទអាក្រក់ ។ ការរស់នៅ ពោលគឺ អាជីពរបស់ពួកភិក្ខុទាំងនេះអាក្រក់, ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកមានការចិញ្ចឹមជីវិតអាក្រក់ ។ ពាក្យដែលនៅសល់ ព្រមទាំងសមុដ្ឋានជាដើម ងាយយល់ទាំងអស់ ។

បាបសមាចារបឋមសិក្ខាបទវណ្ណនា ចប់ ។

## ១០. បាបសមាចារទុតិយសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[៨៥] បទថា ឯវាចារា គឺ ឯវំ អាចារា : ដែលមានអាចារៈយ៉ាងនេះ មានសេចក្ដីថា មានអាចារៈដូចអាចារៈរបស់ពួកលោក ៗ ក្នុងបទទាំងពួង ក៏មានន័យដូច្នេះ ។

បទថា ឧញ្ញាយ[1] គឺ អវញ្ញាយ : ដោយសេចក្ដីមើលងាយ គឺ ដោយករបេះសង្កត់ឱ្យទាប ។

បទថា បរិភវេន : ដោយពេបជ្រាយ បានដល់ ដោយសេចក្ដីដឹង ពេបជ្រាយយ៉ាងនេះថា “នាងទាំងនេះ នឹងធ្វើអ្វីបាន” ?

បទថា អក្ខន្តិយា : ដោយគ្មានអំណត់ គឺ ដោយសេចក្ដីមិនអត់ទ្រាំ សេចក្ដីថា ដោយសេចក្ដីក្រោធខឹង ។

បទថា វេភស្សា : ដោយសំដីបង្គ្រប គឺ ដោយភាពជាអ្នកមានសំឡេងសម្លុតគម្រាម មានសេចក្ដីថា ដោយករគម្រាមឱ្យភ័យខ្លាចដោយប្រកាសកម្លាំងរបស់ខ្លួន ៗ ។

បទថា ទុព្ពល្យា : ដោយលោកទាំងឡាយ មានកម្លាំងថយ គឺ ព្រោះពួកលោកជាអ្នកទន់ខ្សោយ ។ បណ្ឌិតគប្បីឃើញអត្ថសមុច្ចយក្នុង

---

១. ថៃ. អញ្ញាយ ។

បទទាំងពួងយ៉ាងនេះថា ដោយការមើលងាយ និងដោយការប្រមាថ ។

បទថា **វិវិច្ចថ : លោកទាំងឡាយចូរស្ងាត់** គឺ ពួកលោកចូរចែកគ្នានៅចុះ ។ ពាក្យដែលនៅសល់ព្រមទាំងសមុដ្ឋានជាដើម ងាយយល់ទាំងអស់ ។

បាបសមាចារទុតិយសិក្ខាបទវណ្ណនា ចប់ ។

ចំនួនសិក្ខាបទ ក្នុងសង្ឃាទិសេសកណ្ឌ

១. ឧស្សយវាទិកាសិក្ខាបទ ការប្តឹងប្តល់
២. ចោរីវុដ្ឋាបិកាសិក្ខាបទ ការបំបួសស្រីចោរ
៣. ឯកគាមន្តរគមនសិក្ខាបទ ការទៅកាន់ស្រុកតែម្នាក់ឯង
៤. ឧក្ខិត្តកឱសារណសិក្ខាបទ ការសូត្របញ្ចូលភិក្ខុនីដែលសង្ឃលើកវត្ត
៥. បឋមភោជនប្បដិគ្គហណសិក្ខាបទ ការទទួលភោជនទីមួយ
៦. ទុតិយភោជនប្បដិគ្គហណសិក្ខាបទ ការទទួលភោជនទីពីរ
៧. សិក្ខំបច្ចាចិក្ខណសិក្ខាបទ ការខឹងពោលថា ខ្ញុំលាសិក្ខា
៨. អធិករណកុបិតសិក្ខាបទ ការសង្ឃឱ្យចាញ់ព្រោះអធិករណ៍ ហើយខឹងអាក់អន់ចិត្ត
៩. បឋមបាបសមាចារសិក្ខាបទ ការប្រព្រឹត្តអាក្រក់ទីមួយ
១០. ទុតិយបាបសមាចារសិក្ខាបទ ការប្រព្រឹត្តអាក្រក់ទីពីរ

# សរុបសង្ឃាទិសេស ១៧

[៩២] ក្នុងពាក្យថា ឧទ្ទិដ្ឋា ខោ អយ្យាយោ សត្តរស សង្ឃាទិសេសា ធម្មា : បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិសង្ឃាទិសេសទាំង ១៧ ខ្ញុំសម្តែងឡើងហើយ នេះ បណ្ឌិតគប្បីជ្រាបបឋមបត្តិកៈ ៩សិក្ខាបទ បន្ថែមអំពីមហាវិភង្គ ៣សិក្ខាបទនេះ គឺ សញ្ចរិតសិក្ខាបទ១ ទុដ្ឋទោសៈ២សិក្ខាបទ ចូលក្នុងលំដាប់នៃបឋមបត្តិកៈ ៦សិក្ខាបទ គប្បីជ្រាបយាវតតិយកៈ៨សិក្ខាបទ បន្ថែមយាវតតិយកៈ៤សិក្ខាបទ សូម្បីអំពីមហាវិភង្គចូលក្នុងលំដាប់នៃយាវតតិយកៈ៤សិក្ខាបទ ។

បណ្ឌិតគប្បីឃើញសេចក្តីក្នុងពាក្យថា ឧទ្ទិដ្ឋា ខោ ជាដើមនេះ យ៉ាងនេះថា "បពិត្រនាងម្ចាស់ទាំងឡាយ ធម៌ គឺ សង្ឃាទិសេស ១៧ ទាំងអស់ ខ្ញុំលើកឡើងសម្តែងហើយនោះឯង ដោយកំណត់ប្រមាណថា ជាបាតិមោក្ខុទ្ទេស ដោយប្រការយ៉ាងនេះ" ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ព្រោះតែបក្ខមានត្ត ។ ចំណែកបក្ខមានត្តនោះ ពួកយើងនឹងពណ៌នាដោយពិស្តារក្នុងខន្ធកៈនោះឯង ។

សត្តរសកណ្ឌវណ្ណនាក្នុងភិក្ខុនីវិភង្គ ចប់

# តឹសកនិស្សគ្គិយកណ្ឌវណ្ណនា

ធម៌ពួកណាឈ្មោះថា និស្សគ្គិយ៣០ ដែលព្រះមានព្រះភាគទ្រង់ប្រកាសទុកហើយ ដល់ពួកភិក្ខុនី ឥឡូវនេះ នឹងមានវណ្ណនានុក្រមតឹសនិស្សគ្គិយធម៌ទាំងនោះ ដូចតទៅនេះ ៖

## ១. បត្តវគ្គ

## ១. បត្តសន្និចយសិក្ខាបទវណ្ណនា

[៩៣] ជំពូកភាជន៍ ហៅថា អាមត្តា ក្នុងពាក្យថា អាមត្តិកាបណំ : លក់ភាជន៍ដី នេះ ។ ពួកជនអ្នកលក់ភាជនៈទាំងនោះ ត្រាស់ហៅថា អាមត្តិកា ។ រានលក់ទំនិញរបស់ជនពួកនោះ ឈ្មោះថា អាមត្តិកាបណៈ ។ ម្យ៉ាងទៀត សេចក្តីថា បើករានលក់ភាជន៍នោះ ។

ពីរបទថា បត្តសន្និចយំ ករេយ្យ : ធ្វើសេចក្តីសន្សំបាត្រ គឺគប្បីធ្វើការសន្សំបាត្រទុក ។ សេចក្តីថា "រក្សាបាត្រទុកមិនអធិដ្ឋាន ឬមិនវិកប្បរហូតអស់ថ្ងៃមួយ" ។ ពាក្យដែលនៅសល់ បណ្ឌិតគប្បីជ្រាបដោយន័យដូចដែលត្រាស់ទុកហើយក្នុងមហាវិភង្គនុ៎ះឯង ។ តែមានសេចក្តីប្លែកគ្នាត្រឹមតែប៉ុណ្ណេះ គឺ ក្នុងមហាវិភង្គនោះ បានបរិហារ ១០ ថ្ងៃ ក្នុងសិក្ខាបទនេះ (បរិហារ) សូម្បីមួយថ្ងៃក៏មិនមាន ។ ពាក្យដែលនៅសល់ដូចគ្នានុ៎ះឯង ។

សូម្បីសិក្ខាបទនេះ ក៏មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើង

មកកាយវាចា ១ កាយវាចាចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បត្តសន្និចយសិក្ខាបទវណ្ណនា ចប់ ។

## ២. អកាលចីវរសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

[១០២] បទថា ទុច្ចោឡា : មានសំពត់អាក្រក់ គឺ មានសំពត់ខុសពណ៌, សេចក្តីថា មានសំពត់ចាស់ ។

បទថា អបយ្យាហិ កាត់បទថា អបិ អយ្យាហិ : លោកម្ចាស់ទាំងឡាយ (បានចីវរហើយ) ឬ ។

[១០៣] ពីរបទថា អាធិស្ស ធិន្នំ : ទាយកប្រគេនចំពោះ មានសេចក្តីថា ចីវរដែលគេពោលប្រគេនថា "ពួកភិក្ខុនីអ្នកមកដល់ហើយចូរបែងចែកគ្នាចុះ" ដូច្នេះខ្លះ ឬពោលប្រគេនថា "ខ្ញុំប្រគេនសំពត់នេះដល់គណៈ ប្រគេនសំពត់នេះដល់លោកទាំងឡាយ" ដូច្នេះខ្លះ ឬប្រគេនដាក់ទុកជិតជើង ព្រោះបំណងនឹងប្រគេនខ្លះ ឈ្មោះថា ជាចីវរដែលគេប្រគេនចំពោះ, ចីវរនោះចាត់ជាអកាលចីវរទាំងអស់ ។ តែចីវរដែលបានហើយយ៉ាងនេះថា "ខ្ញុំម្ចាស់ប្រគេនដល់នាងម្ចាស់" គប្បីបង្អោនទៅតាម

ដែលគេប្រគេននុ៎ះឯង ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

អកាលចីវរសិក្ខាបទវណ្ណនា ចប់ ។

# ៣. ចីវរបរិវត្តនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[១០៦] បទថា ហន្ទ : លោកចូរយកទៅវិញចុះ គឺ និមន្តលោកទទួលទៅ ។

[១០៧] ពីរបទថា សយំ អច្ឆិន្ទតិ : ភិក្ខុនីដណ្តើមខ្លួនឯង មានសេចក្តីថា កាលភិក្ខុនីឱ្យចីវរតែមួយផ្ទាំង ហើយដណ្តើមមកមួយផ្ទាំង ជានិស្សគ្គិយតែមួយ ក្នុងចីវរច្រើនផ្ទាំង ក៏ជានិស្សគ្គិយច្រើន ។ បើថា ដណ្តើមយកចីវរច្រើនផ្ទាំង ដែលគេបត់រក្សាទុករួមគ្នា ជាអាបត្តិតាមចំនួនវត្ថុ ។ តែក្នុងចីវរច្រើនផ្ទាំង ដែលគេខ្ចប់រួមគ្នាទុកជាអាបត្តិតែមួយប៉ុណ្ណោះ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ចីវរបរិវត្តនសិក្ខាបទវណ្ណនា ចប់ ។

# ៤. អញ្ញវិញ្ញាបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

[១១០] បទថា ការយេន **: ដោយទិញ** គឺ ដោយតម្លៃ ។ បានឮថា ភិក្ខុនីឈ្មោះថុល្លនន្ទានោះយល់ថា "ឧបាសកនោះ សងទឹកដោះថ្លាដែលទិញមកហើយ នឹងនាំសូម្បីប្រេងមកបាន" ទើបបានពោលពាក្យនេះថា "អាវុសោ អាត្មាមិនមានសេចក្ដីត្រូវការដោយទឹកដោះថ្លា អាត្មាត្រូវការប្រេង" ។

បទថា វិញ្ញាបេត្វា **: ហើយសូម** បានដល់ ប្រាប់ឱ្យដឹងហើយ ឬសូមហើយថា "លោកនាំរបស់ឈ្មោះនេះមក" ។

[១១៣] ពីរបទថា តញ្ចេវ វិញ្ញាបេតិ **: ភិក្ខុនីសូមរបស់នោះ** មានសេចក្ដីថា វត្ថុណាដែលខ្លួនសូមពីមុន វត្ថុនោះតិចពេក មិនល្មម ព្រោះដូច្នោះ ទើបសូមរបស់នោះបន្ថែមទៀត ។

ពីរបទថា អញ្ញញ្ច វិញ្ញាបេតិ **: ភិក្ខុនីសូមរបស់ដទៃ** មានសេចក្ដីថា បើថា ខ្លួនសូមទឹកដោះថ្លាទុកមុន, តែព្រោះគ្រូពេទ្យនិយាយថា "នឹងត្រូវចំហៀវរួមគ្នា" ទើបមានសេចក្ដីត្រូវការដោយប្រេង ព្រោះដូច្នោះ ទើបសូមថែមសូម្បីរបស់ដទៃយ៉ាងនេះថា "អាត្មាមានសេចក្ដីត្រូវការនាំប្រេងផង" ។

ពាក្យថា អានិសំសំ ទស្សេត្វា វិញ្ញាបេតិ **: ភិក្ខុនីសម្ដែង**

អានិសង្សហើយសូម មានសេចក្ដីថា ប្រសិនបើថា ទឹកដោះថ្លាដែលគេនាំមកមានតម្លៃដល់កហាបណៈ ភិក្ខុនីសម្ដែងអានិសង្សហើយ សូមយ៉ាងនេះថា "ដោយតម្លៃប៉ុណ្ណោះ នឹងបានប្រេង ២ ដង, និងកិច្ចនេះនឹងសម្រេចបានរហូតដល់អស់ទៅ សូមឲ្យដោយប្រេងនេះ ព្រោះដូច្នោះ លោកចូរនាំប្រេងមកចុះ" ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយានិងជាអកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អញ្ញវិញ្ញាបនសិក្ខាបទវណ្ណនា ចប់ ។

## ៥. អញ្ញចេតាបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[១១៤] បានឮថា ភិក្ខុនីថុល្លនន្ទានោះ សម្គាល់ថា "កុលធីតានេះជាអ្នកស្គាល់ស្អម យើងប្រាប់យ៉ាងនេះហើយ នឹងរក្សាប្រេងនេះទុកនាំសូម្បីទឹកដោះថ្លា អំពីផ្ទះនៃត្រកូលរបស់ខ្លួនមកប្រគេន" ទើបបានពោលពាក្យថា សិក្ខមានេ : នែសិក្ខមានា ជាដើមនេះ ។

បទថា ចេតាបេត្វា : ឱ្យគេទិញ មានសេចក្ដីត្រឹមតែថា បង្គាប់

ឱ្យយល់ហើយប៉ុណ្ណោះ ។ ពាក្យដែលនៅសល់ទាំងអស់ ដូចសិក្ខាបទទី ៤ ទាំងអស់នោះឯង ។

អញ្ញចេតាបនសិក្ខាបទវណ្ណនា ចប់ ។

## ៦. បឋមសង្ឃិកចេតាបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

[១១៨] ពាក្យថា ឆន្ទកំ : បរិក្ខារដែលរៃបានមក នេះ ជាឈ្មោះនៃបរិក្ខារ (វត្ថុសម្រាប់ប្រើប្រាស់)ដែលគេប្រគេន ដែលបង្កឱ្យកើតសេចក្តីពេញចិត្ត និងសេចក្តីពេញចិត្តដល់ពួកអ្នកដទៃ ហើយកាន់យកយ៉ាងនេះថា "ពួកយើងនឹងធ្វើកិច្ចតាមធម៌ (បុញ្ញកម្ម) ឈ្មោះនេះ, លោកទាំងឡាយ ចូរឱ្យវត្ថុដែលពួកលោកអាចនឹងឱ្យបាន" ។

បទថា អញ្ញទត្ថិកេន : ដែលទាយកប្រគេនដើម្បីប្រយោជន៍វត្ថុដទៃ គឺ ដែលគេប្រគេនទុក ដើម្បីត្រូវការជាមូលតម្លៃដល់បច្ច័យយ៉ាងណាមួយ ។

បទថា អញ្ញុទ្ទិសិកេន : គេឧទ្ទិសដើម្បីវត្ថុដទៃ គឺ ដែលគេប្រគេនចំពោះយ៉ាងណាមួយ ។

បទថា សង្ឃិកេន : ជារបស់សង្ឃ គឺ ដែលគេតាំងចិត្តប្រគេន

ដល់សង្ឃ ។

[១២១] ពីរបទថា សេសកំ ឧបនេតិ : ភិក្ខុនីបង្អោនវត្ថុដែលសល់ មានសេចក្តីថា បន្ទាប់ឱ្យចាយវាយបច្ច័យ ដែលគេប្រគេនកប្បិយភណ្ឌៈទុកជាមូលតម្លៃ ហើយបង្អោនរបស់ដែលនៅសល់ ទៅដើម្បីប្រយោជន៍ដល់បច្ច័យដទៃ ។

ពីរបទថា សាមិកេ អបលោកេត្វា : ភិក្ខុនីប្រាប់ម្ចាស់ទានហើយ ទើបបង្អោនទៅ មានសេចក្តីថា សូមអនុញ្ញាតពីម្ចាស់របស់ហើយបង្អោនទៅយ៉ាងនេះថា ពួកលោកប្រគេនកប្បិយភណ្ឌៈ ទុកដើម្បីជាមូលតម្លៃនៃចីវរ, និងចីវររបស់ពួកយើងមាន, តែមានសេចក្តីត្រូវការដោយប្រេងជាដើម ។

បទថា អាបទាសុ : ភិក្ខុនីឱ្យគេចាត់ចែងខុសបំណងទាយកក្នុងពេលដែលមានអន្តរាយ មានសេចក្តីថា ព្រោះអន្តរាយដូច្នោះ ពួកភិក្ខុនីនាំគ្នាបោលវត្តភៀសខ្លួនទៅ ក្នុងអន្តរាយមានសភាពបែបនោះ ទីងផ្លាស់ប្តូរវត្ថុណាមួយ គួរ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយានិងជាអកិរិយា ក្នុងសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បឋមសង្ឃិកចេតាបនសិក្ខាបទវណ្ណនា ចប់ ។

## ៧. ទុតិយសង្ឃិកចេតាបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[១២២] បទថា សញ្ញាចិកេន : ដោយវត្ថុដែលសូមដោយខ្លួនឯង គឺ ដែលខ្លួនសូមមកជាចំណែកខ្លួនឯង ។ បទនេះឯងធ្វើឱ្យផ្សេងគ្នាក្នុងសិក្ខាបទទី ៧ នេះ ។ បទដែលនៅសល់ដូចនឹងសិក្ខាបទទី ៦ ។ ទាំងនោះឯង ។

ទុតិយសង្ឃិកចេតាបនសិក្ខាបទវណ្ណនា ចប់ ។

## ៨. បឋមគណិកចេតាបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

[១២៦] បទថា មហាជនិកេន : ជារបស់គណៈ គឺ ដែលគេតាំងចិត្តប្រគេនដល់គណៈ (ភិក្ខុនីពួកច្រើន) ។ បទថា មហាជនិកេន នេះឯង ដែលធ្វើឱ្យផ្សេងគ្នាក្នុងសិក្ខាបទនេះ ។

បឋមគណិកចេតាបនសិក្ខាបទវណ្ណនា ចប់ ។

## ៩. ទុតិយគណិកចេតាបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

[១៣០] បទថា សញ្ញាចិកេន : ដោយវត្ថុដែលសូមមកដោយខ្លួនឯង នេះ លើសជាងបទថា មហាជនិកេន : ជារបស់គណៈ (ដែលគេតាំងចិត្តប្រគេនដល់ភិក្ខុនីពួកច្រើន) នេះទៅ ។

ទុតិយគណិកចេតាបនសិក្ខាបទវណ្ណនា ចប់ ។

## ១០. បុគ្គលិកចេតាបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[១៣៤] ពីរបទថា បរិវេណំ ឧទ្រិយតិ : ទីបរិវេណក៏បាក់បែកទ្រុឌទ្រោម បានដល់ បរិវេណវិនាស ។ សេចក្ដីថា កំពុងតែបាក់បែក ។ ក៏ពាក្យនេះថា ដែលគេតាំងចិត្តប្រគេនបុគ្គល តែសូមមកជាចំណែកខ្លួន ត្រឹមតែប៉ុណ្ណោះឯង ធ្វើឱ្យផ្សេងគ្នា ។ បទដែលនៅសល់ក៏ដូចនឹងបទដើម ៗ ទាំងនោះឯង ។

បុគ្គលិកចេតាបនសិក្ខាបទវណ្ណនា ចប់ ។

បត្តវគ្គទី១ ចប់ ។

# ជាតរូបវគ្គ

## ១១. គរុបាវុរណសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១១ ដូចតទៅនេះ ៖

[១៣៨] បទថា គរុបាវុរណំ : សំពត់ដណ្តប់ដែលមានសាច់ក្រាស គឺ សំពត់ដណ្តប់ក្នុងរដូវត្រជាក់ ។ ឈ្មោះថា កង្សៈ ក្នុងបទថា ចតុក្កំ សបរមំ : សំពត់ដែលមានតម្លៃបួនកហាបណៈបួនដងជាយ៉ាងច្រើន នេះ មានតម្លៃ ៤ កហាបណៈ; ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងបទភាជនៈថា សោឡសកហាបណគ្ឃនកំ : សំពត់មានតម្លៃ ១៦ កហាបណៈ ។

គរុបាវុរណសិក្ខាបទវណ្ណនា ចប់ ។

## ១២. លហុបាវុរណសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១២ ដូចតទៅនេះ ៖

[១៤២] បទថា លហុបាវុរណំ : សំពត់ដណ្តប់ដែលមានសាច់ស្តើង គឺ សំពត់សម្រាប់ដណ្តប់ក្នុងរដូវក្តៅ ។ ពាក្យដែលនៅសល់ងាយស្រួលយល់ទាំងនោះ សូម្បីក្នុងសិក្ខាបទទាំង ២ ។

សិក្ខាបទនេះ មានសមុដ្ឋាន៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

លហុបាវុរណសិក្ខាបទវណ្ណនា ចប់ ។

ជាតរូបវគ្គ ចប់ ។

ចំនួនសិក្ខាបទអសាធារណៈ ក្នុងនិស្សគ្គិយកណ្ឌ គឺ

១. បត្តសន្និចយសិក្ខាបទ ការសន្សំបាត្រទុក
២. អកាលចីវរសិក្ខាបទ ការអធិដ្ឋានអកាលចីវរហើយចែកគ្នា
៣. ចីវរបរិវត្តនសិក្ខាបទ ការប្ដូរចីវរហើយដណ្ដើមយកវិញ
៤. អញ្ញវិញ្ញាបនសិក្ខាបទ ការសូមរបស់ដទៃ ហើយសូមរបស់ឯទៀត
៥. អញ្ញចេតាបនសិក្ខាបទ ឱ្យគេទិញរបស់ហើយបែរជាឱ្យទិញរបស់ដទៃវិញ
៦. បឋមសង្ឃិកចេតាបនសិក្ខាបទ ឱ្យគេទិញរបស់ ដោយបរិក្ខារគេប្រគេនចំពោះវត្ថុដទៃជារបស់សង្ឃ ទីមួយ
៧. ទុតិយសង្ឃិកចេតាបនសិក្ខាបទ ឱ្យគេទិញរបស់ ដោយបរិក្ខារគេប្រគេនចំពោះវត្ថុដទៃជារបស់សង្ឃ ទីពីរ
៨. បឋមគណិកចេតាបនសិក្ខាបទ ឱ្យគេទិញរបស់ ដោយបរិក្ខារគេប្រគេនចំពោះវត្ថុដទៃជារបស់គណៈ ទី១
៩. ទុតិយគណិកចេតាបនសិក្ខាបទ ឱ្យគេទិញរបស់ ដោយបរិក្ខារគេប្រគេនចំពោះវត្ថុដទៃជារបស់គណៈ ទី២
១០. បុគ្គលិកចេតាបនសិក្ខាបទ ឱ្យគេទិញរបស់ ដោយបរិក្ខារគេប្រគេនចំពោះវត្ថុដទៃជារបស់បុគ្គល
១១. គរុបាវុរណសិក្ខាបទ ចាត់ចែងសំពត់ដណ្ដប់សាច់ក្រាស់ហួសតម្លៃ
១២. លហុបាវុរណសិក្ខាបទ ចាត់ចែងសំពត់ដណ្ដប់សាច់ស្ដើងហួសតម្លៃ

## សរុបនិស្សគ្គិយបាចិត្តិយ

[១៤៦] ក្នុងពាក្យថា ឧទ្ទិដ្ឋា ខោ ជាដើមនេះ បណ្ឌិតគប្បីឃើញសេចក្តីយ៉ាងនេះថា ក្នុងពាក្យថា បពិត្រនាងម្ចាស់ទាំងឡាយ ធម៌គឺនិស្សគ្គិយបាចិត្តិយ៣០ ខ្ញុំលើកឡើងសម្តែងហើយនោះឯង នេះអ្នកសិក្សាគប្បីនាំ ២ សិក្ខាបទ គឺ ធោវនសិក្ខាបទ និងបដិគ្គហណសិក្ខាបទចេញពីចីវរវគ្គក្នុងមហាវិភង្គ ហើយបន្ថែមឱ្យពេញវគ្គទី១ ដោយសិក្ខាបទ គឺ ភិក្ខុនីអធិដ្ឋានអកាលចីវរថា កាលចីវរ ហើយចែកគ្នា និងសិក្ខាបទដែលភិក្ខុនីផ្លាស់ប្តូរចីវរគ្នា ហើយដណ្តើមយកមកវិញ ។ តទៅគប្បីនាំ ៧ សិក្ខាបទខាងដើមនៃឯឡកលោមវគ្គចេញ ហើយបន្ថែមអញ្ញទត្តិកសិក្ខាបទ ៧ សិក្ខាបទចូលមកឱ្យពេញវគ្គទី ២ ។ នាំ ៣ សិក្ខាបទ គឺ បឋមបត្តសិក្ខាបទ វស្សិកសាដិកសិក្ខាបទ និង អារញ្ញកសិក្ខាបទ ចេញពីវគ្គទី ៣ ហើយបន្ថែមវគ្គទី ៣ ឱ្យពេញដោយបត្តសន្និចយសិក្ខាបទ គរុបាបុរណសិក្ខាបទ និងលហុបាបុរណសិក្ខាបទ ។

នាងម្ចាស់ទាំងឡាយ ធម៌គឺ និស្សគ្គិយបាចិត្តិយ ៣០ សូម្បីទាំងអស់យ៉ាងនេះ គឺ ១២ សិក្ខាបទដែលទ្រង់បញ្ញត្តិទុកដល់ភិក្ខុនីទាំងឡាយតែមួយផ្នែកនេះ និង ១៨ សិក្ខាបទដែលទ្រង់បញ្ញត្តិដល់ទាំង ២ ផ្នែក ខ្ញុំលើកឡើងសម្តែងហើយនោះឯង តាមផ្លូវបាដិមោក្ខុទ្ទេស ។ បទដែលនៅសល់ មានន័យដូចពោលហើយទាំងអស់នោះឯង ។

**និស្សគ្គិយបាចិត្តិយវណ្ណនា ចប់**

# បាចិត្តិយកណ្ឌវណ្ណនា

ធម៌ពួកណា រួបរួមបាន ១៦៦ ប្រការ ដែលព្រះធម្មសង្គាហកាចារ្យទាំងឡាយ ចងក្រងទុកក្នុងលំដាប់នៃតឹសកកណ្ឌ ឥឡូវនេះ នឹងពណ៌នាធម៌សូម្បីទាំងនោះ ដូចតទៅនេះ ៖

## ១. លសុណវគ្គ

### ១. លសុណសិក្ខាបទវណ្ណនា

ក្នុងបណ្ដា ៩ វគ្គនោះ គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃលសុណវគ្គជាមុន ។

### រឿងភិក្ខុនីឆាន់ខ្ទឹមស

[១៤៧] បីបទថា ទ្វេ តយោ ភណ្ឌិកេ : ខ្ទឹមពីរបីមើម បាន ដល់ ខ្ទឹមសពីរឬបីមើម ពាក្យថា ពោដ្ឋលកេ : ខ្ទឹមស នេះ ជាឈ្មោះ របស់ខ្ទឹមសមានបណ្ដូលខាងក្នុងសម្បុរ ។

ពីរបទថា ន មត្តំ ជានិត្វា : មិនដឹងប្រមាណ មានសេចក្ដីថា (ភិក្ខុនីថុល្លនន្ទានោះ) មិនស្គាល់ប្រមាណ កាលអ្នកចាំចំការកំពុងហាម

ប្រាម ប្រើឱ្យ (ពួកភិក្ខុនី) ជញ្ជូនយកខ្ទឹមសមកយ៉ាងច្រើន ។

[១៤៨] ពីរបទថា អញ្ញតរំ ហំសយោនឹ : កើតក្នុងកំណើតសត្វហង្ស ១ បានដល់ កំណើតហង្សមាស ។

បីបទថា សោ តាសំ ឯកេកំ : ហង្សនោះឱ្យស្លាបមួយ ៗ ដល់ប្រពន្ធនិងកូនស្រីនោះ មានសេចក្តីថា ហង្សនោះ ជាសត្វលើកជាតិបាន ។ ដូចនោះ ទើបមករកដោយសេចក្តីស្រឡាញ់ក្នុងកាលមុន ហើយលោស់រោមឱ្យដល់ស្ត្រីទាំងនោះម្នាក់មួយរោម ។ រោមនោះ ជាមាសពិតគួរដល់ការរំលាយ ការជំ និងកាត់បាន ។

[១៥១] បទថា មាគធិកំ : ក្នុងដែនមគធៈ គឺ ខ្ទឹមដែលកើតហើយក្នុងដែនមគធៈ ។ ពិតមែន ខ្ទឹមសដែលកើតក្នុងដែនមគធៈ លោកប្រាថ្នាយកថា លសុណំ : ខ្ទឹម ក្នុងសិក្ខាបទនេះ ។ សូម្បីខ្ទឹមសនោះជាខ្ទឹមសដែលមានបណ្តូលខាងក្នុងពេញបរិបូណ៌, មិនមែនខ្ទឹមសដែលមានបណ្តូលខាងក្នុងត្រឹមតែមួយត្របក ឬពីរ ទៅបីត្របកទេ ។ តែក្នុងកុរុន្ទី លោកមិនពោលដល់ប្រទេសដែលកើត ពោលថា ខ្ទឹមសមានបណ្តូលខាងក្នុងសម្បូរ ឈ្មោះថា ខ្ទឹមសមគធៈ ។

ក្នុងពាក្យថា អជ្ឈោហារេ អជ្ឈោហារេ : គ្រប់វារៈដែលលេបចូល នេះ មានវិនិច្ឆ័យដូច្នេះ ៖

បើភិក្ខុនីរួបរួមខ្ទឹមស ២-៣ មើមចូលរួមគ្នាទំពាលេប ជាបាចិត្តិយតែមួយ តែកាលភិក្ខុនីបេះចេញឆាន់ម្ដងមួយគ្រាប ៗ ជាបាចិត្តិយច្រើន ដោយករាប់ប្រយោគនោះឯង ។

បណ្ឌិតគប្បីជ្រាបសេចក្ដីផ្សេងគ្នានៃខ្ទឹមស លឿងជាដើម ដោយពណ៌, ឬ បណ្ដូលក្នុង ។ ពោលអំពីពណ៌មុន ឈ្មោះថា ខ្ទឹមលឿងរមែងមានពណ៌លឿង ខ្ទឹមក្រហមមានពណ៌ក្រហម ខ្ទឹមខៀវមានស្លឹកពណ៌ខៀវ ។

តែពោលអំពីបណ្ដូលខាងក្នុង(ឬគ្រាប) ខ្ទឹមសមានបណ្ដូលខាងក្នុងតែមួយជាន់ ៗ ខ្ទឹមក្រហមមានបណ្ដូលខាងក្នុង២ ជាន់ ៗ ខ្ទឹមខៀវមានបណ្ដូលខាងក្នុង៣ ជាន់ ខ្ទឹមដើមមិនមានបណ្ដូលខាងក្នុង ។ ពិតមែន ខ្ទឹមសនោះ ត្រឹមតែជាពន្លកប៉ុណ្ណោះ ។ តែក្នុងមហាបច្ចរីជាដើមពោលទុកថា ខ្ទឹមលឿងមានបណ្ដូលខាងក្នុង៣ គ្រាប, ខ្ទឹមក្រហមមានបណ្ដូលខាងក្នុង២ គ្រាប, ខ្ទឹមខៀវមានបណ្ដូលខាងក្នុងតែមួយគ្រាប ។ ខ្ទឹមលឿងជាដើមនោះ រមែងគួរ ដោយសភាពតែម្ដង ។

តែក្នុងការស្លសម្លជាដើម សូម្បីខ្ទឹមសមគធៈ ក៏គួរ ។ ពិតមែន ទឹងដាក់ខ្ទឹមសមគធនោះចុះក្នុងសម្លសណ្ដែកជាដើមដែលកំពុងស្លក្ដី ក្នុងបាយប្រភេទដែល ផ្សំដោយត្រីសាច់ក្ដី ក្នុងប្រេងក្ដី ក្នុងទឹកបានៈមានទឹក

ពទ្រាជាដើមក្តី ក្នុងសម្លបន្លែជ្រក់ដែលជូរជាដើមក្តី ក្នុងសម្លឧត្តរិភង្គក្តី ក្នុងសម្លយ៉ាងណាមួយ ដោយហោចទៅ សូម្បីក្នុងយាគូ និងភត្តក៏គួរ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

លសុណសិក្ខាបទវណ្ណនា ចប់ ។

## ២. សម្ភាធលោមសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

[១៥៤] បទថា សម្ពាធេ : ក្នុងទីចង្អៀត គឺ ឱកាសដែលកំបាំង ។ ក៏ដើម្បីសម្ដែងចែកឱកាសទីស្ងាត់ ( កំបាំង ) នោះ ទើបព្រះមានព្រះភាគត្រាស់ថា ឧភោ ឧបកច្ឆកា មុត្តករណំ : ក្លៀកទាំងពីរ កន្លែងបន្ទោបង់ទឹកមូត្រ ។

[១៥៥] ពីរបទថា ឯកម្បិ លោមំ : សូម្បីតែមួយសរសៃ មានសេចក្ដីថា ភិក្ខុនីឱ្យដករោមមួយសរសៃឬច្រើនសរសៃ ដោយប្រយោគតែមួយ ដោយកន្ត្រៃក្ដី ដោយដង្កៀបក្ដី ដោយរបស់មុតយ៉ាងណាមួយក្ដី ជាបាចិត្តិយច្រើន ដោយករាប់ប្រយោគ មិនមែនដោយរាប់សរសៃរោម ។

[១៥៦] បទថា អាពាធបច្ចយា : ភិក្ខុនីឱ្យគេដករោមព្រោះហេតុមានអាពាធ បានដល់ មិនជាអាបត្តិដល់ភិក្ខុនីអ្នកឱ្យដកព្រោះអាពាធមានបូសនិងរមាស់ជាដើមជាបច្ច័យ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៤ កើតឡើងមកកាយ ១ កាយវាចា ១ កាយចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សម្ពាធលោមសិក្ខាបទវណ្ណនា ចប់ ។

# ៣. តលឃាតកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[១៥៧] បទថា តលឃាតកេ : ព្រោះទះនូវផ្ទៃនៃអង្គជាត គឺក្នុងសម្ពស្សបរិវេណអង្គកំបាំង ។

[១៥៨] ក្នុងពាក្យថា អន្តមសោ ឧប្បលបត្តេនបិ : ដោយហោចទៅសូម្បីតែវាយដោយស្លឹកឧប្បល នេះ មានវិនិច្ឆ័យថា ត្រូវបកឈូកខាងទីងរីកធំទៅ ។ កាលទះសូម្បីដោយកេសរឈូក ក៏ជាអាបត្តិដូចគ្នា ។

[១៥៩] បទថា អាពាធប្បច្ចយា : ភិក្ខុនីវាយអង្គជាត ព្រោះហេតុតែមានអាពាធ មានសេចក្តីថា ទីងទះបូស ឬ ដំបៅ គួរ ។ បទដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មានវេទនា ២ ដូច្នេះឯង ។

តលឃាតកសិក្ខាបទវណ្ណនា ចប់ ។

# ៤. ជតុមដ្ឋកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

[១៦០] បទថា បុរាណរាជោរោធោ : ស្រីស្នំរបស់ស្តេចពីដើម បានដល់ ជាព្រះស្នំរបស់ស្តេចផែនដីក្នុងកាលមុន គឺ ក្នុងគ្រាជាគ្រហស្ថ ។

ពីរបទថា ចិរាចិរំ គច្ឆតិ : យូរ ៗទើបទ្រង់មក គឺ យូរ ៗ ព្រះរាជាទើបនឹងស្តេចមក ។

បទថា ឆារេថ : លោកអាចកែកុនបណ្តោះអាសន្ន គឺ នាងម្ចាស់អាច (តាំងនៅបានយ៉ាងណា ?) ។

កាលពួកភិក្ខុនីសួរថា "នេះកម្មរបស់អ្នកណា" ភិក្ខុនីនោះតាំងចិត្តថា "នាង កាលយើងមិនប្រាប់, ភិក្ខុនីទាំងនេះ ក៏នឹងធ្វើសេចក្តីសង្ស័យក្នុងយើង" ទើបបានពោលយ៉ាងនេះថា នេះជាកម្មរបស់ខ្ញុំ" ។

បទថា ជតុមដ្ឋកេ : ព្រោះដងបង្គួរមានសណ្ឋានរលីង ដែលគេធ្វើពីអាចម៍ល័ក្ខ បានដល់ កំណាត់រលោង ៗ ធ្វើដោយជ័រ ។ បទថា ជតុមដ្ឋកេ នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃរឿងប៉ុណ្ណោះ ។ តែកាលស៊ិកកំណាត់មូល ៗ យ៉ាងណាមួយចូលទៅ ជាអាបត្តិទាំងអស់ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ដោយហោចទៅ សូម្បីស៊ិកត្របកឧប្បលចូលទៅ អង្កត់បាំង និងសូម្បីត្របកឧប្បល

នេះ ក៏ធំពេកទៅ តែកាលសីកសូម្បីត្រឹមតែកេសរចូលទៅ ក៏ជាអាបត្តិដូចគ្នា ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។ សមុដ្ឋានជាដើម ក៏ដូចដែលបានពោលហើយក្នុងតលឃាដកសិក្ខាបទនោះឯង ។

ជតុមដ្ឋកសិក្ខាបទវណ្ណនា ចប់ ។

## ៥. ឧទកសុទ្ធិកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[១៦៤] ពាក្យថា អតិគម្ភីរំ ឧទកសុទ្ធិកំ អាទិយតិ : ធ្វើការជម្រះដោយទឹកឱ្យជ្រៅពេក បានដល់ ធ្វើការជម្រះដោយទឹកឱ្យចូលខាងក្នុង ( អង្គជាត ) ជ្រៅពេកទៅ ។

[១៦៥] ពីរបទថា កេសគ្គមត្តំបិ អតិក្កាមេតិ : ធ្វើឱ្យកន្លងកំណត់នោះទៅ សូម្បីតែប៉ុនចុងសក់ មានសេចក្តីថា ភិក្ខុនីសីកម្រាមដៃធ្នាប់ទី ៣ ឬធ្នាប់ទី ៤ ចូលទៅតាមមកវែង ឱ្យហួសមកផ្នែកជ្រៅលើស ២ ថ្នាំងម្រាមដៃទៅសូម្បីត្រឹមតែចុងសរសៃសក់ ជាបាចិត្តិយ ។ សមពិត ដូចពាក្យដែលលោកពោលទុកក្នុងមហាបច្ចរីថា ភិក្ខុនី រមែងមិនបានដើម្បីនឹងប្រើម្រាមដៃ ៣ ថ្នាំងជម្រះខ្លះ នឹងប្រើម្រាមដៃ ៣ ឬ ៤ ម្រាម សូម្បីតែមួយថ្នាំងជម្រះក៏មិនបាន ។ បទដែលនៅសល់ ងាយ

យល់ទាំងអស់ ។ សូម្បីសមុដ្ឋានជាដើម ក៏ដូចពោលហើយ ក្នុងតលឃាដកសិក្ខាបទនោះឯង ។

ឧទកសុទ្ធិកសិក្ខាបទវណ្ណនា ចប់ ។

# ៦. ឧបតិដ្ឋនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

[១៦៨] បទថា ភត្តវិស្សគ្គំ : ការធ្វើភត្តចេញ បានដល់ ភត្តកិច្ច ។

បីបទថា បានីយេន ច វិធូបនេន ច ឧបតិដ្ឋិត្វា : បម្រើដោយទឹកផង ដោយផ្លិតផង សេចក្ដីថា ឈរយកដៃម្ខាងកាន់ផ្ដិលទឹក យកដៃម្ខាងកាន់ផ្លិតបក់នៅជិត ៗ ។

បទថា ឧច្ចារេតិ : ដឹកនាំ មានសេចក្ដីថា ពោលពាក្យជាប់ទាក់ទងនឹងការគ្រប់គ្រងផ្ទះ ល្មើសចារិតរបស់បព្វជិតថា "សូម្បីកាលមុនលោកក៏បរិភោគយ៉ាងនេះ ខ្ញុំម្ចាស់ក៏ធ្វើការប្រណិបត្តិលោកយ៉ាងនេះ" ។

[១៦៩] ពីរបទថា យត្ថិ ពាត្តិ បានីយំ : ទឹកគឺបុគ្គលគប្បីផឹកណាមួយ មានសេចក្ដីថា ទឹកបរិសុទ្ធ ឬប្រេង ទឹកដោះជូរ ទឹកឃ្មុំ ទឹករសជាតិ និងទឹកដោះស្រស់ជាដើមយ៉ាងណាមួយក៏ដោយ ។

ពីរបទថា យា កាចិ វីជនី : វត្ថុសម្រាប់បក់ណាមួយ គឺ

ដោយហោចទៅ សូម្បីជាយចីវរ ក៏ឈ្មោះថា ផ្ទិត ។

ក្នុងពាក្យថា ហត្ថបាសេ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស : ភិក្ខុនីស្ថិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយ នេះ ព្រះមានព្រះភាគទ្រង់ពិន័យបាចិត្តិយ ព្រោះឈរជាបច្ច័យប៉ុណ្ណោះ ។ តែព្រោះការប្រហារជាបច្ច័យ ទ្រង់បញ្ញត្តិទុកុដទុកក្នុងខន្ធកៈ ។

[១៧១] ពីរបទថា ទេតិ ធាបេតិ : (ភិក្ខុនីប្រគេនវត្ថុមានទឹកជាដើម) ដល់ភិក្ខុដោយដៃខ្លួនឯង ១ ភិក្ខុនីឱ្យគេប្រគេនដល់ភិក្ខុ ១ មានសេចក្ដីថា ភិក្ខុនីប្រគេនទឹកឆាន់ ឬសម្លជាដើមថា "និមន្តលោកឆាន់ទឹកនេះ, និមន្តលោកឆាន់ទឹងសម្លនេះចុះ" ។ ប្រគេនផ្លិតស្លឹកត្នោតថា "និមន្តលោកបក់ដោយផ្លិតស្លឹកត្នោតនេះ ឆាន់ចុះ" ឬថា បង្គាប់ឱ្យអ្នកដទៃប្រគេនទឹកឆាន់និងផ្លិតឱ្យ សូម្បីទាំង ២ យ៉ាង មិនជាអាបត្តិ ។

ពីរបទថា អនុបសម្បន្នំ អាណាបេតិ : ភិក្ខុនីបង្គាប់អនុបសម្បន្ន ១ គឺ បង្គាប់សាមណេរី ដើម្បីឱ្យបដិបត្តិមិនជាអាបត្តិ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឧបតិដ្ឋនសិក្ខាបទវណ្ណនា ចប់ ។

# ៧. អាមកធញ្ញសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[១៧៣] ពាក្យថា កុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស : ភិក្ខុនីទទួលដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ មានសេចក្តីថា ទុក្កដនេះ ឈ្មោះថា បយោគទុក្កដ ។ ព្រោះដូច្នោះ មិនមែនជាទុក្កដព្រោះការទទួលប្រគេនតែម្យ៉ាងប៉ុណ្ណោះ ។ នៅជាទុក្កដគ្រប់ប្រយោគទៀត ក្នុងការទទួលប្រគេនហើយនាំមកពីទីដទៃក្តី ក្នុងការហាលឱ្យស្ងួតក្តី ក្នុងការត្រៀមចង្ក្រាន ដើម្បីត្រូវការលីងឆាន់ក្នុងថ្ងៃមានភ្លៀងធ្លាក់ស្រិច ៗ ក្តី ក្នុងការចាត់ចែងក្បៀងក្តី ក្នុងការត្រៀមវែកក្តី ក្នុងការនាំអុសមកបង្កាត់ភ្លើងក្តី ក្នុងការដាក់អង្ករចុះលើក្បៀងក្តី ក្នុងការលីងដោយវែកក្តី ក្នុងការត្រៀមត្បាល់ និងអម្រែងជាដើមដើម្បីនឹងបុកក្តី ក្នុងកិច្ច មានការបុក អុំ និងដុសលាងជាដើមក្តី ដរាបដល់បៀបចូលមាត់ ហើយឈ្លួចទំពាដោយធ្មេញ ដើម្បីលេបចូល ។ ក្នុងវេលាលេបចូល ជាបាចិត្តិយច្រើនតាមចំនួនដែលលេប និងក្នុងសិក្ខាបទនេះ ការសូមនិងការឆាន់ ចាត់ជាប្រមាណ ។ ព្រោះដូច្នោះ សូម្បីភិក្ខុនីសូមដោយខ្លួនឯង ឬប្រើភិក្ខុនីដទៃឱ្យធ្វើការលីង ការបុក និងការចំអិនហើយឆាន់ ក៏ជាអាបត្តិ ។ ដល់ប្រើភិក្ខុនីដទៃឱ្យសូម ហើយធ្វើការលីងឆាន់ដោយខ្លួនឯងជាដើម ក៏ជាអាបត្តិ ។

តែក្នុងមហាបច្ចរីលោកពោលថា "ភិក្ខុនីសូមស្រូវថ្មី ៗធម្មតានេះ សូម្បីចំពោះមាតាមកឆាន់ ក៏ជាបាចិត្តិយដូចគ្នា, ស្រូវថ្មីដែលបានមកដោយមិនបានសូម កាលធ្វើការលីងជាដើមខ្លួនឯង ឬប្រើអ្នកដទៃឱ្យធ្វើហើយឆាន់ ជាទុក្កដ, ស្រូវថ្មី ៗ ដែលភិក្ខុនីដទៃបានមក ដោយករសូម សូម្បីកាលធ្វើការលីងជាដើមខ្លួនឯង ឬប្រើឱ្យភិក្ខុនីនោះធ្វើ ឬប្រើឱ្យភិក្ខុនីដទៃធ្វើហើយឆាន់ ក៏ជាទុក្កដដូចគ្នា" លោកបានពោលទុកទៀតថា ស្រូវថ្មីដែលភិក្ខុនីដទៃបានមកដោយករសូម បើភិក្ខុនីធ្វើការលីងដោយខ្លួនឯងជាដើមនូវស្រូវថ្មីនោះ ហើយឆាន់ ជាបាចិត្តិយដូចគ្នា ។ តែកាលឱ្យអ្នកដទៃធ្វើការលីងជាដើមហើយឆាន់ ជាទុក្កដ ។ ពាក្យក្នុងមហាបច្ចរីនោះ ខុសទាំងខាងដើមទាំងខាងចុង ដែលពិត មិនមានសេចក្តីប្លែកគ្នាក្នុងការធ្វើឯង ឬក្នុងការប្រើឱ្យធ្វើនូវកិច្ច មានការលីងជាដើមនោះ ។ តែក្នុងមហាអដ្ឋកថា លោកពោលទុកដោយមិនប្លែកគ្នាថា ជាទុក្កដដល់ភិក្ខុនីដែលឆាន់អំបុកស្រូវថ្មី ដែលភិក្ខុនីដទៃសូមមក ។

[១៧៤] បទថា អាពាធប្បច្ចយា : ភិក្ខុនីសូម ព្រោះហេតុមានអាពាធ សេចក្តីថា មិនជាអាបត្តិ ព្រោះសូមស្រូវថ្មី ដើម្បីត្រូវការធ្វើការឆ្អិនខ្លួនជាដើម ។ លោកពោលទុកក្នុងមហាបច្ចរីថា "ក៏ការទទួលយកស្រូវ ដែលបានមកដោយករមិនបានសូម ដើម្បីប្រយោជន៍ដល់នវកម្មគួរ" ។

ពីរបទថា អបរណ្ណំ វិញ្ញាបេតិ : ភិក្ខុនីសូមអបរណ្ណជាតិ មានសេចក្ដីថា វៀរធញ្ញជាត ៧ ប្រភេទចេញ ភិក្ខុនីសូមអបរណ្ណជាតិ មានសណ្ដែកខៀវនិងសណ្ដែកលឿងជាដើមក្ដី ពូជផ្លែមានផ្លែឃ្លោក និងផ្លែត្រឡាចជាដើមក្ដី វត្ថុដទៃយ៉ាងណាមួយក្ដី ក្នុងទីនៃញាតិនិងអ្នកបវារណា មិនជាអាបត្តិ ។ តែនឹងសូមស្រូវថ្មី សូម្បីក្នុងទីនៃញាតិនិងអ្នកបវារណា មិនគួរ ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៤ កើតឡើងមកកាយ ១ វាចា ១ កាយចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អាមកធញ្ញសិក្ខាបទវណ្ណនា ចប់ ។

# ៨. បឋមឧច្ចារឆឌ្ឌនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

[១៧៥] រាជភដៈ (ព្រះរាជទ្រព្យ) គឺ ភាសី សួយសារអាករ របស់ស្ដេច ព្រាហ្មណ៍នេះបន្លំលួចយកទៅ, ព្រោះហេតុនោះ ព្រាហ្មណ៍នោះ ទើបឈ្មោះថា និព្វិដ្ឋរាជភដៈ (អ្នកត្រូវរបូតចេញពីរាជការ) ។ អធិប្បាយថា អ្នកទទួលតំណែងយ៉ាងណាមួយ ផ្ដេកខាងសួយសារអាករ

បានបន្ទំ លួចយកបិទបាំងយកផលកម្រែពីតំណែងនោះ ។

ពាក្យថា គតេ្ញាវ[១] ភជបថំ យាចិស្សាមិ : អញនឹងសូមងារនោះវិញ បានដល់ ព្រាហ្មណ៍នោះគិតទឹកថា "យើងថ្វាយសួយដល់ស្តេចហើយ នឹងទូលសូមព្រះរាជទានទូវតំណែងដើមនោះឯងវិញ" ។

បទថា បរិភាសិ : ហាមប្រាម បានដល់ ឧបាសកនោះគម្រាមបំភ័យភិក្ខុនីទាំងនោះថា "ពួកនាងម្ចាស់កុំធ្វើយ៉ាងនេះតទៅទៀត" ។

[១៧៦] បទថា សយំ ឆឌ្ឌេតិ : ភិក្ខុនីចោលដោយខ្លួនឯង មានសេចក្តីថា កាលចាក់វត្ថុទាំង ៤ ចោល ដោយប្រយោគតែមួយ ជាអាបត្តិត្រឹមតែមួយ ។ កាលចោលម្តងមួយ ៗ ជាអាបត្តិច្រើនតាមចំនួនវត្ថុ ។ សូម្បីក្នុងការបង្គាប់ ក៏ន័យនេះឯង ។ សូម្បីក្នុងការចោលឈើជម្រះធ្មេញ ក៏ជាបាចិត្តិយ ដល់ភិក្ខុនីដូចគ្នា ។ ជាទុក្កដដល់ភិក្ខុក្នុងទីទាំងពួង ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយានិងជាអកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បឋមឧច្ចារឆឌ្ឌនសិក្ខាបទវណ្ណនា ចប់ ។

---

១. ថៃ. តំយេវ ។

# ៩. ទុតិយខ្ចារឆឌ្ឌនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

[១៧៩] ត្រើនបទថា យំ មនុស្សានំ ឧបភោគបរិភោគំ រោបិតំ : វត្ថុណាជាដំណាំជាគ្រឿងឧបភោគនិងបរិភោគរបស់មនុស្សទាំងឡាយ មានសេចក្ដីថា ស្រែ ចំការ ឬសួនផ្លែឈើមានដូងជាដើម ក៏ដោយ កាលចាក់វត្ថុទាំងនោះ ចោលក្នុងទីដែលគេដាំរបស់ខៀវស្រស់ទុកកន្លែងណាមួយ គប្បីជ្រាបសេចក្ដីផ្សេងនៃអាបត្តិដោយន័យមុនទុំ:ឯង ។

ភិក្ខុនីអង្គុយឆាន់នៅត្រង់ចំការ ស្រែ ឬសួន ទំពាអំពៅជាដើម កាលនឹងទៅចាក់ទឹកជាសំណាស់ និងឆ្អឹងជាដើម ចុះក្នុងរបស់ខៀវស្រស់ដោយហោចទៅសូម្បីចោលដូងដែលចោះក្បាលផឹកទឹកហើយ ក៏ជាបាចិត្តិយដូចគ្នា ។ ជាទុក្កដដល់ភិក្ខុ ។ តែក្នុងពូជដែលគេព្រោះទុកក្នុងស្រែដែលភ្ជួរហើយ ជាទុក្កដដល់ភិក្ខុ និងភិក្ខុនីទាំងអស់ រហូតដល់អស់វេលាដែលពន្លកមិនទាន់ដុះ ។ នឹងចាក់ចុះក្នុងជ្រុងស្រែជាដើម ដែលគេមិនទាន់បានព្រោះពូជក្ដី លើទំនប់ភ្លឺស្រែជាដើមដែលពូជមិនដុះក្ដី គួរ ។ សូម្បីចាក់ចុះក្នុងទីចោលសម្រាមអាចម៍បន្ទោះរបស់ពួកអ្នកស្រុក ក៏គួរ ។

បទថា ឆឌ្ឌិតក្ខេត្តេ[១] : ក្នុងស្រែដែលគេបោះបង់ចោល មានសេចក្ដីថា កាលពួកអ្នកស្រុកដកសន្ទូងទៅហើយ ឈ្មោះថា ជាស្រែ

---

១. ក្នុងកង្ខាវិតរណី ។

ដែលគេបោះបង់ចោល ។ ទីងចាក់ចុះក្នុងស្រែដែលគេបោះបង់ចោល នោះឯង គួរ ។ តែក្នុងស្រែ ចំការដែលពួកអ្នកស្រុកនៅចាំរក្សាដោយយល់ថា បុព្វណ្ណជាតិជាដើម ដែលច្រូត កាត់ហើយ ទីងដុះឡើងទៀតជាអាបត្តិតាមវត្ថុដូចគ្នា ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយានិងជាអកិរិយា ។ល។ ដូច្នេះឯង ។

ទុតិយឧច្ចារឆឌ្ឌនសិក្ខាបទវណ្ណនា ចប់ ។

## ១០. នច្ចគីតសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[១៨៣] ពីរបទថា យង្កិញ្ចិ នច្ចំ : ការរាំឯណានីមួយ មានសេចក្តីថា ពួកអ្នករបាំជាដើម ឬពួកអ្នកលេង ចូរច្រៀងរាំក៏ដោយ ដោយហោចទៅ សូម្បីសត្វក្ងោក សត្វសេក និងស្វាជាដើមច្រៀងរាំទាំងអស់នោះ ចាត់ជាការច្រៀងរាំទាំងអស់ ។

ពីរបទថា យង្កិញ្ចិ គីតំ : ចម្រៀងឯណានីមួយ មានសេចក្តីថា ការច្រៀងរបស់ពួកអ្នករបាំជាដើម ឬការច្រៀងក៏ឡាឱ្យសម្រេចប្រយោជន៍ដែលប្រកបដោយការសរសើរគុណព្រះរតនត្រ័យ ក្នុងវេលាដែលព្រះអរិយៈទាំងឡាយបរិព្វាន ឬការច្រៀងទំនងសូធ្យធម៌សរភញ្ញៈរបស់ពួក

ភិក្ខុ អ្នកមិនសង្រួមក៏ដោយ ទាំងអស់នេះ ចាត់ជាការច្រៀងទាំងអស់ ។

ពីរបទថា យត្ថិញ្ចិ វាទិតំ : ប្រគំឯណានីមួយ មានសេចក្ដីថា គ្រឿងភ្លេងមានការបន្ទឹងខ្សែជាដើម ឬការប្រគំស្គរក៏ដោយ ដោយហោចទៅ សូម្បីការវាយឧទកភេរី (ស្គរទឹក) ទាំងអស់នេះ ចាត់ជាការប្រគំតន្ត្រីទាំងអស់ ។

ពាក្យថា ទស្សនាយ គច្ឆតិ អាបត្តិ ទុក្កដស្ស : ភិក្ខុទៅដើម្បីមើលត្រូវអាបត្តិទុក្កដ បានដល់ ត្រូវអាបត្តិទុក្កដ ដោយរាប់វារៈជំហាន ។

ពាក្យថា យត្ថ ឋិតា បស្សតិ វា សុណាតិ វា : ភិក្ខុនីឈរមើលក្ដី ស្ដាប់ក្ដី ក្នុងទីណា មានសេចក្ដីថា ភិក្ខុនីកាលក្រឡេកមើលដោយប្រយោគតែមួយឃើញ បានស្ដាប់នូវការច្រៀង ការប្រគំតន្ត្រីរបស់ជនទាំងនោះឯង ជាបាចិត្តិយត្រឹមតែមួយ តែបើក្រឡេកមើលទិសមួយហើយឃើញអ្នករបាំ ក្រឡេកទៅមើលទិសដទៃទៀត ឃើញពួកអ្នកច្រៀងមើលទៅទិសដទៃ ឃើញពួកអ្នកភ្លេង ជាអាបត្តិនីមួយ ៗ ច្រើន ។ ភិក្ខុនីរមែងមិនបានដើម្បីនឹងរាំ ឬច្រៀង ឬប្រគំតន្ត្រីដោយខ្លួនឯង ។ សូម្បីប្រាប់អ្នកពួកដទៃថា ចូររាំ ចូរច្រៀង ចូរលេងភ្លេង ក៏មិនបាន ។ នឹងពោលថា "ឧបាសក ពួកលោកចូរឱ្យការបូជាព្រះចេតិយ"ក្ដី នឹងទទួលពាក្យថា "ល្អណាស់" ក្នុងកាលគេពោលថា "ពួកខ្ញុំនឹងធ្វើការបម្រើព្រះ

ចេតិយរបស់ពួកលោក”ក្តី រមែងមិនបាន ៗ លោកពោលទុកគ្រប់ ៗ អដ្ឋកថាថា ជាបាចិត្តិយក្នុងឋានៈទាំងពួង ។ ជាទុក្កដដល់ភិក្ខុ ។ តែកាលគេពោលថា “ពួកខ្ញុំនឹងធ្វើការថែទាំព្រះចេតិយរបស់ពួកលោក” ភិក្ខុនីនឹងពោលថា “ឧបាសក ឈ្មោះថា ការថែទាំ ជាការល្អ” គួរ ។

[១៨៤] ពីរបទថា អារាមេ ឋិតា : **ភិក្ខុនីឈរក្នុងអារាម** មានសេចក្តីថា ភិក្ខុនីឈរក្នុងអារាមនោះឯងឃើញ ឬបានឮការរាំជាដើមខាងក្នុងអារាមក្តី ខាងក្រៅអារាមក្តី មិនជាអាបត្តិ ។

ពីរបទថា សតិ ករណីយេ : **កាលបើមានកិច្ច** មានសេចក្តីថា ភិក្ខុនីទៅដើម្បីប្រយោជន៍ដល់សលាកភត្តជាដើម ឬដោយករណីយ៍ដទៃណាមួយ បានឃើញ ឬបានឮនៅក្នុងឋានដែលខ្លួនទៅ មិនជាអាបត្តិ ។

បទថា អាបទាសុ : **ភិក្ខុនីមានសេចក្តីអន្តរាយ** មានសេចក្តីថា ភិក្ខុនីត្រូវឧបទ្រវៈ ដូច្នោះ បៀតបៀនចូលទៅកាន់ស្ថានទីមើលមហោស្រពចូលទៅហើយយ៉ាងនេះ បានឃើញក្តី បានឮក្តី មិនជាអាបត្តិ ។ ពាក្យដែលសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

នច្ចគីតសិក្ខាបទវណ្ណនា ចប់ ។

## ចំនួនសិក្ខាបទ ក្នុងលសុណវគ្គ គឺ

១. លសុណសិក្ខាបទ ការទំពាស៊ីខ្ទឹម
២. សម្ពាធលោមសិក្ខាបទ ការឱ្យគេដកពេមក្នុងទីចង្អៀង
៣. តលឃាតកសិក្ខាបទ ការទះនូវផ្ទៃនៃអង្គជាតិ
៤. ជតុមដ្ឋកសិក្ខាបទ ដងបង្គួរមានសណ្ឋានរលីងធ្វើពីអាចម៍ល័ក្ត
៥. ឧទកសុទ្ធិកសិក្ខាបទ ការជម្រះអង្គជាតិដោយទឹកត្រឹម ២ ធ្នាប់
៦. ឧបតិដ្ឋនសិក្ខាបទ ចូលទៅបម្រើភិក្ខុកំពុងឆាន់ដោយទឹក-ផ្លិត
៧. អាមកធញ្ញសិក្ខាបទ ការសូម កិន បុក ចំអិននូវស្រូវស្រស់ បរិភោគ
៨. បឋមឧច្ចារឆឌ្ឌនសិក្ខាបទ ការចោលឧច្ចារជាដើមទៅខាងក្រៅរបង ឬ ជញ្ជាំង
៩. ទុតិយឧច្ចារឆឌ្ឌនសិក្ខាបទ ការចោលឧច្ចារជាដើមក្នុងទីមានវត្ថុមានពណ៌ខៀវ
១០. នច្ចគីតសិក្ខាបទ ការទៅមើលរបាំ ច្រៀង ប្រគំ

លសុណវគ្គ ចប់ ។

# ២. វគ្គនការវគ្គ

## ១. វគ្គនការសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃអន្ធការវគ្គ ដូចតទៅនេះ ៖

[១៨៥] បទថា អប្បទីបេ : **ឥតមានប្រទីប** គឺ ក្នុងទីមិនមានពន្លឺ ដោយបណ្តា ពន្លឺមានប្រទីប ព្រះចន្ទ ព្រះអាទិត្យ និងភ្លើងជាដើមសូម្បីមួយយ៉ាង ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា អប្បទីបេ នោះ ទើបព្រះមានព្រះភាគត្រាស់ថា **អនាលោកេ : មិនមានពន្លឺ ។**

បទថា សល្លបេយ្យ វា : **និយាយក្តី** បានដល់ ពោលពាក្យជាប់ដោយករគ្រប់គ្រងផ្ទះ ។

[១៨៧] ពីរបទថា អរហោបេក្ខោ អញ្ញាវិហិតោ : **ភិក្ខុនីប្រាថ្នានូវទីមិនស្ងាត់** មានសេចក្តីថា មិនសម្លឹងសេចក្តីត្រេកអរក្នុងទីកំបាំង ជាអ្នកបញ្ជូនចិត្តទៅដទៃ ចាកពីសេចក្តីត្រេកអរក្នុងទីកំបាំង សាកសួរដល់ញាតិ ឬអញ្ជើញគេក្នុងការថ្វាយទានក្តី ក្នុងការបូជាក្តី ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចថេយ្យសត្ថសិក្ខាបទ កើតឡើងមកកាយចិត្ត១ កាយវាចាចិត្ត១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា២ ដូច្នេះឯង ។

វគ្គនការសិក្ខាបទវណ្ណនា ចប់ ។

## ២. បដិច្ឆន្នោកាសសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

[១៨៨] ចំពោះពាក្យថា បដិច្ឆន្នេ ឱកាសេ : ក្នុងទីឱកាសដ៏កំបាំង នេះប៉ុណ្ណោះផ្សេងគ្នា ។ បទដែលនៅសល់ទាំងអស់ ប្រាកដដូចសិក្ខាបទមុននុ៎ះឯង ។

បដិច្ឆន្នោកាសសិក្ខាបទវណ្ណនា ចប់ ។

## ៣. អជ្ឈោកាសសល្លបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[១៩១] ពាក្យថា អជ្ឈោកាសេ : ក្នុងទីវាល ផ្សេងគ្នា ។ ពាក្យដែលនៅសល់ទាំងអស់ដូច្នោះឯង ។

អជ្ឈោកាសសល្លបនសិក្ខាបទវណ្ណនា ចប់ ។

# ៤. ទុតិយកឋិនឧយ្យោជនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

[១៩៤] ទីជិតត្រចៀក លោកហៅថា និកណ្ណិកៈ ។ មានពាក្យអធិប្បាយថា ឲ្យបទទីជិតត្រចៀក ។

[១៩៦] ពីរបទថា សតិ ករណីយេ : ភិក្ខុនីមានកិច្ច មានសេចក្ដីថា មានកិច្ចចាំបាច់ ដើម្បីត្រូវការនាំសលាកភត្តជាដើមមក ឬដើម្បីត្រូវការរក្សាទុកដាក់របស់ដែលដាក់ទុកមិនល្អក្នុងវត្ត ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។ សមុដ្ឋានជាដើម ជាដូចគ្នានឹងសិក្ខាបទមុននោះឯង ។

ទុតិយកឋិនឧយ្យោជនសិក្ខាបទវណ្ណនា ចប់ ។

# ៥. អនាបុច្ឆាបក្កមនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[១៩៧] ពីរបទថា យំ សោធេន្តា **: នាំគ្នាជម្រះសំអាតផ្ទះ** មានសេចក្តីថា បានឮថា ជនទាំងនោះ បានមានសេចក្តីបរិវិតក្កនេះថា ការកន្ទួងល្មើសដោយកាយ ដោយវាចាយ៉ាងណាមួយរបស់ព្រះថេរី មិនប្រាកដ ។ ពួកយើងចូរជួយគ្នាសំអាតផ្ទះសិនចុះ ព្រោះដូច្នោះ ពួកម្ចាស់របស់ផ្ទះ កាលជម្រះផ្ទះ ទើបបានជួបអាសនៈ ។

[១៩៨] ពីរបទថា អនោវស្សិកំ អតិក្កាមន្តិយា **: កាលភិក្ខុនីឈានផុតទីដែលភ្លៀងធ្លាក់មិនត្រូវ** មានសេចក្តីថា ភិក្ខុនីកាលឱ្យជើងដំបូងឈានហួសទៅ ជាទុក្កដ ។ កាលឱ្យជើងទី ២ ឈានហួសទៅ ជាបាចិត្តិយ ។ សូម្បីក្នុងការឈានកន្ទួងឧបចារៈ ក៏មានន័យយ៉ាងនេះដូចគ្នា ។

[២០០] បទថា គិលាណាយ **: ភិក្ខុនីមានជម្ងឺ** គឺ មិនអាចនឹងពោលលា ព្រោះអាពាធ ដូច្នោះ ។

បទថា អាបទាសុ **: ភិក្ខុនីមានសេចក្តីអន្តរាយ** មានសេចក្តីថា ក្នុងផ្ទះកើតភ្លើងឆេះឡើង ឬត្រូវពួកចោរប្លន់ ក្នុងអន្តរាយបែបនេះ មិនពោលលាជៀសចេញទៅ មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងមកកាយ វាចា ១ កាយវាចាចិត្ត ១ ជាកិរិយានិងអកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អនាបុច្ឆាបក្កមនសិក្ខាបទវណ្ណនា ចប់ ។

# ៦. អនាបុច្ឆាអភិនិសីទនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

[២០១] បទថា អភិនិសីទេយ្យ **: ហើយអង្គុយ** គឺ គប្បីអង្គុយ ។ កាលអង្គុយហើយក្រោកទៅ ជាអាបត្តិតែមួយ ។ កាលមិនអង្គុយ ដេកហើយទៅ ជាអាបត្តិតែមួយ ។ កាលអង្គុយហើយដេក ជាអាបត្តិ ២ ។

[២០៤] បទថា ធុវប្បញ្ញត្តេ **: អាសនៈដែលគេក្រាលទុកជានិច្ច** បានដល់ អាសនៈដែលគេក្រាលទុកជាប្រចាំ ដើម្បីប្រយោជន៍ដល់ភិក្ខុនីទាំងឡាយ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងមកកាយ

វាចា ១ កាយវាចាចិត្ត ១ ជាកិរិយានិងជាអកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អនាបុច្ឆាអភិនិសីទនសិក្ខាបទវណ្ណនា ចប់ ។

## ៧. អនាបុច្ឆាសន្ថរណសិក្ខាបទវណ្ណនា

សូម្បីក្នុងសិក្ខាបទទី ៧ បណ្ឌិតគប្បីជ្រាបពាក្យទាំងអស់ ដោយន័យដូចបានពោលហើយក្នុងសិក្ខាបទទី ៦ នុ៎ះឯង ។

អនាបុច្ឆាសន្ថរណសិក្ខាបទវណ្ណនា ចប់ ។

## ៨. បរឧជ្ឈាបនកសិក្ខាបទវណ្ណនា

ពាក្យទាំងអស់ក្នុងសិក្ខាបទទី ៨ ងាយយល់ទាំងអស់ ។ សិក្ខាបទនេះ មានសមុដ្ឋាន ៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនាដូច្នេះឯង ។

បរឧជ្ឈាបនកសិក្ខាបទវណ្ណនា ចប់ ។

# ៩. បរអតិសបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

[២១៣] បទថា អភិសបេយ្យ : ផ្តាសាខ្លួនឯង បានដល់ គប្បីធ្វើការផ្តាសា ។ អធិប្បាយថា ដែលឈ្មោះថា ផ្តាសាដោយនរក បានដល់ ជេរប្រទេច បរិភាស ដោយន័យជាដើមយ៉ាងនេះថា "សូមឱ្យយើងកើតក្នុងនរក កើតក្នុងអវិចីចុះ, សូមឱ្យអ្នកលួចកើតក្នុងនរក កើតក្នុងអវិចីចុះ" ។ ដែលឈ្មោះថា ផ្តាសាដោយព្រហ្មចរិយៈ បានដល់ ជេរប្រទេច ដោយន័យជាដើមយ៉ាងនេះថា "សូមឱ្យយើងចូរជាគ្រហស្ថ, ជាអ្នកស្លៀកសំពត់ស, ជាបរិពាជិកាចុះ" ឬ"ភិក្ខុនីក្រៅនេះ ចូរជាដូច្នេះចុះ" ។ ជាបាចិត្តិយគ្រប់ ៗ ពាក្យនិយាយ តែកាលជេរដោយន័យជាដើមថា "សូមឱ្យយើងជាមេសុនខ ជាមេជ្រូក ជាអ្នកខ្វាក់ភ្នែក ជាមនុស្សពិការចុះ" ។ វៀរនរកនិងព្រហ្មចរិយបេញ ជាទុក្កដគ្រប់ ៗ ពាក្យនិយាយ ។

[២១៦] បទថា អត្តបុរេក្ខារាយ : ភិក្ខុនីផ្តាសាព្រោះធ្វើអត្តឱ្យជាប្រធាន គឺ អ្នកពោលអដ្ឋកថា ។

បទថា ធម្មបុរេក្ខារាយ : ភិក្ខុនីផ្តាសាព្រោះធ្វើធម៌ឱ្យជាប្រធាន គឺ អ្នកបង្រៀនបាលី ។

បទថា អនុសាសនីបុរេក្ខារាយ : ភិក្ខុនីផ្តាសាព្រោះធ្វើពាក្យ

ប្រៀនប្រដៅឱ្យជាប្រធាន មានសេចក្តីថា កាលតាំងនៅក្នុងអនុសាសនីពេលទូន្មានយ៉ាងនេះថា "សូម្បីឥឡូវនេះ នាងនៅយ៉ាងនេះ ល្អណាស់ នាងចូរវៀរចាក បើនាងមិនវៀរចាក ហើយធ្វើកម្មបែបនេះទៀត ក៏នឹងកើតក្នុងនរក កើតក្នុងកំណើតសត្វតិរច្ឆានពិតប្រាកដ" មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

បរអភិសបទសិក្ខាបទវណ្ណនា ចប់ ។

## ១០. រោទនសិក្ខាបទវណ្ណនា

ពាក្យទាំងអស់ក្នុងសិក្ខាបទទី ១០ ងាយយល់ទាំងអស់ ។ សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន កើតឡើងមកកាយវាចាចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

រោទនសិក្ខាបទវណ្ណនា ចប់ ។

## ចំនួនសិក្ខាបទ ក្នុងរត្តន្ធការវគ្គ គឺ

១. រត្តន្ធការសិក្ខាបទ ការស្ថិតនៅជាមួយបុរសក្នុងទីយប់ងងឹត
២. បដិច្ឆន្នោកាសសិក្ខាបទ ការស្ថិតនៅជាមួយបុរសក្នុងទីដ៏កំបាំង
៣. អជ្ឈោកាសសល្លបនសិក្ខាបទ ការស្ថិតនៅជាមួយបុរសក្នុងទីវាល
៤. ទុតិយិកឧយ្យោជនសិក្ខាបទ ការស្ថិតនៅជាមួយបុរសក្នុងច្រកមក
៥. អនាបុច្ឆាបក្កមនសិក្ខាបទ ការមិនពោលលាម្ចាស់ផ្ទះហើយចៀសទៅ
៦. អនាបុច្ឆាអភិនិសីទនសិក្ខាបទ ការមិនប្រាប់ម្ចាស់ផ្ទះហើយអង្គុយឬដេក
៧. អនាបុច្ឆាសន្ថរណសិក្ខាបទ ការមិនប្រាប់ម្ចាស់ផ្ទះក្រាលកម្រាល ហើយ អង្គុយឬដេក
៨. បរឧជ្ឈាបនកសិក្ខាបទ ការមើលងាយគេដោយករប្រកាន់អាក្រក់
៩. បរអភិសបនសិក្ខាបទ ការផ្ដាសាគេដោយនរកនិងព្រហ្មចរិយៈ
១០. រោទនសិក្ខាបទ ការវាយតប់ខ្លួនឯងហើយយំ

រត្តន្ធការវគ្គទី ២ ចប់ ។

# ៣. នគ្គវគ្គ

## ១. នគ្គសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី១នៃនគ្គវគ្គ ដូចតទៅនេះ ៖

[២២០] បទថា ព្រហ្មចរិយំ ចិណ្ណេន : សន្សំព្រហ្មចរិយធម៌ គឺ ដោយព្រហ្មចរិយៈដែលពួកលោកនាំគ្នាប្រព្រឹត្ត ។ ម្យ៉ាងទៀត គប្បីឃើញទុតិយាវិភត្តិចុះក្នុងអត្ថនៃតតិយាវិភត្តិ ឬក្នុងអត្ថនៃឆដ្ឋីវិភត្តិយ៉ាងនេះថា ដោយការប្រព្រឹត្តព្រហ្មចរិយៈ ។

[២២២] បទថា អច្ឆិន្នចីវរិកាយ : ភិក្ខុនីមានចីវរដែលពួកចោរលួចយកទៅ នេះ ព្រះមានព្រះភាគត្រាស់សំដៅយកសំពត់ងូតទឹក មិនបានទ្រង់សំដៅយកចីវរប្រភេទដទៃ ។ ព្រោះហេតុនោះ ភិក្ខុនីអាក្រាតកាយងូតទឹក កាលសំពត់ងូតទឹកត្រូវគេដណ្តើមទៅក្តី វិនាសបាត់ក្តី មិនជាអាបត្តិ ។ បើសូម្បីថា ចីវរគឺ សំពត់ងូតទឹកមានតម្លៃច្រើន ភិក្ខុនីមិនអាចដើម្បីនឹងស្លៀកចេញទៅខាងក្រៅបាន សូម្បីយ៉ាងនេះ នឹងអាក្រាតកាយងូតទឹក ក៏គួរ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

នគ្គសិក្ខាបទវណ្ណនា ចប់ ។

## ២. ឧទកសាដិកសិក្ខាបទវណ្ណនា

ពាក្យទាំងអស់ក្នុងសិក្ខាបទទី ២ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឧទកសាដិកសិក្ខាបទវណ្ណនា ចប់ ។

## ៣. ចីវរសិព្វនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[២២៧] បទថា អនន្តរាយិកិនី : ភិក្ខុនី(នោះ)មិនមានអន្តរាយ បានដល់ អ្នកមិនមានអន្តរាយ សូម្បីណាមួយ ក្នុងអន្តរាយ ១០ យ៉ាង ។

[២២៨] ពីរបទថា ធុរំ និក្ខិត្តមត្តេ : ភិក្ខុនីគ្រាន់តែដាក់ធុរៈ មានសេចក្តីថា ភិក្ខុនីដាក់ធុរៈចេញហើយ បើសូម្បីខាងក្រោយទើបដេរ ក៏ជាអាបត្តិដូចគ្នា ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ចីវរសិព្វនសិក្ខាបទវណ្ណនា ចប់ ។

# ៤. សង្ឃាដិចារសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

[២៣១] ៥ថ្ងៃ ឈ្មោះ បញ្ចាហៈ ។ បញ្ចាហៈនោះឯង ឈ្មោះថា បញ្ចាហិក, វារៈផ្លាស់ប្ដូរសំពត់សង្ឃាដិទាំងឡាយ ឈ្មោះថា សង្ឃាដិវារៈ ។ ការផ្លាស់ប្ដូរចីវរ ៥ ផ្ទាំង ដែលបានឈ្មោះថា សង្ឃាដិ ដោយអត្ថថា ផ្លាស់ប្ដូរឆ្លាស់គ្នាទៅ ដោយករបរិភោគប្រើប្រាស់ខ្លះ ដោយអំណាចការហាលថ្ងៃខ្លះ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ទុកក្នុងបទភាជនៈថា "ភិក្ខុនីមិនបានស្លៀក មិនបានគ្រង មិនបានសំដិលហាលនូវចីវរទាំង ៥ អស់ថ្ងៃទី ៥ គឺថា ធ្វើឱ្យកន្លងហួសថ្ងៃទី ៥ ទៅ" ។

[២៣២] ក៏ក្នុងពាក្យថា អាបត្តិ បាចិត្តិយស្ស : ត្រូវអាបត្តិបាចិត្តិយ នេះ មានវិនិច្ឆ័យថា ក្នុងចីវរមួយផ្ទាំងជាអាបត្តិមួយ ក្នុងចីវរ ៥ ផ្ទាំង ជាអាបត្តិ ៥ ។

[២៣៤] បទថា អាបទាសុ : ភិក្ខុនីមានសេចក្ដីអន្តរាយ មានសេចក្ដីថា ចីវរមានតម្លៃឡើងថ្លៃ ជាការដែលភិក្ខុនីមិនអាចនឹងបរិភោគប្រើប្រាស់ ព្រោះអន្តរាយមានចោរភ័យជាដើម ក្នុងឧបទ្រវៈបែបនេះ មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចគ្នានឹងកឋិនសិក្ខាបទ ជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សង្ឃាដិចារសិក្ខាបទវណ្ណនា ចប់ ។

# ៥. ចីវរសង្កមនីយសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[២៣៥] បទថា ចីវរសង្កមនីយំ **:** ចីវរដែលខ្លួនលបយកទៅប្រើប្រាស់មួយសំណើរ គឺ ចីវរដែលផ្លាស់ប្តូរគ្នា សេចក្តីថា ចីវរដែលជារបស់ភិក្ខុនីរូបដទៃ ដែលភិក្ខុនីមិនប្រាប់ដល់ម្ចាស់របស់មុន កាន់យកទៅនឹងត្រូវសងវិញ ។

[២៣៨] បទថា អាបទាសុ **:** ភិក្ខុនីមានសេចក្តីអន្តរាយ មានសេចក្តីថា បើពួកចោរលួចយកសំពត់ដែលនៅមិនបានដណ្តប់ ឬមិនទាន់បានស្លៀកទៅ ។ ក្នុងអន្តរាយបែបនេះ ស្លៀកដណ្តប់ទៅជាអាបត្តិ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ ជាកិរិយានិងអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ចីវរសង្កមនីយសិក្ខាបទវណ្ណនា ចប់ ។

# ៦. គណចីវរសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

[២៨០] ពីរបទថា អញ្ញំ បរិក្ខារំ : បរិក្ខារដទៃ បានដល់បរិក្ខារប្រភេទណាមួយ គឺវត្ថុមានភាជនៈជាដើម ឬភេសជ្ជៈមានទឹកដោះថ្លា និងប្រេងជាដើមយ៉ាងណាមួយ ។

[២៨១] បទថា អានិសំសំ : អានិសង្ស មានសេចក្តីថា ភិក្ខុនីសួរថា "អ្នកទាំងឡាយមានបំណងនឹងប្រគេនសំពត់មានតម្លៃប៉ុន្មាន ?" ពួកទាយកឆ្លើយថា "មានតម្លៃប៉ុណ្ណេះ" ។ ភិក្ខុនីនិយាយយ៉ាងនេះថា "ពួកលោកចូររង់ចាំទៅសិន វេលានេះសំពត់មានតម្លៃឡើងថ្លៃ តទៅបន្តិចទៀត កាលកប្បាសមកដល់ នឹងមានតម្លៃល្មមសមគួរ" ហើយហាមទុកមិនជាអាបត្តិ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

គណចីវរសិក្ខាបទវណ្ណនា ចប់ ។

# ៧. បដិពាហនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[២៤២] បទថា វិបក្កមិសុ[១] : នាំគ្នាចៀសចេញទៅអស់ មានសេចក្តីថា ភិក្ខុនីទាំងឡាយ ពោលនឹងគ្នាថា “ពួកភិក្ខុនីនៅរង់ចាំការមករបស់ភិក្ខុនី សូម្បីពួកដទៃបាន ក៏នឹងរង់ចាំពួកយើងមកជាពិតប្រាកដ” ទើបបាននាំគ្នាទៅក្នុងទីចាំបាច់ត្រូវទៅនោះ ។

បទថា បដិពាហេយ្យ : ហាមឃាត់ គឺ គប្បីបដិសេធទុក ។

[២៤៥] បទថា អានិសំសំ : អានិសង្ស មានសេចក្តីថា សម្តែងអានិសង្សហាមយ៉ាងនេះថា “សំពត់តែមួយផ្ទាំង មិនល្មមសម្រាប់ភិក្ខុនីមួយរូប ពួកលោកចូររង់ចាំសិន បន្តិចទៀតសំពត់នឹងកើតឡើងតពីនោះយើងនឹងបែងចែកគ្នា” ដូច្នេះ មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

បដិពាហនសិក្ខាបទវណ្ណនា ចប់ ។

---

១. ភូមា. បក្កមិសុ ។

# ៨. ចីវរទានសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

[២៤៦] ពួកជនអ្នកហ្វឹកហាត់អ្នករាំ ឈ្មោះថា ពួកមេរបាំ ។ ពួកជនអ្នករាំ ឈ្មោះថា ពួកកូនរបាំ ។ ពួកជនអ្នកធ្វើការលោតឡើងលើរ៉ាវ និងលើខ្សែជាដើម ឈ្មោះថា ពួកអ្នកឡើងរ៉ាវ[១] ។ ពួកជនអ្នកសម្ដែងកល ឈ្មោះថា ពួកអ្នកត្លុក ។ ពួកជនអ្នកលេងដោយស្គរ ឈ្មោះថា ពួកអ្នកវាយស្គរ ។ អាចារ្យពួកខ្លះពោលថា ពួកអ្នកភ្លេងពិណពាទ្យ ក៏មាន ។

[២៤៧] ក្នុងពាក្យថា ឧទតិ អាបត្តិ បាចិត្តិយស្ស : ភិក្ខុនីឱ្យ (សមណចីវរ) ត្រូវអាបត្តិបាចិត្តិយ នេះ បណ្ឌិតគប្បីជ្រាបថា ជាអាបត្តិច្រើនតាមចំនួនចីវរ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ចីវរទានសិក្ខាបទវណ្ណនា ចប់ ។

---

១. ពាក្យថា រ៉ាវ ជាពាក្យបុរាណ ។ វចនានុក្រមជួនណាត ទំព័រ ៦៤៨ ថា រ៉ាវ (ន.) គឺឃ្នាងវែង សម្រាប់ដាក់មនុស្សដែលជាប់ចោទជាទម្ងន់ ចងដៃជើងទាំងពីរ ទាញសន្ទឹងតឹងភ្ជាប់នឹងស្ទឹងខាងមុខ ចងចង្កេះ ទាញសន្ទឹងតឹងភ្ជាប់នឹងស្ទឹងខាងក្រោយ វាយស្គរចម្លើយ : ចងរ៉ាវ, វាយរ៉ាវ (មានប្រើតែក្នុងរាជពិធីពីដើម) ។

# ៩. កាលអតិក្កមនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

[២៤៩] បទថា ទុព្វលចីវរបច្ចាសាយ : ដោយសេចក្ដីប្រាថ្នាចីវរដ៏ទុព្វល គឺ ដោយសេចក្ដីប្រាថ្នានឹងបានចីវរដែលមិនពិតប្រាកដ ។

[២៥២] បទថា អានិសំសំ : អានិសង្ស មានសេចក្ដីថា ដល់សូម្បីពួកអ្នកស្រុកពោលថា នាងម្ចាស់ពួកខ្ញុំមិនទាន់អាច ដូច្នេះ ក៏ពិតកាលភិក្ខុនីសម្ដែងអានិសង្សប្រហាមយ៉ាងនេះថា "វេលានេះ កប្បាសនឹងមកដល់អ្នកស្រុកនោះ បុរសអ្នកមានសទ្ធាជ្រះថ្លា នឹងមក នឹងប្រគេនជាប្រាកដ" មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ងាយទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា៣ ដូច្នេះឯង ។

កាលអតិក្កមនសិក្ខាបទវណ្ណនា ចប់ ។

# ១០. កឋិនុទ្ធារសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[២៥៣] ក្នុងពាក្យថា កឋិនុទ្ធារំ ន ឧស្សារេន្តិ **: មិនឱ្យការដក កឋិន** នេះ មានវិនិច្ឆ័យដូច្នេះ ៖

តើការដោះកឋិនយ៉ាងណាសង្ឃគួរឱ្យ យ៉ាងណាមិនគួរឱ្យ គឺ ការដោះកឋិន ដូចយ៉ាងដែលមានអានិសង្សច្រើន មានការក្រាលជាមូល, មានអានិសង្សតិច មានការដោះជាមូល មិនគួរឱ្យ ។ តែការដោះកឋិន ដូចយ៉ាង ដែលមានអានិសង្សតិច មានការក្រាលជាមូល មានអានិសង្សច្រើន មានការដោះជាមូល គួរឱ្យ ។ ការដោះកឋិនសូម្បីមានអានិសង្សប៉ុនៗគ្នា ។

[២៥៧] បទថា អានិសំសំ **: អានិសង្ស** មានសេចក្ដីថា ភិក្ខុនីសម្ដែងអានិសង្សបែបនេះថា ភិក្ខុនីសង្ឃមានចីវរចាស់ មានលាភច្រើន ដែលមានអានិសង្សនៃកឋិនជាមូល ហើយហាមឃាត់ មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា៣ ដូច្នេះឯង ។

កឋិនុទ្ធារសិក្ខាបទវណ្ណនា ចប់ ។

## ចំនួនសិក្ខាបទ ក្នុងនគ្គវគ្គ គឺ

| | |
|---|---|
| ១. នគ្គសិក្ខាបទ | ការអាក្រាតកាយងូតទឹក |
| ២. ឧទកសាដិកសិក្ខាបទ | ការធ្វើសំពត់ងូតទឹកឱ្យកន្លងលើសប្រមាណ |
| ៣. ចីវរសិព្វនសិក្ខាបទ | រុសចីវររបស់ភិក្ខុនីដទៃហើយមិនដេរឱ្យវិញ |
| ៤. សង្ឃាដិចារសិក្ខាបទ | ញុំាងវារៈនៃសង្ឃាដិឱ្យកន្លងហួស៥ថ្ងៃទៅ |
| ៥. ចីវរសង្កមនីយសិក្ខាបទ | ការលបយកចីវរប្រើប្រាស់មួយសំណើរ |
| ៦. គណចីវរសិក្ខាបទ | ការធ្វើចីវររបស់គណៈឱ្យវិនាសទៅ |
| ៧. បដិពាហនសិក្ខាបទ | ការហាមឃាត់ការចែកចីវរដែលប្រកបដោយធម៌ |
| ៨. ចីវរទានសិក្ខាបទ | ការឱ្យសមណចីវរដល់គ្រហស្ថជាដើម |
| ៩. កាលអតិក្កមនសិក្ខាបទ | ការញុំាងសម័យនៃចីវរកាលឱ្យកន្លងហួស |
| ១០. កឋិនុទ្ធារសិក្ខាបទ | ការហាមឃាត់ការដកកឋិនដែលប្រកបដោយធម៌ |

នគ្គវគ្គទី ៣ ចប់

# ៤. ឥទ្វវគ្គ

## ១. ឯកមញ្ចឥទ្វនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃតុវដ្ដវគ្គ ដូចតទៅនេះ ៖

[២៥៨] បទថា តុវដ្ដយ្យុំ : ដេក គឺ គប្បីដេក ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឯកមញ្ចតុវដ្ដនសិក្ខាបទវណ្ណនា ចប់ ។

## ២. ឯកត្ថរណតុវដ្ដនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

[២៦១] សំពត់ក្រាលទីដេក និងសំពត់ដណ្ដប់របស់ភិក្ខុនី ២ រូបនេះ មួយផ្ទាំងរួមគ្នា; ព្រោះដូច្នោះ នាងទាំង ២ នោះ ទើបឈ្មោះថា មានសំពត់សម្រាប់ក្រាលសម្រាប់ដណ្ដប់តែមួយ ដេកជាមួយគ្នា ។ ពាក្យថា ឯកត្ថរណបាបុរណា នេះ ជាឈ្មោះនៃភិក្ខុនីទាំង ២ អ្នកក្រាលជាយម្ខាងនៃសំពត់បាវារសំពត់ក្រាលដេក និងកន្ទេលផែនជាដើម ដែលឃ្លាតចាកទីបាន ហើយដេកដណ្ដប់ជាយម្ខាង ។

[២៦៤] ពីរបទថា វវត្ថានំ[1] ធស្សេត្វា : សម្ដែងនូវទីកំណត់ មានសេចក្ដីថា មិនជាអាបត្តិដល់ភិក្ខុនីទាំង ២ រូបអ្នកដេកដាក់សំពត់កាសាយៈ ឬឈើច្រត់មនុស្សចាស់ ដោយហោចទៅ សូម្បីវត្តពន្ធចង្កេះ ទុកត្រង់កណ្ដាល ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា សញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឯកត្ថរណតុវដ្ដនសិក្ខាបទវណ្ណនា ចប់ ។

---

១. បិដកខ្មែរថា វត្ថានំ ។

# ៣. អផាសុករណសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[២៦៥] បទថា ឧឡារសម្ភាវិតា : ជាអ្នកដែលមហាជនសរសើរក្រៃពេក មានសេចក្តីថា ដែលមនុស្សទាំងឡាយលើកតម្កើងថា ជាអ្នកខ្ពស់ជាង ព្រោះជាអ្នកចេញមកបួសអំពីត្រកូលខ្ពស់ និងព្រោះជាអ្នកវិសេសជាងដោយគុណទាំងឡាយ ។

បទថា ឥស្សាបកតា : ជាមនុស្សមានសេចក្តីឫស្យាគ្របសង្កត់ មានសេចក្តីថា អ្នកត្រូវសេចក្តីឫស្យាញាំញី គឺ គ្របសង្កត់ហើយ ។

ភិក្ខុនីទាំងនេះ មានការអភិប្រាយច្រើនណាស់ ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកខ្វល់ខ្វាយដោយការអភិប្រាយឱ្យអ្នកដទៃយល់ ។ អធិប្បាយថា ចង្អុលបង្ហាញឱ្យមហាជនយល់រហូតអស់មួយថ្ងៃ ។

ភិក្ខុនីទាំងនេះ មានការពន្យល់បង្ហាញអត្ថ ឱ្យយល់ច្បាស់ច្រើនណាស់ ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកខ្វល់ខ្វាយដោយការពន្យល់បង្ហាញអត្ថឱ្យយល់ច្បាស់ ។ គប្បីជ្រាបថា វិញ្ញត្តិ បានដល់ ការចង្អុលបង្ហាញអត្ថឱ្យយល់ច្បាស់ ដោយន័យផ្សេង ៗ មានហេតុ និងឧទាហរណ៍ជាដើម ។ មិនគប្បីយល់ថា ការសូម ។ គប្បីជ្រាបថា ជាអាបត្តិច្រើន ដោយរាប់ការដើរត្រឡប់ទៅមក ក្នុងការចង្ក្រម ។

[២៦៨] ក្នុងពាក្យថា តិដ្ឋតិ វា : ឈរក្តី ជាដើម គប្បីជ្រាប

ថា ជាអាបត្តិច្រើន ដោយរាប់ប្រយោគ ។

ក្នុងពាក្យថា ឧទ្ទិសតិ វា : សម្ដែងឯងក្ដី ជាដើម គប្បីជ្រាបថា ជាអាបត្តិច្រើន ដោយករាប់បទជាដើម ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ ជាកិរិយានិងជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

អដ្ឋាសុករណសិក្ខាបទវណ្ណនា ចប់ ។

# ៤. នឧបដ្ឋាបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

[២៧១] ពីរបទថា សតិ អន្តរាយេ : កាលបើមានសេចក្ដីអន្តរាយ គឺ កាលមានអន្តរាយ ១០ យ៉ាង ។

ពីរបទថា បរិយេសិត្វា ន លភតិ : ហើយភិក្ខុនីស្វែងរកអ្នកឯទៀតឱ្យជាអ្នកបម្រើជម្ងឺមិនបាន គឺ មិនបានភិក្ខុនីដទៃជួយជំនួស ។

បទថា គិលានាយ : ភិក្ខុនីឈឺខ្លួនឯង គឺ អាពាធដោយខ្លួនឯង ។

បទថា អាបទាសុ : ភិក្ខុនីមានសេចក្ដីអន្តរាយ បានដល់ កាល

មានអន្តរាយបែបនោះ មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ ងាយទាំងអស់ហើយ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

នឧបដ្ឋាបនសិក្ខាបទវណ្ណនា ចប់ ។

## ៥. និក្កឌ្ឍនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[២៧៣] ក្នុងពាក្យថា អញ្ញំ អាណាបេតិ : ភិក្ខុនីបង្គាប់អ្នកដទៃឱ្យទន់ទាញ នេះ មានវិនិច្ឆ័យដូច្នេះ ៖

បើភិក្ខុនីអ្នកបានទទួលបង្គាប់ថា នាងចូរទាញចេញទៅ អូសទាញឱ្យហួសទ្វារសូម្បីច្រើនចេញទៅ ដោយប្រយោគតែមួយ ក៏ជាអាបត្តិតែមួយ ។ បើបានទទួលបង្គាប់យ៉ាងនេះថា ចូរទាញឱ្យចេញផុតទ្វារនេះ និងទ្វារនេះទៅ ទាញឱ្យចេញហួសទៅ ជាអាបត្តិច្រើន ដោយករាប់ទ្វារ ពាក្យដែលនៅសល់ងាយទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

និក្កឌ្ឍនសិក្ខាបទវណ្ណនា ចប់ ។

# ៦. សំសដ្ឋសិក្ខាបទវណ្ណនា

ក្នុងសិក្ខាបទទី ៦ បទទាំងពួង ងាយយល់ទាំងអស់ ។ សិក្ខាបទនេះ មានការស្មូធ្យសមនុភាសនជាសមុដ្ឋាន ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

សំសដ្ឋសិក្ខាបទវណ្ណនា ចប់ ។

# ៧.៨.៩. អន្ទោវដ្ឋតិរោវដ្ឋន្ទោវស្សសិក្ខាបទវណ្ណនា

ក្នុងសិក្ខាបទទី ៧-៨-៩ គ្រប់ ៗ បទ ងាយយល់ទាំងអស់ ៗ គ្រប់ ៗសិក្ខាបទ មានការស្មូធ្យ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អន្តោវដ្ឋតិរោវដ្ឋន្តោវស្សសិក្ខាបទវណ្ណនា ចប់ ។

# ១០. ចារិកនបក្កមនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[២៩២] បទថា អាហុន្ទរិកា : ជ្រៀតបៀត គឺ ចង្អៀត ។

[២៩៣] ពីរបទថា ធុរំ និក្ខិត្តមត្តេ : ភិក្ខុនីគ្រាន់តែដាក់ធុរៈ មានសេចក្ដីថា បើសូម្បីថា ភិក្ខុនីដាក់ធុរៈហើយ ខាងក្រោយទើបជៀសទៅ ជាអាបត្តិដូចគ្នា ។ សូម្បីកាលបវារណាហើយទៅអស់ ៥ យោជន៍ មិនជាអាបត្តិ ។ ក្នុង៦ យោជន៍ មិនមានពាក្យដែលនឹងគប្បីពោលដល់ឡើយ ។ ក៏បើថា ភិក្ខុនីទៅបាន ៣ យោជន៍ ហើយបែរត្រឡប់មកតាមមកដើមវិញទុំះឯង មិនគួរ ។ នឹងមកតាមមកដទៃ គួរ ។

[២៩៤] បទថា អន្តរាយេ : អន្តរាយ គឺ មានអន្តរាយ ១០ យ៉ាង ។ ភិក្ខុនីចេញទៅដោយគិតថា យើងនឹងទៅ តែទឹកជន់ឡើងមកពេញទន្លេ ឬមានពួកចោរចាំស្កាត់ក្បែរច្រកមក ឬពពកខ្មៅតាំងឡើង នឹងត្រឡប់មក ក៏គួរ ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ចារិកនបក្កមនសិក្ខាបទវណ្ណនា ចប់ ។

## ចំនួនសិក្ខាបទ ក្នុងតុវដ្ដវគ្គ គឺ

១. ឯកមញ្ចតុវដ្ដនសិក្ខាបទ ការដេកលើគ្រែមួយរួមគ្នា

២. ឯកត្ថរណតុវដ្ដនសិក្ខាបទ ការដេករួមគ្នា ដោយសំពត់សម្រាប់ក្រាល សម្រាប់ដណ្ដប់តែមួយ

៣. អផាសុករណសិក្ខាបទ ការក្លែងធ្វើសេចក្ដីមិនសប្បាយ

៤. នឧបដ្ឋាបនសិក្ខាបទ ការមិនបម្រើភិក្ខុនីជាសិស្សដែលមានទុក្ខ

៥. និក្កឌ្ឍនសិក្ខាបទ ការឱ្យលំនៅហើយខឹងទន់ទាញចេញវិញ

៦. សំសដ្ឋសិក្ខាបទ ការនៅច្រឡូកច្រឡំដោយគហបតីជាដើម

៧. អន្តោរដ្ឋសិក្ខាបទ ការទៅក្នុងដែនដែលមានសេចក្ដីរង្កៀស

៨. តិរោរដ្ឋសិក្ខាបទ ការទៅក្រៅដែនដែលមានសេចក្ដីរង្កៀស

៩. អន្តោវស្សសិក្ខាបទ ការត្រាច់ចារិកទៅខាងក្នុងវស្សា

១០. ចារិកនបក្កមនសិក្ខាបទ ចាំវស្សារួចហើយមិនចៀសទៅកាន់ចារិក

តុវដ្ដវគ្គទី ៤ ចប់ ។

# ៥. ចិត្តាគារវគ្គ

## ១. រាជាគារសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃចិត្តាគារវគ្គ ដូចតទៅនេះ ៖

[២៩៥] បទថា រាជាគារំ : អាគាររបស់ព្រះរាជា បានដល់ដំណាក់សម្រាប់ក្រសាលរបស់ស្តេច ។

បទថា ចិត្តាគារំ : រោងដ៏វិចិត្រ បានដល់ សាលាសម្តែងចិត្រកម្មគួររីករាយ ។

បទថា អារាមំ : សួន បានដល់ សួនដែលជាស្ថានទីបន្ធូរចិត្ត ។

បទថា ឧយ្យានំ : ឧទ្យាន បានដល់ ឧទ្យានជាទីបន្ធូរអារម្មណ៍ ។

បទថា បោក្ខរណឹ : ស្រះបោក្ខរណី បានដល់ ស្រះបោក្ខរណីជាទីសម្រាប់លេងកីឡា ព្រោះហេតុនោះឯង ក្នុងបទភាជនៈ ទើបព្រះមានព្រះភាគបានត្រាស់ពាក្យថា "ដំណាក់ដែលគេសាងឡើងដើម្បីក្រសាលសប្បាយដល់ស្តេច នៅក្នុងកន្លែងណាមួយ" ជាដើម ។

[២៩៦] ក្នុងពាក្យថា ទស្សនាយ គច្ឆតិ អាបត្តិ ទុក្កដស្ស : ភិក្ខុនីទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ គឺជាទុក្កដ ដោយរាប់ជំហាន ។

ក៏ក្នុងពាក្យថា យត្ថ ឋិតា បស្សតិ : ឈរមើលក្នុងទីណា នេះ មានវិនិច្ឆ័យថា បើភិក្ខុនីឈរក្នុងទីតែមួយទុំះឯង មិនលើកជើងទៅមក នៅមើលដល់ ៥ ដង ក៏ជាបាចិត្តិយតែមួយប៉ុណ្ណោះ ។ តែកាលភិក្ខុនីសម្លឹងមើលទិសាភាគនោះ ៗ ហើយមើល ជាអាបត្តិច្រើន ។ តែជាទុក្កដដល់ភិក្ខុក្នុងទីទាំងពួង ។

[២៩៧] ពីរបទថា អារាមេ ឋិតា : ភិក្ខុនីឈរក្នុងអារាម មានសេចក្តីថា ជនទាំងឡាយសាងព្រះរាជវាំងជាដើមជិតអារាមជាទីនៅ មិនជាអាបត្តិដល់ភិក្ខុនី ដែលមើលឃើញព្រះរាជវាំងជាដើមនោះ ។

ពីរបទថា គច្ឆន្តី វា អាគច្ឆន្តី វា : ភិក្ខុនីកំពុងដើរទៅក្តី ដើរមកក្តី មានសេចក្តីថា មើលឃើញព្រះរាជវាំងជាដើមនោះ មាននៅជិតមករបស់ភិក្ខុនីដែលដើរទៅ ដើម្បីប្រយោជន៍ដល់បិណ្ឌបាតជាដើម មិនជាអាបត្តិ ។

ពាក្យថា សតិ ករណីយេ គន្ត្វា : កាលបើមានកិច្ចភិក្ខុនីទៅ មានសេចក្តីថា ភិក្ខុនីទៅកាន់រាជដំណាក់ដោយកិច្ចចាំបាច់យ៉ាងណាមួយ ហើយឃើញ មិនជាអាបត្តិ ។

បទថា អាបទាសុ : ភិក្ខុនីមានសេចក្តីអន្តរាយ មានសេចក្តីថា ភិក្ខុនីត្រូវអន្តរាយយ៉ាងណា មួយបៀតបៀន លបចូលទៅហើយឃើញ

មិនជាអាបត្តិ ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មាន វេទនា ៣ ដូច្នេះឯង ។

រាជាគារសិក្ខាបទវណ្ណនា ចប់ ។

## ២. អាសន្ទិបរិភុញ្ជនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

[២៩៩] បណ្ឌិតគប្បីជ្រាបថា ជាអាបត្តិច្រើន ដោយករាប់ប្រយោគក្នុងកាលអង្គុយលើនិងដេកលើ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មាន វេទនា ៣ ដូច្នេះឯង ។

អាសន្ទិបរិភុញ្ជនសិក្ខាបទវណ្ណនា ចប់ ។

# ៣. សុត្តកន្តនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[៣០២] បទថា ឧជ្ជវុជ្ជវេ : គ្រប់វារៈដែលបង្វិលមួយជុំ ៗ មានសេចក្តីថា កាលភិក្ខុនីមូរអំបោះប៉ុនដែលលាចេញទៅដោយដៃចូលមក ជាអាបត្តិតែមួយ ៗ តែជាទុក្កដគ្រប់ ៗ ប្រយោគ ដោយវារៈដៃចាប់កាន់ ចាប់តាំងពីជ្រើសរើសកប្បាសមុន ទីងខារ ។

[៣០៣] បទថា កន្តិតសុត្តំ : ការអំបោះ សេចក្តីថា ខារអំបោះជើងជាយឱ្យគួបគ្នាជាដើម ឬខារអំបោះដែលគេខារទុកមិនល្អជាថ្មី ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សុត្តកន្តនសិក្ខាបទវណ្ណនា ចប់ ។

# ៤. គិហិវេយ្យាវច្ចសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

[៣០៥] ក្នុងបទថា យាគុំ វា : បបរក្ដី ជាដើម គប្បីជ្រាបថា ជាទុក្កដ ដោយរាប់ប្រយោគក្នុងគ្រប់ ៗ ប្រយោគ ចាប់តាំងការបុកអង្ករជាដើម ។ ក្នុងបបរនិងបាយគប្បីជ្រាបថា ជាបាចិត្តិយច្រើន ដោយករាប់ភាជន៍ ។ ក្នុងរបស់គួរទំពាជាដើម ជាបាចិត្តិយច្រើន ដោយករាប់ប្រភេទរបស់ ។

[៣០៦] បទថា យាគុបានេ : ទឹកបបរ មានសេចក្ដីថា កាលពួកអ្នកស្រុកកំពុងផ្សំបាយយាគូ ធ្វើទឹកបាន: ឬសង្ឃភត្ត ដើម្បីប្រយោជន៍ដល់សង្ឃ, ភិក្ខុនីចំអិនភោជនយ៉ាងណាមួយ ដោយចូលរួមនឹងអ្នកស្រុកទាំងនោះ មិនជាអាបត្តិ ។ ភិក្ខុនីជាសម្មាញ់បូជាព្រះចេតិយបូជារបស់គ្រឿងអូបជាដើម គួរ ។

ពីរបទថា អត្តនោ វេយ្យាវច្ចករស្ស : ដើម្បីវេយ្យាវច្ចកររបស់ខ្លួន មានសេចក្ដីថា បើសូម្បីថា មាតានិងបិតាមករកភិក្ខុនីនឹងពឹងលោកឱ្យធ្វើរបស់យ៉ាងណាមួយ ឱ្យជាផ្ចិត ឬជងអំបោសក៏បាន តាំងទុកក្នុងឋានៈនៃវេយ្យាវច្ចករជាមុនហើយ ចំអិនភោជនយ៉ាងណាមួយឱ្យ គួរ ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។ សមុដ្ឋានជាដើម ប្រាកដដូចសិក្ខាបទទី ៣ ទាំងអស់នោះឯង ។

គិហិវេយ្យាវច្ចសិក្ខាបទវណ្ណនា ចប់ ។

# ៥. អធិករណសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[៣០៨] ពីរបទថា អសតិ អន្តរាយេ : **កាលបើសេចក្ដីអន្តរាយមិនមាន** បានដល់ កាលមិនមានអន្តរាយ ១០ យ៉ាង ។ ភិក្ខុនីដាក់ធុរៈហើយ ខាងក្រោយទើបវិនិច្ឆ័យ ឈ្មោះថា ត្រូវអាបត្តិមុនហើយ ទើបវិនិច្ឆ័យ ។

[៣១០] ពីរបទថា បរិយេសិត្វា ន លភតិ : **ស្វែងរកគ្នាមិនបាន** មានសេចក្ដីថា មិនបានភិក្ខុនីទាំងឡាយអ្នករួមដៃ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន ជាអកិរិយា សញ្ញាវិមោក្ខ លោកវជ្ជៈ សចិត្តកៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

អធិករណសិក្ខាបទវណ្ណនា ចប់ ។

# ៦. ភោជនទានសិក្ខាបទវណ្ណនា

ពាក្យទាំងអស់ក្នុងសិក្ខាបទទី ៦ បណ្ឌិតគប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងអាគារិកសិក្ខាបទនៃនគ្គវគ្គនុ៎ះឯង ។ តែមានសេចក្ដីប្លែកគ្នាយ៉ាងនេះ ៖

អាគារិកសិក្ខាបទនោះ មានសមុដ្ឋាន ៦ សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ព្រោះលោកពោលថា ដោយដៃរបស់ខ្លួនឯង ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ភោជនទានសិក្ខាបទវណ្ណនា ចប់ ។

# ៧. អាវសថចីវរសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[៣១៧] បទថា បុនបរិយាយេ : តាមវេនជាថ្មីទៀត គឺ លើកក្រោយតទៅ ។

បទថា អាបទាសុ : ភិក្ខុនីប្រើប្រាស់ក្នុងពេលមានអន្តរាយ មានសេចក្ដីថា ពួកចោរលួចចីវរដែលមានតម្លៃថ្លៃ ដែលភិក្ខុនីដោះចេញចាកកាយ រក្សាទុកល្អហើយទៅ ក្នុងអន្តរាយបែបនេះ មិនជាអាបត្តិដល់ភិក្ខុនីអ្នកស្លៀកមិនលះបង់ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងមកកាយវាចា ១ កាយវាចាចិត្ត ១ ជាកិរិយានិងជាអកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អាវសថចីវរសិក្ខាបទវណ្ណនា ចប់ ។

# ៨. អាវសថវិហារសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

[៣១៨] បទថា អនិស្សជ្ជិត្វា **: មិនប្រគល់** មានសេចក្ដីថា មិនប្រគល់ឱ្យដើម្បីប្រយោជន៍ដល់ការរក្សា គឺ មិនប្រគល់យ៉ាងនេះថា "គប្បីជួយគ្នាថែរក្សាបន្ទប់ដែលជាទីនៅនេះឱ្យផង" ដូច្នេះ ។

[៣២១] ពីរបទថា បរិយេសិត្វា ន លភតិ **: ចេញទៅស្វែងរកមិនបាន** គឺ មិនបានអ្នកថែរក្សា ។

បទថា គិលាណាយ **: ភិក្ខុនីឈឺ** គឺ មិនអាចនឹងនិយាយបាន ។

បទថា អាបទាសុ **: ភិក្ខុនីមានសេចក្ដីអន្តរាយហើយក៏ចេញទៅ** មានសេចក្ដីថា កាលព្រំដែនបែកធ្លាយ ពួកភិក្ខុនីទាំងឡាយ បោលអាវាសហើយគេចជៀសទៅ ក្នុងអន្តរាយបែបនេះ មិនជាអាបត្តិ ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។ សមុដ្ឋានជាដើម ក៏ដូចគ្នានឹងសិក្ខាបទបន្ទាប់ទៅនុ៎ះឯង ។

អាវសថវិហារសិក្ខាបទវណ្ណនា ចប់ ។

# ៩. តិរច្ឆានវិជ្ជាបរិយាបុណនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

[៣២៣] ពីរបទថា ពាហិរកំ អនត្ថសញ្ហិតំ : ចំណេះខាងក្រៅដែលមិនប្រកបដោយប្រយោជន៍ បានដល់ (សិល្បៈ វិទ្យាការ) ទម្លាយអ្នកដទៃ មានប្រភេទដូចសិល្បៈជាប់ដោយដំរី សេះ រថ ធ្នូ និងដាវ ជាមួយទឹងមន្តអាថ៌ពន៍ មន្តកប់តុក្កតា មន្តធ្វើឱ្យមានអំណាច មន្តធ្វើឱ្យស្គមស្គាំង និងវិជ្ជាផ្សំថ្នាំពិសជាដើម ។

[៣២៤] បទថា បរិត្តំ : ការពារខ្លួន បានដល់ (វិជ្ជាការពារខ្លួន) មានប្រភេទដូចវិជ្ជាការពារពួកយក្ខ និងការពារពួកនាគ (ពស់) ជាដើម សូម្បីគ្រប់យ៉ាង រមែងសមគួរ ។ បទដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបទសោធម្មសិក្ខាបទ កើតឡើងមកវាចា ១ វាចាចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

តិរច្ឆានវិជ្ជាបរិយាបុណនសិក្ខាបទវណ្ណនា ចប់ ។

# ១០. តិរច្ឆានវិជ្ជាវាចនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[៣២៥] មានបទថា វាចេយ្យ : បង្រៀន (នេះ) ដែលប្លែកគ្នា ។ បទដែលនៅសល់ព្រមទាំងសមុដ្ឋានជាដើម គប្បីជ្រាបដោយន័យដូចពោលហើយក្នុងសិក្ខាបទទី ៩ នោះឯង ។

តិរច្ឆានវិជ្ជាវាចនសិក្ខាបទវណ្ណនា ចប់ ។

ចំនួនសិក្ខាបទ ក្នុងចិត្តាគារវគ្គ គឺ

១. រាជាគារសិក្ខាបទ ការទៅមើលដំណាក់សម្រាប់ស្តេចក្រសាល

២. អាសន្ទិបរិភុញ្ជនសិក្ខាបទ ការប្រើប្រាស់អាសន្ទិ ឬ បល្ល័ង្ក

៣. សុត្តកន្តនសិក្ខាបទ ការមូរអំបោះ

៤. គិហិវេយ្យាវច្ចសិក្ខាបទ ការបម្រើគ្រហស្ថ

៥. អធិករណសិក្ខាបទ មិនធ្វើការខ្វល់ខ្វាយដើម្បីរម្ងាប់អធិករណ៍

៦. ភោជនទានសិក្ខាបទ ការឱ្យខាទនីយៈភោជនៈដល់គ្រហស្ថជាដើម

៧. អាវសថចីវរសិក្ខាបទ ការមិនប្រគល់អាវសថចីវរហើយប្រើប្រាស់

៨. អាវសថវិហារសិក្ខាបទ ការមិនប្រគល់លំនៅហើយចៀសចេញទៅ

៩. តិរច្ឆានវិជ្ជាបរិយាបុណនសិក្ខាបទ ការរៀននូវតិរច្ឆានវិជ្ជា

១០. តិរច្ឆានវិជ្ជាវាចនសិក្ខាបទ ការបង្រៀននូវតិរច្ឆានវិជ្ជា

ចិត្តាគារវគ្គទី ៥ ចប់

# ៦. អារាមវគ្គ

## ១. អារាមបវិសនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃអារាមវគ្គ ដូចតទៅនេះ ៖

[៣៣១] ក្នុងពាក្យថា **បរិក្ខេបំ អតិក្កមន្តិយា : ឈានកន្លងរបង** និង **ឧបចារំ ឱក្កមន្តិយា : ចូលទៅដល់ឧបចារៈ** នេះ គប្បីជ្រាបថា ជាទុក្កដក្នុងជំហានទី១ ជាបាចិត្តិយក្នុងជំហានទី២ ។

[៣៣៣] បទថា **សីសានុលោកិកា : ភិក្ខុនីដែលក្រឡេកឃើញសីស** មានសេចក្ដីថា ភិក្ខុនីតាមចូលទៅចាំមើលសិរ្សៈនៃពួកភិក្ខុនីអ្នកចូលទៅមុន មិនជាអាបត្តិ ។ ពួកភិក្ខុនីអ្នកចូលទៅក្នុងទីណាមុន ធ្វើកិច្ចមានការស្វាធ្យាយ និងថ្វាយបង្គំព្រះចេតិយជាដើម នឹងចូលទៅដោយតាំងចិត្តថា "យើងនឹងទៅកាន់លំនៅនៃភិក្ខុនីទាំងនោះ ក្នុងទីនោះ" គួរ ។

បទថា **អាបទាសុ : ភិក្ខុនីមានសេចក្ដីអន្តរាយ** មានសេចក្ដីថា ភិក្ខុនីត្រូវអន្តរាយយ៉ាងណាមួយបៀតបៀន ក្នុងអន្តរាយបែបនេះ នឹងចូលទៅ ក៏គួរ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន ជាកិរិយានិងជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អារាមបវិសនសិក្ខាបទវណ្ណនា ចប់ ។

# ២. ភិក្ខុអក្កោសនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

[៣៣៤] ពីរបទថា អាយស្មា កបិលកោ : ព្រះកប្បិតកដ៏មានអាយុ គឺ លោកអ្នកមានអាយុនេះ ជាព្រះថេរៈនៅខាងក្នុងចំនួនភិក្ខុជដិលមួយពាន់រូប ។

បទថា សំហរិ : នាំទៅ គឺ ឱ្យសុះសាយហើយ (បាននាំទៅប្រាប់) ។

បទថា សំហដោ : នាំទៅប្រាប់ គឺ ដោយព្រះឧបាលីឱ្យសុះសាយហើយ ។

បទថា គសាវដោ : លោកខ្ទាន់ព្រះកេស គឺ ជាងកោរកាត់ ។ ពួកភិក្ខុនីពោលសំដៅយកអ្នកដែលស្លៀកសំពត់ជ្រលក់ទឹកអម្ចត់ ធ្វើការងារ, ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ភិក្ខុអក្កោសនសិក្ខាបទវណ្ណនា ចប់ ។

# ៣. គណបរិភោសនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[៣៤០] បទថា អនុសាសនីបុរេក្ខាយ : ធ្វើពាក្យប្រៀនប្រដៅឱ្យជាប្រធាន មានសេចក្ដីថា ភិក្ខុនីតាំងនៅក្នុងចំណែកនៃការទូន្មានពោលដោយន័យជាដើមថា "សូម្បីឥឡូវនេះ នាងក៏ជាអ្នកល្ងង់មិនឆ្លាត" មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។ សមុដ្ឋានជាដើម ក៏ដូចនឹងសិក្ខាបទបន្ទាប់ទៅនោះឯង ។

គណបរិភោសនសិក្ខាបទវណ្ណនា ចប់ ។

# ៤. បវារិតសិក្ខាបទវណ្ណនា

[៣៤២-៥] ពាក្យទាំងអស់ក្នុងសិក្ខាបទទី៤ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៤ កើតឡើងមកកាយ ១ កាយនិងវាចា ១ កាយចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយានិងជាអកិរិយា, ជាអកិរិយាព្រោះជាអាបត្តិដល់ភិក្ខុនីអ្នកទទួលនិមន្តហើយ មិនប្រាប់មុនឆាន់ក៏មាន, ជាកិរិយាព្រោះជាអាបត្តិ ដល់ភិក្ខុនីអ្នកហាមភត្តហើយ ឱ្យធ្វើភោជនឱ្យជាកប្បិយខ្លះ មិនឱ្យធ្វើខ្លះ ឆាន់ក៏មាន, ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បវារិតសិក្ខាបទវណ្ណនា ចប់ ។

# ៥. កុលមច្ឆរិនីសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[៣៤៦] សេចក្តីហួងហែងត្រកូល ឈ្មោះថា សេចក្តីកំណាញ់ត្រកូល ។ សេចក្តីកំណាញ់ត្រកូលមានដល់ភិក្ខុនីនោះ ហេតុនោះ ភិក្ខុនីនោះ ទើបឈ្មោះថា អ្នកមានសេចក្តីកំណាញ់ត្រកូល ។ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកកំណាញ់ត្រកូល ព្រោះអត្ថថា ប្រព្រឹត្តខ្វះជាអ្នកហួងហែងត្រកូល ។

[៣៤៧] ពីរបទថា កុលស្ស អវណ្ណំ : ពោលទោសត្រកូល បានដល់ ពោលទោសថា "ត្រកូលនោះ មិនមានសទ្ធា មិនជ្រះថ្លា" ។

ពីរបទថា ភិក្ខុនីនំ អវណ្ណំ : ពោលទោសភិក្ខុនីទាំងឡាយ បានដល់ ពោលទោសរបស់ពួកភិក្ខុនីថា "ពួកភិក្ខុនី ជាអ្នកទ្រុស្តសីល មានធម៌លាមក" ។

[៣៤៨] ពីរបទថា សន្តំយេវ អាទីនវំ : ទោសដែលមានពិត បានដល់ ប្រាប់ទោសមិនមែនគុណដែលមានរបស់ត្រកូល ឬរបស់ពួកភិក្ខុនី ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

កុលមច្ឆរិនីសិក្ខាបទវណ្ណនា ចប់ ។

# ៦. អភិក្ខុកាវាសសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

[៣៥០] បទថា ឱវាទាយ : ឱ្យឱវាទ គឺ ដើម្បីប្រយោជន៍ដល់គរុធម៌ ។

បទថា សំវាសាយ : នៅរួម គឺ ដើម្បីប្រយោជន៍ដល់ការសួរឧបោសថ និងបវារណា ។ នេះសេចក្តីសង្ខេបក្នុងសិក្ខាបទនេះ ។ ចំណែកសេចក្តីពិស្តារ ខ្ញុំបានពោលហើយក្នុងវណ្ណនានៃភិក្ខុនោវាទកសិក្ខាបទនុ៎ះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អភិក្ខុកាវាសសិក្ខាបទវណ្ណនា ចប់ ។

# ៧. អបវារណាសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[៣៥៤] ពីរបទថា បរិយេសិត្វា ន លភតិ : ស្វែងរកហើយ (ឧភតោសង្ឃ )មិនបាន គឺ (ស្វែងរកហើយ ) មិនបានភិក្ខុនី ។

ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។ សេចក្តីពិស្តារនៃសិក្ខាបទនេះ ក៏បានពោលទុកក្នុងភិក្ខុនោវាទកសិក្ខាបទនោះហើយដែរ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

អបវារណាសិក្ខាបទវណ្ណនា ចប់ ។

# ៨. ឱវាទសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

[៣៥៦] ដោយពាក្យថា ឯកកម្មំ : កម្មជាមួយគ្នា ជាដើម ព្រះមានព្រះភាគត្រាស់សំដៅដល់ឧបោសថនិងបវារណាប៉ុណ្ណោះ ។

ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។ សេចក្តីពិស្តារនៃសិក្ខាបទសូម្បីនេះ ក៏បានពោលទុកហើយ ក្នុងភិក្ខុនោវាទកសិក្ខាបទដែរ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិកសិក្ខាបទ ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ឱវាទសិក្ខាបទវណ្ណនា ចប់ ។

# ៩. ឱវាទូបសង្កមនសិក្ខាបទវណ្ណនា

[៣៥៨-៣៦០] ពាក្យទាំងអស់ក្នុងសិក្ខាបទទី ៩ ងាយយល់ទាំងអស់ ។ សេចក្តីពិស្តារនៃសិក្ខាបទសូម្បីនេះ ក៏បានពោលទុកហើយក្នុងភិក្ខុនោវាទកសិក្ខាបទដែរ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ឱវាទូបសង្កមនសិក្ខាបទវណ្ណនា ចប់ ។

# ១០. បសាខេជាតសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[៣៦០] បទថា បសាខេ : **កាយខាងក្រោម** បានដល់ ក្នុងកាយកំណាត់ក្រោម ។ ពិតមែន កាយកំណាត់ក្រោមលោកហៅថា បសាខៈ ព្រោះហេតុថា ភ្លៅទាំង ២ បែកចេញទៅចាកពីកាយកំណាត់ក្រោមនោះ ដូចមែកនៃឈើបែកចេញពីដើមឈើ ដូច្នោះ ។

[៣៦២] ក្នុងបទថា ភិន្ទ : **ទម្លាយ** ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

បើភិក្ខុនីបង្គាប់គ្រប់យ៉ាងថា ចូរចាក់ ចូរពុះ និងឧបាសកនោះធ្វើតាមបង្គាប់យ៉ាងនោះ ភិក្ខុនីត្រូវអាណត្តិទុក្កដ (ទុក្កដព្រោះបង្គាប់) ៦ និងបាចិត្តិយ ៦ ។ បើសួម្បីថា ភិក្ខុនីបង្គាប់យ៉ាងនេះថា ឧបាសកកិច្ចយ៉ាងណាមួយ ដែលគួរធ្វើក្នុងកាយកំណាត់ក្រោមនេះ លោកចូរធ្វើកិច្ចនោះទាំងអស់ និងឧបាសកនោះ ធ្វើកិច្ចមានការចាក់ជាដើម សូម្បីទាំងអស់ ។ ជាអាបត្តិ ១២ គឺ ជាទុក្កដ ៦ បាចិត្តិយ ៦ ព្រោះពាក្យនិយាយតែមួយម៉ាត់ ។ តែបើភិក្ខុនីនិយាយត្រឹមតែម្យ៉ាង ក្នុងបណ្តាកិច្ចមានការចាក់ជាដើមហើយ បង្គាប់ថា ចូរធ្វើកិច្ចនេះ និងឧបាសកនោះធ្វើកិច្ចទាំងអស់ ជាបាចិត្តិយ ព្រោះតែការធ្វើកិច្ចដែលបង្គាប់ប៉ុណ្ណោះ ក្នុងកិច្ចដែលនៅសល់មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ ជាកិរិយានិងជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បសាខេជាតសិក្ខាបទវណ្ណនា ចប់ ។

ចំនួនសិក្ខាបទ ក្នុងអារាមវគ្គ គឺ

១. អារាមបវិសនសិក្ខាបទ   ការមិនប្រាប់ ហើយចូលកាន់អារាម
២. ភិក្ខុអក្កោសនសិក្ខាបទ   ការជេរគំរាមភិក្ខុ
៣. គណបរិភាសនសិក្ខាបទ   ការផ្តាសាគណៈភិក្ខុនីដោយសេចក្តីកំណាច
៤. បវារិតសិក្ខាបទ   ការហាមភត្តហើយឆាន់ខាទនីយភោជនីយៈ
៥. កុលមច្ឆរិនីសិក្ខាបទ   ការកំណាញ់ត្រកូល
៦. អភិក្ខុកាវាសសិក្ខាបទ   ការនៅចាំវស្សាក្នុងអាវាសដែលឥតមានភិក្ខុ
៧. អបវារណាសិក្ខាបទ   មិនបវារណានឹងឧភតោសង្ឃដោយស្ថាន៣
៨. ឱវាទសិក្ខាបទ   ការមិនទៅទទួលឱវាទ និងមិនទៅរួបរួមគ្នា
៩. ឱវាទូបសង្កមនសិក្ខាបទ   ការសួរឧបោសថ និងចូលទៅទទួលឱវាទ
១០. បសាខេជាតសិក្ខាបទ   ការទម្លាយជាដើមនូវពកឬបូសដែលកើតត្រង់ កាយខាងក្រោម

អដ្ឋកថា អារាមវគ្គទី ៦ ចប់

# ៧. គព្ភិនីវគ្គ

## ១. គព្ភិនីសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃគព្ភិនីវគ្គ ដូចតទៅនេះ ៖

[៣៦៥] បទថា អាបន្នសត្តា : ស្រីដែលមានសត្វមកដល់ផ្ទៃហើយ បានដល់ ស្ត្រីអ្នកមានបុត្រចូលមកកើតក្នុងផ្ទៃ ។

គព្ភិនីសិក្ខាបទវណ្ណនា ចប់ ។

## ២. បាយន្តីសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

[៣៦៨] បទថា បាយន្តី : ស្រីមេដោះ បានដល់ ស្ត្រីអ្នកញ៉ាំងទារកឱ្យបៅដោះ ។

[៣៦៩] ពីរបទថា មាតា វា ហោតិ : ជាមាតាក្ដី មានសេចក្ដីថា ជាមាតាក្ដី ជានាងមេដោះក្ដី នៃទារកដែលនៅបៅដោះ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទទាំង ២ នេះ មានសមុដ្ឋាន ៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បាយន្តីសិក្ខាបទវណ្ណនា ចប់ ។

## ៣. បឋមសិក្ខមានសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[៣៧២] ពីរបទថា សិក្ខាសម្មតឹ ទាតុំ : ឱ្យភិក្ខុនីសង្ឃឱ្យសិក្ខាសម្មតិ មានសេចក្ដីថា សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគប្រទានឱ្យសង្ឃឱ្យសិក្ខាសម្មតិ ។

ឆ្លើយថា ទ្រង់ធ្វើក្នុងព្រះហឫទ័យថា ធម្មតាមាតុគ្រាម ជាអ្នកឡេះឡោះ មិនទាន់បានសិក្សាក្នុងធម៌ ៦ ប្រការ ដល់ ២ ឆ្នាំ នឹងបំពេញសីលឱ្យបរិបូណ៌បានលំបាក តែកាលបានសិក្សាហើយ នឹងមិនលំបាកក្នុងកាលជាខាងក្រោយ គឺ នឹងជួយខ្ទបាន (នឹងញ៉ាំងសិក្ខាបទ៦ប្រការឱ្យសម្រេចបាន) ទើបបានទ្រង់ប្រទានឱ្យសង្ឃ ឱ្យសិក្ខាសម្មតិ ។

ពាក្យថា បាណាតិបាតា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម-

សមាទានំ សមាទិយាមិ : ខ្ញុំសូមសមាទាននូវបាណាតិបាតាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ មានសេចក្ដីថា សិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិទុកថា ចេតនាជាគ្រឿងវៀរចាកការធ្វើសត្វមានជីវិតឱ្យធ្លាក់កន្លងទៅ នោះណា ខ្ញុំសូមសមាទានសិក្ខាបទ គឺ ចេតនាជាគ្រឿងវៀរចាកការធ្វើសត្វមានជីវិតឱ្យធ្លាក់កន្លងទៅនោះ ឱ្យជាការសមាទានមាំ មិនប្រព្រឹត្តកន្លងហួតអស់ ២ ឆ្នាំ ។ ក្នុងសិក្ខាបទទាំងពួង ក៏ន័យនេះ ។ សិក្ខាបទទាំង ៦ នេះ ភិក្ខុនីសង្ឃគប្បីឱ្យដូចគ្នាដល់ស្ត្រី ( សាមណេរី ) អ្នកបួសមកហើយដល់ ៦០ វស្សា ។ នាងសិក្ខមានាអ្នកមិនទាន់បានសិក្សាក្នុងសិក្ខាបទ ៦ នេះ មិនគប្បីឱ្យឧបសម្បទា ។

បឋមសិក្ខមានសិក្ខាបទវណ្ណនា ចប់ ។

# ៤. ទុតិយសិក្ខមានសិក្ខាបទវណ្ណនា

[៣៧៦] ពាក្យទាំងអស់ក្នុងសិក្ខាបទទី ៤ ងាយយល់ទាំងអស់ ។ តែបើថា សិក្ខាសម្មតិ ជាការដែលភិក្ខុនីសង្ឃមិនទាន់បានឱ្យមកមុន គប្បីឱ្យសូម្បីក្នុងពេលឧបសម្បទាទុះឯង ។ សិក្ខមានាទាំង ២ នេះ ឈ្មោះថា មហាសិក្ខមានា ។

ទុតិយសិក្ខមានសិក្ខាបទវណ្ណនា ចប់ ។

# ៥. បឋមគិហិគតសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[៣៨៣] កាលភិក្ខុនីញ៉ាំងសិក្ខមានាដែលមានអាយុតិចជាង ១២ ឆ្នាំឱ្យបួស ដោយសេចក្តីសម្គាល់ថា មានអាយុគ្រប់ មិនជាអាបត្តិ ក៏ពិតមែន តែថា សិក្ខមានានោះ ក៏មិនមែនជាឧបសម្បន្នឡើយ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

បឋមគិហិគតសិក្ខាបទវណ្ណនា ចប់ ។

# ៦. ទុតិយគិហិគតសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ ៖

[៣៨៧] ភិក្ខុនីសង្ឃ នឹងឱ្យសិក្ខាសម្មតិដល់ស្រីគ្រហស្ថ អ្នកមានអាយុ ១០ ឆ្នាំ ហើយឱ្យលោកអ្នកមានអាយុគ្រប់ ១២ ឆ្នាំបរិបូណ៌ ឧបសម្បទា គួរ ។

ទុតិយគិហិគតសិក្ខាបទវណ្ណនា ចប់ ។

# ៧. តតិយគិហិគតសិក្ខាបទវណ្ណនា

[៣៨៨] ពាក្យទាំងអស់ ក្នុងសិក្ខាបទទី ៧ ឆាយយល់ទាំងអស់ ៗ សូម្បីសមុដ្ឋានជាដើម ក្នុងគ្រប់សិក្ខាបទ មានសិក្ខាបទទី ៣ ជាដើម ក៏ប្រាកដដូចដែលពោលហើយក្នុងសិក្ខាបទទី ២ នុ៎ះឯង ៗ តែមានប្លែកគ្នាយ៉ាងនេះ គឺ ក្នុងសិក្ខាបទណា មាននូវសម្មុតិ ក្នុងសិក្ខាបទនោះ ជាកិរិយាផង ជាអកិរិយាផង ៗ

តតិយគិហិគតសិក្ខាបទវណ្ណនា ចប់ ៗ

# ៨. បឋមសហជីវិនិសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ ៖

[៣៩២] បទថា ន អនុគ្គណ្ហាបេយ្យ : មិនឱ្យគេប្រៀនប្រដៅ មានសេចក្ដីថា មិនញុំាំងអ្នកដទៃឱ្យអនុគ្រោះដោយឧទ្ទេសជាដើមយ៉ាងនេះថា “នាងម្ចាស់ នាងចូរឱ្យឧទ្ទេសជាដើមដល់ភិក្ខុនីនេះ” ៗ

[៣៩៤] បទថា បរិយេសិត្វា : ហើយស្វែងរក បានដល់ស្វែងរកភិក្ខុនីដទៃហើយមិនបាន ៗ ជាអ្នកអាពាធដោយខ្លួនឯង មិនអាចនឹងឱ្យឧទ្ទេសជាដើមបាន មិនជាអាបត្តិដល់ភិក្ខុនីនោះ ៗ ពាក្យដែលនៅ

សល់ ឆាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

បឋមសហជីវិនិសិក្ខាបទវណ្ណនា ចប់ ។

# ៩. នានុពន្ធនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

[៣៩៦] បទថា ន ឧបដ្ឋហេយ្យ : មិនបម្រើ មានសេចក្តីថា មិនបម្រើដោយកិច្ចដែលគួរធ្វើនោះ ៗ យ៉ាងនេះ គឺ ដោយលំអិត ដោយដីស្អិត ដោយឈើស្ទន់ ដោយទឹកលាងមុខ ។ ពាក្យដែលនៅសល់ ឆាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិកសិក្ខាបទ ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលកម្ម ជាទុក្ខវេទនា ដូច្នេះឯង ។

នានុពន្ធនសិក្ខាបទវណ្ណនា ចប់ ។

# ១០. ទុតិយសហជីវិនិសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[៣៩៨] បទថា នេវ វូបកាសេយ្យ : ហើយមិននាំយកទៅបានដល់ មិននាំយកសហជីវិនីទៅ ។

បទថា ន វូបកាសាបេយ្យ : មិនឱ្យគេនាំយកទៅ បានដល់ មិនបង្គាប់ភិក្ខុនីដទៃថា នាងម្ចាស់ សូមនាំភិក្ខុនីនេះទៅ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន ជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ទុតិយសហជីវិនិសិក្ខាបទវណ្ណនា ចប់ ។

## ចំនួនសិក្ខាបទ ក្នុងគព្ភិនីវគ្គ គឺ

១. គព្ភិនីសិក្ខាបទ ការឱ្យឧបសម្បទាដល់ស្រីមានគភ៌

២. បាយន្តីសិក្ខាបទ ការឱ្យឧបសម្បទាដល់ស្រីមេដោះ

៣. បឋមសិក្ខមានសិក្ខាបទ ការឱ្យឧបសម្បទាដល់សិក្ខមានា ដែលមិនបានសិក្សាអស់ ២ វស្សា

៤. ទុតិយសិក្ខមានសិក្ខាបទ ការឱ្យឧបសម្បទាដល់សិក្ខមានា ដែលសង្ឃមិនបានសន្មត

៥. បឋមគិហិគតសិក្ខាបទ ការឱ្យឧបសម្បទាដល់ស្រីគិហិគតា មានវស្សាខ្វះ ១២ ឆ្នាំ

៦. ទុតិយគិហិគតសិក្ខាបទ ការឱ្យឧបសម្បទាដល់ស្រីគិហិគតា ដែលមិនបានសិក្សាអស់ ២ វស្សា

៧. តតិយគិហិគតសិក្ខាបទ ការឱ្យឧបសម្បទាដល់ស្រីគិហិគតា ដែលសង្ឃមិនបានសន្មត

៨. បឋមសហជីវិនិសិក្ខាបទ ការឱ្យឧបសម្បទាដល់សហជីវិនី ហើយមិនបង្រៀនអស់ ២ វស្សា

៩. នានុពន្ធនសិក្ខាបទ ការមិនតាមបម្រើភិក្ខុនីជាបវត្តិនី ( ឧបជ្ឈាយ៍ )

១០. ទុតិយសហជីវិនិសិក្ខាបទ ការឱ្យឧបសម្បទាដល់សហជីវិនី

ហើយមិន នាំយកទៅ

អដ្ឋកថា គត្ថិនីវគ្គទី ៧ ចប់

# ៨. កុមារិភូតវគ្គ

## ១.២.៣. បឋមកុមារិភូតាទិសិក្ខាបទវណ្ណនា

[៤០១-៤១២] សិក្ខាបទទី ១ ទី ២ និងទី ៣ នៃកុមារិភូតវគ្គ ដូចគិហិគតសិក្ខាបទទាំង ៣ នុ៎ះឯង ។

ក៏មហាសិក្ខមានាទាំង ២ មុន បណ្ឌិតគប្បីជ្រាបថា មានអាយុលើស២០ឆ្នាំហើយ មហាសិក្ខមានាទាំងនោះនឹងជាស្ត្រីគ្រហស្ថ (ធ្លាប់មានស្វាមីហើយ) ឬមិនមែនស្ត្រីគ្រហស្ថក៏ដោយ សង្ឃគួរហៅថា សិក្ខមានាដូចគ្នាក្នុងសម្មតិកម្មជាដើម មិនគួរហៅថា គិហិគតា ឬ កុមារិភូតា ។ ភិក្ខុនីសង្ឃគប្បីឱ្យសិក្ខាសម្មតិ ដល់ស្ត្រីគ្រហស្ថក្នុងវេលាមានអាយុ ១០ឆ្នាំ ហើយធ្វើការឧបសម្បទាក្នុងវេលាមានអាយុ ១២ឆ្នាំ ។ ឱ្យក្នុងវេលាមានអាយុ ១១ឆ្នាំ ហើយធ្វើការឧបសម្បទា ក្នុងវេលាមានអាយុ ១៣ឆ្នាំ ។ ឱ្យសម្មតិក្នុងវេលាមានអាយុ ១២ឆ្នាំ ១៣ឆ្នាំ ១៤ឆ្នាំ ១៥ឆ្នាំ ១៦ឆ្នាំ ១៧ឆ្នាំ និង១៨ឆ្នាំ ហើយគប្បីធ្វើការឧបសម្បទាក្នុងវេលាមានអាយុ ១៤-១៥-១៦-១៧-១៨-១៩-២០ឆ្នាំ ។ ក៏ឯតាំងពីវេលាមានអាយុ ១៨ ឆ្នាំឡើងទៅស្ត្រីគ្រហស្ថនេះ នឹងហៅថា គិហិគតាខ្លះ ថា កុមារិភូតាខ្លះ ក៏បាន ។ តែស្ត្រីដែលជាកុមារិភូតា មិនគួរហៅថា គិហិគតា គួរហៅថា កុមារិភូតាប៉ុណ្ណោះ ។ ចំណែកមហា

សិក្ខមានា នឹងហៅថា គិហិគតាខ្លះ ក៏មិនគួរ ។ នឹងហៅថា កុមារិភូតាខ្លះ ក៏មិនគួរ ។ សូម្បីនាងទាំង ៣ គួរហៅថា សិក្ខមានា ដោយអំណាចការឱ្យសិក្ខាសម្មតិ ។

បឋមកុមារិភូតាទិសិក្ខាបទវណ្ណនា ចប់ ។

# ៤.៥.៦. ឩនទ្វាទសវស្សបរិបុណ្ណទ្វាទសវស្សវុដ្ឋាបនសិក្ខាបទវណ្ណនា

[៤១៣-៤២២] ពាក្យទាំងអស់ក្នុងសិក្ខាបទទី៤ ទី៥ និងទី៦ ងាយយល់ទាំងអស់ ។ គ្រប់សិក្ខាបទមានសមុដ្ឋាន ៣ ។ សិក្ខាបទទី៤ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។ សិក្ខាបទទី៥ ជាកិរិយានិងជាអកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

ចំណែកថា ពាក្យដែលព្រះមានព្រះភាគត្រាស់ទុកក្នុងសិក្ខាបទទី៥ នេះថា សចេ្ឆន បរិច្ឆិន្ទិតព្វា : សង្ឃគប្បីកំណត់ឱ្យដឹង មានសេចក្តីថា ដែលសង្ឃគប្បីពិចារណាមើល ។ សិក្ខាបទទី៦ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា

ដូច្នេះឯង ។

តែពាក្យដែលត្រាស់ទុកក្នុងសិក្ខាបទទី៦ នេះថា បរិច្ឆិន្ទិត្វា : សង្កេត មានសេចក្តីថា បានពិចារណាមើលហើយ ។

ឧទទ្វាទសវស្សបរិបុណ្ណទ្វាទសវស្សឱយនធម្មសិក្ខាបទវណ្ណនា ចប់ ។

## ៧. បឋមសិក្ខមាននវុដ្ឋាបនសិក្ខាបទវណ្ណនា

[៤២៣] ពាក្យទាំងឡាយក្នុងសិក្ខាបទទី ៧ ងាយយល់ទាំងអស់ ។ សិក្ខាបទនេះ មានការដាក់ធុរៈជាសមុដ្ឋាន ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្មវចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

បឋមសិក្ខមាននវុដ្ឋាបនសិក្ខាបទវណ្ណនា ចប់ ។

## ៨. ទុតិយសិក្ខមាននវុដ្ឋាបនសិក្ខាបទវណ្ណនា

[៤២៦] ពាក្យទាំងអស់ក្នុងសិក្ខាបទទី ៨ ក៏ងាយយល់ទាំងអស់ ។ សមុដ្ឋានជាដើម ក៏ដូចគ្នានឹងសិក្ខាបទបន្ទាប់ទៅនុ៎ះឯង ។

ទុតិយសិក្ខមាននវុដ្ឋាបនសិក្ខាបទវណ្ណនា ចប់ ។

# ៩. សោកាវាសសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ ៖

[៤២៩] បទថា សោកាវស្សំ[១] : ជាស្រីបណ្តាលសេចក្តីសោក មានសេចក្តីថា នាងសិក្ខមានាណា ធ្វើការណាត់ហើយ (មិនទៅតាមណាត់) ញ៉ាំងសេចក្តីសោកឱ្យចូលទៅខាងក្នុងចិត្តរបស់ពួកបុរស ព្រោះដូច្នោះ សិក្ខមានានោះ ទើបឈ្មោះថា ជាស្រីបណ្តាលសេចក្តីសោក ។ បំបួសសិក្ខមានាដែលញ៉ាំងប្រុសឱ្យលោកនោះ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ទុកថា "ដែលឈ្មោះថា ជាស្រីបណ្តាលសេចក្តីសោក គឺ សិក្ខមានាញ៉ាំងសេចក្តីទុក្ខឱ្យកើតឡើង គឺ ញ៉ាំងសេចក្តីសោក ឱ្យចូលទៅគ្របសង្កត់ដល់ពួកជនដទៃ" ។

ម្យ៉ាងទៀត នាងសិក្ខមានាសូម្បីនេះ កាលមិនបានសមាគមនឹងបុរស រមែងចូលកាន់សេចក្តីសោកស្តាយដោយខ្លួនឯង ដូចស្រីម្ចាស់ផ្ទះចូលកាន់ផ្ទះ ដូច្នោះ ។ នាងសិក្ខមានាចូលកាន់សេចក្តីសោកណា ដោយអាការយ៉ាងនេះ សេចក្តីសោកនោះ ជាទីនៅនៃសិក្ខមានានោះ ហេតុនោះ សិក្ខមានានោះ ទើបឈ្មោះថា មានសេចក្តីសោកជាទីនៅ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា "រមែងបណ្តាលសេចក្តីសោក" ។

---

១. ភូមា. ថៃ. សោកវសំ ។

[៤៣១] បទថា អជានន្តី : កាលមិនដឹង បានដល់ មិនដឹងថា អ្នកនេះ ជាដូច្នេះ ៗ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ៗ

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ៗ

សោភាវាសសិក្ខាបទវណ្ណនា ចប់ ៗ

## ១០. អននុញ្ញាតសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ ៖

[៤៣៣] បទថា អនាបុច្ឆា : មិនបានយល់ព្រម គឺ មិនពោលលា ៗ ពួកភិក្ខុនីគួរពោលលា ២ដង គឺ ក្នុងពេលបព្វជ្ជា ១ដង ក្នុងពេលឧបសម្បទា ១ដង ៗ តែពួកភិក្ខុសូម្បីកាលពោលលាម្តង ក៏គួរ ៗ

[៤៣៤] បទថា អជានន្តី : មិនដឹង បានដល់ មិនដឹងថា មាតាជាដើម នៅមាន ៗ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ៗ

សិក្ខាបទនេះ មានសមុដ្ឋានដែលសំខាន់មិនធ្លាប់មានមកពីមុន ៤ សមុដ្ឋាន កើតឡើងមកវាចា១ កាយនិងវាចា១ វាចាចិត្ត១ កាយវាចាចិត្ត១ ៗ គឺយ៉ាងណា ? គឺ ភិក្ខុនីអង្គុយក្នុងខណ្ឌសីមា ដោយកិច្ចដែលគួរធ្វើយ៉ាងណាមួយទុំះឯង ក្នុងកម្មមានអព្ភានកម្មជាដើម ពោលថា ពួកលោកចូរហៅសិក្ខមានា ពួកយើងនឹងឱ្យលោកឧបសម្បទា ក្នុងខណ្ឌសីមា

នេះឯង ហើយឱ្យឧបសម្បទាឱ្យ យ៉ាងនេះឈ្មោះថា កើតឡើងមកវាចា១ ។ កាលភិក្ខុនីពោលតាំងពីលំនៅដែលនៅថា យើងនឹងឱ្យឧបសម្បទាហើយដើរទៅកាន់ខណ្ឌសីមា ឈ្មោះថា កើតឡើងមកកាយនិងវាចា១ ។ កាលភិក្ខុនីមិនដឹងឡើយថា ជាសិក្ខាបទដែលទ្រង់បញ្ញត្តិហាមទុក ធ្វើការប្រព្រឹត្តកន្លង ក្នុងឋានៈទាំង ២ ឈ្មោះថា កើតឡើងមកវាចាចិត្ត១ កាយវាចាចិត្ត១ ។ ជាកិរិយា និងជាអកិរិយាព្រោះមិនឱ្យសូមអនុញ្ញាតមុនហើយ ឱ្យឧបសម្បទា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

អននុញ្ញាតសិក្ខាបទវណ្ណនា ចប់ ។

## ១១. បារិវាសិកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យសិក្ខាបទទី ១១ ដូចតទៅនេះ ៖

[៤៣៥] បទថា **បារិវាសិកច្ឆន្ទទានេន**[1] **:** ដោយឱ្យឆន្ទៈឈ្មោះ **បារិវាសិក** គឺ ដោយឱ្យឆន្ទៈផ្ទាកទុក ។ ក្នុងពាក្យថា **បារិវាសិយំ** ការឱ្យឆន្ទៈផ្ទាកទុកនោះ ការផ្ទាកទុកមាន ៤ យ៉ាងគឺ **បរិសបារិវាសិយំ :** ផ្ទាកទុកដោយទីប្រជុំ ១, **រត្តិបារិវាសិយំ :** ផ្ទាកទុកដោយរាត្រី ១, **ឆន្ទ**

១. ភូមា. បរិវាសិកឆន្ទទានេន ។ ថៃ. បរិវាសិយឆន្ទទានេន ។

**បារិវាសិយំ** : ផ្អាកទុកដោយឆន្ទៈ ១, **អជ្ឈាសយបារិវាសិយំ** : ផ្អាកទុកដោយអធ្យាស្រ័យ ១ ។

ដែលឈ្មោះថា ផ្អាកទុកដោយទីប្រជុំ គឺ ពួកភិក្ខុកំពុងប្រជុំគ្នាដោយករណីយកិច្ចយ៉ាងណាមួយ ។ គ្រានោះ មេឃភ្លៀងតាំងឡើងក្តី មានអាជ្ញាស្តេចមកបណ្តេញក្តី ពួកមនុស្សនាំគ្នាមកចោមរោមមើលក្តី ភិក្ខុទាំងឡាយក៏គិតគ្នាថា "ទីនេះគ្មានឱកាស យើងនាំគ្នាទៅទីដទៃចុះ" ហើយមិនទាន់លះបង់ឆន្ទៈ ក៏ក្រោកចេញទៅ ។ យ៉ាងនេះហៅថា ផ្អាកទុកដោយទីប្រជុំ ។ ក៏ការផ្អាកទុកដោយទីប្រជុំ គួរនឹងធ្វើកម្មបាន ព្រោះភិក្ខុទាំងឡាយ មិនទាន់បានលះបង់ឆន្ទៈ ក៏ពិត តែថា នៅពេលយប់ពួកភិក្ខុប្រជុំគ្នាទៀត ដោយតាំងចិត្តថា "ពួកយើងនឹងធ្វើកម្ម" មានឧបោសថជាដើម ទើបអាពធនាទិមន្តភិក្ខុមួយរូប ដោយតាំងចិត្តថា "នឹងស្តាប់ធម៌ដរាបដល់វេលាដែលភិក្ខុមកប្រជុំគ្នាទាំងអស់" ។ កាលភិក្ខុនោះ កំពុងសម្តែងធម្មកថានុ៎ះឯង អរុណរះឡើង ។ បើពួកភិក្ខុអន្ទយប្រជុំគ្នាដោយតាំងចិត្តថា "នឹងធ្វើចាតុទ្ទសីឧបោសថ ហើយធ្វើដោយព្រមព្រៀងគ្នាថា បណ្ណរសីឧបោសថ ក៏បាន ។ បើអន្ទយប្រជុំគ្នាដើម្បីធ្វើ បណ្ណរសីឧបោសថ ថ្ងៃ ១ រោច មិនមែនថ្ងៃឧបោសថ នឹងធ្វើឧបោសថ មិនគួរ, តែនឹងធ្វើសង្ឃកិច្ចយ៉ាងដទៃ គួរ ។ នេះឈ្មោះថា ផ្អាកទុកដោយរាត្រី ។

ពួកភិក្ខុប្រជុំគ្នាទៀត ដោយតាំងចិត្តថា "នឹងធ្វើសង្ឃកម្ម" មាន

អញ្ញានជាដើមយ៉ាងណាមួយនុ៎ះឯង ។ ក្នុងភិក្ខុទាំងនោះ ភិក្ខុមួយរូបជាអ្នកហោរាសាស្ត្រពោលយ៉ាងនេះថា "ថ្ងៃនេះឫក្សអាក្រក់ (ពេលមិនល្អ) សូមពួកលោកកុំធ្វើកម្មនេះ" ។ ភិក្ខុទាំងនោះ លះបង់ឆន្ទៈ តាមពាក្យរបស់ភិក្ខុនោះហើយ នៅអន្លើយប្រជុំគ្នាយ៉ាងនោះឯង ។ ភ្លាមនោះ ភិក្ខុដទៃមកនិយាយឡើងថា "ប្រយោជន៍រមែងកន្លងហួសអ្នកល្ងង់ដែលរវល់តែកាន់ឫក្សយាម" ហើយពោលថា "ពួកលោកនឹងធ្វើអ្វីដោយនក្ខត្តឫក្ស" នេះឈ្មោះថា ផ្ទាក់ទុកដោយឆន្ទៈ និងផ្ទាក់ទុកដោយអធ្យាស្រ័យ ។ ក្នុងការផ្ទាក់ទុកនោះ នឹងមិននាំឆន្ទៈ និងបារិសុទ្ធិមកឬធ្វើកម្ម រមែងមិនគួរ ។

[៤៣៦] ពីរបទថា វុដ្ឋិតាយ បរិសាយ : បរិស័ទក្រោកចេញទៅហើយ សេចក្តីថា កាលដែលប្រជុំលះបង់ឆន្ទៈ ហើយលើកប្រជុំទៅដោយកាយក្តី ដោយអាការត្រឹមតែលះបង់ឆន្ទៈប៉ុណ្ណោះក្តី ។

[៤៣៧] ពាក្យថា អនាបត្តិ អវុដ្ឋិតាយ បរិសាយ : វារៈដែលមិនត្រូវអាបត្តិ គឺ កាលបរិស័ទមិនទាន់បានក្រោកចេញទៅហើយ មានសេចក្តីថា កាលដែលប្រជុំមិនទាន់លះបង់ឆន្ទៈ មិនទាន់លើកប្រជុំ មិនជាអាបត្តិ ។ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៣ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

បារិវាសិកសិក្ខាបទវណ្ណនា ចប់ ។

## ១២. អនុវស្សសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១២ ដូចតទៅនេះ ៖

[៤៣៨] ពីរបទថា ឧបស្សយោ ន សម្មតិ : កន្លែងសម្រាប់ភិក្ខុនីនៅក៏មិនគ្រប់គ្រាន់ បានដល់ លំនៅជាទីនៅមិនគ្រប់ល្មម ។ ពាក្យដែលនៅសល់ងាយយល់ទាំងអស់ ។ សមុដ្ឋានជាដើម ក៏ដូចគ្នានឹងសិក្ខាបទបន្ទាប់ទៅនោះឯង ។

អនុវស្សសិក្ខាបទវណ្ណនា ចប់ ។

## ១៣. ឯកវស្សសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១៣ ដូចតទៅនេះ ៖

[៤៤១] បីបទថា ឯកំ វស្សំ ទ្វេ : ដល់ស្រីពីរនាក់ក្នុងមួយឆ្នាំ បានដល់ ឱ្យសិក្ខមានាបួសមួយឆ្នាំ ២ រូប វៀរទុក ១ ឆ្នាំ ៗ ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ ។ សូម្បីសមុដ្ឋានជាដើម ក៏ដូចគ្នានឹងដែលពោលហើយនុ៎ះឯង ។

ឯកវស្សសិក្ខាបទវណ្ណនា ចប់ ។

## ចំនួនសិក្ខាបទ ក្នុងកុមារិភូតវគ្គ គឺ

១. បឋមកុមារិភូតសិក្ខាបទ ការឱ្យឧបសម្បទាដល់កុមារីភូតា ទីមួយ
២. ទុតិយកុមារិភូតសិក្ខាបទ ការឱ្យឧបសម្បទាដល់កុមារីភូតា ទីពីរ
៣. តតិយកុមារិភូតសិក្ខាបទ ការឱ្យឧបសម្បទាដល់កុមារីភូតា ទីបី
៤. ឩនទ្វាទសវស្សសិក្ខាបទ មានវស្សាមិនគ្រប់១២ ហើយឱ្យឧបសម្បទា
៥. បរិបុណ្ណទ្វាទសវស្សសិក្ខាបទ មានវស្សាគ្រប់១២ តែមិនទាន់បានសន្មត
៦. ខីយនធម្មសិក្ខាបទ បានទទួលពាក្យហើយ ត្រឡប់តិះដៀលវិញ
៧. បឋមសិក្ខមាននវុដ្ឋាបនសិក្ខាបទ មិនឱ្យសិក្ខមានាឧបសម្បទា ទី១
៨. ទុតិយសិក្ខមាននវុដ្ឋាបនសិក្ខាបទ មិនឱ្យសិក្ខមានាឧបសម្បទា ទី២
៩. សោកាវាសសិក្ខាបទ ការញ៉ាំងសិក្ខមានាជាស្រីបណ្ដាលសេចក្ដីសោក ឱ្យបានឧបសម្បទា
១០. អននុញ្ញាតសិក្ខាបទ ការញ៉ាំងសិក្ខមានាដែលមិនមានការអនុញ្ញាតពីមាតាបិតានិងស្វាមី ឱ្យបានឧបសម្បទា
១១. បារិវាសិកសិក្ខាបទ ការឱ្យសិក្ខមានាឧបសម្បទាដោយឆន្ទៈឈ្មោះបារិវាសិកៈ
១២. អនុវស្សសិក្ខាបទ ការឱ្យឧបសម្បទារាល់ឆ្នាំ
១៣. ឯកវស្សសិក្ខាបទ ការឱ្យឧបសម្បទាដល់ស្រីពីរនាក់ក្នុង១ឆ្នាំ

អដ្ឋកថា កុមារិភូតវគ្គទី ៨ ចប់

# ៩. ឆត្តុបាហនវគ្គ

## ១. ឆត្តុបាហនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី១នៃឆត្តវគ្គ ដូចតទៅនេះ ៖

[៤៤៦] ពាក្យថា សកឹបិ ធារេតិ អាបត្តិ បាចិត្តិយស្ស : ភិក្ខុនីប្រើប្រាស់សូម្បីម្តង ក៏ត្រូវអាបត្តិបាចិត្តិយ មានសេចក្តីថា ក្នុងការធ្វើដំណើរ ភិក្ខុនីបាំងឆត្រនិងពាក់ស្បែកជើង សូម្បីរហូតដល់អស់មួយថ្ងៃដោយប្រយោគតែមួយប៉ុណ្ណោះ ក៏ជាអាបត្តិត្រឹមតែមួយ ។ បើទៅដល់ទីមានភក់ជាដើម ដោះស្បែកជើងហើយ បាំងឆត្រតែម្យ៉ាងដើរទៅជាទុក្កដ ។ សូម្បីបើថា ឃើញគុម្ពឈើជាដើម បិទឆត្រហើយ ពាក់តែស្បែកជើងដើរទៅ ជាទុក្កដដូចគ្នា ។ បើបិទឆត្រហើយក្តី ដោះស្បែកជើងហើយក្តី ត្រឡប់បាំងឆត្រនិងពាក់ស្បែកជើងទៀតជាបាចិត្តិយ ។ គប្បីជ្រាបអាបត្តិច្រើនដោយករាប់ប្រយោគយ៉ាងនេះ ។ ពាក្យដែលនៅសល់ ងាយទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឆត្តុបាហនសិក្ខាបទវណ្ណនា ចប់ ។

## ២. យានសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ ៖

[៤៥១] សូម្បីក្នុងពាក្យថា យានេន យាយតិ : ទៅដោយយាន នេះ ក៏គប្បីជ្រាបថា ជាអាបត្តិច្រើន ដោយប្រការរាប់ប្រយោគរបស់ភិក្ខុនីដែលចុះឡើង ៗ (ឡើងចុះរឿយ ៗ) ។ បទដែលនៅសល់មានន័យដូចពោលហើយ ក្នុងសិក្ខាបទទី ១ នោះឯង ។

យានសិក្ខាបទវណ្ណនា ចប់ ។

## ៣. សង្ឃាណិសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ ៖

[៤៥៤] បទថា វិប្បកិរិយឹសុ[១] : កម្រង(ខ្សែក្រវាត់)ជុះរាត់រាយ គឺ ក្បូងកែវមណីគ្រឿងប្រដាប់ចង្កេះធ្លាក់ចុះរាត់រាយ ។ សូម្បីក្នុងសិក្ខាបទនេះ ក៏គប្បីជ្រាបថា ជាអាបត្តិច្រើន ដោយករាប់ប្រយោគរបស់ភិក្ខុនី ដែលឈប់(បិទទិនដោះ) ហើយប្រើ(បាំងទិនពាក់)វិញ ។ សមុដ្ឋានជាដើម មានន័យដូចពោលហើយដែរ ។ ក្នុងសិក្ខាបទនេះ ជាអកុសលចិត្តតែម្យ៉ាង ដូច្នេះឯង ។

សង្ឃាណិសិក្ខាបទវណ្ណនា ចប់ ។

---

១. ថៃ. វិប្បកិរិំសុ ។

## ៤. ឥត្តាលង្ការសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ ៖

[៤៥៧] បណ្តាគ្រឿងប្រដាប់ មានគ្រឿងប្រដាប់សិរ្សៈជាដើម ភិក្ខុនីប្រើគ្រឿងប្រដាប់ប្រភេទណា ៗ គប្បីជ្រាបថា ជាអាបត្តិច្រើន ដោយរាប់វត្ថុដោយអំណាចនៃគ្រឿងប្រដាប់នោះ ៗ ។ ពាក្យដែលនៅសល់ មានន័យដូចពោលហើយ ក្នុងសិក្ខាបទទី ៣ នុ៎ះឯង ។

ឥត្តាលង្ការសិក្ខាបទវណ្ណនា ចប់ ។

## ៥. គន្ធវណ្ណកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះ ៖

[៤៦០] បទថា គន្ធវណ្ណកេន : ដោយគ្រឿងក្រអូបនិងគ្រឿងលាប គឺ ដោយគ្រឿងក្រអូបផង គ្រឿងលាបសម្បុរស្បែកផង ។ ពាក្យដែលនៅសល់ ងាយទាំងអស់ហើយ ។ សមុដ្ឋានជាដើម ក៏ដូចគ្នានឹងសិក្ខាបទទី ៣ ទាំងអស់នោះឯង ។

គន្ធវណ្ណកសិក្ខាបទវណ្ណនា ចប់ ។

## ៦. វាសិតកសិក្ខាបទវណ្ណនា

ពាក្យទាំងអស់ក្នុងសិក្ខាបទទី ៦ ដូចគ្នានឹងពាក្យដែលពោលហើយ ក្នុងសិក្ខាបទទី ៥ នោះឯង ។

វាសិតកសិក្ខាបទវណ្ណនា ចប់ ។

## ៧. ភិក្ខុនិឧម្មទ្ទាបនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ ៖

[៤៦៧] ក្នុងពាក្យថា ឧម្មទ្ទាបេតិ អាបត្តិ បាចិត្តិយស្ស **: ភិក្ខុនីឱ្យគត់រឹត ត្រូវអាបត្តិបាចិត្តិយ** នេះ មានវិនិច្ឆ័យថា ក្នុងការគក់ប្របាច់មិនលែងដៃ ជាអាបត្តិតែមួយ ។ ក្នុងការគក់ប្របាច់លែងដៃរឿយ ៗ ជាអាបត្តិច្រើន ដោយករាប់ប្រយោគ ។ សូម្បីក្នុងការខ្ទាំ ក៏ន័យនេះឯង ។

[៤៦៨] បទថា គិលានាយ **: ភិក្ខុនីឈឺ** បានដល់ មានអាពាធដោយហោចទៅ សូម្បីដោយសេចក្តីនឿយហត់ក្នុងការធ្វើដំណើរ ។

បទថា អាបទាសុ **: ភិក្ខុនីមានសេចក្តីអន្តរាយ** បានដល់ ក្នុងអន្តរាយមានរាងកាយញ័រទន្ទេត់ ព្រោះការខ្លាចពួកចោរជាដើម ។ ពាក្យដែលនៅសល់ ងាយទាំងអស់ហើយ ។ សមុដ្ឋានជាដើម ដូចគ្នានឹងសិក្ខាបទទី ៣ នោះ ដូច្នេះឯង ។

ភិក្ខុនិឧម្មទ្ទាបនសិក្ខាបទវណ្ណនា ចប់ ។

# ៨.៩.១០. សិក្ខមានឧម្មទ្វាបនាទិសិក្ខាបទវណ្ណនា

[៤៦៩] ក្នុង៣ សិក្ខាបទ មានសិក្ខាបទទី ៨ ជាដើម ។ ពាក្យថា សិក្ខមានាយ សាមណេរិយា គិហិនិយា នេះប៉ុណ្ណោះធ្វើឱ្យផ្សេងគ្នា ។ ពាក្យដែលនៅសល់ ដូចគ្នានឹងពាក្យដែលពោលហើយក្នុងសិក្ខាបទទី៧ នោះឯង ។

សិក្ខមានឧម្មទ្វាបនាទិសិក្ខាបទវណ្ណនា ចប់ ។

# ១១. អនាបុច្ឆាសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១១ ដូចតទៅនេះ ៖

[៤៧២] ពីរបទថា ភិក្ខុស្ស បុរតោ : ខាងមុខភិក្ខុ គឺ ត្រង់មុខចំ ៗ ។ ក៏ពាក្យនេះ បណ្ឌិតគប្បីជ្រាបថា លោកពោលសំដៅយកឧបចារៈ (ដែលជិតដោយជុំវិញ ១២ ហត្ថ) ។ ពាក្យដែលនៅសល់ងាយទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងមកកាយវាចា១ កាយវាចាចិត្ត១ ជាកិរិយានិងជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

ឆត្តវគ្គ អនាបុច្ឆាសិក្ខាបទវណ្ណនា ចប់ ។

# ១២. បញ្ញាបុច្ឆនសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងសិក្ខាបទទី ១២ ដូចតទៅនេះ ៖

[៤៧៦] បទថា អនោកាសកតំ : មិនបានសូមឱកាសជាមុនបានដល់ អ្នកដែលខ្លួនមិនទាន់បានធ្វើការសូមឱកាសយ៉ាងនេះថា ខ្ញុំម្ចាស់នឹងសួរក្នុងស្ថានទីឯណោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ក្នុងបទភាជនៈថា "ពាក្យថា មិនបានសូមឱកាស គឺ មិនបានផ្ទៀង" ។

[៤៧៩] បទថា អនោទ្ទិស្ស[1] : មិនចំពោះ មានសេចក្ដីថា មិនកំណត់យ៉ាងនេះថា ខ្ញុំម្ចាស់នឹងសួរក្នុងឋានៈឈ្មោះឯណោះ ពោលយ៉ាងនេះតែម្យ៉ាងថា "ខ្ញុំម្ចាស់នឹងសួរសេចក្ដីដែលគួរសួរ ដែលមាន លោកម្ចាស់" ពាក្យដែលនៅសល់ ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបទសោធម្មសិក្ខាបទ កើតឡើងមកវាចា១ វាចាចិត្ត១ ជាកិរិយានិងជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ វចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

បញ្ញាបុច្ឆនសិក្ខាបទវណ្ណនា ចប់ ។

---

១. ថៃ. អនុទ្ទិស្ស ។

# ១៣. អសង្កច្ចិកសិក្ខាបទវណ្ណនា

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទទី ១៣ ដូចតទៅនេះ ៖

[៤៨១] ពីរបទថា បរិក្ខេបំ អតិក្កមន្តិយា : ឈានកន្លងរបង គឺ កាលឈានទៅ ដោយជំហានដំបូងជាទុក្កដ កាលឈានទៅដោយជំហានទី ២ ជាបាចិត្តិយ ។ សូម្បីក្នុងឧបចារៈក៏ន័យនេះដូចគ្នា ។

[៤៨២] ក្នុងពាក្យថា អច្ឆិន្នចីវរិកាយ : ភិក្ខុនីមានចីវរចោរដណ្តើមយកទៅ ជាដើម ចីវរ គឺ សំពត់រឹតដោះនុ៎ះឯង បណ្ឌិតគប្បីជ្រាបថា ចីវរ ។

បទថា អាបទាសុ : ភិក្ខុនីមានសេចក្តីអន្តរាយ[1] មានសេចក្តីថា សំពត់រឹតដោះមានតម្លៃច្រើន កាលភិក្ខុនីដណ្តប់ដើរទៅ អន្តរាយទឹងកើតឡើងបាន មិនជាអាបត្តិក្នុងអន្តរាយដូច្នេះ ។ ពាក្យដែលនៅសល់ ងាយទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

អសង្កច្ចិកសិក្ខាបទវណ្ណនា ចប់ ។

---

១. ក្នុងបិដកខ្មែរ មិនមាន ។

## ចំនួនសិក្ខាបទ ក្នុងឆត្តុបាហនវគ្គ គឺ

១. ឆត្តុបាហនសិក្ខាបទ  ការបាំងឆត្រ និងពាក់ស្បែកជើង
២. យានសិក្ខាបទ  ការទៅដោយយាន
៣. សង្ឃាណិសិក្ខាបទ  ការពាក់ខ្សែក្រវាត់
៤. ឥត្ថលង្ការសិក្ខាបទ  ការប្រើប្រាស់គ្រឿងអង្ការរបស់ស្រី
៥. គន្ធវណ្ណកសិក្ខាបទ  ការងូតទឹកដោយគ្រឿងក្រអូបនិងគ្រឿងលាប
៦. វាសិតកសិក្ខាបទ  ការងូតទឹកដោយគ្រឿងអប់និងគ្រឿងលំអិត
៧. ភិក្ខុនិឧម្មទ្ទាបនសិក្ខាបទ  ការឱ្យភិក្ខុនីផងគ្នាគត់រឹត ប្របាច់
៨.៩.១០. សិក្ខមានឧម្មទ្ទាបនាទិសិក្ខាបទ ការឱ្យស្រីគ្រហស្ថគត់ រឹត ប្របាច់
១១. អនាបុច្ឆាសិក្ខាបទ  ការមិនប្រាប់ហើយអង្គុយលើអាសនៈមុខភិក្ខុ
១២. បញ្ហាបុច្ឆនសិក្ខាបទ  ការសួរបញ្ហានឹងភិក្ខុដែលខ្លួនមិនសូមឱកាស
១៣. អសង្កច្ចិកសិក្ខាបទ  ការចូលទៅកាន់ស្រុកដោយគ្មានសំពត់ចោមពុង

អដ្ឋកថា ឆត្តវគ្គទី ៩ ចប់

# ១០. ១៦. មុសាវាទាទិវគ្គ

## មុសាវាទាទិសិក្ខាបទវណ្ណនា

[៤៨៣] ក្នុងពាក្យថា ឧទ្ទិដ្ឋា ខោ អយ្យាយោ ឆសដ្ឋិសតា បាចិត្តិយា ធម្មា : បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិបាចិត្តិយទាំងឡាយ ១៦៦ ខ្ញុំបានសម្ដែងឡើងហើយ នេះ គប្បីជ្រាបថា សិក្ខាបទ ១៨៤ ទាំងអស់រួមគ្នា គឺសិក្ខាបទក្នុងខុទ្ទកៈរបស់ពួកភិក្ខុនី ៩៦សិក្ខាបទ, ពួកភិក្ខុ ៩២សិក្ខាបទ, នាំ២២សិក្ខាបទនេះ ចេញពីសិក្ខាបទ ១៨៨នោះ គឺភិក្ខុនីវគ្គទាំងអស់(១០សិក្ខាបទ) បរម្បរភោជនសិក្ខាបទ១ អនតិរិត្តភោជនសិក្ខាបទ១ អនតិរិត្តេនអភិហដ្ឋមបវារណាសិក្ខាបទ១ បណីតភោជនវិញ្ញត្តិសិក្ខាបទ១ អចេលសិក្ខាបទ១ ទុដ្ឋុល្លបដិច្ឆាទនសិក្ខាបទ១ ឩនវីសតិវស្សូបសម្បាទនសិក្ខាបទ១ សិក្ខាបទពោលអំពីការបបួលគ្នាដើរមកឆ្ងាយជាមួយនឹងមាតុគ្រាម១ រាជន្តេបុរប្បវេសនសិក្ខាបទ១ សិក្ខាបទពោលអំពីការចូលស្រុកក្នុងវេលាវិកាល មិនពោលលាភិក្ខុនីដែលមាន១ និសីទនសិក្ខាបទ១ វស្សិកសាដិកសិក្ខាបទ១ ; នៅសល់ ១៦៦សិក្ខាបទទៀត ដែលខ្ញុំលើកឡើងសម្ដែងហើយ តាមមកនៃបាដិមោក្ខុទ្ទេស ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គីតិកាចារ្យពោលថា ឧទ្ទិដ្ឋា ខោ អយ្យាយោ ឆសដ្ឋិសតា បាចិត្តិយា ធម្មា ។ បេ ។ ឯវមេតំ

ធារយាមិ : បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិបាចិត្តិយទាំងឡាយ ១៦៦ ខ្ញុំបានសម្តែងឡើងហើយ ។ល ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការនៅស្ងៀមយ៉ាងនេះ ដូច្នេះ ។

សោឡសមវគ្គ ចប់ ។

សុទ្ធបាចិត្តិយវណ្ណនា ចប់ ។

## វិនិច្ឆ័យសមុដ្ឋានជាដើមដោយសង្ខេប

ក្នុងខុទ្ទកវណ្ណនាធិការនោះ មានវិនិច្ឆ័យសមុដ្ឋាន ដោយសង្ខេប ដូចតទៅនេះ ៖

១០សិក្ខាបទទាំងនេះ គឺ គិរគ្គសមជ្ជសិក្ខាបទ១ ចិត្តាគារសិក្ខាបទ ១ សង្ឃាណិសិក្ខាបទ១ ឥត្ថាលង្ការសិក្ខាបទ១ គន្ធវណ្ណកសិក្ខាបទ១ វាសិតកបិញ្ញាកសិក្ខាបទ ១ ការប្រើភិក្ខុនីជាដើមប្របាច់រឹត ៤ សិក្ខាបទ ជាអចិត្តកៈ លោកវជ្ជៈ ។

ក៏ក្នុងសិក្ខាបទ ១០ ទាំងនេះ មានអធិប្បាយដូចតទៅនេះ ៖

សិក្ខាបទទាំងនេះ ឈ្មោះថា ជាអចិត្តកៈ ព្រោះសូម្បីវៀរចាកចិត្ត ក៏នៅតែត្រូវ, តែកាលមានចិត្ត ក៏ជាលោកវជ្ជៈ ព្រោះត្រូវដោយអកុសល ចិត្តប៉ុណ្ណោះ សិក្ខាបទដែលនៅសល់ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈទាំង

អស់ ។

១៩សិក្ខាបទទាំងនេះ គឺចោរីវុដ្ឋាបនសិក្ខាបទ១ គាមន្តរាគមសិក្ខាបទ១ ក្នុងគព្ភិនីវគ្គ ៧សិក្ខាបទខាងដើម, ក្នុងកុមារិភូតវគ្គ ៥សិក្ខាបទខាងដើម, បុរិសសំសដ្ឋសិក្ខាបទ១ បារិវាសិយឆន្ទទានសិក្ខាបទ១ អនុវស្សវុដ្ឋាបនសិក្ខាបទ១ ឯកន្តរិកវុដ្ឋាបនសិក្ខាបទ១ ជាសចិត្តកៈ បណ្ណត្តិវជ្ជៈ ដែលនៅសល់ជាសចិត្តកៈ លោកវជ្ជៈ ទាំងអស់នោះឯង ។

**បាចិត្តិយកណ្ឌវណ្ណនា ភិក្ខុនីវិភង្គ ចប់**

# បាដិទេសនីយកណ្ឌ

ធម៌ ៨ ពួកណា ឈ្មោះ បាដិទេសនីយៈ ដែលឡើងកាន់សង្គហៈ ដោយសង្ខេប បន្ទាប់លំដាប់ពួកខុទ្ទកៈមក, វណ្ណនាធម៌ទាំងនោះ ដោយសង្ខេបតែប៉ុណ្ណោះ នឹងដំណើរតទៅនេះ ៖

# សប្បិវិញ្ញាបនាទិសិក្ខាបទវណ្ណនា

ក៏បណីតភោជន មានទឹកដោះថ្លានិងប្រេងជាដើមណា ដែលព្រះមានព្រះភាគ ទ្រង់សម្តែងទុកហើយក្នុងបាលីនៃពួកបាដិទេសនីយៈនេះ កាលភិក្ខុនីសូមបណីតភោជន មានទឹកដោះថ្លា និងប្រេងជាដើមនោះឯង មកឆាន់ ជាបាដិទេសនីយៈ ។ តែក្នុងទឹកដោះថ្លាជាដើមក្រៅពីព្រះបាលីគ្រប់យ៉ាង ជាទុក្កដ ។ ពាក្យដែលនៅសល់ក្នុងបាដិទេសនីយៈទាំងនេះ ងាយទាំងអស់ហើយ ។ ក៏បាដិទេសនីយៈទាំង ៨សិក្ខាបទនេះ មានសមុដ្ឋាន៤ កើតឡើងមកកាយ១ វាចា១ កាយវាចា១ កាយវាចាចិត្ត១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សប្បិវិញ្ញាបនាទិសិក្ខាបទវណ្ណនា ចប់ ។

**បាដិទេសនីយវណ្ណនា ចប់**

# សេក្ខិយកណ្ឌ

## ១. បរិមណ្ឌលាទិសិក្ខាបទវណ្ណនា

ក៏ធម៌៧៥ ឈ្មោះថា សេក្ខិយៈពួកណាដែលព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានលើកឡើងសម្តែងទុក និងធម៌ពួកណា ឈ្មោះសត្តាធិករណៈ ដែលលោកលើកឡើង សម្តែងទុកបន្ទាប់ចាកពីលំដាប់សេក្ខិយៈទាំងនោះមក, អត្ថវិនិច្ឆ័យ ធម៌ គឺ សេក្ខិយៈ និងអធិករណៈទាំងនោះយ៉ាងណា ដែលខ្ញុំពោលទុកក្នុងមហាវិភង្គ, សូម្បីក្នុងភិក្ខុនីវិភង្គ លោកអ្នកដឹងទាំងឡាយ ក៏ពោលអត្ថវិនិច្ឆ័យនោះទុកយ៉ាងនោះដែរ, ព្រោះដូច្នោះ ខ្ញុំទើបមិនពោលអត្ថពណ៌នាធម៌ទាំងនោះ ទុកមួយផ្នែកទៀត, ដែលពិតអត្ថវណ្ណនាដែលខ្ញុំបានពោលទុកក្នុងមហាវិភង្គនោះ ឈ្មោះថា បានពោលហើយ ក្នុងភិក្ខុនីវិភង្គនេះដូចគ្នាហោង ។

ភិក្ខុនីវិភង្គវណ្ណនា ចប់ ។

## ឧយ្យោជនគាថារបស់អ្នករចនា

ាចិត្តិយកណ្ឌវណ្ណនាវិភង្គនៃឧភតោបាដិមោក្ខ ដែលព្រះជិនស្រីត្រាស់ទុកនេះចប់ហើយ ដោយមិនមានអន្តរាយយ៉ាងណា សូមសព្វសត្វទាំងអស់ បានសម្រេចមគ្គដែលលះចេញនូវអាសវៈទាំងពួង ហើយជួបប្រសព្វតែសេចក្តីរលត់អស់ដោយមិនមានអន្តរាយ ដូច្នោះ ហោង ។

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## ភិក្ខុនីវិភង្គ

## បច្ឆេកភាគ

## ៥

## ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ បាចិត្តិយាទិ

## ភិក្ខុនីវិភង្គ

## ភាគ ៣-៤-៥



ចប់ ដោយបរិបូណ៌





